សិក្ខាបទព្រះពុទ្ធ



ធម៌ចក្រ

ធម៌ចក្រ ជាពាក្យសំស្ក្រឹតប្រែថា «**កង់នៃព្រះធម៌**» ។ ដូចគ្នានឹងកង់រទេះដែលមានចលនាវិលវង់ជានិច្ច **កង់នៃព្រះធម៌** ជានិមិត្តរូបនៃព្រះពុទ្ធឱវាទដែលចេះតែបន្តផ្សព្វផ្សាយទៅគ្រប់ទិសទី និងមិនមានទីបញ្ចប់។ កាំទាំងប្រាំបីនៃកង់ ជាតំណាងឲ្យផ្លូវដ៏ប្រពៃទាំងប្រាំបីនៃព្រះពុទ្ធសាសនា (អដ្ឋង្គិកមគ្គ) ដែលជាផ្លូវដ៏សំខាន់បំផុតក្នុងការប្រតិបត្តិ។ ផ្លូវដ៏ប្រពៃទាំងប្រាំបីនោះសំដៅទៅលើ សេចក្តីយល់ឃើញត្រូវ (សម្មាទិដ្ឋិ) សេចក្តីត្រិះរិះត្រូវ (សម្មាសង្កប្ប) សម្តីត្រូវ (សម្មាវាចា) ការងារត្រូវ (សម្មាកម្មន្តៈ) ការចិញ្ចឹមជីវិតត្រូវ (សម្មាអាជីវៈ) ការព្យាយាមត្រូវ (សម្មាវាយាមៈ) ការភ្ញាក់រឭកត្រូវ (សម្មាសតិ) និងការតាំងចិត្តខ្ជាប់ត្រូវ (សម្មាសមាធិ) ។ នៅក្នុងសម័យបុរាណ មុនពេលមានការកសាងព្រះពុទ្ធបដិមា និងព្រះពុទ្ធរូប **ធម៌ចក្រ**នេះ គេចាត់ទុកជាសរណវត្ថុជាទីគោរពបូជា។ នៅសម័យបច្ចុប្បន្ន **កង់នៃព្រះធម៌** ត្រូវបានគេប្រើជាអន្តរជាតិ ជានិមិត្តរូបទូទៅនៃព្រះពុទ្ធសាសនា។

Copyright © 1986, 2016, **BUKKYO DENDO KYOKAI**

សិទ្ធិបោះពុម្ពផ្សាយរបស់ សមាគមផ្សាយព្រះពុទ្ធសាសនា គ្រប់ភាគទាំងអស់ក្នុងសៀវភៅនេះ អាចចម្លងយកចេញបាន ដោយសេរី គ្រាន់តែសូមមេត្តាបញ្ជាក់ថា ដកស្រង់ចេញពី **BUKKYO DENDO KYOKAI** ហើយសូមមេត្តាផ្ញើសេចក្តីចម្លងនោះមួយច្បាប់មកយើងខ្ញុំ។ សូមអរគុណ

មូលនិធិជំរឿនព្រះពុទ្ធសាសនា

BUKKYO DENDO KYOKAI

(Society for the Promotion of Buddhism)

3-14, 4-chome, Shiba

Minato-ku, Tokyo, Japan, 108-0014

Phone: (03) 3455-5851

Fax: (03) 3798-2758

E-mail:bdk@bdk.or.jp http://www.bdk.or.jp

Third Printing, 2016

បោះពុម្ពដោយ

Kosaido Co., Ltd

Tokyo, Japan

ព្រះប្រាជ្ញាញាណរបស់ព្រះពុទ្ធ ធំធេង ប្រៀបបាននឹងមហាសមុទ្រ។ ព្រះទ័យរបស់ព្រះអង្គ ពោរពេញទៅដោយសេចក្តីករុណាអាណិតអាសូរ។

ព្រះពុទ្ធ គ្មានរូបរាងទេ។ តែព្រះអង្គទ្រង់បញ្ចេញឲ្យឃើញឡើងក្នុងសភាពល្អឥតខ្ចោះ ហើយដឹកនាំយើងទាំងអស់គ្នា ដោយព្រះទ័យពេញទៅដោយការប្រោសប្រណី។

សៀវភៅនេះមានតម្លៃណាស់ ព្រោះមានសារៈសំខាន់នៃពុទ្ធោវាទនៅក្នុងនោះ។ ពុទ្ធោវាទទាំងនោះ ត្រូវបានកត់ត្រាទុកជាគម្ពីរជាង ៥០០០ ក្បាល ហើយផ្តល់ជាបន្តបន្ទាប់មកដល់យើងរាល់គ្នា ក្នុងរយៈជាង ២៥០០ ឆ្នាំមកហើយ ដោយឆ្លងកាត់តាមរដ្ឋសីមា និងរបាំងជាតិពន្ធជាច្រើន នៃពិភពលោកនេះ។

ពុទ្ធវាចាសម្រាំងក្នុងសៀវភៅនេះ បង្ហាញឲ្យឃើញនូវសភាពពិតនៃជីវិតនិងចិត្តរបស់មនុស្សលោក។ ពុទ្ធវាចាទាំងនេះ ទាក់ទងជាបន្ទាល់ នឹងមនុស្សលោកយើងនេះ។

ធម្មបទ

សេចក្តីស្អប់ មិនអាចបញ្ចប់សេចក្តីស្អប់បានជាដាច់ខាត។ មានតែសេចក្តីស្រឡាញ់ទេ ដែលអាចបញ្ចប់សេចក្តីស្អប់បាន។ នេះជាច្បាប់ពីបុរាណ ។ -**ធម្មបទ** (៥)-

មនុស្សឆ្កួតដែលគិតថាខ្លួនឆ្កួត ជាបណ្ឌិត។ មនុស្សឆ្កួតដែលគិតថាខ្លួនជាបណ្ឌិតពិតជាមនុស្សឆ្កួត។-**ធម្មបទ** (៦៣)-

គេអាចឈ្នះសត្រូវរាប់ពាន់នាក់ ក្នុងលានប្រយុទ្ធរាប់ពាន់កន្លែង។ តែនរណាអាចជម្នះខ្លួនឯងបាន ជាជ័យជម្នះប្រសើរបំផុត។ -**ធម្មបទ** (១០៣)-

រស់តែមួយថ្ងៃ ហើយបានយល់សេចក្តីពិតបំផុត ប្រសើរជាជាងរស់មួយរយឆ្នាំ ហើយមិនបានយល់សេចក្តីពិតបំផុតនោះ។ -**ធម្មបទ** (១១៥)-

កើតមកជាមនុស្ស ជាការក្រ។ ការរស់នៅក្នុងសភាពជាមនុស្ស ជាការក្រ។ បានស្តាប់ព្រះសេចក្តីពិតបំផុត ជាការក្រ។ បានមើលឃើញព្រះពុទ្ធ ជាការក្រ។ -**ធម្មបទ** (១៨២)-

កុំប្រព្រឹត្តអំពើបាប ចូរសាបព្រោះបណ្តុះអំពើល្អ ចូរធ្វើចិត្តឲ្យបានបរិសុទ្ធ។ នេះគឺ ឱវាទរបស់ព្រះពុទ្ធ។

-**ធម្មបទ** (១៨៣)-

កាលណាសេចក្តីស្លាប់មកដល់ហើយ កូនក៏ដោយ ឪពុកក៏ដោយ សាច់ញាតិក៏ដោយ មិនអាចជួយឲ្យរួចផុតពីការស្លាប់នេះបានទេ។ -**ធម្មបទ** (២៨៨)-

បញ្ជីរឿង

ព្រះពុទ្ធ

ចំពូកទី ១: *ព្រះពុទ្ធសក្យមុនី* 2

I. *ពុទ្ធប្បវត្តិ* 2

II. *និព្វានចុងក្រោយរបស់ព្រះពុទ្ធ* 17

ចំពូកទី ២: *ព្រះពុទ្ធអនន្ត និងប្រសើរបំផុត* 25

I. *សេចក្ដីអាសូរនិងពររបស់ព្រះពុទ្ធ* 25

II. *ការសង្គ្រោះរបស់ព្រះពុទ្ធ និងរបៀបស្រោចស្រង់របស់ព្រះអង្គ* 31

III. *ព្រះពុទ្ធអមតៈ* 38

ចំពូកទី ៣: *ទ្រង់ទ្រាយ និងលក្ខណៈព្រះពុទ្ធ* 42

I. *ទ្រង់ទ្រាយបីក្នុងអង្គកាយព្រះពុទ្ធ* 42

II. *ការបញ្ចេញឲ្យឃើញនៃព្រះពុទ្ធ* 48

III. *គុណធម៌របស់ព្រះពុទ្ធ* 54

ព្រះធម៌

ចំពូកទី ១: *ការទាក់ទងហេតុនិងផល* 64

I. *សេចក្តីពិតថ្លៃថ្នូរបួនប្រការ* 64

II. *ការទាក់ទងរវាងហេតុនិងផល* 68

III. *ការទាក់ទងគ្នារវាងហេតុផ្សេងៗ* 70

ចំពូកទី ២: *ទ្រឹស្តីអំពីវិញ្ញាណតែមួយគត់*

និងសភាពពិតនៃវត្ថុជាតុ 76

I. *ភាពមិនឋិតថេរ និងភាពឥតសារជាតិ* 76

II. *ទ្រឹស្តីអំពីវិញ្ញាណតែមួយគត់* 80

III. *ភាពពិតនៃវត្ថុជាតិ* 85

IV. *ផ្លូវកណ្តាល* 92

ចំពូកទី ៣: *សភាពព្រះពុទ្ធ*

I. *ចិត្តបរិសុទ្ធ* 105

II. *សភាពព្រះពុទ្ធ* 115

III. *ភាពព្រះពុទ្ធនិងភាពជាអនត្តា*......................... 121

ចំពូកទី ៤:*តណ្ហា* 129

I. មន្ទិលសៅហ្មងនៃចិត្ត 129
II. សភាពមនុស្សលោក 140
III. ជីវិតមនុស្សលោក 143
IV. សេចក្តីពិតនៃជីវិតមនុស្សលោក 152

ជំពូកទី ៤: *ការស្រោចស្រង់របស់ព្រះពុទ្ធ* 162
I. សេចក្តីប្រាថ្នារបស់ព្រះពុទ្ធអមិដា 162
II. ដែនដីបរិសុទ្ធរបស់ព្រះពុទ្ធអមិដា 174

វត្តប្រតិបត្តិព្រះពុទ្ធសាសនា

ជំពូកទី ១: *វិធីធ្វើឲ្យបានបរិសុទ្ធ* 180
I. វិធីធ្វើឲ្យចិត្តបានបរិសុទ្ធ 180
II. របៀបប្រព្រឹត្តល្អ 192
III. សេចក្តីទូន្មានតាមរឿងព្រេងប្រឌិត 211

ជំពូកទី ២: *វិធីប្រតិបត្តិឲ្យបានសម្រេច* 235
I. ការស្វែងរកសេចក្តីពិត 235
II. វិធីប្រតិបត្តិ.. 256

III. ផ្លូវនៃជំនឿ 277
IV. ពុទ្ធឱវាទ 288

ភាតរភាពនៃពុទ្ធសាសនិក

ចំពូកទី ១: *ករណីយកិច្ចនៃពុទ្ធសាសនិក* 304
I. អ្នកបួស 304
II. អ្នកជាគ្រហស្ថ 312
III. របៀបរស់នៅដោយត្រឹមត្រូវ 330

ចំពូកទី២: *កសាងដែនដីព្រះពុទ្ធ* 350
I. ភាពសុខដុមនៃសហគមន៍ពុទ្ធសាសនិក 350
II. ដែនដីព្រះពុទ្ធ 361
III. អ្នកទ្រទ្រង់ដែនដីព្រះពុទ្ធ 368

ប្រភពដកស្រង់បញ្ជាក់ 377

សេចក្តីបន្ថែម

I. ប្រវត្តិសង្ខេបនៃព្រះពុទ្ធសាសនា 392

II. របៀបបញ្ជូនព្រះពុទ្ធសាសនាជាបន្តៗ
មកជំនាន់ក្រោយៗ 406

III. ប្រវត្តិសៀវភៅ "សិក្ខាបទព្រះពុទ្ធ" 411

IV. តារាងទំព័រ 415

V. អក្ខរានុក្រមនៃពាក្យសំស្ក្រឹត 424

មូលនិធិជំរឿនព្រះពុទ្ធសាសនា 433

ព្រះពុទ្ធ

ចំពូកទី ១

ព្រះពុទ្ធសក្យមុនី

I

ពុទ្ធប្បវត្តិ

1. ***ក្រុងកបិលពស្តុ*** *ជារាជធានីនៃកុលសម្ព័ន្ធសក្យ ស្ថិតនៅជើងភ្នំហិមពាន្ត ក្នុងជម្ពូទ្វីបភាគខាងជើង នាមាត់ស្ទឹង****រោហិនី****។* ***ព្រះមហាក្សត្រសុទ្ធោទនៈ*** *ទ្រង់បានសាងមហាប្រាសាទមួយដ៏ល្អវិចិត្រ និងគ្រប់គ្រងប្រជាពលរដ្ឋដោយព្រហ្មវិហារធម៌។ ព្រះអង្គ ត្រូវបានជាទីនិយមរាប់អាននៃប្រជានុរាស្ត្រគ្រប់ជាន់ថ្នាក់។*

ព្រះអគ្គមហេសី ទ្រង់ព្រះនាម ***មហាមាយារាជទេវី*** *។ ព្រះនាងជាព្រះរាជបុត្រីរបស់ព្រះបិតុលា នៃព្រះមហាក្សត្រដែលសោយរាជ្យនៅនគរជាប់គ្នា ក្នុងកុលសម្ព័ន្ធសក្យជាមួយគ្នា។*

ក្នុងរយៈម្ភៃឆ្នាំ ព្រះមហាក្សត្រ ទ្រង់គ្មានព្រះរាជបុត្រ

សោះ។ ទិវាមួយនោះ ព្រះអគ្គមហេសីទ្រង់យល់សប្តិឃើញដំរីសមួយ ចូលទៅក្នុងផ្ទៃព្រះនាងពីខាងស្តាំ។ បន្ទាប់មក ព្រះនាងក៏ទ្រង់គភ៌។ ព្រះមហាក្សត្រ និងប្រជាពលរដ្ឋត្រេកអរជាពន្ទឹក។ តាមប្រពៃណី ព្រះអគ្គមហេសីទ្រង់ត្រឡប់ទៅនគរមាតាបិតាព្រះនាងវិញដើម្បីប្រសូត្របុត្រ។ នៅតាមផ្លូវ ព្រះនាងទ្រង់ចូលទៅសម្រាកព្រះកាយក្នុង**សួនលុម្ពិនី**។

សួនលុម្ពិនី នានិទាឃរដូវ ពោរពេញទៅដោយផ្កាអសោក។ គ្រាដែលព្រះនាង ឈោងព្រះហស្តស្តាំទៅកាច់ផ្កាមួយទង ព្រះរាជបុត្រក៏ទ្រង់ប្រសូតមក។ មេឃ ដី និងសត្វលោកទាំងអស់ សែនមហាសប្បាយនឹងធព្វណ្ណរង្សីនៃព្រះអគ្គមហេសី និងព្រះរាជបុត្រព្រះនាង។ ទិវាមហាពន្ទឹកនោះត្រូវជាថ្ងៃទី០៨ ខែមេសា។

ព្រះមហាក្សត្រទ្រង់ព្រះអំណរជាទីបំផុត។ ទ្រង់ដាក់ព្រះនាមព្រះរាជបុត្រព្រះអង្គថា **សិទ្ធត្ថៈ** ដែលមានន័យថា «សម្រេចបានគ្រប់សេចក្តីប្រាថ្នា»។

2. ប៉ុន្តែប៉ុន្មានថ្ងៃក្រោយ បន្ទាប់ពីការសប្បាយរីករាយមក

សេចក្ដីទុក្ខព្រួយក៏ត្រូវកើតមានឡើងនៅក្នុងព្រះបរមរាជវាំង ដោយព្រះអគ្គមហេសី **សិរិមហាមាយា** ជាទីស្នេហាទ្រង់សោយទិវង្គតទៅយ៉ាងទាន់ហន់។ អនុជក្សត្រីរបស់ព្រះនាងព្រះនាម **មហាប្រជាបតី** ក៏ទទួលបីបាច់រក្សាព្រះរាជកុមារដោយព្រះទ័យប្រោសប្រណី។

នៅគ្រានោះ មានតាបសឥសីមួយព្រះអង្គឈ្មោះ **អសិត** រស់នៅក្នុងព្រៃភ្នំជិតព្រះបរមរាជវាំងនោះ បានសង្កេតឃើញមានពន្លឺរស្មីចែងចាំងឡើងព័ទ្ធជុំវិញព្រះរាជដំណាក់។ តាបសឥសីនោះកាត់យល់ថា ជាប្រផ្នូលមួយវិសេសអស្ចារ្យ លោកក៏ចុះចាកពីភ្នំទៅព្រះបរមរាជវាំង ដើម្បីទតរាជកុមារ។ លោកក៏បានទស្សន៍ទាយថាៈ «បើព្រះកុមារទ្រង់គង់នៅក្នុងព្រះរាជវាំង ព្រះរាជកុមារនឹងបានទៅជាមហាចក្រពត្រាធិរាជ គ្រប់គ្រងពិភពលោកទាំងមូល។ តែបើប្រសិនជាព្រះកុមារនោះលះបង់រាជសម្បត្តិដើម្បីកាន់យកនូវជីវភាព ជាសាសនិកព្រះអង្គនឹងបានជាព្រះពុទ្ធមួយអង្គ ជាអ្នកដោះទុក្ខពិភពលោក»។

មុនដំបូង ព្រះមហាក្សត្រទ្រង់សព្វព្រះរាជហឫទ័យណាស់

ក្នុងការដែលទ្រង់បានជ្រាបអំពីទំនាយនេះ។ ប៉ុន្តែក្រោយបន្ទិចមក ព្រះរាជាទ្រង់ចាប់មានការព្រួយបារម្ភអំពីយថាភាពនៃព្រះរាជបុត្រតែមួយព្រះអង្គរបស់ព្រះអង្គ ដែលថ្ងៃណាមួយនឹងចាកចេញពីព្រះរាជវាំង ហើយនឹងទៅជាតាបសឥតសីឥតទីលំនៅខ្ជាប់ខ្ជួន។

នៅព្រះជន្មាយុបាន៧វស្សា ព្រះរាជកុមារទ្រង់បានចាប់ផ្ដើមសិក្សាវិជ្ជាគ្រប់គ្រងរដ្ឋ និងយោធាសាស្ត្រ។ តែមនោគតិរបស់ព្រះអង្គ បានត្រូវកែសំដៅទៅកាន់វត្ថុផ្សេងទៀត។ ថ្ងៃមួយនាទិទាយរដូវ ព្រះរាជកុមារបានយាងចេញអំពីព្រះរាជវាំងជាមួយនឹងព្រះបិតា និងព្រះរាជបរិពារ ទ្រង់បានទតឃើញកសិករម្នាក់កំពុងភ្ជួរដី។ ក្នុងពេលនោះ ព្រះរាជកុមារបានសង្កេតឃើញ បក្សីមួយហើរចុះអំពីអាកាសវេហាស៍មកហើយចឹកឆក់យកដង្កូវតូចមួយ ដែលផាលនង្គ័លធ្គឹះត្រឡប់ចេញពីក្នុងដីមក។ ព្រះរាជកុមារទ្រង់អង្គុយក្រោមដើមឈើមួយ ហើយទ្រង់ព្រះសញ្ជឹងគិតតែមួយព្រះអង្គឯងថា៖ «ឱ ! សត្វលោកដែលមានជីវិតរស់នៅៗ ឡើយនោះ ទីបំផុតត្រូវតែសម្លាប់គ្នាទៅវិញទៅមកដូច្នេះឬ ? »។

កាលនោះ ព្រះរាជកុមារ ដែលត្រូវបាត់បង់ព្រះមាតា យ៉ាងឆាប់ក្រោយពីទ្រង់ប្រសូតបានបន្តិចមកដូច្នេះ ទ្រង់មានសេចក្ដីសង្វេគចំពោះវិនាសកម្មនៃសត្វល្អិតទាំងពីរនោះ។

របួសនៃដួងហឫទ័យរបស់ព្រះអង្គ ក៏ចេះតែជ្រៅឡើងៗ ក្នុងពេលដែលព្រះអង្គទ្រង់បានព្រះជន្មចម្រើនឡើង។ ដូចជាសម្ពាកដែលមាននៅក្នុងកូនឈើ ទុក្ខនៃជីវិតជាមនុស្សជាតិក៏ចាក់ឫសកាន់តែជ្រៅឡើងៗ ទៅក្នុងដួងព្រះហឫទ័យ។

ព្រះមហាក្សត្រជាបិតា ទ្រង់ព្រួយបារម្ភកាន់តែខ្លាំងឡើងៗ ដោយទំនាយព្រះតាបសឥសី ហើយទ្រង់បានខំតាមដោយគ្រប់មធ្យោបាយ ដើម្បីធ្វើឲ្យព្រះរាជកុមារ ទ្រង់សប្បាយរីករាយ ហើយបែរអារម្មណ៍ទៅគិតអំពីរឿងផ្សេងទៀត។ ក្នុងពេលព្រះរាជកុមារបានព្រះជន្មាយុ ១៩ ព្រះវស្សា ព្រះរាជាទ្រង់បានរៀបអភិសេកព្រះរាជបុត្រ ជាមួយនឹងព្រះរាជធីតាមួយព្រះអង្គព្រះនាម **យសោធរៈ** ជាបុត្រីនៃ**ព្រះបាទសុប្បពុទ្ធ** ដែលជាព្រះអធិរាជនៃក្រុង**ទេវទហៈ** និងជាព្រះរៀមបង្កើតរបស់ព្រះមហាក្សត្រិយានី **សិរិមហាមាយា**។

3. ក្នុងរយៈពេលដប់ឆ្នាំ ព្រះរាជកុមារ ទ្រង់បានទទួលការរីករាយសប្បាយនឹងភ្លេង របាំ និងការកំសាន្តផ្សេងៗ នារាល់និទាឃរដូវ សរទរដូវ និងរដូវភ្លៀងធ្លាក់ តែចិន្តារបស់ព្រះអង្គតែងតែវិលត្រឡប់មកគិតអំពីបញ្ហាទុក្ខ ជានិច្ចពុំដែលដាច់។ ហើយព្រះអង្គតែងតែខំប្រឹងប្រែងរកឲ្យយល់នូវ ការពិតអំពីន័យរបស់ជីវិតនៃសត្វលោក។

ទ្រង់គិតពិចារណាថា: «ប្រណីតភាពនៃព្រះរាជវាំង សុខភាពនៃរូបកាយ ការសប្បាយគ្រប់យ៉ាងនៃយុវភាព តើសេចក្ដីទាំងអស់នេះ មានន័យអ្វីចំពោះអាត្មាអញ»?។ «ថ្ងៃណាមួយអាត្មាអញនឹងមានជំងឺ នឹងដល់នូវជរាព្យាធិ ហើយនឹងចៀសពុំផុតអំពីការស្លាប់ទេ ! ការសប្បាយភ្លើតភ្លើននឹងយុវភាព និងសុខភាព និងអត្ថិភាព (ជីវិតរស់នៅ) សត្វលោកដែលមានសុភនិច្ឆ័យ គួរតែទុកសេចក្ដីទាំងអស់នេះមួយអន្លើ ! »។

«បុគ្គលដែលតស៊ូដើម្បីជីវិតរបស់ខ្លួន តែងតែស្វែងរក អ្វីដែលមានសារៈសំខាន់ជាធម្មតា។ រីឯការស្វែងរកសារៈវត្ថុនេះមានពីរយ៉ាងគឺ: ផ្លូវត្រូវ និងផ្លូវខុស។ ផ្លូវខុស គឺយ៉ាងនេះ : កាលណាគេសម្គាល់ឃើញថា ជំងឺ ជរា និងមរណៈ ជាការ

ចៀសពុំផុតហើយ ហើយស្វែងរកសារៈវត្ថុនៅក្នុងវត្ថុដែលមានសភាពទទេ ដែលមិនឋិតថេរដែរនុ៎ះ។

ផ្លូវត្រូវក្នុងការស្វែងរកសារៈវត្ថុនោះគឺៈ កាលណាគេដឹងថា ជំងឺ ជរា និងមរណៈ ជាការពិតក្នុងធម្មជាតិ គេត្រូវតែស្វែងរកសារៈវត្ថុនៅក្នុងវត្ថុណា ដែលហួសផុតពីទុក្ខវេទនាទាំងនោះរបស់មនុស្សលោក។ ក្នុងជីវភាពសប្បាយរីករាយក្នុងវាំងប្រាសាទរបៀបនេះ អាត្មាអញដូចជាស្វែងរកសារៈវត្ថុក្នុងផ្លូវខុស»។

4. ហេតុដូច្នេះហើយ បានជាការប្រយុទ្ធខាងផ្លូវចិត្តនៃរាជ-កុមារបានកើតមានឡើងក្នុងព្រះហឫទ័យ រហូតដល់ព្រះអង្គបានព្រះជន្ម២៩ព្រះវស្សា គឺក្នុងពេល **រាហុលកុមារ** ដែលត្រូវជាព្រះរាជបុត្រតែមួយរបស់ព្រះអង្គ ទ្រង់ប្រសូត្រឡើង។ ព្រឹត្តិការណ៍មួយដ៏ធំរកទីបំផុតគ្មាន ក៏បានកើតឡើង គឺព្រះរាជ-កុមារទ្រង់សម្រេចព្រះហឫទ័យចាកចោលព្រះរាជវាំង ហើយស្វែងរកការដោះស្រាយដំណើរជ្រួលច្របល់ចិត្ត ក្នុងភាពជាស្នូមដែលឥតទីលំនៅស្នាក់អាស្រ័យ។ គឺក្នុងរាត្រីកាល ដែល

ព្រះរាជកុមារ ទ្រង់ចាប់ប្រតិបត្តិគោលបំណងរបស់ព្រះអង្គនោះ : ព្រះអង្គបានចាកចេញពីព្រះរាជដំណាក់ ដោយយកតាមព្រះអង្គនូវសារថីតែម្នាក់គត់ឈ្មោះ **ឆន្ន** ហើយទ្រង់គង់អាជានេយ្យជាទីសំណប់របស់ព្រះអង្គ សម្បុរសស្គុសដូចផ្កាទឹកកក ឈ្មោះ **កណ្ឋកៈ** ចាកចេញទៅ។

នៅពេលនោះ កង្វល់មិនបានរលាយបាត់អស់ពីព្រះឱរាទេ អារក្ស បិសាចជាច្រើន បានសាកល្បងព្រះអង្គដោយនិយាយថាៈ «ព្រះរាជាគួរតែវិលត្រឡប់ទៅព្រះរាជវាំងវិញ ហើយរកការដោះស្រាយតាមផ្លូវផ្សេងទៀតល្អជាងៈ បើធ្វើយ៉ាងនេះវិញ ពិភពលោកទាំងមូល ពិតនឹងទៅជាសម្បត្តិទ្រព្យរបស់ព្រះអង្គមិនខាន»។ តែព្រះអង្គទ្រង់ធ្វើឲ្យសំឡេងបិសាចទាំងនោះស្ងប់ស្ងាត់ទៅវិញបាន ដោយព្រះអង្គទ្រង់បានសម្រេចចិត្តថា ក្នុងលោកនេះ គ្មានអ្វីដែលអាចធ្វើឲ្យអង្គអញពេញចិត្តបានទេ។ កាលនោះព្រះអង្គទ្រង់បានកោរព្រះកេសា រួចហើយឈានព្រះបាទធ្វើដំណើរតម្រង់ទៅទិសខាងត្បូង ដោយមានកាន់បាត្រមួយសម្រាប់ការបិណ្ឌបាតផង។

ជាដំបូងបង្អស់ ព្រះរាជាទ្រង់បានទៅជួបនឹង **ឥសីភគ្គវៈ**

ហើយសង្កេតមើលរបៀបប្រតិបត្តិតបៈនៃឥសីនោះ។ បន្ទាប់មក ព្រះអង្គបានទៅសំណាក់នៅនឹងអាចារ្យ **អាឡារកាឡាម** ហើយនឹងអាចារ្យ **ឧទ្ទកៈរាមបុត្ត** ដើម្បីរៀនវិធីការនាស្មឹងស្មាធិ៍ រកផ្លូវដើម្បីបានសម្រេចនិព្វាន តាមរបៀបព្រាហ្មណ៍ទាំងនោះ។ ប៉ុន្តែក្រោយពីនៅបម្រើព្រាហ្មណ៍ ហើយហាត់រៀនវិធីទាំងនោះបន្តិចមក ព្រះអង្គក៏បានយល់ និងជឿជាក់ថា: វិធីទាំងនោះពុំអាចនឹងនាំព្រះអង្គទៅកាន់ការត្រាស់ដឹងបានទេ។ ទីបំផុត ព្រះអង្គបានយាងឆ្ពោះទៅកាន់ដែន **មគធៈ** ហើយប្រតិបត្តិតបៈក្នុងព្រៃ **ឧរុវេលា** ដែលស្ថិតនៅនាមាត់ស្ទឹង **នេរញ្ជរា** ដែលហូរប្រេបនឹងប្រាសាទ **គយា** ។

5. របៀបហាត់ហ្វឹកហ្វឺនរបស់ព្រះអង្គតឹងរឹងជាទីបំផុត ដែលនឹងរកជឿពុំបាន។ ព្រះអង្គទ្រង់បានធ្វើឧបត្តិកម្មក្នុងវិចារណៈថា: «គ្មានតាបសឥសីណាមួយ ក្នុងអតីតកាលក្តី ក្នុងបច្ចុប្បន្នកាលនេះក្តី និងទៅក្នុងអនាគតកាលក្តី ដែលបានប្រតិបត្តិ ឬកំពុងប្រតិបត្តិ ឬនឹងប្រតិបត្តិ ដោយភាពតឹងរឹងបំផុតជាងអាត្មាអញនេះទេ»។

តែព្រះរាជាទ្រង់ពុំអាចយាងទៅដល់គោលបំណង របស់ព្រះអង្គសោះ។ ប្រាំមួយឆ្នាំក្រោយពីពេលដែលព្រះអង្គបានសំណាក់នៅក្នុងអរញ្ញព្រឹក្សនោះមក ព្រះរាជាក៏ទ្រង់លាចាកគ្រប់ការប្រតិបត្តិតបៈទាំងអស់។ ព្រះអង្គទ្រង់យាងទៅស្រង់ទឹកក្នុងស្ទឹង ហើយទ្រង់បានទទួលទឹកដោះគោមួយចានអំពីនាង**សុជាតា** ដែលជាទាសីម្នាក់រស់នៅក្នុងភូមិជិតទីនោះ។

អ្នកតាមដង្ហែព្រះអង្គប្រាំនាក់ ដែលរស់នៅប្រតិបត្តិតបៈជាមួយនឹងព្រះអង្គក្នុងរយៈប្រាំមួយឆ្នាំនោះ ក៏ទាស់ចិត្តយ៉ាងខ្លាំង នឹងការដែលបានឃើញព្រះអង្គទទួលយកទឹកដោះគោអំពីដៃទាសីនោះ។ អ្នកទាំងនោះបានគិតថា ព្រះអង្គប្រាស់ចាកសីលធម៌ហើយ ហើយក៏រត់ចោលព្រះអង្គអស់ទៅ។

យ៉ាងនេះ ព្រះរាជាក៏នៅតែមួយព្រះអង្គឯង។ ព្រះអង្គនៅខ្សោយព្រះកាយនៅឡើយ។ តែព្រះអង្គ ទ្រង់ល្បងធ្វើការភាវនាជាថ្មីទៀត ដោយឥតខ្លាចការអស់ព្រះជន្មឡើយ។ ទ្រង់និយាយទៅកាន់ព្រះអង្គឯងថាៈ «ទោះបីឈាមរបស់អាត្មាអញត្រូវរីងស្ងួតអស់ក៏ដោយ សាច់របស់អាត្មាអញត្រូវរហែករយះរយាយអស់ក៏ដោយ ឆ្អឹងរបស់អាត្មាអញ ត្រូវ

ផុយធ្លាក់ជាធូលីក៏ដោយ អាត្មាអញនឹងមិនចាកចេញពីកន្លែងនេះទេ ដរាបណាអាត្មាអញរកផ្លូវនៃការបានត្រាស់ដឹងមិនទាន់ឃើញ»។

កាលនោះ ព្រះអង្គបានប្រយុទ្ធពុះពារយ៉ាងខ្លាំងក្លាបំផុតដែលមិនអាចរកអ្វីមកប្រៀបផ្ទឹមបាន។ ឱរាព្រះអង្គពោរពេញទៅដោយការអស់សង្ឃឹម និងអារម្មណ៍ច្របូកច្របល់។ វិញ្ញាណព្រះអង្គត្រូវបានគ្របដណ្តប់ដោយអន្ធភាពងងឹតស្លុង ។ ព្រះអង្គត្រូវខ្មោចព្រាយបិសាចទាំងឡាយឡោមព័ទ្ធ ហើយបញ្ឆោតលួងលោមគ្រប់បែបយ៉ាង។ តែព្រះអង្គទ្រង់យកការបញ្ឆោតលួងលោមទាំងនោះមកពិចារណាយ៉ាងហ្មត់ចត់ និងយ៉ាងអត់ធ្មត់មួយម្តងៗ ហើយទាត់ចោលទៅជាបន្តបន្ទាប់គ្នា។ គឺពិតជាការប្រយុទ្ធដ៏មហាពិបាកៈ លោហិតព្រះអង្គត្រូវជ្រាបចេញមក សាច់ព្រះអង្គត្រូវរបេះធ្លាក់ ឆ្អឹងរបស់ព្រះអង្គត្រូវប្រេះបាក់។

តែនៅពេលដែលផ្កាយព្រឹករះឡើងពីទិសខាងកើត ការប្រយុទ្ធក៏បានចប់។ វិញ្ញាណរបស់ព្រះរាជាក្មីចែងចាំងឡើងដូចពន្លឺព្រះអាទិត្យដែលចាប់ផ្តើមរះឡើង។ ក្នុងទីបំផុត ព្រះ

អង្គបានរកផ្លូវដើម្បីការបានត្រាស់ដឹងឃើញហើយ។ គឺនៅថ្ងៃទី០៨ ខែធ្នូ ក្នុងគម្រប់ព្រះជន្ម ៣៥ ព្រះវស្សា ដែលព្រះរាជាទ្រង់បានត្រាស់ជាព្រះពុទ្ធ។

6. ចាប់ពីពេលនោះមក ព្រះរាជាត្រូវបានគេស្គាល់ព្រះអង្គ ក្នុងនាមផ្សេងៗ ជាច្រើន។ អ្នកខ្លះហៅព្រះអង្គ ថា **ព្រះពុទ្ធ** អ្នកខ្លះទៀតដាក់ព្រះនាមព្រះអង្គថា **សក្យមុនី** អ្នកខ្លះទៀតហៅព្រះអង្គថា **អ្នកត្រាស់ញាណគ្រប់សព្វ** អ្នកខ្លះហៅព្រះអង្គថា **ព្រះសក្យមុនីមហាបណ្ឌិតនៃសក្យវង្ស** ជាសម្រេច អ្នកខ្លះផ្សេងទៀតឲ្យព្រះនាមព្រះអង្គថា **បុគ្គលជាទីគោរពបូជា** ក្នុងលោក។

ជាដំបូង ព្រះអង្គបាននិមន្តទៅដល់សួនឧទ្យាន**មិគទាយ** ក្នុងនគរ**ពារាណសី** ដែលព្រាហ្មណ៍ទាំងប្រាំនាក់ដែលបានរស់នៅជាមួយព្រះអង្គ កាលដែលព្រះអង្គទ្រង់ធ្វើទុក្ករកិរិយា ៦ ឆ្នាំនោះរស់នៅ។ មុនដំបូង ព្រាហ្មណ៍ទាំងប្រាំនោះរកកលគេចចេញអំពីព្រះអង្គ។ តែក្រោយដែលព្រះអង្គបាននិយាយពន្យល់សព្វគ្រប់មក ព្រាហ្មណ៍ស្ទួមទាំងនោះក៏ជឿតាមព្រះ

អង្គ ហើយបានទៅជាព្រះសាវ័ករបស់ព្រះអង្គ មុនគេបង្អស់ នាកាលនោះទៅ។ បន្ទាប់មក ព្រះអង្គនិមន្តទៅដល់មហានគរ **រាជគ្រឹះ** ហើយព្រះអង្គបានញ៉ាំងឲ្យព្រះមហាក្សត្រ ព្រះនាម **ពិម្ពិសារ** ឲ្យជឿនូវសាសនាព្រះអង្គ។ គឺចាប់ពីកន្លែងនោះហើយ ដែលព្រះអង្គនិមន្តសុសសព្វទិសទីគ្រប់ជនបទ បិណ្ឌ-បាតចង្ហាន់ ហើយណែនាំពន្យល់អ្នកស្រុកទាំងឡាយ ឲ្យជឿនូវធម៌របស់ព្រះអង្គ។

មហាជនបានជឿតាមព្រះអង្គ បីដូចជាមនុស្សស្រេកទឹក ហើយរត់រកទឹកផឹក ឬបីដូចមនុស្សដែលឃ្លានហើយរត់រកអាហារបរិភោគ។ មហាសាវ័កពីរព្រះអង្គព្រះនាម **ព្រះសារីបុត្ត**១ និង **ព្រះមោគ្គលាន**១ បានដង្ហែព្រះអង្គ ជាមួយនឹងសិស្សពីរពាន់នាក់។

មុនដំបូង ព្រះបាទ**សុទ្ធោទនៈ** ដែលត្រូវជាព្រះបិតារបស់ព្រះពុទ្ធ ដោយទ្រង់នៅមានព្រះទ័យក្រៀមក្រំនៅឡើយនឹងការដែលព្រះរាជបុត្រចាកចោលព្រះបរមរាជវាំង ព្រះអង្គពុំបានចូលព្រះទ័យទេ។ តែដល់ក្រោយមក ព្រះអង្គក៏ត្រឡប់ទៅជាអ្នកជឿតាមព្រះពុទ្ធម្នាក់ដ៏ស្មោះស្ម័គ្រ។

ព្រះនាង **មហាប្រជាបតី** ដែលជាព្រះមាតុច្ឆា និងជាមាតាចិញ្ចឹមរបស់ព្រះពុទ្ធ, ព្រះនាង **យសោធរា** ដែលជាព្រះមហេសីរបស់ព្រះអង្គ និងព្រះញាតិទាំងអស់ក្នុងវង្សសក្យ ក៏ជឿតាមព្រះអង្គ។ មនុស្សជាច្រើនទៀតក៏ជឿតាមព្រះអង្គយ៉ាងស្មោះដែរ។

7. ក្នុងរយៈ ៤៥ ឆ្នាំ ព្រះពុទ្ធទ្រង់និមន្តសុសសព្វក្នុងភូមិប្រទេសនានា ដើម្បីសម្តែងធម្មទេសនា និងពន្យល់ប្រជាជនឲ្យយល់ហើយប្រតិបត្តិតាមរបៀបរស់នៅរបស់ព្រះពុទ្ធអង្គ។ ក្នុងទីបំផុត គឺក្នុងព្រះជន្មបាន ៨០ ព្រះវស្សា នៅពេលព្រះអង្គនិមន្តទៅដល់នគរ **វេសាលី** ក្នុងលំដាប់ផ្លូវដែលព្រះអង្គនិមន្តពី**រាជគ្រឹះ** ទៅ**សាវត្ថី** ព្រះអង្គក៏ធ្លាក់មានអាពាធ ហើយព្រះអង្គទ្រង់ទាយទុកថា ក្នុងបីខែទៅមុខនេះព្រះអង្គនឹងចូលព្រះនិព្វាន។ ព្រះអង្គទ្រង់បន្តដំណើរទៅទៀតទៅដល់នគរ**បាវា**។ នៅទីនោះ ព្រះអង្គទ្រង់អាពាធរឹតតែខ្លាំងឡើងៗ នៅក្រោយពេលដែលព្រះអង្គឆាន់ចង្ហាន់ដែលជាងដំដែកម្នាក់ឈ្មោះ **ចុន្ទៈ** បានប្រគេន។ បន្ទាប់មក ដោយការខិតខំបន្តិចម្តងៗ ទោះបីជាមានការឈឺចាប់ និងការខ្សោយព្រះកាយពលជា

ខ្លាំងក៏ដោយ ព្រះអង្គបាននិមន្តទៅដល់ព្រៃ ដែលស្ថិតនៅជាយក្រុង**កុសិនារា**។

នៅទីនោះ ព្រះអង្គទ្រង់ទម្រេតព្រះកាយនាកណ្ដាលសាលព្រឹក្សធំៗពីរដើម ហើយព្រះអង្គទ្រង់បន្តការប្រៀនប្រដៅដល់សាវ័កទាំងឡាយរបស់ព្រះអង្គ រហូតដល់ព្រះអង្គសុគតទៅ។ នៅទីបំផុត ក្រោយពេលដែលព្រះអង្គបានបំពេញករណីយកិច្ចជាគ្រូអាចារ្យធំបំផុតនៃមនុស្សលោក និងជាទីស្រឡាញ់បំផុតនៃបុគ្គលគ្រប់រូប ព្រះអង្គក៏បានយាងទៅកាន់ស្ថានបរមសុខ គឺឋានសួប់គ្មានទីបំផុត។

8. នៅក្រោមការដឹកនាំរបស់**ព្រះអានន្ទ** ដែលជាសាវ័កសំណាប់បំផុតរបស់ព្រះអង្គ ពុទ្ធបរិស័ទទាំងឡាយបានព្រមព្រៀងគ្នាសម្រេចធ្វើឈាបនកិច្ចសពព្រះពុទ្ធ នៅក្រុង**កុសិនារា**នោះទៅ។

ព្រះបាទ **អជាតសត្តុ** និងអធិរាជប្រាំពីរអង្គទៀត ដែលសោយរាជ្យនៅនគរជាប់គ្នានោះ បានសុំឲ្យចែករំលែកព្រះពុទ្ធសារីរិកធាតុរវាងគ្នា និងគ្នា។ មុនដំបូង ព្រះមហាក្សត្រ

នៃក្រុង**កុសិនារា** ទ្រង់ប្រឆាំងនឹងសេចក្តីស្នើនេះ ដែលជាហេតុមួយបម្រុងនឹងនាំឲ្យមានចម្បាំងផ្ទុះឡើង។ តែដល់ក្រោយមកលុះដោយឱវាទរបស់មហាបណ្ឌិតម្នាក់ឈ្មោះ **ទោណៈ** ការទាស់ទែងគ្នានោះក៏រលាយទៅវិញ ហើយព្រះសារីរិកធាតុ ក៏ត្រូវបានចែកគ្នា រវាងប្រាំបីព្រះរាជាណាចក្រនោះទៅ។ ព្រះសារីរិកធាតុ និងថូដីដាក់ធាតុ ត្រូវបានចែករំលែកទៅព្រះមហាក្សត្រពីរនគរផ្សេងទៀត ដើម្បីជាទីសក្ការៈបូជា។ ហេតុនេះហើយបានជា ស្តូបវិមានជាទីរំលឹកដល់ ព្រះពុទ្ធជាម្ចាស់ត្រូវបានកសាងឡើងជាច្រើន ដើម្បីតម្កល់ព្រះសារីរិកធាតុនៃព្រះពុទ្ធអង្គ។

II

ឱវាទចុងក្រោយរបស់ព្រះពុទ្ធ

1. នៅពេលដែលព្រះអង្គដួលដេកកណ្តាលសាលព្រឹក្ស នាក្រុង**កុសិនារា**នោះ ព្រះពុទ្ធជាម្ចាស់ ទ្រង់មានព្រះពុទ្ធដីកាជាចុងក្រោយបង្គាស់ទៅកាន់ព្រះសាវ័កថា:

«ចូរអ្នកជាប្រទីបបំភ្លឺខ្លួនឯង ចូរអ្នកជួយខ្លួនឯង ចូរអ្នកកុំ

រស់ដោយសារអ្នកដទៃ។ ចូរឲ្យការប្រៀនប្រដៅរបស់តថាគត ជាប្រទីបរបស់អ្នក និងជាទីពំនឹងរបស់អ្នក។ ចូរកុំយោលទៅ តាមការប្រៀនប្រដៅរបស់អ្នកផ្សេងទៀត»។

«ចូរក្រឡេកមើលទៅរូបរបស់អ្នក តើវាមានសភាពមិន បរិសុទ្ធយ៉ាងណា! ដឹងច្បាស់ហើយថា សេចក្ដីសប្បាយរីករាយ និងសេចក្ដីទុក្ខគ្រាំគ្រានៃរូបកាយ ជាមូលហេតុនៃការឈឺចាប់ នោះ តើអ្នកអាចបណ្ដាលឲ្យរូបកាយនោះ វាបំពេញបំណងវា បានដោយសេរីបានឬ ? ចូរក្រឡេកមើលទៅវិញ្ញាណរបស់អ្នក តើវាផ្លាស់ប្ដូរប៉ុន្មានដង? ក្នុងពេលដែលអ្នកដឹងថា មនោ-សញ្ចេតនាទាំងនោះ ច្បាស់ជានឹងនាំអ្នកទៅកាន់សេចក្ដី វេទនា តើអ្នកអាចបណ្ដោយខ្លួនឲ្យធ្លាក់ទៅក្នុងសេចក្ដីភ័ន្តច្រឡំ គំនិត ហើយប្រកាន់យកអភិមានះ និងអត្តទត្តភាពបានឬទេ? ចូលក្រឡេកមើលទៅវត្ថុធាតុគ្រប់ទាំងអស់នៅលើលោកនេះ ចុះ តើអ្នកអាចសម្គាល់ឃើញវត្ថុណាដែលឋិតថេរដែរឬទេ ? តើអ្នកសម្គាល់ឃើញថា វត្ថុទាំងនោះ វាគ្រាន់តែជាការ ប្រមូលផ្ដុំភ្ជាប់គ្នានៃវត្ថុធាតុឯទៀតៗ ដែលយូរឬឆាប់ នឹងត្រូវ តែបែកបាក់គ្នា ហើយបែកខ្ញែកគ្នាជាពុំខាននោះដែរឬទេ ?

ប៉ុន្តែចូរកុំមានការភិតភ័យដោយសារតែបានសម្គាល់ឃើញថា វត្ថុអ្វីៗក៏ជាទុក្ខវេទនានោះ ចូរធ្វើតាមការប្រៀនប្រដៅរបស់តថាគតជានិច្ច ទោះបីក្រោយពេលតថាគតអស់សង្ខារទៅហើយក្តី។ បើអ្នកប្រតិបត្តិតាមឱវាទតថាគត អ្នកមុខជាចាកផុតអំពីទុក្ខ ហើយអ្នកនឹងពិតជាសាវ័ករបស់តថាគតជាពុំខាន។

2. «ម្នាលភិក្ខុទាំងឡាយ! សេចក្តីប្រៀនប្រដៅ ដែលតថាគតបានផ្តល់ឲ្យអ្នកទាំងប៉ុន្មាន ចូរអ្នកកុំភ្លេចឲ្យសោះ ហើយនិងកុំឲ្យបាត់បង់ឲ្យសោះ។ អ្នកត្រូវតែជញ្ជឹងគិតចំពោះការប្រៀនប្រដៅទាំងនោះ ជានិច្ច ហើយត្រូវតែប្រតិបត្តិតាមជានិច្ចនិរន្តរ៍។ បើអ្នកធ្វើតាមការប្រៀនប្រដៅរបស់តថាគត អ្នកនឹងបានប្រកបដោយសុភមង្គលជានិច្ចកាល»។

«សារៈសំខាន់ក្នុងការប្រៀនប្រដៅរបស់តថាគត គឺអ្នកត្រូវតែត្រួតត្រាបំពត់ចិត្តរបស់អ្នក។ អ្នកត្រូវតែលះបង់ការលោភលន់ ហើយធ្វើខ្លួនអ្នកឲ្យត្រង់ ធ្វើចិត្តអ្នកឲ្យបរិសុទ្ធ និងប្រកាន់ពាក្យសម្តីអ្នកឲ្យស្មោះត្រង់។ បើអ្នកជញ្ជឹងគិតជានិច្ច

ថា ជីវិតរបស់អ្នកវាមានសភាពមិនឋិតថេរ នោះអ្នកមុខជានឹងអាចចៀសផុតពីការលោភលន់ និងការមានកំហឹង ហើយអ្នកនឹងអាចចៀសផុតពីទុក្ខគ្រប់យ៉ាងបាន។

«បើអ្នកសង្កេតឃើញថា ចិត្តរបស់អ្នកវាមានចំណង់ ហើយធ្លាក់ទៅក្នុងសេចក្តីលោភលន់ អ្នកត្រូវតែបំបាត់ចោលសេចក្តីលោភលន់នោះ ហើយត្រួតត្រាទប់ចំណង់នោះ ចូរអ្នកតាំងខ្លួនអ្នកជាគ្រូនៃចិត្តរបស់អ្នក»។

«គឺចិត្តរបស់យើងផ្ទាល់នេះហើយ ដែលធ្វើឲ្យយើងបានជាព្រះពុទ្ធមួយអង្គ ឬក៏ធ្វើឲ្យយើងទៅជាសត្វជាតុមួយ។ បើយើងយល់ច្រឡំក្នុងការខុស យើងនឹងទៅជាបិសាច តែបើយើងភ្លឺស្វាង យើងនឹងបានជាព្រះពុទ្ធ។ ហេតុនេះ ចូរអ្នកត្រួតត្រាទប់ចិត្តរបស់អ្នក កុំឲ្យវាឃ្លាតចាកអំពីមាគ៌ាថ្លៃថ្នូរ។

3. «ដោយអនុលោមទៅតាមការប្រៀនប្រដៅ របស់តថាគត ចូរអ្នកត្រូវគេះគោរពគ្នាទៅវិញទៅមក ចូរអ្នកចៀសវាងការឈ្លោះប្រកែកគ្នា។ ចូរអ្នកកុំធ្វើត្រាប់ទឹក និងប្រេង ដែលរុញច្រានគ្នាទៅវិញទៅមកជានិច្ចនោះ តែចូរ

អ្នកធ្វើត្រាប់តាមទឹក និងទឹកដោះ ដែលអាចលាយចូលគ្នាបាន»។

«ចូរអ្នកសិក្សារៀនទាំងអស់គ្នា ចូរអ្នកបង្ហាត់បង្រៀនគ្នាទៅវិញទៅមក ចូរអ្នកធ្វើវត្តប្រតិបត្តិទាំងអស់គ្នា។ ចូរអ្នកកុំបំផ្លាញសតិរបស់អ្នក ហើយធ្វើឲ្យខាតពេលវេលារបស់អ្នកក្នុងភាពទំនេរ និងក្នុងការឈ្លោះទាស់ទែងគ្នា។ ចូរអ្នកទទួលត្រេកអររីករាយនឹងផ្កានៃការបានត្រាស់ដឹង ដែលរីកក្នុងរដូវ ហើយបេះយកផលនៃផ្លូវត្រូវ»។

«សេចក្តីប្រៀនប្រដៅទាំងប៉ុន្មាន ដែលតថាគត បានផ្តល់ដល់អ្នក គឺជាគតិអារម្មណ៍ដែលតថាគតទទួលបាន ដោយតថាគតបានដើរតាមផ្លូវនោះដោយខ្លួនឯង។ ចូរអ្នកធ្វើតាមការប្រៀនប្រដៅទាំងនោះ ហើយចូរអ្នកអនុលោមទៅតាមគ្រប់កាលៈទេសៈទាំងអស់»។

«បើអ្នកមិនរវល់យកចិត្តទុកដាក់នឹងការប្រៀនប្រដៅទាំងនេះ បានន័យថា អ្នកមិនដែលបានជួបនឹងតថាគត ដោយពិតគឺប្រាកដជាអ្នកនៅឆ្ងាយពីតថាគត ទោះបីនៅពេលនេះ អ្នកកំពុងអង្គុយជិតបង្កើយនឹងតថាគតក៏ដោយ។ តែផ្ទុយទៅវិញ បើអ្នកទទួលនឹងប្រតិបត្តិតាមការប្រៀនប្រដៅ របស់តថាគត

ទោះបីជាអ្នកនៅដល់ចុងម្ខាងទៀតនៃពិភពលោក ក៏ដោយ ក៏អ្នកហាក់ដូចជានៅជិតបង្កើយនឹងតថាគតដែរ»។

4. «ម្នាលភិក្ខុទាំងឡាយ! អវសានជីវិតរបស់តថាគតជិតមកដល់ហើយ ការបែកគ្នារវាងយើង ក៏កាន់តែជិតមកដល់ដែរ។ តែចូរអ្នកកុំមានទុក្ខសោកឡើយ។ ជីវិតគឺជាការផ្លាស់ប្តូរជានិច្ចនិរន្តរ៍ ហើយគ្មានអ្វីដែលអាចចៀសផុតពីការរលាយទៅវិញនៃរូបកាយទេ។ តថាគត នឹងបង្ហាញអ្នកទាំងឡាយឲ្យឃើញក្នុងរឿងនេះ នៅពេលឥឡូវនេះ ដោយការមរណៈផ្ទាល់របស់តថាគតនេះឯង រូបកាយរបស់តថាគតនឹងរលាយទៅ ដូចជារទេះដែលទ្រុឌទ្រោមដូច្នោះឯង»។

«ចូរកុំសោយសោកដោយឥតប្រយោជន៍នោះ ចូរអ្នកយល់ឲ្យច្បាស់ថា គ្មានអ្វីដែលឋិតថេរទេ ដូច្នេះហើយជីវិតមនុស្សក៏វាជាសភាពទទេ គ្មានអ្វីសោះយ៉ាងនោះដែរ។ ចូរកុំរក្សាចំណង់ដែលគ្មានទំនង ដោយសារតែយល់ឃើញថា អ្វីៗដែលមិនឋិតថេរ វាអាចទៅជាឋិតថេរនោះ»។

«បិសាចនៃចំណង់ទាំងឡាយក្នុងលោកនេះ រកគ្រប់មធ្យោបាយជានិច្ចកាល ដើម្បីនឹងបំភាន់សតិអ្នក។ បើសិនជាមានពស់វែករស់នៅក្នុងបន្ទប់របស់អ្នក អ្នកអាចដេកដោយសុខសាន្តបាន លុះត្រាតែអ្នកដេញពស់វែកនោះឲ្យចេញពីបន្ទប់អ្នករួចហើយ»។

«អ្នកត្រូវតែផ្តាច់ចំណងនៃចំណង់លោកិយ ហើយបណ្តេញវាចេញ ដូចជាអ្នកបានបណ្តេញពស់វែកឲ្យចេញពីបន្ទប់យ៉ាងនោះដែរ។ អ្នកត្រូវតែការពារសតិរបស់អ្នកឲ្យមធ្យ័ត»។

5. «ម្នាលភិក្ខុទាំងឡាយ! ទីអវសានរបស់តថាគតមកដល់ហើយ តែចូលកុំភ្លេចថា សេចក្តីមរណៈវាគ្រាន់តែជាការរលាយនៃរូបកាយតែប៉ុណ្ណោះទេ។ រូបកាយកើតឡើងពីមាតាបិតា ធំធាត់ឡើងដោយសារចំណីអាហារ តែអ្វីដែលរូបកាយមិនអាចចៀសផុតសម្រាប់រូបកាយគឺ ឈឺ និងស្លាប់»។

«ព្រះពុទ្ធពិតប្រាកដនោះ ពុំមែនជារូបកាយមនុស្សទេ ប៉ុន្តែគឺជាការបានត្រាស់ដឹងនោះឯង។ រូបកាយមនុស្ស ត្រូវតែរលាយបាត់បង់ជាធម្មតា តែព្រហ្មចារីភាពនៃការត្រាស់ដឹង ឋិតថេរជានិច្ចគ្មានទីបំផុត នៅក្នុងការពិតនៃព្រះធម្ម និង

ក្នុងការប្រតិបត្តិព្រះធម្ម។ អ្នកដែលឃើញតែរូបកាយរបស់តថាគត មិនបានឃើញតថាគតដោយពិតទេ។ មានតែអ្នកដែលទទួលយកការប្រៀនប្រដៅរបស់តថាគតទេ ដែលបានឃើញតថាគតដោយពិត។»។

«ក្រោយពេលដែលតថាគតអស់សង្ខារទៅ ព្រះធម្មនឹងទៅជាគ្រូរបស់អ្នក។ ចូរប្រតិបត្តិតាមព្រះធម្ម ធ្វើយ៉ាងនេះអ្នកនឹងបានទៅជាសាសនិកម្នាក់ដែលជឿតាមតថាគត»។

«ក្នុងជីវិតតថាគត ៤៥ ឆ្នាំនេះ តថាគតគ្មានបានលាក់ទុកអ្វីបន្តិចបន្តួចក្នុងការប្រៀនប្រដៅរបស់តថាគតទេ។ គ្មានអ្វីដែលជាការប្រៀនប្រដៅជាសម្ងាត់ទេ ក្នុងន័យលាក់លៀមក៏គ្មានដែរ។ អ្វីៗទាំងអស់ ត្រូវបានប្រៀនប្រដៅទៅដោយស្មោះត្រង់ និងច្បាស់លាស់។ សាវ័កជាទីស្រឡាញ់របស់តថាគតទាំងឡាយអើយ! ពេលនេះជាអវសាននៃតថាគតហើយ។ បន្តិចទៀតនេះ តថាគតនឹងទៅកាន់និព្វានហើយ សេចក្តីទាំងនេះហើយ ជាការប្រៀនប្រដៅរបស់តថាគត»។

ចំពូកទី ២

ព្រះពុទ្ធអនន្ត និងប្រសើរបំផុត

I

សេចក្តីអាសូរ និងពររបស់ព្រះពុទ្ធ

1. *ព្រះទ័យព្រះពុទ្ធ ពោរពេញទៅដោយមហាអាសូរ និង មហាករុណា។ ចិត្តមហាមេត្តាដែលពោរពេញទៅដោយ សេចក្តីស្រឡាញ់ និងករុណា គឺជាការស្ម័គ្រចិត្តជួយដោះទុក្ខ សត្វលោកតាមគ្រប់មធ្យោបាយ។ ចិត្តមហាអាសូរ គឺជាចិត្ត ដែលរុញច្រានឲ្យឈឺជាមួយអ្នកជំងឺ ឲ្យកើតទុក្ខជាមួយអ្នក មានទុក្ខ។*

«ទុក្ខរបស់អ្នក ជាទុក្ខរបស់តថាគត សុភមង្គលរបស់អ្នក ជាសុភមង្គលរបស់តថាគត» នេះជាវាចារបស់ព្រះពុទ្ធ។ *យ៉ាង ណាមិញ ដូចជាមាតាដែលតែងតែស្នេហាបុត្រជានិច្ច។ ព្រះពុទ្ធ អង្គពុំដែលភ្លេចមនោគតិនេះទេ សូម្បីតែមួយភ្លែតក៏គ្មានដែរ ពីព្រោះជាធម្មជាតិរបស់ព្រះពុទ្ធ ដែលមានព្រះទ័យពោរពេញ ទៅដោយការអាណិតអាសូរ។*

ចិត្តអាណិតអាសូររបស់ព្រះពុទ្ធ យោលទៅតាមសេចក្តីត្រូវការរបស់មនុស្សលោក។ ជំនឿរបស់បុគ្គល គឺជាប្រតិកម្មនៃចិត្តអាណិតអាសូររបស់ព្រះពុទ្ធនោះឯង។ ជំនឿនេះហើយដែលនាំឲ្យបុគ្គលនោះទៅកាន់ការត្រាស់ដឹង ប្រាកដដូចជាមាតាដែលបំពេញករណីយកិច្ចជាម្តាយ ដោយសេចក្តីស្នេហាបុត្ររបស់ខ្លួន។ យ៉ាងណាមិញ បុត្រនោះ ដោយមានប្រតិកម្មចំពោះសេចក្តីស្រឡាញ់ស្មោះនៃមាតានោះ ក៏អស់មានការព្រួយបារម្ភ ហើយក៏មានអារម្មណ៍សុខស្រួលទៅ។

តែសត្វលោកមិនយល់ចិត្តរបស់ព្រះពុទ្ធ ហើយនៅតែរងទុក្ខវេទនាមិនចេះចប់ ដោយការកាន់គំនិតនឹងចំណង់ ដែលកើតឡើងពីសេចក្តីល្ងង់ខ្លៅរបស់ខ្លួន។ សត្វលោកមានទុក្ខដោយអំពើផ្ទាល់របស់ខ្លួន ដែលប្រមូលផ្តុំឡើងដោយសារតែតណ្ហាលោកិយ ហើយវង្វេងក្នុងគំនរគំនិតភាន់ច្រឡំ ដោយមានសំពាយមហាធ្ងន់មួយពេញទៅដោយអំពើអាក្រក់ ស្ពាយជាប់នឹងខ្លួនផង។

2. ចូរកុំគិតស្មានថា សេចក្តីអាណិតអាសូររបស់ព្រះពុទ្ធ គឺ

សម្រាប់តែជីវិតបច្ចុប្បន្នតែប៉ុណ្ណោះនោះ។ សេចក្ដីអាណិតអាសូរ ដែលមិនមានកំណត់ពេលវេលារបស់ព្រះពុទ្ធអនន្តនោះ បានបញ្ចេញសកម្មភាពតាំងតែពីកាលដែលសត្វលោកធ្លាក់ក្នុងការវង្វេងគំនិត ដោយហេតុតែល្ងង់ខ្លៅនោះម៉្លេះ។

ព្រះពុទ្ធអនន្តបង្ហាញឲ្យឃើញ ស្ដែងឡើងជានិច្ចចំពោះមុខសត្វលោក ក្នុងភាពជាវរមិត្ត ហើយនាំយកមកផ្ដល់ឲ្យនូវរបៀបដោះទុក្ខភ័យដែលប្រកបដោយគតិបណ្ឌិតជាទីបំផុត។

ព្រះពុទ្ធសក្យមុនី ព្រះអង្គទ្រង់ប្រសូតក្នុងត្រកូលសក្យព្រះអង្គចាកចោលផាសុកភាពនៃព្រះរាជដំណាក់ ហើយទៅរស់នៅក្នុងភាពជាតាបសឥសី។ ដោយសារការស្មឹងស្មាធិ៍ភាវនាក្នុងភាពស្ងប់ស្ងាត់ ព្រះអង្គក៏បានត្រាស់ជាព្រះពុទ្ធ។ ព្រះអង្គបានសម្ដែងធម៌ទូន្មានមហាជន ដែលយកចិត្តទុកដាក់ស្ដាប់ត្រាប់ត្រង់តាមព្រះអង្គ ហើយក្នុងទីបំផុត ព្រះអង្គបានបង្ហាញឲ្យឃើញច្បាស់ ដោយការមរណៈរបស់ព្រះអង្គពីលោកនេះទៅ។

ភារកិច្ចរបស់ព្រះពុទ្ធគ្មានទីបំផុត ដូចជាសេចក្ដីល្ងង់ខ្លៅរបស់សត្វលោកគ្មានទីអវសានដូច្នោះដែរ។ ជម្រៅនៃសេចក្ដីល្ងង់ខ្លៅរបស់សត្វលោកវាជ្រៅគ្មានទីបំផុតយ៉ាងណា សេចក្ដី

អាណិតអាសូររបស់ព្រះពុទ្ធក៏គ្មានព្រំដែនយ៉ាងនោះដែរ។

ការដែលព្រះពុទ្ធកាត់ព្រះទ័យលះបង់ជីវិតលោកិយនេះ ព្រះអង្គបានធ្វើសេចក្តីសច្ចាធំៗ បួនៈ ស្រោចស្រង់សត្វលោកទាំងអស់ លះបង់គ្រប់ការប្រាថ្នាក្នុងលោកិយទាំងអស់ រៀនគ្រប់សិក្ខាបទទាំងអស់ និងសម្រេចបាននូវការត្រាស់ដឹងឥតខ្ចោះកន្លែងណាមួយឡើយ។ សេចក្តីសច្ចារបស់ព្រះអង្គទាំងនេះ បញ្ចេញឲ្យឃើញជាក់ឡើង តាមសេចក្តីស្នេហានិងប្រណីអាសូរ ដែលជាលក្ខណៈសំខាន់បំផុតក្នុងសភាវៈរបស់ព្រះពុទ្ធ។

3. មុនដំបូងបង្អស់ ព្រះពុទ្ធហាត់រៀនឲ្យមានចិត្តល្អចំពោះគ្រប់សត្វលោកដែលមានជីវិតរស់នៅ ហើយចៀសវាងបាបកម្មដោយការសម្លាប់សត្វរស់ទាំងឡាយ។ ជាបន្ទាប់ ព្រះអង្គប្រាថ្នាឲ្យសត្វទាំងអស់ បានប្រកបតែសុភមង្គលក្នុងជីវិតដ៏វែងឆ្ងាយ។

ព្រះពុទ្ធទ្រង់បានហាត់រៀន ចៀសវាងការលួចប្លន់គេ ហើយព្រះអង្គទ្រង់មានប្រាថ្នាឲ្យសត្វលោកទាំងឡាយ អាចនឹងមានគ្រប់វត្ថុទាំងអស់ដែលខ្លួនត្រូវការ។

ព្រះពុទ្ធ ទ្រង់បានហាត់រៀនចៀសវាងអំពើអនាចារផិតក្បត់ គឺការធ្វើឲ្យខូចគុណសម្បត្តិ។ អាស្រ័យដោយបុណ្យបារមីនេះ ព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងឡាយអាចយល់នូវសេចក្តីសុខដែលកើតពីចិត្តបរិសុទ្ធ ហើយលែងមានទុក្ខ-ភ័យដែលកើតពីចំណង់ចង់បានមិនចេះស្កប់ស្កល់។

ព្រះពុទ្ធ ដោយមានប្រាថ្នាឲ្យបានសម្រេចឧត្តមគតិរបស់ព្រះអង្គ ព្រះអង្គបានហាត់រៀនវៀរចាកឲ្យផុតពីអំពើប្រវញ្ចន៍បោកបញ្ឆោតទាំងឡាយ។ អាស្រ័យដោយបុណ្យបារមីនេះ ព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វទាំងឡាយអាចយល់នូវការស្ងប់នៃវិញ្ញាណ ដែលកើតឡើងអំពីសេចក្តីស្មោះត្រង់នៃចិត្ត និងវាចា។

ព្រះពុទ្ធ បានហាត់រៀនចៀសវាងការនិយាយពាក្យបោកបញ្ឆោត អាស្រ័យដោយបុណ្យបារមីនេះ ព្រះអង្គទ្រង់ប្រសិទ្ធពរ ឲ្យសត្វលោកទាំងឡាយ អាចយល់នូវសេចក្តីសប្បាយរីករាយ ដែលបានមកអំពីការចេះស្រឡាញ់រួបរួមគ្នា ហើយនាំគ្នាប្រតិបត្តិធ្វើតាមការប្រៀនប្រដៅរបស់ព្រះអង្គ។

ព្រះអង្គទ្រង់បានហាត់រៀនចៀសវាង ការប្រមាថរំលោក

លើអ្នកដទៃ ហើយព្រះអង្គទ្រង់ប្រសិទ្ធពរ ឲ្យសត្វលោកទាំងឡាយអាចប្រកបនូវសតិស្ងប់ ដែលកើតឡើងពីការចេះរស់នៅដោយសុខសន្តិភាពជាមួយនឹងអ្នកដទៃ។

ព្រះអង្គទ្រង់បានហាត់រៀនចៀសវាងការនិយាយគ្មានខ្លឹមសារ ហើយព្រះអង្គទ្រង់ប្រសិទ្ធពរ ឲ្យសត្វលោកទាំងឡាយអាចស្គាល់នូវសុភមង្គល ដែលកើតឡើងអំពីការចេះមានមេត្តាធម៌។

ព្រះពុទ្ធ ក្នុងបំណងឲ្យបានសម្រេចឧត្តមគតិរបស់ព្រះអង្គ គឺការបានត្រាស់ដឹង ទ្រង់បានហាត់រៀនវៀរចាកឲ្យផុតពីសេចក្តីលោភលន់។ អាស្រ័យដោយបុណ្យបារមីនេះ ព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងឡាយ អាចយល់នូវសុខសន្តិភាព ដែលកើតឡើងបានដោយសារការចេះវៀរចាកនូវសេចក្តីលោភលន់ទាំងឡាយ។

ព្រះអង្គទ្រង់បានហាត់រៀនចៀសវាងកំហឹង ហើយព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងឡាយ ចេះស្រឡាញ់គ្នាទៅវិញទៅមក។

ព្រះអង្គទ្រង់បានហាត់រៀនចៀសឲ្យផុតពីសេចក្តីល្ងង់ខ្លៅ

គឺអវិជ្ជា ហើយព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងឡាយ អាចយល់នូវហេតុធម៌ គឺធម៌ស្តីអំពីការទាក់ទងរវាងហេតុនិង ផល ហើយកុំឲ្យសត្វលោកធ្វេសប្រហែសនឹងធម៌នេះឲ្យសោះ។

ដូច្នេះហើយ សេចក្តីអាសូររបស់ព្រះពុទ្ធគ្របដណ្តប់លើ សត្វលោកទូទៅ ហើយសេចក្តីប្រោសប្រណីជានិច្ចនិរន្តរ៍ របស់ព្រះអង្គ គឺសម្រាប់សុភមង្គលនៃសត្វលោកទាំងនោះ។ ព្រះអង្គស្រឡាញ់សត្វលោក ដូចជាមាតាបិតាស្រឡាញ់បុត្រ។ ព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងនោះ បានប្រកប ដោយសុភមង្គលខ្ពស់បំផុត ពោលគឺៈ ឲ្យបានឆ្លងផុតពី មហាសមុទ្រវដ្តសង្សារ វិលកើតវិលស្លាប់នេះ។

II

ការសង្គ្រោះរបស់ព្រះពុទ្ធ និង របៀបស្រោចស្រង់របស់ព្រះអង្គ

1. ដើម្បីឲ្យពុទ្ធវាចា ដែលចេញពីត្រើយដ៏សែនឆ្ងាយនៃពន្លឺ ត្រាស់ដឹង អាចទៅដល់សត្វលោកដែលកំពុងប្រយុទ្ធពុះពារ មិនចេះចប់ក្នុងលោក ពោរពេញទៅដោយការភាន់ច្រឡំនោះ

ជាការពិបាកពន់ពេកណាស់។ ដូច្នេះហើយបានជា ព្រះពុទ្ធទ្រង់វិលត្រឡប់មកក្នុងលោកនេះវិញ ហើយអនុវត្តរបៀបស្រោចស្រង់របស់ព្រះអង្គ។

ព្រះអង្គទ្រង់មានពុទ្ធដីកាថា: «នៅពេលនេះ តថាគតនឹងនិទានរឿងឧបមាមួយឲ្យអ្នកទាំងឡាយស្ដាប់»។ «នាកាលនោះ មានមហាសេដ្ឋីម្នាក់ ត្រូវភ្លើងឆេះផ្ទះ។ នៅពេលភ្លើងឆេះផ្ទះនោះ មហាសេដ្ឋីពុំបាននៅផ្ទះទេ។ នៅពេលគាត់ត្រឡប់មកវិញ គាត់ឃើញកូនចៅគាត់ កំពុងជក់ចិត្តនឹងល្បែងលេងរបស់វា វាពុំបានចាប់ភ្ញឹកនឹងភ្លើងកំពុងឆេះទ្រលោមនោះទេ ហើយនៅតែលេងក្នុងផ្ទះនោះ ពុំគិតរត់ចេញឡើយ។ ឪពុកក៏ស្រែកថា: «កូនចៅទាំងឡាយ ប្រញាប់រត់ចេញពីផ្ទះឲ្យឆាប់ឡើង ! »។ តែក្មេងទាំងនោះ ពុំបានយកចិត្តស្ដាប់បញ្ជារបស់គាត់ទេ។

ដោយហេតុនោះ ឪពុកដែលភ័យខ្លាំង ក៏ស្រែកឡើងម្ដងទៀត: «កូនទាំងឡាយ អញមានប្រដាប់លេងល្អណាស់ នៅឯនេះនែ៎ ចូរនាំគ្នាចេញពីផ្ទះមកយកភ្លាមទៅ ! »។ លើកនេះក្មេងទាំងនោះ ក៏ចាប់ភ្ញឹកនឹងសំឡេងស្រែកហៅរបស់ឪពុកវា

ហើយក៏នាំគ្នារត់ចេញពីផ្ទះដែលភ្លើងកំពុងឆេះទ្រលោមនោះអស់ទៅ»។

លោកនេះ គឺផ្ទះដែលត្រូវភ្លើងកំពុងឆេះទ្រលោមសន្ធោសន្ធៅនោះឯង។ តែសត្វលោក ដែលមិនដឹងខ្លួនមិនចាប់ភ្ញឹកនឹងអគ្គីភ័យក្នុងផ្ទះនោះ កំពុងតែរស់នៅក្នុងគ្រោះថ្នាក់ធំដោយនឹងត្រូវភ្លើងឆេះពេលដល់ក្តីមរណៈ។ ដោយហេតុនេះព្រះពុទ្ធ ដោយព្រះអង្គទ្រង់មានសេចក្តីអាសូរ ក៏នឹកគិតរកមធ្យោបាយដើម្បីសង្គ្រោះសត្វលោកទាំងនោះ។

2. ព្រះពុទ្ធមានពុទ្ធដីកាថា: «តថាគតនឹងនិទានរឿងប្រៀបធៀបមួយទៀត ឲ្យអ្នកទាំងឡាយស្តាប់។ មានថ្ងៃមួយនោះបុត្រតែមួយរបស់មហាសេដ្ឋីម្នាក់ បានរត់ចេញពីគេហដ្ឋានរបស់ខ្លួន ហើយធ្លាក់ខ្លួនទៅក្នុងក្តីទុក្ខវេទនាក្រៃលែង។

ឪពុកបានចេញពីផ្ទះទៅតាមរកកូន តែត្រូវវង្វេងផ្លូវគ្នាបាត់ដានអស់ទៅ។ ឪពុកបានខិតខំយ៉ាងអស់សមត្ថភាព ដើម្បីរកកូនឲ្យឃើញ តែគ្មានបានលទ្ធផលសោះ។

នៅពេលនោះ បុត្រមហាសេដ្ឋីដែលធ្លាក់ខ្លួនរងទុក្ខវេទនា

នោះ បានដើរវង្វេងវិលវល់នៅជិតកន្លែងដែលឪពុករស់នៅ។

ឪពុកក៏ស្គាល់ជាក់ជាកូនរបស់ខ្លួនភ្លាម ហើយបង្គាប់ខ្ញុំបម្រើឲ្យទៅនាំក្មេងអនាថានោះមក។ ក្មេងអនាថានោះដោយរំភើបនឹងភាពរុងរឿងនៃមហាគ្រឹះស្ថាន និងដោយខ្លាចខ្ញុំបម្រើនោះមើលងាយ ពុំចង់ទៅតាមខ្ញុំបម្រើអស់ទាំងនោះទេ។

ឪពុកបានប្រើខ្ញុំបម្រើឲ្យទៅម្តងទៀត ដោយបង្គាប់ថា ឲ្យៗ ប្រាក់កាសខ្លះដល់កូននោះ បើវាចង់ធ្វើជាអ្នកបម្រើក្នុងផ្ទះម្នាក់របស់មហាសេដ្ឋីដែរ។ លើកនេះ កូននោះក៏ព្រមទៅជាមួយនឹងខ្ញុំបម្រើទាំងនោះ ហើយនៅបម្រើក្នុងផ្ទះមហាសេដ្ឋីនោះទៅ។

ឪពុកបានតម្លើងឋានន្តរស័ក្តិជាលំដាប់លំដោយ រហូតដល់ប្រគល់ទ្រព្យសម្បត្តិ និងឃ្លាំងរតនវត្ថុទាំងអស់ឲ្យគ្រប់គ្រងមើលថែរក្សា តែក្មេងនោះនៅតែមិនស្គាល់ថា ជាឪពុកបង្កើតរបស់ខ្លួនទេ។

ឪពុកសប្បាយចិត្តណាស់ ដោយបានឃើញការស្មោះត្រង់

របស់កូន ហើយនៅពេលអវសាននៃជីវិតជិតមកដល់ហើយនោះ គាត់ក៏ប្រជុំគ្រប់សមាជិកគ្រួសារ និងមិត្តភក្តិទាំងអស់ ហើយមានវាចាថា: «នេះហើយជាកូនតែមួយគត់របស់ខ្ញុំ ដែលខ្ញុំខំដើររកអស់ជាច្រើនឆ្នាំមកហើយ។ អំណឹះតទៅ ទ្រព្យសម្បត្តិ និងឃ្លាំងកំណាប់របស់ខ្ញុំទាំងអស់ នឹងបានជាកម្មសិទ្ធិរបស់កូននេះ។»

កូនក៏ភ្ញាក់នឹងការប្រកាសរឿងសម្ងាត់នេះ ហើយស្រដីថា: «ខ្ញុំមិនគ្រាន់តែបានជួបនឹងឪពុកវិញប៉ុណ្ណោះទេ តែរហូតបានទទួលទ្រព្យសម្បត្តិ និងឃ្លាំងកំណាប់ទាំងអស់របស់គាត់ទៀតក្នុងពេលនេះ»។

ក្នុងរឿងប្រៀបធៀបនេះ មហាសេដ្ឋីជាតំណាងព្រះពុទ្ធ ហើយបុត្រអនាថាជាតំណាងសត្វលោកទាំងអស់។ សេចក្តីអាសូររបស់ព្រះពុទ្ធ គ្របដណ្តប់ទូទៅលើសត្វលោកទាំងអស់ដូចជាសេចក្តីស្នេហារបស់ឪពុក ចំពោះកូនតែមួយរបស់ខ្លួនអញ្ចឹងដែរ។ ក្នុងសេចក្តីស្នេហានេះ ព្រះពុទ្ធបាននឹកគិតរកគ្រប់មធ្យោ-បាយទាំងអស់ ដែលប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ ដើម្បីនាំផ្លូវមនុស្សលោក ប្រៀនប្រដៅមនុស្សលោក និងធ្វើឲ្យមនុស្សលោកបានចម្រុងចម្រើន ដោយសម្បត្តិគតិធម៌។

3. «ភ្លៀងធ្លាក់មកប្រោះព្រំរុក្ខជាតិទាំងឡាយស្មើៗ គ្នា យ៉ាងណា សេចក្ដីអាសូររបស់ព្រះពុទ្ធក៏គ្របដណ្ដប់លើ សត្វលោកទាំងឡាយយ៉ាងស្មើៗភាពគ្នាដូចនោះដែរ។ តែក៏ដូចជា រុក្ខ-ជាតិផ្សេងៗគ្នា ដែលទទួលអត្ថប្រយោជន៍ផ្សេងៗ ខុសគ្នាអំពីភ្លៀងមួយមេដដែលនោះយ៉ាងណា សត្វលោកទាំងឡាយដែលមានភាពខុសៗគ្នា និងដែលនៅក្នុងទេសកាលផ្សេងៗគ្នានោះ ក៏ត្រូវបានទទួលពុទ្ធពរតាមដោយរបៀបផ្សេងៗ ខុសគ្នាយ៉ាងនោះដែរ»។

4. មាតាបិតាស្រឡាញ់កូនទាំងអស់របស់ខ្លួនស្មើៗគ្នា តែសេចក្ដីស្នេហានោះចេញឲ្យឃើញឡើងព្រមជាមួយភាពថ្នាក់ថ្នមជាពិសេសចំពោះកូនណាដែលមានជំងឺ។

សេចក្ដីអាសូររបស់ព្រះពុទ្ធ ក៏មានភាពស្មើគ្នា ចំពោះសត្វលោកទាំងអស់ដូចនោះដែរ ហើយបញ្ចេញឲ្យឃើញឡើង ព្រមជាមួយនឹងការថ្នាក់ថ្នម ជាពិសេសចំពោះមនុស្សណាដែលរងទុក្ខវេទនាជាទម្ងន់ដោយសារសេចក្ដីល្ងង់ខ្លៅ។

ព្រះអាទិត្យរះឡើងពីទិសខាងកើត ហើយកំចាត់អន្ធភាព

នៃពិភពលោក ដោយមិនបានគិតទុកជាមុន ឬក៏មានអនុ-គ្រោះនិយមទៅលើតំបន់ណាមួយជាពិសេសនោះទេ។ យ៉ាងណាមិញ សេចក្តីអាសូររបស់ព្រះពុទ្ធ នៅព័ទ្ធជុំវិញសត្វលោកទាំងអស់ ជួយជម្រុញនិងបំភ្លឺសត្វលោកទាំងនោះឲ្យប្រកាន់យកអ្វីដែលត្រូវ ហើយវៀរចាកអ្វីដែលខុស ក៏យ៉ាងនោះដែរ។ ព្រះអង្គទ្រង់កម្ចាត់អន្ធភាពនៃសេចក្តីល្ងង់ខ្លៅ ហើយដឹកនាំសត្វទៅកាន់ពន្លឺត្រាស់ដឹង។

ព្រះពុទ្ធជាបិតាម្នាក់ក្នុងសេចក្តីអាសូររបស់ព្រះអង្គ និងជាមាតាម្នាក់ក្នុងចិត្តល្អប្រពៃពោរពេញទៅដោយ សេចក្តីអាណិតស្រឡាញ់របស់ព្រះអង្គ។ សត្វលោក ដោយលុះក្នុងការល្ងង់ខ្លៅ និងក្នុងការទាក់ចិត្តនឹងចំណង់លោកិយនោះតែងតែប្រព្រឹត្តអំពើផ្សេងៗ យ៉ាងងប់ងល់ហួសហេតុ។ ដូច្នេះព្រះពុទ្ធក៏រឹតតែមានសេចក្តីអាសូរចំពោះសត្វលោក កាន់តែខ្លាំងឡើងដែរ។ មនុស្សលោកគ្មានអ្វីជាជំនួយទេ បើគ្មានសេចក្តីអាសូររបស់ព្រះពុទ្ធ។ មនុស្សលោកក្នុងឋានៈជាកូនចៅរបស់ព្រះពុទ្ធ ត្រូវតែទទួលយករបៀបស្រោចស្រង់របស់ព្រះពុទ្ធអង្គ។

III

ព្រះពុទ្ធអមតៈ

1. *មនុស្សសាមញ្ញទាំងឡាយជឿថា ព្រះពុទ្ធទ្រង់មានកំណើតជាក្សត្រ ហើយបានសម្រេចសម្ពោធិញ្ញាណក្នុងពេលដែលព្រះអង្គចាកចោលព្រះរាជដំណាក់ ហើយប្រកាន់យកជីវភាពជាសមណៈម្នាក់។ តែតាមពិត គឺជាការរៀបចំទុកមុនតាំងពីអតីតកាលដ៏យូរលង់ណាស់មកហើយ ព្រោះថា ព្រះពុទ្ធបានឋិតនៅជានិច្ចក្នុងពិភពលោកមួយដែលគ្មានទីចាប់ផ្ដើមនិងគ្មានទីបញ្ចប់។*

ក្នុងសភាពជាព្រះពុទ្ធអមតៈ ព្រះអង្គទ្រង់បានយល់អំពីមនុស្សគ្រប់ប្រភេទទាំងអស់ ហើយព្រះអង្គបានអនុវត្តវិធីស្រោចស្រង់គ្រប់បែបយ៉ាងទាំងអស់។

នៅក្នុងព្រះធម៌ដែលឋិតថេរហូតនោះ គ្មានសេចក្ដីបញ្ឆោតបន្លំទេ ព្រោះព្រះពុទ្ធយល់ច្បាស់នូវភាពពិតនៃវត្ថុទាំងអស់ក្នុងលោកនេះ ហើយព្រះអង្គពន្យល់ប្រាប់ទៅគ្រប់សត្វលោកតាមតែសភាពនោះឯង។

តាមការពិត ការរកឲ្យយល់នូវលោកនេះ ក្នុងភាពពិតរបស់វា ជាការពិបាកណាស់ ព្រោះថា ថ្វីបើលោកនេះ

មើលទៅឃើញដូចជាពិត តែវាពុំពិតសោះ ថ្វីបើមើលទៅឃើញដូចជាពោរពេញទៅដោយមន្ទិល តែវាមិនដូច្នោះសោះ។ បុគ្គលល្ងង់ខ្លៅ មិនអាចយល់ការពិតនៃលោកនេះបានទេ។

មានតែព្រះពុទ្ធទេ ដែលយល់យ៉ាងជាក់ច្បាស់នូវលោកនេះក្នុងសភាពពិតរបស់វា ហើយព្រះអង្គមិនដែលថ្លែងអះអាងថា លោកនេះពិតឬជាភពបំភាន់ភ្នែក លោកនេះល្អឬអាក្រក់នោះម្តងណាទេ។ ព្រះអង្គទ្រង់ចង្អុលបង្ហាញអំពីលោកយើងនេះក្នុងសភាពរបស់វាតែប៉ុណ្ណោះ។

អ្វីដែលព្រះពុទ្ធទ្រង់ប្រៀនប្រដៅនោះគឺយ៉ាងនេះ៖ សត្វលោកទាំងឡាយត្រូវតែបណ្តុះឫសគុណធម៌តាមសភាពរបស់ខ្លួនតាមអំពើរបស់ខ្លួន និងតាមជំនឿរបស់ខ្លួន។ ការប្រៀនប្រដៅនេះ វិសេសវិសាលបំផុត គួរតែលោកនេះទទួលយកដោយឥតប្រកែក។

2. ព្រះពុទ្ធប្រៀនប្រដៅមិនត្រឹមតែតាមវាចាសំដីតែប៉ុណ្ណោះទេ ព្រះអង្គថែមទាំងបានប្រៀនប្រដៅតាមជីវិតផ្ទាល់

របស់ព្រះអង្គទៀតផង។ ថ្វីបើជីវិតរបស់ព្រះអង្គគ្មានទីអវសាន យ៉ាងនេះក៏ដោយ ព្រះអង្គទ្រង់បានប្រើគ្រប់មធ្យោបាយការកើត និងការស្លាប់ ដើម្បីដាស់សតិអារម្មណ៍សត្វលោកដែលជាប់ជំពាក់នឹងជីវភាពលោកលន់នៃលោកនេះ។

មានគ្រូពេទ្យម្នាក់ ពេលដែលគាត់មិននៅផ្ទះ បុត្រទាំងអស់របស់គាត់ បាននាំគ្នាផឹកថ្នាំពុលដោយចៃដន់។ នៅពេលត្រឡប់មកដល់ផ្ទះវិញ គ្រូពេទ្យនោះឃើញកូនគាត់ឈឺពុល ក៏ផ្សំថ្នាំឲ្យផឹកបន្សាប។ កូនខ្លះដែលមិនពុលខ្លាំង ក៏ទទួលថ្នាំនោះផឹកហើយបានជាទៅ។ តែកូនខ្លះទៀត ដោយពុលខ្លាំងពេក មិនព្រមផឹកថ្នាំនោះទេ។

លោកគ្រូពេទ្យ ដោយមានសេចក្ដីស្នេហាចំពោះបុត្រក៏សម្រេចចិត្តប្រើឧបាយកលដ៏ហួសហេតុមួយ ដើម្បីឲ្យកូនរបស់លោកបានជាអំពីជំងឺពុលនោះ។ លោកឧទានទៅកូនទាំងអស់ថា: «អញត្រូវធ្វើដំណើរទៅឆ្ងាយ។ អញចាស់ហើយមិនដឹងជាស្លាប់ក្នុងថ្ងៃណាទេ»។ បើអញនៅជាមួយឯងទាំងអស់គ្នា អញអាចនឹងថែទាំឯងទាំងអស់គ្នាបាន តែបើអញស្លាប់ទៅ ឯងទាំងអស់គ្នាមុខជានឹងឈឺធ្ងន់ជាងនេះទៅទៀត។

បើឯងទាំងឡាយបានដឹងថាអញស្លាប់ហើយ អញសុំឲ្យឯងរាល់គ្នាផឹកថ្នាំបន្សាបនេះ ហើយឲ្យជាពោគពុលនេះដោយស័ក្តិសិទ្ធិ»។ និយាយចប់ហើយ លោកគ្រូពេទ្យក៏ចេញដំណើរដ៏ឆ្ងាយនោះបាត់ទៅ។ ទៅបាត់បានយូរបន្តិចថ្ងៃមួយ លោកគ្រូពេទ្យប្រើអ្នកនាំសារម្នាក់ ឲ្យមកប្រាប់កូនទាំងឡាយរបស់គាត់ថា គាត់ស្លាប់ហើយ។

កូនទាំងនេះសោកសង្រេងជាខ្លាំងនឹងដំណឹងមរណភាពឪពុក ហើយនិងដឹងខ្លួនថា ពីថ្ងៃនេះទៅ នឹងលែងបានទទួលការបីបាច់រក្សាថ្នាក់ថ្នមពីឪពុកទៀតហើយ។ ដោយនឹកឃើញទៅដល់បណ្តាំចុងក្រោយរបស់ឪពុក និងដោយមានសេចក្តីទុក្ខសោក និងអស់សង្ឃឹម កូនទាំងនោះក៏លេបថ្នាំបន្សាបនោះហើយបានជាសះស្បើយទៅ។

មិនត្រូវដាក់ទោសលោកគ្រូពេទ្យឪពុក ដែលបានបោកបញ្ឆោតកូនៗនោះឡើយ។ ព្រះពុទ្ធប្រៀបបានទៅគ្រូពេទ្យឪពុកនោះឯង: ព្រះអង្គបានប្រឌិតរឿងកើតនិងស្លាប់នេះយកមកប្រើជាឧបាយ ដើម្បីសង្គ្រោះសត្វលោកដែលលង់ក្នុងទាសូបនីយភាពនៃចំណង់។

ចំពូកទី ៣

ទ្រង់ទ្រាយ និងលក្ខណៈរបស់ព្រះពុទ្ធ

I

ទ្រង់ទ្រាយបីក្នុងអង្គកាយព្រះពុទ្ធ

1. *ចូរកុំស្វែងរកឲ្យស្គាល់ព្រះពុទ្ធតាមរយៈ ទម្រង់រាងកាយឬកេតនភណ្ឌរបស់ព្រះអង្គនោះឡើយ ព្រោះទម្រង់រូបកាយក្តី កេតនភណ្ឌទាំងឡាយក្តី ពុំមែនជាព្រះពុទ្ធពិតប្រាកដទេ។ ព្រះពុទ្ធពិតប្រាកដគឺ សម្ពោធិញ្ញាណ ឬការត្រាស់ដឹងនោះឯង។*

វិធីពិតប្រាកដដែលនាំឲ្យស្គាល់ព្រះពុទ្ធ គឺការធ្វើឲ្យបានសម្រេចការត្រាស់ដឹងនោះឯង។

បើសិនជាបុគ្គលណាម្នាក់បានឃើញរូបតំណាងព្រះពុទ្ធដ៏ល្អវិសេស ហើយនឹកគិតថាខ្លួនបានស្គាល់ព្រះពុទ្ធ គឺបុគ្គលនោះធ្លាក់ក្នុងភាពភាន់ច្រឡំដោយភ្នែកល្ងិតល្ងង់ហើយ ព្រោះព្រះពុទ្ធពិតប្រាកដ មិនអាចបញ្ចូលខ្លួនទៅក្នុងទម្រង់រូបណាមួយបានទេឬ អាចឲ្យមើលឃើញដោយភ្នែកមនុស្សលោក

នោះក៏ទេដែរ។ ទោះបីការពិពណ៌នាអំពីកេតនភណ្ឌព្រះពុទ្ធនោះធ្វើឡើងដ៏ល្អិតល្អន់ឥតខ្ចោះយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់អាចយល់ពីព្រះពុទ្ធបានដែរ។ បានសេចក្តីថា ការធ្វើពិពណ៌នាអំពីកេតនភណ្ឌព្រះពុទ្ធ តាមដោយពាក្យសម្តីមនុស្សលោក ជាការពុំអាចធ្វើបាន។

ថ្វីបើយើងនិយាយអំពីទម្រង់រូបរបស់ព្រះអង្គ ព្រះពុទ្ធអរហន្តគ្មានទ្រង់ទ្រាយច្បាស់លាស់ទេ តែព្រះអង្គអាចបញ្ចេញឲ្យឃើញបានតាមគ្រប់ទម្រង់។ ថ្វីបើយើងធ្វើការពិពណ៌នាអំពីកេតនភណ្ឌព្រះអង្គ ព្រះពុទ្ធអរហន្តគ្មានកេតនភណ្ឌជាក់ច្បាស់ទេ តែព្រះអង្គអាចបញ្ចេញឲ្យឃើញបានតាមគ្រប់កេតនភណ្ឌដ៏វិសេស។

ដូច្នេះហើយ បើបុគ្គលណាឃើញយ៉ាងជាក់ច្បាស់នូវទ្រង់ទ្រាយព្រះពុទ្ធ ឬយល់យ៉ាងជាក់ច្បាស់នូវកេតនភណ្ឌរបស់ព្រះពុទ្ធ ហើយប៉ុន្តែមិនជំពាក់ចិត្តទៅនឹងទ្រង់ទ្រាយ ឬកេតនភណ្ឌទាំងនោះទេ បុគ្គលនោះឈ្មោះថា មានសមត្ថភាពអាចមើលឃើញ និងយល់ព្រះពុទ្ធបាន។

2. អង្គកាយព្រះពុទ្ធ គឺការត្រាស់ដឹង ឬសម្ពោធិញ្ញាណនោះឯង។ ដោយគ្មានរូបរាងនិងគ្មានធាតុ ព្រះពុទ្ធមានស្ថិតនៅ ហើយនឹងស្ថិតនៅតទៅទៀតជានិច្ច។ មិនមែនជាអង្គកាយដែលត្រូវតែទទួលការចិញ្ចឹមបីបាច់ ដោយសារចំណីអាហារនោះទេ គឺជាអង្គកាយអមតៈ ដែលមានព្រហ្មចារិភាពជាធាតុ។ ហេតុដូច្នេះ ព្រះពុទ្ធគ្មានការភ័យ ឬព្រួយបារម្ភអ្វីទេៈ ព្រះអង្គមិនប្រែប្រួលរហូត។

ហេតុនេះ ព្រះពុទ្ធមិនរលត់បាត់ទេ ដរាបណាការត្រាស់ដឹងនៅមាននោះ។ ការត្រាស់ដឹងចេញស្តែងឡើងជាពន្លឺនៃព្រហ្មចារិភាព ដែលដាស់សតិសត្វលោកឲ្យភ្ញាក់ស្វាងក្នុងជីវិតថ្មីមួយ ហើយនិងដែលបណ្តាលឲ្យសត្វលោកទាំងនោះបានទៅកើតឡើងវិញក្នុងភពព្រះពុទ្ធ។

នរជនណា ដែលយល់ច្បាស់សេចក្តីនេះ នឹងបានជាកូនចៅរបស់ព្រះពុទ្ធ។ គឺនរជនទាំងនោះ ប្រតិបត្តិតាមព្រះធម៌ គោរពធ្វើតាមសេចក្តីប្រៀនប្រដៅរបស់ព្រះអង្គ ហើយបញ្ជូនការប្រៀនប្រដៅទាំងនោះទៅឲ្យនរជនជំនាន់ក្រោយៗទៀត។ គ្មានអ្វីដែលអស្ចារ្យជាងឥទ្ធិពលព្រះពុទ្ធទេ។

3. ព្រះពុទ្ធមានអង្គកាយបី គឺៈ **ធម្មកាយ** ដែលជាទិដ្ឋភាពនៃសារធម៌របស់ព្រះអង្គ១ **សព្វង្គកាយ** ឬរូបកាយ ដែលជាទិដ្ឋភាពនៃចិត្តដ៏វិសេសរបស់ព្រះអង្គ១ និងនាមកាយដែលជាទិដ្ឋភាពនៃការសម្តែងចេញឲ្យឃើញឡើងរបស់ព្រះអង្គ១។

ធម្មកាយ គឺជាខ្លឹមសារនៃព្រះធម៌ គឺជាខ្លឹមសារនៃការពិតនោះតែម្តង។ ក្នុងភាពជាខ្លឹមនៃព្រះធម៌ ព្រះពុទ្ធគ្មានរូបរាង និងពណ៌សម្បុរទេ ហើយដោយព្រះអង្គគ្មានរូបរាង និងពណ៌សម្បុរនេះ ព្រះអង្គគ្មានចេញមកពីទីណា ហើយទៅទីឯណាទេ។ ដូចជាផ្ទៃមេឃដែលមានពណ៌ខៀវ ព្រះអង្គទ្រង់គ្របពាសលើគ្រប់វត្ថុធាតុទាំងអស់ ហើយដោយព្រះអង្គជាវត្ថុគ្រប់ទាំងអស់នោះ ព្រះអង្គគ្មានខ្វះអ្វីទាំងអស់។

ព្រះពុទ្ធមិនមានស្ថិតនៅដោយសារតែមនុស្សទាំងឡាយគិតថាមានព្រះពុទ្ធនោះទេ ហើយព្រះអង្គក៏មិនរលត់ទៅបាត់ដោយសារតែមនុស្សទាំងឡាយភ្លេចនឹកគិតដល់ព្រះអង្គក៏ទេដែរ។ ព្រះអង្គពុំបានទទួលការបង្ខំជាពិសេសណាមួយថា ត្រូវតែចេញស្តែងឡើង នៅពេលណាសត្វលោកមានសេចក្តីសុខស្ងប់នោះទេ ហើយព្រះអង្គក៏គ្មានការចាំបាច់ថា ត្រូវតែរលត់

បាត់ទៅនៅពេលណាសត្វលោកធ្វេសប្រហែស ព្រងើយកន្តើយនោះទេ។ ព្រះពុទ្ធគឺហួសវិស័យមនុស្សគិត។

ក្នុងទ្រង់ទ្រាយនេះ រូបកាយរបស់ព្រះពុទ្ធនៅពាសពេញគ្រប់ចន្លោះទីនៃសកលលោក ព្រះអង្គគង់នៅគ្រប់ទិសទីព្រះអង្គឋិតនៅជានិច្ច ទោះបីមនុស្សលោកជឿថាតាម ឬមានការសង្ស័យចំពោះអត្ថិភាពព្រះអង្គក៏ដោយ។

4. ***សព្វង្គកាយ*** គឺជាសភាពនៃព្រះពុទ្ធ ដែលជាការលាយចូលគ្នានៃសេចក្តីអាសូរ និងព្រហ្មចារិភាព ដែលជាវិញ្ញាណឥតរូបភាព ដែលបញ្ចេញឲ្យឃើញឡើងតាមនិមិត្តរូបនៃការកើត និងការស្លាប់ ហើយនិងតាមការធ្វើសច្ចាធិដ្ឋាន ការប្រតិបត្តិ និងការប្រកាសពិសិដ្ឋនាមព្រះអង្គ ដើម្បីដឹកនាំសត្វលោកទាំងអស់ទៅដាក់ដល់ស្ថានផុតទុក្ខ។

យ៉ាងដូច្នេះហើយ សេចក្តីមហាអាសូរជាខ្លឹមសារនៃរូបកាយព្រះអង្គ ហើយនៅក្នុងគោលគំនិតព្រះអង្គ ព្រះអង្គទ្រង់ប្រើប្រាស់វិធីគ្រប់បែបយ៉ាង ដើម្បីរំដោះជនទាំងឡាយណាដែលប្រុងប្រៀបខ្លួនទទួលការរំដោះនោះ។ ដូចជាក្មេងកាល

ណាឆេះហើយ វាមិនរលត់ទេ ដរាបណាប្រេងមិនទាន់អស់យ៉ាងណាមិញ សេចក្តីអាណិតរបស់ព្រះពុទ្ធមិនមានការរួញរាដានិច្ចដរាបណាតណ្ហាមនុស្សលោកមិនទាន់ចប់អស់។ ដូចជាខ្យល់ដែលបក់ផាត់ធូលី សេចក្តីអាសូររបស់ព្រះពុទ្ធ នៅក្នុងសភាពនេះ កំចាត់ធូលីនៃទុក្ខរបស់មនុស្សលោក។

នាមកាយ មានន័យថា ដើម្បីបំពេញការរំដោះទុក្ខដែលព្រះអង្គបានប្រទានតាមសព្វគ្គកាយនោះ ព្រះពុទ្ធទ្រង់បានបញ្ចេញឲ្យឃើញដោយរូបរាងពិតនៅក្នុងលោកនេះ ហើយពន្យល់បង្ហាញសត្វលោកអំពីទិដ្ឋភាពនៃការកើត ការលះបង់លោកិយ និងការបានសម្រេចការត្រាស់ដឹង សម្របទៅតាមសភាពនិងសមត្ថភាពនៃសត្វលោក។ ដើម្បីនឹងដឹកនាំសត្វលោកព្រះពុទ្ធនៅក្នុងសភាពអង្គកាយនេះ ព្រះអង្គទ្រង់ប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាង ដូចជាការឈឺនិងការស្លាប់ជាដើម។

ទ្រង់ទ្រាយព្រះពុទ្ធ ជាដើមដំបូង គឺធម្មកាយ តែមួយគត់។ តែដោយសភាពសត្វលោកផ្លាស់ប្តូរផ្សេងៗគ្នា រូបភាពរបស់ព្រះពុទ្ធក៏ចេញស្តែងឡើងក្នុងសភាពផ្សេងៗ គ្នាទៅតាមនោះ។ តែទោះបីជារូបភាពព្រះពុទ្ធផ្លាស់ប្តូរ ទៅតាម

ចំណង់ផ្សេងៗគ្នា អំពើផ្សេងៗគ្នា និងសមត្ថភាពផ្សេងៗគ្នានៃសត្វលោកក៏ដោយ ព្រះពុទ្ធបានសេចក្តីថាការពិតនៃព្រះធម៌តែមួយប៉ុណ្ណោះ។

ទោះបីព្រះពុទ្ធមានរូបកាយបីក៏ដោយ ព្រះអង្គទ្រង់មានគោលបំណងតែមួយគត់ គឺស្រោចស្រង់សត្វលោកទាំងអស់។

ទោះបីនៅគ្រប់កាលៈទេសៈ ព្រះពុទ្ធទ្រង់បញ្ចេញឲ្យឃើញក្នុងសភាពបរិសុទ្ធឥតខ្ចោះក៏ដោយ ការបញ្ចេញឲ្យឃើញនេះពុំមែនព្រះពុទ្ធទេ ពីព្រោះព្រះពុទ្ធពុំមែនជារូបរាងណាមួយទេ។ សភាពព្រះពុទ្ធបំពេញនៅគ្រប់វត្ថុទាំងអស់ព្រះអង្គបង្កើតអង្គកាយរបស់ព្រះអង្គផ្ទាល់ ពីការត្រាស់ដឹង ហើយក្នុងភាពជាការបានដល់នូវការត្រាស់ដឹងនេះ ព្រះអង្គទ្រង់បានបញ្ចេញឲ្យឃើញចំពោះគ្រប់ជនណា ដែលអាចយល់នូវសេចក្តីពិត។

II

ការបញ្ចេញឲ្យឃើញនៃព្រះពុទ្ធ

1. គឺជាការកម្របំផុតដែលបានព្រះពុទ្ធមួយអង្គមកចាប់កំណើត

ក្នុងលោកនេះ។ កាលបើព្រះពុទ្ធកើតឡើងហើយ ព្រះអង្គបាន សម្រេចការត្រាស់ដឹង ព្រះអង្គបង្កើតព្រះធម៌ ព្រះអង្គជម្រះ សំណាញ់នៃសេចក្តីមន្ទិលសង្ស័យ ព្រះអង្គទ្រង់កម្ចាត់តណ្ហា ទាំងឡាយព្រមទាំងឫស ព្រះអង្គខ្ទប់ផ្លូវបង្វែរនៃទុក្ខ។ ព្រះអង្គ និមន្តសុសសព្វទិសទីក្នុងលោកនេះ តាមតែបំណងព្រះអង្គដោយ ពុំមានឧបសគ្គណាមួយអាចឃាត់ឃាំងព្រះអង្គបានឡើយ។ គ្មាន អ្វីដែលធំជាងការគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះពុទ្ធទេ។

ព្រះពុទ្ធចេញឲ្យឃើញ ក្នុងពិភពដែលពោរពេញទៅ ដោយទុក្ខវេទនា ព្រោះព្រះអង្គមិនអាចបោះបង់ចោលនូវសត្វ លោកដែលមានទុក្ខនោះបានទេ។ គោលបំណងតែមួយគត់ របស់ព្រះអង្គគឺ ការផ្សាយព្រះធម៌ និងការធ្វើឲ្យសត្វលោកបាន ប្រកបសុភមង្គលដោយសារសេចក្តីពិតនៃព្រះធម៌នោះ។

ការពន្យល់បង្ហាញព្រះធម៌នៅក្នុងពិភពដែលពោរពេញ ទៅដោយអយុត្តិធម៌និងគុណវិបត្តិ ក្នុងពិភពដែលពុះពារ តស៊ូ ដោយឥតប្រយោជន៍ជាមួយនឹងតណ្ហាមិនចេះឆ្អែតឆ្អន់ និង ទុក្ខវេទនាដែលបណ្តាលមកពីតណ្ហានោះ ជាការពិបាកណាស់។ ព្រះពុទ្ធប្រឈមមុខតទល់នឹងឧបសគ្គទាំងនេះ ពីព្រោះតែ

ព្រះអង្គមានសេចក្ដីស្រឡាញ់ និងអាសូរដ៏ធំធេង។

2. ព្រះពុទ្ធជាមិត្តដ៏ល្អចំពោះគ្រប់ជនទាំងអស់ក្នុងលោកនេះ បើព្រះអង្គជួបនឹងបុគ្គលណាមានទុក្ខធ្ងន់ ដោយសារតណ្ហាលោកិយ ព្រះអង្គទ្រង់មានសេចក្ដីអាសូរ ហើយរំលែកនូវបន្ទុកដ៏ធ្ងន់នោះ។ បើព្រះអង្គជួបនឹងបុគ្គលណាមានទុក្ខវេទនាដោយសារការយល់ច្រឡំ ព្រះអង្គទ្រង់កម្ចាត់ការយល់ច្រឡំនោះដោយពន្លឺដ៏វិសុទ្ធនៃព្រហ្មចារិភាពរបស់ព្រះអង្គ។

ដូចជាកូនគោ ដែលសប្បាយរីករាយនឹងរស់នៅជាមួយមេវា បុគ្គលទាំងឡាយណាដែលបានស្ដាប់ការប្រៀនប្រដៅរបស់ព្រះពុទ្ធ មិនចង់ចាកចេញពីព្រះអង្គទេ ពីព្រោះការប្រៀនប្រដៅទាំងនោះ ផ្ដល់នូវសុភមង្គលដល់បុគ្គលទាំងឡាយនោះ។

3. កាលណាព្រះចន្ទលិចទៅ អ្នកផងតែងថាព្រះចន្ទលិចបាត់ទៅហើយ ហើយកាលណាព្រះចន្ទរះឡើង អ្នកផងតែងថាព្រះចន្ទរះឡើងហើយ។ តែតាមពិត ព្រះចន្ទគ្មានមកពីណា

ឬបាត់ទៅណាទេ ព្រះចន្ទបែងចាំងដោយគ្មានការផ្លាស់ប្តូរ នៅលើផ្ទៃមេឃ។ ព្រះពុទ្ធក៏ដូចជាព្រះចន្ទនោះយ៉ាងពិតប្រាកដ ព្រះអង្គគ្មានចេញឡើង ឬបាត់ទៅណាទេ។ ព្រះអង្គធ្វើដូចជាកើតឡើងហើយ រលត់បាត់ទៅយ៉ាងនេះ ដោយសារតែព្រះអង្គស្រឡាញ់សត្វលោក ហើយដើម្បីនឹងអាចប្រៀនប្រដៅសត្វលោកទាំងនោះ។

បុគ្គលទាំងឡាយតែងហៅព្រះចន្ទពេញវង់ថា ជាកាលសម័យមួយ ហើយព្រះចន្ទមួយចំណិតថា ជាកាលសម័យមួយផ្សេងទៀត តែតាមការពិត ព្រះចន្ទមានភាពមូលឥតខ្ចោះជានិច្ច ហើយគ្មាន ខ្នើតឬរនោចទេ។ ព្រះពុទ្ធក៏ពិតដូចជាព្រះចន្ទនោះដែរ។ នៅចំពោះភ្នែកមនុស្សលោក ព្រះពុទ្ធហាក់ដូចជាផ្លាស់ប្តូរភាព តែតាមការពិតព្រះពុទ្ធឥតផ្លាស់ប្តូរទេ។

ព្រះចន្ទចេញឡើងនៅគ្រប់ទិសទី នៅលើក្រុងដែលមានមនុស្សកុះករ នៅលើស្រុកភូមិស្ងាត់ជ្រងំ នៅលើព្រៃភ្នំ នៅលើទន្លេស្ទឹង។ ព្រះចន្ទអាចមើលឃើញនៅក្នុងជម្រៅនៃបាតបឹង នៅក្នុងក្អមទឹក នៅក្នុងដំណក់ទឹកសន្សើម ដែលដក់ជាប់នៅនឹងស្លឹកឈើ។ បើទុកជាអ្នកណាម្នាក់ដើរអស់ប៉ុន្មានរយយោជន៍

ក៏ដោយ ក៏ព្រះចន្ទដើរតាមអ្នកនោះដែរ។ ចំពោះមនុស្សលោក ព្រះចន្ទហាក់ដូចជាផ្លាស់ប្ដូរ តែព្រះចន្ទមិនផ្លាស់ប្ដូរទេ។ ព្រះពុទ្ធក៏ដូចជាព្រះចន្ទដែរ ព្រះអង្គត្រាច់តាមមនុស្សលោកនេះគ្រប់កាលៈទេសៈ ដែលប្ដូរផ្លាស់ព្រះអង្គសម្ដែងឲ្យឃើញឡើងក្នុងភាពផ្សេងៗគ្នា តែក្នុងខ្លឹមសារព្រះអង្គៗមិនផ្លាស់ប្ដូរទេ។

4. ការណ៍ដែលព្រះពុទ្ធសម្ដែងឲ្យឃើញឡើង ឬរលត់បាត់ទៅនោះ អាចពន្យល់បានតាមការទាក់ទងហេតុ និងផល កាលណាហេតុ និងល័ក្ខខ័ណ្ឌនោះសមប្រកប ព្រះពុទ្ធក៏ចេញស្ដែងឲ្យឃើញឡើង តែបើសិនជាហេតុនិងល័ក្ខខ័ណ្ឌនោះ មិនសមប្រកបទេ ព្រះពុទ្ធហាក់ដូចជារលត់បាត់ពីលោកនេះទៅ។

ទោះជាព្រះពុទ្ធស្ដែងចេញឡើងក្ដី ឬរលត់បាត់ទៅក្ដី ភាពពិតរបស់ព្រះពុទ្ធនៅដដែលជានិច្ច។ ដោយយល់នូវគោលការណ៍នេះ បុគ្គលម្នាក់ៗត្រូវតែប្រកាន់យកនូវផ្លូវនៃការត្រាស់ដឹង ហើយបានសម្រេចគតិបណ្ឌិតពេញលេញឥតខ្ចោះ មិនមានសេចក្ដីរីករវតេក់ស្លុត នឹងការផ្លាស់ប្ដូរខាងក្រៅ

នៃទម្រង់ព្រះពុទ្ធ ដែលនិម្មិតឡើងទៅតាមល័ក្ខខ័ណ្ឌនៃលោក នេះ និងទៅតាមដំណើរប្រែប្រួលនៃគតិអារម្មណ៍មនុស្សលោក។

មានសេចក្ដីតំណាលពន្យល់ថា ព្រះពុទ្ធពុំមែនជាអង្គរូបវ័ន្តទេ តែគឺជាពន្លឺថែងចាំង ឬការត្រាស់ដឹងនោះឯង។ គេអាចនឹកប្រៀបប្រដូចនូវអង្គមួយទៅនឹងចានប្រជុំពន្លឺ ឬគម្រប់ចង្កៀង។ កាលណាចានប្រជុំពន្លឺនោះ ពេញទៅដោយពន្លឺ ហើយគេអាចហៅចាននោះថា ជាព្រះពុទ្ធបាន។ ហេតុនេះហើយ បើបុគ្គលណាម្នាក់គិតតែពីអង្គរូបវ័ន្តព្រះពុទ្ធ ហើយយំសោក នឹងការបាត់បង់ព្រះពុទ្ធនោះ បុគ្គលនោះនឹងមិនអាច មើលឃើញព្រះពុទ្ធពិតប្រាកដទេ។

ដោយពិត ភាពពិតនៃវត្ថុទាំងអស់ វាហួសពីការដែលមនុស្សលោកបានគិតយល់ និងវែកញែកអំពីការកើតឡើង ហើយបាត់ទៅវិញ អំពីការទៅហើយមក អំពីការល្អ និងអាក្រក់។ វត្ថុទាំងអស់ដូចគ្នាបេះបិទ គឺគ្មានសារជាតិទេ។

ការគិតយល់ និងវែកញែករបស់មនុស្សលោកចំពោះវត្ថុទាំងអស់នោះ គឺដោយសារតែការវិនិច្ឆ័យដោយភាន់ច្រឡំនៃជនទាំងឡាយ ដែលបានឃើញបាតុភូតទាំងនោះតែប៉ុណ្ណោះ

ឯង។ ទ្រង់ទ្រាយពិតរបស់ព្រះពុទ្ធមិនកើតឡើង ឬរលត់ទៅបាត់ទេ។

III

គុណធម៌របស់ព្រះពុទ្ធ

1. ព្រះពុទ្ធទ្រង់បានទទួលការគោរពអំពីសកលលោកដោយសារគុណធម៌របស់ព្រះអង្គទាំងប្រាំគឺៈ ចរិយាប្រសើរបំផុត ទស្សនៈខ្ពង់ខ្ពស់បំផុត ព្រហ្មចារិភាពឥតខ្ចោះ សមត្ថភាពពេញលេញក្នុងការប្រៀនប្រដៅ និងឥទ្ធិពលក្នុងការដឹកនាំសត្វលោកឲ្យប្រតិបត្តិតាមការប្រៀនប្រដៅរបស់ព្រះអង្គ។

ជាពិសេសទៅទៀត ព្រះពុទ្ធមានគុណធម៌ប្រាំបីផ្សេងទៀត ដែលញ៉ាំងឲ្យព្រះអង្គអាចផ្តល់នូវគុណប្រយោជន៍ និងសុភមង្គលដល់សត្វលោកបានគឺៈ នាំអត្ថប្រយោជន៍ភ្លាមៗមកឲ្យលោកនេះ ដោយសារការប្រតិបត្តិតាមសេចក្តីប្រៀនប្រដៅរបស់ព្រះអង្គ១ វិនិច្ឆ័យយ៉ាងត្រឹមត្រូវអំពីល្អ និងអាក្រក់ អំពីត្រូវនិងខុស១ ដឹកនាំសត្វលោកទៅកាន់ការត្រាស់ដឹង ដោយប្រៀនប្រដៅសត្វលោកទាំងនោះនូវផ្លូវត្រូវ១ ដឹកនាំសត្វលោក

តាមដោយមធ្យោបាយត្រឹមត្រូវ សមរម្យ១ ចៀសវាងអតិ-មានះនិងអំនួត១ ធ្វើអ្វីដែលព្រះអង្គបាននិយាយ១ និយាយអ្វីដែលព្រះអង្គបានធ្វើ១ ហើយដោយបានធ្វើដូច្នេះ ព្រះអង្គបានបំពេញបំណងនៃព្រះទ័យព្រះអង្គ ដែលពោរពេញទៅដោយសេចក្ដីអាសូរ១។

ព្រះពុទ្ធទ្រង់ចម្រើនភាវនា រក្សាចិត្តស្ងប់ស្ងួត ចិត្តដែលជះចេញឡើងជារស្មីនៃសេចក្ដីស្រឡាញ់ សេចក្ដីអាសូរសេចក្ដីសប្បាយចិត្តដែលមានភាពនឹងនរ។ ព្រះអង្គទ្រង់ទុកដាក់សត្វលោកទាំងអស់ក្នុងភាពស្មើគ្នា ព្រះអង្គជម្រះគ្រប់មន្ទិលហ្មងសៅអំពីសតិអារម្មណ៍សត្វលោកទាំងនោះ ហើយនាំមកផ្ដល់ឲ្យសត្វលោកទាំងនោះនូវសុភមង្គល ដែលកើតអំពីឯកភាពព្រលឹងបរិសុទ្ធឥតខ្ចោះ។

2. ព្រះពុទ្ធជាបិតាផង ជាមាតាផង សម្រាប់ជនទាំងឡាយនៃលោកនេះ។ ក្នុងរយៈពេលជប់ប្រាំមួយខែចាប់ពីពេល ដែលកូនក្មេងម្នាក់កើតឡើងមក មាតាបិតាត្រូវតែនិយាយភាសាកូនក្មេងជាមួយនឹងវា ហើយជាលំដាប់បន្តបន្ទាប់មកមាតាបិតា

បង្រៀនក្មេងនោះឲ្យនិយាយដូចមនុស្សចាស់។

ព្រះពុទ្ធ ក៏ដូចជាមាតាបិតាទាំងឡាយក្នុងលោក យើងនេះដែរ។ មុនដំបូងព្រះអង្គថែទាំសត្វលោក រួចហើយ ព្រះអង្គទុកសត្វលោកទាំងនោះឲ្យថែទាំខ្លួនដោយខ្លួនឯង។ មុនដំបូងព្រះអង្គផ្ដល់វត្ថុដែលសត្វលោកមានបំណងចង់បាន ជាបន្ទាប់មកព្រះអង្គដឹកនាំសត្វលោកទាំងនោះទៅកាន់ទីជម្រកមួយ ដែលប្រាកដហើយប្រកបដោយសេចក្ដីសុខ។

អ្វីដែលព្រះពុទ្ធបង្រៀនតាមភាសារបស់ព្រះអង្គ សត្វ-លោកទាំងឡាយទទួលយកសេចក្ដីប្រៀនប្រដៅនោះ ទៅបញ្ចូលឲ្យជ្រួតជ្រាបនៅក្នុងភាសារបស់ខ្លួនផ្ទាល់ ហាក់ដូចជាសេចក្ដីប្រៀនប្រដៅនោះទុកសម្រាប់តែខ្លួនឯងម្នាក់។

សភាពវិញ្ញាណរបស់ព្រះពុទ្ធ ផុតហួសពីមនុស្សលោកស្មានគិត។ សតិវិញ្ញាណព្រះពុទ្ធនេះ មិនអាចនឹងយល់បានដោយសារពាក្យសម្ដីទេ គេគ្រាន់តែអាចឲ្យជាយោបល់បានទៅតាមឧបមាកថាតែប៉ុណ្ណោះ ចំពោះសតិវិញ្ញាណព្រះពុទ្ធនេះ។

ទឹកស្ទឹងឡើងរំជួយដោយសារតែហ្វូងសេះ និងហ្វូងដំរីរត់ឆ្លងកាត់ ហើយឡើងល្អក់ដោយសារតែហ្វូងត្រីនិងអណ្តើក

ហែបហែលក្នុងស្ទឹងនោះ។ តែទឹកស្ទឹងហូរយ៉ាងបរិសុទ្ធដោយមិនរីករវនឹងអប្បគ្ឃវត្ថុពាយរងទាំងនេះទេ។ ព្រះពុទ្ធក៏ដូចជាស្ទឹងធំនេះដែរ។ ហ្វូងត្រី និងអណ្តើកនៃសិក្ខាបទផ្សេងៗ ៦ ទៀត ហែលនៅក្នុងជម្រៅគង្គាបញ្ជាក់នឹងខ្សែទឹកតែជាការឥតប្រយោជន៍។ ធម៌ព្រះពុទ្ធហូរយ៉ាងបរិសុទ្ធដោយមិនមានការរីករវទេ។

3. ព្រហ្មចារិភាពឥតខ្ចោះរបស់ព្រះពុទ្ធ ចៀសវាងការវិនិច្ឆ័យទុកមុន ដែលធ្វើឡើងដោយហួសប្រមាណហើយរក្សាទុកនូវការទប់ឲ្យនៅជាកណ្តាល ដែលជាការមួយពុំអាចពិពណ៌នាបានតាមពាក្យសម្តី។ ដោយព្រះអង្គដឹងគ្រប់ ព្រះពុទ្ធយល់ចិត្តគំនិតមនុស្សលោកទាំងអស់ ហើយយល់ភ្លាមមួយរំពេចនូវគ្រប់វត្ថុទាំងអស់។

ដូចជាហ្វូងតារានៅលើមេឃា ដែលចាំងឆ្លុះទៅក្នុងសមុទ្រដ៏ស្ងប់ គំនិតនិងមនោសញ្ចេតនានៃសត្វលោក ព្រមទាំងទេសកាលទាំងអស់ ក៏ឆ្លុះទៅក្នុងជម្រៅនៃព្រហ្មចារិភាពរបស់ព្រះពុទ្ធយ៉ាងនោះដែរ។ ដូច្នេះហើយបានជាព្រះពុទ្ធ ទ្រង់

មានព្រះនាមថា «បុគ្គលមានពន្លឺបរិបូណ៌ឥតខ្ចោះ» គឺថា «បុគ្គលដឹងគ្រប់»។

ព្រហ្មចារិភាពរបស់ព្រះពុទ្ធ ធ្វើឲ្យវិញ្ញាណសោះកក្រោះនៃសត្វលោកបានល្អឡើងវិញ បំភ្លឺសត្វលោកទាំងនោះ ពន្យល់បង្ហាញសត្វលោកទាំងនោះអំពីន័យនៃលោកនេះ អំពីហេតុនិងផល អំពីការកើតឡើង និងការវិនាសបាត់ទៅវិញ។ សម្រេចទៅ ប្រសិនបើគ្មានព្រហ្មចារិភាពរបស់ព្រះពុទ្ធទេ តើទិដ្ឋភាពនៃលោកនេះ ដែលសត្វលោកអាចយល់បាននោះ វារបៀបណាដែរ ? ។

4. ព្រះពុទ្ធពុំស្តែងចេញជាព្រះពុទ្ធជានិច្ចទេ។ ជួនកាលព្រះអង្គចេញស្តែងឡើងជារូបបិសាច ជួនកាលជាស្ត្រី ជួនកាលជាអាទិទេព ជួនកាលជាមហាក្សត្រ ឬរដ្ឋបុរស ជួនកាលព្រះអង្គចេញស្តែងឡើងនៅក្នុងផ្ទះឧបទ្រព ឬក្នុងរោងល្បែង។

ក្នុងពេលមានជំងឺឆ្លងរាតត្បាត ព្រះអង្គចេញស្តែងជាពេទ្យហ្ម ហើយនៅក្នុងសង្គ្រាម ព្រះអង្គបង្រៀនឲ្យមានសេចក្តីអត់

ផ្ចត់ និងឲ្យមានសេចក្ដីអាណិតចំពោះអ្នកដែលឈឺចាប់។ ព្រះអង្គទូន្មានអំពីការមិនឋិតថេរ និងការមិនទៀងដល់ជនដែលគិតថា វត្ថុទាំងឡាយឋិតថេររហូត។ ព្រះអង្គទូន្មានអំពីការលះបង្អាបខ្លួន និងការលះផ្ញើពលិកម្ម ចំពោះជនដែលក្រអឺតក្រអោង និងមានអត្តទត្ដភាព។ ព្រះអង្គបង្ហាញឲ្យឃើញនូវទុក្ខវេទនានៃលោកនេះ ចំពោះជនណាដែលជាប់ក្នុងសំណាញ់នៃតណ្ហាលោកិយ។

កិច្ចការចាំបាច់របស់ព្រះពុទ្ធ គឺបញ្ចេញខ្លឹមសារដ៏បរិសុទ្ធនៃធម្មកាយ ឬសភាពដាច់ខាតរបស់ព្រះអង្គ នៅក្នុងគ្រប់ករណីនិងកាលៈទេសៈ។ ដូច្នេះហើយ សេចក្ដីស្រឡាញ់ និងសេចក្ដីអាសូររបស់ព្រះពុទ្ធ សាយចេញអំពីធម្មកាយនោះទៅជាជីវិតមួយ ដែលគ្មានទីអវសាន និងជាពន្លឺមួយដែលគ្មានព្រំដែន ហើយរំដោះសត្វលោកឲ្យផុតអំពីទុក។

5. លោកនេះដូចជាផ្ទះមួយកំពុងត្រូវភ្លើងឆេះ វិនាសខ្ទេចខ្ទីហើយសាងឡើងវិញ កសាងឡើងវិញហើយវិនាសអស់ទៅវិញ គ្មានលះឈប់ឈរ។ សត្វលោកដោយវិលវល់ក្នុងសេចក្ដី

លិ្ងតល្វង់ ត្រូវឡប់សតិទៅក្នុងកំហឹង ក្នុងការមិនបេះពេញចិត្ត ក្នុងសេចក្ដីច្រណែននិន្ទា ក្នុងសេចក្ដីប្រមាថ និងក្នុងតណ្ហាលោកិយ។ សត្វលោក បីដូចជាកូនក្មេងដែលត្រូវការមាតាជាចាំបាច់ បុគ្គលនីមួយៗត្រូវតែពឹងផ្អែកនឹងសេចក្ដីស្នេហារបស់ព្រះពុទ្ធ។

ព្រះពុទ្ធជាបិតា ចំពោះគ្រប់បុគ្គលក្នុងលោកនេះ។ មនុស្សទាំងអស់ជាកូនចៅរបស់ព្រះពុទ្ធ។ ព្រះពុទ្ធបរិសុទ្ធជាងសន្តបុគ្គលទាំងអស់។ លោកយើងនេះ កំពុងឆេះដោយភ្លើងជរាទុព្វលភាពនិងភ្លើងមរណៈ។ នៅទីណាក៏មានទុក្ខ តែសត្វលោកដែលខំស្វះស្វែងដោយឥតប្រយោជន៍នូវតណ្ហាលោកិយ មិនមានសតិគ្រប់គ្រាន់ដើម្បីបានយល់រឿងនេះទេ ។

ព្រះពុទ្ធបានយល់ឃើញថា ប្រាសាទវិមានដែលពោរពេញទៅដោយការសប្បាយ បើតាមពិតគឺជាផ្ទះដែលកំពុងត្រូវភ្លើងឆេះ។ ហេតុនេះហើយបានជាព្រះអង្គគេចចេញពីទីនោះ ហើយរកឃើញទីជម្រកប្រកបដោយសុខសន្តិភាព នៅក្នុងព្រៃស្ងាត់។ នៅទីស្ងប់ស្ងាត់ដាច់ស្រយាលនោះ ព្រះអង្គទ្រង់បានដល់នូវហឫទ័យមហាអាសូរ ហើយព្រះអង្គទ្រង់មាន

ពុទ្ធដីកាថាៈ «លោកិយដែលប្រែប្រួលនិងពោរពេញទៅដោយទុក្ខវេទនានេះ ជារបស់ផងតថាគត។ អ្នកល្ងង់ខ្លៅអ្នកឆ្កួតវង្វេងទាំងនោះ ជាកូនចៅផងតថាគត។ មានតែតថាគតតែម្នាក់គត់ ដែលអាចស្រោចស្រង់អ្នកទាំងនោះឲ្យរួចផុតពីការយល់ច្រឡំ និងទុក្ខវេទនា»។

ដោយព្រះពុទ្ធជាមហាអធិបតីនៃធម៌ ព្រះអង្គអាចទេសនាប្រៀនប្រដៅសត្វលោកទាំងអស់បានដូចព្រះអង្គប្រាថ្នា។ ដូច្នេះហើយ ព្រះពុទ្ធដែលសម្តែងឲ្យឃើញឡើងនៅក្នុងលោកនេះ គឺដើម្បីធ្វើឲ្យសត្វលោកបានប្រកបនូវសុភមង្គល ដើម្បីស្រោចស្រង់សត្វលោកទាំងនោះឲ្យរួចផុតពីទុក្ខវេទនា ព្រះអង្គទ្រង់បង្រៀនព្រះធម៌ តែដោយត្រចៀកសត្វលោកវាទន់ទៅតាមសេចក្តីលោភលន់ សត្វលោកទាំងនោះក៏មិនបានប្រុងស្មារតី។

តែអ្នកដែលស្តាប់ការទូន្មានរបស់ព្រះអង្គ អាចចាកផុតពីការយល់ច្រឡំទាំងនោះ ហើយរួចផុតពីទុក្ខវេទនានៃជីវិតនេះ។ ព្រះអង្គមានពុទ្ធដីកាថាៈ «សត្វលោកទាំងឡាយមិនអាចសង្គ្រោះអាត្មាឯង ដោយសំអាងលើតែសតិបញ្ញារបស់

ខ្លួនផ្ទាល់នោះបានទេ គឺទាល់តែមានសទ្ធាជ្រះថ្លាចំពោះការប្រៀនប្រដៅរបស់តថាគតផង ទើបបានសម្រេច»។ ហេតុនេះ យើងត្រូវតែស្តាប់ការទូន្មានរបស់ព្រះពុទ្ធ និងប្រតិបត្តិតាមការទូន្មាននោះ៕

ព្រះធម៌

ចំពូកទី ១

ការដាក់ឧបហេតុនិងផល

I

សេចក្តីពិតថ្លៃថ្នូរបួនប្រការ

1. *លោកនេះ ពោរពេញទៅដោយទុក្ខវេទនា។ កើតមកក៏ទុក្ខ ជរាក៏ទុក្ខ ឈឺក៏ទុក្ខ ស្លាប់ក៏ទុក្ខ។ ជួបនឹងមនុស្សជាទីសម្អប់ក៏ទុក្ខ បែកពីអ្នកជាទីស្រឡាញ់ក៏ទុក្ខ មិនអាចបំពេញបំណងក៏ទុក្ខ។ ដោយសរុបទៅ ជីវិតដែលជាប់ក្នុងចំណង់តណ្ហានេះជាទុក្ខ។ នេះហើយដែលហៅថា សេចក្តីពិតបំផុតអំពីទុក្ខវេទនា។*

ហេតុនៃទុក្ខទាំងឡាយរបស់មនុស្សលោក គឺពិតជាមកអំពីតណ្ហាទាំងឡាយ ដែលញាំញីបេះដូងមនុស្សលោក។ បើគេរាវរកឲ្យដល់ឫសគល់នៃតណ្ហាទាំងនេះ គេនឹងឃើញថាតណ្ហាទាំងនេះ វាមានឫសនៅក្នុងចំណង់យ៉ាងងប់ងល់ ដែលបុគ្គលរាល់រូបមានតាំងពីកំណើតមក។ ចំណង់ងប់ងុលទាំងនេះ

ក្នុងបំណងយ៉ាងមាំថា ត្រូវតែរស់ជាមូលហេតុ ក៏ខំប្រឹងឈោង ចាប់យកអ្វីៗទាំងអស់ដែលឃើញ និងអ្វីៗទាំងអស់ដែលឮ ជួន កាលសូម្បីសេចក្ដីមរណៈ ក៏ចំណង់ទាំងនោះឈោងចាប់យក ដែរ។ នេះហើយគឺសេចក្ដីពិតបំផុតអំពីឫសគល់នៃទុក្ខវេទនា។

បើបុគ្គលណាអាចដកឫសតណ្ហាចេញឲ្យអស់បាន ហើយ បំផ្លាញចោលនូវចំណង់តណ្ហាទាំងអស់បាន បុគ្គលនោះនឹង បានផុតទុក្ខវេទនា។ នេះហើយគឺជាសេចក្ដីពិតបំផុត អំពីការ បំបាត់ចោលលែងមានទុក្ខវេទនា។

ដើម្បីនឹងបានដល់នូវភាពគ្មានចំណង់ និងគ្មានទុក្ខ ត្រូវ តែដើរតាមផ្លូវដែលមានប្រាំបីសង្កាត់ ពោលគឺៈ ឃើញត្រូវ១ គិតត្រូវ១ ស្រដីត្រូវ១ ប្រព្រឹត្តត្រូវ១ រស់នៅត្រឹមត្រូវ១ ប្រឹង ប្រែងត្រូវ១ ប្រុងប្រយ័ត្នត្រូវ១ និងសង្រួមចិត្តត្រូវ១។ នេះ ហើយគឺជាសេចក្ដីពិតបំផុត អំពីផ្លូវទៅកាន់ការវៀរចាកទុក្ខ វេទនា។

ត្រូវតែចាំទុកឲ្យច្បាស់ក្នុងចិត្តអំពីសេចក្ដីពិតថ្លៃថ្នូរទាំង នេះ ពីព្រោះលោកនេះពោរពេញទៅដោយទុក្ខវេទនា ហើយបើបុគ្គលណាចង់ឲ្យរួចផុតអំពីទុក្ខវេទនា បុគ្គលនោះ

តោងតែផ្ដាច់ចំណងតណ្ហាលោកិយ។ គឺមានតែការបានត្រាស់ដឹងតែមួយគត់ ដែលអាចឲ្យបុគ្គលបានដល់ភាពរួចផុតពីតណ្ហា និងទុក្ខវេទនា។ រីឯនឹងបានទៅដល់ការបានត្រាស់ដឹង មានតែដើរតាមផ្លូវប្រាំបីថ្នាក់ ឬវិន័យប្រាំបីដ៏ប្រសើរនេះទេ ទើបអាចទៅដល់។

2. អ្នកដែលស្វែងរកការត្រាស់ដឹង ត្រូវតែយល់សេចក្ដីពិតថ្លៃថ្នូរទាំងបួននេះ។ បើមិនយល់សេចក្ដីពិតទាំងនេះទេ មុខតែវង្វេងវិលវល់មិនចេះចប់នៅក្នុងបណ្ដាញយ៉ាងចាក់ស្រែះ នៃការភាន់ច្រឡំនៃលោកនេះជាប្រាកដ។ បុគ្គលណាយល់សេចក្ដីពិតថ្លៃថ្នូរទាំងបួននេះ ឈ្មោះថាបុគ្គលនោះបានចក្ខុសម្ពោធិ-ញ្ញាណ។

ដូច្នេះ ត្រូវតែទទួលយកការប្រៀនប្រដៅរបស់ព្រះពុទ្ធដោយចិត្តស្មោះស្ម័គ្រ ហើយយល់ឲ្យច្បាស់អំពីន័យនៃសេចក្ដីពិតថ្លៃថ្នូរទាំងបួននេះ។ ក្នុងកាលសម័យណាក៏ដោយ សន្ត-បុគ្គលណាចង់បានទៅជាសន្តបុគ្គលពិតប្រាកដ ឬអ្នកដែលគួរដល់នូវការបូជាមែនទែន សន្តបុគ្គលនោះត្រូវតែយល់ឲ្យ

ច្បាស់អំពីសេចក្ដីពិតថ្លៃថ្នូរទាំងបួននេះ ហើយពន្យល់ប្រាប់ទៅអ្នកឯទៀតៗ ជាបន្ដបន្ទាប់។

បើគេយល់សេចក្ដីពិតថ្លៃថ្នូរទាំងបួននេះច្បាស់ហើយ គេអាចចាកផុតពីតណ្ហាទាំងឡាយ។ ហើយបើគេបានចាកផុតពីតណ្ហាហើយ គេមិនឈ្លោះប្រកែក គេមិនសម្លាប់ គេមិនលួចប្លន់ គេមិនប្រព្រឹត្ដអំពើផិតក្បត់ គេមិនភូតភរឆបោក គេមិននិយាយដើមអ្នកឯទៀត គេមិនអួតខ្លួន គេមិនលោភលន់ គេមិនខឹងច្រឡោត គេមិនភ្លេចឡើយអំពីជីវិតមិនទៀង និងមិនឋិតថេរ ហើយគេមិនឃ្លាតចាកពីផ្លូវសុចរិតឡើយ។

3. ដើរតាមផ្លូវប្រសើរថ្លៃថ្នូរ ដូចជាគេកាន់ប្រទីបដើរចូលទៅក្នុងបន្ទប់ងងឹតមួយ។ ភាពងងឹតក៏បាត់ទៅ ហើយពន្លឺនៃប្រទីបក៏បំភ្លឺបន្ទប់នោះឡើង។

បុគ្គលណាយល់ន័យនៃសេចក្ដីពិតថ្លៃថ្នូរទាំងនេះ ហើយដើរតាមផ្លូវប្រសើរថ្លៃថ្នូរនេះ ឈ្មោះថាបុគ្គលនោះមានពន្លឺគតិបណ្ឌិតដែលបណ្ដេញអន្ធភាពងងឹតស្លុងនៃសេចក្ដីល្ងង់ខ្លៅ។

ព្រះពុទ្ធដឹកនាំសត្វលោក ដោយពន្យល់បង្ហាញតែអំពី

សេចក្តីពិតថ្លៃថ្នូរទាំងបួននេះ។ បុគ្គលទាំងឡាយណាយល់ច្បាស់ប្រាកដអំពីសេចក្តីពិតទាំងនេះ នឹងបានសម្រេចការត្រាស់ដឹង។ គឺសេចក្តីពិតថ្លៃថ្នូរទាំងបួននេះហើយ ដែលអាចជួយជ្រោមជ្រែងដឹកនាំបុគ្គលទាំងឡាយក្នុងលោក ដែលប្រកបទៅដោយការវង្វេងវិលវល់នេះបាន។ សេចក្តីពិតថ្លៃថ្នូរទាំងបួននេះសមរម្យណាស់គួរតែជឿតាម។ កាលណាសេចក្តីពិតថ្លៃថ្នូរទាំងបួននេះត្រូវបានយល់ប្រាកដហើយ ប្រកពតណ្ហាទាំងអស់ នឹងវិនាសអស់ជាពុំខាន។

ដោយសារសេចក្តីពិតថ្លៃថ្នូរទាំងបួននេះ ជាគោលមូលដ្ឋាន សាវ័កទាំងឡាយរបស់ព្រះពុទ្ធជាម្ចាស់ អាចយល់គ្រប់ការប្រៀនប្រដៅ និងសេចក្តីពិតផ្សេងៗទៀត ហើយបានដល់នូវគតិបណ្ឌិត ដែលបណ្តាលឲ្យគេអាចដកស្រង់យកបាននូវន័យដ៏ជ្រៅនៃគ្រប់វត្ថុជាតុ ហើយអាចនឹងពន្យល់ប្រៀនប្រដៅគ្រប់សត្វក្នុងលោកនេះជាបន្តទៅទៀតបានដោយសេរី។

II

ការទាក់ទងរវាងហេតុ និងផល

1. ចំពោះទុក្ខនីមួយៗ សុទ្ធតែមានហេតុ ហើយក៏មានមធ្យោបាយមួយដើម្បីនឹងរំលត់ទុក្ខនោះបានដែរ។ ព្រោះហេតុអ្វី? ពីព្រោះនៅក្នុងលោកនេះ អ្វីៗទាំងអស់សុទ្ធតែជាលទ្ធផលនៃការប្រកួតប្រជែងដ៏ធំធេងរវាងហេតុនិងល័ក្ខខ័ណ្ឌ។ អ្វីៗទាំងនោះនឹងវិនាសបាត់ទៅវិញ បើកាលណាហេតុ និងល័ក្ខខ័ណ្ឌនោះផ្លាស់ប្ដូរហើយបាត់ទៅវិញ។

ភ្លៀងធ្លាក់ ខ្យល់បក់ ផ្កាឈើរីកឡើង ស្លឹកឈើជ្រុះ ក៏សុទ្ធតែមានហេតុ ពោលគឺ កើតឡើងហើយស្លាប់ទៅវិញ។

ទារកកើតឡើងតាមល័ក្ខខ័ណ្ឌរបស់មាតាបិតា វាបានធំធាត់ឡើងដោយសារចំណីអាហារ ហើយសតិប្រាជ្ញាវាលូតលាស់ឡើងដោយសារចំណេះវិជ្ជា និងការពិសោធន៍។

រូបកាយ និងសតិប្រាជ្ញាទាំងពីរនេះ ទៅតាមហេតុ ហើយវិវដ្តប្រួលប្រែដោយសារហេតុផ្សេងៗ។

ក្រឡាសំណាញ់ចាក់ស្រែះឡើងបាន ដោយសារកំនួចចំណងៗ យ៉ាងណាមិញ អ្វីៗទាំងអស់ក្នុងលោកនេះ ជាប់ទាក់ទងគ្នាបាន ដោយសារតែចំណងដូច្នេះដែរ។ ការគិតថាក្រឡាញសំណាញ់វាគង់នៅដោយឯកឯងនោះ ជាការយល់ប្រឡំមួយដ៏ធំ។

សំណាញ់កើតឡើងបាន ដោយសារក្រឡាជាច្រើនទាក់ទងជាប់គ្នា ហើយក្រឡានីមួយៗនៃសំណាញ់ ត្រូវការទាក់ទងនឹងក្រឡាឯទៀតៗ ជាចាំបាច់។

2. ផ្កាឈើរីកឡើងដោយសារហេតុច្រើនប្រការ ស្លឹកឈើជ្រុះក៏ដោយសារតែហេតុច្រើនប្រការដែរ។ បើគ្មានហេតុទាំងនោះទេ ផ្កាក៏មិនរីក ស្លឹកក៏មិនជ្រុះដែរ។ ផ្កាឈើរីកដោយសារមានហេតុផ្សេងៗ ស្លឹកឈើជ្រុះក៏ដោយសារមានហេតុផ្សេងៗដែរ។ អ្វីៗទាំងអស់សុទ្ធតែត្រូវទទួលការប្រែប្រួល។ គ្មានអ្វីដែលអាចឋិតនៅដោយឯកឯង ហើយគ្មានអ្វីដែលអាចគង់នៅបានដោយឥតប្រែប្រួលនោះទេ។

រឿងតែមួយគត់ ដែលអាចឋិតថេរជានិច្ចដោយឥតប្រែប្រួលនៅក្នុងលោកនេះ គឺអ្វីៗទាំងអស់កើតឡើងដោយមានហេតុមួយ ហើយវិនាសទៅវិញដោយមានហេតុមួយ។

III

ការទាក់ទងគ្នារវាងហេតុផ្សេងៗ

1. តើឫសគល់នៃទុក្ខ ព្រួយ បារម្ភ និងកង្វល់ នៅកន្លែងណា

ទៅ? បើគិតឲ្យល្អិតល្អន់ទៅ ឫសគល់នោះវានៅនឹងមនុស្ស លោក ដែលល្ងង់ខ្លៅ ហើយមានតណ្ហាជាច្រើនលើសលុប។

មនុស្សលោកជំពាក់ចិត្តនឹងជីវិតសម្បូណ៌ដោយធនធាន និងកិត្តិយស ជីវិតសុខុមាលភាពនិងសប្បាយរីករាយ ជីវិតរំដើប រំជួលប្រកបដោយអត្តទត្តភាព។ មនុស្សលោកគ្មានបានគិតដល់ ថា ចំណង់ចំពោះវត្ថុទាំងនោះវាជាឫសគល់នៃទុក្ខនោះទេ។

តាំងពីលោកនេះកកើតឡើងមក មនុស្សលោកត្រូវបាន ទទួលរងនូវវិបត្តិភ័យព្រួយគ្រប់ប្រការ។ ជាបន្ថែមលើនេះទៀត មនុស្សលោកមិនអាចចៀសឲ្យផុតបានពីឈឺ ជរា និងស្លាប់ ដែលជាហេតុ៣ ប្រការនៃទុក្ខនោះបានទេ។

តែបើគេរិះគិតឲ្យដល់ជម្រៅទៅ គេនឹងឃើញថា គឺ ដោយសារតែការជំពាក់ចិត្តនេះឯង ដែលនាំឲ្យមានទុក្ខព្រួយ។ បើសិនជាអាចបំបាត់ការជំពាក់ចិត្តនេះបាន សេចក្តីទុក្ខព្រួយ នឹងវិនាសអស់ជាពុំខាន។

ហេតុដែលបណ្តាលឲ្យមានការជំពាក់ចិត្តទាំងនេះ គឺមក អំពីសេចក្តីល្ងង់ខ្លៅ ហើយនិងការយល់ខុសទាំងឡាយ ដែល ស្ថិតនៅពេញក្នុងបេះដូងសត្វលោក។

សេចក្ដីល្ងង់ខ្លៅនិងការយល់ខុសទាំងនេះ មកអំពីមនុស្សលោកមិនយល់ច្បាស់ពិត ដែលគ្រប់គ្រងដំណើរបន្តគ្នាគ្មានចេះដាច់នៃវត្ថុធាតុទាំងឡាយ។

ដោយសារតែសេចក្ដីល្ងង់ខ្លៅ និងការយល់ខុសទាំងនេះហើយ ដែលបណ្ដាលឲ្យមនុស្សលោកប៉ងចង់បានរបស់ដែលចាប់យកពុំបាន ហើយលង់ក្នុងការប៉ុនប៉ងចង់បាននោះ។

ធ្វើការវែកញែកចំពោះរបស់ដែលតាមពិតពុំអាចវែកញែកបាននោះ គឺដោយសារតែសេចក្ដីល្ងង់ខ្លៅ និងសេចក្ដីលោភលន់ចង់បាន។ ធ្វើការវែកញែកអំពីភាពល្អ និងភាពអាក្រក់ ដែលតាមពិតវាគ្មានសោះនោះ គឺមកតែអំពីសេចក្ដីល្ងង់ខ្លៅ និងសេចក្ដីលោភលន់។

ដោយសារតែសេចក្ដីល្ងង់ខ្លៅ មនុស្សលោកមានគំនិតយល់ខុសជានិច្ច ហើយបាត់បង់ជានិច្ចការរមិលយល់ត្រូវ។ ដោយសារតែសេចក្ដីល្ងង់ខ្លៅ មនុស្សលោកជំពាក់ចិត្តតែនឹងខ្លួនឯងផ្ទាល់ ហើយប្រព្រឹត្តអំពើខុស។ ទីបំផុតទៅ មនុស្សលោកវង្វេងវិលវល់ក្នុងផ្លូវភាន់ច្រឡំ។

មានសេចក្ដីប្រៀបធៀបមួយថាៈ វិស័យកម្មគឺវាលស្រែ

មួយ គំនិតវែកញែកគឺជាគ្រាប់ពូជ។ មនុស្សសាបព្រោះគ្រាប់ពូជនេះដោយល្ងិតល្ងង់ ស្រោចស្រប់បំណងអាក្រក់ និងអត្តទត្តភាពឲ្យវា ដាក់ជីសេចក្ដីលោភលន់ឲ្យវា។ ដោយហេតុនេះហើយ ការភាន់ច្រឡំក៏ត្រូវបានមកជាផល។

2. ទាំងអស់នេះកើតឡើងនៅក្នុងសតិ។ ដូច្នេះ សតិជាដើមហេតុនៃការសង្ស័យមិនសមហេតុផល ជាដើមហេតុនៃទុក្ខព្រួយលំបាកវេទនា។

លោកដែលពោរពេញទៅដោយសេចក្ដីភាន់ច្រឡំនេះ គឺជាស្រមោលដែលបណ្ដាលមកអំពីសតិតែប៉ុណ្ណោះ។ តែសតិក៏ជាប្រភពនៃការបានត្រាស់ដឹងនោះដែរ។

3. នៅក្នុងលោកនេះ មានការភាន់ច្រឡំបីប្រការ។ បើបុគ្គលណាប្រកាន់យ៉ាងមាំនូវការយល់ច្រឡំទាំងនោះ បុគ្គលនោះមុខតែនឹងគ្មានច្រកចេញរួចទេ នៅក្នុងលោកនេះ។

ការយល់ច្រឡំទី១ គឺជាការជឿថាអ្វីៗទាំងអស់នៅក្នុងលោកនេះ ត្រូវបានទទួលការគ្រប់គ្រងនៃវាសនា។ ការយល់

ប្រទ្បំទី២ គឺការយល់ឃើញថា អ្វីៗទាំងអស់ត្រូវបានកើតឡើង ដោយសារព្រះអាទិទេព ហើយត្រូវតែសម្រេចទៅតាមបំណង នៃព្រះអាទិទេពនោះ។ ការយល់ប្រទ្បំទី៣ គឺការដែលពោល អះអាងថា អ្វីៗទាំងអស់កើតឡើងដោយចៃដន់ គ្មានហេតុ គ្មានល័ក្ខខ័ណ្ឌអ្វីទេ។

បើអ្វីៗទាំងអស់សម្រេចទៅតាមតែវាសនានោះ អំពើល្អ និងអំពើអាក្រក់ត្រូវតែបានកំណត់ទុកមុន សុភមង្គល និង អភ័ព្វត្រូវតែបានកំណត់ទុកមុន។ គ្មានអ្វីដែលមិនត្រូវបាន កំណត់ទុកមុននោះទេ។ បើដូចនេះ គេមិនអាចពោលស្រដី បានថាៈ «ត្រូវធ្វើយ៉ាងនេះ មិនត្រូវធ្វើយ៉ាងនោះ» បានទេ។ សត្វលោកមុខតែអស់សេចក្តីសង្ឃឹម ចំពោះរសជាតិនៃការ តស៊ូជាមិនខាន។ ហើយលោកនេះមុខតែនឹងគ្មានការចម្រើន លូតលាស់ទៅមុខជាពុំខាន។

ការពោលថា អ្វីៗទាំងអស់នៅក្រោមការសម្រេចរបស់ ព្រះអាទិទេព ឬថាគ្មានហេតុ និងគ្មានសម្ព័ន្ធនោះ ក៏នឹងត្រូវ បានទទួលការជំទាស់ដូចខាងលើនេះដែរ។ បើអ្វីៗទាំងអស់វា ទៅជាបែបនេះ មុខតែគ្មានសំអាងអ្វីឡើយនឹងខិតខំចៀសវាង

នូវអំពើអាក្រក់ ហើយខំតែប្រព្រឹត្តអំពើល្អនោះទេ។

ដូច្នេះ ការគិតយល់ទាំងបីប្រការនេះជាការគិតខុសពី ព្រោះអ្វីៗទាំងអស់កើតឡើងដោយសារហេតុមួយ ហើយ វិនាសទៅវិញដោយសារហេតុមួយ។

ចំពូកទី ២

ទ្រឹស្ដីអំពីវិញ្ញាណតែមួយគត់ និងសភាពពិតនៃវត្ថុធាតុ

I

ភាពមិនឋិតថេរ និង ភាពឥតសារជាតិ

1. *រូប និងវិញ្ញាណ កើតឡើងអំពីការប្រកួតប្រជែងគ្នារវាង ហេតុនិងល័ក្ខខ័ណ្ឌ ហេតុនេះរូបគ្មានសារជាតិទេ។ រូបកកើតឡើងអំពីសាច់ និងវត្ថុធាតុផ្សេងៗផ្ដុំប្រមូលគ្នារូបនោះមិនឋិតថេរទេ។*

បើរូបជាវត្ថុមានសារជាតិ រូបនោះអាចធ្វើនេះធ្វើនោះបានតាមបំណង។

ព្រះមហាក្សត្រមានអំណាចនឹងឲ្យរង្វាន់ ឬដាក់ទោសបានតាមចិត្តចង់។ ប៉ុន្តែ ទោះបីព្រះអង្គគ្មានបំណង ឬចំណង់ក៏ដោយ ក៏ព្រះអង្គត្រូវតែឈឺ ជរា ជាមិនខាន ហើយភោគទ្រព្យអាចបំពេញបំណងព្រះអង្គបានដោយតិចតួចណាស់។

វិញ្ញាណ ក៏ជារបស់ឥតសារជាតិដែរ។ វិញ្ញាណរបស់មនុស្ស ក៏ជាវត្ថុផ្តុំគ្នាអំពីហេតុ និងល័ក្ខខ័ណ្ឌដែរ។ វិញ្ញាណប្រែប្រួលជានិច្ច។

បើវិញ្ញាណជាវត្ថុមានសារជាតិ វាអាចនឹងធ្វើអ្វីៗបានតាមបំណង។ តែវិញ្ញាណមិនធ្វើអ្វីដែលយល់ថាត្រូវជានិច្ចនោះទេ វាជាប់ជំពាក់និងអ្វីៗដែលខុស ហើយដែលវាមិនចង់បានសោះ។ គ្មានអ្វីដែលផ្តល់មកឲ្យបានសមនឹងបំណងនោះទេ។

2. បើគេសួរថា រូបឋិតថេរ ឬក៏មិនឋិតថេរទេ នុ៎ះត្រូវតែឆ្លើយថា មិនឋិតថេរទេ។

បើគេសួរថា ជីវិតមិនឋិតថេរជាសុភមង្គល ឬជាទុក្ខ ត្រូវឆ្លើយជាធម្មតាថា វាជាទុក្ខ។

ការនឹកស្មានថា វត្ថុដែលមិនឋិតថេរ ដែលប្រែប្រួលជានិច្ច ហើយដែលពោរពេញទៅដោយទុក្ខយ៉ាងនេះជាវត្ថុមានសារជាតិ នុ៎ះជាការយល់ច្រឡំធំណាស់។

វិញ្ញាណមនុស្សលោក ដែលមិនឋិតថេរហើយពោរពេញទៅដោយទុក្ខបែបនេះ គ្មានរឿងអ្វីនឹងអាចហៅវិញ្ញាណនោះ

ថា ជាវត្ថុមានសារជាតិបានទេ។

ដោយហេតុនេះ រូបនិងវិញ្ញាណដែលជាវត្ថុជាតុដើមនៃជីវិតរបស់មនុស្សជាតិ និងលោកខាងក្រៅដែលហាក់ដូចជានៅព័ទ្ធជុំវិញនោះ គ្មានអត្ថន័យថាជា «អាត្មាអញ» ឬ «ខ្លួនខ្ញុំ» ទេ។

និយាយឲ្យខ្លីទៅ គឺដោយសារតែវិញ្ញាណត្រូវឡើងងងឹតដោយចំណង់មិនបរិសុទ្ធ ហើយមិនព្រមទទួលនូវគតិបណ្ឌិតយ៉ាងនេះ ទើបបានជាបុគ្គលម្នាក់ៗ ចចេសតែគិតអំពី «អាត្មាអញ» ឬ «ខ្លួនខ្ញុំ»។

ដោយហេតុថា រូបព្រមទាំងអ្វីៗ ដែលនៅជុំវិញវាកកើតឡើងពីហេតុ និងល័ក្ខខ័ណ្ឌ វត្ថុទាំងនោះប្រែប្រួលជានិច្ច មិនព្រមឈប់ឈរទេ។

វិញ្ញាណមនុស្សលោកដែលប្រែប្រួលជានិច្ចនោះ បីដូចជាទឹកស្ទឹងដែលហូរជានិច្ច ឬបីដូចជាអណ្តាតភ្លើងទៀន ដែលឆេះទ្រលោមអញ្ចឹងដែរ អាចប្រៀបប្រដូចទៅនឹងសត្វស្វាដែលលោតមិនចេះឈប់ពីកន្លែងមួយទៅកន្លែងមួយ។

បុគ្គលជាបណ្ឌិតដែលបានសង្កេតឃើញដំណើរនេះ ត្រូវ

តែផ្ដាច់ការជាប់ចិត្តចំពោះរូបកាយនិងវិញ្ញាណ បើសិនជាមានចំណង់ចង់ឲ្យបានសម្រេចការត្រាស់ដឹង។

3. នៅក្នុងលោកនេះ មានវត្ថុប្រាំប្រការ ដែលចៀសពុំផុតៈ ទី១ គឺកាលណាចាស់ហើយ មិនអាចបញ្ឈប់កុំឲ្យចាស់បានទេ ទី២ គឺកាលណាឈឺហើយ មិនអាចថាកុំឈឺបានទេ ទី៣ គឺកាលណាកំពុងតែឈានទៅរកសេចក្ដីស្លាប់ហើយ មិនអាចថាកុំស្លាប់បានទេ ទី៤ គឺកាលណាដល់នូវការរលាយហើយ មិនអាចបញ្ឈប់ការរលាយនោះបានទេ ទី៥ គឺមិនអាចចៀសផុតពីការរលត់សាបសូន្យបានទេ។

នៅក្នុងលោកនេះ អ្នកណាក៏ដោយ នៅទីបំផុតត្រូវតែបានជួបប្រទះនឹងការចៀសមិនរួចទាំងប្រាំប្រការនេះ។ អ្នកដែលបានស្ដាប់សេចក្ដីទូន្មានរបស់ព្រះពុទ្ធ កាលណាពេលនេះមកដល់ហើយ មិនឈឺចាប់នឹងប្រការទាំងនោះទេ ព្រោះដឹងថាជាការចៀសពុំផុត។

នៅក្នុងលោកនេះ មានសេចក្ដីពិតបួនប្រការៈ ទី១ គឺមនុស្សលោកកើតឡើងដោយសេចក្ដីល្ងង់ខ្លៅជាហេតុ ទី២

គឺអ្វីៗដែលប៉ះប្រាថ្នាសុទ្ធតែជារបស់មិនឋិតថេរ មិនប្រាកដ ហើយពោរពេញទៅដោយទុក្ខ ទី៣ គឺអ្វីៗដែលឋិតមាននៅ សុទ្ធតែជារបស់មិនឋិតថេរ មិនប្រាកដ ហើយពោរពេញទៅដោយទុក្ខ ទី៤ គឺនៅក្នុងលោកនេះគ្មានអ្វីដែលអាចចាត់តាំងថាជា «អាត្មាអញ» ឬ «របស់អញ» បានទេ។

អ្វីៗទាំងអស់សុទ្ធតែមិនឋិតថេរ សុទ្ធតែជាបណ្តោះអាសន្ន ហើយគ្មានអត្តភាពទេ។ នេះជាសេចក្តីពិតណាស់ ទោះបីជឿថាក្នុងលោកនេះមានព្រះពុទ្ធ ឬគ្មានព្រះពុទ្ធក៏ដោយ។ នេះជាសេចក្តីពិត ដែលពុំអាចប្រកែកជំទាស់បាន។ ព្រះពុទ្ធ ដោយដឹងយល់នូវសេចក្តីនេះហើយ ទើបបានជាព្រះអង្គទេសនាពន្យល់ព្រះធម៌ដល់សត្វលោកទាំងអស់។

II

ទ្រឹស្តីអំពីវិញ្ញាណតែមួយគត់

1. សេចក្តីល្ងង់ខ្លៅនិងការបានត្រាស់ដឹង ទាំងពីរនេះចេញមកពីវិញ្ញាណ ហើយបាតុភូតទាំងឡាយជាលទ្ធផលនៃសកម្ម

ភាពនៃវិញ្ញាណ បីដូចជាវត្ថុទាំងឡាយដែលចេញមកពីការ
ប៉ិនប្រសព្វនៃគ្រូមន្ដអាគមបេះបិ្ដនភ្នែក។

សកម្មភាពនៃវិញ្ញាណគ្មានព្រំដែនទេៈ គឺសកម្មភាពទាំង
នោះហើយ ដែលបង្កើតពិភពនៃជីវិត។ វិញ្ញាណមិនបរិសុទ្ធ
បង្កើតពិភពមិនបរិសុទ្ធ វិញ្ញាណបរិសុទ្ធបង្កើតពិភពបរិសុទ្ធ។
អ្វីៗទាំងអស់ដែលនៅព័ទ្ធជុំវិញខ្លួនយើងនេះ គ្មានវត្ថុអ្វីក្រៅពី
សកម្មភាពនៃវិញ្ញាណរបស់ផងយើងនោះទេ។

ប្រៀបបានទៅនឹងផ្ទាំងគំនូរ ដែលផលិតឡើងទៅតាម
ស្នាដៃនៃវិចិត្រករ អ្វីៗទាំងអស់ដែលនៅព័ទ្ធជុំវិញយើង ជា
ផលិតផលដែលកើតឡើងពីវិញ្ញាណរបស់យើងផ្ទាល់។ ពិភព
ដែលព្រះពុទ្ធបង្កើត ជាពិភពបរិសុទ្ធ តែពិភពដែលមនុស្ស
លោកបង្កើត ជាពិភពមិនបរិសុទ្ធទេ។

នៅក្នុងរូបគំនូរតែមួយគត់នោះ មានសេចក្ដីពិពណ៌នា
ផ្សេងៗជាច្រើនរាប់មិនអស់។ វិញ្ញាណមនុស្សលោកក៏ដូច្នោះ
ដែរ វាបង្កើតពិភពរបស់វាផ្ទាល់ ដែលពោរពេញទៅដោយ
សកម្មភាពរាប់មិនអស់។ នៅក្នុងលោកនេះ គ្មានអ្វីដែលមិន
ផលិតឡើងដោយសារវិញ្ញាណនោះទេ។

ព្រះពុទ្ធទ្រង់យល់យ៉ាងច្បាស់ថា អ្វីៗទាំងអស់ត្រូវបាន កើតឡើងដោយសារវិញ្ញាណ។ ហេតុនេះហើយ បើបុគ្គល ណាយល់សេចក្តីនេះ បុគ្គលនោះអាចនឹងមើលឃើញព្រះ ពុទ្ធពិតប្រាកដ។

2. វិញ្ញាណដែលបង្កើតពិភពរបស់ខ្លួនផ្ទាល់នោះ មិនអាច ចេញឲ្យផុតពីស្រមោលរបស់ខ្លួនបានជាដាច់ខាត: វិញ្ញាណ ស្តាយនូវអតីតកាល ខ្លាចអនាគតកាល ហើយត្អូញត្អែរនឹង បច្ចុប្បន្នកាល ដោយសារតែសេចក្តីល្ងង់ខ្លៅ ព្រមនិងតណ្ហា លោភលន់របស់ខ្លួន។

លោកដែលពេញទៅដោយការយល់ច្រឡំនេះ កើតឡើង ពីក្តីល្ងង់ខ្លៅ និងសេចក្តីលោភលន់។ ការប្រមូលផ្តុំគ្នាដ៏ធំ ទូលាយនៃហេតុនិងល័ក្ខខ័ណ្ឌ ដែលត្រូវការគ្នាទៅវិញទៅមក នោះ ស្ថិតនៅក្នុងវិញ្ញាណនោះឯង គ្មាននៅទីណាផ្សេងទៀត ទេ។

ការរស់នៅនិងការស្លាប់ កើតឡើងពីវិញ្ញាណ ហើយឋិត នៅក្នុងវិញ្ញាណនោះ។ កាលណាវិញ្ញាណបាត់បង់ទៅពិភព

នៃការរស់នៅ និងការស្លាប់ក៏បាត់បង់ទៅតាមវិញ្ញាណនោះដែរ។

ជីវិតល្វឹតល្វើយនិងវង្វេងវង្វាន់ មកពីវិញ្ញាណល្វឹតល្វើយនិងវង្វេងវង្វាន់។ បើយើងបានយល់ថា ពិភពនៃការយល់ច្រឡំវាមិនឋិតនៅទីណាក្រៅអំពីវិញ្ញាណទេនោះ យើងនឹងអាចធ្វើឲ្យវិញ្ញាណយើងបានភ្លឺថ្លា ហើយកាលណាយើងឈប់បង្កើតពិភពមិនបរិសុទ្ធ យើងនឹងអាចដល់នូវការបានត្រាស់ដឹង។

តាមដោយសេចក្តីនេះ ឃើញថា ពិភពនៃការរស់នៅនិងការស្លាប់ ពោលគឺលោកយើងនេះ កើតឡើងដោយសារវិញ្ញាណជិះជាន់ញាំញីដោយសារវិញ្ញាណ គ្រប់គ្រងត្រួតត្រាដោយសារវិញ្ញាណ។ គឺវិញ្ញាណដែលបញ្ជាគ្រប់ស្ថានភាពទាំងអស់។ ពិភពនៃទុក្ខកើតឡើងអំពីវិញ្ញាណវង្វេងវង្វាន់។

3. ដូច្នេះ អ្វីៗទាំងអស់ ត្រូវបានគ្រប់គ្រងជាដំបូងដោយវិញ្ញាណ អ្វីៗទាំងអស់ចេញមកអំពីវិញ្ញាណ។ ដូចជាកង់រិលតាមគោដែលទាញរទេះ ទុក្ខរត់តាមវិញ្ញាណដែលព័ទ្ធជំពាក់

និងគំនិតអសុចិ ហើយនិងតណ្ហាលោកិយ។

បើបុគ្គលណានិយាយហើយប្រព្រឹត្តតាមដោយវិញ្ញាណល្អបរិសុទ្ធ សុភមង្គលនឹងរត់តាមបុគ្គលនោះ ដូចជាស្រមោលអន្ទោលតាមប្រាណដូច្នេះដែរ។ អ្នកប្រព្រឹត្តអាក្រក់នឹងនឹកឃើញជាខាងក្រោយ ថាខ្លួនបានប្រព្រឹត្តអាក្រក់ ហើយការនឹកឃើញនេះត្រូវបានកំណត់ទុកក្នុងខ្លួន ដើម្បីជារង្វាន់ចៀសមិនរួចដល់ខ្លួនវិញ ក្នុងជីវិតជាបន្តៗទៅទៀត។ អ្នកដែលប្រព្រឹត្តអំពើល្អ សប្បាយនឹងអំពើល្អដែលខ្លួនបានធ្វើ ហើយសប្បាយច្រើនទៅទៀត នៅពេលគិតឃើញដល់សុភមង្គលដែលនឹងត្រូវបានអំពីអំពើល្អនេះ ក្នុងជីវិតខាងមុខទៀត។

បើវិញ្ញាណមិនបរិសុទ្ធទេនោះ ផ្លូវនឹងឡើងជាអាក្រក់ពិបាកដើរ ហើយជើងនឹងភ្ទាត់ជំពប់ជាមិនខាន មុខតែប្រទះនឹងការដួលធ្លាក់និងការវេទនាជាច្រើនមិនខាន។ តែបើវិញ្ញាណនោះបរិសុទ្ធ ផ្លូវនឹងឡើងរាបស្មើល្អ ហើយការធ្វើដំណើរនឹងបានប្រកបដោយសេចក្ដីសុខក្សេមក្សាន្ត។

អ្នកដែលមានរូបនិងវិញ្ញាណបរិសុទ្ធ ជាអ្នកដើរតាមផ្លូវរបស់ព្រះពុទ្ធ កំចាត់បង់នូវសំណាញ់អត្តទត្ថភាព នូវគំនិតមិន

បរិសុទ្ធ និងសេចក្តីប្រាថ្នាអាក្រក់។ អ្នកដែលមានវិញ្ញាណស្ងប់ អាចរស់ក្នុងសុខសន្តិភាព ហើយអាចរក្សាជុសខាត់វិញ្ញាណរបស់ខ្លួនបានរាល់យប់ថ្ងៃដោយការផ្ចិតផ្ចង់ច្រើនជានិច្ច។

III

ភាពពិតនៃវត្ថុជាតុ

1. ដោយហេតុតែអ្វីៗទាំងអស់នៅក្នុងលោកនេះ កើតមកអំពីការប្រកួតប្រជែងរវាងហេតុនិងលក្ខខ័ណ្ឌវា មិនអាចនឹងមានការវែកញែកជាគោល រវាងវត្ថុទាំងឡាយនោះបានទេ។ ការវែកញែកដែលជាអាការខាងក្រៅនោះ មកអំពីមនុស្សលោកមានគំនិតរវើរវាយគិតវែកញែក រវាងវត្ថុទាំងនោះតែប៉ុណ្ណោះ។

នៅក្នុងផ្ទៃមេឃ គ្មានការសម្គាល់ឃើញថាខុសគ្នារវាងទិសខាងកើត និងទិសខាងលិចទេ។ តែមនុស្សលោកបង្កើតការវែកញែកសម្គាល់នេះ នៅក្នុងវិញ្ញាណរបស់ខ្លួនផ្ទាល់ ហើយជឿថា ការនេះជាការពិត។

នៅក្នុងគណិតសាស្ត្រ គ្រប់លេខពី១ដល់អសង្ខេយ្យ វា

ពេញលេញគ្រប់គ្រាន់ក្នុងតួរបស់វានីមួយៗហើយ។ តួលេខនីមួយៗគ្មានចំនួនអ្វីខុសគ្នាទេ តែមនុស្សលោកធ្វើការវែកញែកសម្គាល់នូវចំនួនក្នុងតួលេខទាំងនោះ តាមតម្រូវចិត្តរបស់ខ្លួននោះ គឺដើម្បីអាចធ្វើលេខផ្សេងៗបានតែប៉ុណ្ណោះ។

ដើមឡើយ បើគ្មានការកើតឡើង ក៏គ្មានការវិនាសទៅវិញដែរ តែមនុស្សលោកសម្គាល់ឃើញថា ខុសគ្នារវាងការកើតនិងការស្លាប់នេះ។ នៅក្នុងអំពើនីមួយៗ បើគ្មានត្រូវក៏គ្មានខុសដែរ តែមនុស្សលោកធ្វើការវែកញែករវាងត្រូវនិងខុសនេះទៅតាមតម្រូវចិត្តរបស់ខ្លួន។

ព្រះពុទ្ធចៀសវាងការវែកញែកទាំងនេះ ហើយទុកលោកនេះដូចជាពពកដែលផាត់រសាត់ទៅ។ ចំពោះព្រះពុទ្ធវត្ថុទាំងឡាយដែលសម្គាល់ឃើញថាល្អ ឬអាក្រក់នោះ សុទ្ធតែជាការប្លឹនភ្នែក។ ព្រះអង្គដឹងថា អ្វីៗទាំងអស់ដែលវិញ្ញាណចាប់យក ឬទាត់ចោលជារបស់គ្មានស្ថិរភាព។ ហេតុនេះ ព្រះអង្គចៀសវាងអន្ទាក់នៃអាការភាពខាងក្រៅ និងគំនិតវែកញែកវត្ថុ។

2. មនុស្សលោកតោងចាប់យករបស់ទាំងឡាយ ដោយនឹកស្មានថា របស់ទាំងនោះសមនឹងចិត្តខ្លួន។ មនុស្សលោកតោងចាប់យកសុភមង្គល សម្បត្តិទ្រព្យ កិត្តិយស ហើយប្រយុទ្ធនឹងដំណើរជីវិតដោយអស់សង្ឃឹម។

មនុស្សលោកធ្វើការវែកញែកតាមអំពើចិត្ត រវាងអត្ថិភាព ឬភាពវត្ថុដែលមាននៅ និងអនត្ថិភាព ឬភាពដែលគ្មាននៅ រវាងល្អនិងអាក្រក់ រវាងត្រូវនិងខុស។ ចំពោះមនុស្សលោកជីវិតជាដំណើរបន្តគ្នាមិនចេះដាច់នៃបំណង និងការជំពាក់ចិត្ត ហើយដោយសារហេតុនេះ មនុស្សលោកត្រូវតែទទួលរងនូវការបំភាន់ភ្នែកនៃទុក្ខវេទនា។

កាលមួយនោះ មានបុរសម្នាក់ធ្វើដំណើរឆ្ងាយទៅៗ ដល់មាត់ស្ទឹងមួយ។ គាត់គិតតែម្នាក់ឯងថា: «មាត់ស្ទឹងម្ខាងនេះពិបាកហើយគ្រោះថ្នាក់ណាស់ តែមាត់ស្ទឹងម្ខាងនោះវិញដូចជាស្រួលដើរហើយសុខផង តែអញធ្វើដូចម្តេចនឹងឆ្លងទៅបាន ! » ។ គាត់ក៏យកមែកឈើ និងដើមបបុសចងធ្វើជាក្បូនហើយឆ្លងរួចទៅដល់មាត់ស្ទឹងម្ខាងនោះទៅដោយសុវត្ថិភាព។ ដល់ហើយគាត់ក៏ស្រដីតែម្នាក់ឯងថា: «ក្បូននេះផ្តល់ប្រយោជន៍

ឲ្យដល់អញច្រើនណាស់ក្នុងការឆ្លងស្ទឹង អញមិនត្រូវបោះបង់វាចោលឲ្យពុករលួយនៅនឹងមាត់ស្ទឹងនេះទេ អញត្រូវតែនាំយកវាទៅជាមួយអញ»។ គិតដូច្នេះហើយគាត់ក៏សណ្ដូនយកវត្ថុធ្ងន់ឥតប្រយោជន៍នោះទៅតាមខ្លួនគាត់ទៅ។ តើគេអាចថាបុរសនោះ ប្រកបដោយគតិបណ្ឌិតបានដែរឬទេ?។

រឿងឧបមានេះបានន័យថា សូម្បីតែវត្ថុល្អក៏ដោយ តែកាលណាវាទៅជាវត្ថុធ្ងន់ឥតប្រយោជន៍ ត្រូវតែបោះបង់វាចោល ហើយជាងនេះទៅទៀត បើវាជាវត្ថុអាក្រក់នុ៎ះ រឹតតែត្រូវបោះបង់ចោលទៅទៀត។ ព្រះពុទ្ធបានប្រដៅខ្លួនព្រះអង្គ ឲ្យចៀសវាងការពិភាក្សាឥតប្រយោជន៍ និងមិនសំខាន់។

3. វត្ថុទាំងឡាយមិនមានមកឬបាត់ទៅទេ វត្ថុទាំងឡាយមិនកើតឡើងឬវិនាសទៅទេ។ ដូច្នេះ គ្មានអ្វីដែលចំណេញឬខាតទេ។

ព្រះពុទ្ធទូន្មានថា វត្ថុទាំងឡាយមិនកើតឡើង និងមិនវិនាសទៅទេ ព្រោះថា វត្ថុទាំងនោះវាហួសពីការពោល

អះអាងថា មានឋិតនៅផង និងការប្រកែកថា គ្មានឋិតនៅផង។ បានសេចក្ដីថា វត្ថុនីមួយៗដោយវាជាការស្របគ្នានឹងដំណើរបន្តគ្នាមិនដាច់នៃហេតុនិងលក្ខខ័ណ្ឌ វាមិនមាននៅជាពិតប្រាកដទេ ហើយគេអាចថា វាមិនមានឋិតនៅយ៉ាងនេះបាន។ តែព្រមគ្នានោះ ពីព្រោះតែវាជាលទ្ធផលនៃហេតុនិងលក្ខខ័ណ្ឌ គេមិនអាចថាវាមិនមានឋិតនៅនោះបានទេ។

ការជាប់ចិត្តនឹងវត្ថុមួយ ដោយសារតែសម្រស់វត្ថុនោះជាឫសគល់នៃការភាន់គតិ។ បើគេមិនជាប់ចិត្តនឹងសម្រស់នោះទេ ការស្មានយល់ខុស និងការរមិលមើលឃើញមិនទំនងនឹងមិនមានទេ។ ការបានត្រាស់ដឹង គឺជាគតិបណ្ឌិតដែលនាំឲ្យមើលឃើញនូវការពិតនេះ ហើយនិងនាំឲ្យចៀសវាងនូវការរមិលយល់មិនសមហេតុសមផលនេះ។

ពិភពលោកតាមពិត វាដូចជាការយល់សប្ដិ ហើយរតនសម្បត្តិក្នុងលោកនេះ សុទ្ធតែជារបស់ប្រលោមបំភាន់ភ្នែក។ បីដូចជាសភាពផ្សេងៗ ឃើញពីចម្ងាយនៅក្នុងផ្ទាំងគំនូរមួយ វត្ថុទាំងឡាយគ្មានអ្វីជាពិតប្រាកដនៅក្នុងខ្លួនឯងទេ តែវា

បីដូចជាអ័ព្ទដែលត្រូវកម្តៅ។

4. ការជឿថា វត្ថុទាំងឡាយដែលកើតអំពីហេតុផ្សេងៗ រាប់មិនអស់អាចឋិតមាននៅរហូតនោះ ជាកំហុសធំមួយ ដែលហៅថា ទ្រឹស្តីអំពីភាពឋិតថេរ។ តែក៏ជាកំហុសធំមួយទៀតដែលហៅថា ទ្រឹស្តីអំពីភាពមិនមានឋិតនៅ ក្នុងការណ៍ដែលជឿថា វត្ថុទាំងឡាយនឹងវិនាសបាត់អស់គ្មានសល់អ្វីឡើយ។

ការយល់សើៗថា រស់រហូតឬស្លាប់រហូតមានឋិតថេរនៅ ឬគ្មានឋិតថេរនៅ មិនបានន័យទៅលើសភាពជាខ្លឹមនៃវត្ថុទេ វាបានន័យទៅលើតែអាការខាងក្រៅនៃវត្ថុ ដែលមើលឃើញដោយភ្នែកស្រវាំងរបស់មនុស្សលោកតែប៉ុណ្ណោះ។ ដោយសារចំណង់មនុស្សលោក ជាប់ចិត្តទៅលើអាការខាងក្រៅនៃវត្ថុទាំងនោះ។ តែសភាពខាងក្នុងដែលជាខ្លឹមសារនៃវត្ថុទាំងឡាយវាគ្មានទាក់ទងនឹងការវែកញែកបំបែក ឬការជំពាក់ចិត្តណាមួយឡើយ។

ពីព្រោះតែអ្វីៗ ទាំងអស់កើតឡើងដោយសារ ហេតុនិងល័ក្ខខ័ណ្ឌដែលបន្តគ្នាមិនចេះចប់ អាការខាងក្រៅនៃវត្ថុផ្លាស់

ប្តូរជានិច្ចជាកាល។ បានសេចក្តីថា វាគ្មានភាពឋិតថេរក្នុងខ្លួនវា ឲ្យដូចជាសារជាតិពិតប្រាកដនោះទេ។ ដោយសារតែការផ្លាស់ប្តូរមិនចេះចប់នៃអាការខាងក្រៅនេះហើយ ដែលនាំឲ្យយើងស្រឡាញ់វត្ថុទាំងឡាយ ក្នុងការកាន់ក្អែក ឬការយល់សប្តិ។ ប៉ុន្តែថ្វីបើមានការផ្លាស់ប្តូរមិនចេះចប់ នៃសម្បកក្រៅយ៉ាងនេះក៏ដោយ វត្ថុជាតិទាំងឡាយ ក្នុងសភាពជាសារជាតិឋិតនៅជានិច្ច ហើយមិនប្រែប្រួលទេ។

ចំពោះមនុស្សលោក ស្ទឹងហាក់ដូចជាស្ទឹង។ តែចំពោះទមិឡអន្សុតិរ្ទីយ៍ដែលទុកទឹកជាអណ្តាតភ្លើង ស្ទឹងហាក់ដូចជាភ្លើង។ ហេតុនេះ និយាយថាមានស្ទឹងចំពោះមនុស្សលោក វាមានអត្ថន័យមួយ តែបើនិយាយចំពោះខ្មោចបិសាច វាគ្មានន័យទេ។

ដូចគ្នានេះ គេអាចនិយាយថា: «វត្ថុទាំងឡាយជារបស់ថ្លឹនក្អែក មិនអាចថាមានឬអត់បានទេ»។

ម្យ៉ាងទៀត ជាការយល់ច្រឡំមួយទៀត ដែលវែកញែកជីវិតមិនឋិតថេរនេះ ពីជីវិតមិនចេះប្រែប្រួលនៃសេចក្តីពិតនោះ។ គេមិនអាចសន្និដ្ឋានបានថា ក្រៅពីពិភពដែលជាអាការខាងក្រៅ ហើយដែលប្រែប្រួលនេះ វានឹងមានពិភព

លោកមួយទៀត ដែលមិនចេះប្រែប្រួលនោះបានទេ។ ទុកលោកនេះជាពិភពមិនពិតថេរក៏ខុស ហើយទុកដូចជាពិភពពិតប្រាកដក៏ខុស។

ប៉ុន្តែមនុស្សល្ងង់ខ្លៅក្នុងលោកនេះគិតថា លោកនេះវាពិតប្រាកដ ហើយខំប្រព្រឹត្តទៅតាមការយល់ឃើញមិនទំនងនេះ។ តែដោយលោកនេះជាការបំភាន់ភ្នែក អំពើទាំងឡាយរបស់មនុស្សលោក ដោយយោលទៅតាមការយល់ខុសនេះ មិនអាចនាំទៅរកអ្វីក្រៅពីទុក្ខវេទនានោះបានទេ។

បុគ្គលប្រកបដោយគតិបណ្ឌិត ដោយយល់ជាក់ថាលោកនេះគ្រាន់តែជាការថ្លឹនភ្នែកនោះ មិនប្រព្រឹត្តទៅហាក់ដូចជាលោកនេះវាពិតប្រាកដនោះទេ។ ប្រព្រឹត្តយ៉ាងនេះបុគ្គលប្រកបដោយគតិបណ្ឌិតនោះ អាចចៀសផុតពីទុក្ខ។

IV

ផ្លូវកណ្ដាល

1. សម្រាប់អ្នករើសយកផ្លូវទៅកាន់ការត្រាស់ដឹង មានការហួសប្រមាណពីរប្រការ ដែលត្រូវចៀសវាង។ ទី១ គឺបណ្ដោយខ្លួន

ជ្រុលហួសហេតុ ឲ្យលុះទៅតាមអំណាចចំណង់នៃរូបកាយ។ ទី២ គឺផ្ទុយពីខាងលើនេះ មានបុគ្គលខ្លះសម្រេចចិត្តផ្តាច់ការទាក់ទងនឹងជីវភាពលោកនេះ ទៅធ្វើតបធម៌ចង្រ្កមភាវនា ដោយធ្វើបាបខ្លួន និងវិញ្ញាណតឹងតែងហួសហេតុ។

ផ្លូវប្រសើរបំផុត ដែលហួសពីភាពហួសហេតុទាំង២ ប្រការខាងលើនេះ ហើយដែលនាំឲ្យបានដល់នូវការបានត្រាស់ដឹងបានប្រកបនូវគតិបណ្ឌិត និងបានប្រកបនូវសេចក្តីស្ងប់នៃចិត្ត សន្មត់បានថា ផ្លូវកណ្តាល។ តើផ្លូវកណ្តាលនោះជាអ្វីទៅ? គឺជាផ្លូវត្រូវ ដែលចែកចេញជាប្រាំបីផ្នែកគឺៈ ការយល់ឃើញត្រូវ១ បំណងល្អត្រឹមត្រូវ១ ពាក្យសម្តីត្រឹមត្រូវ១ ចរិយាត្រឹមត្រូវ១ របៀបរស់នៅត្រឹមត្រូវ១ ការខំប្រឹងប្រែងត្រឹមត្រូវ១ ការប្រុងប្រយ័ត្នត្រឹមត្រូវ១ និងការសង្រួមចិត្តត្រឹមត្រូវ១។

ដូចបានស្តីពីលើមកហើយ វត្ថុទាំងឡាយកើតឡើង ហើយវិនាសទៅវិញ ដោយសារតែការមកជាបន្តៗគ្នាមិនចប់នៃហេតុជាច្រើនរាប់មិនអស់។ ចំពោះជនល្ងង់ខ្លៅ អ្នកខ្លះមើលឃើញថាមានឋិតថេរនៅ អ្នកខ្លះទៀតមើលឃើញថាគ្មានឋិតនៅ។

តែចំពោះជនជាបណ្ឌិតវិញ គេមើលឃើញហួសពីការមានឋិតនៅ ឬគ្មានឋិតនៅនេះទៅទៀត ចំពោះវត្ថុទាំងឡាយដែលហួសពីការទាំងពីរនេះ។ ការមើលឃើញរបៀបនេះ ក៏ជាផ្លូវកណ្តាលមួយដែរ។

2. ដូចជាអង្កត់ឈើមួយដែលអណ្តែតក្នុងស្ទឹង បើវាមិនកៀងនឹងថ្ម មិនលិចទៅបាតស្ទឹង មិនត្រូវបានគេស្រង់វាឡើង ឬបំផ្លាញវាចោលនោះទេ វានឹងអណ្តែតធ្លាក់ទៅក្នុងសមុទ្រជាទីបញ្ចប់។ ជីវិតក៏ដូចជាអង្កត់ឈើនៅក្នុងស្ទឹងដ៏ធំនោះដែរ។ បើគេមិនទាក់ជាប់នឹងជីវិត ដែលលុះទាំងស្រុងទៅតាមអំណាចតណ្ហា ឬផ្តាច់ទាំងស្រុងអំពីជីវិតលោកនេះ ដោយធ្វើបាបខ្លួនឯងហួសហេតុ បើគេមិនក្រអើតក្រអោងនឹងគុណសម្បត្តិរបស់ខ្លួន បើគេមិនជាប់ជំពាក់នឹងអំពើអាក្រក់ ហើយបើក្នុងការស្វែងរកការត្រាស់ដឹង គេមិនមានកង្វល់ ឬញញើតញញើមប្រទាក់ប្រទងនឹងការបំភាន់ភ្នែកនោះទេ បានន័យថា គេដើរតាមផ្លូវកណ្តាល។

កាលណាគេដើរតាមផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ការសំខាន់

គឺចៀសវាង កុំបណ្តោយខ្លួនឲ្យលុះទៅតាមការប្រកាន់ចិត្ត ហួសប្រមាណ ទាំងពីរប្រភេទនេះ បានន័យថា ត្រូវតែដើរ តាមផ្លូវកណ្តាលជានិច្ច។

បើដឹងថាវត្ថុទាំងឡាយវាឋិតមាននៅក៏មិនមែន ឬមិន ឋិតមាននៅក៏មិនមែននោះ ហើយបើនឹកឃើញថា សភាពនៃ វត្ថុជាតុវាដូចជាការយល់សប្តិនោះ ត្រូវតែចៀសវាងកុំឲ្យអភិ-មានះ ដែលទាក់ទងទៅនឹងការវាយឫកខ្ពស់តម្កើងខ្លួន ហើយ និងការចង់ឲ្យគេអួតសរសើរ អំពើល្អរបស់ខ្លួននោះវាដឹកមុខ បាន។ ត្រូវចៀសវាង កុំឲ្យអ្វីៗសព្វសារពើវាទាក់ទាញដឹកនាំ បានឡើយ។

បើបុគ្គលណាចង់ចៀសវាងការធ្លាក់ចូលទៅក្នុងចរន្តនៃ ចំណង់របស់ខ្លួន ជាដំបូងបង្អស់ បុគ្គលនោះត្រូវតែហាត់បំពត់ ចិត្តកុំឲ្យជំពាក់ទាក់ជាប់នឹងវត្ថុទាំងឡាយ ខ្វាចក្រែងវាធ្លាប់ ហើយទៅជាជាប់ចិត្តវើខ្លួនពុំរួចពីវត្ថុទាំងនោះ។ ចំពោះអត្ថិ-ភាព ឬភាពមានឋិតនៅក្តី អនត្ថិភាព ឬភាពគ្មានឋិតនៅក្តី ចំពោះអ្វីៗដែលជាខាងក្នុង ឬជាខាងក្រៅក្តី ចំពោះវត្ថុល្អ ឬ អាក្រក់ក្តី ចំពោះវត្ថុពិតឬក្លែងក្លាយក្តី គេមិនត្រូវជាប់ជំពាក់

ចិត្តជាមួយទេ។

បើគេជាប់ជំពាក់នឹងវត្ថុទាំងនោះ វាបានតែក្នុងមួយរយៈពេលដ៏ខ្លីប៉ុណ្ណោះ មិនយូរទេជីវិតក្នុងភាពភាន់គតិនឹងចាប់ផ្ដើមហើយ។ អ្នកដែលដើរតាមផ្លូវប្រសើរនៃពន្លឺត្រាស់ញាណមិនត្រូវរក្សាទុកនូវការសោកស្ដាយចំពោះអតីតកាល ហើយមិនខ្វាចចំពោះអនាគតទេ គេត្រូវតែចាប់យកវត្ថុតាមភាពដែលវាមកដល់ដោយសតិស្មើហើយស្ងប់។

3. ពន្លឺត្រាស់ដឹងគ្មានរូបរាងជាក់លាក់ទេ មិនអាចចេញស្ដែងឡើងតាមសភាពណាមួយបានទេ។ ហេតុនេះ នៅក្នុងពន្លឺត្រាស់ដឹង គ្មានអ្វីដែលត្រូវបំភ្លឺទេ។

ពន្លឺត្រាស់ដឹងមានឡើងដោយសារតែមាន សេចក្ដីល្ងង់ខ្លៅ និងការភាន់ភ្នែកតែប៉ុណ្ណោះ។ បើសេចក្ដីទាំងពីរនេះវិនាសបាត់ទៅ ពន្លឺត្រាស់ដឹងក៏បាត់ទៅដែរ។ ផ្ទុយនឹងសេចក្ដីនេះ ក៏ជាការពិតដែរគឺថា: មានសេចក្ដីល្ងង់ខ្លៅនឹងការភាន់ភ្នែក ដោយសារមានពន្លឺត្រាស់ដឹង។ កាលណាពន្លឺត្រាស់ដឹងចប់ហើយ សេចក្ដីល្ងង់ខ្លៅនិងការភាន់ភ្នែកក៏ចប់ទៅដែរ។

ហេតុដូច្នេះ បុគ្គលត្រូវតែចៀសវាងការទុកពន្លឺត្រាស់ដឹង ជាវត្ថុមួយដែលត្រូវចាប់យក ពុំនោះទេ ពន្លឺត្រាស់ដឹងនឹងទៅ ជាឧបសគ្គមួយមិនខាន។ កាលណាវិញ្ញាណដែលនៅក្នុង ភាពងងឹត បានទៅដល់ពន្លឺត្រាស់ដឹងហើយ វានឹងរលត់បាត់ ហើយព្រមជាមួយនឹងការរលត់បាត់នេះ អ្វីដែលគេហៅថា «ពន្លឺត្រាស់ដឹង» ក៏រលត់បាត់ដែរ។

ដរាបណាយើងចង់បានពន្លឺត្រាស់ដឹង ដូចជាវត្ថុមួយ ដែលត្រូវតែចាប់យក បានន័យថា យើងនៅតែមានការភាន់ ភ្នែក យល់ច្រឡំនៅឡើយ។ ហេតុដូច្នេះ ក្នុងការដើរតាមផ្លូវ ទៅកាន់ពន្លឺត្រាស់ដឹង យើងមិនត្រូវគិតតែពីឈោងចាប់យក ពន្លឺនេះទេ ហើយបើយើងបានទៅដល់ពន្លឺនេះហើយ យើង មិនត្រូវនៅបង្អែបង្អង់វិលវល់ក្នុងពន្លឺនោះទេ។

បានសម្រេចការត្រាស់ដឹងតាមរបៀបនេះ បានន័យថា វត្ថុ ទាំងឡាយវាក្លាយែងចាំងឡើងដោយខ្លួនឯង។ ហេតុដូច្នេះ យើង ត្រូវដើរតាមផ្លូវទៅកាន់ពន្លឺត្រាស់ដឹងរហូត លុះត្រាតែតណ្ហា លោកិយ និងពន្លឺត្រាស់ដឹង វាឡើងមានភាពដូចគ្នាសុទ្ធសាធ នៅក្នុងគតិអារម្មណ៍របស់យើង។

4. សេចក្ដីយល់ឃើញចំពោះឯកភាពសាកលនេះ គឺថាវត្ថុទាំងឡាយក្នុងសភាពជាសារខ្លឹមរបស់វា គ្មានសញ្ញាអ្វីជាសម្គាល់ទេៈ នេះគេហៅថា «ដំណើរទទេ» ឬសុញ្ញាភាព។ សុ-ញ្ញាភាព បានន័យថា គ្មានសារជាតិ ភាពគ្មានកើត គ្មានសភាពជារបស់ខ្លួន គ្មានទ្វិកភាព ឬភាពពីរខុសគ្នា។ ព្រោះតែវត្ថុទាំងឡាយគ្មានរូបរាង គ្មានលក្ខណៈនៅក្នុងខ្លួនឯងផ្ទាល់នោះហើយ គេអាចនិយាយបានថា វត្ថុទាំងនោះមិនកើតឡើង ឬវិនាសបាត់ទៅទេ។ ក្នុងភាពជាសារវន្តសំខាន់នៃវត្ថុទាំងឡាយ គ្មានអ្វីដែលអាចឲ្យធ្វើការវែកញែកបានទេដូច្នេះហើយបានជាយើងអាចថា វត្ថុទាំងឡាយគ្មានសារជាតិទេ។

ដូចបានដោបញ្ជាក់មកហើយ វត្ថុទាំងអស់កើតឡើងនិងវិនាសទៅ ដោយសារតែការជួបប្រទះគ្នានៃហេតុនិងល័ក្ខខ័ណ្ឌ។ គ្មានអ្វីដែលឋិតនៅដោយឯកច្ឆ័ន្ទទាំងស្រុងទេ។ វត្ថុនីមួយៗទាក់ទងនិងវត្ថុដទៃទៀតជានិច្ច។

កន្លែងណាមានពន្លឺ វាក៏មានភាពងងឹតដែរ។ កន្លែងណាមានភាពវែង វាក៏មានភាពខ្លីដែរ។ កន្លែងណាមានពណ៌ស វា

ក៏មានពណ៌ខ្មៅដែរ។ ដូចគ្នានេះ ដោយសភាពរបស់ខ្លួនផ្ទាល់នៃវត្ថុទាំងឡាយ មិនមានឋិតនៅដោយឯកឯងទេ នោះ គេអាចថា វត្ថុទាំងឡាយគ្មានសារជាតិទេ។

យោលទៅតាមការពិចារណាដូចគ្នានេះ ពន្លឺត្រាស់ដឹងមិនអាចឋិតមានបាន ដោយឥតមានសេចក្តីល្ងង់ខ្លៅនោះទេ សេចក្តីល្ងង់ខ្លៅ ក៏មិនឋិតមានបានដោយឥតមានពន្លឺត្រាស់ញាណនោះដែរ។ បើវត្ថុទាំងឡាយ ក្នុងសភាពជាសារវន្តរបស់វា មិនខុសគ្នាទេនោះ តើអាចមានទ្វិកភាព ឬភាពពីរខុសគ្នាដែរឬទេ?។

5. មនុស្សលោកគិតថា ខ្លួនឯងនេះ ត្រូវបានចងជាប់ជាមួយនឹងការកើតហើយនិងការស្លាប់។ តែការយល់របៀបនេះមិនអនុលោមទៅតាមសេចក្តីពិតទេ។

កាលណាគេអាចយល់ជាក់នូវសេចក្តីពិតនេះ គេនឹងយល់ច្បាស់អំពីដំណើរគ្មានភាពពីរខុសគ្នា ចំពោះការកើតនិងការស្លាប់នេះ។

ព្រោះតែបុគ្គលរាល់រូបរក្សាទុកនូវគំនិតជារបស់អញ

បានជាបុគ្គលទាំងនោះមានគំនិតគិតនិយមថា ជារបស់ផងខ្លួន។ ប៉ុន្តែ ដោយហេតុតែគ្មានអ្វីដែលជាអាត្មាអញទេនោះ គ្មានអ្វីដែលអាចចាត់ទុកជារបស់អាត្មាអញបានទេ។ កាលណាគេអាចយល់ជាក់នូវសេចក្តីពិតនេះ គេនឹងអាចយល់ជាក់នូវដំណើរគ្មានភាពពីរខុសគ្នា។

មនុស្សលោកជាប់ចិត្តនឹងការវែកញែកភាពបរិសុទ្ធ និងភាពមិនបរិសុទ្ធ តែក្នុងធម្មជាតិវត្ថុ ការវែកញែករបៀបនេះគ្មានទេ។ ការវែកញែកនេះ កើតមកអំពីការរមិលយល់ខុស និងមិនទំនង ដែលមាននៅក្នុងចិត្តមនុស្សលោកតែប៉ុណ្ណោះ។

របៀបដូចគ្នានេះ មនុស្សលោកវែកញែកសម្គាល់នូវភាពអាក្រក់និងភាពល្អ តែភាពអាក្រក់និងភាពល្អនេះមិនឋិតនៅដោយឯកឯងដាច់ស្រឡះពីគ្នាទេ។ បុគ្គលដែលដើរតាមផ្លូវទៅកាន់ពន្លឺត្រាស់ដឹង យល់ច្បាស់ថា ភាពពីរខុសគ្នាយ៉ាងនេះគ្មានទេ។ ហើយដោយសារហេតុនេះ បុគ្គលនោះមិនសរសើរភាពល្អ ហើយមិនដាក់ទោសភាពអាក្រក់ទេ មិនមើលងាយភាពល្អ ហើយបេះអត់ឱនចំពោះភាពអាក្រក់។

ជាធម្មតា មនុស្សលោកខ្លាចទុក្ខវេទនា ហើយប្រាថ្នាចង់បានសុភមង្គល។ តែបើពិនិត្យការវែកញែកនេះឲ្យហ្មត់ចត់ទៅឃើញថា ជួនកាលទុក្ខវេទនានាំឲ្យមានសុភមង្គល ហើយជួនកាលទៀត សុភមង្គលនាំឲ្យមានទុក្ខវេទនា។ បណ្ឌិតហាត់រៀនឲ្យចេះសម្របនឹងកាលៈទេសៈផ្លាស់ប្តូរនៃជីវិត ដោយសតិអារម្មណ៍ស្មើ មិនរំភើបនឹងជោគជ័យ មិនស្រយុត នឹងបរាជ័យ។ យ៉ាងនេះហើយដែលបណ្ឌិតយល់ជាក់នូវដំណើរគ្មានភាព២ ខុសគ្នា ឬទ្វិកភាព។

ហេតុដូច្នេះ ពាក្យថ្លែងអំពីភាពពីរខុសគ្នា ដូចជាបិតមាននៅ និងគ្មានបិតនៅ តណ្ហាលោកិយនិងការចេះដឹងពិតប្រាកដបរិសុទ្ធនិងមិនបរិសុទ្ធ ល្អនិងអាក្រក់ ជាដើម សុទ្ធតែពាក្យផ្ទុយគ្នា ដែលមាននៅក្នុងគំនិតបុគ្គលម្នាក់ៗ តែប៉ុណ្ណោះវាពុំបានជាពាក្យដែលថ្លែងនូវសភាពពិតនោះទេ។ កាលណាគេផ្តាច់ផុតពីពាក្យទាំងនេះ ហើយនិងពីចិត្តរំជួលដែលកើតមានឡើងនោះបាន គេនឹងយល់ជាក់នូវដំណើរពិតជាសាកលនៃភាពទទេសូន្យ ដែលហៅថា សុញ្ញាភាព។

6. ដូចជាផ្កាឈូកដែលបរិសុទ្ធ និងប្រកបដោយក្លិនក្រអូប ឈ្ងុយឈ្ងប់ មិនដុះនៅក្នុងទីវាលរាបស្មើខ្ពស់ល្អនោះទេ វាទៅដុះនៅក្នុងទីទំនាបបឹងភក់ឯនោះទៅវិញ។ ពន្លឺត្រាស់ដឹងដ៏បរិសុទ្ធ ដែលជាសភាពព្រះពុទ្ធ ក៏សាចចេញឡើងពីពំនូកលាមកនៃតណ្ហាលោកិយយ៉ាងនេះដែរ។ សូម្បីតែការយល់ខុសនិងការភាន់ភ្នែក ដែលកើតឡើងពីតណ្ហាលោកិយ ក៏អាចទៅជាគ្រាប់ពូជនៃសភាពព្រះពុទ្ធដែរ។

បើអ្នកមុជវារកត្បូងគជ់ចង់រកឲ្យឃើញនូវត្បូងគជ់ អ្នកនោះត្រូវតែមុជចុះឲ្យដល់បាតសមុទ្រ ដោយមិនខ្លាចញញើតនឹងផ្កាថ្មស្រួចរលែមៗ និងសត្វឆ្លាមឃោរឃៅ។ ដូច្នេះមនុស្សលោកត្រូវតែប្រឈមមុខប្រឆាំងនឹងគ្រោះថ្នាក់ នៃតណ្ហាលោកិយ បើសិនជាប្រាថ្នាចង់បានគជ់ដ៏មានតម្លៃនៃពន្លឺត្រាស់ដឹង។ ជាដំបូង បុគ្គលតែងតែវង្វេងក្នុងភ្នំដែលប្រកបដោយផ្ទាំងថ្មខ្ពស់ចោតនៃអត្តទត្តភាព និងអភិមានះ មុននឹងភ្ញាក់គំនិត គិតចង់ស្វែងរកផ្លូវទៅកាន់ពន្លឺត្រាស់ដឹង។

មានបុរាណនិទានមួយថា មានតាបសមួយអង្គ ដោយចង់រកឲ្យឃើញផ្លូវពិតប្រាកដខ្លាំងពេក តាបសនោះវារឡើង

លើភ្នំមួយ មានផ្ទាំងថ្មច្រូងច្រាង ស្រួចៗ ដូចមុខលំពែងហើយ លោតទម្លាក់ខ្លួនទៅក្នុងភ្នក់ភ្លើងឆេះសន្ធោសន្ធៅ អត់ធ្មត់នឹងគ្រោះថ្នាក់គ្រប់បែបយ៉ាង ដោយសារតែមានបំណងដ៏មុតមាំនោះ។ តាបសឥសីប្រឈមមុខតស៊ូនឹងគ្រោះថ្នាក់គ្រប់បែបយ៉ាងនៃផ្លូវ ក៏បានជួបប្រទះ នឹងខ្យល់ត្រជាក់រំភើយនៅលើភ្នំដែលពោរពេញទៅដោយថ្មស្រួចៗ មុខដូចលំពែងនៃអត្ត-ទត្តភាព ហើយនឹងភ្នក់ភ្លើងនៃទោសៈ ហើយទីបំផុតតាបសនោះក៏បានយល់ជាក់ថា អត្តទត្តភាពនិងតណ្ហាលោកិយ ដែលបានខំតស៊ូទទួលរងនោះហើយ ជាពន្លឺត្រាស់ដឹង។

7. សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ នាំយើងទៅកាន់ភាពគ្មានពីរខុសគ្នា ហើយនិងនាំយើងឲ្យចេញផុតពីគំនិតវែកញែកតាមភាពពីរខុសគ្នា។ ជាកំហុសមួយដែលខំរិះរកវត្ថុដែលស្មានថាល្អនិងពិត ហើយរត់គេចពីវត្ថុ ដែលស្មានថាអាក្រក់និងមិនពិត។

បើខំតែទទូចថា អ្វីៗទាំងអស់វាទទេ និងមិនឋិតថេរនោះក៏ជាការយល់ច្រឡំដ៏ធំ ដូចជាទទូចគិតថា អ្វីៗទាំងអស់វាមិន

ចេះប្រែប្រួលដែរ។ បុគ្គលណាជាប់ចិត្តជឿថា មានអាត្មាអញ ជាការយល់ច្រឡំមួយ ព្រោះការជំពាក់ចិត្តលុះក្នុងជំនឿបែប នេះ និងនាំឲ្យបុគ្គលនោះចៀសពុំផុតពីសេចក្ដីលោភលន់ មិនចេះឆ្អែតឆ្អន់ ហើយទីបំផុតចៀសពុំផុតពីទុក្ខវេទនានោះ បានទេ។ តែបើបុគ្គលនោះមានជំនឿថា គ្មានអាត្មាអញក៏ជា ការភាន់ច្រឡំមួយដែរ ពីព្រោះការជឿរបៀបនេះ នាំឲ្យការខំ ស្វែងប្រតិបត្តិតាមគន្លងការពិតថ្លៃថ្លានោះ ឲ្យទៅជាការឥត ប្រយោជន៍។ បើការទទួចអះអាងថា អ្វីៗទាំងអស់សុទ្ធតែជា ទុក្ខ ក៏ជាកំហុសមួយ ឬថាអ្វីៗទាំងអស់សុទ្ធតែជាសុភមង្គល ក៏ ជាកំហុសមួយដែរ។ ព្រះពុទ្ធបង្ហាត់បង្ហាញយើងឲ្យប្រកាន់ យកនូវផ្លូវកណ្ដាល ដែលចាកផុតអំពីការវិនិច្ឆ័យហួសហេតុ ផុយគ្នាទាំងពីរនេះ ហើយដែលរំលាយ ទ្វិកភាពឬភាពពីរ ខុសគ្នា ឲ្យចូលគ្នាជាភាពតែមួយ៕

ចំពូកទី ៣

សភាពព្រះពុទ្ធ

I

ចិត្តបរិសុទ្ធ

1. *មនុស្សលោកមានចិត្តគំនិតផ្សេងៗគ្នា។ ខ្លះជាបណ្ឌិត ខ្លះជាពាល ខ្លះមានកិរិយាល្អប្រពៃ ខ្លះមានចរិតអាក្រក់ជួរជាតិ ខ្លះស្លូតសុភាព ខ្លះកាចឃោរឃៅ ខ្លះមានចិត្តបរិសុទ្ធ ខ្លះមានចិត្តប្រកបដោយមន្ទិលសៅហ្មង។ ប៉ុន្តែភាពខុសគ្នាទាំងនេះមិនជាសំខាន់ប៉ុន្មានទេ បើគិតទៅដល់ការបានសម្រេចការត្រាស់ដឹង។ លោកនេះប្រៀបបាននឹងបឹងឈូកមួយ ដែលមានរុក្ខជាតិជាច្រើនបែបយ៉ាងដុះពាលពេញ។ មានផ្កាប្រកបដោយពណ៌ផ្សេងៗគ្នា ផ្កាខ្លះមានពណ៌ស ខ្លះមានពណ៌ផ្កាឈូក ខ្លះខៀវ ខ្លះទៀតលឿង ផ្កាខ្លះរីកនៅក្នុងទឹក រុក្ខជាតិខ្លះមានស្លឹកដុះឡើងនៅព្រៀបនឹងផ្ទៃទឹក រុក្ខជាតិខ្លះទៀតមានស្លឹកដុះឡើងផុតពីទឹក។ មនុស្សជាតិរឹតតែមានភាពខុស*

គ្នាច្រើនជាងនេះទៅទៀត។ មនុស្សជាតិក៏មានភេទខុសគ្នាដែរ តែនេះមិនជាសំខាន់ទេ ពីព្រោះថាតាមការហាត់ហ្វឹកហ្វឺនល្អ ស្ត្រីភេទក៏អាចទៅដល់ពន្លឺត្រាស់ដឹងបានដូចបុរស-ភេទដែរ។

ដើម្បីនឹងឲ្យបានទៅជាហ្មដំរីចំណានម្នាក់ ត្រូវតែមានលក្ខណៈសម្បត្តិប្រាំយ៉ាងគឺៈ សុខភាពល្អ១ សេចក្ដីទុកចិត្តលើខ្លួនឯង១ សេចក្ដីវៀសវៃ១ បំណងស្មោះត្រង់ក្នុងខ្លួន១ និងព្រហ្មចារិភាព១។ ដើម្បីប្រតិបត្តិតាមផ្លូវប្រសើរខ្ពង់ខ្ពស់នៃពន្លឺត្រាស់ដឹង ដែលព្រះពុទ្ធបានបង្ហាញប្រាប់ ត្រូវតែមានលក្ខណៈសម្បត្តិដូចគ្នានេះដែរ។ បើមានលក្ខណៈសម្បត្តិទាំងនេះហើយ ទោះបីជាបុរសភេទក្ដី ឬស្ត្រីភេទក្ដី ក៏អាចទៅដល់ពន្លឺត្រាស់ដឹងបានដែរ។ ជាចាំបាច់ ត្រូវតែហាត់រៀនតាមសេចក្ដីទូន្មានរបស់ព្រះពុទ្ធកុំបង្អែបង្អង់ឡើយ ពីព្រោះមនុស្សលោកមានសភាពមួយ ដែលអាចនាំឲ្យបានសម្រេចនូវពន្លឺត្រាស់ដឹង។

2. កាលណាគេប្រតិបត្តិតាមផ្លូវពន្លឺត្រាស់ដឹង គេនឹងឃើញព្រះពុទ្ធយ៉ាងប្រាកដនឹងភ្នែករបស់គេ ហើយគេនឹងជឿប្រាកដ

លើព្រះអង្គនៅក្នុងចិត្តរបស់គេផ្ទាល់។ ភ្នែកដែលមើលឃើញព្រះពុទ្ធ និងចិត្តដែលជឿលើព្រះអង្គ គឺពិតជាភ្នែក និងចិត្តរបស់បុគ្គលដែលកំពុងវង្វេងវិលវល់នឹងការកើត និងការស្លាប់នៃលោកនេះឯង។

បើព្រះមហាក្សត្រមួយព្រះអង្គត្រូវមានកង្វល់នឹងចោរខ្មួយ ព្រះមហាក្សត្រនោះ ត្រូវតែរកឲ្យឃើញជំរំនៃពពួកចោរខ្មួយទាំងនោះ មុននឹងវាយប្រហារវា។ យ៉ាងណាមិញ បើបុគ្គលណាត្រូវឡោមព័ទ្ធដោយតណ្ហាលោកិយ បុគ្គលនោះជាដំបូងបង្អស់ ត្រូវតែរិះគិតសម្គាល់រកឲ្យឃើញច្បាស់នូវឫសគល់នៃតណ្ហាទាំងនោះដូច្នោះដែរ។

ជនម្នាក់នៅក្នុងផ្ទះមួយ កាលណាបើកភ្នែកឡើងជាដំបូង ជននោះសម្គាល់ឃើញអ្វីៗ ដែលមាននៅក្នុងបន្ទប់ មុននឹងក្រឡេកទៅតាមបង្អួច ហើយសម្គាល់មើលអ្វីៗ ដែលមាននៅខាងក្រៅ។ ដូចគ្នានេះ យើងមិនត្រូវបើកភ្នែកទៅក្រឡេកមើលអ្វីៗ ដែលនៅខាងក្រៅ មុននឹងយើងបានក្រឡេកមើលអ្វីៗ ដែលមាននៅក្នុងខ្លួនយើងនោះឡើយ។

បើប្រសិនជាមានវិញ្ញាណនៅក្នុងរូបកាយ វិញ្ញាណត្រូវ

តែស្គាល់ជាបឋម អ្វីៗដែលមាននៅក្នុងរូបកាយ។ ប៉ុន្តែជាធម្មតា មនុស្សលោករវល់តែនឹងអ្វីៗ ដែលមាននៅជាខាងក្រៅ ហើយយកចិត្តទុកដាក់ដោយតិចតួចស្ដួចស្ដើងណាស់នឹងអ្វីៗ ដែលមាននៅក្នុងរូបកាយរបស់ខ្លួន។

បើប្រសិនជាវិញ្ញាណវាស្ថិតនៅខាងក្រៅរូបកាយតើវិញ្ញាណនោះ អាចរក្សាការទាក់ទងជាមួយនឹងសេចក្ដីត្រូវការនៃរូបកាយបានយ៉ាងដូចម្ដេចទៅ? តែតាមពិតរូបកាយយល់នូវអ្វីៗ ដែលវិញ្ញាណដឹង ហើយវិញ្ញាណក៏ដឹងនូវអ្វីៗ ដែលរូបកាយយល់ដែរ។ ដូច្នេះ គេមិនអាចថា វិញ្ញាណនៅខាងក្រៅរូបកាយបានទេ។ តើសារជាតិនៃវិញ្ញាណ វាស្ថិតនៅកន្លែងណាទៅ ? ។

3. តាំងពីអតីតកាលដ៏យូរអង្វែងរកថាមិនបានមកហើយ សត្វលោកត្រូវបានវង្វេងវិលវល់នៅក្នុងសេចក្ដីល្ងង់ខ្លៅ ដោយសារតែការសម្រេចទៅតាមអំពើផ្ទាល់របស់ខ្លួន ហើយនិងយល់ច្រឡំចំពោះសេចក្ដីជាគោលពីរប្រការ ដូចតទៅនេះ។

ជាបឋម សត្វលោកជឿថា គំនិតវែកញែក ដែលជាឫស

គល់នៃជីវិតកើតនិងស្លាប់នេះ ជាសភាពពិតរបស់ខ្លួន។ ទីពីរ សត្វលោកមិនបានដឹងថា គឺនៅក្នុងគំនិតវែកញែកនោះហើយ ដែលវិញ្ញាណបរិសុទ្ធនៃពន្លឺត្រាស់ដឹង ដែលជាសភាពពិតរបស់ខ្លួនពួននៅ។

កាលណាគេក្តាប់ដៃហើយលើឡើង ភ្នែករបស់គេមើលឃើញការក្តាប់ដៃនេះ ហើយវិញ្ញាណរបស់គេសម្គាល់ឃើញការក្តាប់ដៃនេះ។ តែវិញ្ញាណដែលធ្វើការវែកញែកសម្គាល់ឃើញការក្តាប់ដៃនេះ មិនមែនជាវិញ្ញាណពិតប្រាកដទេ។

គំនិតវែកញែក គឺសម្រាប់សម្គាល់មើលភាពខុសគ្នាតាមការស្រមៃឃើញ ដែលចំណង់លោភលន់ហើយនិងតណ្ហាឯទៀតៗ ដែលទាក់ទងនឹងអាត្មាអញនិយមបានបង្កបង្កើតឡើងតែប៉ុណ្ណោះ។ គំនិតវែកញែក សម្រេចទៅតាមហេតុ និងល័ក្ខ-ខ័ណ្ឌ វាគ្មានអ្វីជាសារជាតិទេ វាប្រែប្រួលជានិច្ច។ តែដោយមនុស្សលោកជឿថា នេះហើយជាវិញ្ញាណពិតរបស់ខ្លួនសេចក្តីយល់ខុស ក៏នាំឲ្យមនុស្សលោកលុះក្នុងអំណាចនៃហេតុ និងល័ក្ខខ័ណ្ឌដែលនាំទៅរកក្តីទុក្ខ។

បុគ្គលម្នាក់លាដៃឡើង ហើយវិញ្ញាណរបស់គេដឹងនូវ

ការលាដៃនេះ។ តែអ្វីដែលកម្រើក? វិញ្ញាណឬដៃ? ឬក៏អត់កម្រើកទាំងពីរ? បើថា ដៃវាកម្រើក វិញ្ញាណក៏វាកម្រើកទៅតាមនោះដែរ។ ប៉ុន្តែបើថាវាអត់កម្រើកទាំងពីរក៏ត្រូវដែរ។ ប៉ុន្តែ វិញ្ញាណដែលកម្រើក គឺជាភាពសើខាងក្រៅនៃវិញ្ញាណតែប៉ុណ្ណោះ មិនមែនជាវិញ្ញាណពិតប្រាកដជាគ្រឹះនោះទេ។

4. ជាគ្រឹះសំខាន់ វិញ្ញាណរបស់បុគ្គលរាល់រូបវាបរិសុទ្ធ ប៉ុន្តែជាធម្មតា វិញ្ញាណនោះប្រឡាក់ជាប់ដោយល្អងធូលីតណ្ហាលោកិយ ដែលកកើតឡើងដោយទំនើងពីទេសកាលផ្សេងៗរបស់ខ្លួន។ វិញ្ញាណមិនបរិសុទ្ធ មិនមែនជាធម្មជាតិសំខាន់នៃបុគ្គលម្នាក់ៗទេ: ពិតជាមានវត្ថុអ្វីមួយជាបន្ថែមនៅក្នុងវិញ្ញាណនោះ ប្រៀបដូចជាអ្នកដែលចូលទៅក្នុងផ្ទះគេដោយបំពាន ឬភ្ញៀវដែលចូលទៅក្នុងផ្ទះមួយ អ្នកនោះមិនមែនជាម្ចាស់ផ្ទះនោះទេ។

ព្រះចន្ទត្រូវបានគ្របដណ្ដប់ទៅដោយពពក ជាញឹកញយតែមិនបានប្រែក្លាយដោយសារពពកនោះទេ: ភាពបរិសុទ្ធ

របស់ព្រះចន្ទនៅតែដដែល។ ដូច្នេះ មិនត្រូវយល់ច្រឡំ ដោយគិតថា វិញ្ញាណមិនបរិសុទ្ធនោះជាវិញ្ញាណពិតប្រាកដរបស់ខ្លួនផ្ទាល់នោះឡើយ។

បុគ្គលត្រូវតែរំលឹករឿងនេះឡើងកុំបីឈប់ឈរ ហើយដាស់តឿនបំភ្លឺសតិរបស់ខ្លួនជានិច្ច ព្រោះទៅរកពន្លឺត្រាស់ដឹងដែលបរិសុទ្ធ និងដែលមិនចេះប្រែប្រួល។ ដោយហេតុតែទទួលរងនូវវិញ្ញាណមិនបរិសុទ្ធនិងប្រែប្រួល ដោយហេតុតែយល់ច្រឡំតាមដោយគំនិតខុសរបស់ខ្លួន បានជាបុគ្គលវង្វេងវិលវល់ទៅក្នុងលោកដែលប្រកបទៅដោយការថ្លឹនភ្លែកនេះ។

សេចក្ដីខ្វល់ និងសេចក្ដីសៅហ្មងនៃវិញ្ញាណមនុស្សលោកមកអំពីចំណង់លោភលន់ ហើយនិងប្រតិកម្មចំពោះទេស-កាលដែលប្រែប្រួលជានិច្ច។

វិញ្ញាណដែលមិនរឹករវនឹងវត្ថុទាំងឡាយ ដែលកើតមានឡើងចំពោះមុខ វិញ្ញាណដែលនៅបរិសុទ្ធ និងស្ងប់ចំពោះគ្រប់ទេសកាល គឺវិញ្ញាណនោះហើយដែលពិត ដែលជាម្ចាស់។

គេមិនអាចនិយាយថា ភោជនីយដ្ឋានបាត់រូបទៅដោយសារតែលែងមានអ្នកដំណើរ នោះបានទេ។ ដូចគ្នានេះ គេមិន

អាចថា អាត្ម័នពិតប្រាកដ បាត់រូបទៅដោយសារតែវិញ្ញាណ ប្រឡាក់ជាប់ដោយមន្ទិល ដែលកើតឡើងអំពីទេសៈកាលៈ ប្រែប្រួលនៃជីវិត វិនាសបាត់ទៅនោះបានទេ។ វិញ្ញាណមនុស្ស លោក ដែលប្រែប្រួលទៅតាមដំណើរប្រែប្រួលនៃទេសកាល មិនមែនជាសភាពពិតប្រាកដនៃវិញ្ញាណមែនទែនទេ។

5. បើយើងគិតទៅដល់រោងជំនុំមួយ ដែលភ្លឺព្រោងព្រាត ឡើងនៅពេលព្រះអាទិត្យរះ ហើយងងឹតទៅវិញនៅពេល ព្រះអាទិត្យលិចបាត់ទៅ។

យើងអាចគិតឃើញថា ពន្លឺដើរតាមព្រះអាទិត្យ ហើយ ភាពងងឹតមកតាមរាត្រីកាល តែយើងមិនអាចថា កម្លាំងដែល បណ្ដាលឲ្យយល់នូវភាពភ្លឺ និងភាពងងឹតនោះ វាដើរទៅតាម អ្វី ឬវិលត្រឡប់ទៅកាន់កន្លែងណាមួយនោះបានទេ។ ញាណ សតិ ឬកម្លាំងសតិអារម្មណ៍ ដែលនាំឲ្យយល់នូវភាពភ្លឺ និង ភាពងងឹតនេះ មិនត្រឡប់ទៅទីណាក្រៅពីស្ថិតនៅក្នុងសភាព ពិតរបស់វា គឺសភាពជាគ្រឹះសំខាន់នៃវិញ្ញាណនោះទេ។

ការសម្គាល់ឃើញថា ពេលថ្ងៃកាលណាព្រះអាទិត្យរះ

ឡើង ហើយនិងពេលយប់កាលណាព្រះអាទិត្យលិចបាត់ទៅ នេះជាការកត់សម្គាល់ក្នុងរយៈពេលនៃវិញ្ញាណ ជាបណ្ដោះអាសន្នតែប៉ុណ្ណោះ។

គឺស្ថានភាពវិញ្ញាណជាបណ្ដោះអាសន្ននេះហើយ ដែលផ្លាស់ប្ដូរប្រែប្រួលពីពេលមួយទៅមួយ តាមទេសៈកាលៈជីវិត នេះមិនមែនជាវិញ្ញាណពិតប្រាកដទេ។ វិញ្ញាណដែលជាគ្រឹះនិងពិតប្រាកដនោះ គឺជាវិញ្ញាណដែលយល់ជាក់នូវភាពភ្លឺនិងភាពងងឹត នេះហើយជាសភាពពិតនៃវិញ្ញាណ។

ការមានអារម្មណ៍ក្នុងមួយរយៈពេល ទៅលើភាពល្អនិងភាពអាក្រក់ ទៅលើការស្រឡាញ់និងការស្អប់ ដែលកើតមានឡើង និងវិនាសទៅវិញ ដោយសារហេតុផ្សេងៗជាខាងក្រៅនោះ គ្រាន់តែជាប្រតិកម្មក្នុងមួយរយៈពេល ដែលកើតមានឡើងអំពីវិញ្ញាណមនុស្សលោក ដែលប្រឡាក់ជាប់នូវល្អងធូលីនិងមន្ទិលផ្សេងៗ។

សភាពពិតរបស់វិញ្ញាណ វាបរិសុទ្ធតាំងអំពីដើមកំណើតមក។ ថ្វីបើវាត្រូវបានពាសព័ទ្ធទៅដោយធូលីនៃតណ្ហាលោកិយ សភាពពិតជាសារខ្លឹមរបស់វិញ្ញាណនោះគ្មានមន្ទិលអ្វីទេ។

បើគេដាក់ទឹកក្នុងផើងមានរាងមូល ទឹកនោះក៏ឡើងជាមូល។ បើគេដាក់ទឹកក្នុងផើងមានរាងបួនជ្រុង ទឹកនោះនឹងទៅជារាងបួនជ្រុង។ តាមពិត ទឹកមិនមានរាងមូល ឬរាងបួនជ្រុងទេ តែមនុស្សលោកភ្លេចគិតថា ទឹកឥតរាងរៅ ក៏បណ្ដោយឲ្យសតិយល់ប្រទាំទៅលើរាងរៅទឹកក្នុងផើងនោះ។

មនុស្សយល់ឃើញថា នេះល្អនោះអាក្រក់ នឹកគិតស្រឡាញ់នេះហើយស្អប់នោះ ធ្វើការវែកញែកអំពីរឿងពិតមាននៅ និងគ្មានពិតនៅ។ ដោយសារហេតុនេះ មនុស្សលោកជាប់ជំពាក់ចិត្ត នឹងសភាពជាខាងក្រៅ ហើយក៏ត្រូវតែទទួលទុក្ខដោយសារសភាពជាខាងក្រៅទាំងនេះ។

បើសិនជាមនុស្សលោកអាចរំដោះខ្លួនឲ្យផុតពីការជំពាក់ចិត្តទៅលើសភាពជាខាងក្រៅទាំងនេះបាន ហើយអាចរកឃើញវិញនូវភាពបរិសុទ្ធនៃវិញ្ញាណដើមរបស់ខ្លួន រូបកាយព្រមទាំងវិញ្ញាណនៃមនុស្សលោកទាំងនោះ នឹងបានចាកផុតអំពីមន្ទិលសៅហ្មង និងទុក្ខព្រួយ ហើយនឹងបានស្គាល់តែសេចក្ដីសុខស្ងប់ជាទីបំផុត។

II

សភាពព្រះពុទ្ធ

1. វិញ្ញាណបរិសុទ្ធនិងពិតប្រាកដ ដែលយើងបានដាក់នាមថា វិញ្ញាណជាគ្រឹះ នោះហើយជាសភាពព្រះពុទ្ធ ជាគ្រាប់ពូជពុទ្ធសភាវៈ។

គេអាចបង្កើតភ្លើងបាន ដោយយកកែវហើមបញ្ចាំងរស្មីព្រះអាទិត្យទៅលើប៉ុយ តែភ្លើងនោះវាមកពីណា ? កែវហើមនៅឆ្ងាយក្រៃលែងពីព្រះអាទិត្យ តែប៉ុយអាចឆេះឡើងបានដោយសារកែវហើមនោះ។ ប៉ុន្តែបើប៉ុយនោះមិនមានភាពងាយឆេះទេ ប៉ុយនោះក៏មិនអាចនឹងឆេះបានដែរ។

ដូចគ្នានេះ ពន្លឺពុទ្ធញ្ញាណចាំងផ្ដុំទៅលើចិត្តបុគ្គល ហើយសភាពពិតនៃបុគ្គលនោះ ដែលជាពុទ្ធសភាវៈ នឹងមានពន្លឺចែងចាំងឡើង។ យ៉ាងនេះហើយ ដែលពន្លឺនោះចែងចាំងនៅក្នុងចិត្តសត្វលោក ហើយដាស់តឿនសត្វលោកទាំងនោះឲ្យមានជំនឿទៅលើព្រះពុទ្ធ។ ព្រះពុទ្ធកាន់កែវព្រហ្មចារិភាពបញ្ចាំងទៅគ្រប់នរជន ដូច្នេះ ជំនឿទុកចិត្តនៃគ្រប់នរជននឹងអាចភ្លឺរន្ទាលឡើងបាន។

2. មនុស្សលោកធ្វេសប្រហែសនឹងពុទ្ធញ្ញាណ ដែលជាសភាពពិតប្រាកដរបស់ខ្លួន បានជាមនុស្សលោកធ្លាក់ទៅក្នុងមណ្ឌលជាទីទុក្ខ ដោយសារតែត្រូវបានចងជាប់នឹងភាពល្អ និងភាពអាក្រក់ ដែលជាសម្បកក្រៅ ហើយត្រូវបានគ្របដណ្ដប់ជិតជុំទៅដោយធូលីតណ្ហា។

ចុះហេតុដូចម្ដេចបានជាមនុស្សលោក ដែលមានវិញ្ញាណជាសារៈខ្ទឹមនិងពិតប្រាកដយ៉ាងនេះហើយ នៅតែប្រតោងយិតយោងជាប់ជានិច្ចនឹងការមិលឃើញខុស ហើយធ្វើទុក្ខទោសខ្លួនឯង ដោយបណ្ដោយខ្លួនឲ្យវង្វេងនៅក្នុងលោកដែលពោរពេញទៅដោយការថ្លើនភ្នែក និងក្ដីទុក្ខ ទុកណាជានៅជិតខ្លួននោះមានពន្លឺព្រះពុទ្ធញ្ញាណក៏ដោយយ៉ាងនេះ?

កាលមួយនោះ មានបុរសម្នាក់ឆ្លុះពីខាងក្រោយកញ្ចក់ ហើយពុំបានឃើញក្បាលនិងមុខរបស់ខ្លួន ក៏ទៅជាឆ្កួតលេលា។ តើវាចាំបាច់ត្រូវតែបុរសម្នាក់នោះទៅជាឆ្កួតលេលា ដោយសារតែឆ្លុះកញ្ចក់ខុសទំនងតែប៉ុណ្ណោះដែរឬទេ?។

គឺពិតជាភ្លើ និងជាការឥតអំពើ ចំពោះបុគ្គលណាដែលកើតទុក្ខ នឹងការពុំបានទទួលពន្លឺការត្រាស់ញ្ញាណ ដែលខ្លួន

សង្ឃឹមថានឹងបានសម្រេចៗ កំហុសមិននៅលើពន្លឺញាណដឹង នោះទេៗ កំហុសវានៅត្រង់បុគ្គលទាំងឡាយតាំងពីយូរយារមក ហើយ បានខំស្វះស្វែងរកពន្លឺត្រាស់ដឹងនោះ តាមដោយគំនិត ប្រកាន់ការវែកញែក ដោយពុំបានគិតយល់ថា ការនេះវាពុំមែន ជាវិញ្ញាណពិតប្រាកដនោះទេ គ្រាន់តែជាវិញ្ញាណថ្លឹងថ្លែងដែល កើតឡើងដោយការប្រមូលផ្តុំចំណង់លោភលន់និងការសង្ឃឹម មិនសមហេតុផលទៅលើវិញ្ញាណពិតប្រាកដតែប៉ុណ្ណោះៗ

បើគំនិតយល់ខុសដែលគរឡើងជាគំនរនោះ វិនាសអស់ ទៅ ពន្លឺត្រាស់ដឹងនឹងចេញប្រាកដឡើងៗ ប៉ុន្តែជាការចម្លែក មួយ កាលណាសត្វលោកបានដល់នូវពន្លឺត្រាស់ដឹងនោះ ហើយទើបបានដឹងថា បើអត់គំនិតយល់ខុសទាំងនោះទេ ពន្លឺ ត្រាស់ដឹងក៏នឹងគ្មានដែរៗ

3. ពុទ្ធសភាវៈ មិនចេះវិនាសបាត់បង់ទេៗ ទោះបីមនុស្ស ឃោរឃៅទៅកើតជាសត្វធាតុ ជាអសុរកាយអត់ឃ្លាន ឬជា ប្រេតនរកក៏ដោយ បាបជនទាំងនោះមិនបាត់បង់ពុទ្ធសភាវៈ នេះទេៗ

ទោះបីជាកប់បាត់ទៅក្នុងភក់ជ្រាំកាមគុណ ឬកប់បាត់ទៅក្នុងឫសគល់តណ្ហាលោកិយ ឬត្រូវបានបំភ្លេចចោលក៏ដោយ សមត្ថភាពមនុស្សដែលអាចនឹងទៅជាព្រះពុទ្ធនោះមិនបាត់អស់រលីងឆេងទេ។

4. មានរឿងនិទានថា បុរសម្នាក់ដេកលក់យ៉ាងស្កប់ស្កល់។ មិត្តរបស់គាត់ម្នាក់ ស៊ូទ្រាំនៅដេកប្របក្បែរគាត់ រហូតដល់ពេលត្រូវតែចេញទៅចោលគាត់ដោយខានពុំបាន។ នៅពេលនោះ ដោយខ្លាចមិត្តរបស់ខ្លួនមានសេចក្តីត្រូវការជាចាំបាច់ គាត់ក៏លាក់ត្បូងរ័តន៍មួយគ្រាប់ក្នុងជាយសំពត់បុរសដេកលក់នោះ។ នៅពេលបុរសនោះភ្ញាក់ឡើង ហើយពុំបានដឹងថាមិត្តរបស់ខ្លួនលាក់ត្បូងរ័តន៍មួយគ្រាប់ក្នុងជាយសំពត់នោះ បុរសនោះរស់នៅក្នុងជីវភាពអនាថាក្ររហេមរហាម។ យូរក្រោយមកបុរសទាំងពីររូបនោះក៏បានជួបគ្នាវិញ។ បុរសជាមិត្តក៏ប្រាប់បុរសកំសត់នោះ អំពីរឿងត្បូងរ័តន៍ដែលបានលាក់ទុកឲ្យនោះ ហើយប្រែប្រាប់ឲ្យទៅតាមរកត្បូងនោះ។

ដូចជាបុរសដេកលក់ក្នុងរឿងនេះដែរ មនុស្សលោក

វង្វេងវង្វាន់នៅកណ្ដាលទីទុក្ខនៃការវិលកើតវិលស្លាប់ ឬវដ្ដ-ទុក្ខដោយពុំបានដឹងថា នៅក្នុងជម្រៅរបស់ខ្លួនផ្ទាល់ ដែលជាសភាពពិតបរិសុទ្ធ គ្មានមន្ទិលរបស់ខ្លួននោះ មានលាក់ទុកនូវត្បូងរ័តន៍ពុទ្ធសភាវៈ ដែលកាត់ថ្លៃពុំបាន។

ទោះបីមនុស្សលោកមិនបានដឹងថា ខ្លួនឯងម្នាក់ៗមានសភាវៈដ៏ប្រសើរបំផុតនេះក៏ដោយ ទោះបីមនុស្សលោកល្ងង់ខ្លៅពុករលួយយ៉ាងណាក៏ដោយ ព្រះពុទ្ធមិនអស់សេចក្ដីទុកចិត្តលើសត្វលោកទាំងនោះម្ដងណាទេ ពីព្រោះព្រះអង្គដឹងជាក់ថា គ្រប់មនុស្សលោកមានគុណសម្បត្តិជាពុទ្ធសភាវៈនេះ។

ហេតុដូច្នេះហើយ ព្រះពុទ្ធទ្រង់មានភក្ដីភាពដល់ជនទាំងឡាយដែលវង្វេងដោយសារសេចក្ដីល្ងង់ខ្លៅ ហើយមិនអាចនឹងមើលឃើញពុទ្ធសភាវៈរបស់ខ្លួនឯង។ ព្រះអង្គទ្រង់កម្ចាត់សេចក្ដីភាន់សតិឲ្យចេញឆ្ងាយអំពីជនទាំងនោះ ហើយទូន្មាននរជនទាំងនោះថា ជាដើមកំណើតឡើង វាគ្មានភាពខុសគ្នារវាងនរជនទាំងនោះនឹងព្រះពុទ្ធទេ។

5. ព្រះពុទ្ធជាសត្វលោកមួយរូបដែលបានសម្រេចពុទ្ធញាណ

សត្វលោកជម្មតា គឺជនដែលមានសមត្ថភាពអាចសម្រេចនូវពុទ្ធញាណ។ ភាពខុលគ្នាមានតែប៉ុណ្ណេះឯង។

ក៏ប៉ុន្តែ បើជនណានឹកស្មានថា ខ្លួនបានទៅដល់ពន្លឺត្រាស់ដឹង ជននោះយល់ច្រឡំហើយ ពីព្រោះថា ទុកណាជាជនរូបនោះតម្រង់ឆ្ពោះទៅរកពន្លឺត្រាស់ដឹងនោះក៏ដោយ ជនរូបនោះពុំទាន់បានសម្រេចជាព្រះពុទ្ធនៅឡើយទេ។

សភាពព្រះពុទ្ធមិនលេចឡើងទេ បើគ្មានការខិតខំប្រឹងប្រែងយ៉ាងស្វាហាប់ និងប្រកបដោយជំនឿស្មោះ។ កិច្ចប្រតិបត្តិនេះមិនចេះចប់ទេ ដរាបណាពុទ្ធញាណមិនទាន់លេចធ្លោឡើងនោះ។

6. មានកាលមួយនោះ ព្រះមហាក្សត្រមួយព្រះអង្គបានប្រជុំមនុស្សខ្វាក់ ឲ្យនៅជុំវិញដំរីសារមួយ។ ព្រះមហាក្សត្រសួរជនខ្វាក់ទាំងនោះថា ដំរីសារដូចជាអ្វីដែរ។ ជនខ្វាក់ទី១ដែលស្ទាបត្រូវភ្លុក ឆ្លើយថា ដំរីដូចជាមើមការ៉ុតធំមួយ។ ជនខ្វាក់ទី២ដែលស្ទាបត្រូវត្រចៀក ឆ្លើយថា ដំរីដូចជាផ្លិតធំមួយ។ ជនខ្វាក់ទី៣ ដែលស្ទាបត្រូវប្រមោយ ឆ្លើយថា ដំរីដូចជាអង្រែ

ជំមួយ។ ជនខ្វាក់ទី២ ស្ទាបត្រូវជើង ឆ្លើយឡើងថា ដំរីដូចជាកាំភ្លើងត្បាល់។ ជនខ្វាក់ទី៥ ជាជនចុងក្រោយគេ ស្ទាបត្រូវកន្ទុយក៏ឆ្លើយថា ដំរីដូចជាខ្សែព្ធួរជំមួយ។ គ្មានជនខ្វាក់ណាម្នាក់អាចទូលបញ្ជាក់ប្រាប់ព្រះមហាក្សត្រ អំពីរូបរាងពិតនៃដំរីសារនោះបានទេ។

ដូចគ្នានេះ គេអាចពិពណ៌នាអំពីធម្មជាតិមនុស្ស បានក្នុងភាគខ្លះៗ តែគ្មានជនណាម្នាក់អាចពិពណ៌នា អំពីសភាពពិតរបស់មនុស្ស ដែលជាពុទ្ធសភាវៈនោះបានទេ។

មានតែផ្លូវមួយគត់ ដែលអាចនាំឲ្យស្គាល់ភាពពិតប្រាកដរបស់មនុស្ស ដែលជាពុទ្ធសភាវៈ ដែលតណ្ហាពុំអាចរំខានបាន និងដែលការស្លាប់ពុំអាចបំផ្លាញបាន គឺតួអង្គព្រះពុទ្ធ ហើយនិងសេចក្ដីប្រៀនប្រដៅដ៏ប្រសើរឧត្ដមរបស់ព្រះអង្គ។

III

ភាពព្រះពុទ្ធ និងភាពជាអនត្តា

1. ដូចបាននិយាយមកហើយ សភាពព្រះពុទ្ធមិនអាចពិពណ៌នារៀបរាប់បានទេ។ ថ្វីបើហាក់ដូចជាមានសភាពដូចគ្នានឹង

ព្រលឹងនៃលទ្ធិសាសនាឯទៀតៗ ក៏ដោយ តែជាការមិនដូចគ្នាសោះតែម្តង។

ការជឿជាក់ទៅលើអត្តភាព ឬភាពជាអាត្មាអញ គឺជាការប្រឌិតឡើងនៃគំនិតវែកញែក ដែលជាដំបូងប្រកាន់យកភាពនោះ ហើយជាប់ចិត្តនិងភាពនោះ តែត្រូវតែលះបង់ភាពនោះទីបំផុត។ ផ្ទុយទៅវិញ សភាពព្រះពុទ្ធ ជាវត្ថុមិនអាចពិពណ៌នាបាន ដែលត្រូវតែរកឲ្យឃើញជាបឋម។ ក្នុងន័យមួយសភាពព្រះពុទ្ធប្រដូចបានទៅនឹងន័យថា អត្តភាព តែមិនមានន័យដូចគ្នានឹង «អាត្មាអញ» ឬ«របស់អញ»ទេ។

ការគិតថា មានអាត្មាអញជាឋិតថេរ ជាជំនឿភាន់ច្រឡំ ពីព្រោះយល់ស្មានថា មានឋិតនៅចំពោះវត្ថុដែលគ្មានឋិតនៅ។ ផ្ទុយទៅវិញ ការបដិសេធថា គ្មានសភាពព្រះពុទ្ធ ជាការយល់ខុស ពីព្រោះយល់ទៅលើវត្ថុ ដែលមានឋិតនៅថាគ្មានឋិតនៅទៅវិញ។

មានរឿងនិទានប្រៀបធៀបមួយថា មានមាតាម្នាក់ បីកូនឈឺទៅផ្ទះលោកគ្រូពេទ្យម្នាក់។ លោកគ្រូពេទ្យបានឲ្យថ្នាំកូននោះផឹក ហើយបញ្ជាម្តាយនោះថាកុំឲ្យកូនបៅដោះ ដរាប

ណាថ្នាំមិនទាន់រលាយចូលសព្វ។

ម្តាយក៏យកជាតិល្វីងម្យ៉ាងលាបដោះ ដើម្បីឲ្យកូនចៀសចេញពីដោះនោះ។ នៅពេលថ្នាំរលាយសព្វហើយ ម្តាយក៏លាងដោះឲ្យស្អាតហើយបំបៅដោះកូននោះទៅ។ ម្តាយធ្វើយ៉ាងនេះ គឺដោយសារតែមានសេចក្តីស្នេហាចំពោះបុត្ររបស់ខ្លួនតែប៉ុណ្ណោះ។

ដូចគ្នានេះ ព្រះពុទ្ធ ដោយមានបំណងកម្ចាត់ការភាន់ច្រឡំឲ្យអស់ពីក្នុងខ្លួនយើង ហើយបំបាត់ចោលនូវការជំពាក់ចិត្តទៅលើសភាពជាអាត្មាអញ ព្រះអង្គចាប់ផ្តើមឡើងដោយបដិសេធចោលនូវអត្តភាព ឬភាពជាអាត្មាអញ។ កាលណាការយល់ច្រឡំ និងការជំពាក់ចិត្តរបស់យើងវិនាសទៅអស់ហើយ ព្រះអង្គបង្ហាញប្រាប់យើងអំពីសភាពពិតប្រាកដរបស់យើង ពោលគឺ សភាពព្រះពុទ្ធ នោះឯង។

ការជំពាក់ចិត្តលើអាត្មាអញ នាំឆ្ពោះទៅកាន់ការភាន់ច្រឡំ ប៉ុន្តែការជឿចំពោះសភាពព្រះពុទ្ធ នឹងបានដល់នូវពន្លឺត្រាស់ដឹង។

ដូចជាស្ត្រីម្នាក់ ដែលបានទទួលហិបមួយជាកេរមរតក។

ដោយមិនបានដឹងថានៅក្នុងហិបនោះមានមាស ស្ត្រីនោះរស់នៅក្ររហេមរហាម រហូតដល់មានជនម្នាក់បើកហិបនោះឡើងហើយបង្ហាញមាសទៅគាត់។ ព្រះពុទ្ធក៏យ៉ាងនោះដែរ ព្រះអង្គបើកចិត្តសត្វលោក ហើយបង្ហាញប្រាប់នូវសភាពព្រះពុទ្ធដែលមាននៅក្នុងខ្លួននៃសត្វលោកទាំងនោះ។

2. បើបុគ្គលគ្រប់រូបមានសភាពព្រះពុទ្ធ ចុះហេតុម្តេចក៏បុគ្គលទាំងនោះបោកបញ្ឆោតប្រវញ្ចគ្នា ប្រព្រឹត្តអំពើអាក្រក់ឃោរឃៅកាប់សម្លាប់គ្នា បណ្តាលឲ្យមានទុក្ខព្រួយច្រើនរាប់មិនអស់យ៉ាងនេះ? ហើយចុះហេតុម្តេចក៏មនុស្សលោកមានភាពខុសគ្នាច្រើនម៉្លេះ តួយ៉ាងដូចជាអ្នកខ្លះមានទ្រព្យស្តុកស្តម្ភ អ្នកខ្លះក្ររហេមរហាម?

មានរឿងនិទានមួយថា មានអ្នកលេងចំបាប់ម្នាក់ មានទម្លាប់លំអថ្ងាសខ្លួននឹងត្បូងពេជ្រមួយគ្រាប់។ ថ្ងៃមួយនោះ ក្នុងពេលដែលគាត់កំពុងតែប្រយុទ្ធ ត្បូងពេជ្រក៏លិចចូលទៅក្នុងសាច់បាត់ទៅ។ គាត់ស្មានថាជ្រុះបាត់ត្បូងនោះ ហើយទៅរកលោកគ្រូពេទ្យវះកាត់ម្នាក់ឲ្យព្យាបាលមុខរបួស។ លោកគ្រូ

ពេទ្យវះកាត់បានឃើញត្បូងពេជ្រនៅក្នុងសាច់ លិចកប់ទៅក្នុងឈាមនិងវត្ថុអសោច។ លោកគ្រូពេទ្យយកកញ្ចក់មកឆ្លុះ បង្ហាញអ្នកលេងចំបាប់ក៏បានយល់ត្បូងពេជ្រជាលំដាប់នោះទៅ។

សភាពព្រះពុទ្ធដូចជាត្បូងពេជ្រនោះឯង សភាពព្រះពុទ្ធនោះ ត្រូវបានកប់បាត់ទៅក្នុងសំរាមធូលីកខ្វក់នៃការរមិលយល់ខុស ហើយម្នាក់ៗនឹកស្មានតែបាត់ទៅហើយ តែព្រះបរមគ្រូបានរកឃើញវិញយកមកឲ្យសត្វលោក។

សភាពព្រះពុទ្ធមាននៅក្នុងបុគ្គលរាល់រូប ទោះបីសភាពព្រះពុទ្ធនេះ ត្រូវបានកប់បាត់ទៅក្នុងជម្រៅសែនជ្រៅនៃអភិជ្ឈា ឬចំណង់លោភលន់ សេចក្តីក្រោធខឹង និងសេចក្តីឆ្កួតល្ងីល្ងើ ហើយជាបន្ថែមទៅទៀត ត្រូវបានចងជាប់និងកម្មផល។ ទោះបីយ៉ាងនេះក៏ដោយ ក៏សភាពព្រះពុទ្ធមិនវិនាសបាត់ទៅឯណាឡើយ។ បើគេបំបាត់ចោលឲ្យអស់នូវវត្ថុមិនបរិសុទ្ធទាំងឡាយបាន យូរនិងឆាប់គង់តែសភាពព្រះពុទ្ធនេះនឹងចេញឲ្យឃើញឡើងវិញទេ។

ដូចជាអ្នកលេងចំបាប់នៅក្នុងរឿងនិទានប្រៀបធៀបនេះ ដែលរកឃើញវិញនូវត្បូងពេជ្រ ដែលកប់បាត់ទៅក្នុងសាច់

និងឈាមដោយសារកញ្ចក់ សត្វលោករកសភាពព្រះពុទ្ធរបស់ខ្លួនដែលកប់បាត់ទៅក្នុងចំណង់លោកលន់ និងតណ្ហាឃើញវិញ ដោយសារពន្លឺត្រាស់ញាណរបស់ព្រះពុទ្ធ។

3. សភាពរបស់ព្រះ បរិសុទ្ធនិងស្ងប់ជានិច្ច ទោះបីសត្វលោកត្រូវបានលាយឡំច្របូកច្របល់នឹងទេសកាលដ៏ច្រើនរាប់មិនអស់យ៉ាងនេះក៏ដោយ។ ដូចជាទឹកដោះដែលមានពណ៌សស្គុសជានិច្ច ទោះបីគោនោះមានពណ៌ទង់ដែង ស ឬខ្មៅក៏ដោយ។ ដូចនេះហើយ សភាពព្រះពុទ្ធបរិសុទ្ធជានិច្ច ទោះបីលក្ខណៈរបស់សត្វលោក អំពើនិងផលរបស់សត្វលោក វាយ៉ាងណាក៏ដោយ។

មានរឿងមួយនិទានថា នៅក្នុងព្រៃភ្នំហិមពាន្តមានរុក្ខ-ជាតិថ្នាំពិសេសម្យ៉ាងដុះនៅកណ្តាលល្បាស់ស្មៅខ្ពស់ៗ។ គេបានស្វែងរករុក្ខជាតិថ្នាំនោះជាយូរមកហើយ តែពុំបានជួបប្រទះសោះ។ ថ្ងៃមួយ តាបសឥសីមួយអង្គបានរកឃើញដោយសារក្លិនក្រអូបផ្សព្វផ្សាយចេញពីរុក្ខជាតិនោះ។ តាបសឥសីបានយករុក្ខជាតិនោះទៅរក្សាទុកក្នុងផើងធំមួយ។ តែដល់តាបសឥសីនោះសុគតទៅ រុក្ខជាតិថ្នាំពិសេសនោះក៏កប់បាត់

កណ្ដាលព្រៃភ្នំ នៅក្នុងផើង ដែលមានទឹកឡើងស្អុយជូរមាន ក្លិនអាក្រក់ក្រៃពេក។

ដូចក្នុងរឿងនិទាននេះដែរ សភាពព្រះពុទ្ធកប់បាត់ក្នុង ល្បះស្មៅតណ្ហាសែនខ្ពស់ ដែលមនុស្សធម្មតាពិបាករកឃើញ ណាស់។ ព្រះពុទ្ធជាម្ចាស់ ព្រះអង្គបានកាប់ត្រាយល្បាស់ស្មៅ តណ្ហាហើយដកយកសភាពព្រះពុទ្ធ ដែលមានរសជាតិផ្អែម ស្រទន់អំពីកំណើតនោះ ចេញមកបង្ហាញសត្វលោក។ តែ សភាពព្រះពុទ្ធដែលមានរសជាតិផ្អែមស្រទន់តែមួយគត់នោះ ត្រូវបានផ្លាស់ប្ដូររសជាតិក្លិនផ្សេងៗ ទៅតាមចំណូលចិត្ត និង សមត្ថភាពរបស់បុគ្គលម្នាក់ៗ ដែលទទួលយក។

4. សភាពព្រះពុទ្ធដូចជាត្បូងពេជ្រ រឹងហើយមិនបេះរលួយ ពុកទេ។ ខ្សាច់ និងថ្មធម្មតា អាចផ្ទុះខ្ទេចខ្ទីទៅជាផង់ធូលីបាន ចំណែកពេជ្រ នៅជាប់ជានិច្ច។

រូបនិងវិញ្ញាណអាចវិនាសបាត់បង់ តែសភាពព្រះពុទ្ធមិន បាត់បង់ទេ។

សភាពព្រះពុទ្ធជាវត្ថុឧត្តមបំផុត ដែលមាននៅក្នុងមនុស្ស

ជាតិ។ គេទម្លាប់គិតថា ស្ត្រីទាបជាងបុរស តែតាមសាសនាព្រះពុទ្ធ មិនដូច្នោះទេ។ ជាសំខាន់គឺនៅត្រង់យល់និងស្គាល់សភាពព្រះពុទ្ធនោះឯង។

ដើម្បីបានមាសសុទ្ធ ត្រូវតែដុតរំលាយលោហធាតុ ដើមហើយចម្រាញ់ត្រង់យកជាតិមិនបរិសុទ្ធចេញ។ ដូចគ្នានេះដែរ កាលណាមនុស្សលោករំលាយតណ្ហានៃចិត្តរបស់ខ្លួន ហើយត្រង់យកវត្ថុមិនបរិសុទ្ធ ដែលនាំឲ្យសៅហ្មងនោះចេញបាន មនុស្សលោកអាចនឹងឃើញសភាពព្រះពុទ្ធ ដែលមាននៅក្នុងខ្លួនឯងផ្ទាល់នោះជាពុំខាន។

ចំពូកទី ៤

តណ្ហា

I

មន្ទិលសៅហ្មងនៃចិត្ត

1. *មានតណ្ហាពីរយ៉ាង ដែលគ្របពាសជិតជុំលើសភាពព្រះពុទ្ធ។*

តណ្ហាទី១ គឺការទម្លាប់ធ្វើការវែកញែក ដែលជាហេតុនាំឲ្យមនុស្សវង្វេង។ តណ្ហាទី២ គឺការទាញចិត្តនាំឲ្យរំជួល ដែលជាហេតុនាំឲ្យមនុស្សវង្វេង ដោយឲ្យតម្លៃខុសចំពោះវត្ថុទាំងឡាយ។

តណ្ហាជាដើមឫសទាំងពីរនេះ គឺជាដើមហេតុនៃគ្រប់តណ្ហាឯទៀតៗ។ តណ្ហាដើមឫសទាំងពីរនេះ មាននិទ្ទាការដើមហេតុពីរជាមូលដ្ឋាន គឺសេចក្ដីល្ងង់ខ្លៅ និងចំណង់ផប់ផល់។

ទម្លាប់ធ្វើការវែកញែក មានសេចក្ដីល្ងង់ខ្លៅជាមូលដ្ឋាន

ហើយការនាំចិត្តឲ្យរំជួល យោលយកចំណង់ផប់ផល់ជាបង្អែក។ រួមចូលគ្នាទៅ និន្នាការទាំងពីរនេះបានជាដើមហេតុនៃគ្រប់តណ្ហាឯទៀតៗ។

កាលណាល្ងង់ខ្លៅហើយ គេមិនអាចពិចារណាតាមបែបបទត្រឹមត្រូវប្រាកដបានទេ។ កាលណាបណ្ដោយឲ្យធ្លាក់ក្នុងចំណង់ផប់ផល់ហើយ គេខំតោងខំចាប់យក ខំជំពាក់ចិត្តដោយមិនអាចចៀសរួច។ គឺដោយសារតែខំប្រទាញប្រតោងស្រេកឃ្លានរបស់ជាទីស្រឡាញ់ បានជាគេឃើញ ព្ទ ហើយបណ្ដាលចិត្តឲ្យរំជួលឡើង។ មានពេលខ្លះ គេរហូតដល់ទៅបណ្ដោយឲ្យមានចំណង់ចំពោះសេចក្ដីមរណៈផងក៏មាន។

តណ្ហាទាំងនេះហើយ ជាដើមហេតុនៃតណ្ហាឯទៀតទាំងអស់ ដូចជា សេចក្ដីលោភលន់ សេចក្ដីក្រោធខឹង សេចក្ដីល្ងីល្ងើ ការយល់ខុស ការតូចចិត្ត ការច្រណែននិន្ទា ការបញ្ចើចបញ្ចើ ការបោកប្រាស សេចក្ដីឡឺត ការមើលងាយមើលថោក ការប្រព្រឹត្តហួសហេតុ ការមានអត្តទត្ថភាព។

2. សេចក្ដីលោភលន់ មកអំពីគំនិតខុសដែលមានចំពោះវត្ថុ

ជាទីពេញចិត្ត ហើយប្រាថ្នាចាប់យកវត្ថុនោះ។ សេចក្តីក្រោធខឹង មកអំពីគំនិតខុស ក្នុងការមិនអាចព្រមទទួលយកនូវស្ថានភាព ឬព្រឹត្តិការណ៍ ដែលមិនជាទីពេញចិត្ត។ សេចក្តីល្ងីល្ងើ មកអំពីការមិនចេះកាន់មារយាទឲ្យបានត្រឹមត្រូវ។ ការយល់ខុសមកអំពីគំនិតខុស ដែលចេញមកអំពីសិក្ខាបទអាក្រក់។

សេចក្តីលោភលន់ សេចក្តីក្រោធខឹង និងសេចក្តីល្ងីល្ងើគឺជាភ្លើងទាំងបី ដែលឆេះលោកនេះ។ ភ្លើងនៃសេចក្តីលោភលន់ ឆេះបុគ្គលណាដែលបាត់បង់ការយល់ត្រូវ ដោយហេតុតែសេចក្តីលោភលន់។ ភ្លើងនៃសេចក្តីក្រោធខឹង ឆេះបុគ្គលណាដែលបាត់បង់ការយល់ត្រូវ ដោយហេតុតែក្តីក្រោធ។ ភ្លើងនៃសេចក្តីល្ងីល្ងើ ឆេះបុគ្គលណាដែលបាត់បង់ការយល់ត្រូវ ដោយហេតុតែមិនព្រមយកត្រចៀកស្តាប់ យកចិត្តទុកដាក់នឹងសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់។

តាមពិត លោកនេះត្រូវឆេះដោយអណ្តាតភ្លើង ជាច្រើនចំពូក។ មានអណ្តាតភ្លើងនៃក្តីលោភលន់ អណ្តាតភ្លើងនៃក្តីក្រោធខឹង អណ្តាតភ្លើងនៃការយល់ខុស អណ្តាភ្លើងនៃអត្ត-ទត្តភាព អណ្តាតភ្លើងនៃក្តីល្ងីល្ងើ អណ្តាតភ្លើងនៃជរាភាព

អណ្តាតភ្លើងនៃជំងឺ និងអណ្តាតភ្លើងនៃមរណភាព។ មានអណ្តាតភ្លើងនៃក្តីទុក្ខព្រួយ អណ្តាតភ្លើងនៃក្តីសោកសង្រេង អណ្តាតភ្លើងនៃក្តីវេទនា និងអណ្តាតភ្លើងនៃក្តីថប់បារម្ភ។ អណ្តាតភ្លើងអស់ទាំងនេះ ឆេះសម្បើមណាស់។ វាមិនត្រឹមតែឆេះខ្លួនឯងប៉ុណ្ណោះទេ វាបណ្តាលហេតុដល់អ្នកដ៏ទៃទៀតឲ្យមានទុក្ខវេទនា ឲ្យប្រព្រឹត្តអំពើអាក្រក់ដោយគំនិត ដោយវាចា និងដោយរូបកាយ។ របួសដែលបណ្តាលពីអណ្តាតភ្លើងទាំងនេះមានខ្ទុះហូរចេញឆ្ពងទៅគេឯង បំពុលអ្នកដែលបានប៉ះពាល់ ហើយនាំអ្នកទាំងនោះឲ្យចូលទៅរកផ្លូវនរក។

3. សេចក្តីលោភលន់ កើតមានឡើងចំពោះអ្វីៗ ដែលគួរជាទីពេញចិត្ត។ សេចក្តីក្រោធខឹង កើតមានឡើងនៅចំពោះអ្វីៗ ដែលមិនជាទីពេញចិត្ត។ សេចក្តីឆ្កួតល្ងីល្ងើ មកអំពីចិត្តគំនិតមិនបរិសុទ្ធ។ សេចក្តីលោភលន់ បណ្តាលឲ្យមានមន្ទិលតូចមួយ តែពិបាកនឹងលុបបំបាត់។ សេចក្តីក្រោធខឹង បណ្តាលឲ្យមានមន្ទិលធំជាងនេះ តែស្រួលលុបបំបាត់ជាង។ ផ្ទុយពីនេះ សេចក្តីឆ្កួតល្ងីល្ងើ បណ្តាលឲ្យមានមន្ទិលធំមួយពិបាកនឹងលុបបំបាត់ណាស់។

ពេលណា ទីណាដែលមានអណ្ដាតភ្លើងទាំងនេះឆេះឡើង ហើយ ត្រូវតែពន្លត់ចោលឲ្យអស់ ដោយចេះវិនិច្ឆ័យឲ្យបាន ត្រឹមត្រូវ អំពីអ្វីៗដែលអាចផ្ដល់នូវសេចក្ដីសោមនស្សពិតប្រាកដ ដោយចេះគ្រប់គ្រងចិត្តរបស់ខ្លួនយ៉ាងប្រិតប្រៀប ចំពោះអ្វីៗ ដែលមិនជាទីពេញចិត្តនៃជីវិត និងដោយរំលឹកជាប់ជានិច្ចនូវ ពុទ្ធោវាទៗ បើចិត្តបានពោរពេញទៅដោយគំនិតបរិសុទ្ធប្រកប ដោយគតិបណ្ឌិត លែងមានអត្តទត្តភាពហើយ តណ្ហាទាំង ឡាយនឹងមិនអាចចាប់ឫសដុះឡើងបានទេ។

4. សេចក្ដីលោភលន់ សេចក្ដីក្រោធខឹង និងសេចក្ដីច្លូតភ្លីភ្លើ ប្រៀបបាននិងជំងឺគ្រុនក្ដៅ។ បើបុគ្គលណាមានជំងឺគ្រុនក្ដៅ នេះហើយ បើទុកជាដេកក្នុងវិមានយ៉ាងប្រណីតយ៉ាងណាក៏ ដោយ ក៏ពុំអាចដេកលក់ស្រួលបានដែរ។

បើគេពុំមានជំងឺគ្រុនក្ដៅនេះទេ គេងាយដេកលក់ស្រួល ទោះបីជានៅនារាត្រីសែនត្រជាក់នៃសិសិររដូវ ដោយដេកផ្ទាល់ នឹងដី ដណ្ដាប់តែស្លឹកឈើក៏ដោយ ឬទោះបីជានៅនារាត្រី សែនក្ដៅនៃរដូវក្ដៅ ដោយដេកក្នុងបន្ទប់តូចមួយ ហើយបិទ

ជិតឈើផងក៏ដោយ។

សេចក្តីលោភលន់ សេចក្តីក្រោធខឹង និងសេចក្តីច្ឆួតល្ងីល្ងើជាដើមហេតុបីនៃទុក្ខវេទនារបស់សត្វលោក។ ដើម្បីដកឫសនៃដើមហេតុទុក្ខវេទនាទាំបីនេះ ត្រូវតែចេះរក្សាសិក្ខាបទ ចេះសង្រួមចិត្ត និងមានគតិបណ្ឌិត។ ដោយសារការរក្សាសិក្ខាបទ គេអាចកំចាត់ភាពមិនបរិសុទ្ធនៃសេចក្តីលោភលន់បាន។ ដោយសារការសង្រួមចិត្ត គេអាចកំចាត់ភាពមិនបរិសុទ្ធនៃសេចក្តីក្រោធខឹងបាន។ ដោយសារការមានគតិបណ្ឌិតគេអាចកំចាត់ភាពមិនបរិសុទ្ធនៃសេចក្តីច្ឆួតល្ងីល្ងើបាន។

5. ចំណង់មនុស្សលោក គ្មានព្រំដែនទេ។ គឺដូចជាមនុស្សដែលស្រេកទឹក ហើយផឹកទឹកអំបិល។ មនុស្សនោះមិនបាត់ស្រេក ហើយរឹតតែស្រេកឡើងៗថែមទៀត។

បុគ្គលដែលស្វែងរកសេចក្តីពេញចិត្តនឹងចំណង់របស់ខ្លួនក៏ដូច្នេះដែរ។ ចំណង់រឹតតែមានច្រើនឡើងៗហើយបុគ្គលនោះនឹងទទួលក្តីទុក្ខកាន់តែច្រើនឡើងៗ។

ការពេញចិត្តនឹងចំណង់ មិនចេះចប់ជាដាច់ខាត វា

បណ្ដាលនូវសេចក្ដីព្រួយបារម្ភ និងសេចក្ដីក្ដៅក្រហាយ ដែលមិនចេះស្រាកស្រាន្តជាដាច់ខាត ជានិច្ចកាល។ម្យ៉ាងទៀត បើការពេញចិត្តនឹងចំណង់នោះ វាត្រូវបានគេប្រឆាំងរាំងរា វានឹងនាំឲ្យមនុស្សទៅជាច្ឆួតលេលា ជាញឹកញយ។

ដើម្បីបំពេញចំណង់របស់ខ្លួន មនុស្សលោកប្រយុទ្ធប្រកាប់ប្រចាក់គ្នា ស្ដេចជាមួយនឹងស្ដេច ប្រទេសចំណុះជាមួយនឹងប្រទេសចំណុះ ឪពុកម្ដាយជាមួយនឹងកូនចៅ បងប្អូនប្រុសស្រីជាមួយនឹងបងប្អូនប្រុសស្រី មិត្តភក្ដិជាមួយនឹងមិត្តភក្ដិ។ ដើម្បីបំពេញចំណង់របស់ខ្លួនមនុស្សលោករហូតដល់ទៅសម្លាប់គ្នាទៀតផង។

ជាញឹកញយ មនុស្សលោករហូតដល់ទៅបំផ្លាញជីវិតរបស់ខ្លួន ដើម្បីបំពេញចំណង់ខ្លួន។ នរជនទាំងនោះ លួចប្លន់កុហកបោកប្រាស់ ប្រព្រឹត្តអំពើផិតក្បត់ ហើយនៅទីបំផុតកាលណាគេចាប់បាន ជនទាំងនោះត្រូវអស់កិត្តិយស ហើយទទួលទណ្ឌកម្មជាទម្ងន់។

មនុស្សលោកធ្វើកម្មពៀរនឹងរូបកាយរបស់ខ្លួន នឹងមាត់របស់ខ្លួន ដោយដឹងច្បាស់ហើយថា ការបំពេញចំណង់របស់ខ្លួនទាំងនោះ បណ្ដាលឲ្យមានទុក្ខទោស។ មនុស្សលោកធ្វើ

កម្មពៀរនឹងវិញ្ញាណរបស់ខ្លួន ដោយដឹងច្បាស់ហើយថា ការបំពេញបំណងចំណង់របស់ខ្លួនទាំងនោះនាំមក ជាទីបំផុតនូវទុក្ខព្រួយៗ តែកម្លាំងនៃចំណង់ វាខ្លាំងក្រៃពេកណាស់ ! ហើយទោសទុក្ខ ដែលនឹងត្រូវបានទទួលទៅជាតិមុខ វាយ៉ាងណាទៅ? កម្មផល ដែលនឹងត្រូវបានរងទៅជាតិនានាខាងមុខ វាយ៉ាងណាទៅ?

6. ក្នុងចំណោមតណ្ហាលោកិយទាំងនោះ អភិជ្ឈា ឬចំណង់ជប់ជល់ធំជាងគេៗ ចំពោះតណ្ហាឯទៀតៗ ហាក់ដូចជាក្បួនដង្ហែតាមក្រោយទេៗ

អភិជ្ឈា ដូចជាការសាបព្រោះក្នុងស្រែ ដែលតណ្ហាចំណង់ឯទៀតៗ ដុះចេញឡើងៗ អភិជ្ឈា ដូចជាយក្ខិនីនៅក្នុងរឿងព្រេង ដែលហែកស៊ីអំពើល្អទាំងអស់នៃលោកនេះៗ អភិជ្ឈា ដូចជាពស់វែក ដែលលាក់បំពួនខ្លួនក្នុងគុម្ពផ្កាទាំងឡាយនាសួនច្បារ វាចឹកជនទាំងឡាយដែលមកក្រេបយកសោភណភាពនៃសួនៗ អភិជ្ឈា ដូចជារុក្ខជាតិចង្រៃ ដែលវាឡើងព័ទ្ធដើមព្រឹក្សា ហើយព័ទ្ធព័ន្ធរួតរឹតគ្រប់មែកជាង រហូត

ដល់ព្រឹក្សានោះសូន្យជីវិត។ មែនទែនទៅ គឺអភិជ្ឈានេះវាចាក់ឫសទៅក្នុងជម្រៅនៃចិត្តមនុស្សលោក ហើយបណ្ដេញចេញអស់នូវសុកវិនិច្ឆ័យ រហូតទាល់តែផ្កានៃវិញ្ញាណរុះរោយអស់។ អភិជ្ឈា ដូចជាអន្ទាក់ ដែលបិសាចដាក់ មនុស្សដែលឆោតក្លៅ បណ្ដោយខ្លួនឲ្យជាប់អន្ទាក់នោះ ហើយត្រូវបានប្រអូសប្រទាញឲ្យចូលទៅក្នុងភពនៃទុក្ខវេទនា។

បើគេយកឈាមមកប្រឡាក់ឆ្អឹងស្ងួតគ្រោះមួយ ហើយបោះទៅឲ្យឆ្កែ ឆ្កែនឹងអង្កៀមមឆ្អឹងនោះរហូតទាល់តែវាអស់កម្លាំង ឬក៏គេយកឆ្អឹងនោះចេញពីវា។ អភិជ្ឈាក៏ដូចជាឆ្អឹងនោះដែរ មនុស្សលោកជាប់ជំពាក់ចិត្តនឹងវា រហូតទាល់តែស្កប់ស្កល់ ហើយហេវហត់អស់កម្លាំងនឹងវា។

បើគេចោលដុំសាច់គំរង់សត្វទៅឲ្យសត្វសាហាវពីរ មំសាសត្វទាំងពីរនោះនឹងប្រខាំហែកហួរគ្នា ដណ្ដើមយកដុំសាច់គំរង់នោះ។ បើមនុស្សឆ្កួតក្ញីភ្លើកាន់ចន្លុះដែលឆេះទ្រលោម ហើយដើរបញ្ច្រាស់ខ្យល់ មនុស្សនោះនឹងត្រូវឆេះរលាកខ្លួនឯង។ មនុស្សលោក ដូចជាសត្វសាហាវទាំងពីរនេះ ឬដូចជាមនុស្សឆ្កួតក្ញីភ្លើនេះដែរ មនុស្សលោកបណ្ដាលឲ្យមានរបួសលើខ្លួន

ឯង បណ្ដាលឲ្យលោករលួយខ្លួនឯង ដោយសារចំណង់របស់ខ្លួនឯងផ្ទាល់។

7. ការការពារខ្លួននឹងព្រួញពិស ជាការងាយស្រួលធ្វើទេ ប៉ុន្ដែ ការការពារចិត្តនឹងព្រួញពិសដែលចេញមកអំពីក្នុងខ្លួនឯងផ្ទាល់នោះ ជាការមិនអាចធ្វើបាន។ សេចក្ដីលោភលន់ សេចក្ដីក្រោធខឹង សេចក្ដីឆ្កួតភ្លីភ្លើ សេចក្ដីកាន់ក្អេកនឹងអាត្មាអញ សុទ្ធតែជាព្រួញពិសដែលមានដើមហេតុនៅក្នុងវិញ្ញាណ ហើយដែលចម្លងពិសពុលខ្លាំងបំផុតទៅវិញ្ញាណ។

បើគេត្រូវឆ្លងរោគលោភលន់ រោគក្រោធខឹង និងរោគឆ្កួតភ្លីភ្លើ ទៅក្នុងចិត្តគេហើយ គេចៀសពុំផុតអំពីនិយាយកុហក និយាយត្រឡប់ត្រឡិន និយាយប្រមាថនិយាយបង្កាច់បង្ខូច ហើយប្រព្រឹត្តឃាតកម្ម ចោរកម្ម និងអំពើផិតក្បត់។

គំនិតអាក្រក់ទាំងបី សម្ដីអាក្រក់ទាំងបួន និងអំពើអាក្រក់ទាំងបី រួមផ្គុំគ្នាឡើងបង្កើតបានជាកម្មអាក្រក់ដប់ប្រការ។

បើគេទម្លាប់កុហក គេនឹងប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាង ដោយមិនដឹងខ្លួន។ មុននឹងប្រព្រឹត្តអំពើឃោរឃៅ គេ

គោងតែកុហក។ កាលណាគេចាប់ផ្ដើមកុហកហើយ គេនឹងប្រព្រឹត្តអំពើឃោរឃៅ ដោយឥតនឹកគិតរអែង។

សេចក្ដីលោភលន់ ចំណង់ហួសប្រមាណ សេចក្ដីខ្វាចញញើត សេចក្ដីក្រោធខឹង សេចក្ដីទោមនស្ស ការមិនពេញចិត្តទាំងអស់នេះមកអំពីសេចក្ដីច្ឆតភ្ញីភ្ញើ។ ហេតុនេះ សេចក្ដីច្ឆតភ្ញីភ្ញើ ជាពិសពុលខ្លាំងជាងគេបង្អស់។

8. កាលណាចំណង់លោកិយប្រាកដឡើងហើយ អំពើផ្សេងៗនឹងមកតាមចំណង់នោះ។ កាលណាអំពើប្រាកដឡើងហើយទុក្ខវេទនានឹងមកតាមអំពើនោះ។ ចំណង់ អំពើ និងទុក្ខវេទនាដូចជាកង់ដែលវិលមិនឈប់។

បើកង់វិលគ្មានទីផ្ដើម និងទីបញ្ចប់យ៉ាងនេះ តើគេអាចចៀសផុតពីការវិលរស់វិលស្លាប់យ៉ាងដូចម្ដេចទៅ? ដូច្នេះ ជីវិតគឺជាការវិលទៅវិលមកជានិច្ចនិរន្តរ៍។

បើគេប្រមូលគរផេះនិងឆ្អឹង ដែលគេទុកចោលក្នុងរយៈវេលាវិលរស់វិលស្លាប់មិនចេះចប់នេះ គេនឹងបានជាភ្នំធំមួយ។ បើគេប្រមូលទុកដំណក់ទឹកដោះទាំងអស់ ដែលគេបៅជញ្ជក់

តណ្ហា

ពីដោះមាតា ក្នុងរយៈពេលវិលរស់វិលស្លាប់មិនចេះចប់នេះដែរ គេនឹងបានជាមហាសមុទ្រយ៉ាងជ្រៅបំផុតមួយ។

ប្តីដ្បិតតែបុគ្គលគ្រប់រូបមានសភាពព្រះពុទ្ធនៅក្នុងខ្លួនតែសភាពព្រះពុទ្ធនោះ ត្រូវបានកប់បាត់យ៉ាងជ្រៅទៅក្នុងមន្ទិលសៅហ្មងនៃតណ្ហា ដែលគ្មាននរណាម្នាក់នឹកគិតដល់តាំងពីយូររាប់កោដិឆ្នាំមកហើយ។ ហេតុនេះហើយបានជាទុក្ខវេទនាវាទៅជាសាកលទូទៅយ៉ាងនេះ ហើយជីវិតរងទុក្ខវេទនាត្រូវហូរទៅមិនចេះចប់យ៉ាងនេះ។

II

សភាពមនុស្សលោក

1. សភាពមនុស្សលោក ប្រៀបដូចជាព្រៃគ្រាស់ឥតច្រកចេញចូល ដែលពិបាកចូលទៅជាទីបំផុត។ បើប្រៀបទៅនឹងសភាពសត្វតិរច្ឆាន ឃើញថាសភាពសត្វតិរច្ឆានស្រួលយល់ជាង។ ប៉ុន្តែជាឱរ៉ាល់ទូទៅ យើងអាចឲ្យអត្ថន័យដល់សភាពនៃមនុស្សលោកបានតាមភាពជាខាងក្រៅបួនបែប។

ចំពូកទី១ គឺពពួកមនុស្សដែល ដោយហេតុសិក្ខាបទខុស មិនសមគន្ធង ធ្វើវត្តប្រតិបត្តិតឹងតែងហួស ហើយធ្វើទុក្ខទោសខ្លួនឯងផ្ទាល់។ ចំពូកទី២ គឺមនុស្សដែលដោយសារភាពសាហាវ លួចប្លន់ កាប់សម្លាប់ ឬអំពើកាចឃោរឃៅឯទៀតៗ ធ្វើឲ្យអ្នកឯទៀតមានសេចក្តីឈឺចាប់។ ចំពូកទី៣ គឺពពួកមនុស្ស ដែលធ្វើឲ្យអ្នកដ៏ទៃឈឺចាប់ផង ខ្លួនឯងឈឺចាប់ផង។ ចំពូកទី៤ គឺពពួកមនុស្ស ដែលមិនធ្វើឲ្យខ្លួនឯងឲ្យឈឺចាប់ផង ហើយជួយជ្រោមជ្រែងអ្នកឯទៀតឲ្យរួចផុតពីការឈឺចាប់ផង។ មនុស្សក្នុងចំពូកខាងក្រោយនេះ ដោយជឿតាមពុទ្ធោវាទ វៀរចាកសេចក្តីលោភលន់ សេចក្តីក្រោធខឹង និងសេចក្តីឆ្កួតភ្លីភ្លើ។ គេរស់នៅដោយស្ងប់ យកសេចក្តីករុណាគតិបណ្ឌិតជាគ្រឹះហើយចៀសចេញឆ្ងាយពីការកាប់សម្លាប់លួចប្លន់។

2. មានមនុស្សបីប្រភេទ នៅក្នុងលោកនេះ។ មនុស្សមួយប្រភេទ គឺដូចជាអក្សរដែលគេចារលើថ្ម មនុស្សទាំងនោះឆាប់ខឹងក្រោធណាស់ ហើយទុកគំនុំនោះជាយូរអង្វែង។ មនុស្សមួយប្រភេទទៀត ប្រៀបដូចជាអក្សរដែលគេចារលើខ្សាច់ មនុស្សប្រភេទនេះឆាប់ខឹងក្រោធ តែចិត្តខឹងក្រោធនោះមិននៅយូរ

ទេ។ មនុស្សមួយប្រភេទទៀត ប្រៀបដូចអក្សរដែលគេសរសេរលើទឹកហូរ មនុស្សប្រភេទនេះមិនរក្សាគំនុំទុកក្នុងចិត្តទេ គេបណ្ដោយឲ្យការប្រមាថ និងពាក្យសម្ដីមិនគួរឲ្យចូលចិត្តទៅបាត់ទៅដោយគ្មានយកចិត្តទុកដាក់អំពល់រវល់ ចិត្តរបស់គេនៅបរិសុទ្ធមិនរំភើបញាប់ញ័រ។

មានមនុស្សបីប្រភេទទៀត នៅក្នុងលោកនេះ។ មនុស្សមួយប្រភេទ ឡឹតក្រអឺតក្រអោង ព្រហើនកោងកាច មិនចេះសប្បាយចិត្តនឹងអ្វីទេ សភាពមនុស្សប្រភេទនេះ ស្រួលយល់ទេ។ មនុស្សមួយប្រភេទទៀត ចេះគួរសម ហើយប្រព្រឹត្តអំពើអ្វីៗដោយគិតគូរ សភាពមនុស្សប្រភេទនេះ ពិបាកយល់ណាស់។ មនុស្សក្នុងប្រភេទទីបីគឺមនុស្សដែលចេះគ្រប់គ្រងចំណង់របស់ខ្លួនបានទាំងគ្រប់ សភាពមនុស្សប្រភេទនេះមិនអាចយល់បានទេ។

គេអាចចែកមនុស្សលោកបានជាច្រើនប្រភេទ ប៉ុន្ដែ សភាពរបស់មនុស្សលោកនៅតែពិបាកយល់ជានិច្ច។ មានតែព្រះពុទ្ធជាម្ចាស់ទេ ដែលអាចយល់គ្រប់ ដោយសារព្រះបញ្ញាដ៏វៃ

វិសេសវិសាល ព្រះអង្គអាចដឹកនាំមនុស្សលោកតាមរបៀបទូន្មានផ្សេងៗគ្នា។

III

ជីវិតមនុស្សលោក

1. មានរឿងនិទានស្តីអំពីជីវិតមនុស្សមួយថា: មានបុរសម្នាក់ជិះទូកលេងនៅក្នុងស្ទឹងមួយ។ មានបុរសម្នាក់ទៀតឈរនៅមាត់ច្រាំង ស្រែកព្រមានប្រាប់ទៅបុរសជិះទូកនោះថា: «ចូរឈប់អុំទូកលេងសប្បាយនៅតាមខ្សែទឹក ដែលហូរខ្លាំងក្លានេះទៅ នៅឆ្ងាយពីនេះបន្តិចមានខ្សែទឹកហូរធ្លាក់ខ្លាំង និងខ្សែទឹកក្ដួចប្រកបដោយគ្រោះថ្នាក់មានក្រពើ និងខ្មោចទឹកនៅក្នុងរូងថ្ម។ បើអ្នកទៅមុខបន្តិចទៀតអ្នកនឹងអស់ជីវិតជាពុំខាន!»។

ក្នុងរឿងប្រៀបធៀបនេះខ្សែទឹកក្ដួចខ្លាំង គឺជីវិតអភិជ្ឈា ឬចំណង់ចង់ល់។ អុំទូកលេងយ៉ាងសប្បាយរីករាយ គឺបណ្ដោយខ្លួនឲ្យតណ្ហាដឹកនាំបានដោយសេរី។ ខ្សែទឹកធ្លាក់ខ្លាំងគឺទុក្ខព្រួយដែលអន្ទោលតាមប្រាណ។ ខ្សែទឹកក្ដួចគឺការ

សប្បាយភ្លើតភ្លើន។ ក្រពើនិងខ្មោចទឹក គឺជរាភាពនិងសេចក្ដីស្លាប់ដែលអន្ទោលតាមជីវិតអភិជ្ឈានិងធ្វេសប្រហែស។ បុរសដែលឈរនៅមាត់ច្រាំងស្រែកព្រមានទៅនោះគឺព្រះពុទ្ធ។

មាននិទានមួយទៀតថា: «មានបុរសម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋហើយគេចរត់យ៉ាងលឿន។ ដោយមានប៉ូលិសដេញតាមចាប់ បុរសនោះក៏រត់ទៅពួនក្នុងបាតអណ្ដូងប្រតោងវល្លិឈើ ដែលដុះព័ទ្ធគែមអណ្ដូង។ នៅពេលដែលបុរសប្រតោងវល្លិចុះទៅបាតអណ្ដូង គាត់ប្រទះនឹងពស់វែកមួយនៅបាតអណ្ដូង គាត់ក៏ប្រតោងវល្លិឡើងមកផុតទីគ្រោះថ្នាក់វិញ។ ក្រោយបន្តិចមកនៅពេលដែលគាត់ចាប់ចុកស្រពន់ដៃ គាត់ប្រទះឃើញកណ្ដុរពីរ មួយសមួយខ្មៅ កំពុងតែកកេរកាត់វល្លិ។

បុរសនោះនឹកគិតថា: «បើវល្លិនេះដាច់ទៅ អញនឹងធ្លាក់ទៅក្នុងជំរំពស់វែក ហើយត្រូវវាចឹកស្លាប់ពុំខាន!»។ បុរសនោះងើបក្បាលឡើង ប្រទះនឹងសម្បុកឃ្មុំនៅប្របនឹងមុខ។ ខណៈនោះទឹកឃ្មុំមួយតំណក់ធ្លាក់មកចំមាត់គាត់ គាត់ភ្លេចអស់គ្រោះថ្នាក់ ហើយក្រេបរសជាតិផ្អែមឆ្ងាញ់នៃតំណក់ទឹកឃ្មុំនោះទៅ។

ឃើញថា មនុស្សលោកកើតមកសម្រាប់រងទុក្ខនិងស្លាប់ទៅវិញតែប៉ុណ្ណោះ។ ប៉ូលិសនិងពស់វែកសំដៅទៅលើរូបកាយ និងចំណង់គ្រប់បែបយ៉ាងនៃរូបកាយ។ វល្លិឈើ គឺភាពតគ្នាមិនដាច់នៃជីវិតមនុស្ស។ កណ្ដុរមួយសមួយខ្មៅទាំងពីរ បានន័យចំពោះថ្ងៃ និងយប់ដែលមកដល់ជាបន្តបន្ទាប់គ្នាមិនដាច់។ ទឹកឃ្មុំប្រៀបបានទៅនឹងចំណង់នៃរូបកាយ ដែលបន្ធូបទុក្ខមួយគ្រា។

2. មានរឿងនិទានប្រៀបធៀបមួយទៀតថា: មានក្សត្រមួយព្រះអង្គយកពស់វែកបួនដាក់ក្នុងប្រអប់មួយ ហើយប្រគល់ប្រអប់នោះទៅអាមាត្យម្នាក់ឲ្យរក្សាទុក។ ព្រះមហាក្សត្រទ្រង់បញ្ជាអាមាត្យនោះរក្សាពស់វែកទាំងបួនឲ្យបានហ្មត់ចត់បើធ្វើឲ្យពស់វែកណាមួយខឹង នឹងយកទោសដល់ជីវិត។ អាមាត្យភ័យខ្លាចខ្លាំងពេក ក៏គ្រវាត់ប្រអប់ចោលរួចហើយ គេចរត់ទៅ។

ព្រះមហាក្សត្របញ្ជូនកងរក្សាព្រះអង្គប្រាំនាក់ ឲ្យតាមចាប់អាមាត្យនោះ។ មុនដំបូងកងរក្សាព្រះអង្គទាំងប្រាំនោះចូលទៅជិតអាមាត្យនោះក្នុងភាពជាមិត្ត ដោយសង្ឃឹមថានឹង

ចាប់កុំឲ្យដឹងខ្លួន។ ប៉ុន្តែអាមាត្យមិនជឿសម្ដីផ្អែមល្ហែមនោះទេ ហើយក៏រត់ចូលក្នុងភូមិមួយទៀតទៅ។ ក្នុងការស្រមៃមួយប៉ប្រិចភ្នែក អាមាត្យឮសូរសំឡេងមួយមកប្រាប់ខ្លួនថា នៅក្នុងភូមិនោះមិនបានសុខទេ ពីព្រោះមានចោរប្រាំមួយនាក់បម្រុងនឹងចូលមកប្លន់។ ដោយភ័យខ្លាំងអាមាត្យក៏រត់រហូតទៅទាល់នឹងស្ទឹងមានទឹកហូរខ្លាំងមួយ។ នឹកគិតទៅដល់គ្រោះថ្នាក់ទាំងឡាយដែលតាមកិតពីក្រោយ អាមាត្យនោះក៏ធ្វើក្បូនមួយ ហើយឆ្លងខ្សែទឹកកួច បានរួចផុតពីគ្រោះថ្នាក់ដោយសុវត្ថិភាពដល់ទៅច្រាំងម្ខាងទៀត។

ពស់វែកទាំងបួនដែលជាប់នៅក្នុងប្រអប់ គឺជាតុទាំងបួន គឺៈ ដី ទឹក ភ្លើង ខ្យល់ ដែលផ្គុំគ្នាឡើងបានជារូបកាយ។ រូបកាយជាដើមហេតុនៃអភិជ្ឈា ដែលជាសត្រូវនឹងវិញ្ញាណ។ ដោយសារហេតុនេះហើយ បានជាវិញ្ញាណចេះតែខិតខំរត់ចេញឆ្ងាយពីរូបកាយ។

ក្រុមរក្សាព្រះអង្គទាំងប្រាំនាក់ ដែលចូលមកជិតក្នុងភាពជាមិត្តនោះ គឺខន្ធទាំងប្រាំ ដែលផ្គុំគ្នាបង្កើតជារូបកាយ និង

ចិត្តគឺៈ រូបរាង១ អារម្មណ៍១ ការដឹងដោយវិញ្ញាណ១ ដំណើរកកើតចិត្តគំនិត១ និងមនសិការ១។

ទីជម្រកសុខសាន្ត តំណាងញាណសក្តិទាំងប្រាំមួយ ដែលតាមពិតពុំមែនជាជម្រកសុខសាន្តពិតប្រាកដទេ។ ចោរប្រាំមួយនាក់នោះគឺវត្ថុនៃញាណសក្តិទាំងប្រាំមួយនេះឯង។ ហេតុនេះដោយមើលឃើញគ្រោះថ្នាក់នៅក្នុងញាណសក្តិទាំងប្រាំមួយនេះ អាមាត្យក៏រត់គេចម្តងទៀតទៅប្រទះនឹងខ្សែទឹកហូរខ្លាំងនៃចំណង់លោកិយ។

ក្បូនចម្លង គឺសេចក្តីទូន្មានប្រសើរឧត្តមរបស់ព្រះពុទ្ធ។ ដោយសារសេចក្តីទូន្មានទាំងនេះហើយ ដែលអាមាត្យអាចឆ្លងខ្សែទឹកហូរខ្លាំងនៃតណ្ហារួចទៅដល់ត្រើយម្ខាងទៀតប្រកបដោយសុវត្ថិភាព។

3. មានកាលៈទេសៈបីប្រកបដោយគ្រោះថ្នាក់ ដែលមិនអាចឲ្យកូនជួយសង្គ្រោះម្តាយបាន ឬម្តាយជួយសង្គ្រោះកូនបានគឺៈ អគ្គីភ័យ១ ទឹកជំនន់១ ចោរប្លន់១។ ប៉ុន្តែក្នុងកាលៈទេសៈប្រកបដោយគ្រោះថ្នាក់យ៉ាងនេះក៏ដោយ ក៏នៅមានភ័ព្វល្អអាចជួយគ្នាទៅវិញទៅមកបាន។

តណ្ហា

ប៉ុន្តែមានកាលៈទេសៈបីទៀត ដែលម្តាយពុំអាចជួយកូនបានឬកូនជួយម្តាយបានជាដាច់ខាត គឺៈ ឈឺ ជរា ស្លាប់។

កាលណាម្តាយជរាហើយ តើកូនអាចជរាជួសម្តាយដូចម្តេចបាន? កាលណាកូនឈឺហើយ តើម្តាយអាចឈឺជួសកូនដូចម្តេចបាន?កាលណាមរណកាលមកដល់ហើយ តើម្តាយនិងកូនអាចជួយគ្នាទៅវិញទៅមកដូចម្តេចបាន? ទោះបីគេស្រឡាញ់គ្នាយ៉ាងណាក៏ដោយ ទោះបីជាគេជិតស្និទ្ធនឹងគ្នាយ៉ាងណាក៏ដោយ ក៏គេពុំអាចជួយគ្នាបានជាដាច់ខាតក្នុងកាលៈទេសៈនេះ។

4. ថ្ងៃមួយ ព្រះយម ស្តេចមច្ចុរាជសួរទៅបុរសម្នាក់ដែលធ្លាក់ទៅក្នុងនរក ដោយសារកម្មអាក្រក់ដែលបានប្រព្រឹត្តអំពីជាតិមុនថាៈ កាលពីជាតិមុនអ្នកមានដែលបានជួបនឹងអ្នកនាំសារពីឋានសួគ៌បីនាក់ឬទេ។ បុរសនោះឆ្លើយថាៈ «អត់ទេព្រះបាទជាម្ចាស់ ខ្ញុំមិនដែលបានជួបនឹងជនបែបនេះ ម្តងណាទេ !»។ ព្រះយមបាលក៏សួរទៅទៀតថាៈ «អ្នកមានដែលបានជួបនឹងមនុស្សជរាម្នាក់ មានស្បែកជ្រីវជ្រួញ ដើរនឹងឈើច្រត់ដៃរឬ

ទេ?»។ បុរសនោះឆ្លើយថាៈ «ប្រាកដណាស់ ព្រះជាម្ចាស់ ខ្ញុំតែង បានជួបមនុស្សបែបនេះ ជាច្រើនដង!»។ ព្រះយមបាលក៏ប្រាប់ បុរសថាៈ ដែលអ្នករងទុក្ខទោសក្នុងនរកនៅពេលនេះ ព្រោះតែ អ្នកមិនបានទទួលស្គាល់ថា នៅក្នុងរូបមនុស្សជរានោះ មាន អ្នកនាំសារម្នាក់បញ្ជូនមកពីឋានសួគ៌ដើម្បីព្រមានដល់អ្នកឲ្យ ប្តូរជីវភាពរស់នៅ មុននឹងអ្នកទៅជាចាស់ជរា។

ព្រះយមបាលសួរទៅបុរសនោះទៀតថាៈ «អ្នកមានដែល បានជួបមនុស្សម្នាក់ឈឺគ្រាំគ្រា ក្ររហេមរហាមគ្មានមិត្តភក្តិដែរ ឬទេ?» បុរសនោះឆ្លើយថាៈ «ប្រាកដណាស់ព្រះជាម្ចាស់ ខ្ញុំ បានជួបមនុស្សបែបនេះជាញឹកញយ !» ។ យមបាលក៏ប្រាប់ បុរសនោះថាៈ អ្នកឯងត្រូវចុះមកក្នុងនរកនេះក៏ព្រោះតែអ្នក ឯងពុំបានទទួលស្គាល់ថា នៅក្នុងរូបអ្នកជំងឺអស់ទាំងនោះ មានអ្នកនាំសារបញ្ជូនមកពីឋានសួគ៌ ដើម្បីព្រមានប្រាប់ដល់ អ្នកអំពីជំងឺគ្រាំគ្រារបស់អ្នកឯងផ្ទាល់។

ព្រះយមបាលសួរបុរសនោះជាលើកទី៣ថា «ចុះអ្នកឯង មានដែលឃើញមនុស្សស្លាប់ដែរឬទេ?»។ បុរសនោះឆ្លើយថាៈ «ប្រាកដណាស់ព្រះជាម្ចាស់ ខ្ញុំបានជួបប្រទះនឹងមនុស្សស្លាប់

ច្រើនដង!»។ ព្រះយមបាលក៏ប្រាប់បុរសនោះថាៈ «ដែលអ្នកឯងចុះមកដល់ទីនេះក្នុងគ្រានេះ ក៏ព្រោះតែអ្នកឯងមិនទទួលស្គាល់ថា នៅក្នុងរូបមនុស្សស្លាប់នោះមានអ្នកនាំសារពីឋានសួគ៌បញ្ជូនមក ដើម្បីព្រមានដល់អ្នកថាថ្ងៃណាមួយអ្នកក៏ត្រូវស្លាប់ដែរ។ បើសិនជាអ្នកបានទទួលស្គាល់អ្នកនាំសារពីឋានសួគ៌ទាំងបីនេះ ស្តាប់តាមសេចក្តីព្រមាននៃអ្នកនាំសារទាំងនេះ ហើយអ្នកផ្លាស់ប្តូរជីវភាពរស់នៅ អ្នកមិនត្រូវបានចុះមកក្នុងទីប្រកបដោយទុក្ខវេទនានេះទេ»។

5. កាលមួយនោះមានក្មេងស្រីម្នាក់ឈ្មោះ **កិសគោតមី** ជាស្ត្រីមេម៉ាយប្តីអ្នកមានស្តុកស្តម្ភ។ ស្រីនោះវង្វេងសតិដោយត្រូវកូនស្លាប់។ ស្រីនោះបីកូនស្លាប់ទៅពីផ្ទះមួយទៅផ្ទះមួយដើម្បីអង្វរគេឯងឲ្យព្យាបាលកូនឲ្យបានជាឡើងវិញ។

ជាការប្រាកដណាស់ គ្មាននរណាម្នាក់អាចជួយស្រីនោះបានទេ។ ពេលនោះ ស្រីនោះបានជួបនឹងសាវ័កព្រះពុទ្ធមួយអង្គ។ ព្រះសាវ័កនោះ បានទូន្មានស្រីនោះឲ្យទៅជួបនឹង

ព្រះពុទ្ធ ដែលគង់នៅឯដែនជេតវន។ ស្រីនោះឮហើយក៏បីកូនស្លាប់ទៅរកព្រះពុទ្ធដល់ទីកន្លែង។

ព្រះបរមពិត្រទតទៅស្រីនោះ ដោយក្ដីអាសូរពន់ពេក ហើយក៏មានពុទ្ធដីកាថា: «ដើម្បីព្យាបាលកូនរបស់នាងឲ្យបានជាឡើងវិញ តថាគតត្រូវការឫសដើមអាកៀន។ ចូរនាងទៅរកផ្ទះណាដែលសេចក្ដីមរណៈមិនដែលចូលសោះ ហើយសុំឫសដើមអាកៀនគេឲ្យតថាគតបានបួនប្រាំទង»។

ស្រីវិកលចរិតនោះ ក៏ចេញទៅរកផ្ទះណាដែលសេចក្ដីមរណៈមិនដែលចូលសោះ ប៉ុន្តែរកមិនប្រទះសោះ។ ទីបំផុតស្រីនោះសម្រេចចិត្តវិលមករកព្រះពុទ្ធវិញ។ មកដល់ឃើញព្រះពុទ្ធគង់ក្នុងភាពស្ងប់ជាទីបំផុត សតិស្រីនោះក៏ភ្លឺស្វាងឡើងមួយរំពេច ហើយនាងបានយល់ន័យព្រះពុទ្ធដីកានោះភ្លាម។ នាងក៏យកសពកូននាងទៅបូជាទៅ។ បន្ទាប់មក នាងត្រឡប់មករកព្រះពុទ្ធវិញហើយជឿតាមសាសនាព្រះអង្គតរៀងទៅ។

IV

ភាពពិតនៃជីវិតមនុស្សលោក

1. មនុស្សក្នុងលោកនេះ ជាប់ចិត្តទៅលើតែអត្តទត្តភាព និងអំពើកាចឃោរឃៅ។ គេមិនដឹងថាស្រឡាញ់ និងគោរពគ្នាទៅវិញទៅមក របៀបយ៉ាងដូចម្តេចទេ។ គេប្រកាប់ប្រចាក់គ្នាឥតប្រយោជន៍ បានតែការឈឺចាប់ទុក្ខព្រួយមកលើខ្លួនឯងផ្ទាល់តែប៉ុណ្ណោះ។ ដោយសារហេតុនេះ ជីវិតត្រូវបានព័ទ្ធជុំវិញទៅដោយទុក្ខវេទនា។

មានក្តីឬក្រក្តី មនុស្សលោកព្រួយបារម្ភតែនឹងមាសប្រាក់ គេរងទុក្ខព្រួយព្រោះតែក្រ តែគេរងទុក្ខព្រួយក៏ព្រោះតែមាន។ ដោយសារតែលុះទៅក្នុងចំណង់ មនុស្សលោកនេះមិនចេះសប្បាយចិត្ត និងពេញចិត្តម្តងណាទេ។

អ្នកមានវក់ធ្លួតនឹងស្ថានភាពខ្លួន នឹងវិមានស្តុកស្តម្ភប្រណីតរបស់ខ្លួន នឹងអ្វីៗគ្រប់យ៉ាងដែលខ្លួនមាន។ គេព្រួយបារម្ភដោយនឹកគិតថា ថ្ងៃណាមួយភយន្តរាយនឹងមកដល់ខ្លួនភ្លើងនឹងឆេះផ្ទះខ្លួន ចោរនឹងលួចប្លន់ទ្រព្យសម្បត្តិរបស់ខ្លួន។ គេព្រួយបារម្ភនឹងការស្លាប់ នឹងការចាត់ចែងទ្រព្យសម្បត្តិ

ក្រោយអំពីពេលគេស្លាប់ទៅ។ ជាការពិតគេស្លាប់ទៅតែម្នាក់ឯងគត់គ្មានអ្វីទៅតាមមនុស្សស្លាប់ទេ។

អ្នកក្រកើតទុក្ខជានិច្ចនឹងការខ្វះខាតរបស់ខ្លួន ហេតុនេះគេមានសេចក្ដីប្រាថ្នាចង់បានរបស់ជាច្រើនលើសលប់ មិនចេះឆ្អែតឆ្អន់ ដូចជាផ្ទះសម្បែងទ្រព្យសម្បត្តិជាដើម។ ដោយសារចំណង់លោភលន់វាដុតរោល គេអស់ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ហើយគេត្រូវស្លាប់មុនអាយុ។

គេឃើញហាក់ដូចជាលោកទាំងមូលជាសត្រូវ ចំពោះគេ ហើយសេចក្ដីស្លាប់ហាក់ដូចជាដំណើរមួយសែនឆ្ងាយ ដែលគេត្រូវដើរយ៉ាងកំសត់តែម្នាក់ឯង គ្មានមិត្តភក្ដិទៅជាមួយ។

2. ក្នុងលោកនេះមានអំពើអាក្រក់ប្រាំប្រការគឺ: ទី១ ភាពសាហាវឃោរឃៅ។ សត្វទាំងអស់ សូម្បីសត្វល្អិតតែងតែប្រកួតប្រឆាំងគ្នាទៅវិញទៅមក។ សត្វខ្លាំងប្រហារសត្វខ្សោយ។ សត្វខ្សោយបោកបញ្ឆោតសត្វខ្លាំង។ កន្លែងណាក៏ដោយ ក៏មានអំពើឃោរឃៅប្រកាប់ប្រចាក់គ្នាដែរ។

ទី២ គឺដំណើរគ្មានព្រំដែនកំណត់ជាក់លាក់រវាងសិទ្ធិរបស់

ឪពុក និងសិទ្ធិរបស់កូន រវាងសិទ្ធិរបស់កូនច្បង និងសិទ្ធិរបស់កូនពៅ រវាងសិទ្ធិរបស់ប្ដីនិងសិទ្ធិរបស់ប្រពន្ធ រវាងសិទ្ធិរបស់មនុស្សចាស់ និងសិទ្ធិរបស់មនុស្សក្មេង។ នៅគ្រប់កាលៈទេសៈម្នាក់ៗខំប្រឹងឲ្យបានខ្ពស់ជាងអ្នកឯទៀត ធៀតឲ្យបានលើអ្នកឯទៀត។ ម្នាក់បន្ទំម្នាក់ជាហេតុបណ្ដាលឲ្យមានការមិនទុកចិត្តគ្នា និងការលាក់ពុតរវាងគ្នានឹងគ្នា។

ទី៣ គឺដំណើរគ្មានព្រំដែនកំណត់ជាក់លាក់រវាងចរិយាមារយាទបុរស និងចរិយាមារយាទស្ត្រី។ ម្នាក់ៗលុះក្នុងបំណងអាក្រក់ ជាហេតុបណ្ដាលឲ្យមានការទាស់ទែងសម្ដីគ្នាជួនកាល រហូតដល់ទៅបណ្ដាលឲ្យមានការប្រវាយប្រតប់គ្នា ប្រព្រឹត្តអំពើអយុត្តិធម៌កាចឃោរឃៅ។

ទី៤ គឺមនុស្សលោកមានគំនិតមិនគោរពសិទ្ធិអ្នកដទៃធៀតរកប្រយោជន៍ផ្ទាល់ខ្លួន ដោយគ្មានគិតដល់ការខូចខាតប្រយោជន៍អ្នកដទៃ។ គេផ្ដល់គំរូអាក្រក់ដោយចរិយាអាក្រក់ ដោយពាក្យសម្ដីអាក្រក់ ដោយការបញ្ឆោតប្រវញ្ចន៍ដោយពាក្យមួលបង្កាច់ ដោយការជេរប្រមាថ។

ទី៥ គឺមនុស្សលោកមានគំនិតបំភ្លេចករណីយកិច្ចរបស់

ខ្លួនចំពោះអ្នកដទៃ។ គេគិតតែពីសុខុមាលភាពផ្ទាល់ខ្លួន គិតតែពីសេចក្ដីពេញចិត្តរបស់ខ្លួន។ គេភ្លេចអស់ហើយអំពើល្អទាំងពួងដែលគេបានទទួលពីអ្នកដទៃ ហើយគេមិនខ្លាចនឹងបង្កើតទុក្ខទោសដល់អ្នកដទៃទេ។

3. មនុស្សត្រូវតែមានមេត្រីភាពរវាងគ្នានឹងគ្នា ត្រូវចេះគោរពគ្នាទៅវិញទៅមក ហើយត្រូវចេះជួយគ្នាទៅវិញទៅមក ក្នុងគ្រាក្រលំបាក។ ប៉ុន្តែមិនអញ្ចឹងទេ មនុស្សលោកគិតតែពីខ្លួនឯង ហើយមានចិត្តរឹងរូស។ គេមើលងាយអ្នកឯទៀតដោយសារកំហុសដែលអ្នកទាំងនោះបានធ្វើ។ គេច្រណែននឹងអ្នកឯទៀតព្រោះតែអ្នកទាំងនោះបានប្រយោជន៍ច្រើនជាង។ ចិត្តអាក្រក់ទាំងនេះរីកធំឡើងៗរហូតដល់ទៅលែងចេះអត់ឱនគ្នាកើត។

ចិត្តជាសម្អប់ទាំងនេះ បណ្ដាលឲ្យកើតមានអំពើឃោរឃៅ។ ចិត្តអាក្រក់ទាំងនេះ បំពុលជីវិតដោយក្ដីស្អប់និងក្ដីខឹងក្រោធ ដែលបណ្ដាលឲ្យកើតចិត្តរបៀបនេះ។ មនោសញ្ចេតនាអាក្រក់ទាំងនេះ ផ្តិតជាប់យ៉ាងជ្រៅនៅក្នុងបេះដូងមនុស្សក្នុង

រយៈវិលរស់វិលស្លាប់នេះ។

ជាប្រាកដណាស់ ក្នុងលោកអភិជ្ឈានេះ មនុស្សកើតមកតែម្នាក់ឯង ហើយស្លាប់ទៅវិញតែម្នាក់ឯង។ ការទទួលផលកម្មពីអំពើដែលខ្លួនបានប្រព្រឹត្តក្នុងរយៈវិលកើតវិលស្លាប់ ក៏តែម្នាក់ឯងដែរ។

ច្បាប់ស្តីអំពីហេតុ និងផលនេះ វាសកលទូទៅ។ ម្នាក់ៗ ត្រូវតែស្គាល់យសំពាយកំហុសរបស់ខ្លួនដោយខ្លួនឯង ហើយទទួលផលកម្មតែម្នាក់ឯង។ ច្បាប់ស្តីអំពីហេតុ និងផលនេះ ក៏គ្រប់គ្រងលើអំពើល្អដែរ។ ការរស់នៅក្នុងសភាពល្អប្រកបដោយចិត្តមេត្តាប្រណី នឹងបានដល់នូវសម្បត្តិសួគ៌ា និងសុភមង្គល។

4. ក្នុងរយៈដែលខែនិងឆ្នាំ បេះតែកន្លងទៅមុខនេះ សត្វលោកឃើញខ្លួនជាប់ជំពាក់នឹងចំណង់ នឹងទម្លាប់ នឹងទុក្ខកាន់តែខ្លាំងឡើងៗ ក៏ទៅជាព្រួយចិត្ត ហើយអស់សង្ឃឹម។ ជាញឹកញាប់ ដោយសារតែសេចក្តីអស់សង្ឃឹមនេះ សត្វលោកបង្កើតជម្លោះនឹងអ្នកឯទៀត ហើយធ្លាក់កាន់តែជ្រៅឡើងៗទៅក្នុងបាបកម្ម លះបង់ចោលអស់នូវការខំប្រឹងប្រែង ដើរតាម

ផ្លូវល្អ។ មនុស្សខ្លះ ត្រូវអស់ជីវិតជាបន្ទាន់ដោយសារអំពើកាចឃោរឃៅរបស់ខ្លួន ហើយជាបន្តទៅទៀត គេត្រូវរងទុក្ខទោស រងកម្មពៀរមិនចេះចប់។

ធ្លាក់ខ្លួនក្នុងការអស់សង្ឃឹម ព្រោះតែមានក្ដីអភ័ព្វ មានទុក្ខព្រួយយ៉ាងនេះ មិនត្រូវតាមធម្មជាតិហើយនិងច្បាប់ឋានសួគ៌និងឋានកណ្ដាលនេះជាដាច់ខាត។ ដូច្នេះបុគ្គលទាំងនេះ មិនត្រឹមតែទទួលទុក្ខនៅក្នុងជាតិនេះប៉ុណ្ណោះទេ ទៅក្នុងជាតិជាបន្តទៅទៀត ក៏ត្រូវតែទទួលទុក្ខរងកម្មពៀរទៀត។

ជាការពិតដែលថា អ្វីៗនៅក្នុងលោកនេះ មិនឋិតថេរហើយពោរពេញទៅដោយភាពមិនទៀង។ ប៉ុន្តែជាការគួរឲ្យអាណោចអាធ័មណាស់ ដែលមនុស្សលោកមិនព្រមយល់រឿងពិតនេះ ហើយខំស្វែងរកតម្រេក និងការពេញចិត្តនឹងតម្រេកនោះ។

5. បើសិនជានៅក្នុងលោកនេះ ការគិតនិងការប្រព្រឹត្តទៅតាមអត្តទត្តភាពជាការធម្មតា ការទទួលទុក្ខវេទនាពីអំពើទាំងនេះ ក៏ជាការធម្មតាដូចគ្នាដែរ។

តណ្ហា

មនុស្សលោកគិតតែអំពីខ្លួនឯងផ្ទាល់ មិនរវល់នឹងអ្នកឯទៀតក្រៅពីខ្លួនឯងទេ។ គេបណ្ដោយឲ្យចំណង់របស់គេ ទៅជាការលោភលន់ ទៅជាអភិជ្ឈា ទៅជាអំពើលាមកគ្រប់បែបយ៉ាង។ នេះហើយដែលមនុស្សលោកត្រូវរងទុក្ខទោស រងកម្មពៀរមិនចេះចប់។

ពេលសប្បាយរីករាយនៅមិនយូរប៉ុន្មានទេ វានឹងវិនាសទៅវិញយ៉ាងឆាប់ ដូចកាលដែលវាមកដល់ដែរ។ ក្នុងលោកនេះ មិនអាចសប្បាយនឹងអ្វីមួយឲ្យបានយូរអង្វែងទេ។

6. ហេតុដូច្នេះ បុគ្គលត្រូវលះបង់អភិជ្ឈា ហើយនិងការជាប់ជំពាក់ចិត្តនឹងសម្បត្តិលោកនេះ ទាន់ខ្លួននៅក្មេងហើយមានសុខភាពល្អ។ បុគ្គលត្រូវខិតខំស្វែងរកផ្លូវនៃពន្លឺត្រាស់ដឹង ពីព្រោះគេមិនអាចមានសេចក្ដីស្ងប់មានសុភមង្គលបានទេនៅទីណាដែលគ្មានពន្លឺត្រាស់ដឹង។

ប៉ុន្តែមនុស្សជាច្រើនជឿប្រទ្បំ ហើយពុំយល់នូវច្បាប់ស្ដីអំពីហេតុនិងផលនេះ។ គេប្រព្រឹត្តតាមទម្លាប់អភិជ្ឈានិងអត្ត-ទត្តភាព។ គេភ្លេចថា អំពើល្អផ្ដល់សុភមង្គល អំពើអាក្រក់ផ្ដល់

ទុក្ខវេទនា។ គេមិនជឿប្រាកដទេថា អំពើទាំងឡាយដែលគេបានធ្វើក្នុងជាតិនេះ នឹងផ្តល់ផលកម្មទៅតាមអំពើអស់ទាំងនោះ ទៅជាតិមុខៗទៀត។ គេទម្លាក់ទុក្ខទោសដែលបណ្តាលមកពីអំពើរបស់គេទៅឲ្យអ្នកឯទៀត។

មនុស្សលោកអាណោចអាធ័មនឹងខ្លួនឯង ត្អូញត្អែរនឹងទុក្ខវេទនារបស់ខ្លួនផ្ទាល់។ គេមិនយល់ទាល់តែសោះថា អំពើដែលគេប្រព្រឹត្តក្នុងពេលបច្ចុប្បន្ននេះ នឹងផ្តល់ផលទៅក្នុងជីវិតអនាគតរបស់គេ។ គេមិនយល់ទាល់តែសោះនូវការទាក់ទងគ្នារវាងទុក្ខវេទនាក្នុងបច្ចុប្បន្នកាលរបស់គេនិងអំពើដែលគេបានប្រព្រឹត្តក្នុងជីវិតអតីតកាលរបស់គេ។ គេគិតតែអំពីចំណង់ក្នុងបច្ចុប្បន្នកាលរបស់គេតែប៉ុណ្ណោះ។ គេគិតពីទុក្ខ-វេទនាក្នុងបច្ចុប្បន្នកាលរបស់គេតែប៉ុណ្ណោះ។

នៅក្នុងលោកនេះ គ្មានអ្វីឋិតថេរទេ គ្មានអ្វីនៅជាប់ជាអង្វែងទេ។ អ្វីៗសុទ្ធតែប្រែប្រួលទាំងអស់ អ្វីៗទាំងអស់កើតឡើងតែមួយរយៈពេលប៉ុណ្ណោះ គ្មានអ្វីដែលអាចឲ្យទាយទុកមុនបានទេ។ ប៉ុន្តែមនុស្សលោកមានសេចក្តីល្ងង់ខ្លៅ ហើយនិងអត្តទត្ថភាព។ មនុស្សលោកចាប់អារម្មណ៍ទៅលើតែចំណង់

និងទុក្ខវេទនាក្នុងមួយរយៈវេលាតែប៉ុណ្ណោះ។ មនុស្សលោកមិនយកត្រចៀកស្តាប់សេចក្តីទូន្មានល្អទេ ហើយមិនខិតខំរកឲ្យយល់នូវសេចក្តីទូន្មានល្អទាំងនោះទេ។ មនុស្សលោកផ្តេកផ្តួលទៅលើអ្វីៗ ដែលខ្លួនចូលចិត្តត្រូវការក្នុងពេលភ្លាមៗ តែប៉ុណ្ណោះ ពោលគឺសម្បត្តិទ្រព្យនិងសេចក្តីសប្បាយ។

7. ជាច្រើនកោដិឆ្នាំមកហើយ មនុស្សរាប់មិនអស់បានកើតក្នុងលោកដែលពោរពេញទៅដោយការបំភាន់ភ្នែក និងទុក្ខវេទនានេះ ហើយនៅតែមានមនុស្សកើតឡើងក្នុងលោកនេះទៀត។ ប៉ុន្តែជាភ័ព្វសំណាងមួយ ដែលលោកនេះមានសាសនាព្រះពុទ្ធ ដែលមនុស្សលោកអាចជឿតាមបាន ហើយអាចទទួលការស្រោចស្រង់បានដោយសារជំនឿនេះ។

ដូចនេះមនុស្សលោកត្រូវគិតឲ្យដល់ទីជម្រៅ។ មនុស្សលោកត្រូវតែរក្សាចិត្តឲ្យបរិសុទ្ធ រក្សាខ្លួនឲ្យល្អ។ មនុស្សលោកត្រូវតែលះបង់អភិជ្ឈា ហើយនិងអំពើអាក្រក់ ហើយខំស្វែងរកសេចក្តីល្អ។

ជាសំណាងល្អ សេចក្តីទូន្មានរបស់ព្រះពុទ្ធបានមកដល់

ហើយៈ ដូច្នេះ យើងត្រូវខំជឿ និងប្រតិបត្តិតាម ហើយប្រាថ្នា ឲ្យបានទៅកើតក្នុងឋានបរិសុទ្ធរបស់ព្រះពុទ្ធ។ បើយើងដឹង ហើយយល់សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធហើយ យើងមិន ត្រូវដើរតាមផ្លូវឯទៀត ដែលនាំយើងទៅកាន់អភិជ្ឈា និងអំពើ បាបកម្មផ្សេងៗនោះឡើយ។ យើងក៏មិនត្រូវរក្សាសេចក្តីប្រៀន ប្រដៅរបស់ព្រះពុទ្ធ ទុកសម្រាប់តែខ្លួនឯងម្នាក់នោះឡើយ យើងត្រូវតែដាក់សេចក្តីប្រៀនប្រដៅនោះ ក្នុងការប្រតិ បត្តិ ហើយផ្សាយទៅឲ្យអ្នកឯទៀតជាបន្ត។

ចំពូកទី ៤

ការស្រោចស្រង់របស់ព្រះពុទ្ធ

I

សេចក្តីប្រាថ្នារបស់ព្រះពុទ្ធអមិដា

1. *ដូចយើងបានរែកញែកពន្យល់មកហើយ តាំងពីរាប់កោដិឆ្នាំមកហើយ មនុស្សលោករងទុក្ខទោសនឹងទម្ងន់តណ្ហារបស់ខ្លួនដោយសន្សំប្រមូលកំហុសត្រួតលើកំហុស។ ដូច្នេះ មនុស្សលោក មិនអាចយកគតិបណ្ឌិតរបស់ខ្លួនទៅរំលត់តណ្ហារបស់ខ្លួនបានឡើយ។ បើមិនអាចជម្នះតណ្ហារបស់ខ្លួនបានយ៉ាងដូច្នេះ តើធ្វើដូចម្តេចមនុស្សលោកអាចនឹងយល់ដឹងសភាពពិតរបស់ខ្លួន ពោលគឺសភាពព្រះពុទ្ធនោះបាន ?*

ព្រះពុទ្ធទ្រង់យល់សភាពមនុស្សយ៉ាងជាក់ច្បាស់ ហើយព្រះអង្គទ្រង់មានសេចក្តីករុណាអាសូរជាខ្លាំង។ ព្រះអង្គទ្រង់សច្ចាធិដ្ឋាន នឹងធ្វើគ្រប់អ្វីៗ ទាំងអស់ ដែលព្រះអង្គអាចធ្វើបាន សូម្បីព្រះអង្គត្រូវជួបប្រទះនឹងសេចក្តីលំបាក យ៉ាងណាក៏ដោយ

ចុះ ដើម្បីរំដោះសត្វលោកឲ្យរួចផុតពីតណ្ហា និងទុក្ខវេទនា។ ក្នុងគោលបំណងនេះព្រះអង្គទ្រង់បញ្ចេញឲ្យឃើញក្នុងភាពជាពោធិសត្វហើយសច្ចាធិដ្ឋាន ១០ ប្រការថា:

១-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធសត្វទាំងអស់ដែលទៅកើតក្នុងដែនដីអញ នឹងយល់យ៉ាងប្រាកដអំពីសភាពព្រះពុទ្ធ។ បើពុំនោះទេ អាត្មាអញមិនចង់បានជាព្រះពុទ្ធឡើយ។

២-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ រស្មីរបស់អញនឹងបែងចាំងទៅគ្រប់ទិសទី នាសាកលលោក។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

៣-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យអញអាចរំដោះសត្វលោកឲ្យបានច្រើនបំផុត ក្នុងរយៈជីវិតអាត្មាអញ បើពុំនោះទេអាត្មាអញមិនចង់បានជាព្រះពុទ្ធឡើយ។

៤-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យព្រះពុទ្ធទាំង១០ទិស ប្រកាសឈ្មោះអញ។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

៥-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យសត្វលោកណាដែលប្រាថ្នាទៅកើតក្នុងដែនដីអញ ហើយប្រកាសឈ្មោះអញដោយសុទ្ធចិត្តតែម្តងគត់ បានទៅកើតនៅក្នុងដែនដីអញៗ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយៗ

៦-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យសត្វលោកណាដែលប្រាថ្នាពន្លឺត្រាស់ដឹង ហើយបំពេញកុសលដោយសុទ្ធចិត្តដើម្បីបានទៅកើតក្នុងដែនដីអញបានឃើញតែពពួកពោធិសត្វ នៅព័ទ្ធជុំវិញរង់ចាំទទួលយកទៅឲ្យកើតក្នុងដែនដីបរិសុទ្ធរបស់អញ នៅពេលសត្វលោកនោះស្លាប់ទៅៗ បើពុំនោះទេ អញមិនចង់បានជាព្រះពុទ្ធឡើយៗ

៧-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធសូមឲ្យសត្វលោកទាំងអស់ដែលឮឈ្មោះអញ ដែលគិតដល់ផែនដីអញ ហើយបណ្តុះកុសលក្នុងសេចក្តីសង្ឃឹមយ៉ាងស្មោះថា នឹងទៅកើតក្នុងដែនដីអញបានសម្រេចដូចក្តីប្រាថ្នាៗ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយៗ

៨-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យសត្វលោកទាំងអស់ដែលទៅកើតក្នុងដែនដីអញ បានសម្រេចជា

ប្រាកដនូវសភាពព្រះពុទ្ធដើម្បីអាចដឹកនាំសត្វលោកទៅកាន់ពន្លឺត្រាស់ដឹងដ៏ពេញលេញ។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

៩-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យពន្លឺមហាករុណាអាសូររបស់អញ បានគ្របដណ្ដប់ទៅលើសត្វលោកទាំងអស់ក្នុងពិភពលោកទាំងមូល ញុំាងឲ្យវិញ្ញាណនិងកាយនៃសត្វលោកទាំងនោះបានបរិសុទ្ធ ហើយលើកសត្វលោកទាំងនោះ ឲ្យខ្ពស់ផុតពីលោកនេះ។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

១០-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យមនុស្សក្នុងលោកទាំងមូលដែលបានឮឈ្មោះអញ បានយល់នូវសេចក្ដីពិតអំពីការកើត និងការស្លាប់ បានទទួលនូវមហាគតិបណ្ឌិតដែលអាចញុំាងឲ្យចិត្តបានស្ងប់នាកណ្ដាលទុក្ខវេទនានៃលោកនេះ។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

ដូច្នេះអញសច្ចាថា នឹងមិនត្រាស់ជាព្រះពុទ្ធទេដរាបណាសេចក្ដីសច្ចាធិដ្ឋានរបស់អញទាំងនេះមិនទាន់បានសម្រេច។ អញសូមប្រាថ្នាឲ្យបានជាប្រភពនៃពន្លឺគ្មានទីបំផុត ដែលចែង

ចាំងផ្សព្វផ្សាយទៅនូវកំណាប់ប្រាជ្ញាញាណនិងកុសលរបស់អញ ដើម្បីដាស់តឿនបំភ្លឺ និងសង្គ្រោះសត្វក្នុងលោកនេះ។

2. ក្រោយពីថ្ងៃងសច្ចាធិដ្ឋានទាំងនេះ ហើយសន្សំកុសលជាច្រើនឥតគណនា ក្នុងកាលវេលារាប់មិនអស់ ព្រះអង្គបានបង្កើតដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ ហើយបានត្រាស់ជាព្រះពុទ្ធអាមិដា ព្រះពុទ្ធនៃពន្លឺនិងជីវិតគ្មានទីបំផុត។ សព្វថ្ងៃព្រះអង្គគង់នៅឯសុភលោក ប្រៀនប្រដៅបំភ្លឺជនទាំងឡាយដែលរស់នៅក្នុងដែនដីព្រះអង្គ។

នៅក្នុងដែនដីបរិសុទ្ធសុខស្ងប់នោះគ្មានទុក្ខព្រួយទេ។ ម្នាក់ៗអាចបានរបស់ដែលខ្លួនចង់បានដូចជាសំលៀកបំពាក់ក្តី ចំណីអាហារក្តី វត្ថុទិព្វឯទៀតៗក្តី។ ខ្យល់ត្រជាក់ស្រួលបក់រំភើយតាមដើមព្រឹក្សាប្រកបដោយផ្លែផ្កាជាត្បូងរ័តន៍។ សំឡេងតន្ត្រីព្រះធម៌សែនពីរោះ ធ្វើឲ្យចិត្តអ្នកដែលស្តាប់ឮបានឡើងបរិសុទ្ធ។

នៅក្នុងដែនដីបរិសុទ្ធនោះ មានផ្កាឈូកដែលមានស្រទាប់ស្រស់ៗ ច្រើនរាប់មិនអស់ដុះពាសពេញ។ រស្មីទិព្វនៃស្រទាប់

ផ្កាឈូកទាំងនោះ បែងចាំងឡើងនូវប្រាជ្ញាញាណរបស់ព្រះពុទ្ធ អ្នកដែលបានស្ដាប់ព្ធតន្ត្រីទិព្វនៃពុទ្ធោវាទយ៉ាងពិសិដ្ឋនោះនឹងបានដល់នូវសុភមង្គលពេញលេញឥតខ្ចោះ។

3. ឥឡូវនេះ ព្រះពុទ្ធគ្រប់ទិសទាំង ១០ ប្រកាសកុសលព្រះពុទ្ធអមិដា ដែលជាព្រះពុទ្ធនៃពន្លឺ និងជីវិតគ្មានទីបំផុត។

អ្នកដែលបានឮព្រះនាមព្រះពុទ្ធអង្គនេះជឿទុកចិត្តលើព្រះអង្គដោយទឹកចិត្តរីករាយជ្រះថ្លា ឃើញចិត្តរបស់ខ្លួនរលាយចូលទៅក្នុងចិត្តរបស់ព្រះពុទ្ធហើយ នឹងបានទៅកើតក្នុងដែនដីទិព្វបរិសុទ្ធរបស់ព្រះពុទ្ធ។

អ្នកដែលបានទៅដល់ដែនដីបរិសុទ្ធរបស់ព្រះពុទ្ធហើយនឹងបានទទួលជីវិតគ្មានទីបញ្ចប់។ ចិត្តរបស់គេនឹងបានពោរពេញនូវសេចក្ដីករុណា អាសូរចំពោះសត្វលោកដូចព្រះពុទ្ធដែរហើយគេនឹងចេញទៅផ្សាយ មធ្យោបាយសង្គ្រោះរបស់ព្រះពុទ្ធអមិដានៅគ្រប់ទីកន្លែង។

គេតាំងចិត្តលះបង់ការជំពាក់ចិត្តនឹងលោកិយនេះ ហើយគេយល់ជាក់អំពីភាពមិនឋិតថេរនៃវត្ថុទាំងឡាយ។ គេបញ្ជូន

កុសលរបស់គេ ទៅជួយសង្គ្រោះសត្វលោក។ គេបញ្ជូនជីវិតរបស់គេ ទៅក្នុងជីវិតរបស់អ្នកដែលរស់នៅក្នុងសេចក្ដីទុក្ខវេទនា។ គេចែករំលែកយកនូវការបំភាន់ភ្នែកនិងទុក្ខវេទនា ហើយក្នុងពេលជាមួយគ្នានោះ គេរំដោះខ្លួនគេឲ្យផុតពីការជំពាក់ចិត្តនឹងលោកិយនេះ។

ដោយគេយល់ច្បាស់អំពីឧបសគ្គ និងសេចក្ដីលំបាកផ្សេងៗនៃលោកនេះ គេដឹងថាអានុភាពនៃសេចក្ដីករុណាអាសូររបស់ព្រះពុទ្ធគ្មានព្រំដែនទេ។ គេអាចដើរទៅមុខឬថយក្រោយវិញ ឬឈប់ស្ងៀមបានតាមចិត្តដែលគេយល់ថាត្រឹមត្រូវល្អ។ ប៉ុន្តែគេសម្រេចចិត្តនៅជាមួយអ្នកដែលទទួលយកសេចក្ដីករុណាអាសូររបស់ព្រះពុទ្ធ។

ដូច្នេះអ្នកដែលឮព្រះនាមព្រះពុទ្ធអមិដា ហើយប្រកាសព្រះនាមព្រះអង្គដោយចិត្តស្មោះត្រង់ នឹងបានទទួលនូវសេចក្ដីករុណាអាសូររបស់ព្រះពុទ្ធ។ ដូច្នេះសត្វលោកទាំងអស់ត្រូវតែស្ដាប់ជឿ ហើយប្រតិបត្តិតាមសេចក្ដីទូន្មានរបស់ព្រះពុទ្ធ ទោះបីសម្រាប់ករណីនេះ គេត្រូវឆ្លងកាត់អណ្ដាតភ្លើងនៃការកើត និងស្លាប់នៃលោកិយនេះក៏ដោយ។

អ្នកណា ដែលប្រាថ្នាដោយសុទ្ធចិត្តឲ្យបានសម្រេចនូវពន្លឺត្រាស់ដឹងត្រូវតែពឹងផ្អែកអានុភាពព្រះពុទ្ធពីព្រោះមនុស្សលោកជម្មតា មិនអាចយល់នូវសភាពព្រះពុទ្ធខ្ពង់ខ្ពស់បំផុតរបស់ខ្លួនបានទេ បើអត់ជំនួយពីព្រះពុទ្ធអមិដា។

4. ព្រះពុទ្ធអមិដា មិននៅឆ្ងាយពីយើងទេ។ ថ្វីបើដែនដីបរិសុទ្ធរបស់ព្រះអង្គត្រូវបានពិពណ៌នាថា ស្ថិតនៅសែនឆ្ងាយអំពីលោកនេះយ៉ាងណាក៏ដោយ ដែនដីនោះនៅជិតបង្កើយ នឹងចិត្តរបស់អ្នកដែលប្រាថ្នាពន្លឺត្រាស់ដឹង ហើយមានសទ្ធាមោះមុត នឹងព្រះពុទ្ធអមិដា ហើយប្រកាសព្រះនាមព្រះអង្គដោយស្មោះ។

បើគេនឹកគិតគូររូបភាពព្រះពុទ្ធអមិដា នៅក្នុងវិញ្ញាណរបស់គេ រូបភាពនោះចេញឡើងជាពណ៌មាសមានទិដ្ឋភាព ៨៤០០០ ហើយទិដ្ឋភាពនីមួយៗបញ្ចេញ៨៤០០០កាំរស្មី។ កាំរស្មីនីមួយៗសាយជះពន្លឺទៅគ្រប់ទិសទាំង១០ ក្នុងពិភពលោកបំភ្លឺជនទាំងឡាយណាដែលប្រកាសព្រះនាមព្រះពុទ្ធ។ ហេតុដូច្នេះហើយ បានជាព្រះពុទ្ធខិតខំជ្រោមជ្រែងឲ្យមនុស្សលោកទាំងអស់ ឆ្លៀតទទួលយកនូវការសង្គ្រោះ ដែលព្រះអង្គ

ទ្រង់ប្រទាន។

ការមើលឃើញរូបភាពរបស់ព្រះពុទ្ធនេះអាចនាំឲ្យយើងយល់ច្បាស់នូវព្រះទ័យព្រះពុទ្ធ។ ចិត្តរបស់ព្រះពុទ្ធពោរពេញទៅដោយមហាករុណាអាសូរ ដែលលាតសន្ធឹងរហូតទៅដល់អ្នកដែលមិននឹកនាវរល់ដល់ព្រះអង្គ ហើយជាប្រាកដណាស់ដល់អ្នកមានសទ្ធាជ្រះថ្លា នឹងព្រះអង្គ។

អ្នកមានសទ្ធាជ្រះថ្លានឹងព្រះអង្គ នឹងបានជាអ្នក រួបរួមនឹងព្រះអង្គ។ ចិត្តព្រះពុទ្ធចូលទៅគ្រប់ទិសទី ដូច្នេះចិត្តព្រះពុទ្ធពិតជាចូលទៅក្នុងចិត្តអ្នកដែលជឿព្រះអង្គ។

សេចក្ដីនេះបានន័យថា បុគ្គលណាគិតដល់ព្រះពុទ្ធបុគ្គលនោះនឹងមានចិត្តបរិសុទ្ធ ចិត្តដែលបណ្ដាលឲ្យបានប្រកបនូវសេចក្ដីសុខស្ងប់ និងសុភមង្គលពេញលេញ។ បើនិយាយឲ្យខ្លីទៅចិត្តបុគ្គលនោះ គឺចិត្តព្រះពុទ្ធ។

ដូច្នេះ បុគ្គលណាដែលជឿដោយសុទ្ធចិត្តចំពោះព្រះពុទ្ធបុគ្គលនោះមានចិត្តជាព្រះពុទ្ធ។

5. ព្រះពុទ្ធមានសម្បទាអាចក្លែងភេទបានគ្រប់បែបយ៉ាង។

ព្រះអង្គ អាចបញ្ចេញឲ្យឃើញនៅចំពោះមុខមនុស្សទាំងឡាយក្នុងសភាពផ្សេងៗទៅតាមសមត្ថភាពរបស់មនុស្សម្នាក់ៗ ដែលអាចយល់បាន។

មធ្យោបាយបញ្ចេញឲ្យឃើញឡើងរបស់ព្រះពុទ្ធអមិដាជាសកលហើយគ្មានទីបំផុតទេ វាហួសផុតពីការស្មានយល់របស់មនុស្សលោក។ ព្រះអង្គអាចបញ្ចេញឲ្យឃើញឡើងនៅក្នុងលោកទាំងមូល នៅក្នុងធម្មជាតិរហូតដល់នៅក្នុងមនុស្សជាតិទៀតផងក៏មាន។

តែនៅក្នុងសភាពណាក៏ដោយ ព្រះអង្គតែងតែបញ្ចេញឲ្យឃើញឡើងជាប្រត្យក្សនៅក្នុងវិញ្ញាណ របស់អ្នកដែលប្រកាសព្រះនាមព្រះអង្គដោយសុទ្ធចិត្ត។ នៅពេលដែលព្រះអង្គយាងមក ព្រះអង្គតែងតែនាំពោធិសត្វពីរព្រះអង្គមកជាមួយគឺព្រះពោធិសត្វអវលោកិតេស្វរៈ ពោលគឺព្រះពោធិសត្វមហាករុណាអាសូរ និងព្រះពោធិសត្វមហាធម្មាប្រធាន ពោលគឺព្រះពោធិសត្វប្រាជ្ញាញាណ។ ព្រះពុទ្ធអមិដា បញ្ចេញឲ្យឃើញឡើងពាលពេញពិភពលោក សម្រាប់ឲ្យមនុស្សលោកទូទៅមើលឃើញ ប៉ុន្តែមានតែអ្នកដែលមានសទ្ធាជ្រះថ្លានឹង

ព្រះអង្គទេ ដែលសំគាល់ឃើញព្រះអង្គ។

អ្នកដែលអាចមើលឃើញរូបកាយព្រះពុទ្ធ នឹងបានប្រកប សេចក្ដីសប្បាយរីករាយនិងសុភមង្គលជាច្រើនអនេក ហើយ ជាងនេះទៅទៀត អ្នកដែលអាចជួបនឹងព្រះពុទ្ធដោយប្រត្យក្ស នៅក្នុងដែនដីបរិសុទ្ធរបស់ព្រះអង្គ នឹងបានទទួលនូវសេចក្ដី សុខក្សេមក្សាន្តគ្មានទីចប់។

6. ព្រះពុទ្ធអមិដា ដែលមានព្រះទ័យពោរពេញនូវក្ដីករុណា អាសូរ និងព្រហ្មចារិភាព ព្រះអង្គរំដោះសត្វលោកគ្រប់ប្រភេទ ទាំងអស់។

បុគ្គលណា ដែលដោយសារសេចក្ដីល្ងង់ខ្លៅ ប្រព្រឹត្តកំហុស ធំដូចជាបុគ្គល ដែលមានចិត្តពោរពេញទៅដោយក្ដីលោភលន់ ក្ដីខឹងក្រោធ ក្ដីវក់ឆ្កួត បុគ្គលដែលភូតភរកុហក ដែលនិយាយ ច្រើនឥតប្រយោជន៍ ដែលនិយាយអាក្រក់ពីគេ ដែលបោក បញ្ឆោតគេ បុគ្គលដែលសម្លាប់គេ លួចប្លន់គេ ប្រព្រឹត្តអំពើ មេថុន មនុស្សទាំងឡាយណាដែលប្រព្រឹត្តទោសកំហុសទាំង ១០ ប្រការនេះ ដល់ស្លាប់ទៅនឹងទទួលកម្មពៀរអស់កាលដ៏

យូរអង្វែង។

ប៉ុន្តែនៅពេលហៀបនឹងអស់ជីវិតទៅ មានអ្នកប្រកបដោយគតិបណ្ឌិតជាមិត្តម្នាក់បានប្រាជកឡើង ហើយឧទានទៅកាន់មនុស្សទាំងនោះថា: «ឥឡូវនេះអ្នកជិតដល់នូវសេចក្ដីមរណៈហើយ អ្នកពុំអាចលះបង់ជីវិតពុករលួយរបស់អ្នកបានទេ ។ ប៉ុន្តែអ្នកអាចទៅរកទីជម្រកក្នុងព្រហ្មវិហារធម៌របស់ព្រះពុទ្ធដែលជាទីជម្រកសុខសាន្តបាន បើអ្នកសូត្រព្រះនាមព្រះអង្គ»។

បើមនុស្សពុករលួយទាំងនោះ សូត្រព្រះនាមព្រះពុទ្ធអមិដាដោយចិត្តស្មោះត្រង់ មនុស្សទាំងនោះនឹងបានរួចអំពីកម្មពៀរ។

បើគ្រាន់តែសូត្រព្រះនាមព្រះពុទ្ធតែប៉ុណ្ណោះ ក៏អាចរួចផុតពីកម្មពៀរដែរនោះ ការសង្រួមចិត្តជឿទៅលើព្រះពុទ្ធដោយស្មោះត្រង់ រឹតតែប្រសើរណាស់ទៅទៀត។

អ្នកដែលអាចសូត្រព្រះនាមពិសិដ្ឋនេះបាន នៅពេលជិតអស់សង្ខារ នឹងអាចបានជួបនឹងព្រះពុទ្ធអមិដា។ ពោធិសត្វមហាករុណាអាសូរ និងពោធិសត្វព្រហ្មចារិភាព ទាំង ពីរអង្គនោះនឹងមកនាំអ្នកនោះទៅកាន់ដែនដីព្រះពុទ្ធ ហើយគេនឹង

បានទៅកើតក្នុងភាពបរិសុទ្ធ ដូចផ្កាឈូកស ក្បុស។

ហេតុដូច្នេះជនរាល់រូបត្រូវតែចាំជាប់ក្នុងចិត្តនូវធម្មសូត្រ «**នមោ អមិតា ពុទ្ធោ**» ដែលមានន័យថា «គារវកក្តីដោយសុទ្ធចិត្តចំពោះព្រះពុទ្ធនៃពន្លឺនិងជីវិតឥតទីចប់»។

II

ដែនដីបរិសុទ្ធរបស់ព្រះពុទ្ធអមិដា

1. ព្រះពុទ្ធនៃពន្លឺនិងជីវិតឥតទីចប់ ឋិតមាននៅជានិច្ចមិនចេះចប់ទេ។ ព្រះអង្គផ្សព្វផ្សាយព្រះធម៌ជាអចិន្ត្រៃយ៍។ នៅក្នុងដែនដីបរិសុទ្ធរបស់ព្រះអង្គ គ្មានទុក្ខវេទនាគ្មានភាពងងឹតទេ។ ជីវិតរស់នៅកន្លែងនោះសប្បាយរីករាយរហូត។ ហេតុនេះហើយបានជាផែនដីនោះ ត្រូវបានហៅថា: «ដែនដីសុកមង្គល»។

នៅក្នុងដែនដីនោះ មានស្រះដែលមានទឹកភ្លឺថ្លាបរិសុទ្ធត្រជាក់ស្រួល បាញ់សាចចេញឡើង។ រលកទឹកនោះហាក់លោតទៅប៉ប្រះនឹងច្រាំងខ្សាច់មាស ដោយភាពថ្នាក់ថ្នម។ នៅទីណាក៏មានផ្កាឈូកគ្រប់ពណ៌មានទំហំប៉ុនកង់រទេះរីកស្គុស

ស្គាយដែរ។ ផ្កាឈូកពណ៌ខៀវបញ្ចេញរស្មីខៀវ ផ្កាឈូកពណ៌លឿងបញ្ចេញរស្មីលឿង ផ្កាឈូកក្រហមបញ្ចេញរស្មីក្រហម ផ្កាឈូកពណ៌ស បញ្ចេញរស្មីស។ ក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់ផ្សាយផ្សព្វទៅគ្រប់ទិសទី។

នៅជុំវិញស្រះស្រង់នោះ មានវិមានមាសវិមានប្រាក់វិមានកែវមរកត ដែលមានកាំជណ្ដើរថ្មកែវ ចុះទៅប៉ប្រះ នឹងផ្ទៃទឹក។ មានបង្កាន់ដៃលំអដោយរនាំងក្បូងត្បូងរ័តន៍ព័ទ្ធជុំវិញស្រះ។ នាកណ្ដាលបង្កាន់ដៃទាំងនោះមានរុក្ខាតូចៗ ចោលក្លិនក្រអូបឈ្ងុយឈ្ងប់ និងគុម្ពោតរុក្ខជាតិដែលមានផ្ការីកស្គុសស្គាយ។

ផ្ទៃដីបញ្ចេញសោភណភាពគ្មានពីរ ផ្ទៃមេឃបន្លឺតន្ត្រីទិព្វយ៉ាងរងំ។ ប្រាំមួយដងក្នុងពេលថ្ងៃ និងប្រាំមួយដងក្នុងពេលយប់ស្រទាប់ផ្កាគ្រប់ពណ៌ល្អឆើត ជ្រុះសាយសព្វពីនភាល័យ។ ជនទាំងឡាយនៅឋាននោះ នាំគ្នារើសប្រមូលផ្កាជ្រុះមកនោះដាក់ក្នុងថូ យកទៅថ្វាយព្រះគ្រប់អង្គ។

2. នៅក្នុងដែនដីទិព្វនោះមានសត្វបក្សីបក្សាជាច្រើន ដូចជា

ហង្សពណ៌សដូចផ្កាទឹកក សេកសោម ក្ងោករំលេចពណ៌ភ្លឺ ផ្ទេកៗ បក្សីឋានសួគ៌ និងហ្វូងបក្សីតូចៗឃំតិចៗ យ៉ាងពីរោះរងំៗ នៅក្នុងដែនដីព្រះពុទ្ធ សត្វបក្សីទាំងនោះសូត្រពាក្យទូន្មានរបស់ព្រះពុទ្ធ ច្រៀងសរសើរកុសលរបស់ព្រះអង្គដោយសំឡេងផ្អែមត្រជាក់។

អ្នកដែលបានស្តាប់ឮបទចម្រៀងនៃបក្សីទាំងនោះ បានឮពុទ្ធវាចា ហើយគេនឹកឃើញជាថ្មីឡើងទៀត នូវជំនឿស្មោះត្រង់របស់គេ នូវសេចក្ដីសប្បាយ និងសុខសន្តិភាពរបស់គេដែលបានរស់នៅក្នុងសង្គមពុទ្ធបរិស័ទ។

ខ្យល់រំភើយត្រជាក់ស្រួល បក់តាមចន្លោះដើមព្រឹក្សានៃដែនដីបរិសុទ្ធនោះទៅអង្រួនក្នុងមណ្ឌាបល្អថ្លៃថ្លា ប្រគំឡើងជាតន្ត្រីយ៉ាងរងំៗ

អ្នកដែលបានឮតន្ត្រីឋានសួគ៌នោះ នឹកឃើញដល់ព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃ។ សុក្រឹតភាពទាំងអស់នេះ គឺជាពន្លឺរស្មីនៃទិដ្ឋភាពជាធម្មតាបំផុត ដែលបែងចាំងឡើង នៅក្នុងដែនដីព្រះពុទ្ធនោះ។

3. ហេតុដូចម្ដេចបានជាព្រះពុទ្ធនៃដែនដីនោះ មានព្រះនាមថា អមិដា ឬព្រះពុទ្ធនៃពន្លឺនិងជីវិតឥតទីបញ្ចប់? ព្រោះរស្មីនៃព្រហ្មចរិយធម៌របស់ព្រះអង្គ បែងចាំងទៅគ្រប់ទិសទីនាសកលលោក ហើយព្រោះរយៈវេលានៃជីវិតមហាករុណាអាសូររបស់ព្រះអង្គមិនចេះចប់ទេ។

ហេតុដូច្នេះ ចំនួនអ្នកដែលបានទៅកើតក្នុងដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ ហើយបានសម្រេចពន្លឺត្រាស់ដឹងពេញលេញគ្រប់នោះ រាប់មិនអស់ទេ។ អ្នកទាំងនោះមិនវិលត្រឡប់មកក្នុងលោកបំភាន់ភ្នែកនៃការកើត និងការស្លាប់នេះជាដាច់ខាត។

ចំនួនអ្នកដែលបានភ្ញាក់រលឹកនឹកគិតទៅដល់ជីវិតថ្មីនោះដោយសារពន្លឺរបស់ព្រះពុទ្ធ ក៏រាប់មិនអស់ដែរ។

ហេតុនេះ សត្វលោកក៏ត្រូវតែរក្សាទុកឲ្យខ្ជាប់ខ្ជួនក្នុងចិត្តនូវព្រះនាមព្រះអង្គគឺៈ **«នមោ អមិតា ពុទ្ធោ»**។ ហើយតែមួយថ្ងៃក្ដី ឬមួយអាទិត្យក្ដី គួរតែសូត្រព្រះនាមរបស់ព្រះអង្គដោយជំនឿសុទ្ធចិត្ត។ ធ្វើយ៉ាងនេះដល់ពេលស្លាប់ទៅគេនឹងបានទៅកើតក្នុងដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ ដែលមានព្រះ

ពុទ្ធអមិដា ជួបជុំ ដោយពពួកអង្គសាវ័ក ជាអ្នកដឹកនាំ។

បុគ្គលណាបានឮព្រះនាមព្រះពុទ្ធអាមិដា ជឿតាមសេចក្តីប្រៀនប្រដៅរបស់ព្រះអង្គ បុគ្គលនោះនឹងបានសម្រេចពន្លឺត្រាស់ដឹង ប្រសើរខ្ពង់ខ្ពស់បំផុត។

វត្តប្រតិបត្តិព្រះពុទ្ធសាសនា

ចំពូកទី ១

វិធីធ្វើឲ្យចានបរិសុទ្ធ

I

វិធីធ្វើឲ្យចិត្តចានបរិសុទ្ធ

1. *សត្វលោកមានតណ្ហាលោកិយដែលបណ្ដាលឲ្យកើតមានការភាន់ច្រឡំ និងទុក្ខវេទនា។ មានវិធី៥ ដើម្បីនឹងរំដោះខ្លួនឲ្យផុតពីចំណងនៃតណ្ហាលោកិយ។*

ទី១ គឺត្រូវមានគតិត្រឹមត្រូវចំពោះវត្ថុទាំងអស់ គឺគតិប្រកបដោយការសង្កេតយ៉ាងពិនិត្យពិច័យជាគ្រឹះហើយត្រូវចេះយល់នូវហេតុនិងផលគឺយល់ន័យនៃហេតុនិងផលនេះឲ្យបានត្រឹមត្រូវ។ ទុក្ខវេទនាស្ថិតនៅក្នុងចំណង់និងការជំពាក់នៃចិត្ត ចំណង់និងការជំពាក់នៃចិត្តទាក់ទងនឹងការយល់ខុសអំពីការថាមានអាត្មាអញ ហើយមិនគិតដល់អត្ថន័យនៃច្បាប់ស្ដីអំពីហេតុ និងផល ហើយរឿងទាំងអស់នេះកើតមកអំពីការពិចារណាខុសចំពោះវត្ថុជាតុ។ ហេតុនេះ សេចក្ដីសុខស្ងប់

នឹងអាចកើតឡើងបាន លុះណាតែចិត្តលះបង់ឲ្យដាច់ស្រឡះពីតណ្ហាលោកិយទាំងនេះ។

ទី២ គឺមនុស្សលោកអាចលះបង់ចោលការយល់ខុសទាំងនេះ ហើយចាកផុតពីតណ្ហាទាំងឡាយ ដែលចេញមកពីការយល់ខុសទាំងនេះបាន លុះណាតែចេះអត់ធ្មត់គ្រប់គ្រងចិត្តឲ្យបានហ្មត់ចត់។ ដោយសារការចេះគ្រប់គ្រងចិត្តឲ្យបានស័ក្តិសិទ្ធិនេះ មនុស្សអាចចៀសផុតពីចំណង់ទាំងឡាយ ដែលកើតឡើងពីវិញ្ញាណអារម្មណ៍នៃភ្នែក ត្រចៀក ច្រមុះ អណ្តាត ស្បែកនិងសកម្មភាពនៃចិត្ត ហើយដោយសារអំពើនេះ មនុស្សលោកអាចកាត់ផ្តាច់បាននូវឫសកែវនៃគ្រប់តណ្ហាលោកិយ។

ទី៣ គឺមនុស្សលោកត្រូវចេះគិតគូរប្រើប្រាស់វត្ថុទាំងឡាយឲ្យបានត្រឹមត្រូវតាមគន្លង។ ពោលគឺចំពោះចំណីអាហារ និងសំលៀកបំពាក់ មនុស្សលោកមិនត្រូវទុកដូចជាប្រភពនៃសុខុមាលភាព និងសេចក្តីសប្បាយរីករាយទេ គឺទុកដូចត្រឹមតែជាគ្រឿងឧបត្ថម្ភផ្គត់ផ្គង់សេចក្តីត្រូវការនៃរូបកាយ តែប៉ុណ្ណោះបានហើយ។ សំលៀកបំពាក់ ជាគ្រឿងចាំបាច់សម្រាប់ការពារអង្គប្រាណនឹងកំដៅថ្ងៃ និងធាតុអាកាសត្រជាក់ហួសប្រមាណ

និងសំរាប់បិទបាំងកេរខ្មាស។ ចំណីអាហារជាវត្ថុចាំបាច់សម្រាប់ទ្រទ្រង់រូបកាយក្នុងពេលដែលគេកំពុងធ្វើវត្តប្រតិបត្តិឆ្ពោះទៅរកពន្លឺត្រាស់ដឹង និងពុទ្ធភាវៈ។ តណ្ហាលោកិយទាំងឡាយមិនអាចកើតមានឡើងបានទេ បើគេចេះរបៀបបរិះគិតពិចារណាដ៏ត្រឹមត្រូវនេះ។

ទី៤ គឺមនុស្សលោកត្រូវរៀនឲ្យចេះអត់ធន់: ត្រូវរៀនឲ្យចេះអត់ទ្រាំនឹងភាពមិនសុខស្រួល ដែលបណ្ដាលមកអំពីកំដៅថ្ងៃ អំពីធាតុអាកាសត្រជាក់ និងអំពីការស្រេកឃ្លាន។ ត្រូវរៀនឲ្យចេះមានការអំណត់ កាលណាមានគេប្រព្រឹត្តអំពើអាក្រក់មកលើខ្លួន ឬគេប្រមាថមើលងាយខ្លួន។ ដោយសារការហាត់រៀនឲ្យចេះអត់ធន់នេះមនុស្សលោកអាចពន្លត់ភ្លើងតណ្ហាលោកិយ ដែលឆេះរោលរាលអង្គប្រាណនោះបាន។

ទី៥ គឺមនុស្សលោកត្រូវរៀនចៀសវាងនូវគ្រោះថ្នាក់ទាំងឡាយ។ ដូចជាបណ្ឌិតគេចចៀសពីសេះព្រៃ និងឆ្កែកាចមនុស្សលោក ក៏មិនត្រូវចងមិត្តនឹងមនុស្សកំណាច ឬទៅកន្លែងណាដែលបណ្ឌិតចៀសវាងនោះដែរ។ បើគេហាត់រៀនឲ្យចេះប្រយ័ត្នប្រយែងយ៉ាងនេះបាន ភ្លើងតណ្ហាលោកិយ

ដែលឆេះពេញពាលជីវិត មនុស្សលោកនឹងវិនាសសូន្យ។

2. ចំណង់លោកិយចែកចេញជា ៥ ចំពូកគឺ: ចំណង់ដែលកើតឡើងពីភ្នែកមើលឃើញ១ ចំណង់ដែលកើតឡើងពីត្រចៀកស្តាប់ឮ១ ចំណង់ដែលកើតឡើងពីគន្ធដែលច្រមុះធុំក្លិន១ ចំណង់ដែលកើតឡើងពីរសជាតិដែលអណ្តាតភ្លក់ក្រេប១ ចំណង់ដែលកើតឡើងពីការស្ទាបប៉ះនៃកាយវិញ្ញាណ១។ គឺមកអំពីចំណង់ទាំង៥ចំពូកនេះហើយ ដែលបណ្តាលឲ្យមានការចាប់ចិត្តស្រឡាញ់ចំពោះសុខុមាលភាពនៃរូបកាយ។

បុគ្គលជាច្រើន ដោយលុះក្នុងចំណាចនៃសេចក្តីស្រឡាញ់សុខុមាលភាពនៃរូបកាយនេះ មិនបានចាប់ភ្ញឹកគិតដល់ហេតុផលអាក្រក់ ដែលកើតឡើងអំពីសេចក្តីនេះទេ ហើយបុគ្គលទាំងនោះត្រូវបានជាប់អន្ទាក់បិសាចចង្រៃ ដូចជាសត្វប្រើសជាប់អន្ទាក់ព្រានដូច្នោះដែរ។ ជាការពិតណាស់ ចំណង់ទាំងប្រាំចំពូក ដែលកើតឡើងពីវិញ្ញាណបសាទទាំងប្រាំនេះ ជាអន្ទាក់ប្រកបដោយគ្រោះថ្នាក់ធំជាទីបំផុត។ មនុស្សលោកដោយបណ្តោយខ្លួនឲ្យជាប់អន្ទាក់ទាំងនេះ ក៏ត្រូវបានជាប់ជំពាក់នឹង

តណ្ហាលោកកិយ ហើយក៏ត្រូវរងទុក្ខវេទនា។ មនុស្សលោកត្រូវចេះវិធីរំដោះខ្លួនឲ្យរួចពីអន្ទាក់នៃចំណង់ទាំងប្រាំចំពូកនេះ។

3. ពុំមែនមានតែផ្លូវមួយទេ ដើម្បីរំដោះខ្លួនឲ្យឱ្យរួចពីអន្ទាក់តណ្ហាលោកិយនេះ។ ឧបមាថាបើគេចាប់ពស់១ ក្រពើ១ សត្វស្លាប១ ឆ្កែ១ កញ្ជ្រោង១ និងស្វា១ សត្វ៦ប្រភេទដែលមានចរិតខុសគ្នាស្រឡះ ហើយចងសត្វទាំងនោះនឹងខ្សែជាប់មាំមួយជាមួយគ្នា សត្វទាំង៦នោះនឹងខំរំដោះខ្លួនរត់ត្រឡប់ទៅទីជម្រកតែសព្វខ្លួនវិញ តាមរបៀបផ្ទាល់ខ្លួនវានីមួយៗ។ ពស់នឹងខំលូនទៅរកទ្រុបស្មៅ ក្រពើនឹងខំវារសំដៅទៅរកទឹក បក្សីនឹងខំហើរសំដៅទៅរកផ្ទៃអាកាស ឆ្កែនឹងខំរើរត់សំដៅទៅរកភូមិ កញ្ជ្រោងនឹងខំរត់សំដៅទៅរកកៀនស្ងាត់ ស្វានឹងខំប្រះរត់សំដៅទៅរកដើមឈើក្នុងព្រៃ។ ការល្បងរត់ត្រឡប់ទៅរកទីជម្រកផ្សេងៗគ្នាតែសព្វខ្លួននេះ បណ្តាលឡើងជាការប្រយុទ្ធមួយ តែដោយសត្វទាំងនេះត្រូវបានចងភ្ជាប់គ្នានឹងពួរតែមួយ សត្វដែលខ្លាំងជាងគេនឹងអូសទាញសត្វឯទៀតៗ។

មនុស្សលោក ក៏ដូចជាសត្វទាំងប្រាំមួយក្នុងរឿងឧបមានេះដែរ។ មនុស្សលោកមានបំណងទៅលើចំណង់នៃញាណប្រសាទទាំងប្រាំមួយ ពោលគឺភ្នែក ត្រចៀក ច្រមុះ អណ្ដាតស្បែក និងខួរក្បាល ហើយត្រូវបានលុះទៅក្នុងអំណាចនៃចំណង់ដែលខ្លាំងលើសលុបជាងគេ។

បើគេចងសត្វទាំងប្រាំមួយនោះ ភ្ជាប់នឹងបង្គោលមួយវានឹងខំត្រដររំដោះខ្លួនរហូតដល់អស់កម្លាំងជាចុងក្រោយប៉ុន្តែទីបំផុតវាត្រូវដេកដួលនៅក្បែរបង្គោលនោះ។ យ៉ាងណាមិញបើមនុស្សលោកហាត់បំពត់ចិត្តរបស់ខ្លួនបានហើយ ញាណប្រសាទប្រាំឯទៀតនោះ នឹងលែងញាំញីបានតទៅទៀតហើយ។ បើបំពត់ចិត្តបានហើយ មនុស្សលោកនឹងបានសេចក្ដីស្ងប់សុខ មិនត្រឹមតែក្នុងពេលបច្ចុប្បន្ននេះទេ ទៅក្នុងអនាគតក៏បានសុខដែរ។

4. មនុស្សលោកស្រឡាញ់ចំណង់អត្តទត្តដែលបណ្ដាលមកពីការចង់បានកេរ្ដិ៍ឈ្មោះ និងការចង់ឲ្យគេអួតសរសើរ។ ប៉ុន្តែការមានកេរ្ដិ៍ឈ្មោះ និងការបានគេអួតសរសើរនេះ វាដូចជា

ធូបដែលឆេះ ហើយរលត់អស់ទៅក្នុងរយៈពេលដ៏ខ្លីដូច្នេះដែរ។ បើមនុស្សលោកខំស្វែងរកកិត្តិយស និងការបានគេអបអរសាទរ ហើយលះបង់ចោលផ្លូវនៃសេចក្តីពិត មនុស្សលោកទាំងនោះនឹងធ្លាក់ក្នុងមហាគ្រោះថ្នាក់ ហើយកំពុងតែបណ្តាលនូវហេតុ ដែលនឹងត្រូវបានស្តាយក្រោយជាមិនខាន។

បុគ្គលដែលស្វែងរកកិត្តិនាម សម្បត្តិទ្រព្យ និងសេចក្តីស្នេហា ប្រៀបបាននឹងកូនក្មេងលិទ្ធទឹកឃ្មុំ ដែលជាប់នៅលើមុខកាំបិត។ ក្នុងពេលដែលកូនក្មេងនោះក្រេបរស់ជាតិផ្អែមឆ្ងាញ់នៃទឹកឃ្មុំ វានឹងមុតអណ្តាតនឹងកាំបិតនោះ។ ម្យ៉ាងទៀតគេអាចប្រៀបបានទៅនឹងបុរសកាន់ចន្លុះដើរច្រាសខ្យល់ អណ្តាតភ្លើងចន្លុះ នឹងឆេះដៃនិងមុខបុរសនោះជាមិនខាន។

មិនត្រូវបណ្តោយខ្លួន ឲ្យលុះទៅតាមចំណង់នៃចិត្តនោះទេ ព្រោះចិត្តពោរពេញទៅដោយក្តីលោភលន់ ក្តីក្រោធខឹង និងក្តីភាន់ច្រឡំ។ មិនត្រូវបណ្តោយឲ្យចិត្តប្រព្រឹត្តទៅដោយសេរីទេ ត្រូវតែត្រួតត្រាវាយ៉ាងតឹងរឹង។

5. គ្មានអ្វីពិបាកជាងការត្រួតត្រាចិត្តឲ្យបានល្អឥតខ្ចោះនោះ

ទេ។ បុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែចៀសវាងភ្លើងតណ្ហា ដូចជាអ្នកពាក់ស្បែកជើងធ្វើអំពីចំបើងហាលស្ងួត ចៀសវាងផ្កាភ្លើងយ៉ាងនោះដែរ។

ប៉ុន្តែ ចំពោះបុគ្គលដែលខ្វេះគ្រាប់ភ្នែករបស់ខ្លួនចេញ ដើម្បីកុំឲ្យមានចំណង់នឹងសោភណភាពនៃរូបទម្រង់នោះ ជាអំពើឆ្កួតស្រឡះ។ ពីព្រោះចិត្តជាចៅហ្វាយ បើកាលណាគ្រប់គ្រងចិត្តបានហើយ ចំណង់ទាំងឡាយដែលនៅក្រោមអំណាចនៃចិត្តនោះ នឹងវិនាសអស់ហោង។

ដើរតាមមាគ៌ាទៅកាន់ពន្លឺត្រាស់ដឹង ជាការពិបាក។ ប៉ុន្តែវារឹតតែពិបាកណាស់ទៅទៀត បើកាលណាគ្មានចិត្តតម្រង់ឆ្ពោះទៅរកការស្វែងរកមាគ៌ានោះ។ បើគ្មានពន្លឺត្រាស់ដឹងទេ បុគ្គលនឹងត្រូវរងទុក្ខវេទនាមិនចេះចប់ ក្នុងការវិលរស់វិលស្លាប់នេះ។

បុគ្គលណាស្វែងរកមាគ៌ានៃពន្លឺត្រាស់ដឹង ប្រៀបបានទៅនឹងគោដែលអូសរទេះផ្ទុករបស់យ៉ាងធ្ងន់ ឆ្លងកាត់វាលភក់។ បើគោនោះខំយ៉ាងពេញសមត្ថភាព ដោយគ្មានគិតរវល់នឹងអ្វីៗ ក្រោងទៀតនោះ វានឹងឆ្លងវាលភក់រួច ហើយទីបំផុត នឹង

អាចសម្រាកកម្លាំងបាន។ យ៉ាងណាមិញចិត្តក៏ដូចនោះដែរ តែកាលណាត្រូវគ្រប់គ្រងបានហើយ ដាក់ឲ្យនៅក្នុងគន្លងផ្លូវត្រឹមត្រូវល្អហើយ ភក់ជ្រាំដែលកើតឡើងអំពីតណ្ហាដែលជាឧបសគ្គចំពោះចិត្តនោះនឹងលែងមាន ហើយទុក្ខវេទនាទាំងឡាយនឹងវិនាសសូន្យ។

6. បុគ្គលណាដែលស្វែងរកមាគ៌ាពន្លឺត្រាស់ដឹង មុនដំបូងបង្អស់ ត្រូវលះបង់ចោលនូវអភិមានះ និងការលើកតម្កើងខ្លួនហើយមានចិត្តជ្រះថ្លារាបសាចង់ទទួលនូវពន្លឺពុទ្ធឱវាទ។ កំណប់សម្បត្តិទ្រព្យក្នុងលោកនេះ មាសប្រាក់ កិត្តិយស មិនអាចយកទៅប្រដូចនឹងព្រហ្មចរិយធម៌ និងគុណធម៌បានទេ។

ដើម្បីមានសុខភាពល្អ ដើម្បីផ្តល់នូវសុភមង្គលពិតប្រាកដដល់គ្រួសារ និងដើម្បីផ្តល់នូវសន្តិភាពដល់អ្នកផងទាំងពួងមុនដំបូងបង្អស់ ត្រូវតែបំពត់ត្រួតត្រាចិត្តរបស់ខ្លួនឯងសិន។ បើបុគ្គលណាអាចបំពត់ចិត្តខ្លួនឯងបានហើយ បុគ្គលនោះអាចរកឃើញនូវមាគ៌ាពន្លឺត្រាស់ដឹង ពេលនោះហើយព្រហ្មចរិយធម៌និងគុណធម៌ នឹងមករកបុគ្គលនោះដោយឯកឯង។

ដូចជាកំណាប់ធនធានផុសចេញពីក្នុងដី គុណធម៌សាចចេញឡើងពីការប្រព្រឹត្តល្អ ហើយព្រហ្មចរិយធម៌ផុសចេញឡើងពីចិត្តបរិសុទ្ធស្ងប់។ ដើម្បីដើរដោយសុខសាន្តនៅក្នុងភាពសាំញ៉ាំនៃជីវិតលោកិនេះ គេត្រូវការពន្លឺពោលគឺសតិប្រាជ្ញា និងអ្នកនាំផ្លូវ ពោលគឺគុណធម៌។

សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលពន្យល់មនុស្សលោកអំពីរបៀបបំបាត់ចោលការលោភលន់ ការខឹងក្រោធ និងការភាន់គតិ ជាសិក្ខាបទមួយដ៏ប្រសើរ ហើយបុគ្គលណាប្រតិបត្តិតាមសិក្ខាបទនេះ នឹងបានសម្រេចនូវសុភមង្គលនៃជីវិតដ៏ប្រសើរបំផុត។

7. មនុស្សលោកមានបំណងដើរឆ្ពោះទៅរកទិសដែលគំនិតរបស់ខ្លួនតម្រង់ឆ្ពោះទៅ។ បើគេរក្សាគំនិតលោភលន់ គេនឹងទៅជាមនុស្សលោភលន់កាន់តែខ្លាំងឡើងៗ។ បើគេរក្សាគំនិតក្រោធខឹង គេនឹងទៅជាមនុស្សមានកម្រោធកាន់តែច្រើនឡើងៗ។ បើគេចិញ្ចឹមគំនិតសងសឹក ជើងរបស់គេនឹងនាំគេឆ្ពោះទៅរកទិសនោះឯង។

នៅរដូវប្រូតកាត់ អ្នកស្រែចំការចងគោក្របីរបស់ខ្លួនទុកក្នុងក្រោល ដោយខ្លាចវាបំបាក់របងរត់ទៅក្នុងវាលស្រែ ស៊ីដំណាំគេឯង នាំឲ្យគេសម្លាប់វា ឬនាំឲ្យមានការប្តឹងផ្តល់គ្នា។ យ៉ាងណាមិញ យើងត្រូវតែរក្សាគ្រប់គ្រងចិត្តរបស់យើងឲ្យហ្មត់ចត់ចំពោះអំពើទុច្ចរិត និងអំពើកាចឃោរឃៅ។ យើងត្រូវតែលះបង់ចោលគំនិត ដែលបណ្តាលឲ្យមានការលោភលន់ ការខឹងក្រោធ និងការយល់ច្រឡំ ហើយខិតខំបណ្តុះគំនិតដែលបណ្តាលឲ្យមានមេត្តាធម៌ និងចិត្តល្អ។

កាលណារដូវផ្ការីកមកដល់ហើយ វាលស្មៅនានាមានស្មៅខៀវខ្ចីដុះពាសពេញ អ្នកស្រែចំការទាំងឡាយដឹកក្របីគោរបស់ខ្លួនទៅកាន់វាលស្មៅទាំងនោះ។ ក្នុងពេលនោះទៀតក៏អ្នកស្រែចំការទាំងនោះនៅតែចាំឃ្លាំមើលហ្វូងសត្វពាហនៈរបស់ខ្លួនដែរ។ ចិត្តរបស់មនុស្សលោកក៏ដូច្នោះដែរ ទោះបីនៅក្នុងកាលៈទេសៈ ដ៏គាប់ប្រសើរយ៉ាងណាក៏ដោយ ក៏ត្រូវតែត្រួតពិនិត្យចិត្តនោះដែរ។

8. មានមួយពេលនោះ ព្រះពុទ្ធសក្យមុនី ទ្រង់និមន្តទៅគង់

ក្នុងក្រុងកោសម្ពី។ នៅក្នុងក្រុងនោះ មានបុរសម្នាក់ចងគំនុំនិងព្រះអង្គ ហើយញុះញង់ពួកមនុស្សខិលខូចឲ្យដើរនិយាយអាក្រក់ពីព្រះអង្គគ្រប់បែបយ៉ាង។ ក្នុងស្ថានភាពដ៏ជូរចត់បែបនេះ សាវ័កទាំងឡាយរបស់ព្រះអង្គពិបាកនិមន្តទៅបិណ្ឌបាតចង្ហាន់ឲ្យបានគ្រប់គ្រាន់ណាស់ នៅក្នុងក្រុងនោះ ទៅកន្លែងណាក៏មានគេជេរត្មះតិះដៀលដែរ។

ព្រះអានន្ទទូលព្រះពុទ្ធថា: «គួរតែកុំនៅក្នុងក្រុងនេះតទៅទៀត។ មានក្រុងល្អៗជាងនេះជាច្រើនទៀត ដែលយើងអាចទៅសំណាក់នៅបាន។ យើងចាកចេញអំពីទីក្រុងនេះទៅល្អជាង»។

ព្រះពុទ្ធជាម្ចាស់ត្រាស់ឆ្លើយថា: «បើក្រុងឯទៀតវារបៀបនេះដែរ តើយើងនឹងធ្វើដូចម្ដេច? យើងនឹងទៅនៅក្នុងក្រុងមួយទៀតឬយ៉ាងណាហ្ន៎!»។

ព្រះពុទ្ធជាម្ចាស់ត្រាស់បន្តទៅទៀតថា: «អានន្ទអើយ រឿងនេះមិនចប់ទៅយ៉ាងនេះទេ។ រស់នៅទីកន្លែងនេះ ហើយខំអត់ទ្រាំនឹងការជេរប្រមាថ រហូតដល់វាបាត់អស់ទៅវិញ ជាការប្រសើរជាង រួចហើយសឹមយើងទៅកន្លែងផ្សេង

ទៀត»!

ព្រះអង្គមានពុទ្ធដីកាជាបន្ថែមទៀតថា: «នៅក្នុងលោកនេះ វាមានចំណេញនិងខាត វាមានកិត្តិយស និងការប្រមាថមើលងាយ វាមានការអួតសរសើរ និងការជេរត្មះតិះដៀល។ បណ្ឌិតមិនមានការទាក់ទងនឹងរឿងសំបកខាងក្រៅទាំងនេះទេ។ រឿងជាខាងក្រៅទាំងនេះ នឹងបាត់ទៅវិញយ៉ាងឆាប់រហ័ស ដូចជាកាលដែលវាកើតឡើងមកនោះដែរ»។

II

របៀបប្រព្រឹត្តល្អ

1. បុគ្គលទាំងឡាយដែលស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែចងចាំជានិច្ចថា ការរក្សាកាយ វាចា និងចិត្តឲ្យបាននៅបរិសុទ្ធជានិច្ចជាការចាំបាច់។ ដើម្បីរក្សាកាយឲ្យបរិសុទ្ធត្រូវចៀសវាងការសម្លាប់សត្វមានជីវិត ត្រូវចៀសវាងការលួចប្លន់ ត្រូវចៀសវាងការផិតក្បត់។ ដើម្បីរក្សាវាចាឲ្យបរិសុទ្ធ ត្រូវចៀសវាងការ

និយាយកុហក ត្រូវចៀសវាងការនិយាយបង្កាច់បង្ខូច ត្រូវចៀសវាងការជេរប្រមាថ និងត្រូវចៀសវាងការនិយាយច្រើនឥតប្រយោជន៍។ ដើម្បីរក្សាចិត្តឲ្យបរិសុទ្ធត្រូវចៀសវាងការលោភលន់ ការក្រោធខឹង និងការយល់ច្រឡំ។

តែកាលណាហើយ ចិត្តឡើងជាមិនបរិសុទ្ធ អំពើដែលហូរចេញពីចិត្តមិនបរិសុទ្ធនោះ នឹងទៅជាមិនបរិសុទ្ធដែរ។ តែកាលណាហើយ អំពើមិនបរិសុទ្ធ ទុក្ខវេទនានឹងកើតមានឡើង។ ដូច្នេះ ការរក្សាកាយនិងចិត្តឲ្យបាននៅបរិសុទ្ធជាការសំខាន់បំផុត។

2. សម័យមួយនោះ មានស្រីមេម៉ាយអ្នកមានស្តុកស្តម្ភម្នាក់មានឈ្មោះល្បីល្បាញណាស់ ដោយសារមានការចេះគួរសមសុភាពរម្យទម និងឫកពារទន់ភ្លន់របស់គាត់។ គាត់មានក្មេងបម្រើស្រីម្នាក់ ឆ្លាតវៀសវៃណាស់។

ថ្ងៃមួយក្មេងបម្រើស្រីនោះគិតថា: «ចៅហ្វាយស្រីអញមានឈ្មោះល្បីល្បាញណាស់។ អញចង់ដឹងណាស់ តើគាត់ល្អពីកំណើត ឬគាត់ល្អដោយសារទេសកាល។ អញនឹងសាកល្បង

គាត់មើល អញនឹងបានដឹងច្បាស់ជាពុំខាន»។

ព្រឹកស្អែកឡើង ក្មេងបម្រើស្រីនោះ ដល់ថ្ងៃជិតត្រង់ ទើបទៅគាល់បម្រើចៅហ្វាយស្រីខ្លួន។ ចៅហ្វាយស្រីខឹងណាស់ ហើយជេរប្រទេចខ្ញុំបម្រើស្រីនោះ គ្មានឈប់ឈរទេ។ ស្រីបម្រើឆ្លើយឡើងថា: «ខ្ញុំខ្ជិលច្រអូស តែក្នុងមួយថ្ងៃពីរថ្ងៃប៉ុណ្ណោះ ចៅហ្វាយមិនត្រូវអស់ការអត់ធ្មត់ទេ»។ ចៅហ្វាយស្រីរឹតតែខឹងប្រទ្បាតឡើងថែមទៀត។

ថ្ងៃបន្ទាប់មកទៀត ស្រីបម្រើនោះក្រោកពីដេកយឺតយូរទៀត។ ចៅហ្វាយស្រីខឹងណាស់ ហើយយកដំបងវាយខ្ញុំបម្រើស្រីនោះ។ រឿងហេតុនេះឮដល់អ្នកជិតខាង ហើយស្រីមេម៉ាយអ្នកមានស្លុកស្លម្កនោះក៏អស់ឈ្មោះល្បីល្បាញទៅ។

3. បុគ្គលជាច្រើន ប្រៀបបាននឹងស្រីមហាសេដ្ឋីនេះដែរ។ កាលណាទេសកាលល្អហុចឲ្យ បុគ្គលទាំងនោះឡើងជា ស្លូតបូតមានចិត្តបេះគួរសមរម្យទមរាក់ទាក់។ ប៉ុន្តែកាលណាទេសកាលមានការផ្លាស់ប្តូរទៅ ហើយមិនស្របទៅតាមចិត្តរបស់គេ តើបុគ្គលទាំងនោះនៅតែល្អដដែលឬ? នេះជាបញ្ហាមួយ

ដែលគួររិះគិតឲ្យបានយល់។

បុគ្គលណាចេះរក្សាចិត្តឲ្យបរិសុទ្ធស្ងប់ ហើយនៅតែបន្តការប្រព្រឹត្តល្អជានិច្ច ទោះបីមានពាក្យអាក្រក់ចូលក្នុងត្រចៀករបស់គេក៏ដោយ ទោះបីអ្នកឯទៀតបញ្ចេញនូវភាពឃោរឃៅមកលើគេក៏ដោយ ទោះបីគេត្រូវខ្វះចំណីអាហារមិនបានបរិបូណ៌ ខ្វះសម្លៀកបំពាក់ និងផ្ទះសម្បែងមិនបានសមរម្យក៏ដោយ បុគ្គលនោះទើបបានហៅថាបុគ្គលល្អពិតមែន។

ដូច្នេះហើយ បុគ្គលទាំងឡាយដែលធ្វើអំពើល្អ ហើយរក្សាចិត្តស្ងួតបូតតែក្នុងពេលទេសកាល បានសមប្រកបចំពោះខ្លួននោះ បុគ្គលទាំងនោះមិនពិតជាបុគ្គលល្អទេ។ មានតែបុគ្គលដែលបានទទួលការប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយបានហាត់បំពត់ចិត្តនិងកាយទៅតាមការប្រៀនប្រដៅនោះទេ ដែលអាចត្រូវបានហៅថា បុគ្គលល្អ សុភាព រម្យទមស្លូតបូត ពិតប្រាកដ។

4. មានពាក្យជាគូផ្ទុយនឹងគ្នាប្រាំគូគឺៈទី១ ពាក្យដែលគេអាចប្រើប្រាស់បានក្នុងទេសកាលខ្លះ និងពាក្យដែលគេអាចប្រើប្រាស់បានតែក្នុងទេសកាលផ្សេងទៀត។ ទី២ ពាក្យដែលស្រប

នឹងអំពើ និងពាក្យដែលមិនស្របនឹងអំពើ។ ទី៣ ពាក្យដែលមានសំឡេងចេញមកគួរឲ្យរីករាយ និងពាក្យដែលមានសំឡេងចេញមកយ៉ាងគ្រោតគ្រាត។ ទី៤ ពាក្យដែលផ្តល់សេចក្តីល្អនឹងពាក្យដែលផ្តល់សេចក្តីអាក្រក់។ ទី៥ ពាក្យដែលបង្កើតមិត្តនឹងពាក្យដែលបង្កើតសត្រូវ។

ពាក្យណាក៏ដោយដែលយើងប្រើប្រាស់ យើងតោងតែជ្រើសរើសឲ្យបានហ្មត់ចត់ ពីព្រោះអ្នកស្តាប់ឮពាក្យសំដីនោះនឹងលុះទៅក្នុងអំណាចនៃពាក្យសំដីនោះ ក្នុងន័យអាក្រក់ ក៏ដូចជាក្នុងន័យល្អ។ បើចិត្តរបស់យើង វាពោរពេញទៅដោយមិត្តភាពនិងករុណាធម៌ យើងនឹងមិនត្រូវបានរំខានដោយសារតែពាក្យសំដីដែលយើងបានឮនោះទេ។ យើងមិនត្រូវបណ្តោយឱ្យពាក្យសំដីមិនសមហេតុផល វាហូរចេញតាមបបូរមាត់យើងទេ ពីព្រោះវាបណ្តាលឲ្យកើតមានមនោសញ្ចេតនាក្រោធខឹង និងសម្អប់។ពាក្យដែលយើងស្តីនិយាយ តោងតែជាពាក្យជាមិត្តភាព និងប្រកបដោយគតិបណ្ឌិតជានិច្ច។

ឧបមាថា មានបុរសម្នាក់ ប៉ងបោសច្រាសដីឲ្យបានស្អាតល្អ ដោយយកដំបងមួយ និងបង្គីមួយមកប្រើប្រាស់ ហើយគាត់ខំ

បោសសម្រាមដោយសេចក្តីព្យាយាម តែគាត់មិនបានសម្រេចសោះ។ យើងទាំងឡាយក៏ដូចជាបុរសចម្លួតនេះដែរ បើយើងសង្ឃឹមថានឹងអាចបំបាត់ពាក្យពេចន៍ទាំងអស់ចោលបាន។ យើងគោងតែហាត់បំពត់ចិត្តរបស់យើង ហើយយកភាពជាមិត្តមកបំពេញវា ដើម្បីកុំឲ្យចិត្តយើងវាមានការរីករវរំជួលដោយសារពាក្យពេចន៍គ្រប់បែបយ៉ាង ដែលអ្នកដទៃស្រដីមកកាន់យើង។

គេអាចនឹកស្រមៃយកដក់ជ្រលក់ទឹកថ្នាំពណ៌ ហើយគូររូបមួយនៅលើផ្ទៃមេឃខៀវស្រងាត់បាន តែការវិចិត្ររូបគំនូរនេះ មិនអាចប្រព្រឹត្តទៅដោយពិតបានទេ។ ម្យ៉ាងទៀតគេមិនអាចធ្វើឲ្យទឹកក្នុងទន្លេដ៏ធំមួយរីងហួត ដោយយកគប់ចំបើងមួយទៅដុតកំដៅនោះបានទេ ឬបង្កើតសូរសំឡេងលាន់ប្រឹបៗដោយយកស្បែកដែលសម្ងាប់ទន់ល្អពីរបន្ទះ មកសង្កួតគ្នា នោះក៏ជាការពុំអាចធ្វើកើតដែរ។ ដូចជា ឧទាហរណ៍ទាំងនេះដែរ បុគ្គលគ្រប់រូបគោងតែហាត់ពត់ចិត្តរបស់ខ្លួន កុំឲ្យវាមានការរីករវរំដើបរំជួល នឹងពាក្យពេចន៍បែបណាក៏ដោយដែលបានឮ។

បុគ្គលទាំងឡាយត្រូវបង្ហាត់ចិត្តរបស់ខ្លួន ហើយរក្សាវាឲ្យបានទូលាយធំធេងដូចផែនដី ឲ្យបានល្អល្អេវដូចផ្ទៃមេឃ ឲ្យ

បានជ្រៅដូចមហាសមុទ្រ ឲ្យបានទន់ដូចស្បែកសម្ងាប់ទន់ល្អ។

ទោះបីសត្រូវរបស់អ្នក ចាប់អ្នកយកទៅធ្វើទារុណកម្មក៏ដោយបើអ្នកកើតមានចិត្តចង់គំនុំ បានន័យថា អ្នកមិនធ្វើតាមឱវាទព្រះពុទ្ធទេ។នៅក្នុងទេសកាលបែបណាក៏ដោយអ្នកត្រូវរៀនរិះគិតថា:«ចិត្តអញ មិនចេះរំជួលជាដាច់ខាត ពាក្យសំដីជាកំហឹងនិងសម្អប់ នឹងមិនចេញតាមបបូរមាត់ អញជាដាច់ខាត។ អញនឹងយកការរិះគិតក្នុងភាពជាមិត្ត និងករុណាអាសូរ ទៅគ្របលើសត្រូវរបស់អញ ការរិះគិតដែលហូរចេញពីចិត្តពោរពេញទៅដោយសេចក្ដីស្រឡាញ់ ចំពោះគ្រប់សត្វមានជីវិតទាំងអស់»។

5. មានរឿងល្បើកមួយនិទានថា ថ្ងៃមួយនោះបុរសម្នាក់ប្រទះឃើញសំបុកស្រមោចមួយ នៅពេលថ្ងៃមានភ្លើងឆេះឡើង នៅពេលយប់មានផ្សែងហុយឡើង។ បុរសនោះទៅរកអ្នកប្រាជ្ញបណ្ឌិតម្នាក់ហើយសួរថា តើគួរធ្វើដូចម្ដេចដែរចំពោះសំបុកស្រមោចនោះ។ អ្នកប្រាជ្ញបណ្ឌិតបង្គាប់ឲ្យយកដាវជីកកកាយមើលខាងក្នុងសំបុកស្រមោចនោះ។ បុរសនោះក៏

ធ្វើតាម ហើយបានប្រទះឃើញជាបន្តបន្ទាប់ រនុកទ្វារមួយ ពពុះទឹកមួយពំនូក ច្បូកមួយ ប្រអប់មួយ អណ្ដើកមួយ កាំបិតហាន់សាច់មួយ សាច់មួយដុំ។ ជាចុងក្រោយបង្អស់ បុរសនោះប្រទះឃើញនាគមួយចេញមក។ បុរសក៏យករឿងដែលបានប្រទះឃើញទាំងនោះ ទៅជម្រាបលោកបណ្ឌិត។ លោកបណ្ឌិតពន្យល់បុរសនោះអំពីន័យនៃវត្ថុទាំងនោះសព្វគ្រប់ ហើយបង្គាប់ថា «ចូរអ្នកយកវត្ថុទាំងនោះបោះចោលឲ្យឆ្ងាយ ទុកតែនាគមួយនោះបានហើយ។ ចំពោះនាគនោះ ចូរអ្នកទុកវាឲ្យនៅតែម្នាក់វា កុំរំខានវាឡើយ»។

ក្នុងរឿងប្រឌិតនេះ សំបុកស្រមោចជារូបកាយមនុស្សលោក។ រឿងដែលសំបុកស្រមោចមានភ្លើងឆេះឡើងនៅពេលថ្ងៃ បានន័យថា នៅពេលថ្ងៃមនុស្សទាំងឡាយបំពេញកិច្ចការដែលគេបានគ្រោងទុកពីយប់។ រឿងដែលសំបុកស្រមោចមានផ្សែងហុយឡើងនៅពេលយប់ បានន័យថា នៅពេលយប់មនុស្សទាំងឡាយរំឭកឡើងវិញ ដោយចិត្តរីករាយ ឬសោកស្ដាយនូវអ្វីៗ ដែលគេបានធ្វើពីពេលថ្ងៃ។

នៅក្នុងរឿងប្រឌិតនេះទៀត បុរសនោះគឺបុគ្គលដែលរក

ពន្ទីត្រាស់ដឹង។ លោកបណ្ឌិតគឺព្រះពុទ្ធ។ ដាវគឺគតិបណ្ឌិត បរិសុទ្ធ។ ការជីករកមើលដល់ទីជម្រៅ គឺការខំប្រឹងប្រែង ប្រតិបត្តិ ដើម្បីឲ្យបានដល់ពន្ទីត្រាស់ដឹង។

ម្យ៉ាងទៀត ក្នុងរឿងប្រឌិតនេះ រនុកទ្វារគឺសេចក្ដីល្ងង់ខ្លៅ ពពុះទឹកគឺកំសួលនៃទុក្ខវេទនា ហើយនិងទោសៈ ចម្លូកគឺការ រួញរាហើយនិងការពិបាក ប្រអប់គឺការប្រមូលផ្ដុំទុកនូវសេចក្ដី លោភលន់ សេចក្ដីខឹងក្រោធ សេចក្ដីខ្ជិលច្រអូស ចរិតសាវា សេចក្ដីសោកស្ដាយហើយនិងការខកចិត្ត អណ្ដើក គឺចិត្ត កាំបិតហាន់សាច់គឺការរួមផ្ដុំតណ្ហាទាំងឡាយដែលកើតឡើង ពីវិញ្ញាណទាំងប្រាំ ដុំសាច់សំដៅទៅលើចំណង់ដែលរុញច្រាន មនុស្សលោកឲ្យពួនពីក្រោយសេចក្ដីពេញចិត្ត។ វត្ថុទាំងប៉ុន្មាន នេះ វាចង្រៃចំពោះមនុស្សលោក ហេតុនេះហើយ បានជាព្រះ ពុទ្ធត្រាស់ថា: «ចូរយកវត្ថុទាំងនាំបោះចោលឲ្យអស់»។

ជាបញ្ចប់ ពស់នាគគឺវិញ្ញាណដែលកំចាត់បង់ នូវតណ្ហា លោកិយទាំងអស់។ បុគ្គលណាយកដាវគតិធម៌ជីករកវត្ថុឲ្យ ដល់ទីជម្រៅ បុគ្គលនោះនឹងបានទៅដល់នាគ នៅវេលាចុង ក្រោយបំផុត។ «ចូរទុកវាឲ្យនៅតែម្នាក់ឯង កុំរំខានវាឡើយ»

បានន័យថា ត្រូវស្វែងរកតែវិញ្ញាណដែលមិនជាប់ជំពាក់នឹង ចំណង់លោកិយ។

6. ព្រះបិន្ទោលដែលជាសាវ័កមួយអង្គរបស់ព្រះពុទ្ធ នៅពេលក្រោយបានទៅដល់ពន្លឺត្រាស់ដឹងហើយ ក៏ត្រឡប់មកកាន់ក្រុងកោសម្ពី ដែលជាស្រុកកំណើតរបស់ព្រះអង្គវិញដើម្បីនឹងថ្វែងអំណរគុណ ដល់ជនទាំងឡាយនៅទីនោះ ដែលបានស្រឡាញ់រាប់អានព្រះអង្គ។ ក្នុងកិច្ចថ្វែងអំណរគុណនេះ ព្រះអង្គបានកាប់ឆ្ការដីមួយដុំ ដើម្បីសាបព្រោះសំណាបពុទ្ធសាសនា។

នៅក្នុងសង្កាត់ជាយក្រុងកោសម្ពី មានសួនឧទ្យានមួយតូចបិតនៅតាមផ្លូវតូចតាមមាត់ទន្លេគង្គា។ ទីនោះ មានដើមដូងដុះជាជួរមើលដាច់កន្ទុយភ្នែក បោលម្ប់ត្រឈឹងត្រឈៃមានខ្យល់ត្រជាក់បក់ល្វើយៗ មិនចេះដាច់។

ថ្ងៃមួយនារដូវក្តៅ ព្រះបិន្ទោលអង្គុយភាវនា នៅក្រោមម្លប់ត្រជាក់នៃដើមឈើមួយដើម។ នៅពេលនោះមហាសេដ្ឋីឧទេន នាំប្រពន្ធគាត់ទាំងអស់មកកំសាន្តនៅក្នុងសួននោះដែរ។ ក្រោយពីស្តាប់ភ្លេងនិងកំសាន្តសប្បាយមក គាត់ក៏លង់លក់

នៅក្រោមម្លប់ឈើទៅ។

ក្នុងពេលដែលមហាសេដ្ឋីសម្រាន្តលក់នោះ ប្រពន្ធ និងស្រីអ្នកបម្រើទាំងអស់របស់គាត់នាំគ្នារត់លេង ទៅដល់កន្លែងដែលព្រះបិន្ទោលគង់ភាវនា។ ស្រីទាំងនោះ យល់ឃើញថាព្រះអង្គជាបុគ្គលបរិសុទ្ធ ក៏ថ្វាយបង្គំសុំឲ្យព្រះអង្គប្រៀនប្រដៅធម៌ ហើយក៏បត់ជើងអង្គុយស្តាប់ព្រះធម្មទេសនាទៅ។

នៅពេលដែលមហាសេដ្ឋីភ្ញាក់ឡើង មិនឃើញប្រពន្ធនិងស្រីបម្រើ គាត់ក៏ដើររក ហើយទៅប្រទះឃើញស្រីទាំងនោះនៅព័ទ្ធជុំវិញព្រះបិន្ទោល កំពុងតែស្តាប់ធម្មទេសនា។ ដោយមានចិត្តប្រច័ណ្ឌ និងខ្វះសីលធម៌ មហាសេដ្ឋីខឹងច្រឡោតឡើង ហើយជេរប្រមាថព្រះបិន្ទោលថា «បុគ្គលបរិសុទ្ធដែលនៅកណ្តាលហ្វូងស្រីៗ ហើយនិយាយសំណេះសំណាល បែបចង់របៀបអ្នកឯងនេះ មិនគួរអត់ឱនទោសបានទេ»។ ព្រះបិន្ទោលទ្រង់បិទព្រះនេត្រសន្សឹមៗ ហើយគង់នៅដោយស្ងៀមស្ងាត់ទៅ។

ដោយកំហឹងក្រោធ មហាសេដ្ឋីដកដាវឡើង ហើយគំរាមព្រះបិន្ទោល តែបុគ្គលបរិសុទ្ធនៅតែស្ងាត់ស្ងៀមនឹងថ្កល់បីដូច

ជាផ្ទាំងសីលាជានិច្ច។ មហាសេដ្ឋីរឹតតែខឹងថែមឡើងជាខ្លាំង គាត់កាប់កំចាយសំបុកស្រមោច យកកំទេចដីដែលជាប់ស្រមោចពេញចោលទៅលើព្រះអង្គ តែព្រះបិន្ទោលនៅតែអង្គុយភាវនាឥតកម្រើក អត់ទ្រាំដោយអំណត់នឹងការជេរត្មះតិះដៀលហើយនិងសេចក្តីឈឺចាប់។

ដល់ពេលនេះ មហាសេដ្ឋីដឹងខ្លួនខុស ហើយស្តាយនូវអំពើឃោរឃៅដែលខ្លួនបានប្រព្រឹត្ត គាត់ក៏ថ្វាយបង្គំសុំទោសព្រះបិន្ទោល។ ក្រោយពីឧប្បត្តិហេតុនោះមក ព្រះពុទ្ធសាសនាក៏ត្រូវបានចូលមកក្នុងវិមានមហាសេដ្ឋីនោះ ហើយផ្សព្វផ្សាយចេញទៅពេញទាំងនគរ។

7. ប៉ុន្មានថ្ងៃក្រោយមក មហាសេដ្ឋីឧទេន ទៅថ្វាយបង្គំព្រះបិន្ទោលនៅក្នុងអាស្រមព្រះអង្គក្នុងព្រៃ ហើយទូលសួរព្រះអង្គថា: «ព្រះជាម្ចាស់ តើសាវ័កទាំងឡាយរបស់ព្រះពុទ្ធធ្វើដូចម្តេចក៏អាចរក្សារូបកាយនិងចិត្តឲ្យនៅបរិសុទ្ធបាន ហើយមិនលុះទៅក្រោមតណ្ហា? ហើយព្រះសាវ័កទាំងនោះច្រើនតែបុគ្គលនៅក្មេងផង ! » ។

ព្រះបិន្ទោលឆ្លើយថា: «មហាសេដ្ឋីដ៏ចម្រើន ព្រះពុទ្ធបានប្រដៅយើង ឲ្យគោរពគ្រប់ស្រីទាំងអស់។ លោកបានប្រដៅយើង ឲ្យទុកស្រីចំណាស់ទាំងអស់ជាម្ដាយរបស់យើង ទុកស្រីដែលមានអាយុស្មើនឹងយើង ជាបងប្អូនស្រីរបស់យើង ហើយទុកស្រីដែលមានអាយុតិចជាងយើង ជាកូនស្រីរបស់យើង។ ដូច្នេះហើយ បានជាសាវ័កទាំងឡាយរបស់ព្រះពុទ្ធអាចរក្សារូបកាយនិងចិត្តរបស់ខ្លួនឲ្យនៅបរិសុទ្ធបាន ហើយមិនលុះទៅក្នុងអំណាចតណ្ហា ទោះបីគេនៅកំពុងពេញវ័យក៏ដោយ"។

«ប៉ុន្តែ ព្រះជាម្ចាស់! គេអាចនៅតែមានគំនិតមិនបរិសុទ្ធចំពោះស្ត្រីដដែល ទោះបីស្រីនោះមានវ័យជាមាតារបស់គេក៏ដោយ ជាបងស្រីរបស់គេក៏ដោយ ឬជាកូនរបស់គេក៏ដោយ! តើព្រះសាវ័កទាំងឡាយរបស់ព្រះពុទ្ធ គ្រប់គ្រងសង្កត់ចំណង់របស់ខ្លួនយ៉ាងដូចម្ដេចទៅ?»។

«សេដ្ឋីដ៏ចម្រើន ព្រះពុទ្ធជាម្ចាស់បានប្រដៅយើងឲ្យក្រឡេកមើលខ្លួនឯង ដែលបញ្ចេញវត្ថុអសោចគ្រប់បែបយ៉ាងដូចជាឈាម ខ្ទុះ ញើស ខ្ទាញ់ ជាដើម។ ដោយគិតទៅដល់វត្ថុអសោចទាំងនោះ ទោះបីជាយើងមានវ័យនៅក្មេងក៏ដោយ

យើងអាចរក្សាចិត្តរបស់យើង ឲ្យនៅបរិសុទ្ធបាន»។

មហាសេដ្ឋីមានវាចាទៀតថាៈ «ព្រះជាម្ចាស់ ដ៏ប្រសើរអើយ ! ចំពោះព្រះអង្គ ការប្រព្រឹត្តបែបនេះ វាស្រួលណាស់ ពីព្រោះព្រះអង្គបានហាត់ហ្វឹកហ្វឺនបំពត់រូបកាយ និងចិត្តជាស្រេចហើយ ហើយបានដុសខាត់សតិបញ្ញាឲ្យភ្លឺស្វាងរួចជាស្រេចហើយ ប៉ុន្តែចំពោះបុគ្គលដែលមិនទាន់បានទទួលការហាត់ហ្វឹកហ្វឺនរបៀបនេះម្តងណាសោះនោះ ជាការពិបាកណាស់។ បុគ្គលទាំងនោះអាចខំប្រឹងគិតអំពីភាពអសោចទាំងនោះបាន តែភ្នែករបស់គេ វាជាប់ជំពាក់ទៅលើទ្រង់ទ្រាយដ៏សោភណដែលគេមើលឃើញ។ បុគ្គលទាំងនោះអាចខំប្រឹងគិតអំពីភាពមិនសមរម្យ តែគេនៅតែមានចិត្តប៉ុនប៉ងទៅលើសោភណភាពជាចុងក្រោយបង្អស់ដដែល។ ហេតុនេះ វាត្រូវតែមានហេតុជាសមធម៌ផ្សេងទៀត ដែលនាំឲ្យព្រះសាវ័កក្មេងៗរបស់ព្រះពុទ្ធអាចរក្សាចិត្តរបស់ខ្លួនឲ្យនៅបរិសុទ្ធបាន»។

ព្រះបិណ្ឌោលឆ្លើយថាៈ «ព្រះបរមគ្រូប្រដៅយើងថា ឲ្យចេះរក្សាការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំរបស់យើង។

កាលណា យើងឃើញរូបស្រស់ពណ៌ល្អនៅនឹងភ្នែកយើង កាលណាយើងឮសូរសព្ទពីរោះនៅនឹងត្រចៀកយើង កាលណាយើងធុំក្លិនក្រអូបនៅនឹងច្រមុះយើង កាលណាយើងត្រេកអរសជាតិឆ្ងាញ់នៅនឹងអណ្ដាតយើង ហើយកាលណាយើងស្ទាបវត្ថុទន់ល្មៃនៅនឹងដៃយើង យើងនឹងមិនជាប់ជំពាក់នឹងវត្ថុដែលទាក់ទាញយើង ឬក៏យើងគេចចេញពីវត្ថុដែលរុញច្រានយើងចេញនោះ។ យើងបានរៀនការពារយ៉ាងល្អិតល្អន់ នូវមាត់ទ្វារនៃវិញ្ញាណទាំងប្រាំនេះ។ គឺដោយសារ ការទូន្មានដែលព្រះបរមគ្រូ បានផ្ដល់ឲ្យយើងនេះហើយ បានជាសូម្បីសាវ័កក្មេងៗក៏ដោយ ក៏អាចរក្សារូបកាយ និងចិត្តរបស់គេឲ្យបាននៅបរិសុទ្ធបាននោះដែរ»។

«សេចក្ដីប្រៀនប្រដៅរបស់ព្រះពុទ្ធ ពិតជាប្រសើរល្អជាទីបំផុត។ តាមការពិសោធន៍របស់អាត្មាផ្ទាល់ អាត្មាដឹងថា តែកាលណាអាត្មាជួបប្រទះនឹងវត្ថុល្អស្រស់គួរឲ្យចាប់ចិត្ត អាត្មាតែងតែរំភើបញាប់ញ័រដោយសារការចាប់ចិត្តមានអារម្មណ៍ដែលកើតចេញឡើងពីវិញ្ញាណទាំងប្រាំនោះ នៅពេលណាដែលអាត្មាមិនបានប្រុងប្រយ័ត្ន។ ដូច្នេះ ការប្រុងប្រយ័ត្ន

ការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំនេះ ជាការសំខាន់បំផុត ដើម្បីរក្សាអំពើទាំងឡាយរបស់យើង ឲ្យបានបរិសុទ្ធនៅគ្រប់ពេលវេលា»។

8. នៅពេលណាក៏ដោយ តែកាលណាគេបញ្ចេញ គំនិតអ្វីមួយតែងតែមានការប្រឆាំងកើតឡើងជានិច្ច។ កាលណាគេជេរអ្នក អ្នកនឹងមានបំណងជេរតបទៅវិញ ឬនឹងធ្វើការសងសឹក។ គេត្រូវតែប្រយ័ត្ននឹងប្រតិកម្មជាធម្មជាតិនេះ។ គឺដូចជាគេស្តោះទឹកមាត់បញ្ច្រាសខ្យល់ ទឹកមាត់នោះគ្មានទៅប្រឡាក់អ្នកណា ក្រៅពីខ្លួនគេផ្ទាល់នោះទេ។ គឺដូចជាគេចោលកំទេចសំរាមបញ្ច្រាសខ្យល់ គេគេចមិនផុត អំពីសំរាមនោះទេ គេមុខតែប្រឡាក់ខ្លួនគេនឹងកំទេចសំរាមនោះហើយ។ វាសនាអាក្រក់ ដើរតាមប្រកិតនឹងបុគ្គលដែលបណ្តោយខ្លួនឲ្យមានបំណងសងសឹក។

9. គឺជាអំពើល្អណាស់ ដែលចេះទាត់ចោលនូវការលោភលន់ ហើយចិញ្ចឹមចិត្តមានមេត្តាធម៌។ ប៉ុន្តែរឹតតែប្រសើរណាស់ទៅ

ទៀត ដែលបេះរក្សាចិត្តឲ្យប្រុងប្រៀបទទួលគោរពតាមគន្លង ព្រះធម៌ដ៏ឧត្តម។

គេត្រូវតែបោះបង់ចោលនូវចិត្តអត្តទត្ថៈ ដែលគិតតែពីខ្លួនឯងផ្ទាល់ ហើយប្រកាន់យកចិត្តបេះជួយយកអាសា អ្នកដទៃមកជំនួសវិញ។ កាលណាគេយកអាសាជនណាម្នាក់ឲ្យបានប្រកបសេចក្តីសុខ កិច្ចនេះនឹងបណ្តាលឲ្យជននោះជួយយកអាសាជនម្នាក់ទៀតឲ្យបានប្រកបសេចក្តីសុខ ហើយសុកមង្គលនឹងកើតមានឡើង ដោយសារអំពើទាំងនេះឯងហោង។

គេអាចដុតទៀនមួយពាន់ដើមឲ្យឆេះឡើងបាន ដោយសារតែទៀនមួយដើមគត់ ហើយទៀនមួយដើមនោះ ក៏មិនមានអាយុខ្លី ដោយសារតែការដុតបន្តពីមួយទៅមួយនោះទេ យ៉ាងណាមិញ សុកមង្គល ក៏មិនចុះអន់ថយ ដោយសារតែការចែករំលែកទៅអ្នកឯទៀតនោះដែរ។

បុគ្គលណាដែលស្វែងរកពន្លឺត្រាស់ដឹង តោងតែប្រុងប្រយ័ត្ននូវជំហានទីមួយរបស់ខ្លួន។ ទោះបីជាសេចក្តីប្រាថ្នារបស់ខ្លួនវាខ្ពស់យ៉ាងណាក៏ដោយ ក៏តោងតែឈានទៅកាន់ពន្លឺត្រាស់ដឹងនោះ មួយជំហានម្តងៗ។ ជំហានដើរតាមផ្លូវទៅ

កាន់ពន្លឺត្រាស់ដឹងនេះ ត្រូវតែប្រព្រឹត្តឡើងជារៀងរាល់ថ្ងៃនៃជីវិតរបស់យើង: ថ្ងៃនេះ ថ្ងៃស្អែក ថ្ងៃខានស្អែក និងថ្ងៃជាបន្តៗទៅទៀត។

10. នៅខាងដើមផ្លូវឆ្ពោះទៅកាន់ពន្លឺត្រាស់ដឹងមានកិច្ចកម្រ ២០ យ៉ាង ដែលយើងត្រូវបំពេញនៅក្នុងលោកនេះគឺ: ១-បុគ្គលដែលក្ររហេមរហាម ហើយឲ្យមានចិត្តទូលាយនោះជាការក្រ។ ២-បុគ្គលដែលមានអភិមានះឡើតហើយ ឲ្យរៀនរបៀបដើរទៅកាន់ពន្លឺត្រាស់ដឹងជាការក្រ។ ៣-ការស្វែងរកពន្លឺត្រាស់ដឹងដោយធ្វើពលិកម្មខ្លួនឯង ជាការក្រ។ ៤-ការកើតនៅពេលមានព្រះពុទ្ធមួយព្រះអង្គគង់ក្នុងលោកនេះ ជាការក្រ។ ៥-ការបានស្តាប់ឮសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធជាការក្រ។ ៦-ការរក្សាចិត្តឲ្យបរិសុទ្ធតទល់នឹងសភាវៈរូបកាយជាការក្រ។ ៧-ការមិនចង់បានវត្ថុស្រស់ល្អដែលទាក់ទាញចិត្តជាការក្រ។ ៨-មនុស្សដែលខ្លាំង ហើយកុំឲ្យប្រើកម្លាំងដើម្បីបំពេញបំណងខ្លួន ជាការក្រ។ ៩-ការមិនខឹងតបកាលណាគេជេរ ជាការក្រ។ ១០-ការទប់ចិត្តមិនឲ្យភ្ញើតភ្ញើនជ្រួលច្របល់

ទៅតាមទេសៈកាលៈ ដែលកើតឡើងភ្លាមៗ ជាការក្រៃ ១១-ការបង្ខំខ្លួនដោយខ្លួនឯង ឲ្យស្រង់យកនូវចំណេះវិជ្ជាទូលំទូលាយ ល្អិតល្អន់ ជាការក្រៃ ១២-ការមិនប្រកាន់មើលងាយអ្នកចំណូលថ្មី ជាការក្រៃ ១៣-ការធ្វើខ្លួនឲ្យរាបសា ជាការក្រៃ ១៤- ការរកមិត្តល្អ ជាការក្រៃ ១៥- ការទ្រាំទ្រនឹងវិន័យដែលដឹកនាំទៅកាន់ពន្ធីត្រាស់ដឹង ជាការក្រៃ ១៦-ការមិនរឹកវរចិត្តនឹងសភាពជាខាងក្រៅ ហើយនឹងទេសកាលជាការក្រៃ ១៧-ការបៀនប្រដៅអ្នកដទៃ ដោយសម្របទៅតាមសមត្ថភាពអ្នកទាំងនោះ ជាការក្រៃ ១៨-ការរក្សាចិត្តឲ្យស្ងប់ ជាការក្រៃ ១៩-ការមិនជជែករកខុសរកត្រូវ ជាការក្រៃ ២០-ការស្វែងរករៀនសូត្រវិធីល្អ ជាការក្រៃ

11. មនុស្សល្អនិងមនុស្សអាក្រក់ ខុសគ្នាទៅតាមចរិតរបស់មនុស្សទាំងនោះៗ មនុស្សអាក្រក់មិនមើលឃើញអំពើដែលជាទោស ថាខុសទេៗ បើគេសម្គាល់ឃើញកំហុសណាមួយដែលគេបានធ្វើ គេមិនឈប់ប្រព្រឹត្តកំហុសនោះទេ ហើយគេមិនចង់ឲ្យនរណារំឭកកំហុសនោះដល់គេទេៗ មនុស្សប្រកប

ដោយគតិបណ្ឌិតធាប់ដឹងសេចក្ដីល្អ និងសេចក្ដីអាក្រក់ណាស់។ គេឈប់ធ្វើអំពើដែលអាក្រក់ភ្លាម កាលណាគេឃើញថា អំពើនោះមិនគាប់ប្រសើរ។ គេដឹងគុណដល់អ្នកដែលរំឭកអំពីកំហុសរបស់គេប្រាប់គេ។

ដូច្នេះឃើញថា មនុស្សល្អនិងមនុស្សអាក្រក់ខុសគ្នាយ៉ាងដាច់ស្រឡះ។ មនុស្សអាក្រក់ មិនដែលទទួលស្គាល់នូវសេចក្ដីគួរសម ដែលអ្នកឯទៀតបានផ្ដល់ដល់ខ្លួនម្ដងណាទេ។ ចំណែកមនុស្សល្អវិញគេទទួលយកសេចក្ដីគួរសមនេះ ដោយចិត្តមានអំណរគុណ។ មនុស្សដែលប្រកបដោយគតិបណ្ឌិត ខំប្រឹងប្រែងសម្ដែងនូវចិត្តមានអំណរគុណនេះ ដោយបញ្ចេញឲ្យឃើញនូវសេចក្ដីគួរសមតបទៅវិញ មិនត្រឹមតែចំពោះអ្នកដែលបានធ្វើគុណដល់ខ្លួននោះទេ គេថែមទាំងបេះគួរសមចំពោះអ្នកឯទៀតទៀតផង។

III

សេចក្ដីឧដ្ឋានតាមរឿងព្រេងប្រឌិត

1. កាលពីព្រេងនាយ មានស្រុកមួយមានទំនៀមទម្លាប់ពិសេសចម្លែក គឺគេយកមនុស្សចាស់ជរាទៅបំបរបង់ចោលនៅក្នុងព្រៃភ្នំឆ្ងាយដាច់ស្រយាល ដែលគ្មាននរណាទៅដល់។

មានឧត្តមមន្ត្រីម្នាក់ឃើញថា ទំនៀមទម្លាប់នេះលំបាកនឹងប្រតិបត្តិតាមណាស់ ក្នុងករណីឪពុកបង្កើតរបស់លោក។ ហេតុនេះ លោកក៏សង់លេណដ្ឋានក្រោមដីមួយ ហើយយកឪពុកលោកទៅលាក់ក្នុងលេណដ្ឋាននោះ។

ថ្ងៃមួយ អាទិទេពមួយព្រះអង្គ និម្មិតឲ្យឃើញឡើងនៅចំពោះព្រះភក្ត្រព្រះមហាក្សត្រនគរនោះ ហើយចោទប្រស្នាមួយយ៉ាងពិបាក។ ព្រះអាទិទេពនោះដាក់ខសន្យាថា បើស្តេចមិនអាចដោះប្រស្នានេះឲ្យបានត្រឹមត្រូវសមរម្យទេ យើងនឹងកំទេចនគរនេះចោល។ ប្រស្នានោះមានសេចក្តីថា: «មានពស់ពីរ ចូរស្តេចបញ្ជាក់ប្រាប់យើង តើពស់មួយណាឈ្មោលពស់មួយណាញី»។

ទាំងព្រះមហាក្សត្រ ទាំងនាម៉ឺនមន្ត្រីទាំងអស់នៅក្នុងព្រះបរមរាជវាំង គ្មាននរណាម្នាក់អាចដោះប្រស្នានោះរួចឡើយ។ ហេតុនេះព្រះមហាក្សត្រក៏ប្រកាសសន្យាថា នឹងប្រទានរង្វាន់

ធំដល់អ្នកណាដែលអាចដោះប្រស្នានោះរួច។

លោកឧត្តមមន្ត្រីទៅជួបនឹងឪពុករបស់លោក នៅក្នុងទីលាក់បំពួន ហើយសួរអំពីប្រស្នានោះ។ ឪពុកជរាឆ្លើយថា: «ប្រស្នានេះស្រួលដោះស្រាយណាស់។ ចូរដាក់ពស់ទាំងពីរនោះលើកម្រាលព្រំទន់ល្មើយមួយ ពស់ណាកម្រើក គឺពស់ឈ្មោល ពស់ដែលនៅស្ងៀមជាពស់ញី»។ ឧត្តមមន្ត្រីយកចម្លើយនោះទៅទូលព្រះមហាក្សត្រ ហើយប្រស្នាក៏ត្រូវដោះស្រាយរួចប្រកបដោយជោគជ័យ។

កាលនោះ ព្រះឥន្ទ្របានដាក់ប្រស្នាពិបាកៗផ្សេងទៀតជាច្រើន។ ព្រះមហាក្សត្រក្ដី នាម៉ឺនមុខមន្ត្រីគ្រប់ជាន់ថ្នាក់ក្ដី ពុំអាចដោះប្រស្នាទាំងនោះបានឡើយ។ តែលោកឧត្តមមន្ត្រីតែងតែទៅសួរឪពុកជរារបស់លោក ហើយដោះប្រស្នាទាំងនោះរួចយ៉ាងប្រសើរ។

ប្រស្នាខ្លះៗហើយនិងចម្លើយ មានដូចតទៅនេះ «បុគ្គលដែលដេកលក់ ហើយហៅថាភ្ញាក់រលឹក តើបុគ្គលបែបណាដែរ? បុគ្គលដែលភ្ញាក់រលឹក ហើយហៅថាដេកលក់ តើបុគ្គលបែបណាដែរ?»។ ចម្លើយមានដូចតទៅនេះ «គឺបុគ្គលដែ ល

ហាត់រៀន ដើម្បីឆ្ពោះទៅរកពន្លឺត្រាស់ដឹង។ បើប្រដូចទៅបុគ្គល មិនស្វែងរកពន្លឺត្រាស់ដឹង បុគ្គលនោះហៅថា ភ្ញាក់រលឹក តែបើប្រដូចទៅបុគ្គល ដែលបានទៅដល់ពន្លឺត្រាស់ដឹងហើយនោះ បុគ្គលនោះហៅថាដេកលក់»។

«តើគេអាចថ្លឹងដំរីធំមួយ របៀបណាបាន»?។ ចម្លើយៈ «ចូរយកដំរីធំនោះដាក់ក្នុងទូកធំមួយ ហើយគូសចំណាំជម្រៅដែលទូកលិចទៅក្នុងទឹក។ បន្ទាប់មកចូរយកដំរីចុះចេញពីទូក ហើយយកដុំថ្មផ្ទុកក្នុងទូករហូតដល់ទូកលិចទៅដល់ខ្សែគំនូសចំណាំនោះ។ រួចហើយ យកដុំថ្មនោះមកថ្លឹង ជាការស្រេច!»។

«តើពាក្យថាៈ ទឹកមួយកែវ ច្រើនជាងទឹកមួយសមុទ្រ បានន័យដូចម្តេច?»។ ចម្លើយៈ «ទឹកមួយកែវដែលផ្តល់ឲ្យដល់មាតាបិតា ឬដល់អ្នកជម្ងឺម្នាក់ ដោយចិត្តស្មោះសរ និងករុណាអាសូរ បានបុណ្យធំធេងគ្មានទីចប់។ តែចំពោះទឹកសមុទ្រវិញ ថ្ងៃណាមួយគង់នឹងរីងហួតវិនាសអស់មិនខាន»។

ព្រះឥន្ទ្រក្លែងខ្លួនឡើងម្តងទៀត ជាមនុស្សអត់ឃ្លានរហាមមានតែស្បែកដណ្តប់ឆ្អឹង ហើយថ្លែងថាៈ «នៅក្នុងលោកនេះ តើមាននរណា ដែលអត់ឃ្លានជាងអញនេះទៅទៀតដែរឬ

ទេ?»។ ចម្លើយៈ «បុគ្គលដែលប្រកបដោយអត្តទត្តភាព និង សេចក្ដីលោភលន់ រហូតដល់មិនជឿនូវរតនៈទាំងបី គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមិនដឹងគុណមាតាបិតា គ្រូអាចារ្យ បាធ្យាយ មិនត្រឹមតែអត់ឃ្លានទេ បុគ្គលនោះនឹងធ្លាក់ទៅក្នុង ភពប្រេតអសុរកាយអត់ឃ្លាន ហើយនឹងទទួលក្ដីវេទនាអត់ ឃ្លានគ្មានទីបំផុត»។

«បន្ទះឈើចន្ទន៍មួយបន្ទះនេះ តើខាងណាជាចុង ខាង ណាជាខាងគល់?។ ចម្លើយៈ «ចូរយកបន្ទះឈើនោះទៅដាក់ បណ្ដែតទឹក ខាងណាលិចទៅក្នុងទឹកជ្រៅជាងនោះជាខាង គល់»។

«សេះពីរដែលមានកំពស់និងកិនភាគដូចគ្នាបេះបិទនេះ តើសេះណាជាមេ សេះណាជាកូន?»។ ចម្លើយៈ «ចូរយក ចំបើងមកដាក់ឲ្យសេះទាំងពីនោះស៊ី សេះជាមេនឹងរុញច្រាន ចំបើងនោះទៅដាក់នៅមុខកូនវា»។

ចម្លើយចំពោះប្រស្នាដ៏ពិបាកៗទាំងនោះ ធ្វើឲ្យព្រះឥន្ទ្រ និងព្រះមហាក្សត្រពេញព្រះទ័យណាស់។ ព្រះមហាក្សត្រ ទ្រង់សព្វព្រះរាជហឫទ័យ ដោយបានដឹងថា ចម្លើយទាំង

នោះបានមកពីមនុស្សជរាម្នាក់ ដែលកូនយកទៅលាក់ក្នុងបន្ទប់ក្រោមដី។ ព្រះអង្គក៏បញ្ជាឲ្យលុបទំនៀមទម្លាប់យកមនុស្សជរាទៅបំបរបង់ចោល នៅក្នុងព្រៃភ្នំនោះចោលទៅ ហើយទ្រង់បញ្ជាឲ្យថែរក្សាគោរពមនុស្សចាស់ជរា ដោយចិត្តសប្បុរសធម៌។

2. នៅប្រទេសឥណ្ឌា មានកាលមួយនោះ ព្រះមហាក្សត្រិយានីស្តេចវិទេហៈ ទ្រង់សុបិននិមិត្តឃើញដំរីសមួយ មានដុះភ្លុកប្រាំមួយ។ ព្រះអគ្គមហេសីនឹកចង់បានភ្លុកដំរីសនោះ ក៏ទូលអង្វរព្រះមហាក្សត្រឲ្យរកយកមកថ្វាយ។ ព្រះមហាក្សត្រ ទោះបីយល់ថា ការនេះប្រហែលជាមិនបានសម្រេចទេយ៉ាងនេះ ក៏ដោយ តែដោយក្តីស្នេហាចំពោះព្រះអគ្គមហេសី ព្រះអង្គទ្រង់ប្រកាសថានឹងប្រទានរង្វាន់ធំដល់ព្រានព្រៃណាដែលបានប្រទះឃើញដំរីរបៀបនេះ ហើយយកដំណឹងមកថ្វាយព្រះអង្គ។

កាលនោះនៅក្នុងព្រៃហិមពាន្ត មានដំរីមួយមានភ្លុកប្រាំមួយរស់នៅពិតប្រាកដមែន។ ដំរីសនោះ កំពុងតែហាត់ហ្វឹកហ្វឺន ដើម្បីបានសម្រេចពន្លឺត្រាស់ដឹង។ មានថ្ងៃមួយ ដំរីស

បានជួយសង្គ្រោះព្រានព្រៃម្នាក់ ឲ្យរួចផុតពីគ្រោះថ្នាក់ធំដល់ជីវិតនាកណ្ដាលព្រៃភ្នំ។ ព្រានព្រៃនោះក៏បានរួចរស់មានជីវិតត្រឡប់មកដល់ផ្ទះវិញដោយសុខសាន្ត។ កាលនោះ ព្រានព្រៃដោយវង្វេងស្មារតីនឹងការនឹកសង្ឃឹមចង់បានមហាវង្វាន់ ក៏ភ្លេចអស់នូវគុណ ដែលដំរីសបានធ្វើដល់ខ្លួន។ ព្រានព្រៃត្រឡប់ចូលទៅក្នុងព្រៃភ្នំវិញ ដើម្បីសម្លាប់ដំរីស។

ដោយដឹងថា ដំរីសកំពុងតែបំពេញសេចក្ដីព្យាយាមដើម្បីសម្រេចពន្លឺត្រាស់ដឹង ព្រានព្រៃក៏ក្លែងខ្លួនជាបព្វជិតមួយអង្គលបចូលទៅបាញ់ត្រូវដំរីស ដែលពុំបានប្រុងប្រយ័ត្ននឹងព្រួញពិសមួយ។

ដំរីសដឹងខ្លួនថា នឹងជិតដល់នូវទីអវសាននៃជីវិតហើយ។ ដឹងទៀតថា ព្រានព្រៃងប់ងល់នឹងចំណង់លោភិយដោយចង់បានវង្វាន់។ ដំរីសក៏មានចិត្តអាណិតអាសូរព្រានព្រៃ ហើយយកជើងរាំងរាការពារព្រាននោះនឹងដំរីឯទៀត ដែលប្រុងនឹងប្រហារព្រាន ដើម្បីជាការសងសឹក។ ដំរីសសួរទៅព្រានថា ហេតុដូចម្ដេចក៏អ្នកប្រព្រឹត្តអំពើឆ្គួតលេលារបៀបនេះ។ ព្រានព្រៃនិយាយអំពីរឿងវង្វាន់ប្រាប់ទៅដំរីស ហើយវាចាថា ចង់

ដកយកក្ទុកទាំងប្រាំមួយនោះ។ ភ្លាមនោះ ដំរីក៏បោលដល់នឹងដើមឈើ កាច់យកក្ទុកប្រគល់ឲ្យទៅព្រានព្រៃ ហើយថ្លែងថា: «ដោយខ្ញុំបានធ្វើទាននេះ ខ្ញុំបានចប់ការព្យាយាមរបស់ខ្ញុំដើម្បីទៅកាន់ពុទ្ធញ្ញាណហើយ ហើយខ្ញុំនឹងទៅកើតក្នុងដែនដីបរិ-សុទ្ធ។ កាលណាខ្ញុំបានត្រាស់ជាព្រះពុទ្ធ ខ្ញុំនឹងជួយអ្នកឲ្យបានចាកផុតពីព្រួញពិសទាំងបីគឺ: ការលោភលន់ ការក្រោធខឹង និងការយល់ច្រឡំ»។

3. នៅក្នុងជង្គុំព្រៃឫស្សីនាជើងភ្នំហិមពាន្ត មានសត្វសេកមួយរស់នៅជាមួយនឹងម្រឹគីម្រឹគា បក្សាបក្សីឯទៀតៗ ជាច្រើន។ ថ្ងៃមួយដោយត្រូវខ្យល់បក់ខ្លាំង ដើមឫស្សីពីរដើមកកិតគ្នាបង្កើតបានជាភ្លើងឆេះព្រៃឫស្សីទាំងមូល។ ម្រឹគ បក្សីទាំងឡាយមានការភិតភ័យជាខ្លាំង។ សត្វសេកមានចិត្តអាណិតម្រឹគបក្សីដែលកំពុងរងទុក្ខភ័យ ហើយនឹកដល់គុណដែលសត្វទាំងនោះបានផ្ដល់ដល់ខ្លួនឲ្យបានរស់នៅដោយសុខសាន្តក្នុងព្រៃឫស្សីនោះ ក៏ខំជួយសង្គ្រោះសត្វទាំងនោះ យ៉ាងអស់សមត្ថភាព។ សត្វសេក លោតមុជទៅក្នុងបឹងនៅជិតនោះ ស្រូបពាំយកទឹក

ហើរឡើងទៅលើភ្លើង ហើយព្រួសទឹកចុះមក ដើម្បីពន្លត់អគ្គី-ភ័យ។ សត្វសេកព្យាយាមធ្វើកិច្ចនេះ ដោយចិត្តអាណិតអាសូរ និងដឹងគុណដល់ដង្ហុំព្រៃឫស្សី ។

ចិត្តមានប្រណីមេត្តា និងពលិកម្មនៃសត្វសេកនោះ បានដឹងដល់ព្រះឥន្ទ្រ។ ព្រះឥន្ទ្រក៏ចុះពីឋានសួគ៌មក ហើយមានព្រះបន្ទូលទៅកាន់សេកថា: «អ្នកមានចិត្តក្លាហានក៏ពិតមែនហើយ តែវាបានប្រយោជន៍អ្វី ដែលអ្នកព្រួសដំណក់ទឹកបន្តិចបន្តួចទៅលើភ្លើងដ៏ធំយ៉ាងនេះ ? » ។ សេកឆ្លើយថា «គ្មានអ្វីដែលមិនអាចបំពេញបាន ដោយចិត្តដឹងគុណ និងជាពលិ-កម្មនោះទេ។ ខ្ញុំនឹងខំបំពេញហើយខំទៀត រហូតដល់អនាគតជាតិនៃខ្ញុំជាខាងក្រោយៗទៀត»។ ព្រះឥន្ទ្រាធិរាជ ទ្រង់រំភើបនឹងចិត្តដ៏ប្រសើរនៃសេកនោះ ហើយជួយលត់មហាអគ្គីភ័យនោះឲ្យបានរលត់ទៅ។

4. កាលមួយនោះ នៅក្នុងព្រៃហិមពាន្ត មានបក្សីមួយមានអង្គកាយមួយ និងក្បាលពីរ។ មានមួយថ្ងៃ ក្បាលមួយបានឃើញក្បាលមួយទៀត ស៊ីផ្លែឈើដ៏ឆ្ងាញ់ពិសា ក៏កើតក្តីប្រណែន

ហើយនិយាយទៅកាន់ខ្លួនឯងថា: «អញនឹងស៊ីផ្លែឈើមានពិសពុល»។ គិតដូច្នោះហើយ ក្បាលនោះក៏ស៊ីផ្លែឈើមានពិសពុល ហើយអង្គបក្សីទាំងមូលក៏ក្សិណក្ស័យទៅ។

5. មានមួយកាល កន្ទុយនិងក្បាលនៃសត្វពស់មួយឈ្លោះដណ្តើមគ្នាលូនទៅមុខ។ កន្ទុយនិយាយទៅកាន់ក្បាលថា: «មិនយុត្តិធម៌ទេ! ពេលខ្លះ ឯងគួរតែទុកឲ្យអញនាំមុខផង»។ ក្បាលឆ្លើយថា «នេះជាច្បាប់ធម្មជាតិរបស់យើង ដែលអញត្រូវតែនៅខាងក្បាល អញមិនអាចប្តូរកន្លែងជាមួយនឹងឯងបានទេ»។

ការឈ្លោះប្រកែកគ្នានេះ ចេះតែមានជាបន្តបន្ទាប់ ដរាបទៅរហូតដល់មានមួយថ្ងៃ កន្ទុយទៅរៀនព័ន្ធព័ទ្ធនឹងដើមឈើធំមួយ បណ្តាលឲ្យក្បាលទៅមុខមិនរួច។ នៅពេលដែលក្បាលអស់កម្លាំងប្រយុទ្ធលែងកើត កន្ទុយក៏លូនផ្លោះទៅតាមទិសដែលខ្លួនចង់ទៅនោះទៅ។ ពស់ក៏ធ្លាក់ទៅក្នុងគប់ភ្លើង ហើយក៏ដល់នូវក្តីមរណៈទៅ។

នៅក្នុងធម្មជាតិ តែងតែមានលំដាប់លំដោយមួយ ហើយ

អ្វីៗទាំងអស់សុទ្ធតែមានមុខងារពិសេសផ្ទាល់ផ្សេងៗគ្នា។ បើកាលណាលំដាប់លំដោយនោះមានការរឹកររហើយ ដំណើរការទាំងអស់នឹងឈប់ដើរ ហើយលំដាប់លំដោយទាំងមូលមុខតែនឹងឆ្ពោះទៅរកក្តីវិនាសជាទីបំផុត។

6. ក្នុងសម័យមួយនោះ មានបុរសម្នាក់ឆេវឆាវឆាប់ខឹងជាពន់ពេក។ ថ្ងៃមួយ មានបុរសពីរនាក់សន្ទនាគ្នាអំពីបុរសឆាប់ខឹងនៅមុខផ្ទះបុរសនោះថា: «គាត់ជាមនុស្សគួរជាទីពប់អានស្រឡាញ់តែគាត់ខ្វះសេចក្តីអំណត់។ គាត់មានចរិតឆេវឆាវ ឆាប់ប្រទ្បោតខឹងណាស់»។ បុរសឆាប់ខឹងភ្ញាក់នឹងការសន្ទនាគ្នានេះ ក៏ស្ទុះចេញពីផ្ទះដោយកំរោល ទៅប្រវាយប្រតប់ទាត់ធាក់បុរសពីរនាក់ដែលសន្ទនាគ្នានោះ បណ្តាលឲ្យគ្នាមានរបួសជាច្រើនអន្លើ។

មនុស្សប្រកបដោយគតិបណ្ឌិត កាលណាឮអ្នកដទៃនិយាយអំពីកំហុសរបស់គេ គេយករឿងនោះទៅពិចារណាហើយគេកែចរិយាអាក្រក់របស់គេ។ ផ្ទុយទៅវិញមនុស្សពាលកាលណាមានគេបង្ហាញឲ្យឃើញនូវចរិយាអាក្រក់របស់ខ្លួន

បុគ្គលឆ្កួតពាលនោះ មិនត្រឹមតែមិនយកចិត្តទុកដាក់នឹងការព្រមាននោះទេ គេរឹតតែខំប្រព្រឹត្តកំហុសដដែលនោះជាថ្មីបន្តទៅទៀតផង។

7. កាលនោះ មានជនម្នាក់ជាអ្នកមានស្តុកស្តម្ភ តែឆ្កួតលេលា។ នៅពេលដែលអ្នកមានស្តុកស្តម្ភទៅឃើញផ្ទះ របស់ជនម្នាក់ទៀតមានជាន់ទី៣យ៉ាងល្អឆើត គាត់ក៏កើតចិត្តចង់ឲ្យគេសង់ផ្ទះមួយមានជាន់ទី៣ ល្អដូចរបស់ជនម្នាក់ទៀតនោះដែរ។ គាត់ឲ្យគេហៅជាងធ្វើផ្ទះមក ហើយបង្គាប់ឲ្យសង់ជាន់ទី៣មួយឲ្យគាត់។ ជាងធ្វើផ្ទះទទួលយល់ព្រម ចាប់ផ្តើមចាក់គ្រឹះជាដំបូងស្ថាបនាជាន់ទី១ រួចហើយសង់ជាន់ទី២ ហើយជាចុងក្រោយបង្អស់សង់ជាន់ទី៣។ នៅពេលដែលអ្នកមានស្តុកស្តម្ភឃើញការសង់ផ្ទះរបៀបនេះ គាត់ខឹងច្រឡោតឡើង ហើយស្រែកថា: «អញមិនត្រូវការគ្រឹះ ជាន់ទី១ និងជាន់ទី២ នោះទេ ! អ្វីដែលអញចង់បាន គឺជាន់ទី៣ យ៉ាងល្អឆើតមួយតែប៉ុណ្ណោះ ចូរសង់ឲ្យអញភ្លាមមក ! » ។

មនុស្សឆ្កួត គិតតែពីលទ្ធផលមួយមុខប៉ុណ្ណោះ គេគ្មាន

គិតដល់ការខំប្រឹងប្រែងជាចាំបាច់ ដើម្បីទៅដល់លទ្ធផលនោះទេ ព្រោះមនុស្សបែបនេះ ខ្វះក្ដីអំណត់។ គ្មានការប្រសើរណាកើតដោយឯង ៗ ដោយអត់បានធ្វើការខំប្រឹងប្រែងនោះទេ បើពុំនោះទេ គឺដូចជាគេចង់សង់ជាន់ទី៣ ដោយអត់បានចាក់គ្រឹះសង់ជាន់ទី១ និងជាន់ទី២ ជាបន្តបន្ទាប់ដូច្នោះដែរ។

8. *កាលមួយនោះ មានបុរសលេលាម្នាក់ ដាំរំងាស់ទឹកឃ្មុំ។ មិត្តរបស់គេម្នាក់មកដល់ បុរសលេលានោះនឹកចង់ឲ្យមិត្តផឹកទឹកឃ្មុំ។ តែទឹកឃ្មុំវាក្ដៅពេក បុរសលេលាក៏តាំងផ្លុំដើម្បីឲ្យបានត្រជាក់ដោយមិនបានយកទឹកឃ្មុំចេញពីភ្លើងទេ។ ភាពត្រជាក់ត្រជុំនៃគតិបណ្ឌិតក៏ដូច្នោះដែរ គេមិនអាចទទួលបាននូវគតិបណ្ឌិតដ៏ត្រជាក់នោះទេ បើគេមិនពន្លត់ភ្លើងនៃតណ្ហាលោកិយជាមុនសិននោះទេ។*

9. *ម្ដងនោះ មានបិសាចពីររូបឈ្លោះប្រកែកគ្នាមួយថ្ងៃវាល់ល្ងាច ដណ្ដើមគ្នាយកប្រអប់មួយ ដំបងមួយ និងស្បែកជើងមួយគូ។ មានបុរសម្នាក់ដើរកាត់តាមទីនោះ សួរទៅថា: «ហេតុ*

អ្វីក៏លោកឈ្លោះប្រកែកគ្នា ដោយសាររបស់អស់ទាំងនេះ ? តើរបស់អស់ទាំងនេះ មានឥទ្ធិពលទិព្វដូចម្ដេចដែរ បានជាលោកដណ្ដើមគ្នាដូច្នេះ ? » ។

បិសាចពន្យល់ទៅបុរសនោះថា ប្រអប់ទិព្វនេះអាចផ្ដល់វត្ថុគ្រប់បែបយ៉ាងដែលប្រាថ្នាចង់បាន ដូចជាចំណីអាហារសម្លៀកបំពាក់ សម្បត្តិទ្រព្យ ជាដើម។ ដំបងទិព្វនេះ មានឥទ្ធិឫទ្ធិអាចបង្ក្រាបសត្រូវគ្រប់ទិសទីបាន។ ហើយស្បែកជើងទិព្វមួយគូនេះ អាចពាក់ហោះហើរលើអាកាសបាន។

ឮសេចក្ដីនេះហើយ បុរសនោះស្រដីថា: «តើលោកទាស់គ្នាធ្វើអ្វី បើលោកចេញពីទីនេះតែមួយភ្លែត ខ្ញុំអាចធ្វើការបែងចែករបស់ទាំងនេះដល់លោកដោយយុត្តិធម៌»។ បិសាចទាំងពីរក៏ថយចេញឆ្ងាយបន្តិចទៅ។ ភ្លាមនោះបុរសក៏ពាក់ស្បែកជើងទិព្វ ឆក់យកប្រអប់និងដំបងទិព្វ ហើយស្ទុះហោះទៅលើអាកាសបាត់ទៅ។

បិសាចទាំងពីរនោះ តំណាងពួកអ្នកកាន់សាសនាផ្សេងពីព្រះពុទ្ធសាសនា។ ប្រអប់ទិព្វតំណាងទេយ្យទាន ដែលកើតមានឡើងនៅក្នុងចិត្តប្រកបដោយសប្បុរសធម៌ មនុស្សលោក

មិនយល់ថា តើកំណាប់ទ្រព្យដ៏ច្រើនប៉ុនណា ដែលហូរចេញពីទេយ្យទានប្រកបដោយចិត្តសប្បុរសនេះទេ។ ដំបងទិព្វ តំណាងការព្យាយាមសង្រួមចិត្តៈ មនុស្សលោកមិនយល់ថា គឺដោយសារការព្យាយាមសង្រួមចិត្តនេះហើយ ដែលគេអាចបង្ក្រាបតណ្ហាលោកិយទាំងអស់បាន។ ស្បែកជើងទិព្វមួយគូនោះ តំណាងវិន័យល្អបរិសុទ្ធនៃគំនិតនិងចរិយា ដែលជាយានដឹកនាំសត្វលោកឲ្យផុតពីចំណង់ និងជម្លោះទាស់ទែងទាំងឡាយ។ ដោយមិនយល់នូវសេចក្តីទាំងនេះ មនុស្សលោកឈ្លោះប្រកែកគ្នាដណ្តើមយកប្រអប់ទិព្វ ដំបងទិព្វ និងស្បែកជើងទិព្វ។

10. កាលមួយនោះ មានបុរសម្នាក់ធ្វើដំណើរម្នាក់ឯង ទៅដល់ផ្ទះមួយគ្មានមនុស្សនៅ ក៏សម្រេចចិត្តចូលដេកក្នុងផ្ទះនោះ ដល់ពាក់កណ្តាលអធ្រាត្រ មានបិសាចមួយលីសពមួយ ចូលមកក្នុងផ្ទះនោះ ហើយដាក់សពទៅលើរនាបផ្ទះ។ បន្តិចមកទៀត មានបិសាចមួយទៀតចូលមក ហើយទាមទារខ្មោចនោះថាជារបស់ខ្លួន។ បិសាចទាំងពីរក៏ចាប់ឈ្លោះប្រកែកគ្នា។

បិសាចទី១ ស្តីឡើងថា ឈ្លោះគ្នាបន្តយូរទៅទៀតជាការ

ឥតប្រយោជន៍ហើយស្នើថា គួរតែរកចៅក្រមកាត់សេចក្ដីឲ្យ តើខ្មោចនេះជារបស់អ្នកណា?។ បិសាចទី២យល់ព្រម ក្រឡេក ទៅឃើញបុរសដេកនៅកៀនជញ្ជាំង ក៏ស្នើសុំឲ្យបុរសនោះ កាត់សេចក្ដីឲ្យ។ បុរសមានសេចក្ដីភិតភ័យជាខ្លាំង ដោយគិត ថាៈ «ទោះបីអញកាត់ក្ដីបែបណាក៏ដោយ ក៏បណ្ដាលឲ្យបិសាច ដែលចាញ់ខឹងជាប្រាកដ។ វានឹងសង់សឹកអញហើយសម្លាប់ អញជាមិនខាន»។ បុរសក៏ដាច់ចិត្តនិយាយការពិត ដែលគាត់ បានឃើញនឹងភ្នែក។

ឃើញថាជាការអត់អំពើ បិសាចទី២ ខឹងច្រឡោតឡើង ហើយចាប់កន្ត្រាក់ដៃបុរសម្ខាងរបេះចេញអំពីដងខ្លួនទៅ។ តែបិសាចទី១ យកដៃខ្មោចមកដាក់ជំនួសឲ្យវិញ។ បិសាច ដែលច្រឡោតខឹងចាប់យកដៃបុរសម្ខាងទៀត បិសាចទី១ យកដៃខ្មោចម្ខាងទៀត មកដាក់ជំនួសឲ្យភ្លាមមួយរំពេច ទៀត។ ការនេះចេះតែប្រព្រឹត្តិទៅជាបន្តបន្ទាប់រហូតដល់ ដៃទាំងពីរ ជើងទាំងពីរ ក្បាល និងដងខ្លួននៃបុរសត្រូវបាន ដាក់ជាជំនួសដោយអវយវៈរបស់ខ្មោច។ បន្ទាប់មកបិសាច ទាំងពីរឃើញអវយវៈបុរសនៅរាត់រាយពេញលើរនាប

ក៏ស្ទុះទៅរើសស៊ីអស់ ហើយសើចតិចៗដើរចេញបាត់ទៅ។

បុរសកំសត់ដែលជ្រកក្នុងផ្ទះឥតមនុស្សនៅនោះ មានចិត្តញាប់ញ័រជាខ្លាំងនឹងសំណាងអាក្រក់របស់ខ្លួន។ អវយវៈទាំងឡាយដែលបិសាចស៊ីអស់ទៅនោះ ជាអវយវៈដែលមាតាបិតាបានចែកឲ្យ តែអវយវៈដែលជាប់នឹងខ្លួនក្នុងពេលនេះ ជាអវយវៈរបស់ខ្មោចៗ ទីបំផុតទៅតើខ្លួនជានរណា ? បុរសដោះស្រាយរឿងនេះពុំរួច ទៅជាមនុស្សឆ្កួតលេលាដើរវង្វេងវង្វាន់ចេញពីផ្ទះនោះទៅ។ បុរសដើរតម្រង់ទៅវិហារមួយ ចូលទៅក្នុងវិហារ ហើយថ្លែងរឿងទុក្ខព្រួយប្រាប់ទៅបព្វជិតទាំងឡាយ ដែលគង់ក្នុងវិហារ។ បុគ្គលទាំងឡាយអាចយល់ន័យពិត អំពីភាពគ្មានអាត្មាអញ តាមដោយរឿងនិទាននេះ។

11. កាលមួយនោះ មានស្រីស្រស់ប្រិមប្រិយស្លៀកពាក់ស្អាតបាតម្នាក់ ចូលទៅលេងផ្ទះគេមួយ។ ម្ចាស់ផ្ទះសួរទៅស្រីនោះថា នាងស្រីជានរណា? ស្រីកញ្ញាឆ្លើយថា ខ្ញុំជាទេពធីតានៃ

សម្បត្តិទ្រព្យ។ ម្ចាស់ផ្ទះត្រេកអរជាអនេក ហើយទទួលស្រីកញ្ញាយ៉ាងរាក់ទាក់។

បន្តិចក្រោយមកទៀត មានស្រីម្នាក់ទៀតអាក្រក់គួរខ្លាចស្លៀកពាក់រយីករយាក ដើរចូលមក។ ម្ចាស់ផ្ទះសួរទៅស្រីនោះថា អ្នកឯងជានរណាដែរ ? ។ ស្រីនោះឆ្លើយថា ខ្ញុំជាទេពធីតានៃសេចក្ដីក្រខ្សត់។ ម្ចាស់ផ្ទះភ័យជាខ្លាំង ហើយល្បងបណ្ដេញស្រីនោះឲ្យចេញពីផ្ទះ។ ប៉ុន្តែស្រីនោះពុំព្រមចេញថែមទាំងនិយាយថា៖«ទេពធីតានៃទ្រព្យសម្បត្តិត្រូវជាបងស្រីខ្ញុំ។ យើងបានសន្យាគ្នាថា នឹងមិននៅបែកគ្នាជាដាច់ខាត។ បើអ្នកបណ្ដេញខ្ញុំ បងស្រីខ្ញុំត្រូវតែទៅជាមួយនឹងខ្ញុំដែរ»។ យ៉ាងជាក់ស្ដែង គ្រាន់តែស្រីរូបអាក្រក់ចេញផុតទៅ ស្រីរូបល្អក៏បាត់រូបទៅដែរ។

ការកើតទៅជាមួយនឹងការស្លាប់។ សំណាងល្អទៅជាមួយនឹងសំណាងអាក្រក់។ វត្ថុអាក្រក់ដើរតាមវត្ថុល្អជានិច្ចកាល។ បុគ្គលគ្រប់រូបត្រូវតែដឹងយល់រឿងនេះ។ មនុស្សឆ្កួតលេលាខ្លាចសំណាងអាក្រក់ ហើយរត់តាមសំណាងល្អ។ ប៉ុន្តែបុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹងត្រូវតែឈ្នះនូវសំណាងអាក្រក់ និងសំណាង

ល្អនេះ ហើយចាកផុតពីគ្រប់ចំណង់លោកិយទាំងអស់។

12. សម័យមួយនោះ មានវិចិត្រករក្រខ្សត់ម្នាក់ចាកចោលប្រពន្ធនិងផ្ទះសម្បែង ដើម្បីស្វែងរកទ្រព្យ។ ក្រោយពីការខិតខំយ៉ាងលំបាកអស់បីឆ្នាំមក វិចិត្រករកំសត់សន្សំបានកាសមាសបីរយសន្លឹក ហើយសម្រេចចិត្តត្រឡប់មកផ្ទះវិញ។ មកដល់ពាក់កណ្ដាលផ្លូវ គាត់ប្រទះនឹងវត្តធំមួយ គេកំពុងតែធ្វើបុណ្យដាក់ទាន។ គាត់ជាប់អារម្មណ៍ជាខ្លាំង ហើយគិតក្នុងចិត្តថា:«មកទល់ពេលនេះ អញគិតតែអំពីបច្ចុប្បន្នកាល អញមិនដែលបានគិតអំពីសុកមង្គល ទៅអនាគតកាលសោះ ។ អញមកដល់កន្លែងល្អនេះ ជាសំណាងល្អរបស់អញហើយ។ អញត្រូវតែឆ្លៀតដាំបណ្ដុះគ្រាប់ពូជជាកុសលបុណ្យក្នុងពេលនេះ»។ គិតឃើញដូច្នោះហើយ គាត់ក៏ឲ្យប្រាក់ដែលសន្សំបានទាំងប៉ុន្មាន ទៅវត្តនោះអស់ទៅ ហើយត្រឡប់ទៅផ្ទះវិញគ្មានប្រាក់មួយកាក់សោះ។ មកដល់ផ្ទះប្រពន្ធជេរស្ដីគាត់ថា គ្មានរកបានប្រាក់សូម្បីមួយកាក់មកឲ្យ ដើម្បីចិញ្ចឹមជីវិតសោះ។ វិចិត្រករកំសត់ឆ្លើយថា ខ្ញុំរកបានកាសមាសជាច្រើន តែខ្ញុំបាន

ទុកនៅក្នុងទីកន្លែងប្រាកដល្អមួយ។ នៅពេលដែលប្រពន្ធបេះតែជំរឹតសួរឲ្យប្រាប់កន្លែងដែលគាត់លាក់ វិចិត្រករក៏ប្រាប់ត្រង់ថា គាត់បានប្រគេនទៅព្រះសង្ឃនៅក្នុងវត្តមួយអស់ទៅហើយ។

រឿងនេះបណ្តាលឲ្យប្រពន្ធខឹងច្រឡោត ជេរស្តីគ្រប់ចំពូក។ នៅទីបំផុត ប្រពន្ធយករឿងនេះទៅប្តឹងចៅក្រម។ នៅពេលចៅក្រមសួរចម្លើយ វិចិត្រករឆ្លើយថា ខ្លួនពុំបានប្រព្រឹត្តអំពើឆ្គួតលេលាទេ ពីព្រោះខ្លួនសន្សំប្រាក់មាសបាន ដោយសារការខំប្រឹងប្រែងតស៊ូដ៏លំបាកអស់ពេលជាយូរ ហើយខ្លួនមានបំណងយកមាសនេះ ធ្វើជាគ្រាប់ពូជសម្រាប់ជាសម្បត្តិអនាគត។ នៅពេលទៅដល់វត្តមួយ គាត់យល់ថា នៅកន្លែងនេះហើយ ដែលគាត់គួរតែបណ្តុះគ្រាប់ពូជសម្បត្តិអនាគតរបស់គាត់។ គាត់បន្ថែមទៀតថា: «កាលខ្ញុំប្រគេនមាសទៅព្រះសង្ឃ ខ្ញុំហាក់ដូចជាបានបោះបង់ចោលនូវសេចក្តីលោភលន់ និងសេចក្តីកំណាញ់ ដែលមាននៅក្នុងចិត្តខ្ញុំនៅពេលជាមួយគ្នានោះ។ ខ្ញុំបានយល់ឃើញថា សម្បត្តិពិតប្រាដកពុំមែនមាសនោះទេ គឺចិត្តនោះឯងតែម្តង»។

ចៅក្រមសរសើរការយល់ត្រូវរបស់វិចិត្រករ ហើយអ្នក

ទាំងឡាយដែលបានស្តាប់ឮសេចក្តីនេះ ក៏យល់ស្របតាមហើយជួយជ្រោមជ្រែងវិចិត្រករនោះគ្រប់ចំពូក។ ដោយសារហេតុនេះវិចិត្រករនិងប្រពន្ធ ក៏បានសម្បត្តិល្អជានិច្ចនិរន្តរ៍តទៅ។

13. បុរសម្នាក់រស់នៅជិតកន្លែងកប់ខ្មោច នាយប់ស្ងាត់មួយនោះ បានឮសំឡេងស្រែកហៅខ្លួនចេញពីផ្នូរមួយមក។ គាត់ខ្លាចពេកពុំហ៊ានទៅមើលឲ្យដឹងរឿងទេ។ ព្រឹកស្អែកឡើងគាត់យករឿងនោះទៅប្រាប់មិត្តក្លាហានរបស់គាត់ម្នាក់។ មិត្តនោះប៉ងនឹងទៅមើលកន្លែងដែលបុរសតំណាលប្រាប់ ដើម្បីស្តាប់សំឡេងខ្មោចស្រែកហៅ នៅយប់បន្ទាប់។

នៅពេលដែលបុរសកំសាកកំពុងតែភ័យញាក់ មិត្តរបស់គាត់ទៅកន្លែងកប់ខ្មោចនាយប់បន្ទាប់នោះ ហើយឮសំឡេងស្រែកហៅ ចេញពីផ្នូរមួយមកប្រាកដមែន។ បុរសជាមិត្តសួរទៅថា អ្នកជាអ្វី ហើយចង់បានអ្វី។ សំឡេងចេញពីក្នុងដីមកថា «ខ្ញុំជាកំណប់ដែលគេកប់លាក់ទុកជាយូរមកហើយ ហើយខ្ញុំសម្រេចចិត្តផ្តល់ខ្លួនខ្ញុំនេះឲ្យទៅជនណាម្នាក់។ ពីយប់មុន ខ្ញុំបានធ្វើអំណោយខ្លួនខ្ញុំនេះដល់បុរសម្នាក់ តែបុរសនោះកំសាក

ពេក មិនហ៊ានមកយកដោយខ្លួនឯង ហេតុដូច្នេះ អ្នកត្រូវបាន កំណាប់នេះ ពីព្រោះអ្នកស័ក្តិសមនឹងបានកំណាប់។ ស្អែកព្រឹក ខ្ញុំនឹងទៅផ្ទះអ្នកជាមួយនឹងអ្នកបម្រើរបស់ខ្ញុំប្រាំពីរនាក់»។

បុរសជាមិត្តនិយាយថា: «ខ្ញុំនឹងរង់ចាំអ្នក ប៉ុន្តែសុំមេត្តា ប្រាប់ខ្ញុំ តើខ្ញុំត្រូវរៀបចំទទួលអ្នករបៀបដូចម្តេច?»។ សំឡេង ឆ្លើយឡើងថា: «យើងនឹងទៅផ្ទះអ្នកក្នុងសម្លៀកបំពាក់ជាបព្វ ជិត។ ចូររៀបចំបន្ទប់មួយ និងទឹកទុកឲ្យយើង។ ចូរអ្នកដុស លាងខ្លួនប្រាណរបស់អ្នក ហើយបោសច្រាសបន្ទប់នោះឲ្យ ស្អាត។ ចូររៀបកៅអីនិងបាយប្រាំបីចានទុកឲ្យយើង។ ក្រោយ ពេលយើងបរិភោគរួច ចូរអ្នកនាំយើងទៅក្នុងបន្ទប់បិទជិតមួយ។ នៅក្នុងបន្ទប់នោះ យើងនឹងប្រែខ្លួនយើងឲ្យទៅជាក្អមប្រាំបី ពេញទៅដោយមាស»។

ព្រឹកស្អែកឡើង បុរសជាមិត្តនោះបោសច្រាសបន្ទប់ដូច បានទទួលបញ្ជាមក រួចហើយរង់ចាំបព្វជិតទាំងប្រាំបីអង្គនិមន្ត មកដល់។ សង្ឃទាំងប្រាំបីអង្គនិមន្តមកដល់ តាមពេលសន្យា។ បុរសនោះទទួលដោយសេចក្តីគោរព។ ក្រោយពេលឆាន់ចង្ហាន់ រួច បុរសនិមន្តបព្វជិតទាំងនោះមួយអង្គម្តងៗទៅក្នុងបន្ទប់បិទ

ជិតមួយ។ បព្វជិតគ្រប់អង្គ ក៏ប្រែខ្លួនក្លាយទៅជាក្អមពោរពេញទៅដោយមាស។

កាលនោះ នៅក្នុងភូមិនោះ មានបុរសម្នាក់លោភលន់ជាពន់ពេក។ នៅពេលគាត់បានដឹងរឿងនោះ គាត់នឹកចង់បានក្អមពោរពេញដោយមាសទាំងនោះដែរ។ គាត់ក៏និមន្តបព្វជិតប្រាំបីអង្គនោះទៅផ្ទះគាត់។ នៅពេលឆាន់រួចសព្វគ្រប់ហើយ បុរសលោភលន់នាំបព្វជិតទាំងនោះ ទៅក្នុងបន្ទប់បិទជិតមួយ។ ប៉ុន្តែបព្វជិតទាំងនោះ មិនព្រមប្រែរូបឲ្យទៅជាក្អមពេញដោយមាសទេ ទៅជាច្រឡោតខឹង ហើយនាំគ្នាទៅប្ដឹងក្រុមរក្សាសន្តិសុខ។ ទីបំផុត ក្រុមរក្សាសន្តិសុខចាប់បុរសនោះទៅ។

ចំណែកបុរសកំសាក នៅពេលបានដឹងថា សំឡេងដែលបន្លឺចេញពីផ្ទះ បានផ្ដល់សម្បត្តិស្ដុកស្ដម្ភដល់បុរសក្លាហានយ៉ាងនេះហើយ ដោយមានចិត្តលោភលន់ គាត់ក៏ទៅផ្ទះបុរសក្លាហាន ទាមទារយកមាសទាំងនោះ ដោយសំអាងថាសំឡេងនោះបានស្រែកមករកខ្លួនជាមុន។ នៅពេលដែលគាត់ឈោងចាប់យកក្អមទាំងនោះ ពស់វែកជាច្រើនបើកវែក លូន

ចេញពីក្អមប្រុងនឹងចឹកគាត់។

ព្រះមហាក្សត្រទ្រង់ជ្រាបរឿងនេះ ក៏ដាក់បញ្ញត្តិថា ក្អមទាំងនោះជារបស់បុរសក្លាហាន។ ហើយព្រះអង្គទ្រង់ពិចារណាថា: «រឿងហេតុទាំងពួង វាតែងតែមានឡើងរបៀបនេះជានិច្ចនៅក្នុងលោកនេះ។ មនុស្សឆ្លួតលេលាពោរពេញទៅដោយចំណង់ ចង់បានប្រយោជន៍ តែកំសាកពេក ពុំហ៊ានខឹតខំស្វែងរក។ អាស្រ័យហេតុនេះ មនុស្សកំសាកទាំងនោះ តែងតែមិនបានសម្រេចជានិច្ច។ មនុស្សរបៀបនេះ ខ្វះទាំងជំនឿទុកចិត្ត ខ្វះទាំងសេចក្ដីក្លាហានក្នុងការតស៊ូតាមផ្លូវចិត្ត ដែលជាមធ្យោបាយតែមួយគត់ដើម្បីបានសម្រេចសេចក្ដីសុខសន្តិភាពពិតប្រាកដ»។

ចំពូកទី ២

វិធីប្រតិបត្តិឲ្យបានសម្រេច

I

ការស្វែងរកសេចក្តីពិត

1. *កាលណាគេស្វែងរកសេចក្តីពិត គេតែងតែប្រទះនឹងបញ្ហាដែលឥតប្រយោជន៍ទាល់តែសោះខ្វះ ចោទឡើងជានិច្ច។ សកលលោកនេះធ្វើអំពីអ្វី? សកលលោកនេះឋិតថេរឬទេ? សកលលោកនេះ មានព្រំដែនឬទេ ឬគ្មានទេ? សង្គមមនុស្សលោកនេះ កើតឡើងតាមរបៀបដូចម្តេច? អ្វីទៅដែលជាអង្គការប្រសើរឧត្តមនៃសង្គមមនុស្សលោក?។ បើបុគ្គលណាមួយរង់ចាំរកឲ្យឃើញចម្លើយ ចំពោះបញ្ហាទាំងនេះជាមុនសិន ទើបបានចាប់ស្វែងរក និងប្រតិបត្តិដើម្បីទៅកាន់ពន្លឺត្រាស់ដឹង បុគ្គលនោះនឹងស្លាប់មុនរកឃើញផ្លូវនោះជាពុំខាន។*

ឧបមាថា បុរសម្នាក់ត្រូវព្រួញពិស ជាប្រាកដណាស់

មុខតែឪពុកម្តាយ មិត្តភក្តិរបស់គេមកជុំគ្នា ហើយអញ្ជើញគ្រូពេទ្យមកដកព្រួញចេញ ថែមុខរបួស បន្សាបពិស។

បើសិនជាអ្នករបួសប្រកែកថា: «សុំចាំបន្តិចសិន! មុននឹងលោកដកព្រួញនេះ ខ្ញុំចង់ដឹងថា តើនរណាបាញ់ខ្ញុំ?។ តើអ្នកបាញ់នោះ ប្រុសឬស្រី តើជាអភិជន ឬអ្នកស្រែចំការ។ តើធ្នូធ្វើអំពីអ្វី តើធ្នូតូច ឬធ្នូធំ តើធ្វើអំពីឈើ ឬអំពីឫស្សី តើខ្សែធ្នូធ្វើអំពីអ្វី តើធ្វើអំពីសរសៃឈើ ឬស្បែកសត្វ តើព្រួញធ្វើអំពីផ្តៅ ឬអំពីស្រល់។ តើគេយកស្លាបសត្វអ្វីប្រើ។ មុននឹងលោក ដកព្រួញនេះ ខ្ញុំចង់ដឹងសេចក្តីទាំងនេះសិន»។ ក្នុងកាលៈទេសៈបែបនេះ តើបុរសនោះនឹងទៅជាយ៉ាងណា?

មុននឹងបានដំណឹងពិតឥតល្អៀងទាំងនោះ ពិសមានពេលគ្រប់គ្រាន់នឹងបញ្ចេញសកម្មភាព ហូរចូលទៅក្នុងសរសៃឈាម អាចបណ្តាលឲ្យបុរសនោះស្លាប់បាន។ ករណីមុនដំបូង ដែលត្រូវធ្វើគឺដកយកព្រួញចេញ ហើយបង្ខាំងពិសកុំឲ្យជ្រួតជ្រាបសព្វសាយទាន់។

ក្នុងពេលដែលភ្លើងតណ្ហាកំពុងតែធ្វើឲ្យលោកនេះ មានគ្រោះថ្នាក់ ការរកឲ្យដឹងថា តើលោកនេះកើតឡើងអំពីអ្វី ជា

ការបានប្រយោជន៍តិចតួចស្តួចស្តើងណាស់។ ហេតុនេះ ការរកឲ្យយល់នូវសភាពជាក់លាក់ នៃសង្គមមនុស្សលោកនោះ មិនបានប្រយោជន៍ស្មើនឹងការរត់គេចពីភ្លើង ដែលកំពុងឆេះនោះទេ។

រឿងរកឲ្យដឹងថា តើលោកនេះមានព្រំដែនឬទេ តើឋិតថេរហូតឬទេនោះ អាចរង់ចាំបានរហូតដល់ពេលរកឃើញមធ្យោបាយរំលត់ភ្លើងនៃការកើត ជរា ឈឺ និងស្លាប់។ នៅចំពោះមុខភ្លើងទុក្ខព្រួយ ភ្លើងឈឺចាប់ ភ្លើងវេទនា ជាដំបូងបង្អស់ត្រូវរកឲ្យឃើញផ្លូវរំលត់ភ្លើងទាំងនោះ ហើយតាំងចិត្តប្រតិបត្តិតាមផ្លូវនោះ។

សាសនាព្រះពុទ្ធ ពន្យល់យើងអំពីរឿងមានប្រយោជន៍ដែលយើងត្រូវតែដឹង មិនពន្យល់អំពីរឿងអត់ប្រយោជន៍ទេ។ បានន័យថា យើងត្រូវរៀនអ្វីដែលត្រូវរៀន លះបង់អ្វីដែលត្រូវលះបង់ បណ្តុះបណ្តាលអ្វីដែលត្រូវបណ្តុះបណ្តាល ទទួលចំណេះវិជ្ជាអ្វីដែលត្រូវទទួល។

ហេតុដូច្នេះ មុនដំបូងបុគ្គលគ្រប់រូបត្រូវយល់នូវរឿងដែលសំខាន់ជាងគេបំផុត យល់នូវបញ្ហាទាំងឡាយដែលត្រូវ

ដោះស្រាយជាដំបូងគេបំផុត ហើយយល់នូវបញ្ហាដែលបន្ទាន់ជាងគេបង្អស់។ ដើម្បីកិច្ចនេះ ជាដំបូងបង្អស់ បុគ្គលគ្រប់រូបចាំបាច់ត្រូវតែព្យាយាមហាត់បំពត់ចិត្តរបស់ខ្លួន គឺជាត្រូវចេះគ្រប់គ្រងចិត្តគំនិតរបស់ខ្លួន។

2. ឧបមាថា មានបុរសម្នាក់ចូលទៅក្នុងព្រៃ ដើម្បីរកជ័រឈើដែលមាននៅក្នុងដើមរុក្ខជាតិ តែបុរសនោះកាប់យកបានតែមែកនិងស្លឹកមួយបាច់ត្រឡប់មកផ្ទះវិញ ហើយជឿក្នុងចិត្តថាខ្លួនរកបានរបស់ដែលខ្លួនស្វែងរក។ តើបុរសនោះមិនឆ្កួតទេឬ? ដែលសប្បាយចិត្តនឹងបានសំបកឈើ សាច់ឈើស្រាយៗជាជំនួសជ័រឈើ ដែលខ្លួនចេញទៅរកនោះ? ប៉ុន្តែ មានមនុស្សជាច្រើន ដែលតែងតែធ្វើរបៀបនេះ!។

ដូចជាបុរសម្នាក់ស្វែងរកផ្លូវដើម្បីឲ្យបានចាកផុតពីការកើត ការចាស់ជរា ការឈឺ ការស្លាប់ ការទុក្ខព្រួយ ការឈឺចាប់និងការវេទនា។ នៅពេលសម្គាល់ឃើញថា ខ្លួនបានជឿនលឿនទៅមុខខ្លះហើយនោះ ក៏តាំងកើតចិត្តឡើត ក្រអឺតក្រអោងឡើងអំនួត វាយឫកធំ។ បុរសនោះ មិនខុសពីបុរសដែលស្វែង

រកជ័រឈើ ហើយសប្បាយចិត្តដោយរកបានមែកឈើនិងស្លឹកមួយបាច់នោះទេ។

មានបុរសម្នាក់ទៀតត្រេកអរសប្បាយ ដោយបានលូតលាស់ខ្លះក្រោយពីខ្លួនបានខំប្រឹងប្រែងបន្តិចបន្តួចមក ហើយតាំងលះបង់ចោលការខំប្រឹងប្រែង ទៅជាមានចិត្តក្អេងក្អេងក្រអឺតក្រអោង ឡើងអំនួត។ អាចប្រដូចបានថា បុរសនោះទៅរកបានឯមែកឈើមួយបាច់ ជាជំនួសជ័រឈើ ដែលខ្លួនស្វែងរកនោះទៅវិញ។

មានបុរសម្នាក់ទៀត ឃើញថាចិត្តរបស់ខ្លួនបានស្ងប់បន្តិចហើយៗ គំនិតរបស់ខ្លួនបានភ្លឺថ្លាខ្លះហើយ ក៏តាំងលះបង់ការព្យាយាមចោល ហើយទៅជាក្រអឺតក្រអោង ឡើងអំនួត។ បុរសនោះយកបានឯសំបកឈើ ជាជំនួសជ័រឈើ ដែលខ្លួនស្វែងរកនោះទៅវិញ។

មានបុរសម្នាក់ទៀត ឡើងចិត្តឡឺតអួតអាងដោយសារបានដឹងថា ខ្លួនបានមើលឃើញជម្រៅនៃវត្ថុធាតុខ្លះៗហើយ ។ នេះដូចជាទៅបានឯសាច់ឈើស្រាយៗ ជាជំនួសជ័រឈើដូច្នេះដែរ។ អ្នកសង្វាតរកទាំងនេះ ដែលពេញចិត្តនឹងការព្យាយាម

មិនគ្រប់គ្រាន់ ហើយតាំងឡើងអំនួត មានចិត្តក្រអឺតក្រអោង លះបង់ការព្យាយាមចោល ហើយបណ្ដោយខ្លួនឲ្យធ្លាក់យ៉ាងងាយទៅក្នុងភាពទំនេរខ្ជិលច្រអូស។ បុគ្គលទាំងនោះនឹងបានជួបប្រទះនឹងទុក្ខវេទនាវិញ ជាពុំខាន។

អ្នកស្វែងរកផ្លូវពិតប្រាកដទៅកាន់ពន្លឺត្រាស់ដឹង មិនត្រូវគិតសង្ឃឹមលើការងាយស្រួល លើការដែលនឹងត្រូវតែបានគេគោរព ឬលើកកិត្តិយស និងភក្ដីភាពដែលគេត្រូវតែផ្ដល់ឲ្យនោះទេ។ ម្យ៉ាងទៀតក្នុងការប្រាថ្នារកសេចក្ដីសុខស្ងប់ រកការត្រាស់ដឹងនេះ គេមិនត្រូវព្យាយាមដោយខ្ជីខ្ជាទេ។

មុនដំបូងបង្អស់ គេត្រូវយល់ក្នុងចិត្តឲ្យច្បាស់អំពីសភាពពិតដែលជាគ្រឹះសំខាន់នៃពិភពកើតនិងស្លាប់នេះ។

3. លោកនេះ គ្មានសារជាតិឋិតថេរជារបស់ខ្លួនពិតប្រាកដទេ។ វាគ្រាន់តែជាការប្រមូលផ្ដុំដ៏ធំធេងមួយនៃហេតុនិងផលតែប៉ុណ្ណោះ។ ហើយហេតុនិងផលនេះទៀត មានដើមកំណើតពីសកម្មភាពទាំងឡាយនៃចិត្ត ដែលបណ្ដាលមានឡើងដោយសារសេចក្ដីល្ងង់ខ្លៅ ការរមិលឃើញខុស ការចង់បាន ហើយ

និងការដំពាក់ចិត្ត។ លោកនេះ គឺជារូបបញ្ចាំងនៃគំនិតយល់ខុស ដែលស្ថិតមាននៅក្នុងចិត្តៈ វាគ្មានសារជាតិអ្វីជាប្រាកដមួយឡើយ។ គឺដោយសារដំណើរនៃចិត្តនោះឯង ដែលពិភពលោកនេះកើតមានឡើង។ ចិត្តបញ្ចាំងនូវគតិកាន់ប្រទ្បរបស់ខ្លួនផ្ទាល់។ ពិភពលោកនេះ មានគ្រឹះនៅក្នុងចំណង់ទាំងឡាយនៃចិត្ត នៅក្នុងក្តីទុក្ខសោកកង្វល់ដែលកើតឡើងពីចំណង់កំហឹង និងគតិកាន់ប្រទ្បំ។ បុគ្គលស្វែងរកផ្លូវពន្លឺត្រាស់ដឹង ត្រូវតែប្រុងប្រៀបខ្លួនប្រយុទ្ធតទល់នឹងចិត្តរបៀបនេះ ដើម្បីនឹងបានទៅដល់គោលដៅ។

4. ឱចិត្តរបស់ខ្ញុំ! ម្តេចក៏អ្នកហោះហើរមិនចេះឈប់ឈរនៅក្នុងដំណើរប្រែប្រួលនៃជីវិតដូច្នេះ? ម្តេចក៏អ្នកធ្វើឲ្យខ្ញុំច្របូកច្របល់ រកពេលសម្រាកគ្មានដូច្នេះ? ម្តេចក៏អ្នកបង្ខំខ្ញុំឲ្យប្រមូលទុកនូវវត្ថុដ៏ច្រើនមហិមាយ៉ាងនេះ? អ្នកបីដូចជានង្គ័លដែលបាក់មុនគេចាប់ផ្តើមភ្ជួរដី អ្នកបីដូចជាចង្កូតកប៉ាល់ដែលគេដោះបោះចោលនៅពេលដែលគេកំពុងតែ វង្វេងវង្វាន់នាកណ្តាលមហាសមុទ្រនៃការកើតនិងការស្លាប់។ តើបានប្រយោជន៍អ្វីទៅ

ក្នុងការកើតឡើងវិញជាច្រើនដងរាប់មិនអស់នេះ បើអ្នកមិនចេះប្រើប្រាស់ជីវិតនេះឲ្យបានប្រយោជន៍ល្អ?។

ឱចិត្តរបស់ខ្ញុំ ! ម្ដងអ្នកបណ្ដាលឲ្យខ្ញុំទៅកើតជាស្ដេចផែនដី រួចហើយអ្នកបណ្ដាលឲ្យខ្ញុំទៅកើតជាអ្នកងារ ដើរសុំទានគេស៊ី។ ជួនកាលអ្នកបណ្ដាលឲ្យខ្ញុំទៅកើតនៅក្នុងឋានសួគ៌ សោយសម្បត្តិទិព្វរួចហើយ អ្នកទម្លាក់ខ្ញុំទៅក្នុងឋាននរកដ៏សែនជ្រៅ។

ឱចិត្តចម្លួតរបស់ខ្ញុំ ! ឆ្លួតគ្មានសល់ចន្លោះ ! អ្នកបានដឹកនាំឲ្យដើរតាមផ្លូវដ៏ច្រើនរាប់មិនអស់ ហើយខ្ញុំបានគោរពធ្វើតាមអ្នកដោយគ្មានរើសរូស ! តែពេលនេះ ខ្ញុំបានស្ដាប់ឮសេចក្ដីប្រៀនប្រដៅរបស់ព្រះពុទ្ធហើយ សូមឈប់ធ្វើឲ្យខ្ញុំរឹករវទៀតទៅ ឈប់ធ្វើឲ្យខ្ញុំឈឺចាប់ទៀតទៅ សូមទុកឲ្យខ្ញុំមានខន្ដីខំសង្វាតស្វែងរកពន្លឺត្រាស់ដឹងផង !

ឱ ចិត្តរបស់ខ្ញុំ ! បើអ្នកអាចដឹងតែម្យ៉ាងគត់ថា អ្វីៗទាំងអស់គ្មានសារជាតិទេ អ្វីៗទាំងអស់សុទ្ធតែមិនឋិតថេរ ! បើអ្នកអាចរៀនតែម្យ៉ាងគត់គឺ កុំទាក់ទាមនឹងវត្ថុ កុំប្រាថ្នាចង់បានវត្ថុកុំបណ្ដោយឲ្យលុះទៅក្នុងសេចក្ដីលោភលន់ សេចក្ដីខឹងក្រោធ

និងសេចក្ដីធ្លូតក្ងីក្ងើ ! ពេលនោះ យើងនឹងអាចមានដំណើរជីវិតសុខស្ងប់។ ដូច្នេះ បើយើងយកដាវនៃគតិបណ្ឌិត កាត់ផ្ដាច់ចំណងនៃតណ្ហាទាំងឡាយ បើយើងលែងត្រូវបានវឹកវរនឹងដំណើរប្រែប្រួលនៃកាលៈទេសៈ លែងទាក់ទាមនឹងការមានអត្ថប្រយោជន៍ ឬគ្មានអត្ថប្រយោជន៍ នឹងភាពល្អឬភាពអាក្រក់ នឹងការចំណេញឬខាត នឹងការបានគេសរសើរ ឬបានគេប្រមាថ យើងនឹងអាចរស់ក្នុងសុខសន្តិភាព។

ឱ ចិត្តជាទីស្រឡាញ់របស់ខ្ញុំ ! ជាដំបូងបង្អស់ អ្នកបានរំឭកដាស់តឿនខ្ញុំ ឲ្យមានជំនឿក្នុងការស្វែងរកពន្លឺត្រាស់ដឹង ចុះហេតុដូចម្ដេច ក៏អ្នកបណ្ដោយឲ្យសេចក្ដីលោភលន់ ការស្រឡាញ់ភាពឧត្ដុង្គឧត្ដម្ភ ការស្រើបស្រាលសប្បាយរំជើបរំជួលវាចេញចូលបានដោយសេរី ងាយៗ យ៉ាងនេះ?

ឱ ចិត្តរបស់ខ្ញុំ ! ហេតុដូចម្ដេចក៏អ្នកលោតទៅខាងនេះបន្តិច ខាងនោះបន្តិច គ្មានគោលដៅអ្វីឲ្យប្រាកដប្រជាដូច្នេះ? សូមទុកឲ្យខ្ញុំបានឆ្លងសមុទ្រថ្លីនក្អែកគួរឲ្យខ្លាចនេះរួចផង។ មកទល់ពេលនេះ ខ្ញុំបានប្រព្រឹត្តតាមដោយចំណង់របស់អ្នកទាំងអស់ តែឥឡូវនេះ គឺអ្នកឯងនេះហើយដែលត្រូវតែប្រព្រឹត្ត

តាមខ្ញុំម្តងវិញ គឺយើងទាំងអស់គ្នាត្រូវប្រតិបត្តិតាមសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ។

ឱ ចិត្តជាទីស្រឡាញ់របស់ខ្ញុំ ! ភ្នំទាំងនេះ ស្ទឹងទាំងនេះ សមុទ្រទាំងនេះ សុទ្ធតែប្រែប្រួល ហើយជាភពនៃទុក្ខ។ ដូច្នេះនៅក្នុងពិភពថ្លឹងថ្លែងនេះ តើយើងនឹងរកឃើញសេចក្តីសុខស្ងប់នៅកន្លែងណាទៅ ? យើងគួរតែដើរតាមគន្លងធម៌របស់ព្រះពុទ្ធ ហើយឆ្លងទៅត្រើយម្ខាងទៀតដែលជាត្រើយនៃពន្លឺត្រាស់ដឹង !

5. បុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹង ដោយពិតប្រាកដមែនន៎ះ គេតែងតែដាក់កម្រិតបញ្ញាចិត្តរបស់គេជានិច្ច។ ដូច្នេះបុគ្គលទាំងនោះជឿនទៅមុខ ដោយប្តេជ្ញាចិត្តយ៉ាងស្វាហាប់។ ទោះបីគេត្រូវបានអ្នកខ្លះជេរប្រទេច អ្នកខ្លះទៀតប្រមាថមើលងាយក៏ដោយ ក៏គេបេះតែទៅមុខជានិច្ច ដោយមិនរឹករវឡប់ស្មារតី។ ទោះបីនរណាវាយតប់គេ យកដុំថ្មគប់គេឬយកដាវកាប់គេ បណ្តាលឲ្យមានរបួសក៏ដោយ ក៏គេមិនខឹងតបទៅវិញដែរ។

ទោះបីសត្រូវរបស់គេកាត់ក្បាលគេ ក៏ចិត្តរបស់គេមិនត្រូវបានរឹកររដែរ។ បើគេបណ្តោយឲ្យចិត្តរបស់គេឡើងល្អក់ដោយសាររឿងដែលបណ្តាលឲ្យឈឺចាប់ នោះគេមិនតាមសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធទេ។ ទោះបីព្រឹត្តិការណ៍បែបណាមកដល់គេក៏ដោយ គេត្រូវតែប្តេជ្ញាចិត្តឲ្យនៅម៉ឺងម៉ាត់មិនរំភើបញាប់ញ័រ ហើយផ្សព្វផ្សាយនូវចិត្តមានសេចក្តីប្រណីអាសូរនិងមេត្តាធម៌ជានិច្ច។ ទោះបីត្រូវបានទទួលការប្រមាថឬជួបប្រទះនឹងសំណាងអាក្រក់ក៏ដោយ គេត្រូវតែសម្រេចចិត្តមិនតក់ស្លុត តាំងចិត្តឲ្យស្ងប់ គិតតែផ្ចិតយកនូវឱវាទរបស់ព្រះពុទ្ធ។

ក្នុងបំណងឲ្យបានសម្រេចពន្លឺត្រាស់ដឹង អញនឹងខំបំពេញអ្វីៗដែលមិនអាចធ្វើបាន ទ្រាំទ្រនឹងអ្វីៗ ដែលពុំអាចទ្រាំបាន។ អញនឹងបូជាអ្វីៗទាំងអស់ ដែលអញមាន។ បើសិនជាមានគេថា ដើម្បីបានសម្រេចពន្លឺត្រាស់ដឹង អញតោងតែដាក់កំហិតស៊ីបាយតែមួយគ្រាប់ក្នុងមួយថ្ងៃ នោះអញនឹងស៊ីបាយតែមួយគ្រាប់គត់ក្នុងមួយថ្ងៃ។ បើសិនជាផ្លូវទៅកាន់ពន្លឺត្រាស់ដឹងនោះត្រូវឆ្លងកាត់ភ្លើង អញនឹងឆ្លងកាត់ភ្លើងនោះ។

ប៉ុន្តែគេមិនត្រូវធ្វើកិច្ចទាំងនេះ ក្នុងគោលបំណងណាមួយជាខាងក្រោយនោះទេ។ គេត្រូវគិតថា គេធ្វើកិច្ចទាំងនេះ ពីព្រោះវាប្រកបដោយគតិបណ្ឌិតគួរតែធ្វើ ពីព្រោះវាត្រឹមត្រូវល្អគួរតែធ្វើ។ គេត្រូវធ្វើកិច្ចទាំងនេះដោយចិត្តមានមេត្តាធម៌ប្រណីអាសូរ ដូចជាម្ដាយបំពេញកិច្ចទាំងឡាយចំពោះកូននៅតូច ចំពោះកូនដែលមានជំងឺ ដោយគ្មានគិតដល់កម្លាំងនឿយហត់ ឬសុខុមាលភាពរបស់ខ្លួន។

6. កាលមួយនោះ មានព្រះមហាក្សត្រមួយព្រះអង្គ ស្រឡាញ់ប្រជារាស្ត្រ និងប្រទេសជាតិរបស់ព្រះអង្គណាស់។ ព្រះអង្គគ្រប់គ្រងប្រទេសដោយគតិធម៌និងមេត្តាធម៌ជាទីបំផុត នាំឲ្យប្រទេសព្រះអង្គបានសុខសន្តិភាព ចម្រុងចម្រើនជាទីពន្លឹក។ ព្រះអង្គទ្រង់ស្វែងរកគតិបណ្ឌិត និងពន្លឺត្រាស់ដឹងជានិច្ច ព្រះអង្គរហូតដល់ទៅប្រកាសថា នឹងប្រទានរង្វាន់ដល់អ្នកណាដែលដឹកនាំព្រះអង្គទៅកាន់សិក្ខាបទ ដែលអាចឲ្យព្រះអង្គបានសម្រេច។

ភក្តីភាព និងគតិបណ្ឌិតរបស់ព្រះអង្គ ត្រូវបានដឹងដល់

ទៅព្រះឥន្ទ្រ។ ព្រះឥន្ទ្រក៏ចុះមកសាកល្បងព្រះអង្គដោយក្លែងខ្លួនជាបិសាច ប្រាកដឲ្យឃើញឡើងនៅមុខទ្វារប្រាសាទ។ បិសាចនោះសុំឲ្យគេនាំទៅគាល់ស្តេច ពីព្រោះខ្លួនមានសិក្ខាបទដ៏វិសេសបរិសុទ្ធមួយ នឹងទូលព្រះរាជាឲ្យទ្រង់ព្រះសណ្តាប់។

ព្រះរាជាឮដំណឹងនេះ ទ្រង់មានព្រះទ័យត្រេកអរជាពន់ពេក។ ព្រះអង្គទទួលបិសាចយ៉ាងគួរសម ហើយសុំឲ្យបិសាចបង្រៀនសិក្ខាបទនោះដល់ព្រះអង្គ។ បិសាចក៏ប្រែរូបទៅជាអសុរកាយគួរឲ្យខ្លាចជាពន់ពេក ហើយទាមទាររកចំណីអាហារស៊ី ដោយស្រដីថា វាមិនបង្រៀនជាដាច់ខាត ដរាបណាវាមិនបានទទួលចំណីអាហារដែលវាចង់ស៊ី។ ចំណីអាហារយ៉ាងវិសេសវិសាល ត្រូវបានរៀបថ្វាយបិសាច តែបិសាចនៅតែទទូចទារឲ្យគេយកសាច់មនុស្សនៅក្តៅស្រស់ និងឈាមស្រស់មកឲ្យខ្លួនស៊ី។ ព្រះរាជបុត្របម្រុងរាជ្យ រួចហើយព្រះអគ្គមហេសី បានថ្វាយខ្លួនជាបន្តបន្ទាប់ឲ្យបិសាចស៊ី តែបិសាចនៅតែមិនពេញចិត្ត ហើយវាសុំឲ្យស្តេចដាក់ទានអង្គកាយព្រះអង្គឲ្យវាស៊ី។

ព្រះរាជាទ្រង់យល់ព្រមថ្វាយខ្លួនព្រះអង្គឲ្យបិសាចស៊ី តែ

ទ្រង់ទាមទារសុំឲ្យព្រះអង្គអាចបានស្តាប់សិក្ខាបទ ដ៏វិសេសវិសុទ្ធនោះជាមុនសិន។

ពេលនោះ ព្រះឥន្ទ្រទ្រង់ប្រកាសពាក្យប្រកបដោយគតិធម៌ថាៈ «ទុក្ខព្រួយមកពីចំណង់ ការខ្លាចមកពីចំណង់។ បុគ្គលដែលបានកំចាត់ចំណង់ចោលចេញ នឹងលែងមានទុក្ខព្រួយ លែងមានការខ្លាច»។ ជាបន្ទាប់ភ្លាមនោះ ព្រះឥន្ទ្រក៏ប្រែកាឡាមកជារូបពិតវិញ ចំណែកឯព្រះរាជបុត្រ និងព្រះអគ្គមហេសីក៏រស់ឡើងវិញ។

7. កាលមួយនោះ នៅក្នុងព្រៃហិមពាន្ត មានបុរសម្នាក់ស្វែងរកផ្លូវទៅកាន់សេចក្តីពិត។ បុរសនោះមិនរវល់នឹងសម្បត្តិលោកិយ ឬសេចក្តីសប្បាយនៅឋានសួគ៌ ទាល់តែសោះ។ របស់ដែលគេស្វែងរក គឺសិក្ខាបទដែលអាចឲ្យគេបានចាកផុតពីសេចក្តីភាន់វិញ្ញាណ តែមួយមុខប៉ុណ្ណោះ។

ព្រះឥន្ទ្រមានព្រះទ័យរំភើបនឹងការខំសង្វាត យ៉ាងម៉ឺងម៉ាត់ និងស្មោះត្រង់របស់បុរសនោះ ក៏ចុះមកសាកល្បងបុរស។ ទ្រង់កាឡាខ្លួនជាបិសាចមួយ ដើរស្រែកច្រៀងក្នុងព្រៃហិមពាន្ត

ថា: «អ្វីៗទាំងអស់ប្រែប្រួល អ្វីៗទាំងអស់កើតឡើងហើយវិនាសបាត់ទៅវិញ»។

ពេលដែលបុរសស្វែងរកសេចក្ដីពិតឮចម្រៀងនោះ គេសប្បាយជាពន់ពេក។ គេសប្បាយហាក់ដូចជាមនុស្សស្រេកទឹកបានជួបប្រទះនឹងប្រភពទឹកត្រជាក់ ឬហាក់ដូចជាទាសកម្មករបានរួចខ្លួនជាអ្នកជា ដោយមិនដឹងខ្លួនជាមុន។ គេនិយាយតែម្នាក់ឯងថា: «ទីបំផុត អញបានរកឃើញសិក្ខាបទត្រឹមត្រូវពិតប្រាកដ ដែលអញបានខំស្វែងរកជាយូរណាស់មកហើយ!»។ គេដើរតាមសំឡេងចម្រៀងនោះ ហើយទៅដល់កន្លែងដែលបិសាចគួរខ្លាចនោះស្ថិតនៅ។ គេដើរចូលទៅជិតបិសាចដោយអារម្មណ៍មិននឹងន ហើយថ្លែងថា: «តើអ្នកឯងឬដែលច្រៀងចម្រៀងដែលខ្ញុំបានឮអម្បាញ់មិញ? សូមមេត្តាច្រៀងឲ្យខ្ញុំស្ដាប់បន្តិចទៀតមក!»។

បិសាចឆ្លើយថា: «ពិតហើយ គឺយើងនេះហើយ ដែលបានច្រៀងអម្បាញ់មិញនេះ។ តែយើងមិនអាចច្រៀងតទៅទៀតបានទេ បើយើងមិនបានបរិភោគចំណី ព្រោះយើងឃ្លានពេកណាស់!»។

បុរសអង្វរបិសាចហើយអង្វរទៀត សុំឲ្យច្រៀងបន្តទៅទៀត។ គេនិយាយថា:«ចម្រៀងនោះ មានន័យពិសិដ្ឋសម្រាប់ខ្ញុំ។ ខ្ញុំបានខំស្វែងរកសិក្ខាបទរបៀបនេះ អស់កាលជាយូរមកហើយ។ ខ្ញុំបានស្ដាប់ឮតែមួយផ្នែកនៃចម្រៀងសូមមេត្តាឲ្យខ្ញុំបានស្ដាប់ផ្នែកបន្តទៅទៀតផង!»។

បិសាចនិយាយទៀតថា: «យើងឃ្លានណាស់ បើយើងមិនបានស៊ីសាច់និងឈាមមនុស្សទេ យើងនឹងមិនបញ្ចប់ចម្រៀងនេះជាដាច់ខាត»។

បុរសដោយចង់ស្ដាប់សិក្ខាបទនោះជាពន់ពេក ក៏សន្យានឹងបិសាចថា នឹងប្រគល់ខ្លួនឲ្យបិសាចស៊ី ក្រោយពេលបានស្ដាប់សិក្ខាបទចប់ហើយ។ បិសាចក៏ចាប់សូត្របញ្ចប់កំណាព្យ:

«អ្វី ៗ ទាំងអស់ សុទ្ធតែប្រែប្រួល
អ្វី ៗ ទាំងអស់ កើតឡើងហើយវិនាសបាត់ទៅវិញ
គេនឹងបានសុខស្ងប់ពេញលេញឥតខ្ចោះ
កាលណាគេបានហួសផុតពីការកើតនិងការស្លាប់!»

ក្រោយបានស្ដាប់កំណាព្យនេះហើយ បុរសក៏ចារទុកលើផ្ទាំងថ្មនឹងដើមឈើនៅជុំវិញនោះ រួចហើយឡើងដើមឈើ

លោតទម្លាក់ខ្លួនមកប្របនឹងដើងបិសាច។ ភ្លាមនោះ បិសាច វិនាសបាត់រូបទៅ ចេញឯព្រះឥន្ទ្រប្រកបដោយពន្លឺភ្លឺរន្ទាល នៅឈរវង់ទទួលបុរសនោះឲ្យផុតពីគ្រោះថ្នាក់។

8. ក្នុងសម័យមួយនោះ មានបុរសដើរស្វែងរកផ្លូវពិតប្រាកដម្នាក់ឈ្មោះ **សទប្ររុទិត**។ បុរសនោះលះបង់សេចក្ដីប្រាថ្នាចង់បានកម្រៃនិងកិត្តិយសទាំងអស់ គេខំស្វះស្វែងរកផ្លូវទៅកាន់សេចក្ដីពិត ដោយមិនខ្លាចអស់ជីវិត។ ថ្ងៃមួយមានសំឡេងឮចេញពីលើមេឃមកថា: «**សទប្ររុទិត** ! ចូរអ្នកដើរតម្រង់ទៅទិសខាងកើត។ ចូរអ្នកកុំគិតពីភាពក្ដៅ ឬត្រជាក់ឡើយចូរកុំរវល់នឹងការសរសើរ ឬការប្រមាថរបស់មនុស្សឡើយ ចូរកុំខ្វល់នឹងភាពល្អ ឬភាពអាក្រក់ឡើយ ចូរគិតតែពីដើរតម្រង់ទៅទិសខាងកើតបានហើយ។ កាលណាអ្នកទៅដល់ចុងទិសខាងកើត អ្នកនឹងបានជួបនឹងគ្រូអាចារ្យពិតប្រាកដម្នាក់ ហើយអ្នកនឹងបានទទួលពន្លឺត្រាស់ដឹង»។

សទប្ររុទិត ទទួលគោរពតាមបញ្ជាដ៏ជាក់លាក់នោះដោយចិត្តរីករាយជាអនេក។ គេចាប់ចេញដំណើរតម្រង់ទៅ

ទិសខាងកើតភ្លាមមួយរំពេច។ **សទប្បរុទិត** គិតតែពីដើរទៅមុខយប់កន្លែងណាដេកកន្លែងនោះ ជួនកាលដេកនៅក្នុងវាលស្រែស្ងាត់ជ្រងំ ជួនកាលទៀតគេដេកនៅក្នុងព្រៃភ្នំប្រកបដោយគ្រោះថ្នាក់។ ក្នុងភាពជាជនបរទេស សំណាក់នៅក្នុងប្រទេសគេ បុរសនោះ ត្រូវបានទទួលរងនូវការប្រមាថគ្រប់បែបយ៉ាង។ ម្តងនោះ គេបានលក់ខ្លួនគេជាទាសកម្មករ។ ម្តងនោះទៀត ដោយការស្រេកឃ្លានខ្លាំងពេក គេត្រូវបានលក់សាច់របស់គេ។ តែដល់ទីបំផុត គេបានជួបនឹងគ្រូអាចារ្យពិតប្រាកដ ហើយថ្វាយបង្គំសុំរៀនធម៌។

មានភាសិតមួយថា: «វត្ថុដែលល្អវាតែងតែថ្លៃ»។ **សទប្បរុទិត** ឃើញថា រឿងខ្លួនដូចជាភាសិតនេះបេះបិទ ពីព្រោះគេបានជួបប្រទះនឹងការលំបាកវេទនាជាច្រើន នៅក្នុងដំណើរស្វែងរកសេចក្តីពិតរបស់គេ។គេគ្មានប្រាក់ដើម្បីទិញផ្កា ធូបទៀន យកទៅបូជាគ្រូ។ គេខំដើររកស៊ីឈ្នួលគេ តែគ្មាននរណាម្នាក់ត្រូវការគេឡើយ។ ហាក់ដូចជាមានយក្សកំណាចតាមរារាំងគេ គ្រប់ពេលដែលគេប្រាថ្នាធ្វើអ្វីមួយ។ ផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ពិបាកពន់ពេកណាស់ ហើយអាចថ្លៃស្មើនឹង

ជីវិតអ្នកស្វែងរកផ្លូវនោះ។

ជាទីបំផុត **សទប្បរុទិត** បានទៅជាសិស្សរបស់លោកគ្រូអាចារ្យនោះ។ តែនៅពេលនោះ គេត្រូវបានប្រទះនឹងការលំបាកមួយទៀត។ គេគ្មានក្រដាស ដើម្បីកត់ត្រាសេចក្តីប្រៀនប្រដៅរបស់លោកគ្រូ គេគ្មានជក់នឹងទឹកខ្មៅដើម្បីសរសេរ។ គេក៏ចាក់កដៃរបស់គេបង្ហូរយកឈាម ដើម្បីសរសេរ។ គឺតាមរបៀបនេះឯង ដែលគេរកឃើញសេចក្តីពិតដ៏ប្រសើរថ្លៃថ្លា។

9. កាលមួយនោះមានកុមារម្នាក់ឈ្មោះ **សុធន** ជាអ្នកប្រាថ្នាពន្លឺត្រាស់ដឹងម្នាក់ដែរ វាខំស្វែងរកផ្លូវទៅកាន់ពន្លឺពោធិញាណនោះយ៉ាងម៉ឺងម៉ាត់។ ក្មេងនោះ បានរៀនវិជ្ជាផ្នែកសមុទ្រពីអ្នកនេសាទត្រីម្នាក់ រៀនចេះមានចិត្តអាណិតអាសូរចំពោះអ្នកជំងឺដែលឈឺចុកចាប់ ពីលោកគ្រូពេទ្យម្នាក់។ អ្នកមានស្តុកស្តម្ភម្នាក់ពន្យល់វាថា ដោយសារការសន្សំ បានជាគាត់បានឡើងជាអ្នកមាននេះ សូម្បីមួយសេន ក៏គាត់សន្សំទុកដែរ។ ក្មេងនោះក៏បានយល់ថា ដើម្បីទៅកាន់ពន្លឺត្រាស់ដឹង ការមិន

បណ្ដោយឲ្យឱកាសសូម្បីតែបន្តិច បាត់បង់ទៅនោះ ជាការចាំបាច់បំផុត។

ដោយសារព្រះសង្ឃគង់ចម្រើនភាវនាមួយអង្គ ក្មេងនោះបានយល់ថា ចិត្តបរិសុទ្ធស្ងប់មានឥទ្ធិពលអស្ចារ្យអាចធ្វើឲ្យចិត្តអ្នកឯទៀតបានបរិសុទ្ធស្ងប់។ ថ្ងៃមួយ ក្មេងនោះបានជួបនឹងនារីប្រកបដោយសីលធម៌ពិសេសម្នាក់ ហើយវារំភើបជាខ្លាំងចំពោះចិត្តមានសប្បុរសធម៌របស់នារីនោះ។ ដោយសារនារីនោះ វាបានដឹងថា សប្បុរសធម៌ជាផលនៃគតិបណ្ឌិត។ មានម្ដងទៀត តាចាស់អនាថាម្នាក់និយាយប្រាប់វាថា ដើម្បីទៅកាន់ទីកន្លែងណាមួយ គាត់ត្រូវតែវារឡើងភ្នំ ប្រកបដោយចម្រូងដាវលំពែង ហើយឆ្លងកាត់ជ្រលងភ្នំ ដែលមានភ្លើងឆេះពាសពេញ។ ដោយសារការពិសោធន៍ទាំងនេះ **សុធន** បានដឹងថា ការស្វែងរកសិក្ខាបទពិតប្រាកដអាចនឹងបានសម្រេចតាមដោយអ្វីៗ ដែលគេឃើញ និងតាមដោយអ្វីៗ ដែលគេឮ។

សុធនកុមារ រៀនចេះមានសេចក្ដីអំណត់ ពីស្រីពិការ ក្រតោកយ៉ាកម្នាក់ រៀនចេះមានសេចក្ដីសប្បាយជាធម្មតា ដោយ

សារមើលកូនក្មេងតូចៗរត់លេងតាមផ្លូវ។ វាបានដឹងអាថ៌កំបាំងក្នុងការរស់នៅដោយសុខសន្តិភាពជាមួយអ្នកផងទាំងពួង ពីមនុស្សសុភាពរាបសាគួរជាទីស្រឡាញ់រាប់អានដែលមិនចេះគិតចង់បានវត្ថុណាដែលមានអ្នកឯទៀតចង់បានដែរ។

វាបានយល់អំពីភាពសុខដុម ដោយសារមើលទៅផ្សេងធូបហុយព័ទ្ធពេនចូលគ្នា។ វាបានយល់អំពីការដឹងគុណ ដោយសារការក្រេងផ្កា។ ថ្ងៃមួយវាដើរកាត់ព្រៃ ទៅឈប់សម្រាកក្រោមដើមពោធិមួយ។ នៅជិតនោះ វាបានសម្គាល់ឃើញមានកូនរុក្ខជាតិតូចមួយដុះពីលើដើមឈើរលំដួលពុកមួយដើម។ ការបានសង្កេតឃើញនេះ នាំឲ្យវាយល់អំពីភាពមិនទៀងទាត់នៃជីវិត។

ពន្លឺព្រះអាទិត្យនៅពេលថ្ងៃ និងពន្លឺចាំងផ្ទេកៗនៃហ្វូងតារានៅពេលយប់ ធ្វើឲ្យចិត្តរបស់ក្មេងនោះ បាននៅល្អស្រស់ជានិច្ច។ របៀបនេះហើយ ដែលកុមារសុធន បានដកស្រង់យកផលប្រយោជន៍ ពីការពិសោធន៍ទាំងឡាយ ក្នុងដំណើរជីវិតដ៏វែងឆ្ងាយរបស់គេ។

អ្នកស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែគិតថា ចិត្តរបស់ខ្លួនជា

ប្រាសាទវិមាន ដែលគេត្រូវតែតាក់តែងសំអាតលំអ។ គេត្រូវតែបើកមាត់ទ្វារប្រាសាទនៃចិត្តរបស់ខ្លួនឲ្យធំសម្រាប់ព្រះពុទ្ធ ហើយមានចិត្តជ្រះថ្លានិមន្តព្រះអង្គចូលទៅក្នុងមណ្ឌលសំខាន់ខាងក្នុង ដើម្បីថ្វាយទៀនធូបជាតំណាងនៃចិត្តភក្ដីនិងថ្វាយផ្កាជាតំណាងនៃការដឹងគុណ និងសេចក្ដីត្រេកអរចំពោះព្រះអង្គ។

II

វិធីប្រតិបត្តិ

1. ចំពោះអ្នកស្វែងរកពន្លឺត្រាស់ដឹង មានកិច្ចប្រតិបត្តិបីដែលត្រូវតែយល់ ហើយធ្វើតាម គឺៈ ទី១-ការហាត់រៀនឲ្យមានចរិយាល្អ ទី២-ការហាត់រៀនសង្រួមចិត្ត ទី៣-ការហាត់រៀនឲ្យមានគតិបណ្ឌិត។

អ្វីទៅ ដែលហៅថា ការហាត់រៀនឲ្យមានចរិយាល្អ ? មនុស្សលោកទាំងអស់ ទោះបីជាមនុស្សសាមញ្ញក៏ដោយ ឬជាអ្នកស្វែងរកពន្លឺត្រាស់ដឹងក៏ដោយ ត្រូវតែអប់រំខ្លួនឲ្យមាន

ចរិយាល្អ។ គេត្រូវតែពិនិត្យត្រួតត្រាចិត្តរបស់ខ្លួនផងនិងកាយវិការរបស់ខ្លួនផង ហើយត្រូវតែរក្សាការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំរបស់ខ្លួន។ គេត្រូវតែខ្លាចគ្រប់កំហុសទាំងអស់ ទោះបីកំហុសនោះតូចប៉ុនណាក៏ដោយ ហើយត្រូវខំប្រព្រឹត្តតែអំពើល្អ។

អ្វីទៅ ដែលហៅថា ការហាត់រៀនសង្រួមចិត្ត? បានន័យថា គេត្រូវតែបោះបង់ចោលសេចក្តីលោភលន់ និងបំណងអាក្រក់ភ្លាមមួយរំពេច កាលណាការអពមង្គលទាំងនេះ កកើតមានឡើង ហើយខំរក្សាចិត្តរបស់ខ្លួនឲ្យបានបរិសុទ្ធស្ងប់។

អ្វីទៅ ដែលហៅថា គតិបណ្ឌិត ? គឺការយល់ជាក់ច្បាស់ និងទទួលស្គាល់ដោយឥតសង្ស័យ នូវការពិតបំផុតទាំងបួនពោលគឺៈ ទុក្ខ កំណើតនៃទុក្ខ ការបំបាត់ទុក្ខ និងផ្លូវប្រសើរខ្ពង់ខ្ពស់ដែលនាំឲ្យអស់មានទុក្ខ។ បុគ្គលដែលពិតជាប្រតិបត្តិតាមវិន័យទាំងបីនេះ អាចហៅថាជា «សាវ័ករបស់ព្រះពុទ្ធ» មែនពិត។

ឧបមាថា សត្វលាមួយ ដែលគ្មានរូបរាង គ្មានសំឡេង គ្មានស្នែង ដូចមេគោ ដើរតាមហ្វូងមេគោ ហើយស្រដីថាៈ «ចូរ

អ្នកទាំងអស់គ្នាមើល៍ រូបអញនេះជាមេគោ ! » ។ តើមានអ្នកណាជឿសំដីសត្វលានោះទេ? ក៏ជាការឆ្កួតលេលាដូចសត្វលានេះដែរ ចំពោះបុគ្គលណាដែលមិនប្រតិបត្តិតាមវិន័យទាំងបីនេះ ហើយប្រកាសខ្លួនថា ដើរតាមផ្លូវប្រសើរឧត្តម ឬថាខ្លួនជាសាវ័ករបស់ព្រះពុទ្ធ។

មុននឹងបេះយកផលដំណាំបាន ជាដំបូងកសិករតោងតែភ្ជួររាស់ដី សាបព្រោះគ្រាប់ពូជ បញ្ចូលទឹកស្រោចដំណាំ ហើយដកស្មៅចេញ។ យ៉ាងណាមិញ បុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹងត្រូវតែប្រតិបត្តិវិន័យទាំងបីនេះ ដូច្នេះដែរ។ អ្នកស្រែមិនអាចដេកសង្ឃឹមរង់ចាំឃើញពន្លកដុះឡើងក្នុងថ្ងៃនេះ ឃើញកូនដំណាំលូតចេញឡើងក្នុងថ្ងៃស្អែក ហើយបេះយកផលក្នុងថ្ងៃខានស្អែក នោះបានទេ។ យ៉ាងណាមិញ អ្នកដែលស្វែងរកពន្លឺត្រាស់ដឹង ក៏មិនត្រូវដេកចាំឲ្យចំណង់លោកិយបាត់អស់អំពីខ្លួនក្នុងថ្ងៃនេះ ឲ្យសេចក្ដីជំពាក់ចិត្តនឹងបំណងអាក្រក់ទាំងឡាយវិនាសបាត់អស់ពីខ្លួនក្នុងថ្ងៃស្អែក ហើយបានសម្រេចពន្លឺត្រាស់ដឹងក្នុងថ្ងៃខានស្អែក យ៉ាងដូច្នោះដែរ។

ក្រោយពេលសាបព្រោះហើយ កសិករតែងតែថែទាំដំណាំរបស់គេយ៉ាងអំណត់ ពីរដូវមួយទៅរដូវមួយ រហូតដល់មានផ្លែផ្កា។ យ៉ាងណាមិញ អ្នកស្វែងរកពន្លឺត្រាស់ដឹង ក៏ត្រូវតែមានការអំណត់ព្យាយាមបណ្ដុះគ្រាប់ពូជនៃពន្លឺត្រាស់ដឹង ដោយប្រតិបត្តិតាមវិន័យទាំងបីនេះ កុំបីឃ្លៀងឃ្លាតឡើយ។

2. ដើរទៅមុខតាមផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ជាការពិបាកណាស់ដរាបណាគេនៅតែជំពាក់ចិត្តនឹងសុខុមាលភាពហើយ និងប្រណីតភាព ដរាបណាគេបណ្ដោយឲ្យតណ្ហានៃវិញ្ញាណទាំងប្រាំចូលលុកលុយរំខានចិត្តរបស់គេ។ មានសភាពខុសគ្នាស្រឡះរវាងសប្បាយរីករាយក្នុងការរស់នៅ និងសប្បាយរីករាយក្នុងការដើរតាមផ្លូវប្រសើរឧត្តម។

ដូចបានស្ដីមកហើយ ចិត្តជាប្រភពនៃគ្រប់វត្ថុទាំងឡាយ។ បើចិត្ត វាមានចំណូលនឹងរឿងលោកិយ នឹងការថ្លឹនភ្នែកទាំងពួង ទុក្ខវេទនានឹងរត់ដេញតាមជាមិនខាន។ ផ្ទុយទៅវិញ បើចិត្តសប្បាយនឹងដើរតាមផ្លូវប្រសើរឧត្តម សុភមង្គល សេចក្ដី

សប្បាយរីករាយ ហើយនិងពន្លឺត្រាស់ដឹង នឹងរត់តាមជាពិតប្រាកដមិនខាន។

ហេតុនេះ បុគ្គលដែលស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែរក្សាចិត្តរបស់ខ្លួនឲ្យបានបរិសុទ្ធ ហើយខំប្រតិបត្តិវិន័យទាំងបីដោយព្យាយាមអំណត់។ បើគេខំសង្វាតហាត់រៀន គោរពប្រតិបត្តិតាមវិន័យទាំងបីនេះ គេនឹងបានសង្រួមចិត្តជាមិនខាន កាលបើគេបានសង្រួមចិត្តហើយ គេនឹងបានបំភ្លឺដោយគតិធម៌ ហើយគតិធម៌នេះនឹងដឹកនាំគេទៅកាន់ពន្លឺត្រាស់ដឹង។

វត្តប្រតិបត្តិទាំងបីប្រការនេះ ពោលគឺ ការប្រតិបត្តិច្បាប់វិន័យមួយ ការសង្រួមចិត្តមួយ និងការមានគតិធម៌មួយ ជាផ្លូវពិតប្រាកដទៅកាន់ពន្លឺត្រាស់ដឹង ដោយហេតុតែមិនប្រតិបត្តិតាមសិក្ខាបទទាំងបីនេះហើយ ដែលតាំងពីយូរអង្វែងមក ហើយមនុស្សលោកបានគរទុកនូវគំនិតភាន់ច្រឡំជាគំនររាប់មិនអស់។ ដូច្នេះ គេមិនត្រូវជជែករកខុសត្រូវជាមួយនឹងមនុស្សផងគ្នា នៅក្នុងលោកនេះទេ គេត្រូវតែសង្រួមចិត្តខំជញ្ជឹងគិតធ្វើវត្តប្រតិបត្តិយ៉ាងអំណត់ ដើម្បីឲ្យបានសម្រេចពន្លឺត្រាស់ដឹង។

3. បើគេរែកញែកសិក្ខាបទទាំងបីនេះឲ្យបានល្អិតល្អន់ គេនឹងឃើញជាក់ថាសិក្ខាបទទាំងនេះចែកចេញជា ផ្លូវប្រសើរឧត្តម (មគ្គ) ប្រាំបី ទស្សនបទ (សតិបដ្ឋាន) បួន វិធីខំប្រឹងប្រែងដែលត្រឹមត្រូវល្អ (បធាន) បួន ថាមពលដែលត្រូវយកមកប្រើ (ឥន្ទ្រីយ៍) ប្រាំ ហើយនិងគុណធម៌ (បារមី) ប្រាំមួយ។

ផ្លូវប្រសើរឧត្តម (មគ្គ) ប្រាំបីនោះគឺៈ ការមើលឃើញត្រូវ ១ ការគិតត្រូវ១ ពាក្យសំដីត្រូវ១ អំពើត្រូវ១ ការរស់នៅត្រូវ១ ការខំសង្វាតត្រូវ១ ការប៉ងប្រាថ្នាត្រូវ១ និងការសង្រួមចិត្តត្រូវ១ ។

ការមើលឃើញត្រូវ មានបីចំណែកគឺៈ ការយល់ជាក់ច្បាស់នូវសេចក្ដីពិតខ្ពង់ខ្ពស់ (អរិយសច្ចៈ) ទាំងបួន១ ការទទួលស្គាល់នូវច្បាប់ស្ដីអំពីកម្មផល១ ការមិនលុះក្នុងសភាពជាខាងក្រៅនៃវត្ថុហើយ និងក្នុងចំណង់ទាំងឡាយរបស់ខ្លួន១។

ការគិតត្រូវ បានន័យថា សម្រេចចិត្តមិនបម្រើចំណង់របស់ខ្លួន មិនលោភលន់ មិនខឹងក្រោធ មិនប្រព្រឹត្តអំពីអកុសល។

ពាក្យសំដីត្រូវ បានន័យថា ចៀសវាងពាក្យភូតកុហក ពាក្យឥតបានការ ពាក្យជេរប្រមាថ ពាក្យមួលបង្កាច់។

អំពើត្រូវ បានន័យថា មិនត្រូវបំផ្លាញជីវិតគេ មិនត្រូវលួចប្លន់គេ មិនត្រូវប្រព្រឹត្តការផិតក្បត់។

ការរស់នៅត្រូវ បានន័យថា ចៀសវាងការរស់នៅដែលឲ្យទោសដល់អ្នកឯទៀត។

ការខំសង្វាតត្រូវ បានន័យថា ខំយកចិត្តទុកដាក់ធ្វើវត្តប្រតិបត្តិឆ្ពោះទៅរកទិសត្រូវ។

ការប៉ងប្រាថ្នាត្រូវ បានន័យថា ខំប្រុងប្រយ័ត្នរក្សាចិត្តឲ្យបាននៅបរិសុទ្ធជានិច្ច។

ការសង្រួមចិត្តត្រូវ បានន័យថា ខំរក្សាចិត្តឲ្យបាននៅត្រឹមត្រង់ស្ងប់ ដើម្បីឲ្យបានសម្រេចការត្រាស់ដឹង។

4. ទស្សនបទ (សតិបដ្ឋាន) បួននោះគឺៈ ទី១ គិតពិចារណាថា រូបកាយប្រកបដោយវត្ថុមិនបរិសុទ្ធ មិនត្រូវជំពាក់ចិត្តនឹងរូបកាយនេះទេ។ ទី២ គិតពិចារណាថា វិញ្ញាណារម្មណ៍ទាំងឡាយជាប្រភពនៃទុក្ខ ទោះបីវាមកជាអារម្មណ៍ព្រួយ ឬជាអារម្មណ៍សប្បាយក៏ដោយ។ ទី៣ គិតពិចារណាថា ចិត្តជាចរន្តដែលហូរមិនចេះឈប់។ ទី៤ គិតពិចារណាថា អ្វីៗទាំងអស់នៅក្នុងលោកនេះ សុទ្ធតែជាលទ្ធផលនៃការទាក់ទងរវាង

ហេតុនិងផល ហើយគ្មានអ្វីដែលអាចនៅគង់វង្សរហូត ដោយមិនប្រែប្រួលនោះទេ។

5. វិធីខំប្រឹងប្រែងដែលត្រឹមត្រូវល្អ (សម្មប្បធាន) ទាំងបួននោះគឺៈ ខំការពារកុំឲ្យអំពើអាក្រក់កើតឡើងបាន១ កាលណាអំពើអាក្រក់កើតឡើងហើយ ត្រូវកំចាត់វាចោលភ្លាម១ ខំបង្កើតអំពើល្អ១ ខំធ្វើឲ្យអំពើល្អបានលូតលាស់នៅពេលវាកើតឡើងហើយ១។

6. ថាមពលដែលត្រូវយកមកប្រើ (ឥន្ទ្រីយ៍) ទាំងប្រាំនោះ គឺៈ ជំនឿជ្រះថ្លា១ ការមានចេតនានឹងធ្វើការខំប្រឹងប្រែង១ ស្មារតីប្រុងប្រយ័ត្ន១ សមត្ថភាពក្នុងការសង្រួមចិត្ត១ សមត្ថភាពក្នុងការរក្សាគតិធម៌ភ្លឺថ្លា១។

7. គុណធម៌ខ្ពង់ខ្ពស់បំផុត (បារមី) ទាំងប្រាំមួយ ដែលជាយាននាំយើងទៅដាក់ដល់ត្រើយនៃពន្លឺត្រាស់ដឹងនោះគឺៈ ទាន១ ការគោរពប្រតិបត្តិច្បាប់វិន័យ (សីល)១ ការមានសេចក្តីអំណត់ (ខន្តី) ១ ការខំប្រឹងប្រែងសង្វាត (វីរិយៈ) ១ ការសង្រួមចិត្ត

(ឈាន) ១ ការមានគតិបណ្ឌិត (បញ្ញា) ១។ បើគេដើរតាមផ្លូវប្រសើរទាំងប្រាំមួយនេះ គេប្រាកដជាអាចឆ្លងរួចផុតពីត្រើយដែលពោរពេញទៅដោយការថ្លើនភ្នែក ហើយបានទៅដល់ត្រើយពន្លឺត្រាស់ដឹងជាពុំខាន។

ការធ្វើទាន នាំឲ្យចាកផុតពីអត្តទត្តភាព។ ការគោរពប្រតិបត្តិច្បាប់វិន័យ នាំឲ្យចេះយកចិត្តទុកដាក់ចំពោះសិទ្ធិ និងសុខុមាលភាពរបស់អ្នកដទៃ។ ការមានសេចក្តីអំណត់ នាំឲ្យចេះបង្ក្រាបការខ្លាច និងសេចក្តីខឹងក្រោធ។ ការសង្វាតប្រឹងប្រែង នាំឲ្យមានសេចក្តីវៀសវៃ និងសេចក្តីទៀងត្រង់។ ការសង្រួមចិត្ត នាំឲ្យចេះត្រួតត្រាចិត្តដែលវង្វេងវង្វាន់សាវា។ ការមានគតិបណ្ឌិត បណ្តាលឲ្យសតិងងឹតងងល់ច្របូកច្របល់បានទៅជាសតិភ្លឺថ្លា ឈ្លាសវៃ។

ទាន និងច្បាប់វិន័យ ជាគ្រឹះសំខាន់ជាចាំបាច់ក្នុងការសង់វិមានប្រាសាទ។ សេចក្តីអំណត់ និងសេចក្តីសង្វាតប្រឹងប្រែង ជាកំពែងការពារប្រាសាទ កុំឲ្យសត្រូវមកពីក្រៅចូលបាន។ ការសង្រួមចិត្ត និងការមានគតិបណ្ឌិត ជាគ្រោះសម្រាប់ការពារការវាយលុកនៃការរស់នៅនិងការស្លាប់។

បើគេធ្វើទាន តែក្នុងពេលណា ឃើញប្រយោជន៍ត្រឡប់មកវិញ ឬដោយសារតែធ្វើវាស្រួល ជាជាងមិនធ្វើ ជាពិតប្រាកដណាស់ ទាននោះ ពុំមែនជាទានពិតប្រាកដទេ។ ទានពិតប្រាកដ គឺទានដែលគេធ្វើប្រកបដោយចិត្តជ្រះថ្លា។ម្យ៉ាងទៀត ទានពិតប្រាកដ ត្រូវធ្វើឡើង ពុំមែនតែម្តងទេ គឺត្រូវធ្វើជានិច្ចកាល។

ក៏ពុំមែនជាទានពិតប្រាកដដែរ បើកាលណាគេធ្វើដោយមានចិត្តស្តាយ ឬដោយប្រាថ្នាចង់បានការអួតសរសើរ ទានពិតប្រាកដ គឺទាន ដែលធ្វើឡើងដោយចិត្តរីករាយ គ្មានគិតថាខ្លួនជាអ្នកឲ្យមិនរំលឹកឡើងវិញអំពីអ្នកទទួល ហើយមិនគិតដល់វត្ថុដែលបានឲ្យជាទាន។

ទានពិតប្រាកដ ចេញមកដោយឯកឯងពីចិត្តមានមេត្តាធម៌ គ្មានទឹកសង្ឃឹមចង់បានមកវិញ ប៉ុន្តែដោយប្រាថ្នាឲ្យបានចូលទៅក្នុងគន្លងផ្លូវនៃពន្លឺត្រាស់ដឹងទាំងអស់គ្នា។

ទានទាំងប្រាំពីរយ៉ាង ដែលសូម្បីតែអ្នកក្រខ្សត់ទ្រព្យសម្បត្តិ ក៏អាចធ្វើបានដែរ។ ទានទី១ គឺការធ្វើទានរូប

កាយ។ ទានក្នុងប្រភេទនេះ គឺយកកម្លាំងកាយធ្វើជាទាន ហើយខ្ពង់ខ្ពស់បំផុតទៅទៀត គឺបូជាជីវិតសម្រាប់ជាទាន ដូចជាមានរឿងនិទានក្នុងវគ្គតទៅនេះ។ ទានទី២ គឺការធ្វើទានចិត្ត គឺផ្តល់នូវចិត្តមានមេត្តាធម៌ ចំពោះអ្នកឯទៀត។ ទានទី៣ គឺការធ្វើទានចក្ខុ គឺផ្តល់នូវខ្សែភ្នែកត្រជាក់ ស្រទន់ ដែលជាសញ្ញានៃសេចក្តីសុខស្ងប់សម្រាប់អ្នកឯទៀត។ ទានទី៤ គឺការធ្វើទានទឹកមុខ គឺបញ្ចេញទឹកមុខរីករាយ ស្រទន់ ចំពោះអ្នកឯទៀត។ ទានទី៥ គឺការធ្វើទានពាក្យសំដី គឺមានវាចាពាក់ទាក់ ផ្អែមត្រជាក់ ចំពោះអ្នកឯទៀត។ ទានទី៦ គឺការធ្វើទានកន្លែងអង្គុយ គឺឲ្យកន្លែងអង្គុយទៅអ្នកឯទៀត។ ទានទី៧ គឺការធ្វើទានទីជម្រក គឺឲ្យអ្នកឯទៀតឈប់សំណាក់ក្នុងទីលំនៅរបស់ខ្លួនមួយយប់។ ទានទាំងប្រាំពីរប្រភេទនេះ នរណាក៏អាចធ្វើបានដែរ។

8. សម័យមួយនោះ មានព្រះរាជាមួយព្រះអង្គ ព្រះនាម **សត្វៈ**។ ថ្ងៃមួយ ព្រះសត្វៈយាងទៅប្រពាតព្រៃ ជាមួយនឹង

ព្រះរាមរបស់ព្រះអង្គពីរព្រះអង្គ។ នៅក្នុងព្រៃ ក្សត្របងប្អូនទាំងបីព្រះអង្គបានឃើញមេខ្លាមួយ ដោយឃ្លានពេកបម្រុងនឹងហែកកូនរបស់ខ្លួនទាំងប្រាំពីរស៊ី ដើម្បីសម្រន់ការអត់ឃ្លាន។

ព្រះរាមច្បងទាំងពីរ ភ័យជាខ្លាំង ហើយរត់បាត់ទៅ។ ចំណែក **ព្រះសត្វៈ** ព្រះអង្គទ្រង់ឡើងទៅលើចំណោតខ្ពស់មួយ ហើយលោតទម្លាក់ខ្លួនមកឲ្យមេខ្លាស៊ីជាចំណី ដើម្បីសង្គ្រោះកូនខ្លាទាំងប្រាំពីរ។

ព្រះសត្វៈ ទ្រង់ធ្វើអំពើសប្បុរសនេះ ដោយចិត្តមេត្តាដែលចេញមកដោយឯកឯង។ ប៉ុន្តែព្រះអង្គបានគិតក្នុងចិត្តថាៈ «រូបកាយនេះ វាប្រែប្រួល វាមិនឋិតថេរទេ។ អញស្រឡាញ់ថ្នាក់ថ្នមរូបកាយនេះ ដោយឥតមានចិត្ត ចង់បោះបង់វាចោលទេ ប៉ុន្តែនៅពេលនេះ អញដាក់ទានទៅឲ្យមេខ្លា ក្នុងបំណងឲ្យបានសម្រេចពន្លឺត្រាស់ដឹង»។ ការជញ្ជឹងគិតនេះ បង្ហាញឲ្យឃើញថា បំណងពិតប្រាកដរបស់**ព្រះសត្វៈ** គឺការបានសម្រេចពន្លឺត្រាស់ដឹង។

9. មានសភាពចិត្តធំធេងឥតព្រំដែនបួនយ៉ាង ដែលអ្នកស្វែងរកពន្លឺត្រាស់ដឹង ត្រូវតែបណ្ដុះបណ្ដាលគឺៈ ចិត្តមិនប្រាថ្នាប្រយោជន៍ ចិត្តមានមេត្តាអាសូរ ចិត្តជ្រះថ្លា និងចិត្តប្រកបដោយសមភាព។ គេអាចបំបាត់ចំណង់ ដោយសារចិត្តមិនប្រាថ្នាប្រយោជន៍។ គេអាចបំបាត់កំហឹង ដោយសារចិត្តមានមេត្តាអាសូរ។ គេអាចបំបាត់ទុក្ខ ដោយសារចិត្តជ្រះថ្លា។ គេអាចបំបាត់គំនិតវែកញែករវាងមិត្តនឹងសត្រូវ ដោយសារបណ្ដុះចិត្តប្រកបដោយសមភាព។

ការមិនប្រាថ្នាប្រយោជន៍ បានន័យថា ធ្វើឲ្យអ្នកផងទាំងពួងបានសុខសប្បាយ បានពេញចិត្ត។ ការមានមេត្តាអាសូរ បានន័យថា បំបាត់ចោលអ្វីៗ ដែលបណ្ដាលឲ្យអ្នកផងទាំងពួងមិនបានសុខសប្បាយ មិនបានពេញចិត្ត។ ការមានចិត្តជ្រះថ្លា បានន័យថា រីករាយសប្បាយនឹងឃើញបុគ្គលណាម្នាក់បានសុខសប្បាយ បានពេញចិត្ត។ ការមានចិត្តជាសមភាព បានន័យថា មានមនោសញ្ចេតនាចំពោះសត្វលោកទាំងអស់ ដោយស្មើភាពគ្នា គឺប្រាថ្នាចង់ឲ្យបុគ្គលរាល់រូបបានសុខសប្បាយ បានពេញចិត្ត។

ត្រូវតែផ្ចឹតផ្ចង់បណ្តុះបណ្តាលសភាពចិត្តជំផេង ឥតព្រំដែនទាំងបួននេះ ហើយត្រូវតែកំចាត់ចោលសេចក្តីលោភ ការខឹងក្រោធ ការព្រួយបារម្ភ និងការរែកញែករវាងមិត្តនឹងសត្រូវ។ ប៉ុន្តែកិច្ចទាំងនេះមិនមែនស្រួលនឹងធ្វើទេ។ ការកំចាត់ចោលនូវសភាពចិត្តអាក្រក់ ជាការពិបាក តែការកំចាត់ចោលនូវសភាពចិត្តល្អ ជាការងាយស្រួល។ ការកំចាត់ចោលនូវសភាពចិត្តអាក្រក់ វាពិបាកដូចជាការលុបបំបាត់អក្សរដែលឆ្លាក់ជាប់នៅលើផ្ទាំងថ្ម។ ប៉ុន្តែ ការបំបាត់ចោលនូវសភាពចិត្តល្អ វាងាយដូចជាលុបអក្សរដែលសរសេរទុកលើផ្ទៃទឹក។ ប៉ុន្តែនៅក្នុងជីវិតនេះ មានកិច្ចមួយពិបាកជាទីបំផុត ជាងនេះទៅទៀត គឺការព្យាយាមហាត់រៀន ដើម្បីបានសម្រេចពន្លឺត្រាស់ដឹង។

10. មានបុរសម្នាក់ឈ្មោះ ***សោណៈ*** កើតក្នុងត្រកូលអ្នកមានតែសុខភាពរបស់គាត់ខ្សោយជាពន់ពេកណាស់។ ដោយគាត់ប្រាថ្នាយ៉ាងមុតមាំចង់បានសម្រេចពន្លឺត្រាស់ដឹង គាត់ក៏បានទៅជាសិស្សម្នាក់របស់ព្រះពុទ្ធ។ គាត់បានបំពេញការខំព្យាយាម

យ៉ាងតឹងតែងជាទីបំផុត រហូតដល់ឈាមហូរចេញពីបាតជើង តែគាត់មិនបានសម្រេចពន្លឺត្រាស់ដឹងសោះ។

ព្រះបរមគ្រូ មានចិត្តអាណិតគាត់ជាខ្លាំង ព្រះអង្គក៏មានពុទ្ធដីកាទៅកាន់គាត់ថា: «ម្នាល**សោណៈ**ជាកូន ! កាលឯងនៅផ្ទះ ឯងដែលបានហាត់រៀនលេងពិណាឬទេ? ឯងដឹងឬទេថា ពិណាមិនអាចបញ្ចេញសំឡេងពីរោះបានទេ បើកាលណាខ្សែពិណានោះតឹងពេក ឬធូរពេក។ ពិណាអាចប្រគំជាតន្ត្រីពីរោះបាន លុះណាតែគេរឹតខ្សែពិណានោះតឹងល្មម»។

«ការព្យាយាមដើម្បីបានសម្រេចពន្លឺត្រាស់ដឹង ក៏ដូចជាខ្សែពិណាដែលគេរឹតតឹងល្មមនោះដែរ។ ឯងមិនអាចបានសម្រេចពន្លឺត្រាស់ដឹងទេ បើកាលណាហើយខ្សែចិត្តរបស់ឯង វាធូរពេកឬតឹងពេក។ ដូច្នេះ ឯងត្រូវតែគិតពិចារណាឲ្យបានហ្មត់ហ្មង ហើយព្យាយាមប្រតិបត្តិដោយគតិបណ្ឌិត»។

សោណៈ បានយល់ថាពាក្យទូន្មានទាំងនេះសំខាន់ណាស់ ក៏ប្រព្រឹត្តតាម ហើយទីបំផុតគេក៏បានទទួលវត្ថុ ដែលគេស្វែងរក គឺពន្លឺត្រាស់ដឹង។

11. ក្នុងសម័យមួយនោះ មានស្តេចមួយព្រះអង្គ ស្ទាត់ជំនាញក្នុងការកាន់អាវុធណាស់។ ថ្ងៃមួយ នៅពេលត្រឡប់មកពីទីលានហាត់ហ្វឹកហ្វឺនមកដំណាក់វិញ ព្រះអង្គបានជួបនឹងយក្សមួយ មានសាច់គង់កាប់មិនមុត។

យក្សនោះ ឈរស្តឹងនៅមុខព្រះអង្គ តែស្តេចគ្មានខ្លាចញញើតសោះ។ ស្តេចបាញ់ព្រួញមួយទៅ តែមិនមុតយក្សសោះ។ ស្តេចចោលលំពែងទៅទៀត តែមិនអាចមុតធ្លុះស្បែកយក្សបានឡើយ។ ស្តេចចោលច្បូក ចោលស្នរជាបន្តបន្ទាប់ទៅទៀត តែយក្សគ្មានឈឺស្កៀបបន្តិចឡើយ។ ស្តេចក៏គ្រវីដាវលោតទៅកាប់យក្ស តែដាវនោះ ត្រូវបាក់ទៅទៀត។ ស្តេចក៏វាយប្រហារយក្សនោះ ដោយប្រើដៃជើងព្រះអង្គ តែគ្មានលទ្ធភាពសោះ ព្រោះយក្សនោះចាប់ឱបរឹតព្រះអង្គយ៉ាងមាំនៅក្នុងរង្វង់ដៃដ៏ធំរបស់វា។ ស្តេចសាកល្បងយកព្រះកេសាព្រះអង្គប្រយុទ្ធតទល់ទៀត តែជាអសារឥតការ។

យក្សថ្លែងថា: «តស៊ូឥតប្រយោជន៍ទេ យើងនឹងហែកឯងស៊ីឥឡូវនេះហើយ»។ ស្តេចឆ្លើយឡើងថា: «ឯងស្មានថាយើងអស់អាវុធ នឹងប្រើប្រាស់តែប៉ុណ្ណោះហើយឬ? យើងគ្មាន

អ្វីនឹងការពារខ្លួនទៀតទេឬ ? តាមពិត យើងនៅមានអាវុធមួយទៀត។ បើហែកយើងស៊ី យើងនឹងបានចូលទៅខ្វះបំផ្លាញក្រពះពោះវៀនឯងជាពុំខាន»។

សេចក្ដីក្លាហានរបស់ស្ដេច បានធ្វើឲ្យយក្ស ភ័យជាខ្លាំង ។ យក្សសួរថា: «តើឯងធ្វើរបៀបម៉េច?»។ ស្ដេចឆ្លើយថា: «យើងយកឥទ្ធិពលនៃសេចក្ដីពិតមកប្រើ»។

យក្សក៏លែងស្ដេចទៅ ហើយអង្វរសុំឲ្យបង្រៀនសេចក្ដីពិតនោះ។

រឿងនិទាននេះ ប្រដៅអ្នកបួសរៀនទាំងឡាយ ឲ្យមានចិត្តក្លាហាន មានការព្យាយាមខំប្រឹងប្រែង កុំខ្លាចញញើតឧបសគ្គជាច្រើនរាប់មិនអស់ ដែលកើតមានឡើងនៅចំពោះមុខ។

12. ការឡើតគួរឲ្យស្អប់ និងការឥតអៀនខ្មាស ជាទោសចំពោះមនុស្សលោក។ ប៉ុន្ដែការអាប់យស និងការខ្មាសអៀន ការពារមនុស្សលោក។ បុគ្គលទាំងឡាយគោរពមាតាបិតារបស់គេ

រៀមច្បងរបស់គេ បងស្រីប្រុសរបស់គេព្រោះតែគេចាប់អារម្មណ៍នឹងសេចក្ដីអាប់យស ហើយនិងសេចក្ដីអៀនខ្មាស។ កាលណាគេសញ្ជឹងគិតឲ្យដឹតដល់ទៅ ឃើញថា ការទុកកិត្តិយសឲ្យឆ្ងាយពីខ្លួន ហើយនិងការចេះមានចិត្តអៀនខ្មាសដោយសង្កេតមើលទៅអ្នកដទៃ ជាការសមនឹងបានគុណប្រយោជន៍ជាប្រត្យក្ស។

បើបុគ្គលណាមានចិត្តចេះស្ដាយក្រោយ បាបកម្មទាំងឡាយរបស់បុគ្គលនោះនឹងវិនាសអស់។ ប៉ុន្តែ បើបុគ្គលនោះមានចិត្តមិនចេះស្ដាយក្រោយ បាបកម្មទាំងឡាយរបស់គេ ស្ថិតនៅជាប់នឹងរូបគេរហូត ហើយនឹងតាមផ្ដន្ទាទោសគេមិនចេះចប់។

មានតែបុគ្គលដែលស្ដាប់ឮ យល់ជាក់ ហើយប្រតិបត្តិតាមសិក្ខាបទពិតប្រាកដនុ៎ះទេ ដែលអាចបានទទួលគុណប្រ-យោជន៍អំពី សិក្ខាបទនោះ។ បើបុគ្គលណាបានស្ដាប់ឮសិក្ខាបទពិតប្រាកដនេះហើយ តែមិនប្រតិបត្តិតាម បុគ្គលនោះមុខតែមិនបានសម្រេចក្នុងការស្វែងរកពន្លឺត្រាស់ដឹងទេ។

ការជឿឈ្មោះថា ការគោរពប្រតិបត្តិ ការចេះស្ដាយក្រោយ ការខំប្រឹងប្រែង និងការមានគតិបណ្ឌិត ជាមហាប្រភពនៃ

កម្លាំងសម្រាប់ស្វែងរកពន្លឺត្រាស់ដឹង។ ក្នុងចំណោមគុណ-សម្បត្តិទាំងនេះ ការមានគតិបណ្ឌិតសំខាន់ជាងគេបង្អស់។ ចំពោះគុណសម្បត្តិឯទៀត វាជាទិដ្ឋភាពនៃការប្រកបដោយគតិបណ្ឌិតប៉ុណ្ណោះ។ បុគ្គលណាដែលកំពុងតែបំពេញការព្យាយាម ហើយត្រេកត្រអាលនឹងរឿងលោកិយ សប្បាយនឹងការជជែកគ្នាឥតខ្លឹមសារ បណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុងភាពងោកងុយស្មុរគំនិត បុគ្គលនោះនឹងឃ្លាតចាកឆ្ងាយពីផ្លូវនៃពន្លឺត្រាស់ដឹង។

13. ក្នុងការព្យាយាមដើម្បីបានសម្រេចពន្លឺត្រាស់ដឹង មានអ្នកខ្លះអាចទៅដល់គោលដៅឆាប់រហ័សជាងអ្នកខ្លះទៀត។ ដូច្នេះមិនត្រូវអស់សង្ឃឹមទេ បើកាលណាហើយ ឃើញគេឯងទៀតបានសម្រេចពន្លឺត្រាស់ដឹងមុនយើង។

អ្នករៀនបាញ់ធ្នូ មិនអាចសង្ឃឹមថានឹងបានសម្រេចភ្លាមៗនោះទេ តែគេដឹងថា បើគេហាត់រៀន ដោយព្យាយាមខ្ជាប់ខ្ជួន គេនឹងបានស្ទាត់ជំនាញច្រើនឡើងៗ ជាពុំខាន។ ទន្លេចាប់កកើតមុនដំបូងជាអូរតូចមួយ ហើយរីកធំឡើងៗ រហូតដល់

ទៅជាទន្លេហូរចាក់ទៅក្នុងសមុទ្រ។ ឧទាហរណ៍ទាំងនេះ បង្ហាញឲ្យឃើញថា បើបុគ្គលណាបំពេញការព្យាយាមយ៉ាង អំណត់និងខ្ជាប់ខ្ជួន បុគ្គលនោះប្រាកដជានឹងបានសម្រេចពន្លឺ ត្រាស់ដឹង។

ដូចបានពន្យល់ពីលើមកហើយ បើគេបើកភ្នែកមើល គេ នឹងឃើញសិក្ខាបទនៅគ្រប់ទិសទី។ ដូច្នេះ គេមានផ្លូវច្រើន នឹងបានសម្រេចពន្លឺត្រាស់ដឹង។

សម័យមួយនោះ មានបុរសម្នាក់ដុតធូប ហើយបានសង្កេត ឃើញក្លិនក្រអូប ទៅក៏មិនទៅ មកក៏មិនមក លេចឡើងក៏មិន លេច បាត់ទៅក៏មិនបាត់។ ដោយសារការរាយរងនេះ បុរស នោះបានសម្រេចពន្លឺត្រាស់ដឹង។

មានម្តងនោះ បុរសម្នាក់មុតបន្លានៅបាតជើង។ គាត់ឈឺ ចុកចាប់ជាខ្លាំង ហើយនឹកគិតថា ការឈឺចុកចាប់នេះគ្មានអ្វី ក្រៅពីប្រតិកម្មនៃចិត្តទេ។ ក្រោយពីនោះមក គាត់បានគិត ឃើញថា ចិត្តវារត់លោតគ្មានចេះឈប់ឈរទេ បើកាលណា គេមិនគ្រប់គ្រងវា។ ប៉ុន្តែវាក៏អាចទៅជាបរិសុទ្ធបានដែរ បើ

កាលណាគេត្រួតត្រាវាបាន។ ដោយសារការគិតយល់នេះ បន្តិចក្រោយមក បុរសនោះក៏បានសម្រេចពន្លឺត្រាស់ដឹង។

មានបុរសម្នាក់ទៀត កំណាញ់ស្វិតជាទីបំផុត។ ថ្ងៃមួយ នៅពេលដែលគាត់កំពុងតែគិតទៅដល់ចិត្តលោភលន់ របស់គាត់ គំនិតមួយបានមកដល់គាត់ថា ចំណង់លោភលន់របស់អញនេះគ្មានអ្វីក្រៅពីចំនៀរឈើ និងមែកឈើតូចៗ ដែលគតិបណ្ឌិតអាចដុតបំផ្លាញបាននោះទេ។ ការគិតយល់នេះជាការចាប់ផ្ដើមបានសម្រេចពន្លឺត្រាស់ដឹងរបស់គាត់។

មានពាក្យប្រៀនប្រដៅពីបូរាណកាលមួយថ្ងៃថា: «ចូររក្សាចិត្តឲ្យបានរាបស្មើ! បើចិត្តបានរាបស្មើហើយ ពិភពលោកទាំងមូលនឹងបានរាបស្មើដែរ!។ ចូរយើងគិតពិចារណាចំពោះពាក្យប្រៀនប្រដៅនេះ ! ចូរយើងយល់ថា ភាពខុសគ្នាក្នុងពិភពលោកនេះ បណ្ដាលមកពីចិត្តគិតវែកញែកតែប៉ុណ្ណោះ។ ផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ស្របទាំងស្រុងនឹងពាក្យប្រៀនប្រដៅនេះ។ ផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ពិតជាគ្មានព្រំដែនទេ!។

III

ផ្លូវនៃជំនឿ (សទ្ធា)

1. *ដែលហៅថាសាវ័ករបស់ព្រះពុទ្ធ គឺបុគ្គលដែលប្រគល់កាយថ្វាយជីវិតចំពោះព្រះរតនត្រ័យ ពោលគឺការទទួលយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទុកជាទីពឹងទីរលឹក។ សាវ័ករបស់ព្រះពុទ្ធ កាន់វិន័យគ្រប់គ្រងចិត្ត ទាំងបួន គឺៈ សិក្ខាបទ សទ្ធាទាន និង គតិបណ្ឌិត។*

សាវ័ករបស់ព្រះពុទ្ធ គោរពប្រតិបត្តិវិន័យប្រាំយ៉ាងគឺៈ មិនសម្លាប់សត្វ មិនលួចប្លន់ មិនប្រព្រឹត្តអំពើផិតក្បត់ មិនភូតកុហក មិនសេពគ្រឿងស្រវឹង។

សាវ័ករបស់ព្រះពុទ្ធ មានជំនឿយ៉ាងមាំទៅលើគតិធម៌ល្អឥតខ្ចោះរបស់ព្រះពុទ្ធ។ គេខិតខំចៀសវាងការលោភលន់ការខឹងក្រោធ ហើយខិតខំធ្វើទាន។ គេយល់ច្បាស់នូវច្បាប់ស្ដីអំពីហេតុនិងផល ដោយគិតទុកក្នុងចិត្តជានិច្ចអំពីភាពមិនឋិតថេរនៃជីវិត ហើយគេប្រតិបត្តិតាមច្បាប់គតិធម៌។

ដើមឈើដែលទ្រេតទៅទិសខាងកើត នឹងរលំដួលទៅទិសខាងកើត ជាធម្មតា។ ដូចគ្នានេះ បុគ្គលដែលស្ដាប់ហើយធ្វើតាមឱវាទរបស់ព្រះពុទ្ធ ហើយជឿប្រាកដលើព្រះអង្គ ពិតជានឹងបានទៅកើតក្នុងដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ។

2. ដូចបានពោលយ៉ាងជាក់ច្បាស់មកហើយថា បុគ្គលណាជឿហើយប្រតិបត្តិតាមរតនៈទាំងបីរបស់ព្រះពុទ្ធ ពោលគឺៈ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បុគ្គលនោះហៅថា សាវ័ករបស់ព្រះពុទ្ធ។

ព្រះពុទ្ធគឺមនុស្សលោកមួយរូប ដែលបានសម្រេចនូវការត្រាស់ដឹងដ៏ប្រសើរបំផុត ហើយយកការត្រាស់ដឹងនោះមកប្រើ ដើម្បីស្រោចស្រង់សត្វលោក។ ព្រះធម៌គឺសេចក្ដីពិត គឺព្រលឹងនៃការត្រាស់ដឹង ហើយនិងសិក្ខាបទដែលពន្យល់បញ្ជាក់អំពីការត្រាស់ដឹងនោះ។ ព្រះសង្ឃ គឺក្រុមអ្នកទ្រទ្រង់ភេទជាបព្វជិត ជឿ និងប្រតិបត្តិតាម ព្រះពុទ្ធ ព្រះធម៌ ដោយចិត្តស្មោះត្រង់សុទ្ធសាធ។

យើងនិយាយអំពី ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហាក់ដូចជាវត្ថុទាំងបីនេះផ្សេងៗគ្នា តែតាមពិត គឺជាវត្ថុតែមួយគត់។ ព្រះពុទ្ធចេញស្តែងឡើងនៅក្នុងព្រះធម៌ ព្រះធម៌សម្តែងឡើងដោយសហគមន៍ព្រះសង្ឃ។ ដូច្នេះ ការជឿតាមព្រះធម៌ ហើយគោរពប្រតិបត្តិព្រះសង្ឃ ដូចគ្នានឹងការមានជំនឿមោះមុតទៅលើព្រះពុទ្ធដែរ។ បើនិយាយបែបម្យ៉ាងទៀត ការមានជំនឿមោះមុតទៅលើព្រះពុទ្ធ បានន័យថា ជឿតាមព្រះធម៌ហើយគោរពប្រតិបត្តិព្រះសង្ឃ។

ដូច្នេះឃើញថា បុគ្គលរាល់រូបអាចចាកផុតពីទុក្ខ ហើយបានសម្រេចពន្លឺត្រាស់ដឹង ដោយគ្រាន់តែមានជំនឿមោះមុតទៅលើព្រះពុទ្ធ។ ព្រះពុទ្ធជាអ្នកបានត្រាស់ដឹងគ្រប់ ព្រះអង្គស្រឡាញ់គ្រប់សត្វលោកទាំងអស់ ដូចជាកូនបង្កើតរបស់ព្រះអង្គ។ បុគ្គលណាទុកព្រះពុទ្ធជាឪពុកបង្កើតរបស់ខ្លួន បុគ្គលនោះជាកូនបង្កើតម្នាក់របស់ព្រះពុទ្ធ ហើយនឹងបានសម្រេចពន្លឺត្រាស់ដឹង។

បុគ្គលដែលទុកព្រះពុទ្ធដូចខាងលើនេះ នឹងត្រូវបានគាំទ្រដោយគតិធម៌របស់ព្រះអង្គ ហើយនឹងត្រូវបានប្រោះព្រំដោយគន្ធពិដោរនៃធម៌មេត្តារបស់ព្រះអង្គ។

3. នៅក្នុងលោកនេះគ្មានអ្វីដែលអាចនាំមកនូវគុណប្រយោជន៍ឲ្យបានធំធេងជាងការមានជំនឿលើព្រះពុទ្ធទេ។ ការបានឮព្រះនាមព្រះពុទ្ធ ហើយមានចិត្តសប្បាយរីករាយ ជឿតាមព្រះអង្គតែក្នុងមួយរយៈវេលាប៉ុណ្ណោះ ជាការបានរង្វាន់ធំឥតឧបមា។

ដូច្នេះ បុគ្គលរាល់រូបត្រូវតែសប្បាយរីករាយក្នុងការខំស្វែងរកសិក្ខាបទរបស់ព្រះពុទ្ធ ទោះជាត្រូវឆ្លងកាត់ភ្លើងដែលកំពុងតែឆេះយ៉ាងសន្ធោសន្ធៅក៏ដោយ។

ការបានជួបប្រទះនឹងគ្រូអាចារ្យ ដែលអាចពន្យល់ព្រះធម៌បាន ជាការក្រ។ ការបានជួបនឹងព្រះពុទ្ធ ជាការក្រជាងនេះ។ តែការជឿតាមសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ ជាការរឹតតែកម្រណាស់ទៅទៀត។

នៅពេលនេះ យើងបានជួបនឹងអ្នកចេះពន្យល់ព្រះធម៌ ដែលកម្រនឹងបានជួប ហើយយើងបានស្តាប់ឮសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលកម្រនឹងបានស្តាប់ យើងត្រូវតែសប្បាយរីករាយ ជឿតាម ហើយទុកចិត្តលើព្រះពុទ្ធ។

4. ក្នុងរយៈដំណើរដ៏វែងឆ្ងាយនៃជីវិតមនុស្សលោក ជំនឿមោះមុតជាមិត្តរួមដំណើរប្រសើរជាងគេបង្អស់ ជាគ្រឿងធ្វើឲ្យបានត្រជាក់ស្រួលប្រសើរជាងគេបង្អស់ ជាសម្បត្តិធំជាងគេបង្អស់។

ជំនឿមោះមុត ជាដៃដែលទទួលយកព្រះធម៌ គឺជាដៃបរិសុទ្ធដែលទទួលយកគ្រប់គុណធម៌។ ជំនឿមោះមុត ជាភ្លើងដែលឆេះបំផ្លាញគ្រប់អសុចិភាពនៃចំណង់លោកិយ ជាអ្នកនាំផ្លូវទៅកាន់គោលដៅ។

ជំនឿមោះមុត កំចាត់សេចក្តីលោភលន់ សេចក្តីខ្លាចញញើត សេចក្តីឡប់ឡឺត។ ជំនឿមោះមុត បង្រៀនឲ្យចេះមានការគួរសម មានការគោរពរាប់អានអ្នកដទៃ។ ជំនឿមោះមុតរំដោះឲ្យរួចពីចំណងនៃកាលៈទេសៈ បណ្តាលឲ្យមានសេចក្តីក្លាហាន

នៅចំពោះមុខឧបសគ្គ ផ្តល់កម្លាំងដើម្បីជម្នះនូវចំណង់អាក្រក់។ ជំនឿមោះមុត ធ្វើឲ្យមនុស្សអាចរក្សាអំពើទាំងឡាយរបស់ខ្លួនបាន នៅភ្លឺថ្លា នៅបរិសុទ្ធ។ ជំនឿមោះមុត ធ្វើឲ្យសតិបានប្រកបដោយគតិធម៌។

ជំនឿមោះមុតបណ្តាលឲ្យមានសេចក្តីក្លាហាន ក្នុងដំណើរផ្លូវវែងឆ្ងាយគួរឲ្យធុញទ្រាន់។ ជំនឿមោះមុតដឹកនាំយើងទៅកាន់ពន្លឺត្រាស់ដឹង។

ជំនឿមោះមុតបណ្តាលឲ្យយើងស្រមៃឃើញ ហាក់ដូចជាបានស្ថិតនៅជិតព្រះពុទ្ធ។ ជំនឿមោះមុត នាំយើងទៅដាក់ដល់ទីកន្លែងដែលព្រះហស្តព្រះពុទ្ធនៅរង់ចាំទទួលជ្រោងយើង។ ជំនឿមោះមុត ធ្វើឲ្យចិត្តរឹងរូសប្រកបដោយអត្តទត្ត-ភាពរបស់យើងទៅជាទន់។ ជំនឿមោះមុតបណ្តាលឲ្យយើងមានចិត្តជាមិត្ត មានចិត្តចេះយោគយល់។

5. បុគ្គលណា មានជំនឿមោះមុត បុគ្គលនោះនឹងបានប្រកបដោយគតិបណ្ឌិត ចេះទទួលស្គាល់គ្រប់សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធដែលគេបានស្តាប់ឮ។ បុគ្គលណាមានជំនឿមោះមុតបុគ្គលនោះនឹងបានប្រកបដោយគតិបណ្ឌិតអាចនឹងមើល

ឃើញថា វត្ថុទាំងឡាយគ្រាន់តែជាសភាពខាងក្រៅ ដែលកើតមានឡើងស្របទៅតាមច្បាប់ស្ដីពីហេតុ និងផលតែប៉ុណ្ណោះ។ ដូច្នេះ បុគ្គលទាំងឡាយដែលមានជំនឿមោះមុត អាចនឹងមានចិត្តចេះព្រមទទួលដោយក្ដីអំណត់ នូវគ្រប់រឿងហេតុដែលមកដល់ខ្លួន ហើយនិងមានកម្លាំងគ្រប់គ្រាន់ដើម្បីនឹងសម្របខ្លួនទៅតាមកាលៈទេសៈដោយចិត្តស្ងប់។

ជំនឿមោះមុត ផ្ដល់ដល់បុគ្គលអ្នកជឿនូវគតិបណ្ឌិតចេះទទួលស្គាល់អំពីភាពមិនឋិតថេរនៃជីវិត នូវការមិនចេះភ្ញាក់ផ្អើល ឬកើតទុក្ខនឹងគ្រប់រឿងហេតុទាំងអស់ ដែលកើតមានដល់ខ្លួន សូម្បីរឿងហេតុនោះជាទីអវសាននៃជីវិតរបស់ខ្លួនក៏ដោយ ព្រោះគេយល់ថាកាលៈទេសៈ ហើយនិងសភាពជាខាងក្រៅអាចប្រែប្រួល តែសភាពពិតជាខាងក្នុង នៃជីវិតនៅឋិតថេរជានិច្ច មិនចេះប្រែប្រួលទេ។

ជំនឿមោះមុតមានទ្រង់ទ្រាយសំខាន់បីគឺៈ ការចេះដាក់ខ្លួនឲ្យសុភាពរាបសា ការចេះមានសេចក្ដីរីករាយ មានសេចក្ដីគោរពដោយស្មោះចំពោះគុណធម៌អ្នកដទៃ ការចេះមានសេចក្ដីដឹងគុណយ៉ាងជ្រាលជ្រៅចំពោះព្រះពុទ្ធ។

បុគ្គលរាល់រូប តោងតែបណ្តុះរក្សានូវសភាពទាំងបីនៃជំនឿមោះមុតនេះ គឺថា: ទី១ ត្រូវតែឆាប់ដឹងកំហុស និងអំពើសៅហ្មងរបស់ខ្លួន ត្រូវតែចេះខ្មាសអៀនហើយទទួលសារភាពនូវអំពើសៅហ្មងទាំងនោះ។ ទី២ ត្រូវចេះទទួលស្គាល់ដោយយកចិត្តទុកដាក់ នូវគុណសម្បត្តិ និងអំពើល្អរបស់អ្នកដទៃ ហើយកោតសរសើរអំពើល្អរបស់អ្នកទាំងនោះ។ ទី៣ ត្រូវចេះមានសេចក្តីប្រាថ្នាចង់ប្រព្រឹត្តតាមព្រះពុទ្ធ និងរស់នៅជាមួយព្រះអង្គ។

ចិត្តដែលពេញទៅដោយជំនឿមោះមុត គឺចិត្តស្មោះត្រង់ចិត្តជ្រៅ ចិត្តដែលមានសេចក្តីសប្បាយរីករាយដោយបានព្រះពុទ្ធដឹកនាំទៅដែនដីបរិសុទ្ធរបស់ព្រះ អង្គ។

ព្រះពុទ្ធផ្តល់អានុភាពទៅជំនឿមោះមុត ដែលដឹកនាំសត្វលោកទៅដាក់ក្នុងដែនដីបរិសុទ្ធ អានុភាពដែលធ្វើឲ្យសត្វលោកបានបរិសុទ្ធ អានុភាពដែលការពារសត្វលោកឲ្យរួចផុតពីសេចក្តីយល់ច្រឡំអំពីអាត្មាអញ។ បុគ្គលទាំងឡាយណាមានជំនឿមោះមុតតែក្នុងមួយរយៈពេលក៏ដោយ ឲ្យតែបានស្តាប់

ព្រះនាមព្រះពុទ្ធ ដែលផ្សព្វផ្សាយពាសពេញពិភពលោកទាំងមូល បុគ្គលទាំងនោះ នឹងបានទៅកើតក្នុងដែនដីបរិសុទ្ធ។

6. ជំនឿមោះមុត ពុំមែនជាវត្ថុមួយ ដែលត្រូវបានបន្ថែមទៅក្នុងវិញ្ញាណមនុស្សលោកិយទេ តែគឺជាការសម្តែងចេញឲ្យឃើញឡើងនូវវិញ្ញាណក្នុងសភាពជាព្រះពុទ្ធ។ ហេតុនេះអ្នកដែលយល់ ស្គាល់ព្រះពុទ្ធ គឺជាព្រះពុទ្ធមួយអង្គ។ អ្នកដែលមានជំនឿមោះមុតទៅលើព្រះពុទ្ធ គឺជាព្រះពុទ្ធមួយអង្គ។

ការស្វែងរកឲ្យឃើញសភាពព្រះពុទ្ធរបស់ខ្លួនទុំះ ជាការក្រ។ ការរក្សាវិញ្ញាណរបស់ខ្លួនឲ្យបាននៅបរិសុទ្ធនាកណ្តាលភាពជោរនោចនៃសេចក្តីលោភលន់ សេចក្តីខឹងក្រោធ សេចក្តីប្រាថ្នាលោកិយ ជាការក្រ។ តែជំនឿមោះមុតអាចធ្វើឲ្យការខំប្រឹងប្រែងទាំងនេះប្រព្រឹត្តទៅបាន។

នៅក្នុងព្រៃ ឈើឥរន្ទដែលប្រកបដោយជាតិពុល មានតែដើមឥរន្ទទេដែលអាចដុះបាន ដើមចន្ទន៍ដែលមានក្លិនក្រអូបមិនអាចដុះបានទេ។ គឺជាអព្ភូតហេតុមួយ ដែលដើមចន្ទន៍ប្រកបដោយក្លិនក្រអូបឈ្មុយឈ្ងប់មួយដើមដុះក្នុងព្រៃឈើ

ឥវន្ទ។ ក៏ពិតជាអព្ភូតហេតុមួយដែរ ដែលជំនឿមោះមុតទៅលើព្រះពុទ្ធ អាចកើតឡើងបាននៅក្នុងចិត្តមនុស្សលោក។

ហេតុនេះ ការជឿមោះមុតចំពោះព្រះពុទ្ធ ហៅថា «ជំនឿគ្មានឫស» បានន័យថា គ្មានឫសនៅក្នុងចិត្តមនុស្សលោកទេ ឫសនៃជំនឿមោះមុតនេះ មាននៅក្នុងចិត្តប្រកបដោយសេចក្តីករុណាអាសូរនៃព្រះពុទ្ធ។

7. ជំនឿមោះមុត ផ្តល់ផលដ៏ប្រសើរវិសុទ្ធវិសាល។ ប៉ុន្តែជំនឿមោះមុតកម្រនឹងកើតមាននៅក្នុងចិត្ត ដែលព្រងើយកន្តើយ។ ជាពិសេស មានមន្ទិលប្រាំយ៉ាងដែលលាក់បំពួនខ្លួននៅក្នុងចិត្តមនុស្សលោក ហើយដែលចេះតែខារខាំងរាំងរាចិត្តមនុស្សកុំឲ្យមានជំនឿមោះមុត។

ទី១ គឺមន្ទិលសង្ស័យចំពោះគតិធម៌របស់ព្រះពុទ្ធ។ ទី២ គឺមន្ទិលសង្ស័យចំពោះសិក្ខាបទរបស់ព្រះពុទ្ធ។ ទី៣ គឺមន្ទិលសង្ស័យទៅលើអ្នកដែលផ្សាយសិក្ខាបទព្រះពុទ្ធ។ ទី៤ គឺមន្ទិលសង្ស័យចំពោះរបៀបនិងវិធីព្យាយាមហាត់រៀនផ្សេងៗ ដែលត្រូវយកមកប្រតិបត្តិ ក្នុងការដើរតាមផ្លូវប្រសើរឧត្តម។ ទី៥គឺ

មានបុគ្គលខ្លះ ដោយហេតុតែមានចិត្តក្រអឺតក្រអោង និងខ្វះសេចក្តីអំណត់ មានមន្ទិលសង្ស័យទៅលើសេចក្តីស្មោះត្រង់នៃអ្នកដែលយល់ហើយប្រតិបត្តិតាមសិក្ខាបទព្រះពុទ្ធ។

ដោយពិត គ្មានអ្វីដែលគួរឲ្យខ្លាចជាងការមានទម្លាប់មានមន្ទិលសង្ស័យទាំងនេះទេ។ គឺមន្ទិលសង្ស័យទាំងនេះហើយដែលប្រឆាំងនឹងមនុស្សលោក។ គឺជាពិសពុលមួយ ដែលបំបែកបំបាក់មិត្តភាព ដែលបំបែកបំបាក់ចំណងមេត្រីភាពជាមួយអ្នកដទៃគឺជាបន្លា ដែលមុតឈឺចុកចាប់ គឺជាដាវដែលកាត់ផ្តាច់ជីវិត។

ពន្លកនៃជំនឿមោះមុត ត្រូវបានសាបព្រោះបណ្តុះដោយសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ អស់កាលជាយូរណាស់មកហើយ។ កាលណាគេមានជំនឿមោះមុត គេត្រូវតែយល់រឿងនេះឲ្យជាក់ ហើយត្រូវតែមានសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅដល់សប្បុរសធម៌របស់ព្រះពុទ្ធ។

បុគ្គលទាំងឡាយត្រូវតែដឹងថា ជំនឿមោះមុតកើតមានឡើងអំពីសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ។ តាំងពីយូរអង្វែងណាស់មកហើយ ព្រះពុទ្ធបានបញ្ចូលពន្លឺបរិសុទ្ធនៃសទ្ធានេះ ទៅក្នុងចិត្តមនុស្សលោក បណ្តេញកំចាត់អន្ធភាពនៃសេចក្តីល្ងង់

ខ្លៅពីមនុស្សលោក។ អ្នកដែលរីករាយនឹងសទ្ធាជ្រះថ្លានៅពេលបច្ចុប្បន្ននេះ នឹងបានទទួលមរតកសម្បត្តិទៅអនាគត។

ទោះបីជាប្រកបការរស់នៅ យ៉ាងសាមញ្ញរបៀបណា ក៏ដោយអ្នកដែលភ្ញាក់រលឹក មានសទ្ធាជ្រះថ្លាដែលបំភ្លឺជានិច្ចនិរន្តរ៍ដោយសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ នឹងបានទៅកើតក្នុងដែនដីបរិសុទ្ធ។

ពិតណាស់ការកើតនៅក្នុងលោកនេះ ជាការក្រ។ ការបានស្តាប់ឮព្រះធម៌ ជាការក្រ។ ប៉ុន្តែ ការមានសទ្ធាជ្រះថ្លា រឹតតែក្រជាងនេះទៅទៀត។ ដូច្នេះ បុគ្គលរាល់រូបគោងតែខំប្រឹងស្តាប់សេចក្តីទូន្មានរបស់ព្រះពុទ្ធ។

IV

ពុទ្ធឱវាទ

1. «វាបានជេរអញ វាបានចំអកឡកឡឺយឲ្យអញ វាបានវាយអញ»។ ដរាបណា បុគ្គលណានៅតែរក្សាគំនិតទាំងនេះ កំហឹងរបស់គេនឹងមិនចប់ទេ។

ដរាបណាគំនុំនៅតែមានក្នុងចិត្ត កំហឹងក៏នៅតែមានដែរ។ ប៉ុន្តែបើកាលណាគំនុំវិនាសអស់ហើយកំហឹងក៏វិនាសអស់ទៅដែរ។

ផ្ទះដែលដំបូលធ្វើមិនល្អ ធ្លុះធ្លាយដោយអន្ទើ ទឹកភ្លៀងនឹងលិចចូលទៅក្នុងផ្ទះ។ យ៉ាងណាមិញ ចិត្តដែលបង្ហាត់មិនបានល្អ ហើយដែលមិនអាចត្រួតត្រាបាននោះ គំនិតលោភលន់នឹងចូលទៅញាំញីបាន។

ការនៅទំនេរស្ងៀម ជាផ្លូវទៅកាន់សេចក្ដីស្លាប់។ ការឧស្សាហ៍រៀសរវៃ ជាផ្លូវសម្រាប់ជីវិតរស់នៅ។ បុគ្គលឆ្កួតលេលា នៅទំនេរស្ងៀម។ ចំណែកបុគ្គលជាបណ្ឌិត មានការឧស្សាហ៍រៀសរវៃ។

អ្នកធ្វើព្រួញ ខំធ្វើព្រួញឲ្យបានត្រង់។ ដូចគ្នានេះ បុគ្គលជាបណ្ឌិត ខំរក្សាចិត្តរបស់គេឲ្យបានត្រឹមត្រង់។

ចិត្តសៅហ្មង កម្រើកជានិច្ច លោតពីទីមួយទៅទីមួយ ពិបាកនឹងគ្រប់គ្រងណាស់។ ផ្ទុយទៅវិញ ចិត្តស្ងប់ មានភាពសុខស្ងប់។ ដូច្នេះ ការរក្សាចិត្តឲ្យបាននៅស្ងប់ ជាគតិបណ្ឌិត។

ពុំមែនសត្រូវទេ គឺពិតជាចិត្តរបស់ខ្លួនផ្ទាល់តែម្តង ដែលដឹកនាំមនុស្សទៅកាន់ផ្លូវអាក្រក់។

បុគ្គលដែលចេះការពារចិត្តរបស់ខ្លួន ទប់ទល់នឹងសេចក្តីលោភលន់ សេចក្តីខឹងក្រោធ អំពើអាក្រក់ នឹងបានប្រកបសេចក្តីសុខស្ងប់ពិតប្រាកដមិនចេះចប់។

2. មានវាចាល្អតែមិនធ្វើតាម អាចប្រៀបបានទៅនឹងផ្កាមានពណ៌ស្រស់ល្អតែឥតក្លិនក្រអូប។

គន្ធពិដោរនៃផ្កា មិនក្រអូបបញ្ច្រាសខ្យល់ទេ។ តែកេរ្តិ៍ឈ្មោះរបស់មនុស្សល្អ ផ្សព្វផ្សាយគ្រប់ទិសទីបញ្ច្រាសខ្យល់បាន។

រាត្រីកាលហាក់ដូចជាយូរណាស់ ចំពោះអ្នកដេកមិនលក់ ផ្លូវដើរហាក់ដូចជាឆ្ងាយណាស់ ចំពោះអ្នកធ្វើដំណើរដោយលំបាក។ ដូចគ្នានេះ ពេលវេលានៃការយល់ច្រឡំនិងទុក្ខព្រួយហាក់ដូចជាវែងណាស់ ចំពោះអ្នកមិនយល់សិក្ខាបទពិតប្រាកដ។

កាលណាគេធ្វើដំណើរ គេគួរតែដើរជាមួយនឹងមិត្តម្នាក់

ដែលមានសតិប្រាជ្ញាស្មើនឹងគេ ឬខ្ពស់ជាងគេ។ ប៉ុន្តែ គេគួរដើរម្នាក់ឯងល្អជាងដើរជាមួយនឹងមនុស្សឆ្កួតលេលា។

គេខ្លាចសត្វសាហាវ តែគេគួរខ្លាចមិត្តអាក្រក់ ច្រើនជាងសត្វសាហាវ។ សត្វសាហាវបណ្ដាលឲ្យមានរបួសត្រឹមតែរូបកាយ តែមិត្តអាក្រក់បណ្ដាលឲ្យមានរបួសដល់បេះដូង។

ដរាបណា គេមិនអាចគ្រប់គ្រងចិត្តរបស់គេបាន គេមិនអាចបោះបង់គំនិតថា «នេះជាកូនរបស់អញ» «នេះជាទ្រព្យកំណាប់របស់អញ» បានទេ។ បុគ្គលឆ្កួតលេលា រងទុក្ខនឹងគំនិតរបៀបនេះ។

ឆ្កួតហើយដឹងខ្លួនថាឆ្កួត វាប្រសើរជាជាងឆ្កួតហើយនឹកស្មានថាខ្លួនជាបណ្ឌិត។

ស្លាបព្រាមិនអាចដឹងរសជាតិនៃម្ហូប ដែលដួសឡើងទុំទេ។ យ៉ាងណាមិញ បុគ្គលឆ្កួតមិនអាចយល់គតិបណ្ឌិតរបស់អ្នកប្រាជ្ញបណ្ឌិតបានទេ ទោះបីជាបុគ្គលឆ្កួតនោះរស់នៅជាមួយអ្នកប្រាជ្ញបណ្ឌិតនោះក៏ដោយ។

តាមធម្មតា ដូចជាទឹកដោះស្រស់ដែលមិនងាយនឹងកករឹងភ្លាមៗ អំពើអាក្រក់មិនផ្ដល់ហេតុផលភ្លាមៗទេ។ អំពើអាក្រក់

ដូចជារងើកភ្លើងដែលកប់ក្នុងផេះ ហើយដែលនៅទីបំផុតឆេះឆ្លោឡើង។

ការសង្វាតរកប្រយោជន៍ឯកសិទ្ធិ រកបាននូវស័ក្តិ រកកម្រៃ រកកិត្តិយស ជាការឆ្កួត។ ការប្រាថ្នាទៅលើវត្ថុទាំងនេះមិនអាចនាំមកនូវសុភមង្គលបានទេ ផ្ទុយទៅវិញវារឹតតែបន្ថែមសេចក្តីទុក្ខព្រួយ។

មិត្តល្អដែលបង្ហាញសេចក្តីយល់ច្រឡំ និងកំហុសរបស់អ្នកដល់អ្នក ដែលស្តីប្រដៅអ្នកអំពីអំពើអាក្រក់របស់អ្នក គួរជាទីគោរព បីដូចជាមិត្តនោះបានប្រាប់ទីលាក់កំណប់មួយដល់អ្នក។

3. បុគ្គលដែលសប្បាយរីករាយនឹងទទួលការទូន្មានល្អ អាចដេកលក់ដោយសុខស្ងប់ព្រោះចិត្តរបស់គេត្រូវបានលាងស្អាត។

ជាងធ្វើផ្ទះ ខំធ្វើធ្នឹមផ្ទះឲ្យបានត្រង់ល្អ។ អ្នកធ្វើព្រួញខំធ្វើព្រួញឲ្យបានត្រឹមត្រូវតាមកំហឹត។ អ្នកជីកប្រឡាយបង្ហូរទឹកបញ្ចូលស្រែ ខំធ្វើយ៉ាងណាឲ្យទឹកបានហូរស្រួល។ ដូចគ្នានេះបុគ្គលជាបណ្ឌិត ខំគ្រប់គ្រងចិត្តរបស់គេឲ្យមានដំណើរស្រួលឲ្យមានភាពត្រឹមត្រង់។

ដុំថ្មធំ មិនអាចរញ្ជួយដោយសារខ្យល់ទេ។ ដូចគ្នានេះ ចិត្តរបស់បុគ្គលជាបណ្ឌិត មិនអាចរញ្ជួយដោយសារកិត្តិយស ឬការប្រមាថមើលងាយទេ។

ជម្នះខ្លួនឯងបាន ជាមហាជោគជ័យមួយ ធំជាងឈ្នះសត្រូវមួយពាន់នាក់ក្នុងលានប្រយុទ្ធទៅទៀត។

រស់តែមួយថ្ងៃ ហើយបានស្តាប់ឮសេចក្តីប្រៀនប្រដៅវិសុទ្ធល្អ ប្រសើរជាជាងរស់មួយរយឆ្នាំ ហើយពុំបានស្តាប់ឮសេចក្តីទូន្មានល្អវិសុទ្ធ។

បើស្រឡាញ់ខ្លួន គោងតែឃ្លាំមើលវាជានិច្ចកុំឲ្យវាធ្លាក់ទៅក្នុងចំណង់អាក្រក់។

លោកនេះជាភ្លើងឆេះជានិច្ច ឆេះដោយភ្លើងលោភលន់ ភ្លើងកំហឹង ភ្លើងល្ងង់ខ្លៅ។ គោងតែរត់គេចពីគ្រោះថ្នាក់ទាំងនេះជាបន្ទាន់។

លោកនេះដូចជាពពុះទឹក ដូចជាសរសៃសំបុកពីងពាង ដូចជាក្អែលនៃក្អមកខ្វក់។ បុគ្គលពាល់រូបគោងតែរក្សាការពារភាពបរិសុទ្ធនៃចិត្តរបស់ខ្លួនជានិច្ច។

4. ចូរចៀសវាងអំពើអាក្រក់ទាំងអស់ ចូរស្វែងរកអំពើល្អ ចូរ

រក្សាចិត្តឲ្យបានបរិសុទ្ធៈ ទាំងនេះហើយ ជាសេចក្ដីទូន្មានរបស់ព្រះពុទ្ធ។

សេចក្ដីអំណត់ ជាវិន័យមួយក្នុងចំណោមវិន័យដែលពិបាកជាងគេបង្អស់។ ប៉ុន្ដែ មានតែអ្នកមានអំណត់ទេ ដែលត្រូវបានទទួលជោគជ័យ នៅទីបំផុត។

កាលណាគេកើតមានគំនុំ គេត្រូវតែកំចាត់គំនុំនោះចោល។ កាលណាគេមានទុក្ខព្រួយ គេត្រូវតែកំចាត់ទុក្ខព្រួយនោះចោល។ កាលណាគេមានចិត្តបាក់ទៅលើ សេចក្ដីលោភលន់ គេត្រូវតែកំចាត់សេចក្ដីលោភលន់នោះចោល។ ដើម្បីរស់នៅក្នុងជីវភាពប្រកបដោយសប្បុរសធម៌ ត្រូវតែមើលមកខ្លួនឯងថា គ្មានអ្វីទាំងអស់ ដែលជាកម្មសិទ្ធិរបស់ខ្លួន។

មានសុខភាពល្អ ជាអត្ថប្រយោជន៍ធំមួយ។ សប្បាយរីករាយនឹងឃើញគេឯទៀតមានបាន វាប្រសើរជាជាងមានសម្បត្តិស្ដុកស្ដម្ភផ្ទាល់ខ្លួនឯង។ ធ្វើឲ្យអ្នកឯទៀតមានការទុកចិត្តជាសញ្ញាមិត្តភាពពិតប្រាកដ។ បានសម្រេចពន្លឺត្រាស់ដឹងជាសុភមង្គលខ្ពស់បំផុត។

កាលណា គេបានវៀរចាកអំពើអាក្រក់ កាលណាគេបាន

ប្រកបអារម្មណ៍ស្ងប់ កាលណាគេបានមានចិត្តរីករាយនឹងទទួលយកដំបូន្មានល្អ គេនឹងបានចាកផុតពីសេចក្តីបារម្ភខ្វាច។

ចូរកុំជំពាក់ចិត្តនឹងអ្វីៗ ដែលអ្នកចូលចិត្ត ចូរកុំរុញច្រានចោលអ្វីៗ ដែលអ្នកមិនចូលចិត្ត។ សេចក្តីព្រួយ សេចក្តីខ្លាច និងសេចក្តីជាប់ជំពាក់ទាំងនេះ មកអំពីការចូលចិត្ត និងការមិនចូលចិត្តនេះឯង។

5. ច្រែះកើតចេញមកអំពីដែក ហើយស៊ីទម្លុះដែក។ ដូចគ្នានេះ អំពើអាក្រក់កើតចេញអំពីចិត្ត ហើយស៊ីទម្លុះចិត្ត។

សៀវភៅដែលគេមិនបើកមើលជារឿយៗ ឆាប់ជាប់ធូលី។ ផ្ទះដែលគេមិនជួសជុលឲ្យទាន់ពេលវេលា មុខជានឹងទ្រុតទ្រោមបាក់បែក។ ដូចគ្នានេះ បុគ្គលដែលរស់នៅក្នុងភាពទំនេរខ្ជិល នឹងទៅជាអសុចិមួយរំពេច។

អំពើអាសអាភាស នាំឲ្យខូចកិត្តិនាមនារី។ ការកំណាញ់ស្វិត នាំឲ្យខូចទាន។ ដូចគ្នានេះ អំពើអាក្រក់នាំឲ្យខូចជីវិតបច្ចុប្បន្ន និងជីវិតអនាគត។

មន្ទិលសៅហ្មងដែលគួរខ្លាចជាងគេបង្អស់ គឺមន្ទិលសៅ

ហ្មង់នៃសេចក្ដីល្ងង់ខ្លៅ។ គេមិនអាចសង្ឃឹមនឹងធ្វើខ្លួន ហើយនិងចិត្តរបស់គេ ឲ្យបានបរិសុទ្ធទេ ដរាបណាគេមិនកំចាត់សេចក្ដីល្ងង់ខ្លៅចេញ។

ការរអិលធ្លាក់ទៅក្នុងអំពើឥតអៀនខ្មាស ការឡើងចិត្តគឃើន ការឡើងឡឹតក្រអឺតក្រអោងដូចមាន់គក ការប្រព្រឹត្តអាក្រក់ទៅលើអ្នកដទៃ ដោយគ្មានចិត្តចេះនឹកស្ដាយក្រោយជាការងាយស្រួលណាស់។

ប៉ុន្តែ ការធ្វើខ្លួនឲ្យសុភាពរាបសា ការចេះគោរពនិងផ្ដល់កិត្តិយសដល់អ្នកដទៃ ការមិនជាប់ជំពាក់ចិត្ត ការរក្សាគំនិតនិងអំពើរបស់ខ្លួនឲ្យបានស្អាតបរិសុទ្ធ ការធ្វើខ្លួនឲ្យបានជាបណ្ឌិតជាការពិបាក។

ការមើលឃើញកំហុសអ្នកដទៃ ជាការងាយស្រួល ប៉ុន្តែការមើលឃើញកំហុសរបស់ខ្លួនឯងផ្ទាល់ ជាការពិបាក។ គេប្រកាសកំហុសអ្នកដទៃយ៉ាងឮរំពង តែគេលាក់កំហុសរបស់គេផ្ទាល់ដូចជាអ្នកលេងបៀលាក់សន្លឹកបៀ។

មេឃាមិនទុកដាននៃសត្វបក្សាបក្សី ដាននៃផ្សែង ឬដាននៃខ្យល់ព្យុះទេ។ សេចក្ដីទូន្មានអាក្រក់ មិនដឹកនាំទៅកាន់ពន្លឺ

ត្រាស់ដឹងទេ។ នៅក្នុងលោកនេះ គ្មានអ្វីដែលមិនប្រែប្រួលទេ។ ប៉ុន្តែ អ្នកបានសម្រេចពន្លឺត្រាស់ដឹង នឹងបានស្ថិតនៅក្នុងសេចក្តីសុខស្ងប់ ឥតប្រែប្រួលរហូត។

6. ដូចជាឆ្មាំដែលយាមរក្សាទ្វាររាំងប្រាសាទ បុគ្គលរាល់រូបត្រូវតែរក្សាការពារចិត្តរបស់ខ្លួន ទប់ទល់នឹងសត្រូវទាំងខាងក្រៅទាំងខាងក្នុង ហើយកុំប្រហែសវាឲ្យសោះ។

យើងជាម្ចាស់លើខ្លួនយើង យើងទីពឹងលើខ្លួនយើង។ ហេតុនេះយើងគោងតែគ្រប់គ្រងខ្លួនយើងផ្ទាល់។

ជំហានទីមួយ ក្នុងការរំដោះវិញ្ញាណឲ្យរួចពីច្រវាក់ និងចំណងលោកិយ គឺត្រូវតែគ្រប់គ្រងចិត្តរបស់ខ្លួន ត្រូវតែចៀសវាងការនិយាយច្រើនឥតប្រយោជន៍ ត្រូវតែមានស្មារតីប្រុងប្រយ័ត្ន។

ព្រះអាទិត្យបំភ្លឺលោកនៅពេលថ្ងៃ ព្រះចន្ទធ្វើឲ្យរាត្រីកាលមានសម្រស់ អាវក្រោះធ្វើឲ្យទាហានរឹតតែបានឡើងខែង។ ដូចគ្នានេះ ការចម្រើនភាវនាដោយស្ងប់ជាកិច្ចសម្គាល់អ្នកដែលស្វែងរកពន្លឺត្រាស់ដឹង។

បើកាលណា គេមិនអាចរក្សាការពារវិញ្ញាណទាំងប្រាំរបស់គេ ពោលគឺភ្នែក ត្រចៀក ច្រមុះ អណ្តាត និងរូបកាយបានទេនុ៎ះ គេមិនអាចព្យាយាមដើម្បីសម្រេចពន្លឺត្រាស់ដឹងបានទេ។ បុគ្គលណាដែលចេះរក្សាការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំ ហើយចេះគ្រប់គ្រងចិត្ត បុគ្គលនោះអាចព្យាយាមប្រកបដោយជោគជ័យដើម្បីសម្រេចពន្លឺត្រាស់ដឹង។

7. បើកាលណាគេលុះក្នុងអំណាចនៃការចូលចិត្ត និងការមិនចូលចិត្ត គេមិនអាចយល់ឲ្យបានត្រឹមត្រូវអំពីន័យនៃទេស-កាលទេ ហើយដោយហេតុនេះ គេតែងតែខំដណ្តើមយកឈ្នះចាញ់។ បើកាលណាគេចាកផុតពីការជំពាក់ចិត្ត គេនឹងយល់យ៉ាងត្រឹមត្រូវអំពីទេសកាល ហើយអាស្រ័យហេតុនេះគេនឹងឃើញថាវត្ថុទាំងអស់តែងតែប្រែប្រួល។

សុភមង្គលតាមក្រោយទុក្ខព្រួយ ទុក្ខព្រួយតាមក្រោយសុភមង្គល។ ប៉ុន្តែបើកាលណាគេមិនធ្វើការវែកញែករវាងសុភមង្គលនឹងទុក្ខព្រួយ រវាងល្អនឹងអាក្រក់ នុ៎ះគេអាចបានស្គាល់នូវសុខសិរីពិតប្រាកដ។

ព្រួយបារម្ភនឹងអនាគត ហើយស្តាយស្រណោះនឹងអតីត ប្រដូចបានទៅនឹងដើមបបុសដែលគេកាត់ហាលសួត។

សេចក្តីជាអាថ៌ដើម្បីសុខសួស្តីនៃរូបកាយនិងវិញ្ញាណ គឺ មិនសោកស្រណោះនឹងអតីត មិនព្រួយបារម្ភនឹងអនាគត មិន រឹកររនឹងរឿងដែលនឹងត្រូវមកដល់ ផ្ទុយទៅវិញគឺចេះរស់នៅ ក្នុងភាពបច្ចុប្បន្នប្រកបដោយគតិបណ្ឌិត ក្នុងភាពជាធម្មតា។

ចូរកុំគិតទាក់ទាមនឹងអតីត ចូរកុំរង់ចាំអនាគត កិច្ចតែ មួយគត់គឺ ត្រូវចេះរស់នៅប្រកបដោយចិត្តនឹងនក្នុងបច្ចុប្ប-កាលនេះ។

ការបំពេញកិច្ចបច្ចុប្បន្នឲ្យបានល្អ ជាការប្រសើរមួយៈ ចូរកុំនឹកខំចៀសវាងកិច្ចបច្ចុប្បន្នឬទុកវាទៅថ្ងៃស្អែក។ បើអ្នក បំពេញកិច្ចបច្ចុប្បន្នឲ្យបានសមរម្យល្អបាន គឺអ្នករស់នៅដោយ សប្បាយរីករាយបានមួយថ្ងៃ។

គ្មានអ្នកបំភ្លឺផ្លូវណាប្រសើរជាងគតិធម៌ទេ គ្មានមិត្តណា ប្រសើរជាងជំនឿជ្រះថ្លាទេ។ បុគ្គលទាំងឡាយតោងតែខំរត់ គេចចេញពីអន្ធភាពនៃសេចក្តីល្ងង់ខ្លៅនិងទុក្ខព្រួយ ហើយខំ ស្វែងរកពន្លឺត្រាស់ដឹង។

កាលណាគេគ្រប់គ្រងកាយ និងចិត្តរបស់គេបាន នេះជាសញ្ញានៃអំពើប្រកបដោយគុណធម៌ នេះជាករណីយកិច្ចខ្ពង់ខ្ពស់បំផុត។ ពេលនោះ ជំនឿជ្រះថ្លានឹងបានជាសម្បត្តិ សេចក្ដីស្មោះត្រង់នឹងផ្ដល់រសជាតិផ្អែមត្រជាក់ដល់ជីវិត ហើយការប្រមូលសន្សំកុសលបុណ្យនេះនឹងបានជាករណីយកិច្ចមួយប្រសើរបំផុត។

ក្នុងដំណើរនៃជីវិត ជំនឿជ្រះថ្លាជាចំណីអាហារ គុណធម៌ជាទីជម្រក គតិធម៌ជាពន្លឺនៅពេលថ្ងៃ ការចេះប្រុងប្រយ័ត្នដ៏ត្រឹមត្រូវជាសម្ភារៈការពារនៅពេលយប់។ បុគ្គលណាចេះរស់នៅក្នុងជីវិតស្អាតបរិសុទ្ធ គ្មានអ្វីអាចមកបំផ្លាញគេបានទេ។ បុគ្គលណាបានឈ្នះសេចក្ដីលោភលន់ គ្មានអ្វីអាចកំណត់ព្រំដែននៃសេរីភាពរបស់គេបានទេ។

គេតោងតែបំភ្លេចខ្លួនគេ ដើម្បីសេចក្ដីស្នេហាដល់គ្រួសារគេ។ គេតោងតែបំភ្លេចគ្រួសារគេ ដើម្បីសេចក្ដីស្នេហាដល់ភូមិស្រុកគេ។ គេតោងតែបំភ្លេចភូមិស្រុកគេ ដើម្បីសេចក្ដីស្នេហាដល់ប្រទេសជាតិគេ។ ទីបំផុត គេតោងតែបំភ្លេចអ្វីៗទាំងអស់ ដើម្បីសេចក្ដីស្នេហាពន្លឺត្រាស់ដឹង។

អ្វីៗទាំងអស់សុទ្ធតែប្រែប្រួល អ្វីៗទាំងអស់កើតឡើងហើយ

វិនាសទៅវិញជាធម្មតា គ្មានសេចក្តីសុខស្ងប់ទេ ដរាបណាគេ មិនបានរួចផុតពីដំណើរប្រែប្រួល នៃការរស់ និងការស្លាប់ នេះៗ

កាតរកាពរ៉ាង៍ពុទ្ធសាសនិក

ចំពូកទី ១

ករណីយកិច្ចនៃពុទ្ធសាសនិក

I

អ្នកបួស

1. *អ្នកប្រាថ្នាចង់បានជាសាវ័ករបស់តថាគត ត្រូវតែតាំងចិត្តសច្ចាលះបង់ការទាក់ទងជាបន្ទាល់ជាមួយនឹងគ្រួសារ លះបង់ការរស់នៅក្នុងសង្គមលោកិយ លះបង់ការជំពាក់ចិត្តនឹងមាសប្រាក់សម្បត្តិទ្រព្យ។*

អ្នកលះបង់គ្រប់ការទាក់ទងទាំងនេះ ដើម្បីរកព្រះធម៌ ហើយគ្មានទីជម្រកជាអចិន្ត្រៃយ៍សម្រាប់រូបកាយនិងវិញ្ញាណរបស់ខ្លួន នឹងបានជាសាវ័កមួយអង្គរបស់តថាគត ហើយបានឈ្មោះថា អ្នកបួសគ្មានលំនៅខ្ជាប់ខ្ជួន។

បុគ្គលណា ទោះបីដើរតាមដានជើងរបស់តថាគត ហើយស្លៀកស្បង់របស់តថាគតក៏ដោយ បើចិត្តរបស់គេនៅជាប់ជំ-ពាក់នឹងចំណង់លោភលន់ បុគ្គលនោះនៅឆ្ងាយពីតថាគត។ បើ

បុគ្គលណា ស្លៀកពាក់ជាអ្នកបួស តែមិនទទួលយកសេចក្តីប្រៀនប្រដៅរបស់តថាគត បុគ្គលនោះមើលតថាគតមិនឃើញទេ។

បុគ្គលណាលះបង់ចោលគ្រប់ចំណង់លោភលន់ ហើយមានចិត្តបរិសុទ្ធស្ងប់ ទោះបីបុគ្គលនោះនៅឆ្ងាយ អំពីតថាគតរាប់រយយោជន៍ក៏ដោយ ក៏ហាក់ដូចជានៅបង្កើយនឹងតថាគតដែរ។ បើបុគ្គលណាទទួលយកព្រះធម៌ បុគ្គលនោះនឹងអាចមើលឃើញតថាគតតាមព្រះធម៌នោះឯង។

2. សាវ័ករបស់តថាគត ដែលជាអ្នកបួសឥតទីលំនៅជាខ្ជាប់ខ្ជួន ត្រូវតែប្រតិបត្តិវិន័យទាំងបួន ហើយយកវិន័យទាំងនោះជាគ្រឹះសម្រាប់ជីវិតរបស់ខ្លួន។

ទី១-ស្លៀកសម្លៀកបំពាក់ចាស់ ដែលគេបោះចោល។ ទី២ បានចំណីអាហារ ដោយសារការដើរបិណ្ឌបាត។ ទី៣ ជ្រកសំណាក់នៅក្រោមដើមឈើ ឬលើផ្ទាំងសិលា កាលណារាត្រីកាលមកដល់។ ទី៤ មើលថែជំងឺរបស់ខ្លួន តែនឹងថ្នាំពិសេស ដែលផ្សំឡើងអំពីទឹកមូត្រនៃសត្វពាហនៈដែលអ្នកបួសដូចគ្នានាំយកមកឲ្យ។

ជីវិតជាអ្នកសុំទាន គឺកាន់បាត្រដើរសុំទានគេ ពីផ្ទះមួយ

ទៅផ្ទះមួយៗ តែកិច្ចនេះមិនមែនត្រូវបាន អ្នកណាម្នាក់បង្ខំគេឡើយ ឬកាលៈទេសៈណាមួយ ឬសេចក្តីប្រាថ្នាលោកណាមួយរបស់គេ មកបង្ខំគេឲ្យធ្វើកិច្ចនេះ ក៏ទេដែរ។ គេធ្វើដោយឆន្ទៈល្អរបស់គេផ្ទាល់ ពីព្រោះគេយល់ថា ជីវិតក្នុងជំនឿជ្រះថ្លានាំឲ្យគេបានចៀសផុតពីភាពថ្លឹងថ្លែងនៃជីវិត នាំឲ្យគេបានចៀសផុតពីទុក្ខ ហើយនាំឲ្យគេបានទៅដល់ពន្លឺត្រាស់ដឹង។

ជីវិតអ្នកបួសឥតទីស្នាក់អាស្រ័យខ្ជាប់ខ្ជួន មិនមែនជាជីវិតស្រណុកស្រួលទេ។ គេមិនត្រូវប្រកបជីវិតនេះទេ បើគេមិនអាចរក្សាគ្រប់គ្រងចិត្តរបស់គេ ឲ្យបានរួចផុតពីចំណង់លោភលន់និងសេចក្តីខឹងក្រោធ បើគេមិនអាចត្រួតត្រាចិត្តនិងវិញ្ញាណទាំងប្រាំរបស់គេបាន។

3. ដើម្បីតាំងខ្លួនជាអ្នកបួសឥតទីលំនៅខ្ជាប់ខ្ជួន ហើយអាចឆ្លើយរួចថាខ្លួនជាអ្នកបួស គេត្រូវតែតាំងចិត្តសច្ចាថាៈ

«ខ្ញុំសច្ចាថានឹងបំពេញគ្រប់កិច្ចទាំងអស់ ដែលជាចាំបាច់សម្រាប់អ្នកបួស។ ខ្ញុំសច្ចាតាំងចិត្តស្មោះត្រង់ ខិតខំឲ្យបានទៅជាអ្នកបួសពិតប្រាកដមួយរូប។ ខ្ញុំនឹងដឹងគុណជនទាំងឡាយ

ដែលធ្វើទានដល់ខ្ញុំ ហើយខ្ញុំនឹងខំធ្វើឲ្យជនទាំងនោះបានប្រកប សេចក្តីសុខជាទីបំផុត ដោយសារអានិសង្សនៃជីវិតតឹងរឹងល្អ ប្រសើររបស់ខ្ញុំ»។

កិច្ចផ្សេងៗ ដែលអ្នកបួសឥតទីលំនៅខ្ជាប់ខ្ជួនត្រូវព្យាយាម ប្រតិបត្តិគឺៈ ត្រូវធាប់ចេះមានការអៀនខ្មាស ហើយធាប់ចាប់ អារម្មណ៍ដល់ការអាប់យស កាលណាបានប្រព្រឹត្តខុស។ ត្រូវ រក្សាកាយវាចា និងចិត្ត ឲ្យបានបរិសុទ្ធ ដើម្បីរស់ក្នុងជីវិតបរិ-សុទ្ធ។ ត្រូវប្រុងប្រយ័ត្នការពារមាត់ទ្វារនៃវិញ្ញាណទាំងប្រាំ។ មិនត្រូវឡប់សតិ ដោយសារសេចក្តីសប្បាយ ដែលមិនឋិត ថេរ។ មិនត្រូវអួតខ្លួនឯង ហើយមើលងាយអ្នកឯទៀត។ មិន ត្រូវខ្ជិលច្រអូស ហើយដេកដំអក់យូរលង់។

ពេលល្ងាច ត្រូវអង្គុយភាវនាដោយស្ងៀមស្ងប់ មួយរយៈ វេលា រួចហើយចេញដើរបន្តិចមុននឹងចូលដេក។ ដើម្បីដេក ឲ្យបានសុខស្ងប់ ត្រូវដេកផ្អៀងទៅស្តាំ យកជើងផ្គុំគ្នា ហើយ គិតជាចុងក្រោយដល់ពេលដែលត្រូវភ្ញាក់ឲ្យបានរហ័សពីព្រឹក ព្រហាម។ នៅពេលព្រឹក ត្រូវមានពេលមួយរយៈទៀត ដើម្បី អង្គុយភាវនាដោយស្ងាត់ស្ងៀម រួចហើយចេញដើរបន្តិច។

ជារៀងរាល់ថ្ងៃ ត្រូវប្រុងប្រយ័ត្នរក្សាគ្រប់គ្រងចិត្តឲ្យបាន ត្រឹមត្រូវជានិច្ច។ ត្រូវរកកន្លែងស្ងប់ស្ងាត់អង្គុយភាវនាគិតរក្សា ការពារកាយ និងចិត្ត ទប់ទល់នឹងសេចក្ដីលោភលន់សេចក្ដី ក្រោធខឹង សេចក្ដីល្ងង់ខ្លៅ សេចក្ដីខ្ជិលច្រអូស សេចក្ដីធ្វេស ប្រហែស សេចក្ដីសោកស្ដាយ ការមានមន្ទិលសង្ស័យ ហើយ និងចំណង់លោកិយឯទៀតទាំងអស់។

ព្រមដោយការសង្រួមចិត្តនេះ គេត្រូវបណ្ដុះបណ្ដាល គតិធម៌ប្រសើរបំផុតឲ្យបែងចាំឡើង ហើយប្រាថ្នាឆ្ពោះទៅរក ពន្លឺត្រាស់ដឹងពេញលេញតែមួយគត់។

4. អ្នកបួសណាក្មេងខ្ចី រអិលធ្លាក់ទៅក្នុងចំណង់លោភលន់ បណ្ដាលឲ្យសេចក្ដីក្រោធខឹងចេញចូលបានតាមចិត្ត ចិញ្ចឹម ចិត្តបង់គំនុំ ចិត្តប្រណែននិន្ទា ចិត្តឡើងអំនួត ចិត្តឡឹត ចិត្ត លាក់ពុត គឺដូចជាកាន់ដាវមុខពីរ ដែលស្រោបដោយស្បៃ យ៉ាងស្ដើងហៀ ដូច្នោះដែរ។

គ្រាន់តែស្លៀកស្បង់រហែករយ៉ីរយ៉ៃជាអ្នកបួស ហើយកាន់ បាត្រមួយនោះ មិនមែនជាអ្នកបួសទេ។ គ្រាន់តែបេះសូត្រធម៌

រុំលឥតទាក់នោះ មិនមែនជាអ្នកបួសទេ។ បុគ្គលទាំងនេះគឺបួសតែសម្បកក្រៅ តែប៉ុណ្ណោះ។

ទោះបីជាមានសភាពខាងក្រៅជាអ្នកបួសទុំះក៏ដោយតែបើមិនអាចកំចាត់បង់នូវចំណង់លោកិយបានទេ មិនមែនជាអ្នកបួសទេ។ គឺដូចជាកូនក្មេងដែលស្លៀកស្បង់លោកសង្ឃតែប៉ុណ្ណោះ។

បុគ្គលដែលអាចហៅបានថា ជាអ្នកបួសពិតប្រាកដ គឺបុគ្គលដែលអាចសង្រួមគ្រប់គ្រងចិត្តរបស់ខ្លួនបាន បុគ្គលដែលមានគតិបណ្ឌិត បុគ្គលដែលចៀសផុតពីគ្រប់ចំណង់លោកិយ បុគ្គលដែលមានគោលបំណងតែមួយគត់ គឺការបានសម្រេចពន្ទឹត្រាស់ដឹង។

អ្នកបួសពិតប្រាកដ សម្រេចចិត្តខំព្យាយាមឲ្យទាល់តែបានសម្រេចពន្ទឹត្រាស់ដឹង ទោះបីគេត្រូវអស់តំណក់ឈាមជាទីចុងក្រោយរបស់គេក៏ដោយ ឬឆ្អឹងរបស់គេ ត្រូវខ្ទេចខ្ទីទៅជាផង់ធូលីក៏ដោយ។ អ្នកបួសដែលខំព្យាយាមយ៉ាងអស់សមត្ថភាពនឹងបានសម្រេចគោលបំណង ដែលជាប្រត្យក្សភាពនៃសមត្ថភាពរបស់ខ្លួន ក្នុងការបំពេញកុសលកិច្ចនៃអ្នកបួសដើរគ្រប់ទីកន្លែង ឥតកំណត់។

5. បេសកកម្មរបស់អ្នកបួស គឺផ្សាយពន្លឺធម៌ទូន្មានរបស់ព្រះពុទ្ធ។ អ្នកបួសមានភារកិច្ចទេសនាពន្យល់ព្រះធម៌ដល់មហាជនទូទៅ ដាស់អ្នកដេកលក់ឲ្យក្រោក កែតម្រង់អ្នកយល់ខុស ជួយដាស់តឿនមហាជនឲ្យបានប្រកបនូវឧត្តមគតិ។ អ្នកបួសត្រូវចេញដើរសព្វទិសទី ដើម្បីទេសនាផ្សាយព្រះធម៌ឲ្យបានសាយសុស ទោះបីភារកិច្ចនេះ អាចនឹងបណ្ដាលគ្រោះថ្នាក់ដល់ជីវិតដ៏ដោយ។

បេសកកម្មរបស់អ្នកបួស មិនមែនស្រួលទេ។ ហេតុនេះ អ្នកដែលប្រាថ្នាចង់បានជាអ្នកបួស ត្រូវតែស្លៀកស្បង់ព្រះពុទ្ធ អង្គុយលើអាសនៈព្រះពុទ្ធ ហើយចូលទៅក្នុងសំណាក់ព្រះពុទ្ធ។

ស្លៀកស្បង់ព្រះពុទ្ធគឺតាំងខ្លួនឲ្យរាបសា ខំព្យាយាមដោយទៀងទាត់។ អង្គុយលើអាសនៈព្រះពុទ្ធ គឺមើលឃើញវត្ថុទាំងឡាយអត់ខ្លឹមសារ ហើយគ្មានការជំពាក់ចិត្តទៅលើវត្ថុទាំងនោះ។ ចូលទៅក្នុងសំណាក់ព្រះពុទ្ធ គឺមានសេចក្ដីករុណាមហាអាសូរចំពោះគ្រប់សត្វលោក។

6. អ្នកដែលប្រាថ្នាផ្សាយព្រះធម៌ឲ្យបានលទ្ធផល ត្រូវមានការ

គិតប្រុងប្រយ័ត្នបួនគឺៈ ទី១ ត្រូវប្រយ័ត្នដំណើរឫកពារបស់ខ្លួន ទី២ ត្រូវប្រយ័ត្នពាក្យសំដីនិយាយពន្យល់គេ ទី៣ត្រូវគិតពីគោលបំណងក្នុងការនិយាយពន្យល់គេ ទី៤ត្រូវគិតទៅដល់សេចក្ដីករុណាមហាអាសូរ។

ដើម្បីបានជាគ្រូអាចារ្យបង្រៀនព្រះធម៌ អ្នកបួសត្រូវតែៈ ទី១ មានសេចក្ដីព្យាយាមទៀងទាត់ មានសភាពរម្យទម មិនឈ្ងើយឬចង់បានមុខមាត់ គិតជានិច្ចដល់ភាពទទេឥតខ្លឹមសារនៃវត្ថុទាំងអស់ ហើយមិនជាប់ជំពាក់ចិត្តនឹងវត្ថុអ្វីមួយឡើយ។ ការចេះគិតប្រុងប្រយ័ត្នរបៀបនេះ អាចឲ្យបានប្រកបចរិយាមារយាទត្រឹមត្រូវ។

ទី២ ត្រូវមានការប្រុងប្រយ័ត្ន កាលណាចូលទៅក្នុងសង្គមមនុស្សផ្សេងៗ។ ត្រូវចៀសវាងមនុស្ស ដែលប្រកបជីវិតកាចសាហាវ ឬប្រកាន់អំណាច។ ត្រូវចៀសវាងកុំចូលជិតស្រី។ ត្រូវទុកមនុស្សគ្រប់ប្រភេទជាមិត្ត ដោយនឹកគិតជានិច្ចថា អ្វីៗទាំងអស់ សុទ្ធតែជាការប្រមូលបញ្ចូលគ្នាមកអំពីហេតុ និងល័ក្ខខ័ណ្ឌ។ ដោយហេតុនេះ មិនត្រូវបន្ទោសបុគ្គល មិនត្រូវជេរបុគ្គល មិនត្រូវទិទៀនបុគ្គល ឬហែកកេរ្តិ៍បុគ្គលទេ។

ទី៣ ត្រូវរក្សាចិត្តរបស់ខ្លួនឲ្យបានស្ងប់ ដោយទុកព្រះពុទ្ធជាបិតានៃសាសនា ទុកអ្នកបួសឯទៀត ដែលមានជម្រុលទៅមុខក្នុងការព្យាយាមដើម្បីសម្រេចពន្លឺត្រាស់ដឹង ជាគ្រូអាចារ្យ ហើយយកចិត្តទុកដាក់នឹងមនុស្សគ្រប់ប្រភេទ ដោយចិត្តមានមេត្តាអាសូរ។ ដូច្នេះ អ្នកបួសត្រូវប្រៀនប្រដៅមនុស្សលោកគ្រប់ប្រភេទ ឲ្យបានស្មើៗគ្នា។

ទី៤ ត្រូវបញ្ចេញចិត្តមេត្តាអាសូររបស់ខ្លួន ឲ្យបានធំបំផុតដូចព្រះពុទ្ធ។ ត្រូវមានសេចក្តីប្រាថ្នាមោះមុត ចង់ឲ្យអ្នកដែលមិនស្គាល់ផ្លូវទៅកាន់ពន្លឺត្រាស់ដឹង បានស្តាប់ហើយប្រតិបត្តិតាមធម៌ព្រះពុទ្ធ។ ត្រូវប្រសិទ្ធិពរឲ្យអ្នកទាំងនោះបានសម្រេចពន្លឺត្រាស់ដឹង ហើយខំបំពេញបំណងអ្នកទាំងនោះដោយមិនគិតដល់ប្រយោជន៍ផ្ទាល់ខ្លួន។

II

អ្នកជាគ្រហស្ថ

1. ដូចបានស្តីពីលើមកហើយ ដើម្បីនឹងបានជាសាវ័ករបស់ព្រះពុទ្ធ គេត្រូវតែជឿលើរតនៈទាំងបី គឺព្រះពុទ្ធ ព្រះធម៌

ព្រះសង្ឃ។

ដើម្បីបានជាពុទ្ធសាសនិកមួយរូប ត្រូវមានជំនឿជ្រះថ្លាលើព្រះពុទ្ធ ជឿតាមសេចក្ដីទូន្មានរបស់ព្រះអង្គ ហាត់រៀន និងប្រតិបត្តិតាមសេចក្ដីទូន្មាននោះ ហើយបណ្ដុះពង្រីកពុទ្ធិកសហគមន៍។

ពុទ្ធសាសនិក ត្រូវប្រតិបត្តិវិន័យប្រាំគឺៈ មិនសម្លាប់ មិនលួចប្លន់ មិនប្រព្រឹត្តអំពើផិតក្បត់ មិនភូតភរបោកប្រាស់ មិនសេពគ្រឿងស្រវឹង។

ពុទ្ធសាសនិក មិនត្រឹមតែជឿលើរតនៈទាំងបី ប្រតិបត្តិតាមវិន័យទាំងប្រាំ សម្រាប់តែខ្លួនឯងម្នាក់នោះទេ ក្នុងករណីដែលអាចធ្វើបាន គេត្រូវតែចែករំលែកជំនឿនិងកិច្ចប្រតិបត្តិទាំងនោះដល់អ្នកដទៃឯទៀតផង ជាពិសេសដល់មាតាបិតាមិត្តភក្ដិ ដោយខិតខំក្រើនរំលឹកអ្នកទាំងនោះ ឲ្យមានជំនឿជ្រះថ្លាលើព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃ ដើម្បីឲ្យអ្នកទាំងនោះអាចបានរួមទទួលសេចក្ដីមហាករុណាអាសូររបស់ព្រះពុទ្ធជាមួយផង។

ពុទ្ធសាសនិក ត្រូវនឹកគិតជានិច្ចថា វិចារណញ្ញាណដែល

នាំឲ្យខ្លួនមានជំនឿលើរតនៈទាំងបី ហើយប្រតិបត្តិតាមវិន័យទាំងប្រាំគឺ ការអាចនឹងបានសម្រេចពន្លឺត្រាស់ដឹងនៅទីបំផុត។ ហេតុនេះ ទោះបីជារស់នៅក្នុងពិភពដែលពោរពេញទៅដោយចំណង់យ៉ាងនេះក៏ដោយ គេត្រូវតែចៀសវាងកុំបីមានការជាប់ជំពាក់ចិត្ត។

ពុទ្ធសាសនិក ត្រូវគិតជានិច្ចថា យូរឬឆាប់ គេនឹងត្រូវបែកឃ្លាតពីឪពុកម្ដាយគ្រួសារបងប្អូន។ ហេតុនេះ គេមិនត្រូវជាប់ជំពាក់ចិត្តនឹងវត្ថុទាំងឡាយក្នុងជីវិតនេះទេ តែត្រូវបែរចិត្តទៅរកពិភពពន្លឺត្រាស់ដឹង ដែលគ្មានអ្វីត្រូវបានវិនាសបាត់ជាដាច់ខាត។

2. អ្នកដែលស្ដាប់ហើយមានជំនឿជ្រះថ្លាមុតមាំ លើសេចក្ដីទូន្មានរបស់ព្រះពុទ្ធ សេចក្ដីសុខស្ងប់នឹងកើតមានឡើងជាប្រត្យក្សនៅក្នុងចិត្តរបស់គេ សេចក្ដីស្ងប់ដែលជះចេញជាពន្លឺរស្មីទៅគ្រប់អន្លើ ហើយចាំងត្រឡប់មករកខ្លួនគេវិញ។

ចិត្តមានជំនឿជ្រះថ្លាមុតមាំ ជាចិត្តបរិសុទ្ធ ស្ងប់ មានសេចក្ដីអំណត់និងសេចក្ដីក្លាហានជានិច្ច។ ជាចិត្តមិនសន្សំដម្ងោះ

មិនបណ្ដាលទុក្ខទោសដល់អ្នកផងទាំងពួង។ តែផ្ទុយទៅវិញ ជាចិត្តបេះនឹកគិតដល់ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ យ៉ាង នេះ សេចក្ដីសុខស្ងប់នឹងកើតមានឡើងដោយឯកឯងនៅក្នុង ចិត្តដ៏ប្រសើរនោះ ហើយរស្មីនៃពន្លឺត្រាស់ដឹងនឹងត្រូវបាន មើលឃើញនៅសព្វទិសទី។

ដោយសារជំនឿជ្រះថ្លាមុតមាំនេះ ពុទ្ធសាសនិកទាំងឡាយ អាចបានស្ថិតនៅជិតព្រះពុទ្ធ អាចបានចាកផុតពីអត្តទត្តភាព ពីការជាប់ជំពាក់ចិត្តនឹងទ្រព្យសម្បត្តិ។ ដូច្នេះ គេមិនភ័យខ្លាច នឹងជីវិតសព្វថ្ងៃ មិនព្រួយបារម្ភនឹងការនិន្ទាឈ្នានីស។

ដោយគេជឿជាក់ថានឹងបានទៅកើត នៅក្នុងដែនដីព្រះ ពុទ្ធ គេលែងភ័យខ្លាចសេចក្ដីស្លាប់។ ដោយគេជឿលើសេចក្ដី ពិត និងសន្តិភាពនៃពុទ្ធសាសនា គេអាចលាតត្រដាងជំនឿ ជ្រះថ្លារបស់គេនៅមុខប្រជុំជន ដោយសេរី ដោយមិនខ្លាច ញញើត។

ដោយចិត្តរបស់គេបានពោរពេញទៅដោយសេចក្ដីមេត្តា អាសូរចំពោះមនុស្សទូទៅ គេមិនធ្វើការរើកញែកស្រឡាញ់ អ្នកនេះស្អប់អ្នកនោះឡើយ។ ផ្ទុយទៅវិញគេទុកបុគ្គលទាំង

ឡាយក្នុងភាពស្មើគ្នា។ ដោយចិត្តគេបានរួចផុតពីការស្រឡាញ់និងការស្អប់ គេនឹងអាចបំពេញអំពើជាកុសលដោយសុចិភាព សមភាព និងក្តីសប្បាយរីករាយ។

ទោះបីគេរស់នៅក្នុងភាពក្ររហេមរហាមក៏ដោយ ឬក្នុងភាពមានស្តុកស្តម្ភក៏ដោយ ការបណ្តុះបណ្តាលជំនឿជ្រះថ្លាមុតមាំរបស់គេនៅតែចម្រើនទៅមុខជានិច្ច។ គេគោរពប្រណិប័តន៍សេចក្តីទូន្មានរបស់ព្រះពុទ្ធជានិច្ច។ ពាក្យសច្ចានិងការប្រព្រឹត្តិរបស់គេត្រូវបានសមហេតុផល ស្របគ្នាជានិច្ច។ គេយកគតិធម៌ ជាយានសម្រាប់ដឹកនាំគេ។ ចិត្តរបស់គេនឹងនមាំដូចភ្នំគេប្រាថ្នាតែម្យ៉ាងគត់ គឺខំដើរទៅមុខតាមគន្លងនៃពន្លឺត្រាស់ដឹង។

ទោះបីគេត្រូវបានបង្ខំឲ្យរស់ក្នុងស្ថានភាពដ៏ពិបាក នៅក្នុងចំណោមមនុស្សពាលក៏ដោយ ដោយគេមានជំនឿជ្រះថ្លាលើព្រះពុទ្ធ ចិត្តរបស់គេជាចិត្តព្រះពុទ្ធគេនឹងខំពន្យល់ណែនាំជនពាលទាំងនោះឲ្យដើរតាមគន្លងធម៌ ឲ្យទាល់តែបាន។

3. ដូច្នេះ កិច្ចសំខាន់ជាងគេបង្អស់ គឺការប្រាថ្នាចង់ស្តាប់

ប្រតិបត្តិតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធ។

បើមានគេទូន្មានយើងថា ឲ្យដើរឆ្លងកាត់ភ្លើងដើម្បីទៅដល់ពន្លឺត្រាស់ដឹង យើងត្រូវតែមានបំណងនឹងដើរឆ្លងកាត់ភ្លើងនោះ។

ក្នុងលោកដែលមានភ្លើងឆេះសន្ធោសន្ធៅនេះ ការបានស្តាប់ឮព្រះនាមព្រះពុទ្ធ ជាការបានទទួលការស្រោចស្រង់ដ៏ជាទីពេញចិត្ត។

អ្នកដែលប្រាថ្នាស្តាប់ ប្រតិបត្តិតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធ មិនត្រូវមានអត្តទត្តភាពគិតតែពីខ្លួនឯងនោះទេ ត្រូវមានចិត្តបុណ្យចំពោះមនុស្សទូទៅ ក្នុងភាពស្មើៗគ្នា។ គេត្រូវគោរពបុគ្គលដែលគួរគោរព ត្រូវបម្រើបុគ្គដែលគួរបម្រើ ត្រូវទុកបុគ្គលទូទៅក្នុងភាពជាទីស្រឡាញ់ពេញចិត្តស្មើៗគ្នា គឺមិនស្រឡាញ់អ្នកនេះជាងអ្នកនោះ។

គឺតាមរបៀបនេះហើយ ដែលពុទ្ធសាសនិកទាំងឡាយត្រូវចាប់ផ្តើមហាត់បំពត់ចិត្តរបស់ខ្លួន កុំឲ្យមានការសៅហ្មងដោយសារអំពើផ្សេងៗរបស់អ្នកដទៃ។ គឺតាមរបៀបនេះហើយដែលគេទទួលសេចក្តីទូន្មានរបស់ព្រះពុទ្ធ យកមកប្រតិបត្តិ

តាមដោយគ្មានប្រាថ្នាអាក្រក់លើអ្នកឯទៀត ដោយមិនរវល់នឹងពាក្យនិន្ទាពីអ្នកឯទៀត ដោយមិនគិតបែកបែរទៅរកផ្លូវផ្សេងទៀត។

អ្នកដែលមិនជឿព្រះពុទ្ធ មើលឃើញជិត គិតតែពីខ្លួនឯងផ្ទាល់ ជាហេតុបណ្តាលឲ្យចិត្តរបស់គេឡើងជាចង្អៀតចង្អល់មានមន្ទិលសៅហ្មង។ អ្នកដែលជឿព្រះពុទ្ធ ជឿយ៉ាងមុតមាំលើព្រហ្មវិហារធម៌របស់ព្រះពុទ្ធ ដែលគ្របដណ្តប់សត្វលោកទូទៅ ជាហេតុបណ្តាលឲ្យចិត្តរបស់គេបានទូលាយ អស់មន្ទិលសៅហ្មង។

4. អ្នកដែលបានស្តាប់ឮហើយទទួលយកសេចក្តីទូន្មានរបស់ព្រះពុទ្ធ ដឹងថាជីវិតរបស់គេមិនឋិតថេរ រូបកាយរបស់គេជាការប្រមូលផ្តុំនៃទុក្ខ ជាប្រភពនៃកម្មអាក្រក់។ ហេតុនេះ គេអស់មានចិត្តជាប់ជំពាក់នឹងរូបកាយនោះ។

តែនៅពេលជាមួយគ្នានោះ គេមិនត្រូវធ្វេសប្រហែសក្នុងការថែរក្សារូបកាយរបស់គេឡើយ។ គេថែរក្សារូបកាយរបស់គេ មិនមែនក្នុងបំណងបំពេញចំណង់រូបកាយនោះទេ តែដោយសាររូបកាយ ជារបស់ចាំបាច់សម្រាប់ការបានសម្រេច

គតិធម៌ ចាំបាច់សម្រាប់ការបំពេញបេសកកម្មពន្យល់ផ្លូវដល់អ្នកឯទៀត។

បើគេមិនថែរក្សារូបកាយរបស់គេ គេមិនអាចរស់បានយូរទេ។ បើគេរស់មិនបានយូរ គេមិនអាចធ្វើវត្តប្រតិបត្តិពុទ្ធសាសនាឲ្យបានល្អិតល្អន់ទេ គេមិនអាចផ្សាយសាសនានេះឲ្យបានសុសសព្វទេ។

អ្នកដែលប្រុងផ្ទងស្ទឹង គេមើលថែរក្សាក្បូនចម្លងរបស់គេ។ អ្នកដែលប្រុងធ្វើដំណើរផ្លូវឆ្ងាយ គេមើលថែទាំសេះរបស់គេ។ ដូចគ្នានេះ អ្នកដែលប្រាថ្នាឲ្យបានសម្រេចពន្លឺត្រាស់ដឹង គេមើលថែទាំរូបកាយរបស់គេ។

ពុទ្ធសាសនិកទាំងឡាយស្លៀកសម្លៀកបំពាក់ ដើម្បីការពារដំណើរផ្លាស់ប្តូរនៃធាតុអាកាសត្រជាក់ក្តៅ ដើម្បីបិទបាំងកេរខ្មាស មិនមែនដើម្បីលំអរូបកាយទេ។

គេបរិភោគចំណីអាហារសម្រាប់ទ្រទ្រង់រូបកាយ ដើម្បីនឹងបាន ស្តាប់ព្រហើយទទួលយកសេចក្តីទូន្មានរបស់ព្រះពុទ្ធ ហើយពន្យល់ប្រាប់បន្តទៅអ្នកឯទៀត មិនមែនសម្រាប់ការត្រេកត្រអាលទេ។

គេដេកពួនក្នុងផ្ទះក៏ដូច្នោះដែរ គឺដើម្បីការពាររូបកាយរបស់គេ ទប់ទល់នឹងការលុកលុយនៃតណ្ហាលោកិយ ហើយនិងព្យុះសង្ឃរានៃសេចក្ដីទូន្មានអាក្រក់របស់ទមិឡអន្យតិរ្ថីយ៍។ ហេតុនេះ គេត្រូវប្រើប្រាស់ផ្ទះក្នុងគោលបំណងត្រឹមត្រូវពិតប្រាកដ មិនមែនដើម្បីបង្អួតគេ ឬដើម្បីលាក់អំពើអត្តទត្ថរបស់ខ្លួនទេ។

ដូច្នេះ គេត្រូវចេះថ្លឹងតម្លៃនៃវត្ថុទាំងឡាយ ហើយប្រើប្រាស់វាតែនៅក្នុងគោលបំណងសម្រាប់ពន្លឺត្រាស់ដឹង ហើយនឹងសេចក្ដីទូន្មានរបស់ព្រះពុទ្ធ។ គេមិនត្រូវជាប់ជំពាក់នឹងវត្ថុទាំងនោះ ដោយសារតែមានចិត្តអត្តទត្ថនោះឡើយ តែគេត្រូវប្រើប្រាស់របស់អស់នោះជាយាន ដើម្បីបញ្ជូនសេចក្ដីទូន្មានរបស់ព្រះពុទ្ធទៅអ្នកឯទៀត។

ដូច្នេះ គេត្រូវមានចិត្តគិតដល់សេចក្ដីទូន្មានរបស់ព្រះពុទ្ធជានិច្ច ទោះបីគេរស់នៅជាមួយនឹងគ្រួសារក៏ដោយ។ គេត្រូវចេះគ្រប់គ្រងរក្សាគ្រួសាររបស់គេ ដោយគតិធម៌ និងសេចក្ដីស្រឡាញ់ថ្នាក់ថ្នម ហើយរកគ្រប់មធ្យោបាយ ដើម្បីក្រើនរំលឹកសមាជិកទាំងអស់នៃគ្រួសារ ឲ្យបានកើតមានជនឿជ្រះថ្លាលើពុទ្ធឱវាទ។

5. *ពុទ្ធសាសនិកទាំងឡាយ ជារៀងរាល់ថ្ងៃត្រូវគិតដល់កិច្ចដូចតទៅនេះ ៖ តើត្រូវគោរពបម្រើមាតាបិតារបៀបណា? តើត្រូវទំនុកបម្រុងក្រុមគ្រួសាររបៀបណា? តើត្រូវគ្រប់គ្រងខ្លួនឯងរបៀបណា? តើត្រូវគោរពធ្វើតាមព្រះពុទ្ធរបៀបណា?។*

ដើម្បីគោរពបម្រើមាតាបិតាឲ្យបានគាប់ប្រសើរ គេត្រូវរៀនឲ្យចេះមានមេត្តាធម៌ដល់សត្វមានជីវិតទាំងអស់។ ដើម្បីរស់នៅជាមួយប្រពន្ធកូនឲ្យបានសុខសប្បាយ គេត្រូវចេះលះបង់គ្រប់ចំណង់ និងគំនិតចង់បានសុខស្រួលផ្ទាល់ខ្លួន។

ក្នុងពេលបានស្តាប់ឮតន្ត្រីពីរោះនៃជីវិតគ្រួសារ គេមិនត្រូវភ្លេចនឹកដល់តន្ត្រីនៃពុទ្ធសាសនា ដែលរឹតតែស្រទន់ពីរោះជាងនេះទៅទៀត។ ក្នុងពេលបានរស់នៅដោយសុខសាន្តក្នុងជម្រកផ្ទះសម្បែង គេត្រូវគិតជារឿយៗ ដល់ជម្រកនៃពុទ្ធសាសនា ដែលរឹតតែបានសុខជាងនេះទៅទៀត ដែលសន្តបុគ្គលទាំងឡាយ យកជាទីជ្រកពួនការពារសេចក្តីសៅហ្មងហើយនិងសេចក្តីទុក្ខ។

ពុទ្ធសាសនិកទាំងឡាយ កាលណាធ្វើទាន ត្រូវធ្វើដោយ

ស្មោះ ត្រូវកំចាត់សេចក្តីប្រាថ្នាលោភលន់ឲ្យអស់ពីក្នុងចិត្ត។ កាលណា គេនៅកណ្តាលចំណោមមនុស្សគ្រប់ប្រភេទ ចិត្តរបស់គេត្រូវនៅជាមួយនឹងសន្តបុគ្គល។ កាលណាគេជួបប្រទះទុក្ខព្រួយ គេត្រូវរក្សាចិត្តឲ្យស្ងប់ ឲ្យរួចផុតពីឧបសគ្គ។

កាលណាគេជ្រកកោននឹងព្រះពុទ្ធ គេត្រូវប្រាថ្នារកប្រាជ្ញាញាណរបស់ព្រះអង្គ។

កាលណាគេជ្រកកោននឹងព្រះធម៌ គេត្រូវប្រាថ្នារកឲ្យយល់សេចក្តីពិត ដែលធំធេងដូចមហាសមុទ្រប្រាជ្ញាញាណរបស់ព្រះពុទ្ធ។

កាលណាគេជ្រកកោននឹងព្រះសង្ឃ គេត្រូវប្រាថ្នាចែករំលែកសេចក្តីសុខស្ងប់រវាងគ្នានឹងគ្នា ដោយមិនគិតដល់ប្រយោជន៍សម្រាប់តែខ្លួនឯងម្នាក់។

កាលណាគេស្លៀកពាក់ គេមិនត្រូវភ្លេចសំលៀកបំពាក់ជាកុសល និងជាអំពើរាបទាប យកមកស្លៀកពាក់ផងទេ។

កាលណាគេបន្ទោបង់លាមក គេត្រូវប្រាថ្នាឲ្យសេចក្តីលោភលន់ សេចក្តីខឹងក្រោធ សេចក្តីយល់ប្រឡំ បានចេញអស់អំពីចិត្តរបស់គេ។

កាលណាគេប្រឹងឡើងផ្លូវចោត គេត្រូវទុកផ្លូវ នោះជាផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ដែលនាំគេឲ្យបានរួចផុតពីពិភពពោរពេញទៅដោយការបំភាន់ភ្នែក។ កាលណាគេដើរតាមផ្លូវស្រណុកស្រួល គេត្រូវឆ្លៀតយកសេចក្តីស្រណុកស្រួលនេះជាជម្រុលដើម្បីឆាប់បានទៅដល់សភាពព្រះពុទ្ធ។

កាលណាគេឃើញស្ពាន គេត្រូវប្រាថ្នាបង្កើតស្ពានព្រះពុទ្ធសាសនា ដើម្បីឲ្យមហាជនឆ្លង។

កាលណា គេជួបប្រទះនឹងមនុស្សមានទុក្ខវេទនា គេត្រូវមានចិត្តសង្វេគដល់ពិភពលោក ដែលប្រែប្រួលមិនចេះឈប់ឈរនេះ។

កាលណា គេជួបប្រទះនឹងមនុស្សមានសេចក្តីលោភលន់ពេញខ្លួន គេត្រូវប្រាថ្នាយ៉ាងមុតមាំរំដោះខ្លួនគេឲ្យរួចផុតអំពីការបំភាន់ភ្នែកនៃជីវិតលោកិយនេះ ហើយប្រាថ្នាឲ្យបានសម្រេចសម្បត្តិពិតប្រាកដគឺពន្លឺត្រាស់ដឹង។

កាលណាគេឃើញចំណីឈ្ងុយឆ្ងាញ់ គេត្រូវមានការប្រុងប្រយ័ត្ន។ កាលណាគេឃើញចំណីមិនឆ្ងាញ់ គេត្រូវប្រាថ្នាកុំឲ្យសេចក្តីលោភឃ្លានកើតមានដល់គេទៀត។

នៅពេលក្តៅខ្លាំងនាវដូវក្តៅ គេត្រូវប្រាថ្នាឲ្យបានរួចផុតពីក្អក់ក្អើងនៃតណ្ហាលោកិយ ហើយប្រាថ្នាឲ្យបានទទួលភាពត្រជាក់ស្រួលនៃពន្លឺត្រាស់ដឹង។ នៅពេលរងាខ្លាំងនារដូវត្រជាក់ គេត្រូវប្រាថ្នាឲ្យបានទទួលនូវកំដៅឃុំស្រួលនៃព្រហ្មវិហារធម៌របស់ព្រះពុទ្ធ។

កាលណាគេសូត្រគម្ពីរព្រះធម៌ គេត្រូវតាំងចិត្តថាមិនបំភ្លេច ហើយប្រតិបត្តិតាមព្រះធម៌នោះ។

កាលណាគេគិតដល់ព្រះពុទ្ធ គេត្រូវប្រាថ្នាយ៉ាងមុតមាំឲ្យភ្នែករបស់គេបានភ្លឺដូចព្រះពុទ្ធ។

កាលណាគេដេកនាពេលយប់ គេត្រូវប្រាថ្នាឲ្យអង្គកាយវាចា និងចិត្តរបស់គេ បានត្រជាក់បរិសុទ្ធល្អ។ កាលណាគេក្រោកឡើងនាពេលព្រឹកព្រហាម គេត្រូវប្រាថ្នា ជាដំបូងបង្អស់ឲ្យចិត្តរបស់គេបានភ្លឺថ្លាពេញមួយថ្ងៃ ដើម្បីបានយល់ជាក់ច្បាស់នូវវត្ថុទាំងពួង។

6. អ្នកដែលជឿតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធដោយគេយល់ថាអ្វីៗទាំងអស់សុទ្ធតែអត់ខ្លឹមសារ ដូច្នេះគេមិនគិតងាយចំពោះ

វត្ថុទាំងអស់ដែលទាក់ទងនឹងជីវិតមនុស្សលោក។ ផ្ទុយទៅវិញ គេទទួលយកវត្ថុទាំងនោះតាមសភាពរបស់វា ហើយគេខិតខំធ្វើវាឲ្យទៅជាគ្រឿងឧបករណ៍ សម្រាប់ទៅកាន់ពន្លឺត្រាស់ដឹង។

គេមិនត្រូវគិតថាពិភពមនុស្សលោកនេះឥតន័យ ពោរពេញទៅដោយសេចក្តីស្មុកស្មាញច្របូកច្របល់ ហើយគិតស្រមៃថា ពិភពពន្លឺត្រាស់ដឹងពោរពេញទៅដោយអត្ថរស ហើយនិងសេចក្តីសុខសាន្ត។ ផ្ទុយទៅវិញគេត្រូវសម្លឹងគិតទៅផ្លូវពន្លឺត្រាស់ដឹងតាមដោយរឿងទាំងអស់ដែលកើតមានឡើងនៅក្នុងលោកនេះ។

អ្នកដែលក្រឡេកមើលពិភពលោក ដោយភ្នែកល្អក់ស្រវាំងដោយសារសេចក្តីល្ងង់ខ្លៅ នឹងឃើញពិភពលោកនេះប្រកបទៅដោយកំហុស។ ប៉ុន្តែបើគេក្រឡេកមើលពិភពលោកនេះ តាមដោយប្រាជ្ញាភ្លឺថ្លា គេនឹងឃើញពិភពលោកដូចជាពិភពនៃពន្លឺត្រាស់ដឹងតែម្តង។

តាមពិត មានពិភពតែមួយគត់ គ្មានពីរទេ។ គ្មានពិភពមួយឥតន័យ ហើយពិភពមួយទៀតពោរពេញទៅដោយន័យ

នោះទេ។ គ្មានពិភពមួយល្អ ហើយពិភពមួយទៀតអាក្រក់នោះទេ។ គឺដោយសារតែគំនិតវែកញែករបស់មនុស្សលោក ដែលនាំឲ្យគេគិតជានិច្ចថា មានពិភពពីរ។

បើគេអាចលះបង់គំនិតវែកញែកនេះបាន ហើយរក្សាចិត្តឲ្យបានបរិសុទ្ធតាមដោយពន្លឺសតិប្រាជ្ញា នោះគេនឹងឃើញថា មានពិភពតែមួយគត់ ដែលនៅក្នុងនោះអ្វីៗទាំងអស់សុទ្ធតែមានន័យ។

7. អ្នកដែលជឿតាមព្រះពុទ្ធ នឹងបានយល់អំពីភាពបរិសុទ្ធជាសកលតែមួយគ្មានពីរនៃវត្ថុទាំងឡាយ នៅក្នុងលោកនេះ។ ហេតុនេះ គេមានចិត្តប្រកបដោយមេត្តាធម៌ចំពោះមនុស្សទូទៅ ហើយមានចរិយារាបទាបក្នុងការជួយសង្គ្រោះអ្នកផងទាំងពួង។

ដូច្នេះ អ្នកជឿតាមព្រះពុទ្ធ មិនត្រូវមានចិត្តឡឹតប្រកបដោយអភិមានះទេ ត្រូវរក្សាចិត្តរាបទាប បេះគួរសម បេះជួយធុរៈអ្នកឯទៀត។ ចិត្តរបស់គេត្រូវតែឲ្យបានដូចជាដីមានជីជាតិ ដែលទទួលចិញ្ចឹមគ្រប់រុក្ខជាតិ ដោយគ្មានលំអៀងទៅខាង

ណាៗ ចិត្តដែលចេះជួយធុរៈអ្នកឯទៀត ដោយគ្មានការត្អូញត្អែរ ចិត្តដែលចេះស៊ូទ្រាំដោយក្តីអំណត់ ចិត្តដែលត្រង់ទៀងទាត់ជានិច្ច ចិត្តដែលមានសេចក្តីរីករាយជាទីបំផុត ក្នុងការជួយសង្គ្រោះជនកំសត់ទុរគត ហើយបណ្តុះគ្រាប់ពូជនៃសេចក្តីទូន្មានរបស់ព្រះពុទ្ធនៅក្នុងសន្តានចិត្តរបស់អ្នកទាំងនោះ។

ចិត្តដែលប្រកបដោយសេចក្តីអាសូរ ចេះមានមេត្តាធម៌ចំពោះជនកំសត់ទុរគត ទុកដូចជាមាតានៃមនុស្សលោកទាំងអស់ គឺចិត្តចេះគោរពមនុស្សទូទៅ ទុកមនុស្សទូទៅជាមិត្តចេះគោរពមនុស្សទូទៅទុកដូចជាឪពុកម្តាយរបស់ខ្លួន។

ដូច្នេះ ទោះបីជាមានមនុស្សរាប់ម៉ឺននាក់ស្អប់អ្នកកាន់សាសនាព្រះពុទ្ធ ហើយមានបំណងអាក្រក់មកលើពុទ្ធបរិស័ទទាំងនោះក៏ដោយ ក៏មិនអាចបណ្តាលទុក្ខទោសដល់អ្នកទាំងនោះបានឡើយ ព្រោះទុក្ខទោសទាំងនោះដូចជាពិសពុលមួយតំណក់តូច ដែលធ្លាក់ទៅក្នុងមហាសមុទ្រដូច្នោះដែរ។

8. ពុទ្ធសាសនិកទាំងឡាយ នឹងបានក្រេបរសជាតិនៃសុកមង្គល ដោយសារទម្លាប់ចេះនឹកគិតដឹងគុណដល់ព្រះពុទ្ធ។

គេនឹងបានយល់ច្បាស់ថា ជំនឿមុតមាំរបស់គេគឺសេចក្តីករុណាអាសូររបស់ព្រះពុទ្ធតែម្តង ហើយជាអំណោយដែលព្រះពុទ្ធប្រទានមក។

ភក់ជ្រាំនៃតណ្ហាលោកិយ មិនអាចបង្កើតគ្រាប់ពូជនៃជំនឿមុតមាំបានទេ។ ប៉ុន្តែគឺដោយសារសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ ដែលគ្រាប់ពូជនៃជំនឿមុតមាំនោះ អាចកើតមាននៅក្នុងភក់ជ្រាំនៃតណ្ហាលោកិយនោះបាន។ ហើយទីបំផុត គ្រាប់ពូជនៃជំនឿមុតមាំនោះបណ្តាលឲ្យចិត្តបានបរិសុទ្ធរហូតដល់មានជំនឿលើព្រះពុទ្ធ។

ដើមច័ន្ទន៍ ដែលមានក្លិនក្រអូប មិនអាចដុះក្នុងព្រៃឥរន្ធបានទេ។ យ៉ាងណាមិញ គ្រាប់ពូជនៃជំនឿលើព្រះពុទ្ធមិនអាចស្ថិតមាននៅក្នុងពិភព ពេញដោយសេចក្តីភាន់ច្រឡំនោះបានទេ។

តែពេលនេះ ផ្កានៃជំនឿជ្រះថ្លាបានរីកនៅក្នុងទីភក់ជ្រាំនោះដោយពិតៗ។ ចំពោះរឿងនេះ យើងត្រូវសន្និដ្ឋានថា ផ្ការីកនៅកណ្តាលពិភពភាន់ច្រឡំក៏ពិតមែនហើយ តែឫសរបស់វាស្ថិតនៅកន្លែងផ្សេងទៀតទេ ពោលគឺនៅក្នុងចិត្តរបស់ព្រះពុទ្ធនោះឯង។

ពុទ្ធសាសនិកណាបណ្តោយឲ្យមានចិត្តជាអាត្មាអញ គេនឹងមានចិត្តប្រណែននិន្ទា លោភលន់ កាចសាហាវជាមិនខានពីព្រោះ ចិត្តរបស់គេនឹងពោរពេញទៅដោយសេចក្តីលោភលន់ សេចក្តីខឹងក្រោធ សេចក្តីឡឹតឆ្កួតលេលា។ ប៉ុន្តែបើគេបែរទៅរកព្រះពុទ្ធ គឺគេបំពេញកិច្ចធំៗរបស់ព្រះពុទ្ធ ដូចបានរៀបរាប់ពីខាងលើមកហើយ។ តាមពិត កិច្ចទាំងនេះវាហួសពីការអាចបរិយាយបានទៅទៀត។

III

របៀបរស់នៅដោយត្រឹមត្រូវ

1. *ការគិតស្មានថា ទុក្ខទាំងឡាយមកពីទិសខាងកើត ឬទិសខាងលិច ជាការយល់ខុសស្រឡះ។ ទុក្ខទាំងឡាយ កើតមាននៅក្នុងចិត្តរបស់យើងផ្ទាល់តែម្តង។ ហេតុនេះ ជាការឆ្កួតសោះ ដែលខំការពារខ្លួនទប់ទល់នឹងទុក្ខ មកពីខាងក្រៅ ហើយមិនគិតគ្រប់គ្រងចិត្តរបស់ខ្លួនឯងផ្ទាល់។*

មានទម្លាប់ពីបូរាណកាលមួយ ដែលមនុស្សសាមញ្ញទាំងឡាយនៅតែគោរពប្រតិបត្តិនៅឡើយ គឺពេលគេក្រោកពីដេកនៅពេលព្រឹក មុនដំបូងបង្អស់គេលាងមុខ ខ្ពុរមាត់ រួចហើយគេឱនក្រាបឆ្ពោះទៅទិសទាំងប្រាំមួយ គឺទិសខាងកើត ខាងលិច ខាងត្បូង ខាងជើង ខាងលើ ខាងក្រោម សុំកុំឲ្យមានទុក្ខមកពីទិសទាំងនោះ ហើយសុំឲ្យបានប្រកបសេចក្តីសុខពេញមួយថ្ងៃ។

ប៉ុន្តែ កិច្ចនេះខុសនឹងសេចក្តីទូន្មានរបស់ព្រះពុទ្ធ។ ព្រះពុទ្ធប្រដៅយើងឲ្យធ្វើគារវកិច្ចទៅទិសទាំងប្រាំមួយនៃសច្ចធម៌ ហើយឲ្យប្រព្រឹត្តតាមដោយគតិបណ្ឌិត និងគុណធម៌ យ៉ាងនេះយើងនឹងចៀសផុតពីទុក្ខទាំងឡាយ។

ដើម្បីយាមការពារមាត់ទ្វារនៃទិសទាំងប្រាំមួយ បុគ្គលត្រូវបំបាត់ចោលអំពើពុករលួយបួនប្រការ ត្រូវត្រួតពិនិត្យបាបចិត្តបួនប្រការ ត្រូវខ្ទប់រន្ធទាំងប្រាំមួយ ដែលបណ្តាលឲ្យខូចបង់ទ្រព្យសម្បត្តិ។

អំពើលាមកបួនប្រការនោះគឺ កាប់សម្លាប់ លួចប្លន់ ផិតក្បត់ បោកបញ្ឆោត។

បាបចិត្តបួនប្រការនោះគឺ ចិត្តលោភលន់ ចិត្តក្រោធខឹង ចិត្តច្លូតលេលា ចិត្តខ្លាចញញើត។

រន្ធប្រាំមួយដែលបណ្តាលឲ្យខូចបង់ទ្រព្យនោះគឺៈ សេពទឹកស្រវឹង ហើយប្រព្រឹត្តអំពើច្លូតលេលា ដើរលេងយប់ជ្រៅ វក់ក្នុងការកំសាន្តនឹងតន្ត្រីល្ខោន ប្រព្រឹត្តល្បែងភ្នាល់ សេពគប់នឹងបាបមិត្ត ធ្វេសប្រហែសករណីយកិច្ចរបស់ខ្លួន។

ក្រោយពីបានបំបាត់ចោលអំពើពុករលួយទាំងបួន ចៀសវាងបាបចិត្តទាំងបួន ចុករន្ធបំផ្លាញទ្រព្យទាំងប្រាំមួយរួចហើយ ពុទ្ធសាសនិកទាំងឡាយឱនក្រាបធ្វើគារវកិច្ចទៅទិសទាំងប្រាំមួយនៃសច្ចធម៌។

តើទិសទាំងប្រាំមួយនៃសច្ចធម៌នោះជាអ្វីខ្លះទៅ ? ទិសខាងកើតជាផ្លូវសម្រាប់មាតាបិតានិងបុត្រ ទិសខាងត្បូងជាផ្លូវសម្រាប់គ្រូ និងសិស្ស ទិសខាងលិចជាផ្លូវសម្រាប់ស្វាមី និងភរិយា ទិសខាងជើងជាផ្លូវសម្រាប់បុគ្គល និងមិត្ត ទិសខាងក្រោមជាផ្លូវសម្រាប់ចៅហ្វាយ និងខ្ញុំកំដរ ទិសលើជាផ្លូវសម្រាប់អ្នកកាន់ពុទ្ធសាសនា។

កូនត្រូវគោរពឪពុកម្ដាយ បំពេញកិច្ចដែលគាត់សង្ឃឹមចង់បានពីខ្លួន ត្រូវបម្រើគាត់ ជួយធ្វើកិច្ចការគាត់ រក្សាចំណងគ្រួសារ ការពារទ្រព្យសម្បត្តិគ្រួសារ ហើយទីបំផុតត្រូវធ្វើបុណ្យជូនគាត់ នៅពេលគាត់ស្លាប់ទៅ។

មាតាបិតាត្រូវបំពេញកិច្ចប្រាំប្រការចំពោះបុត្រភ្វា គឺចៀសវាងអំពើអាក្រក់ ធ្វើខ្លួនឲ្យបានជាគំរូល្អដល់កូន ផ្ដល់ចំណេះវិជ្ជាដល់កូន រៀបអាពាហ៍ពិពាហ៍ឲ្យកូន ចែកទ្រព្យ

សម្បត្តិឲ្យកូននៅពេលដែលត្រូវចែក។ បើមាតាបិតា និងបុត្រ ប្រតិបត្តិតាមច្បាប់វិន័យនេះ គ្រួសារទាំងមូល នឹងបានរស់នៅក្នុងសុខសន្តិភាពជានិច្ច។

សិស្សត្រូវក្រោកឈរជានិច្ច នៅពេលលោកគ្រូដើរចូលមក ត្រូវគោរពបម្រើលោកគ្រូ ត្រូវស្តាប់បង្គាប់បទបញ្ជាលោកគ្រូ ត្រូវដឹងគុណលោកគ្រូ ត្រូវធ្វើតាមសេចក្តីប្រៀនប្រដៅរបស់លោកគ្រូ ដោយគោរព។

ក្នុងពេលជាមួយគ្នានេះ គ្រូត្រូវធ្វើខ្លួនឲ្យបានត្រឹមត្រូវ ដើម្បីជាគំរូល្អដល់សិស្ស ត្រូវបញ្ជូនចំណេះវិជ្ជា ដែលខ្លួនបានរៀនចេះមក ឲ្យបានត្រឹមត្រូវដល់សិស្ស ត្រូវប្រើប្រាស់មធ្យោបាយត្រឹមត្រូវក្នុងការពន្យល់ណែនាំសិស្ស ហើយខំធ្វើឲ្យសិស្សបានប្រកបកិត្តិយស មិនត្រូវភ្លេចការពារសិស្សទប់ទល់នឹងអំពើអាក្រក់ ក្នុងករណីដែលអាចធ្វើបាន។ បើគ្រូ និងសិស្សប្រតិបត្តិតាមច្បាប់វិន័យនេះ ការរួបរួមគ្នារវាងគ្រូ និងសិស្សនឹងមានដំណើរស្រួល។

ប្តីត្រូវទុកដាក់ប្រពន្ធដោយគោរព ដោយចេះគួរសមដោយមានស្វាមីភក្តិ។ ប្តីត្រូវទុកកិច្ចការក្នុងផ្ទះឲ្យប្រពន្ធហើយ

ពេលខ្វះ ត្រូវបំពេញសេចក្តីត្រូវការរបស់ប្រពន្ធ។ នៅពេលព្រមគ្នានេះ ប្រពន្ធត្រូវចេះខ្វល់ខ្វាយនឹងកិច្ចការក្នុងផ្ទះ ត្រូវចេះប្រើខ្ញុំកំដរដោយគតិធម៌ ត្រូវរក្សាលក្ខណៈសម្បត្តិរបស់ខ្លួនឲ្យបានជាប្រពន្ធល្អ មិនត្រូវខ្ជះខ្ជាយទ្រព្យសម្បត្តិដែលប្តីរកបានមក ត្រូវរៀបចំផ្ទះឲ្យបានស្អាតស្អំ ត្រូវមានចិត្តស្មោះត្រង់។ បើគេប្រតិបត្តិតាមច្បាប់វិន័យនេះ គ្រួសាររបស់គេនឹងបានស្គាល់សេចក្តីសុខ ហើយការឈ្លោះទាស់ទែងគ្នា មិនអាចកើតឡើងបានឡើយ។

ច្បាប់វិន័យរវាងមិត្តនឹងមិត្តគឺ ត្រូវចេះសម្រួបចិត្តគ្នាទៅវិញទៅមក។ អ្នកម្ខាងត្រូវចេះផ្តល់ដល់អ្នកម្ខាងទៀតនូវរបស់ដែលគ្នាខ្វះខាត ត្រូវចេះផ្តល់ប្រយោជន៍ដល់គ្នា ត្រូវប្រើតែវាចាស្មោះគួរជាទីស្រឡាញ់រវាងគ្នា។

គេត្រូវជួយឃិតយោងមិត្តរបស់គេ កុំឲ្យធ្លាក់ទៅក្នុងផ្លូវអាក្រក់។ គេត្រូវការពារទ្រព្យសម្បត្តិមិត្តរបស់គេហើយជួយដោះទុក្ខគ្នា។ បើមិត្តមានគ្រោះកាច គេត្រូវជួយសង្គ្រោះគ្នាហើយជួយទ្រទ្រង់គ្រួសារគ្នាថែមទៀតផង បើសិនជាការចាំបាច់។ យ៉ាងនេះ គេនឹងអាចរក្សាមិត្តភាពរវាងគ្នានឹងគ្នា

ហើយគេនឹងបានស្គាល់សេចក្តីសុខចម្រើនទាំងអស់គ្នាជាលំដាប់។

ចៅហ្វាយត្រូវកាន់វិន័យប្រាំប្រការចំពោះខ្ញុំបម្រើ គឺត្រូវប្រគល់កិច្ចការឲ្យខ្ញុំបម្រើធ្វើទៅតាមសមត្ថភាពរបស់គ្នា ត្រូវឲ្យរង្វាន់ដល់ខ្ញុំបម្រើឲ្យបានសមរម្យ ត្រូវមើលថែរក្សាខ្ញុំបម្រើនៅពេលគ្នាមានជំងឺ ត្រូវចែករំលែករបស់ជាទីគាប់ចិត្តដល់ខ្ញុំបម្រើ ត្រូវអនុញ្ញាតឲ្យខ្ញុំបម្រើបានឈប់សម្រាកតាមត្រូវការ។

ខ្ញុំបម្រើត្រូវកាន់វិន័យប្រាំគឺៈ ត្រូវក្រោកមុនម្ចាស់ហើយដេកក្រោយម្ចាស់ ត្រូវស្មោះត្រង់នឹងម្ចាស់ជានិច្ច ត្រូវខំធ្វើកិច្ចការរបស់ខ្លួនឲ្យបានល្អ ត្រូវខំធ្វើយ៉ាងណាកុំឲ្យម្ចាស់ខូចកិត្តិនាម។ បើគេប្រតិបត្តិតាមច្បាប់វិន័យនេះ គេនឹងបានសុខហើយការទាស់ទែងគ្នារវាងចៅហ្វាយនឹងខ្ញុំបម្រើមិនអាចនឹងកើតឡើងបានឡើយ។

ពុទ្ធសាសនិកទាំងឡាយ ត្រូវជួយជម្រុញឲ្យក្រុមគ្រួសាររបស់ខ្លួនប្រតិបត្តិតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធ។ គេត្រូវចេះគោរព យកចិត្តទុកដាក់នឹងគ្រូអាចារ្យបង្រៀនព្រះធម៌។ គេ

ត្រូវចេះគួរសមនឹងគ្រូអាចារ្យ។ គេត្រូវស្តាប់បង្គាប់ប្រតិបត្តិតាមសេចក្តីប្រៀនប្រដៅរបស់គ្រូអាចារ្យ ហើយដឹងគុណលោកជានិច្ច។

គ្រូអាចារ្យអ្នកបង្រៀនព្រះធម៌ ត្រូវយល់ព្រះធម៌ឲ្យបានត្រឹមត្រូវ ត្រូវចៀសវាងការបកស្រាយខុស ត្រូវពន្យល់បញ្ជាក់អំពីអំពើល្អ ត្រូវខំដឹកនាំអ្នកមានជំនឿលើសាសនាឲ្យដើរតាមផ្លូវល្អ។ កាលណាបើក្រុមគ្រួសារណាមួយដើរតាមផ្លូវល្អនេះ ហើយជឿទុកចិត្តលើសេចក្តីទូន្មានពិតប្រាកដ ក្រុមគ្រួសារនោះនឹងបានប្រកបសុភមង្គល។

អ្នកដែលឱនក្រាបធ្វើគារវកិច្ចទៅទិសទាំងប្រាំមួយ គឺមិនមែនដើម្បីឲ្យបានរួចផុតពីទុក្ខ ដែលមកពីខាងក្រៅនោះទេ។ គេប្រព្រឹត្តយ៉ាងនេះ ជាការប្រុងប្រយ័ត្ន ដើម្បីការពារខ្លួនទប់ទល់នឹងបាបកម្ម ដែលប្រុងនឹងកើតមាននៅក្នុងចិត្តរបស់គេផ្ទាល់។

2. បុគ្គលរាល់រូប ត្រូវចេះមើលមនុស្សដែលគួរសេពគប់ និងមនុស្សដែលមិនគួរសេពគប់។

មនុស្សដែលមិនគួរសេពគប់គឺ មនុស្សលោភ និយាយច្រើន បញ្ឆោត បង្កិនបង្ហោច។

មនុស្សដែលគួរសេពគប់គឺ មនុស្សចេះជួយគ្នា មនុស្សមានចិត្តចេះចែករំលែកសេចក្តីសប្បាយ និងសេចក្តីព្រួយរវាងគ្នានឹងគ្នា មនុស្សចេះឲ្យដំបូន្មានល្អដល់គ្នា មនុស្សមានចិត្តជាមិត្ត។

មិត្តពិតប្រាកដ ដែលអាចសេពគប់បាន តែងតែដើរតាមគន្លងផ្លូវសុចរិតជានិច្ច។ គេមានចិត្តចង់ឲ្យតែមិត្តរបស់គេ បានប្រកបសុភមង្គល គេចេះលួងលោមសម្រាលទុក្ខមិត្ត ចេះជួយមិត្តនៅពេលមានធុរៈ ចេះលាក់ការសម្ងាត់របស់មិត្ត ចេះឲ្យដំបូន្មានល្អដល់មិត្ត។

មិត្តរបៀបនេះ ពិបាករកណាស់ ដូច្នេះត្រូវតែខំប្រឹងខ្លួនឯងឲ្យបានទៅជាមិត្តរបៀបនេះ។ ដូចជាព្រះអាទិត្យកំដៅដីមានជីជាតិ មិត្តល្អក្លីចែងចាំងនៅក្នុងសង្គម ដោយសារអំពើល្អរបស់គេ។

3. ចំពោះសេចក្តីស្រឡាញ់ថ្នាក់ថ្នមបីបាច់ថែរក្សា ដែលមាតា

បិតាមានទៅលើបុត្រ បុត្រមិនអាចសងគុណរួចទេទោះបីជាគេអាចបញ្ជិះឪពុកលើស្មាស្តាំ ហើយបញ្ជិះម្តាយលើស្មាឆ្វេងរបស់គេ រាប់រយឆ្នាំក៏ដោយ។

ទោះបីជាគេអាចផ្ងូតទឹកមាតាបិតា ដោយទឹកអប់ផ្កាក្រអូបអស់រាប់រយឆ្នាំក៏ដោយ។ ទោះបីជាគេអាចបម្រើគាត់ក្នុងភាពជាកូនល្អឥតខ្ចោះក៏ដោយ ទោះបីជាគេអាចធ្វើឲ្យគាត់បានសោយរាជ្យជាស្តេចផែនដីក៏ដោយ ទោះបីជាគេអាចយកសម្បត្តិទាំងពិភពលោកមកជូនគាត់ដ៏ដោយ ក៏គេមិនអាចសងបំណុលគាត់ឲ្យបានគ្រប់គ្រាន់ដែរ។

ប៉ុន្តែ បើគេដឹកនាំឪពុកម្តាយគេឆ្ពោះទៅរកព្រះពុទ្ធពន្យល់គាត់ឲ្យជឿសាសនាព្រះពុទ្ធ បញ្ចុះបញ្ចូលគាត់ឲ្យវៀរចាកផ្លូវអាក្រក់ហើយដើរតាមផ្លូវត្រូវ ដឹកនាំគាត់ឲ្យលះបង់ការលោភលន់ ហើយឲ្យគាត់ចេះសប្បាយរីករាយ ក្នុងការធ្វើទានកុសលនោះគេអាចសងបំណុលគាត់រួចជាពិតប្រាកដ។

4. គ្រួសារគឺជាកន្ទែងមួយ ដែលចិត្តប្រជុំទាក់ទងគ្នា។ បើចិត្ត ចេះស្រឡាញ់រូបរួមគ្នា គ្រួសារនឹងបានល្អប្រិមប្រិយដូចជាសួនដែលមានបុប្ផារីកស្គុសស្គាយ។ ប៉ុន្តែបើចិត្តមិនចូល

សម្រុងគ្នាទេ គឺដូចជាខ្យល់ព្យុះដែលបក់រំលើងសួនឧទ្យាន។

បើមានការទាស់ទែងគ្នា កើតឡើងក្នុងគ្រួសារ មិនត្រូវដាក់កំហុសទៅអ្នកក្រៅទេ ត្រូវពិនិត្យកែតម្រង់ចិត្តរបស់ខ្លួនឯងផ្ទាល់។

5. ក្នុងបូរាណកាលដ៏យូរលង់មកហើយ មានបុរសម្នាក់មានជំនឿក្នុងសាសនាយ៉ាងមុតមាំ។ ឪពុកបានស្លាប់ចោលទៅតាំងពីបុរសនោះនៅក្មេងវ័យ។ បុរសរស់នៅតែពីរនាក់នឹងម្ដាយដោយសុខសាន្ត។ ក្រោយមក បុរសក៏មានប្រពន្ធ។

មុនដំបូង គ្រួសារនេះរស់នៅជាមួយគ្នាដោយសុខសាន្ត តែបន្ទាប់មក ដោយហេតុទាស់សម្ដីគ្នាបន្តិចបន្តួច ប្រពន្ធនឹងម្ដាយក្មេក ក៏ទៅជាស្អប់គ្នាទៅវិញទៅមក។ ការស្អប់គ្នានេះរីកធំឡើងៗ រហូតដល់ទីបំផុត ម្ដាយបានចាកចេញពីគូស្រករក្មេងនេះទៅរស់នៅតែម្នាក់ឯងទៅ។

ក្រោយពីម្ដាយក្មេកចេញបាត់ទៅ គូស្រករក្មេងនោះបានកូនប្រុសមួយ។ ប្រពន្ធក្មេងតែងតែ រំលឹកនិយាយសម្អប់ពីម្ដាយក្មេកថា: «ម៉ែ គាត់អំពល់ទុក្ខយើងគ្រប់ពេលវេលា។

ពេលដែលគាត់នៅជាមួយយើង យើងមិនដែលបានសប្បាយម្ដងណាទេ។ គ្រាន់តែគាត់ចេញទៅបាត់បានបន្តិច យើងបានសប្បាយដោយបានកូនប្រុសមួយយ៉ាងនេះ»។

ពាក្យនិយាយសម្ពប់នេះ បានឮទៅដល់ម្ដាយក្មេក។ គាត់ខឹងជាខ្លាំង ហើយថ្លែងថា: «ការបណ្ដេញម្ដាយក្មេកឲ្យចាកចេញពីផ្ទះ ត្រូវបានបណ្ដាលឲ្យមានព្រឹត្តិការណ៍ដ៏ជាទីសប្បាយរីករាយយ៉ាងនេះ ឃើញថាលោកនេះ វាត្រឡប់ត្រឡិនអស់ហើយ ! ភាពត្រឹមត្រូវតាមគន្លងធម៌ ត្រូវបានវិនាសសូន្យពីលោកនេះហើយ !»។

«នៅពេលនេះ យើងគួរតែធ្វើបុណ្យ បញ្ជូនកុសលឲ្យខ្មោចនៃភាពត្រឹមត្រូវតាមគន្លងធម៌នេះ!»។ ដូចជាស្រីឆ្កួតម្ដាយក្មេកដើរតម្រង់ទៅផ្នូរខ្មោច ដើម្បីធ្វើបុណ្យបញ្ជូនកុសលដល់ខ្មោចនៃភាពត្រឹមត្រូវតាមគន្លងធម៌។

ព្រះឥន្ទ្រទ្រង់ជ្រាបរឿងនេះ ក៏ចុះមកប្រត្យក្សនៅមុខម្ដាយក្មេក ហើយសាកល្បងពន្យល់គាត់ គ្រប់បែបយ៉ាងតែជាការឥតប្រយោជន៍។

ព្រះឥន្ទ្រ ក៏មានព្រះបន្ទូលថា: «បើអញ្ចឹង យើងផុត ទារកនិងម្ដាយវាឲ្យស្លាប់បង់។ យើងធ្វើដូច្នេះ តើអ្នកពេញចិត្ត ឬទេ?»។

នៅពេលឮព្រះឥន្ទ្រមានព្រះបន្ទូលដូច្នេះ ម្ដាយក្មេកក៏ ភ្ញាក់រលឹកដឹងកំហុសរបស់ខ្លួន ហើយក្រាបសំពះសុំទោសព្រះ ឥន្ទ្រអង្វរសុំឲ្យទុកជីវិតឲ្យទារកនិងម្ដាយ។ ក្នុងខណៈនោះដែរ ឯខាងប្រពន្ធប្ដី ក៏ភ្ញាក់រលឹកយល់នូវអំពើអយុត្តិធម៌របស់ខ្លួន ចំពោះម្ដាយចាស់ ហើយនាំគ្នាទៅរកគាត់ដល់ផ្នូរខ្មោច។ ព្រះ ឥន្ទ្រក៏ផ្សះផ្សាអ្នកទាំងនោះ។ បន្ទាប់ពីពេលនោះមកអ្នកទាំង នោះក៏បានរស់នៅជាមួយគ្នា ដោយសុខសាន្ត។

ភាពត្រឹមត្រូវតាមគន្លងធម៌ មិនវិនាសបាត់រហូតទេ បើគេ មិនបាត់សតិរបស់គេផ្ទាល់។ ចួនកាល ភាពត្រឹមត្រូវតាមគន្លង ធម៌នេះហាក់ដូចជាវិនាសបាត់ទៅ តែតាមពិត វាមិនដែល វិនាសបាត់ទេ។ កាលណាភាពត្រឹមត្រូវតាមគន្លងធម៌នេះ ហាក់ដូចជាវិនាសបាត់ គឺដោយសារតែយើងត្រូវបាត់បង់ភាព ត្រឹមត្រូវនៃសតិរបស់យើងផ្ទាល់នោះឯង។

ចិត្តមិនស្របគ្នា បណ្ដាលឲ្យកើតមានភយន្តរាយ ជាញឹកញយ។ ការទាស់ទែងគ្នាជាធម្មតាតូចមួយ អាចនាំឲ្យមានទុក្ខធំ។ គេត្រូវប្រយ័ត្នជានិច្ច ចៀសវាងនូវការទាស់ចិត្តគ្នានេះ នៅក្នុងជីវិតគ្រួសារ។

6. ក្នុងជីវិតគ្រួសារ បញ្ហាចាយវាយជារឿងរាល់ថ្ងៃត្រូវចេះគិតគូរលៃលកឲ្យបានហ្មត់ចត់ជាទីបំផុត។ សមាជិកគ្រួសារម្នាក់ៗត្រូវខំធ្វើការឲ្យម៉ឺងម៉ាត់ ដូចជាសត្វស្រមោចដែលរវៀសរវៃ សត្វឃ្មុំដែលរវល់ជានិច្ច។ អ្នកណាក៏ដោយ មិនត្រូវដេកពឹងកម្លាំងអ្នកឯទៀតទេ មិនត្រូវសង្ឃឹមលើអំណោយទានពីអ្នកឯទៀតទេ។

ម្យ៉ាងទៀត គេមិនត្រូវគិតទុករបស់ ដែលរកបានមកសម្រាប់តែខ្លួនឯងម្នាក់ទេ។ គេត្រូវចេះចែករំលែកមួយភាគឲ្យទៅអ្នកឯទៀត ទុកមួយភាគសម្រាប់ពេលខ្វះខាត ទុកមួយភាគសម្រាប់ការត្រូវការនៃសង្គម ហើយទុកមួយភាគទៀតសម្រាប់ធ្វើបុណ្យទាន។

គេត្រូវរំលឹកគិតជានិច្ចថា នៅក្នុងលោកនេះ គ្មានអ្វីដែលអាចហៅបានថាជារបស់ឯកសិទ្ធិ សម្រាប់តែខ្លួនឯងម្នាក់នោះបានទេ។ អ្វីក៏ដោយ ដែលគេរកបានមក សុទ្ធតែជារបស់ដែលកើតមកអំពីការផ្សំបញ្ចូលគ្នានៃហេតុនិងល័ក្ខខ័ណ្ឌ។ គេអាចរក្សាទុករបស់នោះ បានតែក្នុងមួយរយៈវេលាប៉ុណ្ណោះ។ ហេតុដូច្នេះ គេមិនត្រូវប្រើប្រាស់របស់នោះ ដោយមានចិត្តគិតទុកសម្រាប់តែខ្លួនឯងម្នាក់ ឬក្នុងគោលបំណងអាក្រក់មិនសមរម្យនោះទេ។

7. នៅពេលដែលព្រះនាង **សាមាវតី** ព្រះអគ្គមហេសីព្រះបាទ **ឧទេន** ទ្រង់ប្រទានស្បង់ប្រាំរយដល់**ព្រះអានន្ទ** **ព្រះអនន្ទ**ទ្រង់ទទួលយកដោយព្រះទ័យត្រេកអរជាទីបំផុត។

ព្រះមហាក្សត្រ នៅពេលបានជ្រាបរឿងនេះ ទ្រង់មានការសង្ស័យទៅលើ**ព្រះអានន្ទ**ថាមិនស្មោះត្រង់ព្រះអង្គក៏ត្រាស់សួរ**ព្រះអានន្ទ**ថា តើយកស្បង់ទាំងប្រាំរយនោះទៅធ្វើអ្វី?។

ព្រះអានន្ទឆ្លើយថា: «សូមព្រះមហាក្សត្រជ្រាប! ភិក្ខុសង្ឃ

ជាច្រើន ស្បៀកស្បង់រហែករយ៉ុរយ៉ៃ។ ទូលព្រះបង្គំយកស្បង់ទាំងនេះ ទៅចែកពួកភិក្ខុសង្ឃនោះ»។

«តើអ្នកយកស្បង់ចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកស្បង់ចាស់ទៅធ្វើកម្រាលគ្រែដេក»

«តើអ្នកយកកម្រាលចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកកម្រាលចាស់ទៅធ្វើខ្នើយកើយ»

«តើអ្នកយកខ្នើយចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកខ្នើយចាស់ទៅធ្វើកម្រាលរនាបក្តារ»

«តើអ្នកយកកម្រាលរនាបចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកកម្រាលរនាបចាស់ទៅធ្វើកន្ទបជូតជើង»

«តើអ្នកយកកន្ទបជូតជើងចាស់ទៅធ្វើអ្វី ?»

«យើងខ្ញុំយកកន្ទបជូតជើងចាស់ទៅធ្វើកន្ទបជូតរនាប»

«តើអ្នកយកកន្ទបជូតរនាបចាស់ទៅធ្វើអ្វី ?»

«ព្រះករុណាតម្កល់លើត្បូង! យើងខ្ញុំហែកកន្ទបជូតរនាបចាស់នោះជាចំណែកតូចៗ យកទៅលាយនឹងភក់ ហើយយកទៅបូកជញ្ជាំងកុដិ»។

វត្ថុនីមួយៗ ដែលយើងបានមក យើងត្រូវចេះប្រើប្រាស់វា

ដោយផ្ចិតផ្ចង់ ឲ្យបានជាប្រយោជន៍ ពីព្រោះវត្ថុនោះមិនមែនជារបស់យើងរហូតទេ យើងបានវាមកជាបណ្ដោះអាសន្នតែប៉ុណ្ណោះ។

8. ដំណើររួមរស់នៃគូស្វាមីភរិយា មិនមែនសម្រាប់តែសេចក្ដីសុខស្រួល ទាំងផ្លូវកាយទាំងផ្លូវចិត្ត នៅក្នុងផ្ទះមួយជាមួយគ្នាតែប៉ុណ្ណោះទេ។ គូស្វាមីភរិយា ត្រូវបេះឆ្មៀតទាញយកប្រយោជន៍អំពីភាពស្និទ្ធស្នាលនៃការរួមរស់ជាមួយគ្នានេះ ជួយណែនាំគ្នាឲ្យបណ្ដុះបណ្ដាលចិត្តមានជំនឿជ្រះថ្លាក្នុងព្រះសាសនា។

មានស្វាមីភរិយាចំណាស់មួយគូ ដែលជាប់ឈ្មោះថាជាគូស្វាមីភរិយាឧត្ដម បានទៅថ្វាយបង្គំព្រះពុទ្ធ ហើយទូលសួរថា «ព្រះពុទ្ធជាម្ចាស់ ! យើងខ្ញុំព្រះករុណាបានគ្នាជាប្ដីប្រពន្ធក្រោយពេលដែលបានស្គាល់គ្នាតាំងពីនៅក្មេងដូចគ្នា ហើយយើងខ្ញុំស្គាល់តែសេចក្ដីសុខ ពុំដែលមានរឿងសៅហ្មងនឹងគ្នាម្ដងណាទេ។ សូមព្រះអង្គមេត្តាពន្យល់ប្រាប់យើងខ្ញុំផង តើយើងខ្ញុំត្រូវធ្វើយ៉ាងណា ដើម្បីអាចនឹងបានជួបគ្នាទៀត នៅជាតិក្រោយ»។

ព្រះពុទ្ធ ទ្រង់មានពុទ្ធដីកាប្រកបដោយគតិបណ្ឌិតថាៈ «បើអ្នកទាំងពីរមានជំនឿសាសនាដូចគ្នាបេះបិទ បើអ្នកទាំងពីរទទួលយកសេចក្ដីទូន្មាននៃព្រះពុទ្ធសាសនាតាមរបៀបដូចគ្នាបេះបិទ បើអ្នកទាំងពីរសាងកុសលទានដូចគ្នា ហើយបានប្រកបនូវបុណ្យបារមីដូចគ្នា ទៅជាតិក្រោយទៀតអ្នកទាំងពីរនឹងបានប្រកបដោយចិត្តដូចគ្នាទៀតជាមិនខាន»។

9. ចំពោះផ្លូវទៅកាន់ពន្លឺត្រាស់ដឹង គ្មានការប្រកាន់ភេទស្រីឬប្រុសទេ។ ស្ត្រីក៏ដោយ កាលណាមានចិត្តស្វែងរកពន្លឺត្រាស់ដឹង នឹងបានជាវីរនារីមួយរូបនៃភាពបរិសុទ្ធនេះ។

ព្រះនាង**មល្លិកា** បុត្រីស្ដេច**ប្រសេនជិត** និងជាអគ្គមហេសីព្រះរាជាអយុធ្យា ជាវីរនារីមួយរូប។ ព្រះនាងមានជំនឿមុតមាំនឹងព្រះពុទ្ធសាសនា ព្រះនាងបានធ្វើសច្ចាធិដ្ឋានជប់ប្រការនឹងព្រះពុទ្ធ ដូចតទៅនេះៈ

«ព្រះពុទ្ធជាម្ចាស់ ! រហូតដល់នាងខ្ញុំបានសម្រេចនូវពន្លឺត្រាស់ដឹង នាងខ្ញុំនឹងមិនប្រព្រឹត្តរំលងនឹងធម្មវិន័យឡើយ

នាងខ្ញុំនឹងមិនក្រអឺតក្រអោងនឹងអ្នកមានវ័យច្រើនជាងនាងខ្ញុំ នាងខ្ញុំនឹងមិនខឹងនឹងអ្នកណាម្នាក់ឡើយ»។

«នាងខ្ញុំនឹងមិនច្រណែនឫស្យានឹងអ្នកឯទៀត ហើយមិនប្រាថ្នាចង់បានទ្រព្យសម្បត្តិអ្នកទាំងនោះឡើយ។ នាងខ្ញុំនឹងមិនប្រកាន់ចិត្តអត្តទត្តឡើយ។ នាងខ្ញុំនឹងខំធ្វើឲ្យអ្នកក្រីក្របានសប្បាយរីករាយ ដោយប្រើប្រាស់វត្ថុទាំងឡាយដែលនាងខ្ញុំមាន ហើយនាងខ្ញុំនឹងមិនប្រាថ្នាប្រមូលរបស់អស់ទាំងនោះទុកសម្រាប់តែខ្លួននាងខ្ញុំម្នាក់ឡើយ។

«នាងខ្ញុំនឹងទទួលមនុស្សគ្រប់ចំពូក ដោយរាក់ទាក់គួរសម នឹងធ្វើទាននូវវត្ថុទាំងឡាយណាដែលអ្នកទាំងនោះត្រូវការជាចាំបាច់។ នាងខ្ញុំនឹងរាប់អានអ្នកទាំងនោះដោយស្មោះនាងខ្ញុំនឹងខំប្រព្រឹត្តល្អចំពោះអ្នកទាំងនោះ ដោយមិនលំអៀងទៅខាងណាមួយឡើយ»។

«បើនាងខ្ញុំឃើញអ្នកណាម្នាក់រស់នៅក្នុងភាពកំព្រាឯកាក្នុងពន្ធនាគារ ឬក្នុងភាពមានទុក្ខដោយជំងឺ ឬដោយការព្រួយបារម្ភផ្សេងទៀត នាងខ្ញុំនឹងខិតខំជួយអ្នកនោះ ឲ្យបានសប្បាយ

រីករាយ ដោយពន្យល់អ្នកនោះ ឲ្យយល់នូវហេតុ និងច្បាប់វិន័យ»។

«បើនាងខ្ញុំឃើញអ្នកណាម្នាក់ ចាប់សត្វយកមកធ្វើបាប ឬប្រព្រឹត្តបំពាននឹងច្បាប់វិន័យ នាងខ្ញុំនឹងធ្វើទោសអ្នកនោះ បើសិនជាអ្នកនោះសមតែទទួលទោស នាងខ្ញុំនឹងស្តីប្រដៅ បើសិនជាអ្នកនោះសមត្រឹមតែទទួលការប្រៀនប្រដៅ ហើយនាងខ្ញុំនឹងខិតខំកែកំហុសអ្នកនោះ យ៉ាងអស់សមត្ថភាពនាងខ្ញុំ»។

«នាងខ្ញុំនឹងមិនភ្លេចស្តាប់សេចក្តីទូន្មានត្រឹមត្រូវ ដោយនាងខ្ញុំដឹងថា បើគេធ្វេសប្រហែសសេចក្តីទូន្មានត្រឹមត្រូវ គេនឹងឃ្លាតចាកពីសេចក្តីពិតយ៉ាងឆាប់រហ័ស ហើយយ៉ាងនេះគេមុខតែមិនបានសម្រេចពន្លឺត្រាស់ដឹងជាពិតប្រាកដ»។

បន្ទាប់មកទៀត ព្រះនាងបានធ្វើសច្ចាធិដ្ឋានបីប្រការដើម្បីជួយសង្គ្រោះអ្នកក្រីក្រ។ «ទីមួយ នាងខ្ញុំនឹងខំធ្វើឲ្យជនទាំងអស់បានសុខសន្តិភាព។ នាងខ្ញុំជឿថា ទៅមុខទៀតនាងខ្ញុំមានជីវិតបែបណាក៏ដោយ ក៏សេចក្តីប្រាថ្នានេះនឹងបានជាឫសនៃកុសលសម្រាប់ការបានត្រាស់ដឹងនូវធម៌វិសុទ្ធ»។

«ទីពីរ កាលណានាងខ្ញុំបានទទួលការត្រាស់ដឹងនូវធម៌វិសុទ្ធនេះហើយ នាងខ្ញុំនឹងយកទៅពន្យល់អ្នកឯទៀត ដោយមិនគិតដល់ការនឿយហត់របស់នាងខ្ញុំឡើយ»។

«ទីបី នាងខ្ញុំនឹងរក្សាការពារធម៌វិសុទ្ធនេះ ទោះបីនាងខ្ញុំត្រូវបូជារូបកាយ ជីវិត ឬទ្រព្យសម្បត្តិរបស់នាងខ្ញុំ ក៏ដោយ»។

*ន័យពិតនៃជីវិតគ្រួសារគឺ ឱកាស ដែលសមាជិកគ្រួសារម្នាក់ៗ ជួយជំរុញគ្នា ជ្រោមជ្រែងគ្នាក្នុងដំណើរផ្លូវទៅកាន់ពន្លឺត្រាស់ដឹង។ ស្ត្រីប្រភេទណាក៏ដោយ ក៏អាចបានជាសាវ័កវិសេសវិសាល របស់ព្រះពុទ្ធ ដូចជាព្រះនាង**មល្លិកា**ដែរ បើសិនស្រីនោះមាន ប្រាជ្ញាស្វែងរកពន្លឺត្រាស់ដឹងដូចព្រះនាង ហើយធ្វើសច្ចាធិ-ដ្ឋានដូចព្រះនាង។*

ចំពូកទី ២

កសាងដែនដីព្រះពុទ្ធ

I

ភាពសុខដុមនៃសហគមន៍ពុទ្ធសាសនិក

1. *ចូរយើងនឹកស្មានមើលទៅក្នុងសមុទ្រខ្សាច់មួយដែលធ្លាក់ក្នុងភាពងងឹតស្លុង ហើយមានមនុស្សជាច្រើនវង្វេងវិលវល់មើលអ្វីពុំឃើញ នៅក្នុងទោនោះ។*

ជាធម្មតា មនុស្សទាំងនោះនឹងមានការភ័យភិត រុញច្រានគ្នាទៅវិញទៅមក ដោយមិនស្គាល់គ្នាឡើយ។ មនុស្សទាំងនោះដើរប្រវេប្រវាលែងចេះឈប់ វង្វេងវង្វាន់គ្នាទៅដោយខ្លួនទីទៃៗ។ គឺពិតជាទិដ្ឋភាពមួយសែនវេទនា។

នៅពេលនោះ មានវីរបុរសម្នាក់ កាន់ចន្លុះមួយនៅដៃ បញ្ចេញខ្លួនឲ្យឃើញឡើង បណ្ដាលឲ្យភ្លឺគ្រប់ទិសទី។

មនុស្សម្នាទាំងឡាយ ដែលមកទល់ពេលនេះ ប្រវេប្រវារស្ទាបក្នុងទីងងឹត ក៏បានភ្លឺស្វាងឡើង ហើយក្រឡេកមើលជុំ

វិញខ្លួន។ គេសម្គាល់ឃើញមានមនុស្សដូចគេដែរនៅជុំវិញគេ គេក៏ស្រែកហ៊ោសប្បាយរត់ទៅឱបគ្នា ហើយនិយាយកាន់គ្នាទៅវិញទៅមកដោយភាពស្និទ្ធស្នាល។

សមុទ្រខ្សាច់នោះ គ្មានអ្វីក្រៅពីជីវិតមនុស្សលោកនេះទេ។ ភាពងងឹតគឺសេចក្ដីល្ងង់ខ្លៅនោះឯង។ មនុស្សដែលគ្មានពន្លឺគតិបណ្ឌិតនៅក្នុងចិត្ត ត្រូវបានវង្វេងវង្វាន់នៅក្នុងសភាពតែលតោលម្នាក់ឯង និងក្នុងសភាពភ័យភិត។ មនុស្សទាំងនោះ កើតមកម្នាក់ឯង ហើយស្លាប់ទៅវិញម្នាក់ឯង។ មនុស្សទាំងនោះ មិនចេះស្គាល់គ្នាទេ មិនចេះរស់នៅដោយសុខដុមទេ ហើយជាធម្មតា គេរស់នៅក្នុងភាពភ័យភិតនិងភាពអស់សង្ឃឹម។

វីរបុរសកាន់ចន្លុះ គឺព្រះពុទ្ធដំណែងខ្លួនជាមនុស្សលោក ចុះមកបំភ្លឺពិភពលោកដោយប្រាជ្ញាញាណ និងសេចក្ដីអាសូររបស់ព្រះអង្គ។

មនុស្សលោកដែលត្រូវបានបំភ្លឺដោយពន្លឺនេះ អាចមើលឃើញខ្លួនឯងល្អដូចគេឯទៀតដែរ ហើយកើតមានចិត្តសប្បាយរីករាយក្នុងការបង្កើតសហគមន៍ និងការទាក់ទងគ្នាដោយ

ភាពសុខដុម។

មនុស្សរាប់លាននាក់អាចរស់នៅជាមួយគ្នាបាន តែគេមិនអាចរួបរួមគ្នាជាសហគមន៍បានទេ ដរាបណាគេមិនស្គាល់គ្នាទៅវិញទៅមកដោយសមានចិត្ត។

នៅក្នុងសហគមន៍ពិតប្រាកដ តែងតែមានពន្លឺនៃជំនឿទុកចិត្តនិងគតិបណ្ឌិត ចែងចាំងព្រោងព្រាយ។ សហគមន៍ពិតប្រាកដជាទីកន្លែងដែលជនទាំងឡាយចេះស្គាល់គ្នា ជឿទុកចិត្តគ្នាទៅវិញទៅមក ហើយរស់នៅជាមួយគ្នាដោយសុខដុម។

ភាពសុខដុម គឺជាជីវិត ជាគោលបំណងពិតនៃសហគមន៍ពិតប្រាកដទាំងឡាយ។

2. មានសហគមន៍បីប្រភេទ គឺ: ទី១ សហគមន៍ដែលកើតឡើងដោយអានុភាពទ្រព្យសម្បត្តិ ឬអំណាចនៃមេកើយធំ។

ទី២ គឺក្រុមបក្សដែលបង្កើតឡើងដោយបុគ្គលមានភាពត្រូវគ្នា។ ក្រុមបក្សរបៀបនេះអាចគង់វង្សបាន ដរាបណាសមាជិកទាំងអស់យល់ព្រមចិត្តគ្នាទៅវិញទៅមក ហើយមិនឈ្លោះប្រកែកគ្នា។

ទី៣ គឺសហគមន៍ដែលកកើតឡើងអំពីសិក្ខាបទល្អ សហ-គមន៍ដែលយកភាពសុខដុមជាគោលការណ៍ សម្រាប់គង់នៅឋិតថេរ។

ប្រាកដណាស់ ក្នុងចំណោមក្រុមបក្ស ទាំងបីប្រភេទនេះ មានតែក្រុមបក្សប្រភេទទី៣ទេ ដែលពិតប្រាកដ។ សមាជិកទាំងអស់នៃក្រុមបក្សប្រភេទនេះ រស់នៅដោយមានចិត្តដូចគ្នា។ ការចេះរស់នៅដោយមានចិត្តស្របគ្នានេះ បណ្ដាលឲ្យភាពស្រុះស្រួលគ្នា និងគុណធម៌គ្រប់ចំពូក បានរីកលូតលាស់ ហើយសេចក្ដីសុខ សេចក្ដីសប្បាយ សេចក្ដីពេញចិត្ត សុភ-មង្គល ក៏នឹងអាចកើតឡើងបានទៅតាមនោះ។

ពន្លឺត្រាស់ដឹងពេញលេញ ប្រដូចបានទៅនឹងទឹកភ្លៀង ដែលធ្លាក់លើកំពូលភ្នំ បង្កើតបានជាអូរ ជាស្ទឹង រួចហើយជាទន្លេធំ ហូរធ្លាក់ទៅក្នុងមហាសមុទ្រនៅទីបំផុត។

ភ្លៀងនៃព្រះសាសនាជាទីគោរពបូជា ធ្លាក់សាយទៅលើមនុស្សលោកទាំងអស់ នៅគ្រប់ស្ថានភាព និងគ្រប់កាលៈទេសៈ។ អ្នកដែលជឿតាមព្រះសាសនា រួបរួមផ្ដុំគ្នាជាក្រុមតូចៗ ជាសមាគម ជាសហគមន៍ ហើយនៅទីបំផុត គេទៅជួបជុំគ្នានៅក្នុងមហាសមុទ្រនៃពន្លឺត្រាស់ដឹងពេញលេញ។

ចិត្តរបស់អ្នកទាំងនោះ រលាយចូលគ្នា ដូចទឹកដោះនឹងទឹកសុទ្ធ ដើម្បីផ្គុំគ្នាជាសហគមន៍ប្រកបដោយភាពសុខដុម។

ដូច្នេះ សិក្ខាបទពិតប្រាកដជាគ្រឹះសំខាន់នៃសហគមន៍ល្អឥតខ្ចោះ ជាពន្លឺបណ្តាលឲ្យមនុស្សទាំងឡាយ ចេះស្គាល់គ្នាទៅវិញទៅមក ចេះសម្រុះសម្រួលគ្នាទៅវិញទៅមក ចេះបំបាត់សេចក្តីគ្រោតគ្រាតនៃចិត្ត។

ដូច្នេះ អង្គការដែលកើតឡើងដោយសិក្ខាបទល្អវិសេសរបស់ព្រះពុទ្ធ អាចហៅបានថា សហគមន៍ព្រះសង្ឃ។

សមាជិកទាំងឡាយនៃពុទ្ធិកសហគមន៍ ត្រូវជួយជម្រុញគ្នាទៅវិញទៅមក ឲ្យគោរពប្រតិបត្តិសិក្ខាបទល្អនេះ ហើយខំហាត់ហ្វឹកហ្វឺនចិត្តទៅតាមនោះ។ ដូច្នេះ ពុទ្ធិកសហគមន៍ដែលអ្នកណាក៏ដោយក៏អាចចូលបានដែរនោះ តាមពិត មានតែអ្នកមានជំនឿដូចគ្នាទេ ដែលជាសមាជិក។

3. នៅក្នុងពុទ្ធិកសហគមន៍ មានសមាជិកពីរប្រភេទ គឺៈ អ្នកបង្រៀន ហើយនិងអ្នកផ្គត់ផ្គង់អ្នកបង្រៀន។ សមាជិកទាំងពីរប្រភេទនេះ ត្រូវរួបរួមគ្នា ខិតខំផ្សាយនិងថែរក្សាសាសនាឲ្យ

បាននៅឋិតថេរ។

ដូច្នេះ ដើម្បីឲ្យសហគមន៍បានល្អពេញលេញ ភាពសុខដុមត្រូវតែមានជាចាំបាច់នៅក្នុងចំណោមសមាជិកទាំងអស់។ អ្នកបង្រៀនត្រូវប្រៀនប្រដៅសមាជិក សមាជិកត្រូវគោរពអ្នកបង្រៀន ដើម្បីឲ្យមានភាពសុខដុមរវាងគ្នានឹងគ្នា។

សមាជិកទាំងឡាយនៃសហគមន៍របស់ព្រះពុទ្ធ ត្រូវជួបជុំគ្នាដោយមិត្តភាព ត្រូវមានចិត្តចង់រស់នៅជាមួយគ្នា ដោយសុខសាន្ត ហើយប្រាថ្នាឲ្យបានចិត្តស្រុះស្រួលគ្នាជាឯកភាព។

4. មានកិច្ចប្រាំមួយប្រការ ដែលនាំឲ្យសហគមន៍បានប្រកបនូវភាពសុខដុម គឺៈ ទី១ វាចាស្មោះត្រង់ ទី២ អំពើស្មោះត្រង់និងគួរសម ទី៣ ចិត្តស្មោះត្រង់និងសប្បុរស ទី៤ ការចេះចែករំលែកទ្រព្យសម្បត្តិរួមឲ្យបានស្មើភាពគ្នា ទី៥ ការចេះប្រតិបត្តិតាមសិក្ខាបទល្អបរិសុទ្ធដូចគ្នា ទី៦ ចេះមានការពិចារណាត្រឹមត្រូវ។

ក្នុងចំណោមប្រការទាំងនេះ ប្រការទី៦ ពោលគឺ ការចេះពិចារណាត្រឹមត្រូវ ជាស្នូល ដែលមានប្រការទាំងប្រាំឯទៀត

នៅព័ទ្ធជុំវិញ។

មានច្បាប់វិន័យពីរពួក មួយពួកៗមាន វិន័យប្រាំពីរដែលត្រូវប្រតិបត្តិ ដើម្បីជោគជ័យនៃសហគមន៍។ វិន័យក្នុងពួកទី១ សម្រាប់ទាំងអស់គ្នាប្រព្រឹត្តតាម គឺ:

១-ជួបជុំគ្នាឲ្យបានញឹកញាប់ ដើម្បីស្តាប់ការប្រៀនប្រដៅ ហើយពិភាក្សាគ្នា។

២-រួបរួមគ្នាដោយសេរី ហើយគោរពគ្នា ទៅវិញទៅមក។

៣-គោរពព្រះសាសនាទាំងអស់គ្នា គោរពវិន័យទាំងអស់គ្នា ហើយមិនកែប្រែវិន័យទាំងនោះ។

៤-សមាជិកចំណាស់ និងសមាជិកក្មេង ត្រូវទុកដាក់គ្នាដោយគួរសម។

៥-ត្រូវមានសេចក្តីស្មោះត្រង់ និងសេចក្តីគោរពនៅក្នុងចិត្ត។

៦-ត្រូវធ្វើចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ នៅក្នុងទីសុខស្ងប់ ហើយត្រូវលះបង់សេចក្តីសុខស្ងប់នេះឲ្យដល់អ្នកឯទៀត មុននឹងយកជារបស់ផ្ទាល់ខ្លួន។

៧-ត្រូវស្រឡាញ់មនុស្សទាំងអស់ ដោយមិនរើសមុខ ត្រូវទទួលភ្ញៀវដោយរាក់ទាក់ ត្រូវថែទាំអ្នកជំងឺដោយថ្នមថ្នាក់។ សហគមន៍ដែលគោរពប្រតិបត្តិវិន័យទាំងប្រាំពីរនេះ មិនរលំដាដាច់ខាត។

វិន័យក្នុងពួកទី២ សម្រាប់ឲ្យបុគ្គលម្នាក់ៗ ធ្វើតាម។ បុគ្គលម្នាក់ៗត្រូវ: ទី១ រក្សាចិត្តឲ្យបរិសុទ្ធ ហើយមិនទាមទារចង់បានរបស់ច្រើនហួសហេតុ ទី២ រក្សាបូរណភាព ហើយបំបាត់ចោលគ្រប់ការលោភលន់ ទី៣ មានសេចក្ដីអំណត់ ហើយមិនរករឿងឈ្លោះប្រកែក ទី៤ រក្សាការស្ងៀមស្ងាត់ ហើយមិននិយាយច្រើនឥតប្រយោជន៍ ទី៥ គោរពប្រតិបត្តិច្បាប់វិន័យ ហើយមិនបំពានលើ ទី៦ រក្សាចិត្តជាសមភាព ហើយមិនគោរពតាមសិក្ខាបទដទៃទៀត ទី៧ចេះសំចៃត្បិតត្បៀតក្នុងជីវិតរស់នៅជារៀងរាល់ថ្ងៃ។ បើសមាជិកទាំងឡាយ ធ្វើតាមវិន័យទាំងប្រាំពីរនេះ សហគមន៍នឹងបានឋិតថេរ មិនរលំដាដាច់ខាត។

5. ដូចបានអធិប្បាយពីខាងលើមកហើយថា សហគមន៍ត្រូវ

រក្សាភាពសុខដុម ទុកជាវិន័យគ្រឹះ។ ដូច្នេះ បុគ្គលណាមិន រក្សាភាពសុខដុមទេ មិនអាចហៅថាសមាជិកនៃសហគមន៍ទេ។ សមាជិកម្នាក់ៗ ត្រូវប្រយ័ត្នកុំឲ្យមានការទាស់ទែងបែកបាក់គ្នា។ បើមានការទាស់ទែងគ្នាកើតឡើង ត្រូវតែបំបាត់វាជាបន្ទាន់ ពីព្រោះការទាស់ទែងគ្នានេះនឹងបំផ្លាញសហគមន៍ទាំងមូល យ៉ាងឆាប់រហ័ស ។

ស្នាមប្រឡាក់ឈាម មិនអាចបំបាត់បាន ដោយយក ឈាមទៅបន្ថែមពីលើទេ។ ការស្អប់ មិនអាចបំបាត់បានដោយ យកការស្អប់ទៅបន្ថែមពីលើទេ។ ការស្អប់អាចបំបាត់បាន ដោយសារការបំភ្លេចវាចោល។

6. ក្នុងសម័យមួយនោះ មានស្តេចមួយព្រះអង្គទ្រង់ព្រះនាម ព្រះបាទ**វិបត្តិភ័យ**។ ប្រទេសព្រះអង្គ ត្រូវបានរងសង្គ្រាម ឈ្លានពានពីស្តេចស្រឡាញ់សង្គ្រាមមួយព្រះអង្គ ព្រះនាម ព្រះបាទ**ព្រហ្មទត្ត**។ ក្រោយពីនាំព្រះអគ្គមហេសី និងព្រះរាជ បុត្ររត់គេចបន្តិចមក ព្រះបាទ**វិបត្តិភ័យ** ត្រូវគេចាប់បាន។ តែ សំណាងល្អ ព្រះអង្គម្ចាស់ជាកូនរត់គេចរួច។

ព្រះរាជបុត្រ រកមធ្យោបាយដើម្បីរំដោះព្រះបិតាពុំបាន សោះ។ នៅថ្ងៃគេពិឃាតព្រះបិតា ព្រះរាជបុត្របន្លំខ្លួនចូល ទៅក្នុងទីលានពិឃាត តែមិនអាចធ្វើអ្វីកើតក្រៅពីឈរមើល គេពិឃាតព្រះបិតាកំសត់ ដោយក្ដីអស់សង្ឃឹម។

ស្ដេចឪពុកឃើញកូននៅក្នុងហ្វូងមនុស្ស ក៏និយាយខ្សឹបៗ តែម្នាក់ឯងថា: «កុំស្វែងរកយូរពេល! កុំប្រព្រឹត្តដោយប្រញាប់ ប្រញាល់! ទោសៈ អាចស្ងប់ទៅវិញបាន ដោយសារការបំភ្លេច វាចោល តែមួយមុខគត់!»។

ថ្ងៃជាបន្តៗមក ស្ដេចកូនខិតខំរកមធ្យោបាយសងសឹក មិនដែលលស់ពេលណាទេ។ នៅទីបំផុត ស្ដេចកូនបានចូល ទៅបម្រើព្រះបាទ**ព្រហ្មទត្ត** ជាសេនាមាត្យ ហើយបានជាទី សំណប់នៃព្រះមហាក្សត្រ។

ថ្ងៃមួយ ស្ដេចកូនហែស្ដេចទៅបរបាញ់សត្វ ស្ដេចកូនរក ឱកាសនឹងសងសឹក។ ស្ដេចកូនបានបញ្ឆោតនាំស្ដេចឲ្យឃ្លាង ទៅកន្លែងស្ងាត់ ឆ្ងាយពីគេឯង។ នៅទីនោះ ដោយអស់កម្លាំង ពេក ស្ដេចក៏ផ្ទំកើយព្រះកេសាលើភ្លៅព្រះអង្គម្ចាស់លង់លក់ ទៅ ដោយទុកព្រះទ័យទាំងស្រុងលើព្រះអង្គម្ចាស់។

ព្រះអង្គម្ចាស់ដកដាវ ភ្ជង់បំពង់កស្តេច តែពុំដាច់ចិត្តចាក់ស្តេចសោះ។ ពាក្យបណ្តាំដែលស្តេចឪពុកឱ្យប្រាប់ នៅពេលហៀបមរណៈ ត្រូវបានរំលឹកនឹកឃើញជាថ្មីនៅក្នុងចិត្តរបស់ព្រះអង្គ។ ព្រះអង្គបានល្បងលើកដាវចាក់ស្តេចជាច្រើនដង តែព្រះអង្គមិនអាចសម្រេចព្រះទ័យសម្លាប់ស្តេចបាន។ ភ្លាមនោះ ស្តេចតើនឡើង ហើយនិទានរឿងយល់សប្តិអាក្រក់ថា ឃើញបុត្រព្រះបាទ**វិបត្តិភ័យ**ប៉ុនប៉ងនឹងសម្លាប់ព្រះអង្គប្រាប់ទៅព្រះអង្គម្ចាស់។

ព្រះអង្គម្ចាស់លើកដាវភ្ជង់កស្តេច បញ្ជាក់ប្រាប់ថា ព្រះអង្គជាបុត្រព្រះបាទ**វិបត្តិភ័យ** ហើយប្រកាសថាពេលវេលាត្រូវសងសឹកឲ្យព្រះបិតាមកដល់ហើយ តែព្រះអង្គសម្រេចកិច្ចនេះមិនរួច។ ព្រះអង្គម្ចាស់ ក៏បោះដាវចោលភ្លាមទៅ ហើយលុតជង្គង់ក្រាបប្របនឹងព្រះបាទាស្តេច។

នៅពេលដែលស្តេចបានជ្រាបរឿងរបស់ព្រះអង្គម្ចាស់ និងវាចាចុងក្រោយរបស់ស្តេចឪពុក ព្រះអង្គមានព្រះទ័យរំជើបរំជួលជាខ្លាំង ហើយសុំទោសព្រះអង្គម្ចាស់។ ក្រោយមកព្រះបាទ**ព្រហ្មទត្ត** ក៏ប្រគល់ប្រទេសទៅឲ្យព្រះអង្គម្ចាស់នោះ

វិញ ហើយប្រទេសទាំងពីរក៏ចងមិត្តនឹងគ្នារហូតទៅ។

ពាក្យបណ្តាំរបស់ព្រះបាទ**វិបត្តិភ័យ** នៅពេលហៀបមរណៈ «កុំស្វែងរកយូរពេល» បានន័យថា កុំចងគំនុំយូរ។ «កុំប្រព្រឹត្តដោយប្រញាប់ប្រញាល់» បានន័យថា ចំណងមិត្តភាពមិនត្រូវកាត់ផ្តាច់ភ្លាមៗទេ។

ទោសៈ មិនអាចបំពេញបាន ដោយទោសៈទេ។ ទោសៈ អាចបំបាត់បាន ដោយសារការបំភ្លេចវាចោលតែមួយមុខគត់។

សមាជិកទាំងឡាយនៃសហគមន៍ដែលយកភាពសុខដុមនៃសិក្ខាបទពិតប្រាកដជាគ្រឹះ នឹងអាចស្គាល់តម្លៃនៃរឿងនិទាននេះជានិច្ច។

មិនត្រឹមតែសមាជិកទាំងឡាយនៃសហគមន៍ទេ មនុស្សលោកទូទៅ ក៏ត្រូវតែស្គាល់តម្លៃនៃរឿងនិទាននេះ ហើយប្រតិបត្តិតាម កុំបីឃ្លៀងឃ្លាតដែរ។

II

ដែនដីព្រះពុទ្ធ

1. ដូចបានអធិប្បាយពន្យល់ពីលើមកហើយ សហគមន៍ណា

មិនភ្លេចករណីយកិច្ចរបស់ខ្លួនគឺ ខំផ្សាយព្រះសាសនា ហើយចេះរស់នៅរួបរួមគ្នាក្នុងភាពសុខដុម សហគមន៍នោះនឹងបានរីកធំឡើងៗជាលំដាប់ ហើយព្រះសាសនា ក៏រឹតតែរីកសាយទូលំទូលាយទៅតាមនោះ។

សេចក្តីនេះបានន័យថា ចំនួនអ្នកស្វែងរកពន្លឺត្រាស់ដឹងនឹងកើនឡើងជាពន្លឹក។ ម្យ៉ាងទៀតបានន័យថា ទ័ពបិសាចចង្រៃនៃសេចក្តីលោភលន់ សេចក្តីខឹងក្រោធ សេចក្តីឆ្កួតលេលា ដែលមានសេចក្តីល្ងង់ខ្លៅនឹងតណ្ហាទាំងឡាយជាអ្នកដឹកនាំ នឹងចាប់ដកខ្លួនថយចេញ ហើយគតិបណ្ឌិត ពន្លឺ ជំនឿ សេចក្តីសប្បាយរីករាយ នឹងចូលមកគ្រប់គ្រងជំនួស។

ដែនដីបិសាច ពោរពេញទៅដោយសេចក្តីលោភលន់ ទៅដោយភាពងងឹត ទៅដោយការប្រយុទ្ធ ទៅដោយសង្គ្រាម ទៅដោយដាវលំពែង ទៅដោយការបង្ហូរឈាម។ ដែនដីបិសាចពោរពេញទៅដោយការច្រណែននិន្ទាគ្នា ទៅដោយបុរេនិច្ច័យ ទៅដោយទោសៈ ទៅដោយការបោកបញ្ឆោតគ្នា ទៅដោយការបញ្ឆោរគ្នា ទៅដោយការលោក់លៀមគ្នា ទៅដោយការជេរប្រមាថគ្នា។

ប៉ុន្តែ បើពន្លឺនៃគតិធម៌ចាប់ចែងចាំងរស្មីលើដែនដីនោះ ហើយភ្លៀងនៃធម៌មេត្តាចាប់បង្អុរធ្លាក់ទៅលើដែនដីនោះ បើជំនឿចំពោះព្រះសាសនាចាប់ចាក់ឫស ដុះរីកបានជាផ្កានៃសេចក្តីសប្បាយរីករាយហើយ ដែនដីបិសាចនោះ នឹងបានទៅជាដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ។

ដូចជាខ្យល់រំហើយចាប់ធ្លាក់ ផ្កាចាប់រីក ប្រកាសប្រាប់ថារដូវផ្ការីកជិតមកដល់ហើយដូច្នោះដែរ កាលណាបុគ្គលបានសម្រេចពន្លឺត្រាស់ដឹង រុក្ខាលតាវល្លិ ភ្នំ ស្ទឹងទន្លេ និងគ្រប់វត្ថុទាំងឡាយ ដែលនៅជុំវិញបុគ្គលនោះ នឹងចាប់កម្រើករំពើកក្នុងជីវិតថ្មីមួយទៀត។

បើចិត្តបុគ្គលបានបរិសុទ្ធ អ្វីៗទាំងអស់ដែលនៅជុំវិញគេក៏ទៅជាបរិសុទ្ធដែរ។

2. កន្លែងណាដែលមានសិក្ខាបទពិតប្រាកដ ជនទាំងអស់ដែលរស់នៅកន្លែងនោះ នឹងមានចិត្តបរិសុទ្ធស្ងប់។ ជាការពិតសេចក្តីមេត្តាអាសូររបស់ព្រះពុទ្ធ ផ្តល់គុណប្រយោជន៍ទៅមនុស្សលោកទាំងអស់មិនចេះឈប់ឈរទេ ហើយរស្មីនៃសេចក្តី

មេត្តាអាសូរនោះ នឹងបំបាត់មន្ទិលទាំងអស់ពីក្នុងចិត្ត។

មិនយូរប៉ុន្មាន ចិត្តបរិសុទ្ធនឹងទៅជាចិត្តជ្រៅ ចិត្តដែលដើរតាមផ្លូវព្រះធម៌ខ្ពង់ខ្ពស់ ចិត្តស្រឡាញ់ការធ្វើទានកុសល ចិត្តស្រឡាញ់ការប្រតិបត្តិសិក្ខាបទល្អ ចិត្តអំណត់ ចិត្តទៀងទាត់ ចិត្តស្ងប់ ចិត្តប្រកបដោយគតិបណ្ឌិត ចិត្តប្រកបដោយមេត្តាធម៌ ចិត្តដែលដឹកនាំសត្វលោកទាំងឡាយ ឆ្ពោះទៅកាន់ពន្លឺត្រាស់ដឹង តាមគ្រប់មធ្យោបាយត្រឹមត្រូវ។ យ៉ាងនេះហើយដែលដែនដីព្រះពុទ្ធ ត្រូវបានកសាងឡើង។

យ៉ាងដូច្នេះឯង គ្រួសារដែលមានតែប្ដីប្រពន្ធ និងបុត្រធីតា នឹងបានទៅជាគ្រួសារមួយដែលមានព្រះពុទ្ធនៅជាមួយ។ ដូចគ្នានេះ ប្រទេសដែលរងទុក្ខដោយសារការប្រកាន់វណ្ណៈសង្គម នឹងបានទៅជាសហគមន៍មួយ ដែលមនុស្សទាំងឡាយមានចិត្តជាបងប្អូន។

ទោះជាប្រាសាទមាសក៏ដោយ បើវាប្រឡាក់ទៅដោយឈាម វាមិនអាចជាទីលំនៅរបស់ព្រះពុទ្ធបានទេ។ ផ្ទុយទៅវិញ ខ្ទមតូចមួយដែលមានពន្លឺព្រះចន្ទចាំងចូលតាមដំបូលផ្ទះធ្លាយ ក៏នឹងអាចទៅជាទីលំនៅរបស់ព្រះពុទ្ធបាន បើចិត្តរបស់

អ្នកទាំងឡាយនៅក្នុងខ្ទមនោះបរិសុទ្ធ ។

បើដែនដីព្រះពុទ្ធត្រូវបានកសាងឡើងនៅក្នុងចិត្តបរិសុទ្ធនៃបុគ្គលតែម្នាក់គត់ ចិត្តបរិសិទ្ធនោះនឹងទាក់ទាញចិត្តនៃបុគ្គលឯទៀតឲ្យចងសម្ពន្ធគ្នាជាសហគមន៍សុខដុម។ ជំនឿលើព្រះពុទ្ធ សាយចេញពីបុគ្គលម្នាក់ទៅដល់គ្រួសារ ពីគ្រួសារមួយទៅដល់ភូមិ ពីភូមិមួយទៅដល់ស្រុក ដល់ខេត្ត ដល់ក្រុង ដល់ប្រទេស ហើយនៅទីបំផុត ដល់ពិភពលោកទាំងមូល។

ជាការពិតប្រាកដណាស់ ដើម្បីផ្សាយពង្រីកព្រះសាសនាគ្មានអ្វីក្រៅពីខំពង្រីកដែនដីព្រះពុទ្ធនេះទេ។

3. លោកនេះ ដែលពោរពេញទៅដោយសេចក្ដីលោភលន់ទៅដោយអយុត្តិធម៌ ទៅដោយថ្កុកឈាម មើលទៅហាក់ដូចជាដែនដីបិសាច។ ប៉ុន្តែបើកាលណា ហើយមនុស្សទាំងឡាយជឿទុកចិត្តលើពន្លឺត្រាស់ញាណរបស់ព្រះពុទ្ធ ឈាមនោះនឹងប្រែក្លាយទៅជាទឹកដោះ សេចក្ដីលោភលន់នឹងប្រែក្លាយទៅជាមេត្តាធម៌ ហើយដែនដីបិសាចនោះនឹងប្រែក្លាយជាដែនដីព្រះពុទ្ធ។

ធ្វើឲ្យសមុទ្ររីងដោយយកស្លាបព្រាតូចមួយ ទៅដួសទឹកចេញ ដូចជាធ្វើមិនកើត ប៉ុន្តែបើគេសម្រេចចិត្តត្រូវតែធ្វើ ទោះបីត្រូវអស់រាប់រយជាតិក៏ដោយ នោះគឺជាចិត្តសម្រេចទទួលយកនូវពន្លឺត្រាស់ញាណរបស់ព្រះពុទ្ធ។

ព្រះពុទ្ធនៅរង់ចាំឯត្រើយនាយ ដែលជាដែនដីនៃពន្លឺត្រាស់ដឹង។ នៅទីនោះ គ្មានសេចក្តីលោភលន់ គ្មានសេចក្តីខឹងក្រោធ គ្មានសេចក្តីល្ងង់ខ្លៅ គ្មានទុក្ខព្រួយ គ្មានភ័យអាសន្ន មានតែពន្លឺនៃគតិធម៌ និងភ្លៀងនៃសេចក្តីមេត្តាអាសូរ។

ទីនោះ ជាឋានប្រកបដោយសុខសន្តិភាព ជាជម្រកសម្រាប់អ្នកមានទុក្ខ មានព្រួយ មានភ័យអាសន្ន ជាកន្លែងឈប់សម្រាករបស់អ្នកផ្សាយព្រះសាសនា។

នៅក្នុងដែនដីបរិសុទ្ធនោះ ពន្លឺចែងចាំងគ្រប់ទិសទី ជីវិតឋិតថេររហូត។ អ្នកដែលបានទៅដល់ឋានសុខស្ងប់នោះ នឹងមិនវិលត្រឡប់មកឋាន ដែលពោរពេញទៅដោយរឿងថ្លឹងថ្លែកនេះវិញទេ។

ដោយពិត ឋានបរិសុទ្ធនោះ ដែលមានផ្កាគ្រប់ពណ៌ផ្សព្វផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់នៃគតិធម៌ មានសត្វបក្សីល្អៗ

ប្រគំបទចម្រៀងព្រះធម៌យ៉ាងពីរោះលន្លោច ជាទីត្រេកអរ ទៅនៅទីបំផុត សម្រាប់សត្វលោកទាំងអស់។

4. ឋានបរិសុទ្ធនោះជាកន្លែងសម្រាកកម្លាំង ក៏ពិតហើយ តែមិនមែនជាកន្លែងសម្រាប់ការខ្ជិលច្រអូសទេ។ គុម្ពោតផ្កាក្រអូបឈ្ងុយឈ្ងប់ ពុំមែនសម្រាប់ភាពព្រងើយកន្តើយទេ គឺសម្រាប់សម្រាកកាយ ដើម្បីឲ្យមានកម្លាំងរឿសរវៃជាថ្មីឡើងវិញ ដើម្បីនឹងបន្តបេសកកម្មព្រះពុទ្ធតទៅទៀត។

បេសកកម្មព្រះពុទ្ធ មិនចេះចប់ទេ។ ដរាបណា សត្វលោកនៅមានជីវិតរស់នៅ ហើយចិត្តអត្តទត្ថៈ ពោរពេញទៅដោយអំពើពុករលួយនៅតែមាន បេសកកម្មនេះ នឹងមិនចប់ជាដាច់ខាត។

កូនចៅព្រះពុទ្ធ ដែលបានទៅដល់ត្រើយនាយនៃដែនដីបរិសុទ្ធដោយសារមហាអនុភាពនៃព្រះពុទ្ធ**អាមិដា** នឹងបានទទួលកម្លាំងរឿសរវៃគ្រប់គ្រាន់ ដើម្បីត្រឡប់មកជួយធ្វើបេសកកម្មរបស់ព្រះពុទ្ធ នៅក្នុងលោកនេះវិញ ។

ពន្លឺនៃទៀនតែមួយដើមគត់អាចបន្តទៅទៀនឯទៀតជា

បន្តបន្ទាប់បានយ៉ាងណា ពន្លឺនៃធម៌មេត្តារបស់ព្រះពុទ្ធក៏អាច បន្តពីដួងចិត្តមួយទៅដួងចិត្តមួយ ជាបន្តបន្ទាប់ គ្មានទីបញ្ចប់ យ៉ាងនោះដែរ។

ដោយមានចិត្តប្រកបដោយមេត្តាធម៌ កូនចៅព្រះពុទ្ធ ទទួលធ្វើកិច្ចការសម្រាប់សេចក្ដីត្រាស់ដឹង និងសេចក្ដីបរិសុទ្ធ របស់ព្រះអង្គ ហើយបន្តកិច្ចការនោះរៀងរហូត ពីជំនាន់មួយ ទៅជំនាន់មួយ ដើម្បីឲ្យដែនដីព្រះពុទ្ធបានជាឋានប្រសើរ ជានិច្ចតរៀងទៅ។

III

អ្នកទ្រទ្រង់ដែនដីព្រះពុទ្ធ

1. ព្រះនាង **សាមាវតី** មហេសីទីមួយនៃព្រះបាទ **ឧទេន** ទ្រង់មានភក្ដីភាពយ៉ាងជ្រាលជ្រៅចំពោះព្រះពុទ្ធ។

ព្រះនាងគង់នៅក្នុងប្រាសាទមួយដាច់ស្រយាលឆ្ងាយពីគេនៅក្នុងទីខាងក្នុងបំផុតនៃព្រះបរមរាជវាំង។ នាងគមដែលជាភិលៀងជំនិតរបស់ព្រះនាង ជាស្រីមានស្មារតីពូកែចាំអស្ចារ្យ។

នាងគម តែងតែចេញទៅស្តាប់ព្រះធម្មទេសនា របស់ព្រះពុទ្ធជាម្ចាស់ហើយយកមកនិទានថ្វាយព្រះអគ្គមហេសី ជាទីសណ្តាប់ៗ ដូច្នេះ ព្រះអគ្គមហេសីរឹតតែមានសតិប្រាជ្ញាខ្ពង់ខ្ពស់នឹងជំនឿមុតមាំ កាន់តែជ្រៅឡើងៗ។

មហេសីទីពីរ មានសេចក្តីច្រណែននឹងព្រះនាង ក៏រកឧបាយកលសម្លាប់ព្រះនាង។ មហេសីទីពីររករឿងគ្រប់បែបយ៉ាង ទូលញុះញង់ស្តេច រហូតដល់ស្តេចជឿតាម ហើយបញ្ជាឲ្យសម្លាប់ព្រះនាង **សាមាវតី** មហេសីទីមួយរបស់ព្រះអង្គ។

ព្រះនាង **សាមាវតី** ទ្រង់គង់នៅយ៉ាងស្ងៀមស្ងាត់គ្មានព្រះបន្ទូលមួយម៉ាត់តបតនឹងព្រះមហាក្សត្រ រហូតដល់ស្តេចអស់មានចិត្តនឹងប្រហារព្រះនាង។ ព្រះមហាក្សត្រក៏បានស្ងប់ព្រះចិន្តាឡើងវិញ ហើយសុំទោសព្រះនាង ចំពោះការដែលព្រះអង្គមិនទុកចិត្តនឹងព្រះនាង។

សេចក្តីច្រណែននិន្ទានៃព្រះមហេសីទីពីរ កាន់តែរីកធំឡើងៗ ជាលំដាប់។ ព្រះមហេសីទីពីរ ទ្រង់បញ្ជូនអ្នកលេងកាប់ចាក់ឲ្យទៅដុតចុងជាយវាំង នៅពេលស្តេចមិននៅ។ ព្រះនាង **សាមាវតី** ទ្រង់រក្សាសេចក្តីស្ងប់ជានិច្ច លួងលោមលើក

ទឹកចិត្តស្រីបម្រើទាំងឡាយដែលភិតភ័យ។ រួចហើយព្រះនាងទ្រង់សុគតទៅដោយឥតតក់ស្លុត ដោយចិត្តស្ងប់ទៅតាមសេចក្ដីទូន្មានរបស់ព្រះពុទ្ធជាម្ចាស់។ នាងគម **ឧត្តរា** ក៏ស្លាប់នៅក្នុងភ្លើងជាមួយនឹងព្រះនាង ក្នុងពេលនោះដែរ។

ក្នុងចំណោមស្រីជាឧបាសិការបស់ព្រះពុទ្ធ ស្រីទាំងពីរនេះ ជាទីគោរពបូជាប្រសើរជាគេបង្អស់ គឺៈព្រះនាង**សាមាវតី** ជាស្រីមានចិត្តប្រកបដោយសេចក្ដីមេត្តាធម៌ នាងគមជាស្រីប្រកបដោយគតិធម៌ ។

2. ព្រះបាទ **មហានាម** ក្នុងវង្សសក្យ ត្រូវជាបងប្អូនជីដូនមួយនឹងព្រះពុទ្ធ ទ្រង់មានជំនឿជ្រាលជ្រៅក្នុងព្រះសាសនា ហើយជាសាវ័កស្មោះត្រង់ជាងគេមួយព្រះអង្គ។

ថ្ងៃមួយ ស្ដេចឃោរឃៅនៃនគរ**កោសល** ព្រះនាម**វិរុឡ្ហក** ចូលមកច្បាំងដណ្ដើមយកនគរ**សក្យ**។ ព្រះបាទ**មហានាម** យាងចេញទៅក្រាបបង្គំទូលស្ដេចឃោរឃៅនោះ សុំឲ្យទុកជីវិតឲ្យប្រជារាស្ត្រព្រះអង្គ តែស្ដេចឃោរឃៅមិនព្រមស្ដាប់សេចក្ដីអង្វរនេះឡើយ។ ព្រះបាទ**មហានាម** ក៏ទូលស្នើសុំឲ្យ

មហារាជ**វិរុឡ្ហក** ដោះលែងអ្នកជាប់ឃុំទាំងអស់ឲ្យរត់ចេញពីវាំងប្រាសាទ ក្នុងអំឡុងពេលដែលព្រះអង្គមុជបាត់ទៅក្នុងត្រពាំងទឹកមួយនៅជិតនោះ។

ស្តេចឃោរឃៅ ក៏យល់ព្រម ដោយជឿជាក់ថា ព្រះបាទ**មហានាម** មិនអាចទ្រាំមុជក្នុងទឹកបានយូរទេ។

នៅពេលព្រះបាទ**មហានាម** មុជនៅក្នុងទឹក ទ្វារវាំងក៏បើកឡើង ហើយអ្នកជាប់ឃុំទាំងឡាយក៏ប្រាសរត់រកព្រះអាយុរៀងខ្លួន។ ប៉ុន្តែមិនឃើញព្រះបាទ**មហានាម** ងើបចេញពីទឹកសោះ ព្រះអង្គទ្រង់បូជាជីវិតព្រះអង្គសម្រាប់ប្រជារាស្ត្រព្រះអង្គ ដោយយកសក់ទៅចងភ្ជាប់នឹងឫសឈើដែលដុះក្នុងទឹក។

3. មានដូនជីម្នាក់ឈ្មោះ **ឧប្បលវណ្ណា** ល្បីល្បាញមានប្រាជ្ញាស្មើនឹងព្រះមោគ្គល្លាន ដែលជាសាវ័កធំជាងគេមួយព្រះអង្គរបស់ព្រះពុទ្ធ។ នាង**ឧប្បលវណ្ណា** ពិតជាដូនជីឧត្តមមួយក្នុងពពួកដូនជីទាំងឡាយ។ នាងតែងតែដឹកនាំ បង្ហាត់បង្រៀនព្រះសាសនា ដល់ពួកដូនជីទាំងឡាយ ដោយគ្មានគិតដល់ការនឿយហត់របស់ព្រះនាងឡើយ។

ទេវទត្ត ជាបុរសឃោរឃៅអាក្រក់បំផុត។ បុរសនេះបំពុលចិត្តស្តេច **អជាតសត្តុ** ហើយបញ្ចុះបញ្ចូលព្រះអង្គ ឲ្យប្រឆាំងនឹងសាសនាព្រះពុទ្ធ។ ក្រោយមកមហារាជ**អជាតសត្តុ** ទ្រង់មានសេចក្តីស្តាយក្រោយ ទ្រង់ផ្តាច់ចំណងមិត្តភាព ជាមួយនឹង**ទេវទត្ត** ហើយព្រះអង្គបានជាសាវ័ករបស់ព្រះពុទ្ធម្នាក់។

ថ្ងៃមួយ **ទេវទត្ត**ចង់ចូលទៅជួបស្តេច តែត្រូវអ្នកយាមទ្វារបណ្តេញមិនឲ្យចូលវាំង។ ពេលនោះ **ទេវទត្ត** បានឃើញដូនជី **ឧប្បលវណ្ណា** ចេញពីក្នុងវាំងមក។ **ទេវទត្ត**ខឹងណាស់ ហើយវាយដូនជីរហូតដល់មានរបួសជាទម្ងន់។

ដូនជី ខំប្រវេប្រវា ដើរផងវារផង ទាល់តែបានមកដល់អាស្រមវិញ ទាំងសេចក្តីឈឺចាប់ជាខ្លាំង។ នៅពេលដែលដូនជីឯទៀតកំពុងខិតខំលួងលោមនាង ដូនជីមានវាចាថា: «ម្នាលដូនជីទាំងឡាយ ! ជីវិតមនុស្ស មិនអាចទាយទុកមុនបានទេ។ អ្វីៗទាំងអស់ មិនឋិតថេរទេ គ្មានខ្លឹមសារទេ។ មានតែពិភពពន្លឺត្រាស់ដឹងទេ ដែលឋិតថេរសុខស្ងប់។ ចូរបន្តជីវិតរស់នៅរបស់អ្នកក្នុងព្រះសាសនា ជាបន្តទៅទៀត កុំបីខាន»។

មានវាចាចប់ហើយ ដូនជី **ឧប្បលវណ្ណា** ក៏រំលាយខន្ធទៅដោយសុខស្ងប់។

4. ពីដើម **អង្គុលិមាល** ជាមេចោរកាចសាហាវសម្បើមណាស់ បានកាប់សម្លាប់មនុស្សរាប់មិនអស់។ ប៉ុន្តែ ក្រោយមកព្រះពុទ្ធជាម្ចាស់បានស្រោចស្រង់មេចោរនេះ ហើយគេក៏បានទៅជាសមាជិកនៃពុទ្ធិកសហគមន៍ម្នាក់ទៅ។ ថ្ងៃមួយ ភិក្ខុអតីតមេចោរ បានចេញទៅបិណ្ឌបាតនៅក្នុងក្រុង តែភិក្ខុត្រូវបានទទួលរងនូវទារុណកម្មជាច្រើន ដោយសារអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តពីអតីតកាល។

អ្នកស្រុកនាំគ្នាវាយដំប្រំផាក់ភិក្ខុអតីតមេចោរ គ្មានមេត្តាប្រណីបន្តិចឡើយ។ ភិក្ខុអតីតមេចោរ ត្រឡប់មកវត្តវិញ ទៅលុតជង្គង់ក្រាបប្របព្រះបាទាព្រះពុទ្ធជាម្ចាស់ទាំងឈាមហូរសស្រាក់ ដើម្បីសម្ដែងសេចក្ដីដឹងគុណដល់ព្រះអង្គ ក្នុងការដែលព្រះអង្គទ្រង់បានរកឱកាសឲ្យគេទទួលទុក្ខទោសចំពោះអំពើឃោរឃៅ ដែលគេបានប្រព្រឹត្តពីមុនមក។

ភិក្ខុអតីតមេចោរ ក្រាបទូលព្រះពុទ្ធថា: «ឱព្រះជាម្ចាស់! ដើមឡើយ ឈ្មោះរបស់ខ្ញុំព្រះអង្គនេះ មិនជាអាក្រក់ទេ។ តែ

ក្រោយមក ខ្ញុំព្រះអង្គបានសម្លាប់មនុស្សអស់ជាច្រើន ហើយកាត់យកម្រាមដៃអ្នករងគ្រោះទាំងនោះសន្សំទុក ខ្ញុំព្រះអង្គ ក៏ត្រូវបានទទួលឈ្មោះថា **អង្គុលិមាល** ឬអ្នកសន្សំម្រាមដៃ តាំងពីពេលនោះមក។

«តែពេលនេះ ដោយសារសេចក្តីអាសូររបស់ព្រះជាម្ចាស់ ខ្ញុំព្រះអង្គក៏បានយល់នូវគតិធម៌ ហើយមានភក្តីភាពចំពោះរតនៈទាំងបី គឺៈ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ អ្នកដែលចង់ជិះសេះ ឬជិះគោ ត្រូវតែកាន់រំពាត់ខ្សែតីមួយ ជាចាំបាច់។ តែចំពោះព្រះជាម្ចាស់ ព្រះអង្គអាចធ្វើឲ្យខ្ញុំព្រះអង្គបានបរិសុទ្ធ ដោយគ្មានប្រើរំពាត់ខ្សែតីអ្វីឡើយ។

«ឱព្រះជាម្ចាស់ ! ថ្ងៃនេះ ខ្ញុំព្រះអង្គ បានទទួលរបស់ដែលត្រូវទទួល។ ខ្ញុំព្រះអង្គមិនចង់រស់ ប៉ុន្តែ ក៏មិនចង់ស្លាប់ដែរ។ ខ្ញុំព្រះអង្គ រង់ចាំពេលវេលា ដែលត្រូវមកដល់ខ្លួនខ្ញុំព្រះអង្គ តែប៉ុណ្ណោះ»។

5. ព្រះ**មោគ្គល្លាន** នឹងព្រះ**សារីបុត្ត** ជាសាវ័កផុតថ្នាក់របស់ព្រះពុទ្ធ។ នៅពេលដែលពួកបព្វជិតនៃសាសនាដទៃទៀតឃើញទឹកអម្រឹតបរិសុទ្ធនៃសាសនាព្រះពុទ្ធ ធ្លាក់សាយប្រោះព្រំលើ

សត្វលោក ហើយសត្វលោកទទួលផឹក ដោយអការៈស្រេកឃ្លាន ពួកបព្វជិតនៃសាសនាឯទៀតទាំងនោះ ក៏កើតមានសេចក្តីច្រណែន ហើយបង្កឧបសគ្គរឿងហេតុគ្រប់បែបយ៉ាងចំពោះសាសនាព្រះពុទ្ធ។

តែគ្មានឧបសគ្គណាមួយអាចទប់ទល់រាំងរាព្រះសាសនាកុំឲ្យរីកសាយបានឡើយ។ ដោយហេតុនេះ ពួកកាន់សាសនាដទៃទៀតនោះ ប៉ុនប៉ងនឹងសម្លាប់ព្រះ**មោគ្គល្លាន**។

ព្រះ**មោគ្គល្លាន** ទ្រង់បានគេចផុតអំពីការប៉ុនប៉ងឃោរឃៅនេះពីរលើក។ តែនៅលើកទីបី ព្រះ**មោគ្គល្លាន**ត្រូវបានពួកឃាតករជាច្រើនព័ទ្ធជាប់ ហើយធ្វើគតព្រះអង្គក្នុងពេលនោះទៅ។

ដោយមានពន្លឺត្រាស់ដឹងជួយទ្រទ្រង់ ព្រះ**មោគ្គល្លាន**ទ្រង់ទទួលរងការធ្លាក់វាយប្រហារនៃឃាតករទុរយស ដោយស្ងប់ស្ងៀម ឥតតក់ស្លុត។ សាច់របស់ព្រះអង្គ ត្រូវបានគេវះហែកជាចំណែក ឆ្អឹងរបស់ព្រះអង្គ ត្រូវបានគេកិនបំបាក់ជាកំណាត់ល្អិត តែព្រះ**មោគ្គល្លាន**គ្មានការឈឺចាប់ ព្រះអង្គទ្រង់អស់សង្ខារទៅ ដោយសុខស្ងប់។

អង្គុត្តរនិកាយ

ម្នាលភិក្ខុទាំងឡាយ! មានបុគ្គលឯកមកកើតក្នុងលោកនេះ សម្រាប់ជាប្រយោជន៍នៃបុគ្គលជាច្រើន សម្រាប់ជាសុភមង្គលនៃបុគ្គលជាច្រើន។ បុគ្គលឯកនោះមកចាប់កំណើត ដោយសារសេចក្ដីករុណាអាសូរចំពោះលោកនេះ និងដើម្បីជាប្រយោជន៍នៃលោកនេះ ដើម្បីជាសុខុមាលភាព និងសុភមង្គលនៃទេវលោកផង និងមនុស្សលោកផង។ តើបុគ្គលឯកនោះជាអ្នកណា? ម្នាលភិក្ខុទាំងឡាយ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! មានបុគ្គលឯក ដែលមិនងាយនឹងបញ្ចេញឲ្យឃើញទេ នៅក្នុងលោកនេះ។ តើបុគ្គលឯកនោះ ជាអ្នកណា? ម្នាលភិក្ខុទាំងឡាយ ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! នៅក្នុងលោកនេះ មានបុគ្គលអស្ចារ្យម្នាក់ដែលមិនងាយនឹងបានជួបប្រទះ។ តើបុគ្គលអស្ចារ្យនោះ ជាអ្នកណា? បុគ្គលអស្ចារ្យនោះគឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! មានបុគ្គលឯក ដែលនៅពេលស្លាប់ទៅសត្វលោកទាំងអស់ស្ដាយស្រណោះ។ តើបុគ្គលឯកនោះ ជាអ្នកណា? ម្នាលភិក្ខុ ទាំងឡាយ ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! មានបុគ្គលឯកកើតក្នុងលោកនេះ ដែលគ្មានអ្នកណាម្នាក់អាចប្រៀបស្មើបាន។ តើបុគ្គលឯកនោះ ជាអ្នកណា? ម្នាលភិក្ខុទាំងឡាយ ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ! មានបុគ្គលឯក ដែលចេញឲ្យឃើញប្រត្យក្សក្នុងភាពមាននេត្រាប្រកបដោយអានុភាព មានពន្លឺភ្លឺត្រចេះត្រចង់ មានរស្មីសាយចេញធំមហិមា។ តើបុគ្គលឯកនោះ ជាអ្នកណា? ម្នាលភិក្ខុទាំងឡាយ ! បុគ្គលឯកនោះ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ -អង្គុត្តរនិកាយ ១-១៣ -

ប្រភពដកស្រង់បញ្ជាក់

ពាក្យបំព្រួញ : ទ.ន. : ទីឃនិកាយ
ម.ន. : មជ្ឈិមនិកាយ
ស.ន. : សំយុត្តនិកាយ
អ.ន. : អង្គុត្តរនិកាយ

ព្រះពុទ្ធ

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
ចំពូកទី ១			
1	2	1	គម្ពីរផ្សេងៗ
	7	1	អ.ន. ៣ - ៣៨ សុខុមាលាសូត្រ
	7	14	ម.ន. ៣ - ២៦ អរិយបរិយេសនសូត្រ
	8	9	សុត្តន្តបិដក
	10	11	ម.ន. ៩ - ៨៥ ពោធិរាជកុមារសូត្រ
	11	1	សុត្តន្តបិដក
	11	12	សុត្តនិបាត ៣ - ២ បធានសូត្រ
	12	4	គម្ពីរព្រះសូត្រផ្សេងៗ
	13	4	វិន័យ មហាវគ្គ ១
	15	5	ទ.ន. ១៦ មហាបរិនិព្វានសូត្រ
2	17	3	ទ.ន. ១៦ មហាបរិនិព្វានសូត្រ
	19	7	បរិនិព្វានសូត្រ
	23	2	បរិនិព្វានសូត្រ

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
	23	10	ទ.ន. ១៦ មហាបរិនិព្វានសូត្រ

ជំពូកទី ២

1	25	1	អមិតាយុរធ្យានសូត្រ វិមលកិរ្តិនិរទេសសូត្រ
	25	6	សូរំគមសូត្រ
	26	1	វិមលកិរ្តិនិរទេសសូត្រ មហាបរិនិព្វានសូត្រ
	26	16	សទ្ធម៌បុណ្ឌរីកសូត្រ ១៦
	28	2	មហាយានជាតក ចិត្តភូមិបរិក្សសូត្រ
	28	9	មហាបរិនិព្វានសូត្រ
2	31	14	សទ្ធម៌បុណ្ឌរីកសូត្រ ៣
	33	9	សទ្ធម៌បុណ្ឌរីកសូត្រ ៤
	36	1	សទ្ធម៌បុណ្ឌរីកសូត្រ ៥
3	38	1	សទ្ធម៌បុណ្ឌរីកសូត្រ ១៦

ជំពូកទី ៣

1	42	1	អវតំសកសូត្រ ៣
	44	1	មហាបរិនិព្វានសូត្រ
	44	8	អវតំសកសូត្រ
	45	1	សុវណ៌ប្រភាសោត្តមរាជសូត្រ ៣
2	48	16	អវតំសកសូត្រ
	49	8	អវតំសកសូត្រ ៣៤ គណ្ឌព្យូហៈ
	49	13	សុខាវតីព្យូហៈសូត្រតូច
	50	2	អវតំសកសូត្រ

វគ្គ	ទំព័រ	បន្ទាត់	ប្រកពជកស្រង់
	50	8	ស.ន. ៣៥ - ៥
	50	13	មហាបរិនិព្វានសូត្រ
3	54	5	ម.ន. ៨ - ៧៧ មហាសកុលូទយិសូត្រ
	55	13	មហាបរិនិព្វានសូត្រ
	56	12	លង្កាវតារសូត្រ
	57	7	អវតំសកសូត្រ ៣២
	58	10	សទ្ធម៌បុណ្ឌរីកសូត្រ ២៥
	58	15	មហាបរិនិព្វានសូត្រ
	59	14	សទ្ធម៌បុណ្ឌរីកសូត្រ ២
	60	6	សទ្ធម៌បុណ្ឌរីកសូត្រ ២

ព្រះធម៌

ជំពូកទី ១

1	64	1	វិន័យ មហាវគ្គ ១-៦ ស.ន. ៥៦-១១-១២ ធម្មចក្កប្បវត្តនសូត្រ
	66	6	ឥតិវុត្តកៈ ១០៣
	67	3	ម.ន. ២ សព្វាសវសូត្រ
	67	10	សូត្រ ៤២ ជំពូក ១៨
	68	9	ស្រីមាលាទេវីសីហនាទសូត្រ
3	70	16	អវតំសកសូត្រ ២២ ទសភូមិកៈ

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
ចំពូកទី ២			
1	76	1	ម.ន. ៤ - ៣៥ ចូឡសច្ចកសូត្រ
	79	3	អ.ន. ៥ - ៤៩ មុណ្ឌរាជវគ្គ
	79	15	អ.ន. ៤ - ១៨៥ សមណសូត្រ
	80	7	អ.ន. ៣ - ១៣៤ ឧប្បាទសូត្រ
2	80	15	លង្ការវតារសូត្រ
	81	3	អវតំសកសូត្រ ២
	81	13	អវតំសកសូត្រ ១៦
	82	10	អវតំសកសូត្រ ២២ ទសភូមិកៈ
	83	3	លង្ការវតារសូត្រ
	83	8	អ.ន. ៤ - ១៨៦ ឧម្មគ្គសូត្រ
	83	14	ធម្មបទ ១, ២, ១៧, ១៨
	84	11	ស.ន. ២-១-៦ កាមទសូត្រ
3	85	6	អវតំសកសូត្រ ១៦
	85	16	លង្ការវតារសូត្រ
	87	1	ម.ន. ៣-២២ អលគទ្ទូបមសូត្រ
	88	6	លង្ការវតារសូត្រ
	88	12	លង្ការវតារសូត្រ
4	92	15	វិន័យ, មហាវគ្គ ១-៦
	93	14	លង្ការវតារសូត្រ
	94	5	ស.ន. ៣៥-២០០ ទារុក្ខន្ធសូត្រ

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
	94	16	លង្កាវតារសូត្រ និង គម្ពីរផ្សេងៗទៀត
	96	2	ម.ន. ២-១៨ មធុបិណ្ឌិកសូត្រ
	97	1	លង្កាវតារសូត្រ
	98	1	លង្កាវតារសូត្រ
	99	10	វិមលកិត្តិនិទ្ទេសសូត្រ
	102	16	អវតំសកសូត្រ ៣២ គណ្ឌព្យូហៈ
	103	10	លង្កាវតារសូត្រ និងគម្ពីរផ្សេងៗទៀត

ចំពូកទី ៣

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
1	105	1	វិន័យ, មហាវគ្គ ១-៩
	106	5	វិន័យ, ចូឡវគ្គ ៩-២១
	106	15	សូរំគមសូត្រ
2	115	1	សូរំគមសូត្រ
	117	13	មហាបរិនិព្វានសូត្រ
	118	5	សទ្ធម៌បុណ្ឌរីកសូត្រ ៧ សូរំគមសូត្រ
	119	5	អវតំសកសូត្រ ៣២
	119	10	មហាបរិនិព្វានសូត្រ
	119	16	ព្រហ្មជាលសូត្រ
	120	11	មហាបរិនិព្វានសូត្រ
3	121	15	មហាបរិនិព្វានសូត្រ

ចំពូកទី ៤

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
1	129	1	ស្រីមាលាទេវីសីហនាទសូត្រ

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
	130	16	អ.ន. ២-១១
	131	6	ឥតិវុត្តក: ៩៣
	131	14	វិន័យ មហាវគ្គ
	132	10	អ.ន. ៣-៦៨ អញ្ញាតិដ្ឋិកសូត្រ
	133	9	អ.ន. ៣-៣២ អាឡវកសូត្រ
	134	10	វេបុល្យសូត្រ
	134	16	វិន័យ មហាវគ្គ ១-៦ ធម្មចក្កប្បវត្តនសូត្រ
	135	5	ម.ន. ២-១២ ចូឡទុក្ខខន្ធសូត្រ
	136	7	មហាបរិនិព្វានសូត្រ
	138	3	ឥតិវុត្តក: ២២
2	140	11	ម.ន. ៦-៥១ កន្ទរក:សុត្តន្ត:
	141	13	អ.ន. ៣-១៣០
	142	6	អ.ន. ៣-១១៣
3	143	5	ឥតិវុត្តក: ១០០
	144	4	សំយុក្តវត្ថុបិដកសូត្រ
	145	8	មហាបរិនិព្វានសូត្រ
	147	13	អ.ន. ៣-៦២
	148	10	អ.ន. ៣-៣៥ ទេវទូតសូត្រ
	150	9	ថេរីគាថា អដ្ឋកថា
4	152	1	សុខាវតីព្យូហ:សូត្រ ក្បាលទី ២

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់

ចំពូកទី ៤

1	162	1	សុខាវតីព្យូហៈសូត្រ ក្បាលទី ១
	167	4	សុខាវតីព្យូហៈសូត្រ ក្បាលទី ២
	169	5	អមិតាយុរធ្យានសូត្រ
2	174	7	សុខាវតីព្យូហៈសូត្រ គម្ពីរតូច

វត្តប្រតិបត្តិព្រះពុទ្ធសាសនា

ចំពូកទី ១

1	180	1	ម.ន.២ សព្វាសវសូត្រ
	183	2	ម.ន. ៣-២៦ អរិយបរិយេសនសូត្រ
	184	3	ស.ន. ៣៩-២០៦ ឆបានសូត្រ
	185	14	សូត្រ ៤២ ចំពូក ៤១-២
	189	11	ម.ន. ២-១៩ ទ្វេធាវិតក្កសូត្រ
	190	16	ធម្មបទ អដ្ឋកថា
2	192	11	អ.ន. ៣-១១៧
	193	10	ម.ន. ៣-២១ កកចូបមសូត្រ
	198	11	ម.ន. ៣-២៣ វម្មីកសូត្រ
	201	3	ជាតក ៤-៤៩៧ មាតង្គជាតក
	207	4	សូត្រ ៤២ ចំពូក ៩
	207	14	សូត្រ ៤២ ចំពូក ១១
	209	14	សូត្រ ៤២ ចំពូក ១៣

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
	210	14	អ.ន. ២-៤សមចិត្តសូត្រ
3	212	1	សំយុក្តវត្ឋបិដកសូត្រ
	227	14	មហាបរិនិព្វានសូត្រ
	229	2	សំយុក្តវត្ឋបិដកសូត្រ

ជំពូកទី ២

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
1	235	1	ម.ន. ៧-៦៣ ចូឡមាលុក្យសុត្តន្ត
	238	5	ម.ន. ៣-២៩ មហាសារោបមសូត្រ
	240	12	មហាមាយាសាស្ត្រា
	241	10	ថេរគាថា អដ្ឋកថា
	244	9	ម.ន. ៣-២៨ មហាហត្ថិបទោបមសូត្រ
	245	11	មហាបរិនិព្វានសូត្រ
	246	8	អវទានសតកសូត្រ
	248	9	មហាបរិនិព្វានសូត្រ
	251	4	បញ្ចវិមំសតិ សាហស្រិកា ប្រាជ្ញាបារមិតាសូត្រ
	253	9	អវតំសកសូត្រ ៣៤ គណ្ឌព្យូហៈ
2	256	8	អ.ន. ៣-៨៨
	257	14	អ.ន. ៣-៨១
	258	4	អ.ន. ៣-៨២
	259	3	បរិនិព្វានសូត្រ ក្បាលទី ២
	260	14	ម.ន. ១៤-១៤១ សច្ចវិភង្គសូត្រ
	262	7	បរិនិព្វានសូត្រ ក្បាលទី ២

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
	263	5	អ.ន. ៥-១៦ ពលសូត្រ
	263	9	អវតំសកសូត្រ ៦
	264	14	មហាបរិនិព្វានសូត្រ
	265	11	សំយុក្តវត្ថុបិដកសូត្រ ២៦
	266	10	សុវណ៌ ប្រភាសសូត្រ ២៦
	267	12	មហាបរិនិព្វានសូត្រ
	269	7	ថេរគាថា អដ្ឋកថា
	270	11	ជាតក ៥៥ បញ្ញាវុធជាតក
	272	8	ឥតិវុត្តក ៣៩-៤០
	273	5	មហាបរិនិព្វានសូត្រ
	273	7	មហាបរិនិព្វានសូត្រ
	273	10	អ.ន. ៥-១២
	274	3	បរិនិព្វានសូត្រ
	274	15	សូរំគមសូត្រ
3	276	12	ស.ន. ៥៥-២១ ២២ មហានាមសូត្រ
	277	13	អ.ន. ៥-៣២ ចុន្ទីសូត្រ
	278	8	វិមលកិត្តិនិរទេសសូត្រ
	279	6	សូរំគមសូត្រ
	279	14	សុខាវតីព្យូហៈសូត្រ ក្បាលទី ២
	280	9	ស.ន. ១-៤-៦
	280	13	អវតំសកសូត្រ ៣៣

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
	282	1	អវតំសកសូត្រ ២៤
	283	1	សុវណ៌ប្រភាសសូត្រ ៤
	283	13	អមិតាយុរធ្យានសូត្រ
	283	16	សុខាវតីព្យូហៈសូត្រ
	284	6	មហាបរិនិព្វានសូត្រ
	285	10	ម.ន. ២-១៦ ចេតោខិលសូត្រ
	286	12	សុខាវតីព្យូហៈសូត្រ ក្បាលទី ២
4	287	16	ធម្មបទ
	298	14	ស.ន. ១-៤-៦
	299	12	អ.ន.
	299	17	មហាបរិនិព្វានសូត្រ

ភាគភាពរាជ័ពុទ្ធសាសនិក

ចំពូកទី ១

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
1	304	1	ឥតិវុត្តក ១០០, ម.ន. ១-៣ ធម្មទាយាទសូត្រ
	304	9	ឥតិវុត្តក ៩២
	305	8	វិន័យ មហាវគ្គ ១-៣០
	306	12	ម.ន. ៤-៣៩ មហាអស្សបុរសូត្រ
	308	10	ម.ន. ៤-៤០ ចូឡអស្សបុរសូត្រ
	310	1	សទ្ធម៌បុណ្ឌរីកសូត្រ ១៩
	310	8	សទ្ធម៌បុណ្ឌរីកសូត្រ ១៩

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់
	310	16	សទ្ធម៌បុណ្ឌរីកសូត្រ១៤
2	312	15	ស.ន. ៥៥-៣៧ មហានាមសូត្រ
	313	9	អ.ន. ៣-៧៥
	313	17	ស.ន. ៥៥-៣៧ មហានាមសូត្រ
	314	6	ស.ន. ៥៥-៥៤ គិលាយនំសូត្រ
	314	11	អវតំសកសូត្រ ២២
	316	16	មហាបរិនិព្វានសូត្រ
	321	1	អវតំសកសូត្រ ៧
	324	15	មហាមាយាសូត្រ
	326	8	អវតំសកសូត្រ ២១
	327	15	មហាបរិនិព្វានសូត្រ
3	330	1	ទ.ន. ៣១ សិង្គាលោវាទសូត្រ
	337	16	អ.ន. ២-៤ សមចិត្តសូត្រ
	338	15	អ.ន. ៣-៣១
	339	5	ជាតក ៤១៧ កច្ចានិជាតក
	342	5	ទ.ន. ៣១ សិង្គាលោវាទសូត្រ
	343	1	ធម្មបទអដ្ឋកថា ១
	345	4	តាមអដ្ឋកថាពុទ្ធសាសនាភូមា
	346	7	ស្រីមាលាទេវីសីហនាទសូត្រ

វគ្គ	ទំព័រ	បន្ទាត់	ប្រភពដកស្រង់

ចំពូកទី ២

1	350	1	មហាបរិនិព្វានសូត្រ
	352	11	អ.ន. ៣-១១៨ សោចេយ្យនសូត្រ
	354	14	ស.ន.
	355	9	វិន័យ មហាវគ្គ ១០-១-២
	356	2	ទ.ន. ១៦ មហាបរិនិព្វានសូត្រ
	357	16	វិន័យ មហាវគ្គ ១០-១-២
2	361	16	ស.ន.
	363	6	សាស្ត្រា ជីអ៊ីផក្ស
	363	13	វិមលកិត្តិនិរទេសសូត្រ
	365	10	មហាបរិនិព្វានសូត្រ
	366	12	សុខាវតីព្យូហៈសូត្រ គម្ពីរតូច
	367	3	សុខាវតីព្យូហៈសូត្រ
	367	16	វិមលកិត្តិនិរទេសសូត្រ
3	368	11	ធម្មបទអដ្ឋកថា ១
	369	5	អ.ន. ៣៤-២
	370	9	ធម្មបទអដ្ឋកថា ១
	371	11	អ.ន. ៥-១
	372	1	មូលសព៌ាស្តិវាទ សង្ឃភេទកពស្តុ ១០
	373	2	ម.ន . ៩-៨៦ អង្គុលីមាលសូត្រ
	374	15	អ.ន. ២៦

សេចក្ដីបន្ថែម

I

ប្រវត្តិសង្ខេបនៃព្រះពុទ្ធសាសនា

១- ប្រទេសឥណ្ឌា

ព្រឹត្តិការណ៍ដ៏ធំមួយក្នុងប្រវត្តិជំនឿសាសនា ដែលគួរកត់សម្គាល់ បាន កើតឡើង នៅពេលដែល «ពន្លឺអាស៊ីទ្វីប» ចាប់មានរស្មីភ្លឺត្រចេះត្រចង់ នៅ ក្នុងភូមិភាគកណ្ដាលនៃប្រទេសឥណ្ឌា។ បើនិយាយម៉្យាងទៀតគឺ នៅពេល នោះមហាប្រាជ្ញាញាណ និងមហាករុណាអាសូរនៃព្រះពុទ្ធបានចាប់ផ្ដើម ផុស ចេញឡើង បណ្ដុះបណ្ដាល ទាក់ទាញចិត្តមនុស្សលោកជាបន្តបន្ទាប់រាប់ សតវត្សរហូតមកទល់សព្វថ្ងៃនេះ។

ព្រះពុទ្ធគោតម ដែលពុទ្ធសាសនិកទាំងឡាយស្គាល់ព្រះអង្គក្នុងព្រះនាម ថា ព្រះសក្យមុនី ព្រះអង្គជា «អ្នកប្រាជ្ញបណ្ឌិតក្នុងកុលសម្ព័ន្ធសក្យ» ព្រះ អង្គទ្រង់បានចាកចោលព្រះរាជដំណាក់ ប្រែភេទជាស្នូម ហើយបោះជំហាន ឈានឆ្ពោះទៅទិសខាងត្បូងនៃមគធនគរ។ តាមការស្មានយល់នៃជនទាំងឡាយ គឺ ព្រះអង្គទ្រង់បានសម្រេចពន្លឺត្រាស់ដឹង នៅពាក់កណ្ដាលសតវត្សទី៦ មុន គ្រិស្តសករាជ នៅក្រោមដើមពោធិព្រឹក្ស។ ចាប់តាំងពីពេលនោះរហូតមកទល់ ពេលព្រះអង្គចូលមហាបរិនិព្វាន គឺក្នុងអំឡុង៤៥ឆ្នាំ ព្រះអង្គទ្រង់បានបំពេញ ពុទ្ធកិច្ច ផ្សាយព្រះសាសនា ប្រោសសត្វលោក ដោយគ្មានគិតដល់ការនឿយ ហត់របស់ព្រះអង្គឡើយ។ វត្តអារាមនៃពុទ្ធសាសនា ក៏ចេះតែមានចំនួនកើត

ច្រើនឡើងជាលំដាប់ នៅក្នុងរាជាណាចក្រទាំងឡាយ ក្នុងកុលសម្ព័ន្ធទាំងឡាយ នាប្រទេសឥណ្ឌាភាគកណ្ដាល។

ក្នុងរជ្ជកាលស្ដេច អសោក ក្សត្រទី៣ក្នុងសន្ដតិវង្សមោរ្យ សោយរាជ្យពីឆ្នាំ ២៦៨ ដល់ឆ្នាំ ២៣២ មុនគ្រិស្ដសករាជ សាសនាព្រះពុទ្ធគោតម ត្រូវបានផ្សព្វផ្សាយពាសពេញប្រទេសឥណ្ឌាទាំងមូល រហូតដល់ទៅប្រទេសក្រៅទៀតផង។

នគរមោរ្យ ជារដ្ឋទី១ ក្នុងចំណោមនគរធំៗ នៃឥណ្ឌាទ្វីប។ ក្នុងរាជ្យស្ដេចទី១ ព្រះនាម ចន្រ្ទគុប្ដ ប្រហែលឆ្នាំ ៣១៧-២៩៣ មុនគ្រិស្ដសករាជ នគរនេះមានដែនដីធំធេងជាស្រេច ទៅខាងជើងលាតសន្ធឹងដល់ជួរភ្នំហេមពាន្ដ ទៅខាងកើតលាតសន្ធឹងដល់ឈូងសមុទ្របង់ហ្គាល ទៅខាងលិចលាតសន្ធឹងដល់ជួរភ្នំហិន្ទូគុស្ហ នៅខាងត្បូងលាតសន្ធឹងដល់ជួរភ្នំវិនធ្យ។ ព្រះបាទអសោកទ្រង់បានពង្រីកទឹកដីជាបន្ដទៅទៀត នៅតាមខ្លង់រាប នៃតំបន់ ដេក្កង់ ដោយព្រះអង្គបានច្បាំងយកតំបន់ កលិង្គ និងតំបន់ឯទៀតជាច្រើន។

មានគេនិយាយថា ស្ដេចអង្គនេះមានចរិតឆេវឆាវ ឆាប់ខ្ញាល់ណាស់ រហូតដល់មានព្រះនាមមួយទៀតថា ឆន្ទាសោក ឬស្ដេចកំហឹងអសោក។ ប៉ុន្ដែក្រោយមក ស្ដេចអង្គនេះបានកែប្រែចរិតខឹងក្រោធចោលចេញអស់ នៅពេលដែលព្រះអង្គទ្រង់បានយល់នូវលទ្ធផលខូចខាតធំ ក្នុងសង្រ្គាមជាមួយនគរកលិង្គ ហើយព្រះអង្គ ក៏បានទៅជាអ្នកជឿតាមសាសនាព្រះពុទ្ធយ៉ាងស្មោះស្ម័គ្របំផុតម្នាក់។ ចាប់តាំងពីពេលនោះមក ព្រះអង្គទ្រង់បានកសាងកុសលជាច្រើន ក្នុងភារៈជាអ្នកកាន់ព្រះពុទ្ធសសនា។ ក្នុងចំណោមកុសលធំៗ ទាំងឡាយមានកុសលពីរជាពិសេស ដែលគួរកត់សម្គាល់។

សមិទ្ធិទី១ គឺ «រាជបញ្ញត្តិព្រះអសោក» ដែលជាគោលច្បាប់សម្រាប់រាជរដ្ឋាភិបាល ដែលយោលយកព្រះពុទ្ធសាសនាជាគ្រឹះ។ ព្រះអង្គទ្រង់បញ្ជាឲ្យគេចារិកគោលច្បាប់ទាំងនោះ ទុកនៅលើសសរថ្ម និងជញ្ជាំងថ្ម ដែលជាកិច្ចមួយបណ្ដាលឲ្យ ព្រះពុទ្ធសាសនារឹតតែបានរីកសុសសាយឡើង។

សមិទ្ធិទី២ គឺ ព្រះអង្គទ្រង់បានបញ្ជូនគណៈបេសកកម្ម ទៅគ្រប់ទិសតំបន់ដើម្បីផ្សាយព្រះពុទ្ធសាសនា។ ជាពិសេសគួរកត់សម្គាល់គឺ គណៈបេសកកម្មទាំងឡាយដែលត្រូវបានបញ្ជូនទៅភូមិភាគដូចជា ប្រទេសស៊ីរី ប្រទេសអេហ្ស៊ីប ប្រទេសលីប៊ី ប្រទេសម៉ាសេដ្វាន និងប្រទេសអេពៀរ៍ បានផ្សាយព្រះពុទ្ធសាសនាពាសពេញបស្ចឹមទ្វីប។ ក្រៅពីនេះ អ្វីដែលគួរកត់សម្គាល់ដែរគឺ សាសនទូតឈ្មោះ មហេន្ទ ដែលត្រូវបានបញ្ជូនទៅប្រទេសសិរីលង្កា បានទទួលមហាជោគជ័យក្នុងការរៀបចំផ្សាយសាសនាប្រសើរបំផុតនេះ នៅក្នុងលង្កាទ្វីប ហើយបានបង្កើតមូលដ្ឋានដើម្បីចេញផ្សាយព្រះពុទ្ធសាសនាលើកោះទាំងមូល។

២- ដើមកំណើតពុទ្ធសាសនាមហាយាន

«ចលនាពុទ្ធសាសនាឆ្ពោះទៅទិសខាងកើត» ទើបតែត្រូវបានពុទ្ធសាសនិកទាំងឡាយនាំគ្នានិយាយជាញឹកញាប់ ក្នុងរយៈប៉ុន្មានសតវត្សចុងក្រោយនេះទេ។ ប្រវត្តិសាស្ត្របញ្ជាក់ឲ្យឃើញថា ពុទ្ធសាសនាបានបែរមុខឆ្ពោះទៅទិសខាងលិច តាំងពីច្រើនសតវត្សមុនគ្រិស្តសករាជមកហើយ ទើបតែនៅមុនគ្រិស្តសករាជបន្តិច ឬក្រោយនោះបន្តិចនេះទេ ដែលពុទ្ធសាសនាចាប់បែរមុខឆ្ពោះទៅទិសខាងកើត។

ប៉ុន្តែមុននឹងចូលដល់រឿងនេះ យើងត្រូវនិយាយអំពី ការប្រែប្រួលធំមួយនៅក្នុងប្រវត្តិពុទ្ធសាសនា។ ការប្រែប្រួលនេះ គឺ«ចលនាថ្មី» ដែលមានឈ្មោះថា ពុទ្ធសាសនាមហាយាន ឬពុទ្ធសាសនាយានធំ ដែលចាក់ឫសយ៉ាងជ្រៅ ហើយដុះចេញឡើងជាមែកធាងយ៉ាងធំ នៅក្នុងពុទ្ធសាសនា នាពេលនោះ។

តើ «ចលនាថ្មី» នេះចាប់កំណើតយ៉ាងដូចម្តេច នៅទីកន្លែងណា? គ្មាននរណាម្នាក់អាចផ្តល់ចម្លើយឲ្យបានច្បាស់លាស់ ពិតប្រាកដ ក្នុងរឿងនេះទេ។ ចំពោះរឿងនេះ យើងអាចបញ្ជាក់បានតែព្រឹត្តិការណ៍ខ្លះៗ ដូចតទៅនេះ : ទី១ គឺ និន្នាការដែលត្រូវតែកើតឡើងនៅក្នុងគំនិតនៃមហាសង្ឃិកនិកាយ ក្នុងចំណោមពពួកសង្ឃជឿនលឿនជាងគេក្នុងពេលនោះ។ ព្រឹត្តិការណ៍ទី២ គឺគោលសំខាន់ខ្លះនៃគម្ពីរមហាយាន មានតាំងពីក្នុងសតវត្សទី១ មុនគ្រិស្តសករាជមកម្ល៉េះ។ ហើយនៅពេលដែលគតិដ៏ប្រសើរថ្លៃថ្លា នៃព្រះថេរៈ **នាគាវជុនៈ** ដែលមានគម្ពីរមហាយានជាគ្រឹះ បានលូតលាស់មានសកម្មភាពឡើង ពុទ្ធសាសនាមយាហាន ក៏មានពន្លឺចែងចាំងឡើង ភ្លឺជាងគេនៅក្នុងប្រវត្តិសាស្ត្រនាសម័យនោះ។

ក្នុងប្រវត្តិសាស្ត្រដ៏វែងនៃព្រះពុទ្ធសាសនា ពុទ្ធសាសនាមហាយានមានមុខងារសំខាន់ណាស់។ នៅក្នុងប្រទេស ដូចជាប្រទេសចិន ប្រទេសជប៉ុនជាដើម សឹងតែក្នុងរយៈពេលមួយចប់ប្រវត្តិសាស្ត្ររបស់គេ ព្រះពុទ្ធសាសនាត្រូវបានលូតលាស់ឡើងនៅក្រោមអានុភាពមហាយាន។ ក្នុងរឿងនេះ គ្មានអ្វីគួរឆ្ងល់ទេ ព្រោះមហាយានបានបង្កើតឧត្តមគតិថ្មីមួយក្នុងគោលបំណងស្រោចស្រង់មនុស្សជាស្រេចមកហើយ ដោយគិតទុកសន្តបុគ្គលថ្មីៗ ដែលមានជីវិត

រស់នៅៗឡើយ ជាពោធិសត្វ ដែលមានភារៈយកឧត្តមគតិនេះទៅអនុវត្ត ដើម្បីស្រោចស្រង់សត្វលោក។ ម្យ៉ាងទៀត គោលគំនិតនៃពួកទស្សនវិទូខាងមហាយានក្នុងការគាំទ្រឧត្តមគតិនេះតាមដោយបរមត្ថវិជ្ជា ឬចិត្តសាស្ត្រ ពិតជាវិសេសពន់ពេកណាស់។ តាមរបៀបនេះ គណៈមហាយានមានការទាក់ទងនឹងសេចក្ដីប្រៀនប្រដៅរបស់ព្រះពុទ្ធគោតម ក៏ពិតហើយ តែមានអភិវឌ្ឍន៍ថ្មីៗជាច្រើន ដែលទាក់ទងនឹងព្រះប្រាជ្ញាញាណ ហើយនឹងព្រះមហាសន្ដោសអាសូរត្រូវបានបន្ថែមទៅលើពុទ្ធឱវាទនេះ។ ដោយសារអភិវឌ្ឍន៍ថ្មីៗទាំងនេះ ព្រះពុទ្ធសាសនាមានសកម្មភាពជាខ្លាំង ហើយបានរីកចម្រើនជាពន្លឺកនៅចុងបូព៌ាប្រទេស ប្រដូចបានទៅនឹងចរន្តទឹកហូរខ្លាំងនៃទន្លេ។

៣- អាស៊ីកណ្ដាល

គឺពីប្រទេសក្នុងភូមិភាគមជ្ឈិមអាស៊ីនេះហើយ ដែលប្រទេសចិនបានទទួលពុទ្ធសាសនាជាដំបូង។ ដូច្នេះ ដើម្បីបង្ហាញឲ្យឃើញថា តើសាសនានេះចេញពីប្រទេសឥណ្ឌាទៅប្រទេសចិនរបៀបណានោះ ជាការចាំបាច់ត្រូវតែនិយាយអំពី «ផ្លូវសូត្រ»។ ផ្លូវនេះ កាត់តាមភូមិភាគជំទូលាយឥតព្រំដែននៃអាស៊ីភាគកណ្ដាល ក្នុងបំណងភ្ជាប់បូព៌ាទ្វីប នឹងបស្ចិមទ្វីប។ ផ្លូវសេដ្ឋកិច្ចនេះត្រូវបានបើកឡើង ក្នុងរាជ្យស្ដេច វូ ១៤០-៨៧ មុនគ្រិស្ត ក្នុងសន្តតិវង្សហាន។ ក្នុងសម័យនោះ អំណាចចក្រពត្រនៃវង្សក្សត្រ ហាន បានវាតសន្ទឹងយ៉ាងឆ្ងាយឆ្ពោះទៅបស្ចិមទិស ដោយបានភ្ជាប់ភូមិភាគទាំងឡាយ ដូចជាប្រទេស តេរហ្គាន សុហ្គឌីយ៉ាន តុខារា បារថីយ៍ ជា ដើម។ គំនិតពាណិជ្ជ-

និយមដែលផុសឡើងជាដំបូង ពីអធិរាជ **អាឡិចសង់មហារាជ** មានសកម្ម-ភាពខ្លាំងក្លាជាទីបំផុត។ នៅតាមដងផ្លូវដែលកាត់តាមភូមិភាគទាំងនេះ សូត្រមានមុខងារសំខាន់ជាងគេបង្អស់ ក្នុងផ្នែពាណិជ្ជកម្ម។ ហេតុដូច្នេះហើយបានជា ផ្លូវនេះមានឈ្មោះថា «ផ្លូវសូត្រ»។ នៅមុនគ្រិស្តសករាជបន្តិច ឬក្រោយគ្រិស្តសករាជបន្តិច ប្រទេសឥណ្ឌា និងប្រទេសចិន ចាប់មានការទាក់ទងគ្នាខាងផ្នែកវប្បធម៌ តាមផ្លូវនេះឯង។ ដូច្នេះ គេអាចនិយាយបានដែរថា ផ្លូវនេះជា«ផ្លូវផ្សាយព្រះពុទ្ធសាសនា»។

៤- ប្រទេសចិន

ប្រវត្តិពុទ្ធសាសនាចិន ចាប់ផ្តើមឡើង នៅពេលបានទទួលគម្ពីរពុទ្ធ-សាសនា ហើយចាប់បកប្រែគម្ពីរទាំងនោះ។ ស្នាដៃនិពន្ធដែលចាស់ជាងគេនាបូរាណកាលនោះ បើតាមគេនិយាយគឺមាន «ព្រះសូត្រ ៤២ មាត្រា» ឬជាភាសាចិនថា ស៊ឺស្ហិញអែរចាងជិង និពន្ធដោយព្រះថេរៈ កាស្យបមាតង្គ និងស្នាដៃឯទៀតៗ ក្នុងសម័យ យីងប៉ិង ៥៨-៧៦ នៃគ្រិស្តសករាជ ក្នុងរាជ្យស្តេចមិញ នៃសម័យខាងក្រោយបន្តិរបស់ហានផ្នែកខាងកើត។ ប៉ុន្តែសព្វថ្ងៃនេះគេទុករឿងតំណាលនេះ ជារឿងព្រេងទៅវិញ។ សព្វថ្ងៃនេះ តាមមតិដែលយោលទៅតាមកស្តុតាងគ្រប់គ្រាន់ គឺព្រះថេរៈ អានស្ហិនកៅ ដែលបានបកប្រែមុនដំបូង នៅ លោយ៉ាង ពីឆ្នាំ ១៤៨ ដល់ ១៧១។ ចាប់តាំងពីពេលនោះរហូតមកដល់សន្តតិវង្ស សុង ខាងដើង ឆ្នាំ ៩៦០-១១២៩ ការប្រែភាសាត្រូវបានធ្វើជាបន្តបន្ទាប់ ក្នុងរយៈពេលជិតមួយពាន់ឆ្នាំ។

ជាច្រើនឆ្នាំមុនដំបូង អ្នកនាំចូល និងបកប្រែគម្ពីរទាំងឡាយ ដែលគួរកត់សម្គាល់ គឺព្រះសង្ឃភាគច្រើន ដែលមកពីអាស៊ីភាគកណ្តាល។ ឧទាហរណ៍ដូចជា ព្រះថេរៈ អានស្ហិនកៅ មកពីតំបន់ បរថិយ៍។ ព្រះថេរៈ ***ក្វាងសេងកៃ*** *ចូលមកតំបន់ លោយ៉ាង នៅក្នុងសតវត្សទី៣ ហើយបានបកប្រែគម្ពីរ* ***សុខាវតីព្យូហៈ*** *ឬគម្ពីរព្រះសូត្រស្តីអំពីជីវិតគ្មានទីបំផុត នោះជាជនមកពីតំបន់* ***សមរកន្ទ។*** *ក្រៅពីនេះ ព្រះថេរៈ* ***ធូហ្វាហូ*** *ឬឈ្មោះជាបាលីថា* ***ធម្មរក្ស****ដែលល្បីល្បាញក្នុងការបកប្រែគម្ពីរ* ***សទ្ធម៌បុណ្ឌរីក*** *មកពីតំបន់* ***ទុខារ*** *ហើយមកតាំងទីលំនៅ។ លោយ៉ាង ឬ ឆាងអាន ពីចុងសតវត្សទី៣ មកដល់ដើមសតវត្សទី៤។ នៅពេលដែល****កុមារជីវៈ*** *មកពីតំបន់* ***កុឆា*** *បានបញ្ចេញមុខឡើង នៅដើមសតវត្សទី៥ ការបកប្រែគម្ពីរនៅប្រទេសចិនបានឡើងដល់កំពូល។*

គឺចាប់ពីសម័យនោះហើយ ដែលពួកព្រះសង្ឃចាប់ចេញពី ប្រទេសចិនទៅប្រទេសឥណ្ឌា ដើម្បីស្វែងរករៀនភាសាសំស្ក្រឹត និងពុទ្ធវិន័យ។ ក្នុងចំណោមព្រះសង្ឃទាំងនោះ មានព្រះសង្ឃមួយអង្គឈ្មោះ ***ហ្វាស៊ី អេន*** *៣៣៩-៤២០?។ ព្រះសង្ឃអង្គនេះ ចេញពី លោយ៉ាង នៅប្រទេសឥណ្ឌា ក្នុងឆ្នាំ ៣៩៩ ហើយត្រឡប់មកវិញ ដប់ប្រាំឆ្នាំក្រោយនោះ។ ក្នុងចំណោមព្រះសង្ឃដែលទៅប្រទេសឥណ្ឌា ព្រះថេរៈ ហ្សីអានធូវអាង ឆ្នាំ ៦០២-៦៦៤ មានឈ្មោះល្បីល្បាញជាងគេបង្អស់។ ព្រះសង្ឃអង្គនេះ និមន្តទៅប្រទេសឥណ្ឌាក្នុងឆ្នាំ ៦២៧ ហើយត្រឡប់មកវិញក្នុងឆ្នាំ ៦៤៥ គឺ១៩ឆ្នាំ ក្រោយមក។ ក្រៅពីនោះ មានព្រះថេរៈ អ៊ីធិង ឆ្នាំ ៦៣៥-៧១៣ ព្រះអង្គនិមន្តទៅប្រទេស*

ឥណ្ឌា តាមផ្លូវសមុទ្រ ក្នុងឆ្នាំ ៦៧១ ហើយត្រឡប់មកស្រុកកំណើតវិញតាមផ្លូវដដែល ២៥ឆ្នាំ ក្រោយនោះ។

ពួកព្រះសង្ឃទាំងនោះ ទ្រង់និមន្តទៅប្រទេសឥណ្ឌា ដោយចិត្តឯងដើម្បីរៀនភាសាសំស្ក្រឹត នាំយកមកប្រទេសកំណើតវិញនូវគម្ពីរ ដែលបានជ្រើសរើសដោយផ្ចិតផ្ចង់ ហើយចាប់បកប្រែគម្ពីរទាំងនោះ។ ជាពិសេសចំណេះខាងភាសាវិទ្យារបស់ព្រះថេរៈ **ហ្សឺអានឆាង** អស្ចារ្យណាស់។ ដោយសារសកម្មភាពដ៏ខ្លាំងក្លានៃព្រះថេរៈអង្គនេះ ការបកប្រែគម្ពីរនៅប្រទេសចិនបានឡើងដល់ចុងកំពូលមួយទៀត។ ពួកអ្នកប្រាជ្ញបណ្ឌិតខាងពុទ្ធសាសនាជំនាន់ក្រោយមក បានដាក់ឈ្មោះថា «ភាសាបរិវត្តន៍ចាស់» ចំពោះការបកប្រែដែលធ្វើឡើងនៅសម័យមុនដំបូង ដោយពួកព្រះសង្ឃ ដូចជា ព្រះថេរៈ **កុមារជីវៈ** ជាដើម ហើយដាក់ឈ្មោះថា «ភាសាបរិវត្តន៍ថ្មី» ចំពោះការបកប្រែដែលធ្វើឡើងដោយព្រះថេរៈ ហ្សឺអានឆាង និងពួកអ្នកបកប្រែភាសាជំនាន់ក្រោយៗ មកទៀត។

ដោយពឹងផ្អែកទៅលើគម្ពីរពុទ្ធសាសនាជាច្រើនមហិមា ដែលបានបកប្រែពីសំស្ក្រឹតទាំងនេះ គោលគំនិត និងសកម្មភាពសាសនាជាច្រើនមហិមានៃអ្នកប្រាជ្ញាបណ្ឌិតទាំងនោះ បានជ្រួតជ្រាបបន្តិចម្តងៗ តែប្រាកដប្រជា ទៅក្នុងចិត្តគំនិតរបស់គេ តាមសភាពជាចិននិយម។ ត្រង់នេះបង្ហាញឲ្យឃើញទាំងស្រុងនូវសភាព ពូជសាសន៍ សេចក្តីត្រូវការ និងជំនឿទុកចិត្តទៅលើនិន្នាការនេះ។ ក្នុងវិស័យបរមត្ថវិជ្ជាការដែលព្រះសង្ឃទាំងនោះ តាំងពីដើមដំបូងមក មានគោលគំនិតឆ្ពោះទៅរក «ភាពទទេ» ដែលមាននិទាននៅក្នុង

សាស្ត្រា «ប្រាជ្ញា» ជាពិសេសនោះ ជាការបញ្ជាក់ឲ្យឃើញនូវនិន្នាការនេះ។ ក្រោយមកព្រះសង្ឃទាំងនោះបានបោះបង់ចោលនូវការនិយម ដែលគេហៅថា «ហីនយាន» ឬយានតូច ហើយបែរគំនិតទាំងស្រុងទៅរក «មហាយាន» ឬ យានធំវិញ។ម្យ៉ាងទៀត និន្នាការនេះកាន់តែច្បាស់ឡើង ជាលំដាប់ នៅក្នុងនិកាយ ***តេនដៃ*** ហើយគេអាចនិយាយបានថានិន្នាការនេះបានឡើងដល់ចុងកំពូល នៅពេលដែលនិកាយ ហ្វ៊ន កើតឡើង។

នៅចុងសតវត្សទី៦ និកាយ តេនដៃ បានឡើងដល់ភាពពេញបរិបូរណ៍ នៅក្នុងប្រទេសចិន ក្រោមឥទ្ធិពល តេនដៃដៃស៊ី ឬឈីអ៊ី គ.ស.៥៣៨-៥៩៧ ក្នុងសម្តេចព្រះសង្ឃរាជទី៣ របស់ខ្លួន។ ឈីអ៊ី នេះ ជាអ្នកតំណាងគំនិតពុទ្ធសាសនានិយមខ្ពង់ខ្ពស់ជាងគេមួយរូប។ ទ្រឹស្តីបែងចែក ចាត់ជាថ្នាក់ នូវពុទ្ធោវាទ ជា៥កាល និង៨វាទៈ ដែលធ្វើឡើងដោយសន្តបុគ្គលអង្គនេះ មានឥទ្ធិពលខ្លាំងក្លាជាយូរអង្វែង ទៅលើពុទ្ធសាសនាក្នុងប្រទេសចិន ក៏ដូចជាក្នុងប្រទេសជប៉ុនដែរ។

ការស្រាវជ្រាវយ៉ាងល្អិតល្អន់បានបង្ហាញឲ្យឃើញថា សាស្ត្រាទាំងឡាយ ត្រូវបាននាំចូលមកក្នុងប្រទេសចិន ដោយមិនបានគិតដល់ប្រវត្តិកំណើតនៃសាស្ត្រាទាំងនោះទេ ហើយត្រូវបានបកប្រែជាបន្តបន្ទាប់ នៅពេលដែលសាស្ត្រាទាំងនោះចូលមក។ ចំពោះសាស្ត្រាជាច្រើនអនេកនេះ សំនួរត្រូវបានចោទឡើង អំពីការរកឲ្យយល់នូវដើមកំណើត និងតម្លៃ នៃសាស្ត្រាទាំងនោះ។ ជាការចាំបាច់ ត្រូវតែគិតថ្លឹងតម្លៃព្រះពុទ្ធសាសនា ក្នុងសភាពជាទូទៅ ហើយម្នាក់ៗជាចាំបាច់ ត្រូវតែគិតទៅតាមចំណេះប្រាជ្ញា យល់ឃើញរបស់ខ្លួនផ្ទាល់។ ក្នុងការឲ្យតម្លៃដល់សាស្ត្រាទាំងឡាយ និន្នាការនៃជំនឿ តាមរបៀបចិននិយម មានមុខងារសំខាន់ណាស់។ ការឲ្យតម្លៃតាមជំនឿនៃព្រះថេរៈ ឈី

អ៊ី មានរបៀបរបបជាងគេបង្អស់ ដូច្នេះត្រូវបានគេជឿតាមយ៉ាងអស្ចារ្យ។ ប៉ុន្តែ ដោយការស្រាវជ្រាវពុទ្ធសាសនាសម័យថ្មីបានកើតឡើង ឥទ្ធិពលខ្លាំងក្លានេះ ត្រូវអស់បន្តិចម្តងៗ ជាលំដាប់។

នៅក្នុងប្រវត្តិពុទ្ធសាសនាចិន និកាយដែលកើតក្រោយគេបង្អស់គឺនិកាយហ្សិន។ តាមពាក្យគេនិយាយ អ្នកបង្កើតនិកាយនេះ ជាអ្នកបួសមួយអង្គ មកពីបរទេស មាននាមថា ពោធិធម៌ ឆ្នាំ ?-៥២៨ ក្រោយគ្រិស្តសករាជ។ ប៉ុន្តែ គ្រាប់ពូជដែលព្រះសង្ឃអង្គនេះបានបណ្តុះ បានប្រកបផលផ្លែផ្កា យ៉ាងរុងរឿង នៅក្រោយរជ្ជកាល ហួយ ណេង គ.ស.៦៣៨-៧១៣ ឯណោះ គឺនៅក្នុងជំនាន់ទី៦ នៃត្រកូលនេះ។ ក្រោយសតវត្សទី៨ និកាយនេះបានបញ្ចេញព្រះសង្ឃជំនាញៗ ជាច្រើន ជាបន្តបន្ទាប់ ដែលបណ្តាលឲ្យនិកាយ ហ្សិននេះ បានចម្រើនរុងរឿងក្នុងរយៈជាច្រើនសតវត្ស។

គេសង្កេតឃើញថា ចំពោះព្រះពុទ្ធសាសនា មានការគិតពិចារណាតាមរបៀបថ្មីមួយ ដែលមានឫសគល់យ៉ាងជ្រៅនៅក្នុងចរិតនៃប្រជាជនចិន។ ការនេះ គ្មានអ្វីក្រៅពីពុទ្ធសាសនា ដែលយោលទៅតាមគតិនិយមចិន នោះទេ។ ដោយសារមានចរន្តគតិនិយមថ្មីនេះជាបន្ថែម សាសនាព្រះពុទ្ធគោតមរឹតតែរីកធំឡើងទៀត ហើយបានលូតលាស់សម្បើមនៅចុងបូព៌ាប្រទេស។

៥- ប្រទេសជប៉ុន

ប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសជប៉ុន ចាប់ផ្តើមឡើងក្នុងសតវត្សទី៦ នៃគ្រិស្តសករាជ។ ក្នុងឆ្នាំ ៥៣៨ ព្រះមហាក្សត្រនៃនគរ ប៉េចេ ជាភាសាជប៉ុន ហៅថា គឺដារ៉ា គឺប្រទេស កូរ៉េ សព្វថ្ងៃនេះ បានបញ្ជូនរាជទូតឲ្យនាំព្រះពុទ្ធរូប

មួយព្រះអង្គ និងសាស្រ្តាមួយក្បាល មកថ្វាយព្រះចៅអធិរាជគិមម៉ី។ នេះជាការនាំចូលនូវព្រះពុទ្ធសាសនា ជាលើកទីមួយ ទៅក្នុងប្រទេសជប៉ុន។ ដូច្នេះប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសជប៉ុនមកទល់សព្វថ្ងៃនេះ បានជាង ១៤០០ ឆ្នាំហើយ។

ក្នុងប្រវត្តិដ៏វែងនេះ យើងអាចគិតពិចារណាចំពោះពុទ្ធសាសនាជប៉ុនបានតាមមជ្ឈមណ្ឌលបី។ មជ្ឈមណ្ឌលទី១ គឺព្រះពុទ្ធសាសនា ក្នុងសតវត្សទី ៧ និងទី៨។ ដើម្បីបំភ្លឺការនេះឲ្យបានច្បាស់លាស់ យើងអាចរៀបរាប់អំពីព្រះវិហារហូរីយឺហ្សី គ.ស. ៦០៧ និងព្រះវិហារ តូដៃហ្សី គ.ស. ៧៥២។ ព្រះវិហារទាំងពីរនេះ បានសង់ឡើងក្នុងស័យនោះ។ កាលណាគេរំលឹកឡើងវិញអំពីសម័យនោះ គេមិនត្រូវភ្លេចគិតដល់កំពស់វប្បធម៌ដ៏ខ្ពង់ខ្ពស់អស្ចារ្យនៅក្នុងទ្វីបអាស៊ីទាំងមូល នាសម័យនោះទេ។ ក្នុងសម័យនោះ នៅពេលដែលអារ្យធម៌នៅបស្ចិមប្រទេសមានភាពងងឹតជ្រប់នោះ អារ្យធម៌នៅបូព៌ាប្រទេសមានដំណើរយ៉ាងសកម្ម សម្បើមអស្ចារ្យ។ នៅក្នុងប្រទេសចិន អាស៊ីកណ្តាល ឥណ្ឌា និងប្រទេសឯទៀតៗ នៅតំបន់អាគ្នេយ៍ សកម្មភាពក្នុងវិស័យបញ្ញាវន្តសាសនា និងវិចិត្រកម្ម មានដំណើរខ្លាំងក្លាណាស់។ ស្របជាមួយនឹងចលនានេះ ព្រះពុទ្ធសាសនា បានស្រោចស្រពពិភពខាងកើត នូវចរន្តមនុស្សធម៌ដ៏ធំធេង។ ចលនាថ្មីនៃវប្បធម៌ជប៉ុន ដែលមានសំណង់ព្រះវិហារ ហូរីយឺហ្សី និងតូដៃហ្សី ដ៏ល្អឆើតឆាយជាកស្តុតាង ហើយនឹងសកម្មភាពសាសនា និងវិចិត្រសិល្បៈ ប្រកបដោយពណ៌ឆើតឆាយដែលទាក់ទងនឹងព្រះវិហារទាំងនោះជាបន្ទាល់ បង្ហាញឲ្យឃើញច្បាស់ អំពីកំរិតវប្បធម៌ ដែលគ្របដណ្តប់ទៅលើផ្ទៃដ៏ធំធេងនៃអាស៊ីទ្វីប រហូតដល់ទៅចុងបូព៌ាប្រទេស។

ប្រទេសជប៉ុន ដែលមកទល់ពេលនោះ នៅមានអារ្យធម៌ទន់ទាបនៅឡើយ ក៏ត្រូវបានស្រោចស្រពដោយចរន្តវប្បធម៌ដ៏ធំនេះ ហើយផ្ទៃផ្កានៃអារ្យ-ធម៌ ក៏បានរីកយ៉ាងឆាប់រហ័ស។ នេះជាភ័ព្វវាសនាល្អមួយ ដែលប្រជាជនជប៉ុនបានទទួល នៅសតវត្សនោះ។ ដើមហេតុសំខាន់បំផុតដែលបណ្ដាលឲ្យមានការលូតលាស់នៃវប្បធម៌នេះ គ្មានអ្វីក្រៅពីព្រះពុទ្ធសាសនាទេ។ វិហារពុទ្ធសាសនាទាំងឡាយនាសម័យនោះ ត្រូវបានជាមណ្ឌលដ្ឋានសំខាន់នៃសង្គម ហើយព្រះសង្ឃទាំងឡាយមានមុខងារជាអ្នកដឹកនាំ ក្នុងផ្នែកសិក្សាអប់រំថ្មីនេះ។ មិនត្រឹមតែផ្នែកសាសនា តែមួយមុខប៉ុណ្ណោះទេ ព្រះសង្ឃទាំងនោះបានពង្រីកចេញជាវប្បធម៌ដ៏ធំទូលាយមួយ។ នេះហើយជាស្ថានភាពព្រះពុទ្ធសាសនា នៅពេលដែលនាំចូលមកក្នុងប្រទេសជប៉ុន មុនដំបូង។

មជ្ឈមណ្ឌលទី២ គឺ ព្រះពុទ្ធសាសនា នៅសតវត្សទី១២ និង១៣។ ក្នុងប្រទេសជប៉ុននៅពេលនោះ បព្វជិតល្បីល្បាញធំៗ ជាច្រើន បានលេចឈ្មោះឡើង ដូចជា ព្រះថេរៈ ហូនេន គ.ស. ១១៣៣-១២១២ ព្រះថេរៈ ស៊ីនរ៉ាន គ.ស. ១១៧៣-១២៦២ ព្រះថេរៈ ដូហ្គេន គ.ស. ១២០០- ១២៥៣ ព្រះថេរៈ នីជីរ៉ិង គ.ស. ១២២២-១២៨២ ជាដើម។ សព្វថ្ងៃនេះក៏ដោយ តែកាលណាគេនិយាយអំពីពុទ្ធសាសនាជប៉ុន គេមិនអាចបរិយាយដោយមិនបញ្ជាក់អំពីបព្វជិតធំៗទាំងនោះបានទេ។ ហេតុដូចម្ដេចបានជា បព្វជិតល្បីល្បាញអស្ចារ្យបានកើតឡើង នៅតែក្នុងសតវត្សនោះ ដូច្នេះ? គ្មានអ្វីគួរឆ្ងល់ទេ ពីព្រោះបញ្ហាជាទូទៅមួយ បានកើតឡើងចំពោះមហាបុគ្គល ទាំងឡាយក្នុងសម័យនោះ។ តើបញ្ហាជាទូទៅនោះជាបញ្ហាអ្វីទៅ? មើលទៅប្រហែលជាមកអំពី

ហេតុការណ៍ ដែលព្រះពុទ្ធសាសនាត្រូវបានប្រជាជនជប៉ុនទទួលយក ក្នុងបែបផែនពិសេសជាជប៉ុននិយម។

រឿងនេះនាំឲ្យយើងមានសំនួរថា: ចុះម្តេច ក៏ដូច្នេះ? ព្រះពុទ្ធសាសនាត្រូវបាននាំចូលមកក្នុងប្រទេសជប៉ុននេះ តាំងពីយូរយារណាស់មកហើយនុ៎ះ មិនពិតទេ ឬអី? បើយោលទៅតាមប្រវត្តិសាស្ត្រ រឿងនេះពិតជាអញ្ចឹងមែន។ ប៉ុន្តែរឿងមួយទៀត ក៏ជារឿងពិតដែរ គឺថាប្រជាជនជប៉ុនត្រូវការពេលច្រើនសតវត្សជាចាំបាច់ ដើម្បីអាចនឹងទទួលជឿយ៉ាងពេញលេញនូវសាសនា ដែលនាំចូលមកនោះ ហើយកែទម្រង់ឲ្យទៅជាសាសនារបស់ខ្លួនពិតប្រាកដ។ រួមសេចក្តីទៅ គឺក្នុងរយៈសតវត្សទី៧ និងទី៨ ដែលប្រទេសជប៉ុនចាប់ផ្តើមខំប្រឹងខ្នះខ្នែងទទួលយកព្រះពុទ្ធសាសនា ប៉ុន្តែការខំប្រឹងខ្នះខ្នែងនេះ ត្រូវបានផលផ្លែផ្កា ដល់ទៅក្នុងសតវត្សទី១២ ទី១៣ ក្រោមសកម្មភាពនៃព្រះសង្ឃធំៗឯណោះទៅវិញទេ។

ជាបន្តមក ពុទ្ធសាសនាជប៉ុន ដែលបព្វជិតធំៗ ទាំងនោះបានកសាងគ្រឹះហើយនោះ ក៏បន្តសកម្មភាពប្រកបដោយជោគជ័យ រហូតមកដល់សព្វថ្ងៃនេះ។ ក្រោយពីជំនាន់មហាបព្វជិតអស្ចារ្យទាំងនោះមក ពន្លឺភ្លឺឲ្យបានដូចពន្លឺនៅក្នុងសតវត្សនោះ ក៏ឈប់មានឡើងទៀត នៅក្នុងប្រវត្តិពុទ្ធសាសនាជប៉ុន។ ប៉ុន្តែតាមលំនាំអ្នកនិពន្ធសៀវភៅនេះ ហាក់ដូចជាមានរឿងមួយជាពិសេសផ្សេងទៀត ដែលទាក់ទាញអារម្មណ៍យើង គឺ: លទ្ធផលនៃការស្រាវជ្រាវអំពីពុទ្ធសាសនាដើម ដែលបានធ្វើឡើងក្នុងសម័យថ្មីៗនេះ។

តាំងពីពេលដែលប្រទេសជប៉ុនបានទទួលយកជាដំបូងមក ពុទ្ធសាសនាជប៉ុន ស្ទើរតែទាំងមូល ជាពុទ្ធសាសនាមហាយាន នៅក្រោមឥទ្ធិពលពុទ្ធ-

សាសនាចិន។ ជាពិសេស ក្រោយពេលដែលព្រះថេរៈធំៗ នាសតវត្សទី១២ និងទី១៣ បានកើតឡើង ពុទ្ធសាសនាមហាយានជាមូលដ្ឋានធំបង្អស់ រហូតមកដល់សព្វថ្ងៃនេះ ដោយយោលយកពួកអ្នកបង្កើតនិកាយនេះ ជាមជ្ឈ-មណ្ឌល។ នៅក្នុងប្រវត្តិពុទ្ធសាសនាជប៉ុន ការស្រាវជ្រាវអំពីពុទ្ធសាសនាដើម បានចាប់ផ្ដើមឡើង ប្រមាណជាក្រោយពាក់កណ្ដាលសករាជ ម៉ីហ្សុី។ រូបភាពនៃព្រះពុទ្ធគោតម បានចេញឲ្យឃើញឡើងជាថ្មីយ៉ាងប្រត្យក្ស នៅចំពោះភ្នែកអ្នកដែលមានការភ្ញេចគិតថា ពុំមែនពួកអ្នកបង្កើតនិកាយនេះទេ គឺព្រះពុទ្ធ-គោតមនោះឯង ជាអ្នកបង្កើតពុទ្ធសាសនា។ ហើយពួកអ្នកដែលគ្មានគិតអ្វីក្រៅពីសាសនាមហាយាននោះ ក៏បានយល់ច្បាស់ថា នៅក្នុងមហាយាននោះ មានគោលជំនឿជាគ្រឹះមួយទៀត នៃពុទ្ធសាសនា។ ការវិវត្តន៍ថ្មីនេះ ស្ថិតនៅទាំងស្រុងក្នុងផ្នែកទស្សនសិក្សានៅឡើយ ហេតុនេះ មិនទាន់អាចបណ្ដាលឲ្យមាន សកម្មភាពខ្លាំងក្លាខាងជំនឿសាសនា នៅឡើយទេ។ ប៉ុន្តែ ចំណេះវិជ្ជានៃប្រជាជនជប៉ុនក្នុងព្រះពុទ្ធសាសនា ហាក់ដូចជាបានទៅដល់ផ្លូវបត់ធំមួយទៀត។ អ្នកនិពន្ធសៀវភៅនេះ មានបំណងចង់បញ្ជាក់អំពីរយៈដំណើរវិវត្តន៍ថ្មីនេះ ហើយទុកជាមជ្ឈមណ្ឌលប្រធានទី៣ ក្នុងចំណោមមជ្ឈមណ្ឌលប្រធានទាំង៣ ដែលបានចែងពីខាងលើមកហើយ។

II

របៀបបញ្ជូនព្រះពុទ្ធសាសនាជាបន្តៗ មកជំនាន់ក្រោយៗ

ព្រះពុទ្ធសាសនា ជាសាសនាមួយដែលមានសិក្ខាបទរបស់ព្រះសក្យមុនីជាគ្រឹះ។ ព្រះអង្គទ្រង់បានផ្សាយសិក្ខាបទនេះ ក្នុងរយៈ ៤៥ឆ្នាំចុងក្រោយនៃជីវិតរបស់ព្រះអង្គ។ ដូច្នេះ ពាក្យពេចន៍ទាំងឡាយ ដែលព្រះអង្គប្រើប្រាស់ក្នុងព្រះធម្មទេសនា មានន័យប្រកបដោយអាថ្មាជាច់ខាត ក្នុងសាសនានេះ។ ព្រះធម៌ទាំង ៨៤០០០ ធម្មក្ខន្ធ និងគណៈនិកាយជាច្រើន ដែលបានកើតមានឡើង សុទ្ធតែមានការទាក់ទងនឹងសិក្ខាបទព្រះសក្យមុនីនេះ។ សៀវភៅទាំងឡាយ ដែលស្តីអំពីសិក្ខាបទព្រះពុទ្ធ ត្រូវបានគេដាក់ឈ្មោះថា អ៊ីស្សៃក្យូ ឬពាក្យមួយទៀតថា ដៃហុក្យូ ដែលមានន័យថា ប្រជុំគ្រប់សន្តគម្ពីរ។

ព្រះសក្យមុនី ទ្រង់បានពោលអះអាង យ៉ាងម៉ឺងម៉ាត់អំពីភាពស្មើគ្នានៃមនុស្សជាតិ ហើយទ្រង់បានសម្តែងធម៌ទូន្មាន ជាពាក្យសាមញ្ញ ច្បាស់លាស់ ដើម្បីឲ្យសត្វលោកទូទៅ អាចបានយល់ពេញលេញនូវពាក្យប្រៀនប្រដៅទាំងនេះ។ រហូតដល់ថ្ងៃអវសាននៃជីវិតរបស់ព្រះអង្គ ក្នុងព្រះជន្ម ៨០ ព្រះវស្សា ព្រះអង្គទ្រង់បានបន្តការសម្តែងព្រះធម្មទេសនា ដើម្បីជាប្រយោជន៍សម្រាប់មនុស្សលោក ឥតដែលបានឈប់សម្រាកមួយវេលាណាឡើយ។

ក្រោយពីព្រះសក្យមុនី ទ្រង់ចូលនិព្វានទៅ ពួកសាវ័កទាំងឡាយរបស់ព្រះអង្គ បានសម្តែងព្រះធម្មទេសនា ទៅតាមតែសេចក្តីដែលខ្លួនបានស្តាប់ឮមក។ ហេតុនេះ ចំពោះការបញ្ជូនសិក្ខាបទនេះជាបន្តៗ មកក្រោយៗទៀត

ការខុសល្អៀងខ្លះៗ ជាការចៀសពុំផុត។ ការភាន់ច្រឡំដោយអចេតនាទាំងនេះ បានកើតឡើងដោយពុទ្ធសាវ័កទាំងឡាយ ដែលគិតតែពីពន្យល់ផ្សាយព្រះសាសនា ទៅតាមសេចក្តីដែលខ្លួនបានស្តាប់ឮ និងយល់ឃើញ។

ប៉ុន្តែ ជាការចាំបាច់ ពុទ្ធដីកាព្រះសក្យមុនី ត្រូវតែបញ្ជូនបន្តមកជំនាន់ក្រោយៗ ឲ្យបានត្រឹមត្រូវ និងពិតប្រាកដ ហើយសត្វលោកគ្រប់ជាន់ថ្នាក់ទាំងអស់ត្រូវតែអាចបានស្តាប់ឮសេចក្តីប្រៀនប្រដៅរបស់ព្រះអង្គ។ ដូច្នេះហើយ ព្រះសង្ឃធំៗបានប្រជុំគ្នា ដើម្បីសម្របសម្រួលពាក្យ និងសិក្ខាបទ ដោយសូត្រប្រាប់គ្នាទៅវិញទៅមកនូវរឿងទាំងឡាយ ដែលម្នាក់ៗបានស្តាប់ឮ ហើយយល់ឃើញ។ ការប្រជុំនេះ បានប្រព្រឹត្តឡើងអស់ជាច្រើនខែ។ ស្នាដៃដែលជាលទ្ធផលនៃមហាសន្និបាតនេះ មានឈ្មោះថា «កេត្សឺហ្សឺ» ឬ«ការរៀបចំឲ្យមានរបៀបរៀបរយ»។ ការនេះបង្ហាញឲ្យឃើញថា តើមហាសង្ឃទាំងនោះមានសេចក្តីករុណា និងការរួបរួមគ្នាជញ្ជឹងគិតប៉ុនណាដើម្បីបញ្ជូនបន្តនូវពាក្យពិត ដែលព្រះបរមគ្រូទ្រង់បានថ្លែងទុកមក។ សិក្ខាបទដែលបានសម្របសម្រួលហើយនេះ ក៏ត្រូវបានចារទុក ជាលាយលក្ខណ៍អក្សរ។ នៅក្នុងសិក្ខាបទ ដែលបញ្ជូនបន្តមកក្រោយៗ ជាលាយលក្ខណ៍អក្សរនេះ ព្រះសង្ឃធំៗក្នុងសម័យដំបូង បានបញ្ចូលអត្ថាធិប្បាយ និងសេចក្តីបកស្រាយរបស់ខ្លួនផ្ទាល់ ដែលគេហៅថា «រ៉ុង» ឬ«សេចក្តីអភិប្រាយ»។ សិក្ខាបទព្រះពុទ្ធ សេចក្តីអត្ថាធិប្បាយដែលបន្ថែមពីលើ និងពុទ្ធវិន័យ ទាំងបីពួកនេះ ហៅរួមថា «សានហ្សូក្យូ» ឬជាភាសាសំស្ក្រឹត «ព្រះត្រៃបិដក» មានន័យថា «ប្រជុំគម្ពីរទាំងបីផ្នែក»។

«សានហ្សូក្យូ» ឬ «ព្រះត្រៃបិដក» នេះចែកចេញជា «ក្យូហ្សូ»«រីត្សឹហ្សូ» និង «រ៉ុងហ្សូ»។ ពាក្យ «ហ្សូ» បានន័យថា ភាជន៍ ឬ ប្រជុំ។ ពាក្យ «ក្យូ» ជាសំស្ក្រឹតថា សូត្រ សំដៅទៅលើ ពាក្យឱវាទរបស់ព្រះពុទ្ធ។ ពាក្យ «រីត្សឹ» ជាសំស្ក្រឹតថា វិន័យ សំដៅទៅលើច្បាប់ទាំងឡាយដែលទាក់ទងនឹងជីវិតនៃពុទ្ធសហគមន៍។ ពាក្យ «រ៉ុង» ជាសំស្ក្រឹតថា សាស្ត្រា ឬ អភិធម្ម សំដៅទៅលើសេចក្ដីអត្ថាធិប្បាយ ដែលព្រះសង្ឃធំៗ បានសរសេរទុកមក។

តាមរឿងតំណាល ព្រះពុទ្ធសាសនាបានចូលទៅក្នុងប្រទេសចិន ក្នុងឆ្នាំទី១០ នៃសម័យ យុង-ពីង គ.ស. ៦៧។ ប៉ុន្តែនៅបច្ចុប្បន្ននេះ គេយល់ថាពុទ្ធគម្ពីរទាំងឡាយ បានចាប់ផ្ដើមចូលមកក្នុងប្រទេសចិន ហើយត្រូវបានបកប្រែនៅរវាង ៨២ឆ្នាំ ក្រោយមក គឺក្នុងឆ្នាំទី១ នៃសម័យយាន់-ឈា ឆ្នាំ១៥១ ក្រោយគ្រិស្តសករាជ ក្នុងរាជ្យព្រះចៅអធិរាជ ហាន ក្នុងសន្តតិវង្សហាន ខាងកើត ជំនាន់ក្រោយ។ ចាប់ពីពេលនោះមក ការខំប្រឹងប្រែងបកប្រែគម្ពីរទៅជាភាសាចិន បានប្រព្រឹត្តឡើងជាបន្តៗ ក្នុងរយៈពេលជាង១៧០០ឆ្នាំ។ អត្ថបទចំនួន ១៤២០ បោះចេញជាគម្ពីរ ៥៥៨៦ ក្បាល ត្រូវបានបកប្រែនៅសម័យនោះ។ ការខិតខំរកវិធីរក្សាទុកគម្ពីរ ដែលបានបកប្រែហើយទាំងនោះ បានចាប់ផ្ដើមធ្វើឡើង តាំងពីក្នុងសម័យសន្តតិវង្ស វ៉ិយ ៣៨៦-៥៣៥ ប៉ុន្តែការបោះពុម្ព ត្រូវបានចាប់ផ្ដើមធ្វើឡើង នៅក្នុងសម័យសន្តតិវង្សសុងខាងជើង ឆ្នាំ ១១២៧។ ចាប់ពីពេលនោះមក ស្នាដៃនៃព្រះសង្ឃចិនធំៗទាំងនោះ ត្រូវបានបញ្ចូលជាបន្ថែមទៅក្នុងពុទ្ធគម្ពីរ ជាហេតុនាំឲ្យគេឈប់ទទួលស្គាល់សៀវភៅទាំងនេះទុកជា គម្ពីរព្រះត្រៃបិដក។ គឺនៅក្នុងសម័យសន្តតិវង្ស ស៊ីអ៊ី

គ.ស. ៥៨១-៦១៨ ដែលប្រជុំសៀវភៅទាំងនេះ ត្រូវបានឈ្មោះថា «អ៊ីស៊ែរក្យូ» ឬ សមូហកម្មពេញលេញនៃសន្តគម្ពីរ។ នៅក្នុងសម័យសន្តតិវង្ស តាង គ.ស. ៦១៨-៩០៦ គេបានដាក់ឈ្មោះថ្មីថា«ដៃហ្សូក្យូ» ចំពោះសមូហកម្មគម្ពីរក្បួនច្បាប់វិន័យ នៃព្រះពុទ្ធសាសនានេះ។

ពុទ្ធសាសនាបានចូលទៅក្នុងប្រទេសទីបេត៍ នៅរវាងគ្រិស្តសករាជទី៨។ ក្នុងរយៈវេលា ១៥០ឆ្នាំ ចាប់ពីសតវត្សទី ៩ ដល់សតវត្សទី១១ ការខំបកប្រែគម្ពីរចេះតែប្រព្រឹត្តទៅជាបន្តបន្ទាប់ រហូតដល់ស្ទើរតែគម្ពីរទាំងអស់ ត្រូវបានបកប្រែជាភាសាទីបេត៍ នៅពេលនោះ។

សរុបទៅ ដោយឃើញថា គម្ពីរទាំងឡាយ មិនត្រឹមតែត្រូវបានបកប្រែជាភាសា កូរ៉េ ជប៉ុន សិង្ហាលេស៍ ខ្មែរ ទួរគី និងភាសានៃបូព៌ាប្រទេសឯទៀតៗ ជាច្រើន តែប៉ុណ្ណោះទេ គម្ពីរទាំងនោះត្រូវបានបកប្រែជាភាសាឡាតាំង បារាំង អង់គ្លេស អាល្លឺម៉ង់ដ៍ អ៊ីតាលី ជាបន្ថែមទៀតផងនោះ គេអាចសន្និដ្ឋានដោយប្រាកដប្រជាបានថា សព្វថ្ងៃនេះ ការទទួលប្រសិទ្ធិពរព្រះពុទ្ធសាសនា ត្រូវបានរីកសព្វសាយ ពាសពេញសកលលោក។

ប៉ុន្តែ បើគិតពិចារណា ដោយយោលទៅតាមលក្ខណៈដំណើរលូតលាស់ និងដំណើរប្រែប្រួលនៃពុទ្ធសាសនា ក្នុងរយៈពេលជាង ២០០០ឆ្នាំ និងដោយយោលទៅតាមសៀវភៅជាង ១០០០០ក្បាល ដែលបានសរសេរទុកមកនោះ ក៏ឃើញថាពិបាកនឹងដកស្រង់យកន័យពិត អំពីពាក្យសំដីនៃព្រះសក្យមុនី ទោះបីមានគម្ពីរ «ដៃហ្សូក្យូ»ដែលប្រជុំគ្រប់គម្ពីរ គ្រប់ច្បាប់វិន័យនៃពុទ្ធសាសនានេះជាជំនួយផងក៏ដោយ។ ដោយហេតុនេះ ជាការចាំបាច់ត្រូវតែដកស្រង់

យកចំណុចសំខាន់ៗពីគម្ពីរ «ដៃហ្សូក្យូ» ដើម្បីធ្វើជាលក្ខណវិនិច្ឆ័យ និងជាមូលហេតុ សម្រាប់ឲ្យបុគ្គលម្នាក់ៗអាចស្តាបនាជំនឿសាសនារបស់ខ្លួនផ្ទាល់។

នៅក្នុងព្រះពុទ្ធសាសនា អាជ្ញាខ្ពស់បំផុតស្ថិតនៅលើពាក្យសំដីទាំងឡាយដែលព្រះសក្យមុនី ទ្រង់បានថ្លែងមក។ ប៉ុន្តែ សេចក្តីទូន្មានរបស់ព្រះពុទ្ធត្រូវតែមានការទាក់ទងយ៉ាងជិតស្និទ្ធ ជាមួយនឹងការពិតនៃជីវិតរស់នៅសព្វថ្ងៃ។ បើមិនដូច្នេះទេ សាសនានេះមិនអាចនឹងបញ្ចូលចិត្តមនុស្សលោកឲ្យជឿយ៉ាងស្មោះទៅលើបានទេ។ ដូច្នេះ ដើម្បីឲ្យសិក្ខាបទនេះ អាចបានទៅជាសិក្ខាបទរបស់បុគ្គលគ្រប់គ្នាទាំងអស់ ជាការចាំបាច់ ត្រូវតែសិក្ខាបទនេះមានភាពជាធម្មតា ជាក់លាក់ មានលក្ខណៈជាសមភាពចំពោះមនុស្សទូទៅ គ្រប់ជាន់ថ្នាក់ ហើយជាងនេះទៅទៀត ពាក្យទាំងឡាយត្រូវតែឲ្យបាន ជាក់លាក់ និងជាពាក្យដែលគេប្រើប្រាស់ក្នុងជីវិតជារៀងរាល់ថ្ងៃ។

សៀវភៅនេះបានចងក្រងឡើង ក៏ដោយសារមានការពិចារណាដូចបានពោលមកពីខាងលើនេះ ហើយជាកេរដំណែលនៃមហាគម្ពីរ «ដៃហ្សូក្យូ» ដែលមានប្រវត្តិជាង ២៥០០ ឆ្នាំ មកហើយ។ ដោយពិត សេចក្តីអធិប្បាយក្នុងសៀវភៅនេះ មិនអាចទុកជាលេញលេញបានទេ។ ពាក្យសំដីរបស់ព្រះពុទ្ធមានន័យជ្រៅ ឥតទីបំផុត គុណធម៌នៃពាក្យទាំងនោះទូលំទូលាយ ឥតព្រំដែនមិនងាយនឹងដាក់តម្លៃបានទេ។

ប៉ុន្តែ យើងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងបានល្អឡើងៗ ហើយបានត្រឹមត្រូវតាមសេចក្តីពិត ជាលំដាប់តទៅ នៅពេលពិនិត្យកែតម្រូវ និងបោះពុម្ពជាថ្មី ជាបន្តៗ ទៅអនាគត។ នេះហើយ ជាសេចក្តីប្រាថ្នារបស់យើងខ្ញុំ។

III

ប្រវត្តិសៀវភៅ «សិក្ខាបទព្រះពុទ្ធ»

សៀវភៅពុទ្ធសាសនានេះ ជាលទ្ធផលនៃការរើសប្រមូល ពិនិត្យឡើងវិញនូវសៀវភៅដើមជប៉ុន «កម្រងអត្ថបទពុទ្ធសាសនាបកប្រែជាថ្មី» ដែលបោះពុម្ពនៅ ខែកក្កដា ឆ្នាំ ១៩២៥ ដោយសមាគមផ្សាយ «សៀវភៅពុទ្ធសាសនា បកប្រែជាថ្មី» ដែលមានព្រះមហាថេរៈ មីអាន-គីហ្ស៊ី ជាអ្នកដឹកនាំ។ សៀវភៅបោះពុម្ពលើកទី១ ជាភាសាជប៉ុននេះ បានចងក្រងឡើងដោយបណ្ឌិត ស៊ីយឺហ្គាគី យ៉ាម៉ាបេ និងបណ្ឌិត ជីហ្សេង-អាកានីម៉ា ព្រមដោយកិច្ចសហប្រតិបត្តិការនៃគ្រូអាចារ្យពុទ្ធសាសនាជប៉ុនជាច្រើនផង ក្នុងរយៈជាង ៥ ឆ្នាំ។

នៅក្នុងសម័យ ស្យូវ៉ា គ.ស.១៩២៦ «អត្ថបទស្តីអំពីពុទ្ធសាសនា ដែលគេនិយមច្រើន» ត្រូវបានបោះពុម្ពជាភាសាជប៉ុន ដោយសមាគមខាងលើនេះ ហើយត្រូវបានផ្សព្វផ្សាយពាសពេញប្រទេសជប៉ុន។

ក្នុងខែកក្កដា ឆ្នាំ ១៩៣៤ នៅពេលប្រជុំសមាជពុទ្ធិកយុវជននៃភូមិភាគ ប៉ាស៊ីហ្វិកទាំងមូល នៅប្រទេសជប៉ុន សៀវភៅ «សិក្ខាបទព្រះពុទ្ធ» ដែលបកប្រែជាភាសា អង់គ្លេស ពីអត្ថបទស្តីអំពីពុទ្ធសាសនា ដែលបានចែងមកហើយពីខាងលើនេះ ត្រូវបានបោះពុម្ពផ្សាយដោយ សហព័ន្ធពុទ្ធិកយុវជន ប្រទេសជប៉ុនទាំងមូល ដោយមានលោក ហ្គូដារដ៍ (Goddard) ជួយជ្រោមជ្រែងផង ដើម្បីទុកជាទីរំឭក។ ក្នុងឆ្នាំ ១៩៦២ ដើម្បីរំឭកថ្ងៃខួបឆ្នាំ

ទី ៧០ នៃការនាំចូលនៃព្រះពុទ្ធសាសនាទៅក្នុងប្រទេស អាមេរិក លោក យ៉េហាន-នីម៉ាតា ដែលជាប្រធានក្រុមហ៊ុន មីតស៊ីតូយ៉ូ បានបោះពុម្ពផ្សាយ សៀវភៅ «សិក្ខាបទព្រះពុទ្ធ» នេះ ជាភាសាអង់គ្លេស ម្តងទៀត។

ក្នុងឆ្នាំ ១៩៦៥ នៅពេលលោក នីម៉ាតា បានបង្កើត «មូលនិធិជំរឿន ពុទ្ធសាសនា» នៅទីក្រុងតូក្យូ ការផ្សាយសៀវភៅនេះជាភាសាអង់គ្លេសទៅ ក្នុងពិភពលោកទាំងមូល ត្រូវបានគ្រោងទុកជាសកម្មភាពមួយ របស់មូលនិធិ នេះ។

ដើម្បីសម្រេចគម្រោងការនេះ គណៈកម្មាធិការសើរើពិនិត្យ និងប្រមូល ទុកនូវឯកសារទាក់ទងនឹង «សិក្ខាបទព្រះពុទ្ធ» ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៦៦។ សមាជិកនៃគណៈកម្មាធិការនេះមាន លោកសាស្ត្រាចារ្យ កាហ្សុឹ យ៉ូស៊ី-គីណូ លោកសាស្ត្រាចារ្យស៊ីយឺ-កាណាអូកា លោកសាស្ត្រាចារ្យ ហេរួន ណូ-អ៊ីស៊ីហ្គាមី លោកសាស្ត្រាចារ្យ ស៊ីងកូ-សាយ៉េគី លោកសាស្ត្រាចារ្យ កូដូ-ម៉ាត់ស៊ឹណាមី លោកសាស្ត្រាចារ្យ សូជុន-បាន់ដូ និងលោកសាស្ត្រាចារ្យ តាកេ មី-តាកាសេ។ លោកសាស្ត្រាចារ្យ ហ្វឹមីអូ-ម៉ាស៊ឹតានី លោកសាស្ត្រាចារ្យ វ៉ាដែល និងលោកសាស្ត្រាចារ្យ តូស៊ិស៊ឹកេ-ស៊ីមីហ្សុឹ ក៏បានជួយធ្វើការពិនិត្យ កែតម្រូវនេះដែរ។ ជាលទ្ធផលនៃការពិនិត្យកែតម្រូវនេះ «សិក្ខាបទព្រះពុទ្ធ» ត្រូវបានបោះពុម្ពផ្សាយចេញក្នុងទម្រង់ថ្មីមួយទៀតជាភាសាអង់គ្លេស-ជប៉ុន។

ក្នុងឆ្នាំ ១៩៧២ លោកសាស្ត្រាចារ្យ ស៊ីយឺ-ណាកាអូកា លោកសាស្ត្រា-ចារ្យ ហេរួនណូ-អ៊ីស៊ីហ្គាមី លោកសាស្ត្រាចារ្យ ស្ស៊ីយឺ-ហាណាយ៉ាម៉ា លោក

សាស្ត្រាចារ្យ ក្វានស៊ី-តាមូរ៉ា និងលោកសាស្ត្រាចារ្យ តាកេមិ-តាកាសេ បាន ពិនិត្យឡើងវិញ កែសេចក្តីខុសខ្លះៗ ហើយបោះពុម្ពសាជាថ្មី។

បន្ទាប់មក គណៈកម្មាធិការមួយរួមមាន លោកសាស្ត្រាចារ្យ រីយោតាត ត្ស៊ឹ ស៊ីអូអ៊ីរិ, តាកេមិ តាកាសេ, ហ៊ីរ៉ូស៊ិ តាស៊ីការ៉ា, ក្វាន់ស៊ី តាមូរ៉ា, សូជុន បាន់ដូ និងសូយូ ហាណាយ៉ាម៉ា (និពន្ធនាយក) ត្រូវបានបង្កើតឡើង ដើម្បីបំពេញបន្ថែមអត្ថបទភាសាជប៉ុននៃ «***សិក្ខាបទព្រះពុទ្ធ***» និងបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៧៣។

ជាថ្មីម្តងទៀត នៅក្នុងឆ្នាំ ១៩៧៤ គណៈកម្មាធិការមួយរួមមាន លោកសាស្ត្រាចារ្យ កូដូ ម៉ាត្ស៊ុណាមិ, សូជុន បាន់ដូ, ស៊ិនកូ សាយេគិ, ដូយូ តុគុណាហ្គា, ក្វាន់ស៊ី តាមូរ៉ា និង សូយូ ហាណាយ៉ាម៉ា (និពន្ធនាយក) ត្រូវបានបង្កើតឡើង ដើម្បីបំពេញបន្ថែមអត្ថបទភាសាអង់គ្លេស នៃ «***សិក្ខាបទព្រះពុទ្ធ***» ដែលពួកគេបានធ្វើឡើងដោយមានកិច្ចសហប្រតិបត្តិការជាមួយ លោក រិចឆាទដ៍ រ. ស្តេនី។ នោះជាការចងក្រងគួបផ្សំគ្នា ជាមួយច្បាប់ជាភាសាជប៉ុន (បោះពុម្ពផ្សាយក្នុងឆ្នាំ១៩៧៣) ដែលជាលទ្ធផលនាំទៅដល់ការបោះពុម្ពផ្សាយ «***សិក្ខាបទព្រះពុទ្ធ***» ច្បាប់ភាសាអង់គ្លេស-ជប៉ុន។

នៅឆ្នាំ១៩៧៨ លោកសាស្ត្រាចារ្យ ស៊ីហ្គេអូ កាម៉ាតា និងលោកសាស្ត្រាចារ្យ យ៉ាស៊ុអាគិ ណារ៉ា បានចូលរួមក្នុងគណៈកម្មាធិការ។ នៅឆ្នាំ២០០១ លោកសាស្ត្រាចារ្យ ខេណេត តាណាកា, សូហ៊្គុ រ៉ាតាណាបិ, យោស៊ីយ៉ាស៊ឹ យោណិហ្សារ៉ា និងលោកសាស្ត្រាចារ្យ សេនហ្គាគឺ ម៉ាយេដា (និពន្ធនាយកស្តីទី)បាន ចូលរួមក្នុងគណៈកម្មាធិការនិពន្ធ។

ក្រោយមក នៅឆ្នាំ២០១៣ សមាគមដើម្បីផ្សាយព្រះពុទ្ធសាសនាបានប្ដូរឋានៈរចនាសម្ពន្ធចាត់តាំងរបស់ខ្លួនពី «មូលនិធិសហសាជីវកម្ម» មកជា «មូលនិធិសហសាជីវកម្មដើម្បីប្រយោជន៍សាធារណៈ» វិញ។

*នៅក្នុងពេលផ្លាស់ប្ដូរនោះ សមាជិកនៃគណៈកម្មាធិការនិពន្ធ រួមមានៈ លោកសាស្ត្រាចារ្យសេនហ្គាគឺ ម៉ាយេដា (និពន្ធនាយក) លោកសាស្ត្រាចារ្យ ហេរូនណូ អ៊ីស៊ីហ្គាមិ, គីយូតាកា គីមួរ៉ា, ខេណោត តាណាកា, ម៉ាគីអូ តាកេមួរ៉ា, យ៉ាស៊ុអាគិ ណារ៉ា, ស៊ីហ្សូកុ យូស៊ីមីហ្ស៊ី, យោស៊ីយ៉ាស៊ុ យោណិហ្សាវ៉ានិង លោកសាស្ត្រាចារ្យ សូហ្គ៊ុ វ៉ាតាណាបិ។ គណៈកម្មាធិការនិពន្ធ ប្រជុំរៀងរាល់ឆ្នាំក្នុងការខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យសៀវភៅ **«សិក្ខាបទព្រះពុទ្ធ»** បានឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃសង្គមបច្ចុប្បន្ន ។*

កក្កដា ២០១៤

តារាងជំពូក

ជីវិតមនុស្សលោក

	ទំព័រ	បន្ទាត់
ន័យនៃជីវិត	7	14
សភាពបច្ចុប្បន្ននៃលោកនេះ	153	11
របៀបរស់នៅដោយថ្លៃថ្នូរ	362	13
ការគិតខុសអំពីជីវិត	73	11
ការយល់ត្រូវអំពីជីវិត	69	1
ការរស់នៅដោយមានលំអៀងទៅម្ខាងៗ	92	15
ចំពោះអ្នកយល់ច្រឡំ -រឿងល្បើក	198	11
ជីវិតមនុស្ស -រឿងល្បើក	144	4
បើគេរស់នៅប្រកបដោយសេចក្ដីលោភលន់និងតណ្ហា	143	5
តើ មនុស្សជរា មនុស្សឈឺ មនុស្សស្លាប់ បង្រៀនអំពីអ្វីដែរ -រឿងនិទាន	148	10
ការស្លាប់ ចៀសពុំរួចទេ -រឿងនិទាន	150	9
កិច្ចប្រាំប្រការ ដែលគ្មាននរណាម្នាក់អាចបំពេញបាន នៅក្នុងលោកនេះ	79	3
សេចក្ដីពិតបួនប្រការ នៅក្នុងលោកនេះ	79	15
ការយល់ច្រឡំ និងការបានត្រាស់ដឹង ទាំងពីរនេះ ចេញមកពីចិត្ត	80	15

តារាងជំពូក

	ទំព័រ	បន្ទាត់

កិច្ច ២០ ប្រការដែលពិបាក តែប្រសើរថ្លៃថ្នូរ
សម្រាប់មនុស្សសាមញ្ញបំពេញ..209 4

ជំនឿ

ជំនឿជាអគ្គី 281 5
ជំនឿមានសភាពសំខាន់បី..283 14
ជំនឿ ជាបាតុកម្មមួយ...285 13
ជំនឿចេញឲ្យឃើញស្ដែងឡើងនៅក្នុងចិត្តស្មោះត្រង់.............282 15
ដើម្បីបានយល់សេចក្ដីពិត ជាការពិបាក ដូចជាមនុស្សខ្វាក់
ខំប្រឹងធ្វើពិពណ៌នាអំពីទ្រង់ទ្រាយដំរីដោយយកដៃស្ទាប
រឿងល្បើក...120 11
តើសភាពព្រះពុទ្ធស្ថិតនៅកន្លែងណា រឿងនេះត្រូវបាន
បង្ហាញបញ្ជាក់ដោយសិក្ខាបទពិតប្រាកដនៃព្រះពុទ្ធ
សាសនា-រឿងល្បើក 124 12
សភាពព្រះពុទ្ធត្រូវបានលាក់បំពួនខ្លួន
ដោយសារតណ្ហា -រឿងល្បើក 118 5
ការមានមន្ទិលសង្ស័យ ជាឧបសគ្គរាំងរាជំនឿ 286 7
ព្រះពុទ្ធជាបិតានៃលោកទាំងមូល
សត្វលោក ជាកូនចៅរបស់ព្រះអង្គ.......................................60 6
ប្រាជ្ញារបស់ព្រះពុទ្ធធំធេងហើយជ្រៅដូចសមុទ្រ.......................57 13
ចិត្តរបស់ព្រះពុទ្ធពោរពេញដោយសេចក្ដីសន្ដោសអាសូរ..........25 1

សារបញ្ជីជំពូក

	ទំព័រ	បន្ទាត់
សេចក្តីសន្តោសអាសូរ របស់ព្រះពុទ្ធ មិនចេះចប់ទេ..................	26	16
ព្រះពុទ្ធគ្មានរូបកាយទេ..	23	15
ព្រះពុទ្ធទ្រង់បានយោនយកកំណើតមានជារូបកាយ ដើម្បីពន្យល់ ព្រះសាសនាដល់សត្វលោក..............................	39	15
ព្រះពុទ្ធទ្រង់បានយករឿងកើត និងវិនាសទៅវិញនៃរូបកាយ មកបញ្ជាក់ឃើញដើម្បីសត្វលោកជឿ..................................	39	15
ព្រះពុទ្ធទ្រង់ស្រោចស្រង់សត្វលោកបានចាកផុតពីទុក្ខវេទនា ដោយប្រើឧបាយតាមរឿងល្បើក..	32	4
------------------ជ------------------..	33	9
ពិភពនៃពន្លឺត្រាស់ដឹង..	366	5
ដើម្បីបានជាអ្នកគោរពតាម ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ..........	279	1
របៀបរៀនឲ្យចេះរក្សាច្បាប់វិន័យ ចេះសង្រួមចិត ចេះប្រព្រឹត្តតាមគតិធម៌..	256	8
ផ្លូវថ្លៃថ្នូរប្រាំបី..	261	6
ផ្លូវប្រាំមួយ ដើម្បីទៅដល់ត្រើយនាយនៃពន្លឺត្រាស់ដឹង............	263	11
កិច្ចប្រតិបត្តិត្រឹមត្រូវ ៤..	263	3
ការពិចារណាត្រឹមត្រូវ ៤..	262	11
កម្លាំង ៥ ដើម្បីបានសម្រេចពន្លឺត្រាស់ដឹង..............................	263	8
សភាពធំធេងឥតព្រំដែន ៤នៃចិត្ត..	268	1
បុគ្គលដែលយល់សេចក្តីពិតថ្លៃថ្នូរទាំង៤................................	66	6
ការស្លាប់ និង ការមិនទៀងនៃជីវិត......................................	22	5
អ្នកបានសូត្រព្រះនាមព្រះពុទ្ធអមិដានឹងបានទៅកើត		

តារាងជំពូក

	ទំព័រ	បន្ទាត់
ក្នុងដែនដីបរិសុទ្ធរបស់ព្រះអង្គ	177	13
ចូរបណ្ដាឲ្យមានពន្លឺដោយខ្លួនឯង ចូរទីពឹងលើខ្លួនឯង	17	16

ការហាត់រៀនបំពត់ចិត្ត

ម្នាក់ៗត្រូវចេះយល់រឿងសំខាន់បំផុតរបស់ខ្លួន -រឿងឧបមា	235	7
ចូរប្រយ័ត្ននូវជំហានទីមួយរបស់ខ្លួន	208	14
ចូរកុំភ្លេចអ្វីដែលខ្លួនស្វែងរក -រឿងឧបមា	238	5
ដើម្បីបានសម្រេចជោគជ័យក្នុងរឿងទាំងឡាយ គេត្រូវតែមានការអំណត់ និងការលំបាក -រឿងនិទាន	248	9
ចូរលើកទឹកចិត្តរបស់ខ្លួនជានិច្ច ទោះបីជាមានការមិនបាន សម្រេចជាច្រើនដងក៏ដោយ -រឿងនិទាន	271	1
ចូរកុំបណ្ដោយឲ្យចិត្តមានការរីករវរ ទោះបីនៅក្នុង ស្ថានភាពមិនជាទីគាប់ចិត្ត ក៏ដោយ-រឿងនិទាន......................	193	10
បុគ្គលដែលយល់ ហើយប្រព្រឹត្តតាមផ្លូវប្រសើរឧត្តម ប្រៀបដូចជាបានចូលទៅក្នុងទីងងឹត ដោយយក ពន្លឺទៅជាមួយផង	67	10
គេនឹងបានចេះអំពីជីវិតរស់នៅ នៅគ្រប់ទីកន្លែង ដែលគេបានដើរទៅដល់-រឿងនិទាន..	253	8
មនុស្សលោកប៉ុននឹងដើរទៅតាមទិស ដែលចិត្តរបស់ខ្លួនបញ្ជា	189	11
ចំណុចសំខាន់នៃពុទ្ធវាទ គឺចេះគ្រប់គ្រងចិត្ត...........................	19	14

សារាងជំពូក

	ទំព័រ	បន្ទាត់
ចូរគ្រប់គ្រងចិត្តរបស់ខ្លួន មុនអ្វីៗទាំងអស់	330	1
បើអ្នកគ្រប់គ្រងចិត្តរបស់អ្នកបាន	190	1
សភាពផ្សេងៗ នៃចិត្ត -ល្បើករឿង	184	3
ចិត្តពុំមែនជាអាត្មាអញទេ	77	4
ចូរកុំបណ្ដោយឲ្យចិត្តដឹកនាំបាន	18	4
ចូរជម្នះចិត្តរបស់ខ្លួន	20	5
ចូរធ្វើជាម្ចាស់នៃចិត្តរបស់ខ្លួន	20	7
អំពើបាបទាំងអស់ចេញពី កាយ មាត់ ចិត្ត	138	13
ការទាក់ទងគ្នារវាងចិត្តនឹងពាក្យសំដី	195	14
រូបកាយនេះគ្មានអ្វីក្រៅពីរបស់ខ្ពើគេទេ	225	10
រូបកាយនេះពោរពេញទៅដោយ របស់មិនបរិសុទ្ធគ្រប់ប្រភេទ	204	14
ចូរកុំលោភចំពោះអ្វីៗ ទាំងអស់	18	4
ចូររក្សា កាយ វាចា ចិត្ត ឲ្យបានបរិសុទ្ធ	192	11
ចូរកុំលំអៀងទៅម្ខាងៗ ចូរកុំខំហួសហេតុ-រឿងនិទាន	269	13

ទុក្ខវេទនានៃមនុស្សលោក

ទុក្ខនៃមនុស្សលោកកើតចេញមកអំពីចិត្តមានសេចក្ដីជាប់ជំពាក់	70	16
វិធីការពារទុក្ខ	23	1
ការយល់ច្រឡំនិងការល្ងង់ខ្លៅ ជាមាត់ទ្វារទៅកាន់ពន្ធនាគារ	96	12
វិធីធ្វើឲ្យបានឆ្លងផុតពីទុក្ខ	180	1
កាលណាភ្លើងតណ្ហាត្រូវបានរលត់ ពន្ធនាគារនឹងបានសម្រេច	223	6

តារាងជំពូក

	ទំព័រ	បន្ទាត់
ចំណង់ចប់ចល់ ជាប្រភពធំបំផុតនៃអវិជ្ជា	136	7
ចូរគិតថា ចំណង់ចប់ចល់ជាពស់វែកពួនក្នុងគុម្ពផ្កា	136	10
ចូរកុំជំពាក់ចិត្តនឹងផ្ទះដែលឆេះទ្រលោម-រឿងល្បើក	32	15
តណ្ហា ជាប្រភពនៃអំពើបាប	183	9
លោកនេះ ជាភ្លើងកំពុងឆេះ	131	14
នរជនណាសង្វាតចង់បានកេរ្តិ៍ឈ្មោះ និងកិត្តិយស គឺយកភ្លើងដុតខ្លួនឯង	185	14
នរជនណាលោភចង់បានទ្រព្យសម្បត្តិគឺបំផ្លាញខ្លួនឯង	186	6
លក្ខណៈពិសេស នៃជនជាបណ្ឌិត និងជនពាល	210	13
ជនពាលមិនយល់កំហុសរបស់ខ្លួនទេ-រឿងល្បើក	221	13
ជនពាលមើលឃើញតែលទ្ធផល ហើយច្រណែននឹងគេឯង -រឿងល្បើក	222	4
ការដែលជនពាលអាចធ្វើកើត-រឿងល្បើក	231	4

ការរស់នៅជារៀងរាល់ថ្ងៃ

ចូរធ្វើទាន ហើយបំភ្លេចកិច្ចនោះ	265	7
ការធ្វើទានប្រាំពីរយ៉ាង ដោយមិនបាច់មានទ្រព្យ	265	15
របៀបធ្វើឲ្យចម្រើនទ្រព្យ -រឿងព្រេង	229	2
របៀបបង្កើតសុភមង្គល	208	3
ចូរកុំបំភ្លេចសប្បុរសធម៌ ដែលបានទទួល-រឿងព្រេង	218	8
ចរិតមនុស្ស	141	13
ភ័ព្វអាក្រក់តាមជាប់នរជនណា ដែលប្រាថ្នាការសងសឹក	207	4

តារាងជំពូក

	ទំព័រ	បន្ទាត់
របៀបរំងាប់ចិត្តចង់គំនុំ -រឿងព្រេង	358	11
ចូរកុំរឹករវរនឹងការនិន្ទានៃអ្នកដទៃ-រឿងព្រេង	190	16
អ្នកពុំមែនរស់ដើម្បីសំពត់អាវ ចំណី-អាហារ ផ្ទះសំបែងទេ	319	14
ចំណីអាហារ និងសំលៀកបំពាក់ ពុំមែនសម្រាប់ការហ៊ឺហា និងការត្រេកត្រអាលទេ	181	11
នៅពេលបរិភោគចំណីអាហារ តើអ្នកត្រូវគិតពីអ្វី	323	15
នៅពេលស្លៀកសំលៀបំពាក់ តើអ្នកត្រូវគិតពីអ្វី	322	13
នៅពេលចូលដេក តើអ្នកត្រូវគិតពីអ្វី	324	10
នៅពេលក្តៅ ឬពេលត្រជាក់ តើអ្នកត្រូវគិតពីអ្វី	324	1
ក្នុងជីវិតរស់នៅសព្វថ្ងៃ តើអ្នកត្រូវគិតពីអ្វី	321	9

សេដ្ឋកិច្ច

របស់ទាំងឡាយត្រូវតែប្រើប្រាស់ឲ្យបានត្រឹមត្រូវ -រឿងព្រេង	343	9
គ្មានសម្បត្តិណាដែលជារបស់ផងខ្លួនរហូតទេ	342	11
គេមិនត្រូវប្រមូលរបស់ទុកសម្រាប់តែខ្លួនឯងម្នាក់ទេ	347	3
វិធីធ្វើឲ្យមានទ្រព្យសម្បត្តិ -រឿងព្រេង	229	2

ជីវិតគ្រួសារ

គ្រួសារគឺកន្លែងដែលសមាជិកទាំងឡាយ ទាក់ទងគ្នា ខាងផ្លូវចិត្ត	338	15
រឿង ដែលបំផ្លាញគ្រួសារ	331	13

តារាងជំពូក

	ទំព័រ	បន្ទាត់
របៀបសងគុណមហាធ្ងន់ដែលមាតាបិតាមានចំពោះបុត្រ.......	338	10
កិច្ចប្រតិបត្តិត្រឹមត្រូវ ដែលបុត្រធីតាត្រូវធ្វើ ចំពោះមាតាបិតា..........	332	11
កិច្ចប្រតិបត្តិត្រឹមត្រូវរវាងស្វាមីនឹងភរិយា..........	333	16
ស្វាមីភរិយាត្រូវមានជំនឿដូចគ្នា-រឿងព្រេង..........	345	9

ផ្លូវសម្រាប់អ្នកបួសអត់ជីលំនៅខ្ជាប់ខ្លួន

	ទំព័រ	បន្ទាត់
អ្នកដែលគ្រាន់តែស្លៀកពាក់ជាសង្ឃ ហើយសូត្រគម្ពីរសាស្ត្រា ពុំមែនជាអ្នកបួសឥតទីលំនៅទេ..........	308	15
អ្នកបួសឥតទីលំនៅ ពុំមែនជាអ្នកទទួលមរតកវិហារវត្ត និងសម្បត្តិរបស់វត្តអារាមទេ..........	304	1
បុគ្គលលោភលន់មិនអាចបានជាអ្នកបួសពិតប្រាកដទេ	304	9
ជីវភាពពិតប្រាកដ ដែលអ្នកបួសត្រូវប្រកប..........	307	4

ជីវិតសមាជិកសហគមន៍ពុទ្ធសាសនិក

	ទំព័រ	បន្ទាត់
ន័យអំពីជីវិតសហគមន៍	351	5
ស្ថានភាពបច្ចុប្បន្ននៃសង្គមក្នុងលោកនេះ	153	11
សមាគម ៣ប្រភេទ..........	352	11
ជីវិតសហគមន៍ពិតប្រាកដ	353	4
មហាពន្លឺដែលបំភ្លឺភាពងងឹត	350	8
ភាពសុខដុមក្នុងការទាក់ទងគ្នារវាងមនុស្សជាតិ..........	354	1
របៀបជួយជំរុញសង្គមឲ្យមានភាពសុខដុម..........	355	9
ឧត្តមគតិនៃពុទ្ធិកសហគមន៍..........	354	7

តារាងជំពូក

	ទំព័រ	បន្ទាត់
ឧត្តមគតិនៃសង្គមពុទ្ធបរិស័ទ	365	10
អ្នកដែលបណ្ដាលឲ្យមានការរឹករេដល់ច្បាប់រៀបរយ នឹងបានដល់នូវក្ដីវិនាស-រឿងល្បើក	220	4
អ្នកដែលច្រណែននិន្ទា រករឿងឈ្លោះប្រកែកនឹងអ្នកឯទៀត នឹងបានដល់នូវក្ដីវិនាស -រឿងល្បើក	220	4
ចូរគោរពមនុស្សចាស់ -រឿងព្រេង	212	1
តើសិស្សនិងគ្រូ ត្រូវប្រព្រឹត្តរវាងគ្នានឹងគ្នាបៀបណា	332	4
របៀបចងមិត្ត	334	9
របៀបជ្រើសរើសមិត្តល្អ	335	15
របៀបដែលម្ចាស់ និងអ្នកបម្រើ ត្រូវប្រព្រឹត្តរវាងគ្នានឹងគ្នា	335	3
អាកប្បកិរិយាចំពោះឧក្រិដ្ឋជន	347	14
រឿង ដែលអ្នកបង្រៀនព្រះធម៌ត្រូវយកចិត្តទុកដាក់	310	16

V

អក្ខរានុក្រមពាក្យសំស្ក្រឹត

អនាត្មន : *ភាពគ្មានអាត្មា*

គឺជាចំណុចសំខាន់ជាងគេមួយក្នុងព្រះពុទ្ធសាសនា។ នៅក្នុងលោកនេះ គ្រប់វត្ថុដែលមាននៅ គ្រប់បាតុភូតដែលកើតឡើង ទីបំផុតទៅ សុទ្ធតែគ្មានខ្លឹមសារពិតប្រាកដ។ ដូចពុទ្ធសាសនាបានពោលអះអាង អំពីភាពមិនទៀង ឬអនិច្ចតា នៃវត្ថុទាំងអស់ យ៉ាងនេះបញ្ជាក់បានយ៉ាងងាយថាភាពមិនទៀងនេះមិនអាចនឹងមានខ្លឹមសារអ្វីមួយ ដែលឋិតថេរទេ។ អនាត្មន អាចប្រែបានម្យ៉ាងទៀតថា «គ្មានអាត្មន» ។

អនិត្យ : *មិនទៀង*

គឺជាចំណុចសំខាន់មួយទៀត ក្នុងព្រះពុទ្ធសាសនា។ គ្រប់វត្ថុដែលមាននៅគ្រប់បាតុភូតដែលកើតឡើង នៅក្នុងលោកនេះ ប្រែប្រួលជានិច្ច មិននៅដដែលរហូតទេ។ វត្ថុទាំងអស់ តែងតែវិនាសទៅវិញ ក្នុងថ្ងៃណាមួយ ជាមិនខាន។ ការប្រមើលឃើញអនាគតនេះ ជាប្រភពពិតនៃទុក្ខ។ ប៉ុន្តែមិនត្រូវកាត់យល់នូវសេចក្តីនេះ តាមដោយទស្សនៈទុទិដ្ឋិនិយមតែប៉ុណ្ណោះទេ ព្រោះការវិវត្តន៍ ឬការកើតឡើងវិញ ក៏ជាការសម្តែងឲ្យឃើញនូវការប្រែប្រួលជានិច្ចនេះដែរ។

ពោធិសត្វ : *អ្នកដែលកំពុងខំប្រឹងបំពេញបារមី ប្រុងនឹងបានត្រាស់ជាព្រះពុទ្ធ*

ដើមឡើយ ពាក្យនេះត្រូវបានប្រើចំពោះព្រះគោតមសិទ្ធត្ថ មុនព្រះអង្គបានសម្រេចពន្លឺត្រាស់ដឹង។ ក្រោយពេលដែលពុទ្ធសាសនាមហាយានបានកើតឡើង គ្រប់បុគ្គលដែលខំប្រឹងបំពេញបារមី ប្រុងនឹងបានត្រាស់ជាព្រះពុទ្ធ

ត្រូវបានទទួលឈ្មោះនេះ។ ក្រោយមកទៀត អ្នកដែលយកសេចក្ដីមេត្តាអាសូរជាយាន ដើម្បី ជួយដឹកនាំគេឯទៀតទៅកាន់ភាពព្រះពុទ្ធ ក្នុងពេលដែលខ្លួនឯងផ្ទាល់ក៏កំពុងខំសង្វាតដែរនោះ ក៏ត្រូវបានឈ្មោះថា ព្រះពោធិសត្វដែរ។ តួយ៉ាង អវលោកិតេស្វរៈ ឬ ក្វានណុង ក្សិតិគារភៈ ឬ ហ្ស៊ីហ្សូ មញ្ជុស្រី ឬ ម៉ុនហ្ស៊ឺ ជាដើម។

ពុទ្ធ : អ្នកភ្ញាក់រលឹក អ្នកមានពន្លឺត្រាស់ដឹង

ដើមឡើយ ព្រះគោតមសិទ្ធត្ថ ឬសក្យមុនី ទ្រង់បានទទួលព្រះនាមនេះ ក្រោយពេលដែលព្រះអង្គទ្រង់បានសម្រេចពន្លឺត្រាស់ដឹង ក្នុងព្រះជន្ម ៣៥ ព្រះវស្សា គឺប្រមាណជា ២៥០០ ឆ្នាំមុន។ ទោះបីនៅក្នុងគណៈនិកាយណាក៏ដោយ ឬមានជំនឿផ្អៀងទៅខាងណាក៏ដោយ អ្នកកាន់ពុទ្ធសាសនាទាំងឡាយមានគោលបំណងតែមួយគត់គឺ ប្រាថ្នាឲ្យបានជាព្រះពុទ្ធ។ពុទ្ធសាសនាត្រូវបានបែងចែកជានិកាយជាច្រើន ទៅតាមរបៀប ប្រតិបត្តិផ្សេងៗ គ្នាដើម្បីបានសម្រេចភាពព្រះពុទ្ធនេះ។ តាមជំនឿពុទ្ធសាសនាមហាយាន ក្រៅពីព្រះសក្យ-មុនី ដែលជាព្រះពុទ្ធក្នុងប្រវត្តិសាស្ត្រនោះ មានព្រះពុទ្ធជានិមិត្តរូបជាច្រើន ដូចជា ព្រះអមិតាភៈ ឬអមិដា ព្រះមហាវៃរោចនៈ ឬ ដៃនីជី ព្រះវៃសជ្យគ្រូ ឬ យ៉ាគឹស៊ី ។ល។ ដែលត្រូវបានគេទុកជា និមិត្តរូបនៃពុទ្ធសាសនា។ នៅប្រទេសជប៉ុន ដោយយោលទៅតាមជំនឿខាងពុទ្ធសាសនិយម «ឋានបរិសុទ្ធ» គឺថាអ្នកដែលបានទៅកើត ក្នុងដែនដីបរិសុទ្ធរបស់ព្រះពុទ្ធអមិដា នឹងបានជាព្រះពុទ្ធ គេជឿថា មនុស្សទាំងអស់ ដល់ស្លាប់ទៅ នឹងបានឈ្មោះថា ព្រះពុទ្ធ ជាភាសាជប៉ុនហៅថា «ហុតុកេ»។ ព្រះពុទ្ធជារតនៈមួយ ក្នុងរតនៈទាំងបីនៃពុទ្ធសាសនា។

ធម៌ : *លទ្ធិពុទ្ធសាសនា*

គឺសិក្ខាបទ ដែលព្រះពុទ្ធជាទីគោរពបូជានៃលោក ទ្រង់បានទូន្មានប្រៀនប្រដៅ។ សិក្ខាបទនោះ មានចងជាគម្ពីរ ៣ប្រភេទ គឺ: ព្រះសូត្រ ដែលជាសេចក្ដីទូន្មានដែលព្រះពុទ្ធបានប្រៀនប្រដៅ ផ្ទាល់ព្រះអង្គ ព្រះវិន័យ ដែលជាច្បាប់ដែលព្រះពុទ្ធបានបង្កើតទុកមក និងព្រះអភិធម្ម ដែលជាសេចក្ដីអត្ថាធិប្បាយវែកញែកនូវព្រះសូត្រនិងព្រះវិន័យ ដែលគ្រូអាចារ្យធំៗ ជំនាន់ក្រោយៗមកបានធ្វើ។ ប្រជុំគម្ពីរទាំងបីប្រភេទនេះ ហៅថា ព្រះត្រៃបិដក។ ព្រះធម៌ ជារតនៈមួយក្នុងចំណោមរតនៈទាំងបីនៃពុទ្ធសាសនា។

កម្ម : *អំពើ*

ន័យដើមនៃពាក្យនេះ គឺ «អំពើ»។ ប៉ុន្តែយោលទៅតាម ទ្រឹស្ដីអំពីការទាក់ទងហេតុនិងផល ពាក្យនេះសំដៅទៅលើកម្លាំងសក្ដានុភូត មួយបែបដែលជាលទ្ធផលនៃអំពើពីអតីតរបស់យើង។ អំពើនីមួយៗ របស់យើង ផ្ដល់នូវផលអាក្រក់ឬល្អ ជាទីសប្បាយរីករាយ ឬជាទុក្ខ ទៅតាមអំពើនោះ។ អំពើទាំងឡាយ មានឥទ្ធិពលជាខ្លាំងទៅលើអនាគតរបស់ខ្លួនយើង ដែលចាត់ទុកថាជាកម្មរបស់មនុស្ស។ គេជឿថា បើអំពើល្អត្រូវបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ កុសលល្អនឹងត្រូវបានប្រមូលផ្ដុំច្រើនឡើង។ ហើយកម្លាំងផលបុណ្យនោះនឹងមានឥទ្ធិពលជាប្រយោជន៍សម្រាប់អនាគតរបស់យើង។ តាមសិក្ខាបទនេះ មានអំពើបីប្រភេទ គឺ: អំពើនៃកាយ អំពើនៃវាចា និងអំពើនៃចិត្ត។

មហាយាន : *យានធំ*

នៅក្នុងដំណើរប្រវត្តិសាស្ត្រពុទ្ធសាសនា មានចរន្តសំខាន់បំផុតពីរ គឺៈ មហាយាន និងថេរវាទ។ មហាយាន ត្រូវបានរីកសាយ នៅក្នុង ប្រទេស ទីបេត៍ ចិន កូរ៉េ ជប៉ុន ។ល។ ថេរវាទ ត្រូវបានរីកសាយ នៅក្នុង ប្រទេស ភូមា ស្រីលង្កា កម្ពុជា ថៃ ។ល។ យានធំ ទទួលដឹកនាំមនុស្សទាំងអស់ដែលវង្វេងទុក្ខនៅក្នុងលោកវិលកើតវិលស្លាប់នេះ ទៅកាន់ភាពត្រាស់ដឹងដោយមិនប្រកាន់ការរើសញែក។

និព្វាន : *សេចក្តីស្ងប់បំផុត*

ពាក្យនេះបានន័យថា «រលត់»។ គឺជាសភាព ដែលគ្រប់រឿងពុករលួយ និងគ្រប់តណ្ហានៃមនុស្សលោកត្រូវបានរលត់សូន្យ ដោយសារការហាត់ហ្វឹកហ្វឺននិងការត្រិះរិះជញ្ជឹងគិតតាមដោយសតិប្រាជ្ញាត្រឹមត្រូវ។ អ្នកដែលបានសម្រេចសភាពនេះ ហៅថា ព្រះពុទ្ធ។ ព្រះគោតួមសិទ្ធត្ថ ទ្រង់បានសម្រេចសភាពនេះ ហើយបានជាព្រះពុទ្ធ ក្នុងព្រះជន្ម ៣៥ ព្រះវស្សា។ ប៉ុន្តែ ព្រះអង្គទ្រង់បានសម្រេចសេចក្តីស្ងប់បំផុត ដល់ទៅពេលព្រះអង្គទ្រង់រលត់ខន្ធឯណោះទេ ពីព្រោះគុណវិបត្តិខ្លះ តែងតែមាននៅជាប់នឹងមនុស្សលោក ដរាបណារូបកាយនៅមាននៅឡើយ។

បាលី :

គឺជាភាសា ដែលគេច្រើនប្រើនៅក្នុងពុទ្ធសាសនាថេរវាទ។ គម្ពីរពុទ្ធ-សាសនាចាស់ជាងគេ ដែលមានបន្តមកដល់យើងសព្វថ្ងៃនេះ ត្រូវបានសរសេរ

ទុកមក ជាភាសានេះឯង។ បាលី ជាគ្រាមភាសាមួយ នៃភាសាសំស្ក្រឹត ហេតុនេះ បាលីនិងសំស្ក្រឹត មិនសូវខុសគ្នាប៉ុន្មានទេ។ ឧទាហរណ៍ដូចជាសំស្ក្រឹតថា ធម៌ បាលីថា ធម្ម សំស្ក្រឹតថា និរ្វាន បាលីថា និព្វាន។

ចារមិតា : ឆ្លងទៅត្រើយនាយ

គឺបានទៅដល់ឋានព្រះពុទ្ធ ដោយសារវិធីគោរពប្រតិបត្តិផ្សេងៗ តាមពុទ្ធសាសនា។ ក្នុងចំណោមវិធីគោរពប្រតិបត្តិទាំងនោះមានវិធីប្រតិបត្តិប្រាំមួយដែលគេតែងតែយកមកប្រើប្រាស់ ដើម្បីឆ្លងពីពិភពវិលកើតវិលស្លាប់នេះទៅកាន់ឋាននៃពន្លឺត្រាស់ដឹង គឺមាន ទាន១ ធម្មចរិយា១ សេចក្តីអត់ធ្មត់១ សេចក្តីម៉ឺងម៉ាត់១ ការសង្រួមចិត្ត១ ការយល់ត្រូវ ឬសតិប្រាជ្ញា១។ ពិធីបុណ្យ «ហ៊ីហ្គាំង» បានន័យថា ត្រើយនាយ នៅនិទាឃរដូវ និងវស្សានរដូវ ដែលជាទំនៀមទម្លាប់ជាតិជប៉ុន ចេញមកពីជំនឿនេះឯង។

ច្រាជ្ញា : ការចេះដឹង

គឺជាបារមិតាមួយ ក្នុងចំណោមបារមិតាទាំងប្រាំមួយ។ គឺជាមុខងារនៃគតិដែលអាចឲ្យបានយល់ឃើញដោយឥតច្រឡំអំពីជីវិត ហើយបានដឹងជាក់អំពីការពិតនិងការមិនពិត។ អ្នកដែលបានសម្រេចការនេះពេញបរិបូណ៌ហៅថា ព្រះពុទ្ធ។ គឺជាការចេះដឹងខ្ពស់បំផុត ភ្លឺបំផុត ដែលខុសគ្នាពីប្រាជ្ញានៃមនុស្សលោកធម្មតា។

សង្ឃ : *ពុទ្ធសហគមន៍*

នៅក្នុងពុទ្ធសហគមន៍ មានបព្វជិត និងគ្រហស្ថ ទាំងពីរភេទ។ ក្នុងសម័យជាដំបូង សហគមន៍នេះកកើតឡើងដោយអ្នកបួសប្រុសស្រី ដែលគ្មានទីលំនៅខ្ជាប់ខ្ជួន។ ក្នុងនិកាយមហាយាន អ្នកទាំងអស់ដែលស្វែងរកសភាពជាពោធិសត្វ ទាំងបព្វជិតទាំងគ្រហស្ថ រួមផ្តុំគ្នាជាសហគមន៍នេះ។ គឺជារតនៈមួយ ក្នុងរតនៈទាំងបីនៃពុទ្ធសាសនា។

សំស្ក្រឹត :

គឺជាភាសាដើម នៃប្រទេសឥណ្ឌាសម័យបូរាណ។ ភាសានេះ នៅក្នុងក្រុមភាសា ឥណ្ឌូ-អឺរ៉ុប។ ភាសានេះចែកចេញជា វេទសំស្ក្រឹត និងសំស្ក្រឹតបុរាណ។ គម្ពីរពុទ្ធសាសនាមហាយានទាំងឡាយ ត្រូវបានសរសេរជាភាសានេះឯង ហើយបែបនិពន្ធនេះហៅថា «ពុទ្ធសំស្ក្រឹតលាយ»។

សង្សារ : *ដំណើរអន្ទោលទៅមកនៃការវិលកើតវិលស្លាប់*

ដំណើរអន្ទោលទៅមកមិនឈប់ឈរ នៃការវិលកើតវិលស្លាប់ នៃអតីតកាល នៃបច្ចុប្បន្នកាល នៃអនាគតកាល នៅក្នុងពិភពថ្កើនភ្នែក ទាំងប្រាំមួយពោលគឺ នរក បិសាចអត់ឃ្លាន សត្វធាតុ អសុរា មនុស្សលោក ទេវលោកទាំងនេះ ហៅថា សង្សារ។ ដរាបណាយើងមិនបានសម្រេចពន្លឺត្រាស់ដឹងទេ យើងមិនអាចគេចរួចពីកង់វដ្តសង្សារនេះទេ។ អ្នកដែលរំដោះខ្លួនរួចពីវដ្ត-សង្សារនេះ ហៅថា ព្រះពុទ្ធ។

សុញ្ញតា : *ភាពទទេ ឥតខ្លឹមសារ*

គឺការយល់ឃើញថា វត្ថុទាំងអស់សុទ្ធតែអត់ខ្លឹមសារ មិនឋិតថេរ។ គឺជាចំណុចសំខាន់មួយ ក្នុងពុទ្ធសាសនា។ ដោយហេតុតែអ្វីៗ ទាំងអស់ យោលទៅតាមការទាក់ទងហេតុនិងផល វត្ថុអស់ទាំងនោះមិនអាចមានអ្វីជាខ្លឹមសារឋិតថេរ សម្រាប់ខ្លួនផ្ទាល់ទេ។ តែក៏មិនត្រូវគិតថា វត្ថុទាំងអស់សុទ្ធតែអត់ខ្លឹមសារ ឬមានខ្លឹមសារ នោះដែរ។ មនុស្សលោកក្តី វត្ថុធាតុឯទៀតក្តី សុទ្ធតែត្រូវបានស្ថិតនៅក្នុងភាពមិនទៀងនេះឯង។ ដូច្នេះ ការយល់ថា យោបល់ណាមួយ ឬសិក្ខាបទណាមួយ ឬមនោគមវិជ្ជាណាមួយ ទុកជាត្រឹមត្រូវឥតល្អៀងន៉ុះ ជាការមិនទំនងសោះ។ នេះជាគោលការណ៍សំខាន់មួយ ក្នុងគម្ពីរពុទ្ធសាសនាមហាយានស្តីអំពី ប្រាជ្ញា។

សូត្រ : *គម្ពីរ*

គឺការកត់ត្រាទុកនូវធម្មទេសនារបស់ព្រះពុទ្ធ។ ន័យដើមនៃពាក្យនេះគឺ «ខ្សែ»។ គឺជាសម្រាំងអត្ថបទ ដែលជ្រើសរើសតាមរយៈការស្រាវជ្រាវដ៏ធំធេងក្នុងសាសនវិទ្យា។ គម្ពីរព្រះសូត្រ ជាគម្ពីរមួយផ្នែកក្នុងប្រជុំគម្ពីរ៣ចំណែក ឬព្រះត្រៃបិដក។

ថេរវាទ :

ជាទំនៀមទម្លាប់ជំនឿពុទ្ធសាសនា នៅភូមិភាគខាងត្បូង។ ថេរៈបានន័យថា ចាស់បូរាណ។ នេះជាក្រុមនិកាយសង្ឃចាស់ៗ ដែលកាន់ធម៌ វិន័យយ៉ាងតឹងរឹង ខុសពីក្រុមសង្ឃខាងមហាយាននៅភូមិភាគខាងជើង ដែលមាន

សេរីភាព និងវឌ្ឍននិយមជាង។ ការខ្វែងយោបល់គ្នា ក្នុងពុទ្ធសហគមន៍នេះ បានកើតមានឡើងយ៉ាងឆាប់រហ័ស ក្នុងប៉ុន្មានសតវត្សក្រោយពីព្រះពុទ្ធ ទ្រង់សុគតទៅ នៅពេលដែលព្រះមហាទេវៈ ដែលជាព្រះសង្ឃជឿនលឿនបានអន្ទោកអន្ទោលបកស្រាយដោយសេរីជាងនូវច្បាប់វិន័យពុទ្ធសាសនា ទាំងប្រាំចំពូក។ រឿងនេះបណ្តាលឲ្យមានការបែកបាក់គ្នារវាង ថេរវាទ នឹងមហាសង្ឃិក។ មហាសង្ឃិកនេះ ក្រោយមក បានទៅជាប្រភពនៃនិកាយមហាយាន។

ត្រៃបិដក : *ល្អីបី ឬប្រជុំនៃល្អីបី*

គឺប្រជុំគម្ពីរព្រះធម៌ ៣ចំណែក គឺៈ ព្រះសូត្រ ដែលជាពាក្យទូន្មាន ដែលព្រះពុទ្ធទ្រង់សម្តែងពន្យល់ ព្រះវិន័យ ដែលជាច្បាប់ដែលព្រះពុទ្ធទ្រង់បញ្ញត្តិ និងព្រះអភិធម្ម ដែលជាបទអត្ថាធិប្បាយពន្យល់នូវច្បាប់វិន័យពុទ្ធសាសនា។ ក្រោយមកទៀត សៀវភៅពុទ្ធសាសនា ដែលនិពន្ធដោយ ពុទ្ធសាសនបណ្ឌិតធំៗ នៃប្រទេសចិននិងជប៉ុន ក៏ត្រូវបានបញ្ចូលទៅក្នុង ប្រជុំគម្ពីរនេះដែរ។ -សូមមើលពាក្យ ធម៌-

មូលនិធិជំរឿនព្រះពុទ្ធសាសនា

កាលណាគេនិយាយអំពី មូលនិធិជំរឿនព្រះពុទ្ធសាសនា ឬសមាគមផ្សាយព្រះពុទ្ធសាសនា ជាចាំបាច់ គេត្រូវតែរំលឹកអំពី អ្នកជំនួញម្នាក់ឈ្មោះ យ៉េហាន-នីម៉ាតា ដែលជាអ្នកបានបង្កើតក្រុមហ៊ុនធ្វើគ្រឿងប្រដាប់វាស់វែងដោយទៀតទាត់ មួយឈ្មោះ ក្រុមហ៊ុនមីត្សឹតូយ៉ូ ជាង៧០ឆ្នាំ មកហើយ។

លោក នីម៉ាតា បានជឿជាក់ថា ជោគជ័យនៃសហគ្រាស នីមួយៗ សម្រេចទៅលើការស្រុះស្រួលសុខដុមគ្នារវាងឋានសួគ៌ ឋានកណ្ដាល និងមនុស្សលោក ហើយភាពល្អឥតខ្ចោះនៃចិត្តមនុស្សលោកនឹងបានសម្រេច លុះណាតែមានកិច្ចសហការស្មើគ្នាជាសមតានៃសតិប្រាជ្ញា សេចក្ដីករុណាអាសូរ និងសេចក្ដីក្លាហាន។ ដោយមានជំនឿមុតមាំនេះ លោក នីម៉ាតា បានខិតខំតាមកម្លាំងដែលអាចធ្វើបាន ដើម្បីធ្វើឲ្យបានរឹតតែប្រសើរនូវបច្ចេកទេសផលិតកម្ម គ្រឿងប្រដាប់វាស់វែង ហើយនិងដើម្បីការចម្រើនលូតលាស់នៃមនោគតិមនុស្សលោក។

លោក នីម៉ាតា ជឿជាក់ថា សន្តិភាពសកលលោកអាចកើតឡើងបាន លុះណាតែមនោគតិមនុស្សលោកបានប្រសើរឥតខ្ចោះ ហើយព្រះពុទ្ធសាសនាជាយានសម្រាប់ដឹកនាំទៅកាន់ទីដៅនេះ។ អាស្រ័យហេតុនេះ ជាង៤០ឆ្នាំមកហើយ ដែលលោកដឹកនាំក្រុមហ៊ុនផលិតកម្មរបស់លោក លោក នីម៉ាតា បានខិតខំយ៉ាងអស់ពីសមត្ថភាព ដើម្បីពង្រីក និងផ្សាយព្រះពុទ្ធសាសនា។

នៅខែ ធ្នូ ឆ្នាំ ១៩៦៦ លោកនីម៉ាតា បានបង្កើតសមាគមផ្សាយ ព្រះពុទ្ធសាសនាមួយ ដោយថវិកាផ្ទាល់របស់លោក ក្នុងគំនិតជាជំនួយដល់ការខំ

ប្រឹងប្រែងដើម្បីសន្តិភាពសកលលោក។ យ៉ាងនេះហើយដែលមូលនិធិជំរឿន ព្រះពុទ្ធសាសនា បានចាប់កើតឡើងជាអង្គការសាធារណៈមួយ។

តើត្រូវធ្វើដូចម្ដេចទៅ ដើម្បីផ្សាយពុទ្ធសាសនា ឲ្យបានដល់គ្រប់ទិសទី ដើម្បីឲ្យសត្វលោកទាំងអស់អាចទាញយកប្រយោជន៍ ហើយបានសប្បាយ រីករាយនឹងពន្លឺព្រះមហាប្រាជ្ញា និងព្រះមហាករុណាអាសូររបស់ព្រះពុទ្ធ នេះ បាន? នេះជាករណីយកិច្ចរបស់មូលនិធិជម្រឿនព្រះពុទ្ធសាសនា ក្នុងការ ដោះស្រាយបញ្ហានេះដោយក្ដី អំណត់ ដែលជាគោលបំណងរបស់អ្នកបង្កើត មូលនិធិ។

ជាសរុប ការខំខ្នះខ្នែងយ៉ាងអស់សមត្ថភាពដើម្បីផ្សាយពុទ្ធសាសនានេះ គឺជាសកម្មភាពដោយសុទ្ធចិត្ត ដែលមូលនិធិជំរឿនព្រះពុទ្ធសាសនា បានធ្វើ។

សៀវភៅ «សិក្ខាបទព្រះពុទ្ធ» នេះ ជាលទ្ធផលនៃការត្រិះរិះជញ្ជឹងគិត របស់យើងខ្ញុំ ទៅលើប្រវត្តិសាស្ត្រសាសនានៅប្រទេសជប៉ុន ហើយយើងខ្ញុំ ជឿថា សៀវភៅនេះជាសៀវភៅតែមួយ ដែលបញ្ជាក់បង្ហាញអំពីសាសនា ព្រះពុទ្ធ ក្នុងន័យពិតប្រាកដតាមជប៉ុននិយម។

សៀវភៅនេះ ចងក្រងឡើងជាកូនសៀវភៅ អាចដាក់លើតុសរសេរ ឬ ដាក់ក្នុងហោប៉ៅបាន ជាការងាយស្រួលដកយកមកអានដើម្បីជាជំនួយចិត្ត-សាស្ត្រ។

មូលនិធិជំរឿនព្រះពុទ្ធសាសនា សូមប្រសិទ្ធិពរ សូមឲ្យសៀវភៅនេះ បានទៅដល់ក្រុមគ្រួសារដ៏ច្រើនអនេក និងសូមឲ្យអស់លោកអ្នក បានទទួល ការប្រោះព្រំនូវពន្លឺនៃព្រះបរមគ្រូ។